


# សៀវភៅណែនាំអំពី
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ភាគ ២៖ យុត្តិសាស្ត្រ**

សំណៅដើមមុនបោះពុម្ព

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

# សៀវភៅណែនាំ
# អំពី
# អង្គជំនុំជម្រះវិសាមញ្ញ
# ក្នុងតុលាការកម្ពុជា

## ភាគ ២៖ យុត្តិសាស្ត្រ

## ឯកសារយោងដែលត្រូវបានយោងជាញឹកញាប់ និងពាក្យកាត់

### ក្របខណ្ឌច្បាប់

| **អាគតដ្ឋានវែង** | **អាគតដ្ឋានបំព្រួញ** |
|---|---|
| កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ *ចូលជាធរមាន*ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ 2329 U.N.T.S. 117 | កិច្ចព្រមព្រៀង អ.ស.ប.-រាជរដ្ឋាភិបាលកម្ពុជា |
| ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) | ច្បាប់ អ.វ.ត.ក. |
| វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី១០) វិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ | វិធានផ្ទៃក្នុង |

### សេចក្ដីណែនាំអនុវត្ត

| **អាគតដ្ឋានវែង** | **អាគតដ្ឋានបំព្រួញ** |
|---|---|
| *ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក.* សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក. /០១/២០០៧/វិ.លើកទី៨ ដែលត្រូវបានវិសោធនកម្មនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ | សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ |
| *ការចូលរួមនៃជនរងគ្រោះ* សេចក្ដីណែនាំអនុវត្ត ០២/២០០៧/វ.០១ ដែលត្រូវបានវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ | សេចក្ដីណែនាំអនុវត្តស្ដីពីការចូលរួមរបស់ជនរងគ្រោះ |
| *វិធានការការពារ* សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក./០៣/២០០៧/វ.០១ ដែលត្រូវបានវិសោធនកម្មថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ | សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ |

### យុត្តិសាស្ត្រ

| **អាគតដ្ឋានវែង** | **អាគតដ្ឋានបំព្រួញ** |
|---|---|
| ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ **D99** | ដីកាដំណោះស្រាយ សំណុំរឿង ០០១ |
| សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ **D99/3/42** | សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០១ |
| សាក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ **E188** | សាលក្រម សំណុំរឿង ០០១ |
| សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **F28** | សាលដីកា សំណុំរឿង ០០១ |
| ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ **D427** | ដីកាដំណោះស្រាយ សំណុំរឿង ០០២ |
| សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/4/15** | សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ខៀវ សំផន) សំណុំរឿង ០០២ |

| | |
|---|---|
| សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ **D427/2/15 & D427/3/15** | សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) សំណុំរឿង ០០២ |
| សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ **D427/1/30** | សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) សំណុំរឿង ០០២ |
| សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E313** | សាលក្រម សំណុំរឿង ០០២/០១ |
| សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** | សាលដីកា សំណុំរឿង ០០២/០១ |
| សាលក្រម សំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** | សាលក្រម សំណុំរឿង ០០២/០២ |
| សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ **F76** | សាលដីកា សំណុំរឿង ០០២/០២ |
| ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **D266** | ដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង ០០៣ |
| ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **D267** | ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សំណុំរឿង ០០៣ |
| សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ឯកសារ **D266/27 & D267/35** | សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៣ |
| ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **D381** | ដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង ០០៤ |
| ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **D382** | ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សំណុំរឿង ០០៤ |
| សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ **D381/45 & D382/43** | សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤ |
| ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** | ដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង ០០៤/០១ |
| សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ **D308/3/1/20** | សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤/០១ |
| ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ **D359** | ដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង ០០៤/០២ |
| ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ **D360** | ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សំណុំរឿង ០០៤/០២ |
| សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ **D359/24 & D360/33** | សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿង ០០៤/០២ |

# ១. យុត្តាធិការ

## ១.១. យុត្តាធិការលើរូបបុគ្គល

អ.វ.ត.ក. ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ (“អ.ស.ប.”) និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានព្រមព្រៀងគ្នានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣[1]។ មាត្រា ២(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា “ទទួលស្គាល់” ថា អ.វ.ត.ក. មាន “យុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង” ពោលគឺ “ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”។ កាន់តែច្បាស់ជាងនេះទៀត មាត្រា ៥(៣) និង ៦(៣) នៃកិច្ចព្រមព្រៀង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ចែងថា “គេត្រូវយល់ថា” ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត និងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាត្រូវ “កំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម” តែប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ ច្បាប់ អ.វ.ត.ក. ជាច្បាប់ជាតិដែលបង្កើត អ.វ.ត.ក. បានចែងថា គោលបំណងរបស់ច្បាប់នេះគឺដើម្បី “វិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់ [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម”[2]។

ឯកសារមូលដ្ឋានគោលទាំងអស់នេះមិនបានកំណត់និយមន័យច្បាស់លាស់ថាតើអ្នកណាជា “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ” ឬ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម” នោះទេ។ ហេតុដូច្នេះ បញ្ហាចោទបានកើតមានឡើងអំពីអត្ថន័យនៃពាក្យពេចន៍ទាំងពីរនេះ និងថាតើអ្នកធ្វើសេចក្ដីព្រាងក្របខ័ណ្ឌគតិយុត្ត មានបំណងឱ្យពាក្យពេចន៍នេះបង្កើតបានជាលក្ខខណ្ឌតម្រូវគតិយុត្តដែលអាចវិនិច្ឆ័យបាន នៃយុត្តាធិការលើរូបបុគ្គលរបស អ.វ.ត.ក. ឬយ៉ាងណា។ ទោះបីជាការកំណត់អត្ថន័យពាក្យ “មេដឹកនាំជាន់ខ្ពស់” មិនសូវមានភាពចម្រូងចម្រាស អត្ថន័យនៃពាក្យ “ទទួលខុសត្រូវខ្ពស់បំផុត” ត្រូវបានដោះស្រាយយ៉ាងយូរ ដោយសារមន្ត្រីតុលាការមានទស្សនៈខុសៗគ្នា លើកត្តានានានៃការកំណត់និយមន័យពាក្យនេះ។

### ១.១.១. គោលដៅសម្រាប់ការចោទប្រកាន់

គោលដៅផ្ដាច់មុខសម្រាប់ការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. គឺ “កម្មាភិបាលខ្មែរក្រហម”[3]។ ដូច្នេះ ពាក្យ “មេដឹកនាំជាន់ខ្ពស [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” បានដកអ្នកដែលមិនមែនជាកម្មាភិបាលខ្មែរក្រហមចេញពីយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក.[4]។

អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យមើលការចរចាបង្កើត អ.វ.ត.ក. ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីគោលដៅដែលជាគោលបំណងសម្រាប់ការចោទប្រកាន់[5]។ ក្នុងការសន្និដ្ឋានថា ពាក្យនេះ “បានឆ្លុះបញ្ចាំងនូវគោលបំណងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលផ្ដុំធនធានដែលមានកម្រិត ដើម្បីធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋទៅលើកម្មាភិបាលខ្មែរក្រហមមួយចំនួន ដែលនៅរស់រានមាន

---

[1] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល។
[2] ច្បាប់ អ.វ.ត.ក. មាត្រា ១។ ច្បាប់ អ.វ.ត.ក. ត្រូវបានអនុម័តដោយរដ្ឋសភាជាតិកម្ពុជា នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ដោយវិសោធនកម្មត្រូវបានអនុវម័តក្នុងឆ្នាំ២០០៤ ដើម្បីឱ្យស្របទៅនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែមអំពីការចរចា ការបង្កើត ប្រតិបត្តិការដំបូង និងអាណត្តិរបស់ អ.វ.ត.ក. សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក.* (ភគ ១) ជំពូក ២-៣។
[3] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥១-៥២។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ៣១។
[4] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥២។
[5] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៦-៥៧។ សម្រាប់ព័ត៌មានបន្ថែមអំពីការចរចាដែលនាំឱ្យមានការបង្កើត អ.វ.ត.ក. សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក.* (ភគ ១) ជំពូក ២។

ជីវិត" (ដូច្នេះមិនរាប់បញ្ចូលអ្នកដែលមិនមែនជាកម្មាភិបាលខ្មែរក្រហម)[6] អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើ៖

i. លិខិតចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ពីសហនាយករដ្ឋមន្ត្រី ផ្ញើជូនអគ្គលេខាធិការ អ.ស.ប. ("អគ្គលេខាធិការ អ.ស.ប.") ស្នើសុំជំនួយរបស់ អ.ស.ប. ដើម្បី "កាត់សេចក្តីជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" ហើយអគ្គលេខាធិការ អ.ស.ប. បានសង្ខេបសំណើនេះថាជា "សំណើលើកដំបូងរបស់កម្ពុជាដើម្បីសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម"[7]។

ii. សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប. លេខ ៥២/១៣៥ ដែលបានអនុម័តការណែនាំរបស់តំណាងពិសេសនៃអគ្គលេខាធិការ អ.ស.ប. និងបានស្នើសុំ អគ្គលេខាធិការ អ.ស.ប. ឱ្យស្វែងរកលទ្ធភាពតែងតាំងអ្នកជំនាញមួយក្រុម "ដើម្បីវាយតម្លៃភស្តុតាងដែលមាន [អំពីការទទួលខុសត្រូវរបស់ខ្មែរក្រហមលើការរំលោភសិទ្ធិមនុស្ស] និងលើកសំណើវិធានការបន្ថែម"[8]។

iii. សមត្ថកិច្ចរបស់ក្រុមអ្នកជំនាញក្នុងការ "ស្វែងរកជម្រើសនានា សម្រាប់កាត់សេចក្តីមេដឹកនាំខ្មែរក្រហម នៅចំពោះមុខយុត្តាធិការអន្តរជាតិ ឬយុត្តាធិការជាតិ" និងការយល់ឃើញរបស់ខ្លួនថាសមត្ថកិច្ចនេះ "កំណត់ត្រឹមតែអំពើទាំងឡាយរបស់ខ្មែរក្រហមហើយមិនមែនអំពើរបស់ជនណាផ្សេងទៀត ឬជារដ្ឋណាមួយ ដែលបានប្រព្រឹត្តអំពើរំលោភបំពានលើសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា"[9]។

iv. អនុសាសន៍របស់ក្រុមអ្នកជំនាញដែលស្នើឱ្យ អ.ស.ប. "បង្កើតតុលាការអន្តរជាតិពិសេសមួយដើម្បីជំនុំជម្រះកម្មាភិបាលខ្មែរក្រហមពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩"[10]។ និង

v. កិច្ចពិភាក្សាខែតុលា ឆ្នាំ២០០៤ របស់សភាជាតិកម្ពុជាលើការអនុម័តកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងវិសោធនកម្មច្បាប់ អ.វ.ត.ក. ឆ្នាំ២០០១ ដែលឧបនាយករដ្ឋមន្ត្រី សុខ អាន បានពន្យល់ថា "មេដឹកនាំជាន់ខ្ពស់" សំដៅទៅលើមនុស្ស "មិនលើសពី ១០ នាក់ឡើយ" (ដោយមិនបញ្ជាក់ថា ពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍នោះទេ) និងថា "មិនមានចំនួនមនុស្សជាក់លាក់ដែលត្រូវចោទប្រកាន់នៅក្នុងក្រុមទីពីរឡើយ" ចំពោះ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ហើយថា អ.វ.ត.ក. ត្រូវទទួលខុសត្រូវក្នុងការធ្វើការសម្រេចទាំងនេះ[11]។

## ១.១.២. បុគ្គលពីរប្រភេទ

សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង ដំបូងឡើយបានបកស្រាយពាក្យ "និង" នៅក្នុងពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់ [...] *និង* ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយដាច់ចេញពីគ្នា ដោយសម្រេចថាពាក្យនេះ "សំដៅលើបុគ្គលពីរប្រភេទដាច់ដោយឡែកពីគ្នា ដែលមានន័យថា មេដឹកនាំជាន់ខ្ពស់ ឬជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[12]។ សហចៅក្រមស៊ើបអង្កេតមិនបានវិភាគដាច់ដោយឡែកពីគ្នាលើលក្ខខណ្ឌតម្រូវគតិយុត្តនៃយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. (ឬ ថាតើ វាសំដៅលើប្រភេទមួយ ឬច្រើន) មុនពេលសន្និដ្ឋានថា ឌុច ទោះបីជាមិនមែនជាមេដឹកនាំជាន់ខ្ពស់ "ក៏គាត់អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការបំពារបំពានយ៉ាង

---

[6] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥២។
[7] ដូចខាងលើ កថាខណ្ឌ ៤៦។
[8] ដូចខាងលើ កថាខណ្ឌ ៤៧។
[9] ដូចខាងលើ កថាខណ្ឌ ៤៨-៤៩។
[10] ដូចខាងលើ កថាខណ្ឌ ៥០។
[11] ដូចខាងលើ កថាខណ្ឌ ៥១។
[12] *សូមមើល* ដូចខាងលើ កថាខណ្ឌ ៤៥។ សូមមើលផងដែរ សំណុំរឿង ០០១ ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ១៧-២៥។

ធ្ងន់ធ្ងរ”[13]។ ដោយកត់សម្គាល់ថា ទាំងកិច្ចព្រមព្រៀងរវាងអ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា មិនមាន “ចែងច្បាស់អំពី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ” ឬ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”” អង្គជំនុំជម្រះសាលាដំបូងក៏បានបកស្រាយស្របៀងគ្នានៅក្នុងសាលក្រមសំណុំរឿង ០០១ ចំពោះយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ថាសំដៅលើបុគ្គលពីរប្រភេទ[14]។

នៅដំណាក់កាលបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពាក្យ “មេដឹកនាំជាន់ខ្ពស់ [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” សំដៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទដែល “ខុសគ្នាប៉ុន្តែប្រភេទទាំងពីរនេះមានទំនាក់ទំនងគ្នា” ឬមិនត្រួតគ្នា[15]។ បុគ្គលមួយប្រភេទដែលស្ថិតក្រោមយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. គឺ “មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត” ប្រភេទមួយផ្សេងទៀតគឺ “អ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត”[16]។ បុគ្គលទាំងពីរប្រភេទត្រូវតែជាកម្មាភិបាលខ្មែរក្រហម ហើយស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត[17]។

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការសន្និដ្ឋានដែលថា ពាក្យ “មេដឹកនាំជាន់ខ្ពស់ [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” សំដៅលើតែបុគ្គលមួយប្រភេទ “គឺមេដឹកនាំជាន់ខ្ពស់ *ជាអ្នក*ទទួលខុសត្រូវខ្ពស់បំផុត”[18]។ ក្នុងការសន្និដ្ឋានថា ពាក្យពេចន៍នេះសំដៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទ ដែល “ខុសគ្នាប៉ុន្តែប្រភេទទាំងពីរនេះមានទំនាក់ទំនងគ្នា” អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា៖

i. ការពន្យល់របស់ឧបនាយករដ្ឋមន្ត្រី ក្នុងអំឡុងពេលប្រជុំពិភាក្សាលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងវិសោធនកម្មទៅលើច្បាប់ អ.វ.ត.ក. ឆ្នាំ២០០៧ ដែលការកំណត់គោលដៅរបស់ អ.វ.ត.ក. សម្រាប់ការចោទប្រកាន់គឺ “មេដឹកនាំជាន់ខ្ពស់ ដែលជាមុខសញ្ញាសំខាន់បំផុតរបស់អង្គជំនុំជម្រះវិសាមញ្ញ និងជនមួយចំនួនទៀតដែលអាចមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែ អំពើរបស់ពួកគេមានលក្ខណៈធ្ងន់ធ្ងរខ្លាំងជាង ហើយមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ពួកគេពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរខ្លាំងជាងអ្នកដទៃទៀត”[19]។

---

[13] សំណុំរឿង ០០១ ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩។ សម្រាប់ព័ត៌មានបន្ថែមអំពីការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយបញ្ជូនខ្លួន ឌុច ទៅជំនុំជម្រះ សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.១.៣.៤។

[14] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ១៩ (គូសបញ្ជាក់បន្ថែម)។ សម្រាប់ព័ត៌មានបន្ថែមអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. លើ ឌុច សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.១.៥.៤។

[15] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥២។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៤។ សំណុំរឿង ០០៥ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣១។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់។

[16] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥២។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៤។ សំណុំរឿង ០០៥ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣១។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦០១។

[17] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥២។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៤។ សំណុំរឿង ០០៥ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣១។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦០១។

[18] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៥, ៥៣-៥៧។ សូមមើលផងដែរ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១១ ឯកសារ F1/2.1 ទំព័រ ៥២-៦២ (គូសបញ្ជាក់បន្ថែម)។

[19] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៣។

ii. ក្រុមអ្នកជំនាញបានសន្និដ្ឋានថា អ.វ.ត.ក. គប្បីផ្តោតលើ “មេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវទៅលើការរំលោភបំពានទាំងឡាយ ព្រមទាំងជនទាំងឡាយនៅថ្នាក់ទាបជាងដែលមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើយង់ឃ្នងយ៉ាងធ្ងន់ធ្ងរបំផុត”[20]។
iii. ការកត់សម្គាល់របស់លោកសាស្ត្រាចារ្យ David Scheffer ដែលថា មិនមានត្រង់ណានៅក្នុងអំឡុងពេលនៃការចរចា ដែលអ្នកចរចាពិតជាបានលើកឡើងថាជនសង្ស័យណាក៏ដោយត្រូវតែជាមេដឹកនាំជាន់ខ្ពស់ *ផង និង*ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត *ផង* ដើម្បីត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. នោះទេ[21]។

សហចៅក្រមស៊ើបអង្កេតបានប្រើការកំណត់ប្រភេទរបស់អង្គជំនុំជម្រះតុលាការកំពូល ចំពោះប្រភេទទាំងពីរនេះ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ក្នុងសំណុំរឿង ០០៣ និង ០០៤[22]។

## ១.១.៣. លក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ឬ គោលការណ៍នៃការចោទប្រកាន់ និងការស៊ើបអង្កេត?

យុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. គ្របដណ្តប់លើ “កម្មាភិបាលខ្មែរក្រហម”[23]។ បញ្ហាចោទថាតើបុគ្គលម្នាក់ត្រូវបានចាត់ទុកថាជា កម្មាភិបាលខ្មែរក្រហមដែរឬយ៉ាងណា គឺជាបញ្ហាយុត្តាធិការដែលអាចវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[24]។ ផ្ទុយទៅវិញ បញ្ហាចោទថាតើបុគ្គលម្នាក់ត្រូវបានចាត់ទុកថាជា “មេដឹកនាំជាន់ខ្ពស់” ឬ “ទទួលខុសត្រូវខ្ពស់បំផុត” ឬយ៉ាងណា គឺមិនមែនជាបញ្ហាយុត្តាធិការដែលអាចវិនិច្ឆ័យបាននោះទេ ប៉ុន្តែគឺជាបញ្ហាគោលការណ៍នៃការចោទប្រកាន់ និងការស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតទៅវិញទេ ដែលស្ថិតក្រោមវិសាលភាពតិចតួចបំផុតនៃការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ចំពោះការរំលោភឆន្ទានុសិទ្ធិ[25]។

ក្នុងការវាយតម្លៃថាតើទាំងអស់ ឬផ្នែកខ្លះនៃពាក្យពេចន៍ “មេដឹកនាំជាន់ខ្ពស់ [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” បង្កើតបានជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក. ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា មាត្រា ៣១ និង ៣២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញាអាចអនុវត្តបាន[26] និងថាអង្គជំនុំជម្រះតុលាការកំពូលក៏អាច “ស្វែងរកបទដ្ឋានណែនាំនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលមានបទប្បញ្ញត្តិប្រហាក់ប្រហែលនៅក្នុងយុត្តាធិការផ្សេងៗទៀត” ក្នុងមាត្រា ២(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា[27]។ ដោយកត់សម្គាល់ថា ពាក្យ “យុត្តាធិការលើរូបបុគ្គល” ក្នុងមាត្រា ២(១) ក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា បញ្ជាក់ថា ពាក្យនេះគឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា អង្គជំនុំជម្រះក៏ត្រូវតែពិនិត្យផងដែរថាតើ ការបកស្រាយនេះមានសង្គតិភាពជាមួយនឹងកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ដែរ ឬយ៉ាងណា និងថាតើ ការបកស្រាយនេះនឹងនាំឱ្យមានលទ្ធផលមួយដែល “មិនសមស្រប និងមិនសមហេតុផលយ៉ាងច្បាស់ក្រឡែត” ដែរ ឬយ៉ាងណា[28]

---

[20] ដូចខាងលើ កថាខណ្ឌ ៥៤-៥៥។
[21] ដូចខាងលើ កថាខណ្ឌ ៥៦។
[22] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥២។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៦។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣១។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦០១។
[23] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦១។
[24] ដូចខាងលើ។
[25] ដូចខាងលើ កថាខណ្ឌ ៧៩-៨០។
[26] ដូចខាងលើ កថាខណ្ឌ ៥៩។
[27] ដូចខាងលើ កថាខណ្ឌ ៥៩។ យោងតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល អាចស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធី ដែលបានបង្កើតនៅកម្រិតអន្តរជាតិ “នៅពេលដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ”។
[28] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦០។

។ អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃបុគ្គលចំនួនបីប្រភេទ - (១) "កម្មាភិបាលខ្មែរក្រហម" (២) "មេដឹកនាំជាន់ខ្ពស់" និង (៣) "អ្នកទទួលខុសត្រូវខ្ពស់បំផុត" - ដើម្បីសម្រេចថាតើ ពួកវាអាចត្រូវបានបកស្រាយយ៉ាងសមហេតុផលថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ដែរឬយ៉ាងណា[29]។

**កម្មាភិបាលខ្មែរក្រហម៖** អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា អង្គជំនុំជម្រះសាលាដំបូងគឺជាអ្នកដែលមានសមត្ថកិច្ចត្រឹមត្រូវជាងគេ នៅក្នុងការសម្រេចលើបញ្ហាអង្គហេតុ ថាតើនរណាជាកម្មាភិបាលខ្មែរក្រហម ដោយសារវា "ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុប្រវត្តិសាស្ត្រ ដែលមានលក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្តល់ឆន្ទានុសិទ្ធិតិចតួច ឬមិនបានផ្តល់ឆន្ទានុសិទ្ធិទាល់តែសោះ"[30]។

***មេដឹកនាំជាន់ខ្ពស់*៖** អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការទេ ប៉ុន្តែជាគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់ ពីព្រោះពាក្យពេចន៍នេះ "មានលក្ខណៈបត់បែនយ៉ាងគ្រប់គ្រាន់" និងមិនមានភាពចាំបាច់កំហិតត្រឹមតែបុគ្គលនៅក្នុងគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.") នោះឡើយ ដោយកត់សម្គាល់ថា ការពិភាក្សានៅក្នុងរដ្ឋសភាជាតិកម្ពុជាបញ្ជាក់ថា និយមន័យនេះមិនត្រូវបានកំណត់ជាក់លាក់ទេ[31]។

នៅក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតមិនយល់ស្របទៅនឹង "ការធ្វើចំណាត់ថ្នាក់របស់ អ.ជ.ត.ក. អំពី "យុត្តាធិការបុគ្គល" ថាជាលក្ខណៈវិនិច្ឆ័យមិនមែនយុត្តាធិការ" នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន[32]។ សហចៅក្រមបានពន្យល់ថា ពួកគាត់ចាត់ទុកប្រភេទ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការពិតប្រាកដ ទោះបីជាស្ថិតក្នុងកម្រិតនៃការវិនិច្ឆ័យយ៉ាងទូលំទូលាយ (ផ្ទុយពីគោលការណ៍ណែនាំដែលមិនត្រូវបានកំហិត)[33]។ ពួកគាត់បានផ្តល់សំអាងហេតុថា "ការយោង[របស់អង្គជំនុំជម្រះតុលាការកំពូល]ទៅការបំពានឆន្ទានុសិទ្ធិ ដោយផ្អែកលើភាពពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ជាការសន្មតជាមុនថា មានរង្វាស់ដែលអាចវាស់វែង និងត្រូវតែវាស់វែងលើការអនុវត្តឆន្ទានុសិទ្ធិ" និងថា អង្គជំនុំជម្រះតុលាការកំពូលមិនអាចគិតថា "មានឆន្ទានុសិទ្ធិដោយគ្មានកំណត់" នោះទេ[34]។ ពួកគាត់ក៏ជំទាស់ទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា មិនមានវិធីសាស្ត្រសត្យានុម័តក្នុងការប្រៀបធៀប និងធ្វើចំណាត់ថ្នាក់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កម្មាភិបាលខ្មែរក្រហម[35]។

នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ និង ០០៤ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គលរបស់សហចៅក្រមស៊ើបអង្កេត

---

[29] ដូចខាងលើ កថាខណ្ឌ ៦០-៧៩។

[30] ដូចខាងលើ កថាខណ្ឌ ៦១។

[31] ដូចខាងលើ កថាខណ្ឌ ៧៥-៧៦។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា បើទោះជាលក្ខន្តិកៈបក្សបានផ្តល់ឱ្យគណៈកម្មាធិការមជ្ឈិមនូវ "អំណាចប្រតិបត្តិការខ្ពស់បំផុត" ក៏គណៈកម្មាធិការអចិន្ត្រៃយ៍គឺជាគណៈកម្មាធិការតូចមួយ ដែលចុងក្រោយអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើរបបនោះ។ សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២០២-២០៣។ សម្រាប់រចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ សូមមើល សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១) ជំពូក ១។

[32] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩-១០។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ឡើងវិញយ៉ាងច្បាស់អំពីការមិនយល់ព្រមនេះនៅក្នុងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០២, ០០៣, និង ០០៤។ សូមមើល សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣២។ សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជាក់ឡើងវិញអំពីការមិនឯកភាពនេះនៅក្នុងសំណុំរឿង ០០៤/០២ និង ០០៤ ប៉ុន្តែមិនមាននៅក្នុងសំណុំរឿង ០០៣ ទេ។ សូមមើល។ សូមមើល សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៣០-៤៣២។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦០៤-៦០៥។ *ធៀបនឹង* សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦០-៤០៧។

[33] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩-១០។

[34] ដូចខាងលើ កថាខណ្ឌ ៩។

[35] ដូចខាងលើ កថាខណ្ឌ ៩។

អាចវិនិច្ឆ័យបាននៅចំពោះមុខអង្គបុរេជំនុំជម្រះ យោងទៅតាមបទដ្ឋាននៃការពិនិត្យឡើងវិញដែលអាចអនុវត្តបានចំពោះសេចក្ដីសម្រេចផ្អែកតាមឆន្ទានុសិទ្ធិ[36]។ អង្គបុរេជំនុំជម្រះបានពិចារណាថា ទោះបីជាភាពបត់បែននៃពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" តម្រូវឱ្យមានការវាយតម្លៃខ្លះដោយសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ឆន្ទានុសិទ្ធិនេះមិនមែនគ្មានដែនកំណត់នោះដែរ និងគប្បីត្រូវបានអនុវត្ត "ទៅតាមគោលការណ៍ច្បាប់ដែលមានច្បាស់លាស់"[37]។ ការពិចារណាទាំងអស់នេះមិនត្រូវបានពិនិត្យឡើងវិញដោយអង្គជំនុំជម្រះថ្នាក់ខ្ពស់ជាងនេះទេ[38]។

**អ្នកទទួលខុសត្រូវខ្ពស់បំផុត៖** អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុថាលទ្ធផល "មិនសមស្រប" នឹងកើតមានឡើង ប្រសិនបើប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានបកស្រាយថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ពីព្រោះ៖

i. "ពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ធ្វើការប្រៀបធៀប និងធ្វើការកំណត់ចំណាត់ថ្នាក់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កម្មាភិបាលខ្មែរក្រហមទាំងអស់បានឡើយ"[39]។

ii. ការសម្រេចដោយប្រៀបធៀបលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ នឹងមានន័យស្មើនឹង "ការបង្កើតឱ្យមាននយោបាយការពារដោយប្រយោល ដោយមូលហេតុបញ្ជារបស់ថ្នាក់លើ ហើយផ្ទុយនឹង" គោលបំណងនៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ដែលចែងថា "តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ"[40]។

iii. ការកំណត់ថាតើនរណាម្នាក់ "ទទួលខុសត្រូវខ្ពស់បំផុត" តម្រូវឱ្យមានឆន្ទានុសិទ្ធិជាច្រើន ផ្ទុយទៅនឹងយុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្ដី របស់ អ.វ.ត.ក. ដែលចែងតាមរយៈ "និយមន័យច្បាស់លាស់" និងអាចផ្ទៀងផ្ទាត់បាន ដោយសារយុត្តាធិការទាំងពីរនេះ "ពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុ ឬអង្គច្បាប់សុទ្ធសាធ ដែលមានលក្ខណៈច្បាស់លាស់ក្នុងការធ្វើការសម្រេចតាមផ្លូវច្បាប់បាន"[41]។

iv. ក្របខ័ណ្ឌ អ.វ.ត.ក. ផ្ដល់ឱ្យសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា នូវឆន្ទានុសិទ្ធិឯករាជក្នុងការកំណត់ថាតើ ការស៊ើបអង្កេត ឬការចោទប្រកាន់ជាក់លាក់ ស្ថិតក្នុងវិសាលភាពនៃពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬយ៉ាងណា[42]។

v. តួនាទីរបស់អង្គបុរេជំនុំជម្រះ ក្នុងការដោះស្រាយបញ្ហាខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា និងរវាងសហចៅក្រមស៊ើបអង្កេត មិនផ្លាស់ប្ដូរការសន្និដ្ឋានដែលថា ប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនមែនជាបញ្ហាយុត្តាធិការនោះទេ ដោយសារ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ" ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងភាគច្រើនលើសលប់ ទៅលើវិវាទរវាងសហចៅក្រមស៊ើបអង្កេត លើបញ្ហាថាតើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់ សម្រាប់មូលហេតុដែលថា ជនសង្ស័យគឺជា ឬមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[43]។

---

[36] សំណុំរឿង ០០៤/០១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២០-២២។

[37] ដូចខាងលើ កថាខណ្ឌ ២០។ សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៦។ សំណុំរឿង ០០៤ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤។

[38] សូមមើល វិធានផ្ទៃក្នុង វិធាន ៧៦(៧)។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ១១១។

[39] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦២។

[40] ដូចខាងលើ។

[41] ដូចខាងលើ។

[42] ដូចខាងលើ កថាខណ្ឌ ៦៤។

[43] ដូចខាងលើ កថាខណ្ឌ ៦៥។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើលទ្ធភាពដែលថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត អាចមិនឯកភាពគ្នាលើបញ្ហាថាតើ ជនសង្ស័យ ឬជនត្រូវចោទ គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"៖ "តួនាទីរបស់អង្គបុរេជំនុំជម្រះនឹងត្រូវសម្រេចពីបញ្ហាខ្វែងគំនិតគ្នារបស់សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត។ ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ដោយមូលហេតុ ជនត្រូវចោទគឺជា

vi. ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍ឱ្យបកស្រាយពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថាជា "គោលការណ៍ណែនាំនៃការចោទប្រកាន់" វិញ ហើយរបាយការណ៍របស់ពួកគេបង្កើតបានជា "ផ្នែកដ៏សំខាន់មួយនៃ*ការងារត្រៀមរៀបចំ*កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ហើយរបាយការណ៍នេះ មានលក្ខណៈស៊ីចង្វាក់គ្នាជាមួយនឹងពាក្យពេចន៍នៅក្នុងលិខិតុបករណ៍ទាំងនេះ"[44]។

vii. ដំណើរការពិនិត្យផ្ទៀងផ្ទាត់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR") មានតួនាទីជាគោលការណ៍ណែនាំដែលមានគោលបំណងជួយតុលាការទាំងនេះ ឱ្យប្រមូលធនធានដែលមានតិចតួចរបស់ខ្លួន ទៅប្រើប្រាស់ក្នុងការជំនុំជម្រះលើរឿងក្តី ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួនតែប៉ុណ្ណោះ ដែលគាំទ្រការចាត់ទុកពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងក្របខ័ណ្ឌ អ.វ.ត.ក. ថាជាគោការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់[45]។

viii. ប្រព័ន្ធបញ្ជូនរឿងក្តីនៅតុលាការ ICTY បានស្នើឡើងថា ពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាគោលការណ៍ណែនាំនៃការស៊ើបអង្កេត និងការចោទប្រកាន់ ដោយមានលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាកំណត់សមត្ថកិច្ច សម្រាប់កំណត់ថាតើនរណាម្នាក់គប្បីត្រូវជំនុំជម្រះនៅចំពោះមុខតុលាការ ICTY ឬនៅចំពោះមុខតុលាការជាតិ *ពោលគឺ* "ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ" ដែលជាគោលការណ៍នៃការចោទប្រកាន់ ជាជាងលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ[46] និង

ix. សាលដីកាអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់សៀរ៉ាលេអូន ("SCSL") ក្នុងរឿងក្តី *Brima* និងគូកន គាំទ្រការបកស្រាយនេះ សាលដីកានោះបានសម្រេចថា ពាក្យពេចន៍ "អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខន្តិកៈ SCSL មិនមែនជាលក្ខខណ្ឌតម្រូវនៃការចោទប្រកាន់ទេ ប៉ុន្តែជាគោលការណ៍ណែនាំសម្រាប់ការចោទប្រកាន់[47]។

### ១.១.៤. កត្តាសម្រាប់កំណត់ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់"

យុត្តិសាស្ត្រ អ.វ.ត.ក. មិនបានដោះស្រាយកត្តាពាក់ព័ន្ធឱ្យបានច្បាស់លាស់ទាំងស្រុង សម្រាប់ការកំណត់ថាតើនរណាជា "មេដឹកនាំជាន់ខ្ពស់" នោះទេ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចក្នុងសំណុំរឿង ០០១ ថា ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់" មិនចាំបាច់កំណត់ត្រឹមសមាជិកគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលមិនបានដាក់ចេញនូវកត្តាពាក់ព័ន្ធណាមួយ សម្រាប់កំណត់ថាតើនរណាម្នាក់ជាមេដឹកនាំជាន់ខ្ពស់នោះដែរ[48]។

ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន គឺជាមេដឹកនាំជាន់ខ្ពស់ "ដោយសារអំណាចឋានានុក្រមជាក់ស្តែង និងតាមច្បាប់ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "តួនាទីរបស់ជនជាប់ចោទ" នៃដីកាដំណោះស្រាយ"[49]។ សហចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់បន្ថែមលើសំអាងហេតុនេះទេ។ មិនមានជនត្រូវចោទណាម្នាក់បានជំទាស់ទៅនឹងការកំណត់នេះនៅចំពោះមុខអង្គបុរេជំនុំជម្រះទេ ហើយអង្គជំនុំជម្រះសាលាដំបូង ដោយដកស្រង់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងគោលការណ៍នៃការស៊ើបអង្កេត និងការចោទប្រកាន់ មិនបាន

---

ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ""។

[44] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៦-៦៨។

[45] ដូចខាងលើ កថាខណ្ឌ ៦៩។

[46] ដូចខាងលើ កថាខណ្ឌ ៧១។

[47] ដូចខាងលើ កថាខណ្ឌ ៧៣។

[48] ដូចខាងលើ កថាខណ្ឌ ៧៥-៧៦។

[49] សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៧។

វិភាគដាច់ពីគ្នាថាតើ ខៀវ សំផន ឬ នួន ជា គឺជា "មេដឹកនាំជាន់ខ្ពស់" ឬបន្ទាប់ពីបញ្ជាក់យុត្តាធិការលើពួកគេថាជា "កម្មាភិបាលខ្មែរក្រហម" នៅក្នុងសាលក្រមសំណុំរឿង ០០២/០១[50]។

នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៣ និង ០០៤/០២ សហចៅក្រមស៊ើបអង្កេតជាតិបានជំទាស់ទៅនឹងអង្គជំនុំជម្រះតុលាការកំពូល និងបានពិចារណាថា "មេដឹកនាំជាន់ខ្ពស់" សំដៅលើសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. ដែល "បានចូលរួមក្នុងការរៀបចំគោលនយោបាយ ការអនុវត្ត និងតាមដានមើលការអនុវត្តគោលនយោបាយទាំងនោះ"[51]។ សហចៅក្រមស៊ើបអង្កេតជាតិបានយោងទៅដីកាដំណោះស្រាយសំណុំរឿង ០០២ និងអត្ថបទដែលវិភាគអំពីការចរចាបង្កើត អ.វ.ត.ក.[52]។

## ១.១.៥. កត្តាសម្រាប់កំណត់ពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

ទោះបីជាប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានពិភាក្សានៅក្នុងរឿងក្ដីជាច្រើនក៏ដោយ ក៏យុត្តិសាស្ត្រ អ.វ.ត.ក. មិនបានឈានដល់ការកំណត់និយមន័យច្បាស់លាស់អំពីពាក្យពេចន៍នេះទេ។ ក្រោយពីផ្ដល់ទិដ្ឋភាពសង្ខេបអំពីយុត្តាធិការលើរូបបុគ្គលនៅក្នុងរឿងក្ដីនីមួយៗរួចមក ផ្នែកនេះនឹងបង្ហាញកត្តាជាច្រើនដែលបានពិនិត្យដោយសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ។

ក្នុងសំណុំរឿង ០០១ ឌុច មិនបានជំទាស់ទៅនឹងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. លើរូបគាត់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនោះឡើយ។ នៅក្នុងដីកាដំណោះស្រាយរបស់ពួកគេដែលបានចោទប្រកាន់បញ្ជូនខ្លួន ឌុច ទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋានថា បើទោះជា ឌុច មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ក៏គាត់ "អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនានា ដែលបានប្រព្រឹត្តក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន ក្នុងឋានៈជាអនុលេខា បន្ទាប់មកជាលេខាមន្ទីរ ស-២១" ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម[53]។ សហចៅក្រមស៊ើបអង្កេតមិនបានវិភាគដាច់ដោយឡែកពីគ្នាលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដើម្បីកំណត់អត្ថន័យពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់ [...] និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ ហើយក៏មិនបានដាក់ចេញនូវលក្ខណៈវិនិច្ឆ័យណាមួយសម្រាប់កំណត់ថាតើ នរណាម្នាក់ស្ថិតនៅក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទទាំងនេះ ឬយ៉ាងណានោះទេ។ ឌុច និង សហព្រះរាជអាជ្ញាមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការកំណត់យុត្តាធិការលើរូបបុគ្គលរបស់សហចៅក្រមស៊ើបអង្កេត ទៅកាន់អង្គបុរេជំនុំជម្រះឡើយ។ នៅដំណាក់ជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តលក្ខណៈវិនិច្ឆ័យចំនួនពីរ ពីយុត្តិសាស្ត្ររបស់តុលាការ ICTY និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") - ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និង កម្រិតនៃការទទួលខុសត្រូវរបស់បុគ្គល - នៅក្នុងការសន្និដ្ឋានថា ឌុច ស្ថិតនៅក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. "ក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង" ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ[54]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បញ្ហាចោទថាតើនរណាម្នាក់គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា គឺមិនអាចវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយមិនមានការពិនិត្យមើលលក្ខណៈវិនិច្ឆ័យរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ[55]។

ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន អាចត្រូវបានពិចារណាម្យ៉ាងទៀតថាស្ថិតនៅក្នុងប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់

---

[50] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧-១៩។

[51] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៤។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៥។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៧។

[52] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៤។

[53] សំណុំរឿង ០០១ ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩។

[54] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៥។

[55] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៥-៤៦។

បំផុត” ដោយយោងទៅលើ “ការចូលរួមជាបុគ្គលរបស់បុគ្គលទាំងនេះនៅក្នុងការអនុវត្តផែនការរួមរបស់ ប.ក.ក. តាមមធ្យោបាយឧក្រិដ្ឋ” របស់ពួកគេ[56]។ សហចៅក្រមស៊ើបអង្កេតមិនបានពន្យល់លើសំអាងហេតុរបស់ពួកគេទេ។ ដោយហេតុថាមិនមានជនត្រូវចោទណាម្នាក់បានជំទាស់ទៅនឹងយុត្តាធិការ នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងដីកាដំណោះស្រាយនោះ អង្គបុរេជំនុំជម្រះមិនបានពិភាក្សាថាតើ ជនត្រូវចោទគឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ឬយ៉ាងណានោះទេ[57]។ ដោយពិចារណាលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងគោលការណ៍នៃការចោទប្រកាន់ និងការស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ មិនបានវិភាគដាច់ដោយឡែកពីគ្នាថាតើ ជនជាប់ចោទគឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ឬយ៉ាងណាទេ បន្ទាប់ពីបញ្ជាក់យុត្តាធិការលើពួកគេថាជា “កម្មាភិបាលខ្មែរក្រហម” នៅក្នុងសាលក្រមសំណុំរឿង ០០២/០១[58]។ ខៀវ សំផន និង នួន ជា មិនបានជំទាស់ទៅនឹងការកំណត់យុត្តាធិការលើរូបបុគ្គលរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួនជំទាស់នឹងសាលក្រមសំណុំរឿង ០០២/០១ នោះទេ។ ដោយសារបញ្ហាយុត្តាធិការលើរូបបុគ្គលត្រូវបានដោះស្រាយដាច់ស្រេចរួចហើយក្នុងសំណុំរឿង ០០២/០១ ដូច្នេះបញ្ហានេះមិនត្រូវបានលើកឡើងវិញនៅក្នុងសំណុំរឿង ០០២/០២ នោះទេ។

យុត្តាធិការលើរូបបុគ្គលគឺជាបញ្ហាចម្រូងចម្រាសក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមន្ត្រីតុលាការមានការបកស្រាយផ្សេងគ្នាលើបញ្ហាចោទថាតើ ជនត្រូវចោទស្ថិតក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ដែរ ឬយ៉ាងណា។ នៅពេលចាប់ផ្ដើមការស៊ើបអង្កេតបឋម សហព្រះរាជអាជ្ញាមានការខ្វែងយោបល់គ្នាលើបញ្ហាថាតើត្រូវបើកការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ដែរ ឬយ៉ាងណា[59]។ ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការពីចៅក្រមចំនួនបួនរូប ដើម្បីសម្រេចលើបញ្ហាខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា ដូច្នេះសហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីបានបន្តដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីចំនួនពីរ ដែលបើកកិច្ចស៊ើបសួរទៅលើអ្វីដែលក្រោយមកបានក្លាយជាសំណុំរឿង ០០៣ និង ០០៤[60]។

បើទោះបីជាចុងបញ្ចប់សហចៅក្រមស៊ើបអង្កេតបានបដិសេធរួមគ្នាទៅនឹងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម យ៉ាងណាក្ដី ក៏ពួកគាត់បានធ្វើកំណត់ហេតុនៃការខ្វែងយោបល់ផ្ទៃក្នុងជាច្រើន ក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់ខ្លួនលើបញ្ហាចោទថាតើ មាស មុត, អោ អាន និង យឹម ទិត្យ ស្ថិតនៅក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ដែរ ឬយ៉ាងណា[61]។ ជាលទ្ធផលនៃការខ្វែងយោបល់គ្នារបស់ពួកគាត់ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ ថា ពួកគេពិចារណាចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដោយសំអាងលើការខ្វែងយោបល់គ្នារវាងពួកគាត់

---

[56] សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៨។

[57] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ខៀវ សំផន)។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ)។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) ។

[58] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧-១៩។

[59] សូមមើល ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3។

[60] ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ៤៥។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៧១(៤)(គ)។ សំណុំរឿង ០០៤ ចុងក្រោយត្រូវបានបំបែកទៅជាសំណុំរឿង ០០៤/០១ ទាក់ទងនឹង អោ អាន ហើយសំណុំរឿង ០០៤ នៅតែជាសំណុំរឿងទាក់ទងនឹង យឹម ទិត្យ។ សម្រាប់ព័ត៌មានបន្ថែមអំពីសំណុំរឿង ០០៣ និង ០០៤ សូមមើលសៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១) ផ្នែក ៥.៣។

[61] ក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតបានដាក់ករណីខ្វែងយោបល់នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣, ទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ទី១៧ ខែកក្កដា ឆ្នាំ២០១៤, ទី១៦ ខែមករា ឆ្នាំ២០១៧ និងទី១៧ ខែកញ្ញា ឆ្នាំ២០១៨។ សូមមើល សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥, ៧, ១៥, ២៧។ ក្នុងសំណុំរឿង ០០៤/០២ សហចៅក្រមស៊ើបអង្កេតបានដាក់ករណីខ្វែងយោបល់នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ទី៤ ខែមេសា ឆ្នាំ២០១៣, ទី១៦ ខែមករា ឆ្នាំ២០១៧ និងទី១២ ខែកក្កដា ឆ្នាំ២០១៨។ សូមមើល សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១។ ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតបានដាក់ករណីខ្វែងយោបល់នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ទី៤ ខែមេសា ឆ្នាំ២០១៣, ទី២១ ខែតុលា ឆ្នាំ២០១៥, ទី១៦ ខែមករា ឆ្នាំ២០១៧ និងទី២១ ខែមករា ឆ្នាំ២០១៩។ សូមមើល សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣, ៧, ២១។ ករណីខ្វែងយោបល់ទាំងអស់នេះត្រូវបានធ្វើកំណត់ហេតុផ្ទៃក្នុងអនុលោមតាមវិធាន ៧២(១) នៃវិធានផ្ទៃក្នុង និងនៅតែជាការសម្ងាត់។

ដូចដែលអាចអនុញ្ញាតឱ្យធ្វើទៅបានតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[62]។ ជាលទ្ធផល នៅក្នុងសំណុំរឿងទាំងបីនេះ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់[63] ក្នុងពេលដំណាលគ្នាជាមួយនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[64]។

អង្គបុរេជំនុំជម្រះក៏មិនឯកភាពគ្នាផងដែរនៅក្នុងរឿងក្តីទាំងអស់នេះ និងមិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានទេ[65]។ ទោះបីជាមានការប្រកាសជាឯកច្ឆន្ទនៅក្នុងរឿងក្តីនីមួយៗថា សហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចខុសច្បាប់នៅក្នុងការចេញដីកាដំណោះស្រាយពីរ អង្គបុរេជំនុំជម្រះមិនបានធ្វើការសម្រេចច្បាស់លាស់ ឬដាច់ស្រេច ថាតើដីកាដំណោះស្រាយមួយណា (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់) មានសុពលភាព នោះទេ[66]។ ចុងបញ្ចប់ សំណុំរឿង ០០៤/០២, ០០៣ និង ០០៤ បានបន្តទៅដល់អង្គជំនុំជម្រះតុលាការកំពូល ដែលបានបង្គាប់ឱ្យបញ្ចប់រឿងក្តីទាំងបីនេះ ដោយមូលហេតុមិនមាន "ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាន" ដោយផ្អែកលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ដែលខ្លួនពិចារណាថាបានបដិសេធ ឬបានមោឃភាពអានុភាពដីកាដំណោះស្រាយ[67]។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបកត្តាផ្សេងៗ ដែលបានប្រើដោយសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ ក្នុងការសម្រេចថាតើនរណាម្នាក់ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។

អង្គជំនុំជម្រះសាលាដំបូង ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (បម្រុង) បានពិចារណាលើកត្តាខាងក្រោម ដែលត្រូវបានបង្កើតឡើងនៅក្នុងយុត្តិសាស្ត្រក្រុមប្រឹក្សា

---

[62] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D355/1 កថាខណ្ឌ ១៣-១៦។

[63] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់។

[64] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

[65] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

[66] ចំពោះមូលហេតុផ្សេងគ្នា សូមមើល សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៨-១២៤ (ដែលបានសន្និដ្ឋានជាឯកច្ឆន្ទថា សហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចខុសច្បាប់ក្នុងការចេញដីកាដំណោះស្រាយពីរក្នុងពេលដំណាលគ្នា) កថាខណ្ឌ ២៧៣-៣០២ (ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះដែលបានតម្កល់ ដីកាសម្រេចលើកលែងចោទប្រកាន់)។ កថាខណ្ឌ ៣០៤-៦៨៧ (ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះដែលបានតម្កល់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១១-១១៨ (ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះដែលបានសន្និដ្ឋានថា សំណុំរឿង ០០៣ "គប្បីត្រូវតម្កល់ទុកក្នុងបណ្ណសារ") កថាខណ្ឌ ១១៩-៣៥៨ (ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះដែលបានសន្និដ្ឋានថា សំណុំរឿង ០០៣ ត្រូវតែបន្តទៅជំនុំជម្រះ ដោយសារតែ ដីកាសម្រេចលើកលែងចោទប្រកាន់មានវិការៈ)។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៧-១៣១ (ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះដែលបានសន្និដ្ឋានថា បុគ្គលដែលជាគោលដៅនៃការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. នោះគឺ ឌុច, ខៀវ សំផន, នួន ជា, អៀង សារី និង អៀង ធីរិទ្ធ និងថាសហព្រះរាជអាជ្ញាអន្តរជាតិបានបំពេញកិច្ចជាសម្ងាត់ និងខុសច្បាប់ ក្នុងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ និង ០០៤) កថាខណ្ឌ ១៣២-៥៣៩ (ដែលបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤ មានសុពលភាព និងថារឿងក្តីគប្បីបន្តទៅជំនុំជម្រះ)។

[67] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៥៣, ៦៧, ៦៩។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1 កថាខណ្ឌ ៤២, ៤៤។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 កថាខណ្ឌ ៣១។

កំណត់សមត្ថកិច្ច និងយុត្តិសាស្ត្ររបស់តុលាការ ICC លើដីកាបង្គាប់ឱ្យនាំខ្លួន ក្នុងការកំណត់ថាតើនរណាម្នាក់ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[68]៖

i. ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[69] រួមមាន៖
   - ចំនួនជនរងគ្រោះ
   - វិសាលភាពភូមិសាស្ត្រនិងពេលវេលានៃឧក្រិដ្ឋកម្ម
   - របៀបដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង និង
   - ចំនួនហេតុការណ៍នីមួយៗដែលកើតមានឡើង និង

ii. កម្រិតនៃការទទួលខុសត្រូវរបស់បុគ្គល[70] រួមមាន៖
   - កម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម
   - ឋានានុក្រម ឬមុខតំណែង*តាមព្រឹត្តន័យ* និង*តាមនីតិន័យ*របស់ជនជាប់ចោទ
   - ចំនួននៃអ្នកក្រោមបង្គាប់ និងថ្នាក់លើរបស់គាត់ និង
   - ភាពអចិន្ត្រៃយ៍នៃមុខតំណែង/រយៈពេលកាន់កាប់អំណាចរបស់គាត់

បន្ថែមលើកត្តាទាំងអស់នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ(បម្រុង) បានពិចារណាលើកត្តាខាងក្រោម ពីយុត្តិសាស្ត្រតុលាការ ICTY ដើម្បីវាយតម្លៃកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៣[71]៖

i. នីតិវិធីដែលបានអនុវត្តសម្រាប់ការតែងតាំងកាន់មុខតំណែង
ii. សមត្ថកិច្ចក្នុងការចេញបញ្ជា
iii. ថាតើបញ្ជាទាំងនោះតាមពិតត្រូវបានអនុវត្តដោយថ្នាក់ក្រោមឬទេ
iv. ការដឹងឮពិតប្រាកដថា ថ្នាក់ក្រោមកំពុងប្រព្រឹត្តឧក្រិដ្ឋកម្ម "រួមទាំងចំនួន ប្រភេទ និងទំហំនៃឧក្រិដ្ឋកម្មទាំងនោះ ពេលវេលាក្នុងអំឡុងពេលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ទីតាំងភូមិសាស្ត្ររបស់ឧក្រិដ្ឋកម្ម ក៏ដូចជាលក្ខណៈរីករាលដាលចុងក្រោយនៃអំពើទាំងនោះ"។
v. សិទ្ធិអំណាចក្នុងការចរចា ចុះហត្ថលេខា ឬ អនុវត្តកិច្ចព្រមព្រៀង
vi. ការគ្រប់គ្រងលើការចូលមកកាន់ទឹកដី

---

[68] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២២។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២១។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥២។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨៦។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍ស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 កថាខណ្ឌ ១៥ (ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តា ធិការបុគ្គល ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D181 ដោយមិនបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមានកំហុសក្នុងការផ្អែកលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងការធ្វើការសន្និដ្ឋានរបស់ខ្លួនទេ)។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍ស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D49 កថាខណ្ឌ១៥។

[69] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២២។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២៧។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨៧។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 កថាខណ្ឌ ១៦។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D49 កថាខណ្ឌ១៦។

[70] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២២។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៣២។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥៣។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០០។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃការស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 កថាខណ្ឌ ២៤។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃការស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D49 កថាខណ្ឌ ២១។

[71] សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃការស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 កថាខណ្ឌ ២៤។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃការស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D49 កថាខណ្ឌ ២១។

vii. តួនាទីពិតប្រាកដនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និង
viii. ថាតើអ្នកដែលមានឋានៈខ្ពស់ជាងនេះត្រូវបានផ្តន្ទាទោសហើយឬនៅ។

នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតមិនកម្រិតខ្លួនឯងទៅនឹងការអនុវត្តយ៉ាងតឹងរឹងនៃលក្ខណៈវិនិច្ឆ័យទាំងពីរ គឺភាពធ្ងន់ធ្ងរ និងកម្រិតនៃការទទួលខុសត្រូវ ដើម្បីកំណត់ថាតើជនត្រូវចោទគឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណានោះទេ។ នៅក្នុងការសម្រេចរួមគ្នាលើកលែងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតបានពន្យល់ថា ពួកគាត់បានពិចារណាលើកត្តាខាងក្រោមនេះថាពាក់ព័ន្ធ៖

i. គោលជំហររបស់ អ.វ.ត.ក. នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា - យុត្តាធិការលើរូបបុគ្គល យុត្តាធិការលើពេលវេលា និងយុត្តាធិការលើរឿងក្តី[72]
ii. *គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ[73]
iii. ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ដែលអ្នកតាក់តែងច្បាប់បានដឹងឮយ៉ាងច្បាស់អំពីចំនួនសរុបនៃការស្លាប់ និងចំនួនចារីជាច្រើន[74] និង
iv. ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ និងកម្រិតដែលជនត្រូវចោទអាចចូលរួមចំណែក ឬកំណត់គោលនយោបាយ ប.ក.ក. និង/ឬ ការបកស្រាយគោលនយោបាយទាំងនោះ[75]។

***គោលជំហររបស់ អ.វ.ត.ក.***៖ សហចៅក្រមស៊ើបអង្កេតបានបដិសេធអំណះអំណាងបែបទ្រឹស្តីថា ពួកគាត់គប្បីអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានទូលាយតាមដែលអាចធ្វើទៅបាន ដើម្បីជាប្រយោជន៍នៃការសន្និដ្ឋានអំពីយុត្តាធិការលើរូបបុគ្គល ដើម្បីបញ្ចៀសនូវគម្លាតនៃនិទណ្ឌភាព[76] ដោយសន្និដ្ឋានថា ការប្រៀបធៀបមិនត្រឹមត្រូវទៅនឹងច្បាប់យុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនៃតុលាការ ICTY គឺជាចុងក្រោយ "ពុំមានប្រយោជន៍ទេ ដោយសារ *បរិបទនៃការចរចា* នៅក្នុងករណី អ.វ.ត.ក. មានភាពខុសគ្នាទាំងស្រុង"[77]។ ពួកគាត់ផ្តល់ទឡ្ហីករណ៍ថា អ្នកតាក់តែងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. "ចង់កំហិតយុត្តាធិការបុគ្គលចំពោះអ្នកដែលមានការទទួលខុសត្រូវខ្ពស់ជាងគេបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពួកគេបានដឹងយ៉ាងច្បាស់ពីចំនួនសរុបនៃការស្លាប់ដែលត្រូវបានស្មានយ៉ាងតិចមានចំនួន ១,៧ លាននាក់"[78]។

***គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ**៖ សហចៅក្រមស៊ើបអង្កេតបានពិចារណាថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* "មានតួនាទីនៅក្នុងការបកស្រាយបទប្បញ្ញត្តិច្បាប់ ហើយការអនុវត្តគោលការណ៍នេះកំហិតត្រឹមតែវិមតិសង្ស័យដែលនៅមាន ក្រោយពេលអនុវត្តវិធានបទដ្ឋាននៃការបកស្រាយ"[79]។ សហចៅក្រមក៏យោងទៅគោលការណ៍នៃការបកស្រាយក្នុងន័យចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ ក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦[80] និងលក្ខន្តិកៈទីក្រុងរ៉ូមផងដែរ[81] ដោយពិចារណាថា "ការអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* /ការបកស្រាយក្នុងន័យចង្អៀត មានសារៈសំខាន់ជាងគេនៅ

---

[72] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១-២៥។
[73] ដូចខាងលើ កថាខណ្ឌ ២៦-៣៦។
[74] ដូចខាងលើ កថាខណ្ឌ ៣៧-៣៩។
[75] ដូចខាងលើ កថាខណ្ឌ ៤០-៤១។
[76] ដូចខាងលើ កថាខណ្ឌ ១២។
[77] ដូចខាងលើ កថាខណ្ឌ ១៨ (គូសបញ្ជាក់ក្នុងច្បាប់ដើម)។
[78] ដូចខាងលើ។
[79] ដូចខាងលើ កថាខណ្ឌ ២៦។
[80] ដូចខាងលើ កថាខណ្ឌ ២៦ សម្គាល់ជើងទំព័រ ២៣។
[81] ដូចខាងលើ កថាខណ្ឌ ២៦ សម្គាល់ជើងទំព័រ ២៤។

ក្នុងប្រព័ន្ធដែលច្បាប់មិនបានចែងពេញលេញ ហើយដែលនៅតែកើតមាននៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ (ដែលមានលក្ខណៈ)អន្តរជាតិ”[82]។

***ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម៖*** សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ចំណុចត្រូវពិនិត្យមើលដ៏ត្រឹមត្រូវគឺ ភាពធ្ងន់ធ្ងរដែលពាក់ព័ន្ធនៃសកម្មភាពផ្ទាល់របស់ជនត្រូវចោទ និងផលវិបាកនៃអំពើទាំងនោះ ដែល “ពុំមែនខុសគ្នាទាំងស្រុងនឹងការពិចារណាសម្រាប់គោលបំណងដាក់ទោស”។ ទោះជាយ៉ាងណា ពួកគាត់បានពិចារណាថា ចំណុចនេះអ្នកតាក់តែងច្បាប់ត្រូវតែដឹងឮអំពីចំនួនសរុបនៃការស្លាប់ និងថាមានបុគ្គលអាចជាចារីច្រើន ដែលចារីម្នាក់ៗអាចទទួលខុសត្រូវចំពោះការសម្លាប់មនុស្សរាប់រយ ឬរាប់ពាន់នាក់[83]។

***កម្រិតនៃការទទួលខុសត្រូវ៖*** សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ទោះបីជា “លក្ខខណ្ឌដំបូងជាក់ស្ដែង” ប៉ុន្តែមិនមែនសំខាន់ខ្លាំងដាច់ខាត គឺជាគោលជំហរផ្លូវការនៅក្នុងឋានានុក្រមយ៉ាងណាក្ដី ក៏ការពិចារណាដ៏សំខាន់ក្នុងការកំណត់ថាតើនរណាម្នាក់គឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” គឺកម្រិតដែលជនជាប់ចោទអាចចូលរួមចំណែកក្នុងការសម្រេចលើគោលនយោបាយ និង/ឬ ការអនុវត្តគោលនយោបាយ[84]។

***ការធ្វើសេចក្ដីសម្រេចនៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ៖*** ដោយពិចារណាលើភ័ស្ដុតាងក្នុងសំណុំរឿង សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ករណីបុគ្គលម្នាក់បានបង្កើត ឬត្រូវបង្កើតគំនិតផ្ដួចផ្ដើមរបស់ខ្លួនគឺពុំមែនជាលក្ខណវិនិច្ឆ័យមួយ ដែលអាចនឹងឱ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ដោយសារតែ “សេចក្ដីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់កំពូល និងបន្ទាប់មកត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងលក្ខណបុគ្គលទោះនៅថ្នាក់ណាក៏ដោយ ប៉ុន្តែផលវិបាកកើតមានកាន់តែច្រើននៅថ្នាក់ក្រោម តាមរយៈខ្សែចង្វាក់នៃការបញ្ជាដែលគេអាចមើលឃើញ ប្រសិនបើបញ្ជាទាំងនោះពុំត្រូវបានគោរពតាម”[85]។

សហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូលគ្នានូវការវិភាគរួមនេះ នៃពាក្យពេចន៍ “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ទៅក្នុងដីកាដំណោះស្រាយទាំងអស់ជាបន្តបន្ទាប់របស់ខ្លួន ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤[86]។

ទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិបានដាក់បញ្ចូលភាគច្រើននៃការវិភាគរួមអំពីច្បាប់ របស់សហចៅក្រមស៊ើបអង្កេតពីសំណុំរឿង ០០៤/០១ នៅក្នុងដីកាដំណោះស្រាយបន្តបន្ទាប់របស់គាត់ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ យ៉ាងណាក៏ដោយ ក៏គាត់បានប្រើប្រាស់វិធីសាស្ត្រផ្សេងក្នុងការបកស្រាយប្រវត្តិនៃការចរចា។ ក្នុងសំណុំរឿង ០០៣ គាត់បានពន្យល់ថា ឃ្លា “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ត្រូវបានដាក់បញ្ចូលយ៉ាងជាក់លាក់ក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដោយសំដៅទៅលើ ឌុច និងថាការដាក់បញ្ចូល ឌុច ក្នុងន័យ “ថាជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនេះ ជាបុគ្គលដែលដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ កៀកកិតនឹងការប្រព្រឹត្ត មានស្វ័យភាពក្នុងការងារ និងអំណាចតាមការអនុវត្តជាក់ស្ដែង”[87]។ ផ្អែកលើសំអាងហេតុដូចគ្នានេះដែរ ចៅក្រមបានសន្និដ្ឋាននៅក្នុងសំណុំរឿង ០០៤/០២ និង ០០៤ ថា ឌុច គឺជា “បុគ្គលតែម្នាក់ប៉ុណ្ណោះ ដែលជាជនទទួលខុសត្រូវខ្ពស់បំផុត”[88]។

ក្នុងសំណុំរឿង ០០៤/០២ និង សំណុំរឿង ០០៤ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា គោលដៅដែលជាគោលបំណងសម្រាប់ការចោទប្រកាន់ មានមិនលើសពីបុគ្គលចំនួនប្រាំនាក់ឡើយ ពោលគឺ

---

[82] ដូចខាងលើ កថាខណ្ឌ ២៧។

[83] ដូចខាងលើ កថាខណ្ឌ ៣៨ (សូមមើលផងដែរ កថាខណ្ឌ ១៨)។

[84] ដូចខាងលើ កថាខណ្ឌ ៣៨-៣៩។

[85] ដូចខាងលើ កថាខណ្ឌ ៤០។

[86] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៩-៥៦, ៦៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៨-៣៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣២-៣៤។

[87] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៦-៣៩៧។

[88] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៤២។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៣៨។

អ្នកដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២៖ នួន ជា, ខៀវ សំផន, អៀង សារី នឹង អៀង ធីរិទ្ធ និង ឌុច[89]។ ក្នុងសំណុំរឿង ០០៤/០២ ពួកគេបានពន្យល់ថា (១) មានតែបុគ្គលចំនួនប្រាំពីរនាក់ប៉ុណ្ណោះដែលជាមេដឹកនាំជាន់ខ្ពស់ ពោលគឺអ្នកដែលស្ថិតនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក. (ប៉ុល ពត, នួន ជា, អៀង សារី, សៅ ភឹម, តាម៉ុក, វន វ៉េត និង សុន សេន)[90] (២) ឌុច បើទោះជាមិនមែនជាមេដឹកនាំជាន់ខ្ពស់ ដូច្នេះ "ប្រាកដជាប្រភេទ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម"[91] (៣) "ភ័ស្តុតាងច្បាស់ក្រឡែត" ត្រូវបានផ្តល់ជូនក្នុងអំឡុងពេលកិច្ចប្រជុំរដ្ឋសភាកម្ពុជានាខែតុលា ឆ្នាំ២០០៤ ថា "ជនដែលត្រូវនាំយកមកកាត់ទោសនៅ អ.វ.ត.ក. មានចំនួនតែ ៣ ឬ ៤ នាក់ប៉ុណ្ណោះ"[92] និង (៤) មិនមានបុគ្គលណាំនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ និងទីបី ក្នុងសំណុំរឿង ០០៣ និង ០០៤ គឺជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ[93]។ ក្នុងសំណុំរឿង ០០៤ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាបន្ថែមទៀតថា ចំនួនមនុស្សនៅក្នុងសំណុំរឿង ០០១ និង ០០២ មានភាពស្របគ្នាទៅនឹងការលើកឡើងរបស់ឧបនាយករដ្ឋមន្ត្រី នៅក្នុងកិច្ចប្រជុំពិភាក្សាដេញដោលរបស់រដ្ឋសភាជាតិនាខែតុលា ឆ្នាំ២០០៤[94]។

### ១.១.៦. បទដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់ការកំណត់យុត្តាធិការលើរូបបុគ្គល

អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា ការកំណត់យុត្តាធិការលើរូបបុគ្គលរបស់សហចៅក្រមស៊ើបអង្កេត គឺធ្វើឡើងតាមឆន្ទានុសិទ្ធិ និងអាចត្រូវបានបដិសេធចោលប្រសិនបើសេចក្តីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនត្រឹមត្រូវ ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត ដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ និង /ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង[95]។ អង្គបុរេជំនុំជម្រះបានពន្យល់ថា ប្រសិនបើខ្លួនបដិសេធសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេ "នឹងបញ្ជូនសេចក្តីសម្រេច" ទៅឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការពិចារណាសាជាថ្មី ប៉ុន្តែអង្គបុរេក៏អាចចេញសេចក្តីសម្រេចរបស់ខ្លួនជំនួសបានដែរ ក្នុងករណីពិសេស និងចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច[96]។ សេចក្តីពិចារណាទាំងអស់នេះ មិនត្រូវបានពិនិត្យឡើងវិញបន្ថែមទៀតនៅចំពោះមុខ អ.វ.ត.ក. ទេ[97]។

### ១.២. យុត្តាធិការលើពេលវេលា

យុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. ត្រូវបានកំណត់និយមន័យថារយៈពេលចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[98]។ កាលបរិច្ឆេទនេះចំពេលដែលទីក្រុងភ្នំពេញធ្លាក់

---

[89] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៥០។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១២៨-១២៩។
[90] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២២២-២២៤។
[91] ដូចខាងលើ កថាខណ្ឌ ២២៣។
[92] ដូចខាងលើ កថាខណ្ឌ ២៤៩។
[93] ដូចខាងលើ កថាខណ្ឌ ២២៥។
[94] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១២៣, ១២៥។
[95] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២១។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៩។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៧។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥។
[96] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២២។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៨។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦។
[97] សូមមើល វិធានផ្ទៃក្នុង វិធាន ៧៦(៧)។ សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ១១១។
[98] កិច្ចព្រមព្រៀង អ.ស.ប.-រាជរដ្ឋាភិបាលកម្ពុជា មាត្រា ១។ ច្បាប់ អ.វ.ត.ក. មាត្រា ១, ២ (ថ្មី)។

ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ និងការមកដល់របស់កងកម្លាំងដែលគាំទ្រដោយវៀតណាមចូលកាន់កាប់រដ្ឋធានីក្នុងខែមករា ឆ្នាំ១៩៧៩[99]។

យោងតាមបទប្បញ្ញត្តិទាំងអស់នេះ អ.វ.ត.ក. មានយុត្តាធិការក្នុងការសម្រេចលើឧក្រិដ្ឋកម្មដែល*ត្រូវបានប្រព្រឹត្ត*ក្នុងអំឡុងរយៈកាលនេះ។ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ("JCE") ដែលរួមមាន គោលបំណង (ឧក្រិដ្ឋ)រួម តាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដូច្នេះតម្រូវឱ្យអង្គជំនុំជម្រះបកស្រាយបទប្បញ្ញត្តិទាំងនេះ[100]។ ជាងនេះទៀត ការបង្កើត អ.វ.ត.ក. ដោយមានយុត្តាធិការលើពេលវេលាជាក់លាក់ និងយុត្តាធិការលើរូបបុគ្គល បាននាំឱ្យមានបញ្ហាចោទថាតើ យុត្តាធិការរបស់ អ.វ.ត.ក. មានលក្ខណៈដាច់ខាត ឬយ៉ាងណា នៅក្នុងអំឡុងរយៈកាលនេះ ឬថាតើ (និងក្នុងទំហំណា) ដែលតុលាការទូទៅនឹងបន្តមានយុត្តាធិការ[101] និងថាតើអង្គជំនុំជម្រះអាចពឹងផ្អែកលើភស្តុតាង ពាក់ព័ន្ធនឹងអង្គហេតុនៅក្រៅរយៈពេលខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ដែរ ឬយ៉ាងណា[102]។

### ១.២.១. គោលការណ៍វិសាលភាពពេលវេលា

មាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ១ និង ២(ថ្មី) នៃច្បាប់ អ.វ.ត.ក. បានចែងថា អ.វ.ត.ក. ត្រូវបានបង្កើតឡើងសម្រាប់អំពើជាក់លាក់ "ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"។ ជាងនេះទៀត មាត្រា ៥(៣) និង ៦(៣) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា បានចែងថា វិសាលភាពនៃការស៊ើបអង្កេត និងការចោទប្រកាន់ (ដោយសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា) កម្រិតត្រឹមតែ "ឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ នឹងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ និងដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"។

#### ១.២.១.១. ការបកស្រាយយុត្តាធិការលើពេលវេលា

អ.វ.ត.ក. មិនមានយុត្តាធិការលើពេលវេលាក្នុងករណីដែល*អំពើសត្យានុម័ត*នៃបទឧក្រិដ្ឋ ត្រូវបានប្រព្រឹត្តនៅក្រៅអំឡុងពេលថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ឡើយ[103]។ ទោះជាយ៉ាងណា ក្នុងករណីដែលជនជាប់ចោទមិនបានអនុវត្ត*អំពើសត្យានុម័ត*ដោយខ្លួនឯងផ្ទាល់ទេនោះ អ.វ.ត.ក. មានយុត្តាធិការលើអំពើប្រព្រឹត្ត *ដែលបង្កើតឱ្យមាន*ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ផ្អែកលើការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ អំពើប្រព្រឹត្តនេះត្រូវតែ "ជាផ្នែកនៃការរួមចំណែកយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តគោលបំណងរួមដែលបានបន្តនៅក្រោយថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥"។ ជនជាប់ចោទនៅតែទទួលខុសត្រូវចំពោះអំពើទាំងអស់នេះ ក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. លុះត្រាតែពួកគេបានដកខ្លួនចេញពីសហឧក្រិដ្ឋកម្មរួមតាំងពីដំបូង[104]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យយុត្តាធិការរបស់ អ.វ.ត.ក. លើអំពើប្រព្រឹត្តដែលមានកាលបរិច្ឆេទមុនយុត្តាធិការលើពេលវេលារបស់ខ្លួន ប៉ុន្តែបានបង្កើតឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ផ្អែកលើការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា៖ (១) នៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងរួមគ្នាដោយបុគ្គលជាច្រើននាក់ក្នុងគោលបំណងល្មើសរួម និងអ្នកដែលរួមចំណែកតាមវិធីសាស្ត្រពាក់ព័ន្ធក្នុងការអនុវត្តគោលបំណងនេះ បង្កើតបានជាបណ្តុំនៃការអនុវត្តផែនការយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកដែលប្រព្រឹត្តអំពើ*សត្យានុម័ត*ដោយផ្ទាល់ ហើយ

[99] សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ជំពូក ១។
[100] សូមមើល ផ្នែក ១.២.១.១។
[101] សូមមើល ផ្នែក ១.២.១.២។
[102] សូមមើល ផ្នែក ១.២.១.៣។
[103] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២១៣។
[104] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៨២៣-១៨៣៤។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២២១។

(២) អ្នកចូលរួមទាំងអស់នេះត្រូវបានចាត់ទុកថាជាសហចារី ដែលជាធាតុផ្សំសំខាន់នៅក្នុងការព្រមព្រៀងគ្នាជំរុញគោលបំណងរួម[105]។ ”

ក្នុងការធ្វើសេចក្តីសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់សំអាងហេតុថា ផ្អែកតាមទស្សនៈនៃច្បាប់សារធាតុ ជាការ "ពុំសមស្របក្នុងការបំបែកចេញនូវការបំពេញកិច្ចការនេះដែលមានលក្ខណៈស្មុគស្មាញ និងអូសបន្លាយពេលយូរ ដែលអាចយល់បានតែក្នុងករណីដែលសមាសភាពទាំងអស់នៃសហឧក្រិដ្ឋកម្មរួមត្រូវបានពិចារណារួមគ្នា"[106]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ពេលវេលានៃការអនុវត្តផែនការនេះ គិតចាប់ពីពេលរួមចំណែកដំបូងក្នុងគោលបំណងរួម ដែលជាការបង្ហាញឱ្យឃើញច្បាស់អំពីចេតនាល្មើសរួម និងបញ្ចប់ "នៅពេលសកម្មភាពល្មើសបន្ថែមទៀតណាមួយរបស់សហឧក្រិដ្ឋកម្មនេះឈប់បន្ត ឬពាក់ព័ន្ធទៅនឹងបុគ្គលដែលបានរួមចំណែកនៅក្នុងការអនុវត្តនោះដកខ្លួនចេញពីសហឧក្រិដ្ឋកម្ម ដែលការដកខ្លួននេះតម្រូវឱ្យមានការបញ្ឈប់នូវការរួមចំណែកណាមួយបន្តទៀត ព្រមទាំងការបោះបង់ចេតនាល្មើសរួមផងដែរ"។ ” អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិធីសាស្ត្រនេះនៅតែមានសុពលភាព "បើទោះបីជាអាចមានភាពចាំបាច់ក្នុងការកាត់បង្រួមដើម្បីប្រកាសពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម តាមរយៈការកំណត់ដែនយុត្តាធិការ ដូចជា អាជ្ញាយុកាល អាយុរបស់ចារី ការកម្រិតដែនកំណត់ពេលវេលា ជាដើម"[107]។

អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់បន្ថែមទៀតថា បញ្ហាចោទថាតើបុគ្គលដែលសហការដោយមានចេតនាឧក្រិដ្ឋ រួមបញ្ចូលទាំងអ្នកដែលបង្កើតគោលបំណងឧក្រិដ្ឋរួម និងចូលរួមចំណែកក្នុងផែនការនោះ គប្បីត្រូវបានចាត់ទុកថាជាសហចារី រួមគ្នាជាមួយនឹងអ្នកដែលអនុវត្តបទល្មើសនោះ ឬយ៉ាងណានោះ "ទំនងជាពុំបានកើតមាន" នៅក្នុងបរិបទច្បាប់អន្តរជាតិនោះទេ[108]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានរកឃើញការគាំទ្រក្នុងយុត្តាធិការក្នុងស្រុក "ដែលប្រើប្រាស់ទម្រង់នៃការទទួលខុសត្រូវសម្រាប់ការចូលរួមនៅក្នុងសកម្មភាពដែលមានចារីផ្ទាល់ច្រើន ដែលប្រហាក់ប្រហែលគ្នាទៅនឹងសហឧក្រិដ្ឋកម្មរួមដែរ" ពោលគឺនៅក្នុងប្រទេសអង់គ្លេស និង វែល៍ និងនៅសហរដ្ឋអាមេរិក៖

i. យោងតាមយុត្តិសាស្ត្ររបស់អង់គ្លេស និងវែល៍ សមាជិកណាមួយនៃសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវចំពោះរាល់អំពើទាំងអស់របស់ក្រុម លើកលែងតែពួកគេដកខ្លួនចេញជាផ្លូវការពីសហឧក្រិដ្ឋកម្មរួមក្នុងលក្ខណៈច្បាស់លាស់ និងទាន់ពេលវេលា។ ចំណុចផ្តោតត្រង់នេះគឺលើការបន្តចូលរួមនៅអំឡុងពេលនៃការប្រព្រឹត្តិ*អំពើសត្យានុម័ត* មិនមែនផ្តោតលើការចូលរួមជាលក្ខណៈបុគ្គលទេ។ ស្រដៀងគ្នាទៅនឹងបទឧក្រិដ្ឋនៃការសមគំនិតដែរ សហឧក្រិដ្ឋកម្មរួមសង្កត់ធ្ងន់លើការព្រមព្រៀងបន្ត ដែលធ្វើឱ្យយុត្តិសាស្ត្រស្តីពីយុត្តាធិការពេលវេលានៃការសមគំនិតមានភាពពាក់ព័ន្ធផងដែរ។ នៅក្នុងប្រទេសអង់គ្លេស និងវែល៍ ទោះបីជាបទឧក្រិដ្ឋនៃការសមគំនិតត្រូវបានចាត់ទុកថា បានប្រព្រឹត្តនៅពេលណាមានការព្រមព្រៀងរវាងអ្នកសមគំនិតត្រូវបានធ្វើឡើងក៏ដោយ ក៏បទឧក្រិដ្ឋនេះបន្តរហូតដរាបណាផែនការនៃការសមគំនិតនេះនៅតែបន្តអនុវត្ត[109]។
ii. នៅក្នុងច្បាប់សហរដ្ឋអាមេរិក ការសមគំនិតត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋដែលកំពុងបន្ត ដូច្នេះអាជ្ញាយុកាលមិនចាប់ផ្តើមគិតឡើយ រហូតទាល់តែការព្រមព្រៀងលើបទល្មើសបានបញ្ចប់ បានបោះបង់ចោល ឬបន្ទាប់ពីសកម្មភាពឥតលាក់លៀមចុងក្រោយក្នុងការជំរុញការព្រមព្រៀងត្រូវបានធ្វើឡើង ដោយមិនគិតពីពេលវេលានៃការចូលរួមជាបុគ្គលទេ[110]។

ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា បទល្មើសក្នុងសំណុំរឿង ០០២/០១ "ត្រូវបានប្រព្រឹត្ត" នៅក្នុងយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. ដោយយល់ឃើញថា ការចូលរួម

[105] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២១៥។
[106] ដូចខាងលើ។
[107] ដូចខាងលើ។
[108] ដូចខាងលើ កថាខណ្ឌ ២១៦។
[109] ដូចខាងលើ។
[110] ដូចខាងលើ។

ចំណែករបស់ជនជាប់ចោទដែលកើតមានឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាផ្នែកមួយនៃបណ្តុំរបស់សហឧក្រិដ្ឋកម្មរួមដែល "បានបន្តអស់មួយរយៈពេល និងបានចេញជាផ្លែផ្កានោះ អំពើ*សត្យានុម័ត*ពាក់ព័ន្ធត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃយុត្តាធិការរបស់ អ.វ.ត.ក."[111]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា អំពើប្រព្រឹត្តដែលត្រូវបានចោទប្រកាន់មិនមែនជាអំពើតែមួយ (ដូចជា ការរៀបចំផែនការ ឬការញុះញង់) ដែលបានប្រព្រឹត្តឡើងក្រៅវិសាលភាពពេលវេលានៃយុត្តាធិការរបស់ អ.វ.ត.ក. ដែលចុងក្រោយក្លាយជាបទល្មើសនៅក្នុងយុត្តាធិការពេលវេលា ផ្ទុយទៅវិញគឺជាផ្នែកនៃការរួមចំណែកយ៉ាងទូលំទូលាយក្នុងការអនុវត្តគោលបំណងរួម ដែលបានបន្តក្នុងអំឡុងពេលក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ជនជាប់ចោទនៅតែទទួលខុសត្រូវ ពីព្រោះពុំមានការបង្ហាញថា ជនជាប់ចោទបានដកខ្លួនចេញពីគោលបំណងរួមនៅពេលណាមួយនោះឡើយ[112]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានរំលឹកឡើងវិញនូវការសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានរារាំងក្នុងការពិចារណាលើភស្តុតាងនៃអំពើ ឬសកម្មភាពមុនៗដែលមានតម្លៃជាភស្តុតាងសក្កានុពល និងជាប់ពាក់ព័ន្ធ "ក្នុងការបង្ហាញថាតើ លំនាំដែលជាប់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ក្នុងពេលជំនុំជម្រះនេះ បានស្តែងឱ្យឃើញជាក់លាក់ ដែរឬយ៉ាងណា និងសំខាន់ជាងនេះទៀត ថាតើលំនាំនោះត្រូវបានអនុវត្តតាមក្នុងអំឡុងពេលយុត្តាធិការពេលវេលាចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតមកក្នុងបរិបទនៃការអនុវត្តគោលបំណងរួមដែរ ឬយ៉ាងណា"[113]។

### ១.២.១.២. យុត្តាធិការផ្តាច់មុខលើរឿងក្តីសម័យខ្មែរក្រហម

យុត្តិសាស្ត្ររបស់ អ.វ.ត.ក. មិនដាច់ស្រេចលើបញ្ហាថាតើ អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការផ្តាច់មុខលើបទល្មើសនៅក្នុងយុត្តាធិការលើពេលវេលារបស់ខ្លួនដែរ ឬយ៉ាងណាឡើយ។

នៅក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា អ.វ.ត.ក. មានយុត្តាធិការផ្តាច់មុខលើរឿងក្តីនានានៅក្នុងវិសាលភាពរបស់ខ្លួន ដូច្នេះដាក់កម្រិតយុត្តាធិការរបស់តុលាការធម្មតាលើរឿងក្តីនានាស្ថិតក្រោមយុត្តាធិការលើរូបបុគ្គល និងលើពេលវេលារបស់ អ.វ.ត.ក.[114]។ នៅពេលសម្រេចបដិសេធការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា ប្រសិនបើយុត្តាធិការលើរូបបុគ្គលត្រូវបានបដិសេធ ពុំមានតុលាការជាតិណាមានអយុត្តាធិការលើរឿងក្តីទាំងអស់នេះឡើយ ដោយសារតែលក្ខណៈពិសេសរបស់ អ.វ.ត.ក. ដែលគ្មានការបញ្ជូនរឿងក្តី ធៀបទៅនឹងសាលាក្តីផ្សេងទៀត[115]។ សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុថា វិធីសាស្ត្របែបជ្រើសរើសនេះ និង "គម្លាតនិទណ្ឌភាពជាខ្លាំង" ដែលកើតចេញពីវានឹង "ទំនងជាពុំពេញចិត្ត និងអយុត្តិធម៌សម្រាប់មនុស្សភាគច្រើន" ប៉ុន្តែគឺជា "ជម្រើសមនសិការនយោបាយ" ហើយក៏ជា "លក្ខណៈទូទៅនៃប្រព័ន្ធយុត្តាធិការ (ដែលមានលក្ខណៈ)អន្តរជាតិ ដែលបានបង្កើតឡើងដើម្បីបញ្ចប់សុីណារីយ៉ូក្រោយជម្លោះតាមផ្លូវតុលាការ" ផងដែរ[116]។

ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបានសម្រេចថា អ.វ.ត.ក. *ពុំ*មានយុត្តាធិការផ្តាច់មុខលើបទល្មើសដែលស្ថិតក្នុងយុត្តាធិការលើពេលវេលារបស់ខ្លួននោះទេ[117]។ អង្គបុរេបានពិចារណាឃើញថា រឿងក្តីដែល អ.វ.ត.ក. បានទទួលមិនអាចត្រូវបានបញ្ជូនទៅតុលាការក្នុងស្រុកទេ ដោយសារតែច្បាប់ជាធរមានមិនបានប្រមើលអំពីនីតិវិធីបញ្ជូនរឿងក្តីទេ[118] និងថា តុលាការកម្ពុជាមានយុត្តាធិការពេញលេញជាប់មកជាមួយលើ

[111] ដូចខាងលើ កថាខណ្ឌ ២១៧។
[112] ដូចខាងលើ កថាខណ្ឌ ២១៧, ២២១។
[113] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៨២៣។
[114] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៣។
[115] ដូចខាងលើ កថាខណ្ឌ ១៤-២៥។ នៅក្នុងសំអាងហេតុរបស់ពួកគេ សហចៅក្រមស៊ើបអង្កេតមិនបានបែងចែករវាងសំណុំរឿងដែល អ.វ.ត.ក. បានទទួល និងសំណុំរឿងដែល អ.វ.ត.ក. មិនបានទទួលនោះទេ។
[116] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥, ៣២, ៣៥។
[117] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៥-៥៩។
[118] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៤។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៦។

បញ្ហាយុត្តិធម៌ព្រហ្មទណ្ឌ ដែលរួមបញ្ចូលទាំងយុត្តាធិការលើរឿងក្តីសម័យខ្មែរក្រហម ដែល អ.វ.ត.ក. មិនបានទទួល[119]។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា ច្បាប់ អ.វ.ត.ក. ជាធរមាន មិនរារាំងយុត្តាធិការរបស់តុលាការធម្មតានោះទេ ដោយសារមិនមានត្រង់ណានៅក្នុងច្បាប់ជាធរមានបានបញ្ជាក់ថា អ.វ.ត.ក. មានយុត្តាធិការផ្តាច់មុខលើរឿងក្តីសម័យខ្មែរក្រហមនោះឡើយ[120]។ អង្គបុរេក៏បានសន្និដ្ឋានផងដែរថា ប្រវត្តិនៃការចរចាគាំទ្រការសន្និដ្ឋានថា អ.វ.ត.ក. ពុំបានរារាំងយុត្តាធិការរបស់តុលាការធម្មតាទេ[121]។

ភាពផ្តាច់មុខនៃយុត្តាធិការរបស់ អ.វ.ត.ក. លើរឿងក្តីសម័យខ្មែរក្រហម មិនត្រូវបានពិនិត្យបន្ថែមទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលនោះឡើយ។"

### ១.២.១.៣. គោលការណ៍ស្តីពីការប្រើប្រាស់ភ័ស្តុតាង

#### ១.២.១.៣.១. *ភ័ស្តុតាង ឬអង្គហេតុនៅក្រៅយុត្តាធិការពេលវេលា ឬវិសាលភាពនៃរឿងក្តី*

ពីដើមដំបូងនៃកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានឯកភាពថា ខ្លួនអាចពឹងផ្អែកលើភ័ស្តុតាងដែលស្ថិតក្រៅវិសាលភាពនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.៖ (១) ដើម្បីបំភ្លឺបរិបទ (២) ដើម្បីធ្វើការសន្និដ្ឋានធាតុផ្សំ [...] នៃអំពើល្មើសដែលបានកើតឡើងក្នុងអំឡុងពេលពាក់ព័ន្ធនោះ ឬ (៣) ដើម្បីបង្ហាញលំនាំនៃអំពើគិតទុកជាមុន"[122]។ ភ័ស្តុតាងនេះពិតជាអាចបង្ហាញបានថាពាក់ព័ន្ធទៅនឹងបញ្ហានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. និងវិសាលភាពនៃការជំនុំជម្រះ[123]។ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងសំណើសុំឱ្យទទួលយកភ័ស្តុតាង ទាក់ទងនឹងព្រឹត្តិការណ៍នៅក្រៅយុត្តាធិការពេលវេលា ជាមួយនឹងភារកិច្ចរបស់ខ្លួន ក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស[124]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការសន្និដ្ឋានរបស់ខ្លួនលើការសន្មតថា ក្នុងកាលៈទេសៈជាក់លាក់ អង្គជំនុំជម្រះអាចផ្អែកលើភ័ស្តុតាងទាក់ទងនឹងអំពើមុនឆ្នាំ១៩៧៥ ឬក្រោយឆ្នាំ១៩៧៩[125]។ មិនមានភាគីណាបានប្តឹងសាទុក្ខជំទាស់ទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើ

---

[119] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៧។
[120] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧២-៨០។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៨-៥៩។
[121] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៨។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៧។
[122] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៦៦៦។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ១៩៥។ សំណុំរឿង ០០២/០១ សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E93 ទំព័រ ២។ សំណុំរឿង ០០២ ដីកាសម្រេចលើពាក្យសុំ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ឯកសារ D300 កថាខណ្ឌ ៩-១០។
[123] សំណុំរឿង ០០២/០១ សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E93 ទំព័រ ២។
[124] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E116 កថាខណ្ឌ ២០។ សូមមើលផងដែរ សំណុំរឿង ០០២ សំណើរួមលើកទី១ សុំបំពេញកិច្ចស៊ើបសួរបន្ថែម ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ឯកសារ E88 កថាខណ្ឌ ១២។
[125] សូមមើល សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ១១៥។ នៅក្នុងផ្នែកសំអាងហេតុ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់លើតួនាទីរបស់ជនជាប់ចោទ នៅក្នុងគុក ម១៣ និងបានរកឃើញថា "នៅខែកក្កដា ឆ្នាំ១៩៧១ ជនជាប់ចោទបានទទួលភារកិច្ចគ្រប់គ្រងមន្ទីរម១៣ ដែលជាមន្ទីរសន្តិសុខសម្រាប់សួរចម្លើយជនទាំងឡាយណាដែលត្រូវបានគេសង្ស័យថាជា "គិញ" ឬខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា"។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ក្នុងជើងទំព័រ ១៩២ ចំពោះសំអាងហេតុទាំងអស់នេះថា ៖ "ព្រឹត្តិហេតុដែលទាក់ទងនឹងមន្ទីរម១៣ មិនស្ថិតនៅក្នុងយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក. ទេ"។ សូមមើល មាត្រា ២ (ថ្មី) នៃច្បាប់ អ.វ.ត.ក. (ដែលបានកំណត់យុត្តាធិការ អ.វ.ត.ក. ត្រឹមឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង "ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩)។ ដោយសារតែ ម១៣ ជាមន្ទីរឃុំឃាំងដែលមានលក្ខណៈដូចគ្នាច្រើនមុន ស-២១ ហេតុដូច្នេះអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មទាក់ទងនឹងមុខងាររបស់ ម១៣ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងមន្ទីរនោះ។

បញ្ហាប្រើប្រាស់ភ័ស្តុតាងពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. នោះទេ ហើយជាលទ្ធផលបញ្ហានេះមិនត្រូវបានពិភាក្សានៅក្នុងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលទេ។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ព័ត៌មានណាដែលមានធាតុផ្សំបរិបទ ក៏អាចមានធាតុផ្សំបរិបទជាក់លាក់ពិតប្រាកដតិចតួច ដែលស្ថិតនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ផងដែរ។ អង្គបុរេបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានយោងយ៉ាងត្រឹមត្រូវទៅបទដ្ឋានដែលបានកំណត់ដោយសាលដីការបស់តុលាការ ICTR ក្នុងរឿងក្តី *Nahimana*[126]។

ក្នុងអំឡុងពេលដំណាក់កាលរៀបចំការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ "ការលើកលែងខ្លះដែលមានកម្រិតដល់ភាគី ដើម្បីបង្ហាញភ័ស្តុតាងដែលពុំស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. នៅពេលដែលភ័ស្តុតាងទាំងនោះមានភាពពាក់ព័ន្ធដើម្បីបញ្ជាក់អំពីព័ត៌មាន ឬបរិបទសាវតារ"[127]។ អង្គជំនុំជម្រះសាលាដំបូងក្រោយមកបានបញ្ជាក់គោលជំហររបស់ខ្លួនឡើងវិញ ដោយសម្រេចថា បញ្ហាបរិបទប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍នៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. អាចត្រូវបានពិចារណា "តែនៅពេលណាដែលមានការបង្ហាញឱ្យឃើញថាវាមានភាពពាក់ព័ន្ធទៅនឹងបញ្ហាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. និងនៅក្នុងវិសាលភាពនៃការជំនុំជម្រះ ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះតែប៉ុណ្ណោះ"[128]។ សាលក្រមសំណុំរឿង ០០២/០១ និង ០០/០២ បានអនុម័តវិធីសាស្ត្រនេះ និងបានយោងជាពិសេសនូវបទដ្ឋានដែលបានកំណត់ដោយសាលដីការបស់តុលាការ ICTR ក្នុងរឿងក្តី *Nahimana*[129]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងអាចពឹងផ្អែកយ៉ាងត្រឹមត្រូវលើភ័ស្តុតាងនៅក្រៅវិសាលភាពនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ដើម្បី៖ (១) បំភ្លឺបរិបទ (២) ធ្វើការសន្និដ្ឋានធាតុផ្សំនៃអំពើល្មើស ឬ (៣) ដើម្បីបង្ហាញលំនាំនៃអំពើគិតទុកជាមុន"[130]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានយោងយ៉ាងត្រឹមត្រូវទៅលើសាលដីការបស់តុលាការ ICTR ក្នុងរឿងក្តី *Nahimana* នៅពេលធ្វើការវាយតម្លៃភ័ស្តុតាងឯកសារបន្ទាប់ពីបំបែកសំណុំរឿង និងបានអនុវត្តយ៉ាងត្រឹមត្រូវនូវគោលការណ៍ស្តីពី "ភ័ស្តុតាងជាប់ពាក់ព័ន្ធនៅក្រៅវិសាលភាព"[131]។ ក្នុងការធ្វើសេចក្តីសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា អនុលោមតាមវិធាន ៨៩ស្ទួនបី (៣) ភ័ស្តុតាងទាក់ទងនឹងអង្គហេតុដែលត្រូវបានដកចេញ នៅតែអាចត្រូវបានពិចារណា ប្រសិនបើមានការជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅសេសសល់នោះ[132]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងត្រឹមត្រូវថា ភ័ស្តុ

---

[126] សំណុំរឿង ០០២ ដីកាសម្រេចលើពាក្យសុំ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ឯកសារ D300 កថាខណ្ឌ៩-១០។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៤៩ សម្គាល់ជើងទំព័រ ១២៩។

[127] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងជំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ឯកសារ E185 កថាខណ្ឌ ២៩។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E93 ទំព័រ ២។

[128] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E116 កថាខណ្ឌ ២០។

[129] សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ១៩៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ១៦៤១។

[130] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៦៦៦។

[131] ដូចខាងលើ កថាខណ្ឌ ៦៦៥-៦៦៨, ៩៧០ សម្គាល់ជើងទំព័រ ២៧៥៤, ២៣៣២, ១៨២៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦០។ ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បណ្តាលឱ្យមានភាពចាំបាច់ក្នុងការពិចារណាឡើងវិញលើភ័ស្តុតាងឯកសារដែលអាចទទួលយកបាន នៅក្នុងសំណុំរឿង។ ហេតុដូច្នេះ ភាពពាក់ព័ន្ធនៃរាល់ឯកសារទាំងអស់ត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះ បន្ទាប់ពីសវនាការលើឯកសារ ដែលភាគីបានដាក់គោលជំហររបស់ខ្លួនលើភាពពាក់ព័ន្ធ តម្លៃជាភ័ស្តុតាង និងភាពអាចទទួលយកបានរបស់ឯកសារ។

[132] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៦៦៥។

តាងក្រៅវិសាលភាព អាចត្រូវបានពិចារណា តែនៅពេលណាដែលវាស៊ីចង្វាក់គ្នាទៅនឹងភ័ស្តុតាងផ្សេងទៀតប៉ុណ្ណោះ[133]។ អាស្រ័យហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងអាច "សំអាងសមស្របទៅលើភ័ស្តុតាងក្រៅវិសាលភាពនៃពេលវេលា ឬភូមិសាស្ត្រនៃរឿងក្តីដើម្បីបង្ហាញតាមរយៈការយោងនូវធាតុផ្សំនៃអំពើល្មើស"[134]។

#### *១.២.១.៣.២. ភ័ស្តុតាងក្រោយការកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេត*

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា បន្ទាប់ពីកំណត់វិសាលភាពនៃការស៊ើបអង្កេតក្នុងអំឡុងពេលដំណាក់កាលស៊ើបសួរ ភ័ស្តុតាងដែលទាក់ទងទៅនឹងអង្គហេតុដែលបានដកចេញ នៅតែអាចពឹងផ្អែកលើអនុលោមតាមវិធាន ៦៦*ស្ទួនពីរ* (៥) ក្នុងលក្ខខណ្ឌដែលថាវាទាក់ទងទៅនឹងអង្គហេតុដែលនៅសល់[135]។

ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាថា បទប្បញ្ញត្តិនេះអនុវត្ត *បើមានការចាំបាច់* ចំពោះភ័ស្តុតាងអង្គហេតុជាមូលដ្ឋាន ដែលអាចត្រូវបដិសេធដោយផ្អែក អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង[136]។ យោងតាមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការស៊ើបអង្កេតស្មុគស្មាញ វាមានភាពជាក់ស្តែងជាងក្នុងការជៀសវាងការជូនដំណឹងផ្លូវការ និងការបដិសេធដោយផ្អែក។ វិធានការបែបទាំងនេះនឹងនាំឱ្យមាននីតិវិធី និងបណ្តឹងរារាំងមិនចាំបាច់ ដែលប៉ះពាល់ដល់ប្រសិទ្ធភាព។ ផ្ទុយទៅវិញ វិធីសាស្ត្រជាក់ស្តែងដែលផ្តោតលើការបែងចែកធនធាន សម្រាប់ការស៊ើបអង្កេតដែលនៅសល់គឺល្អជាង[137]។

### ១.៣. ការរារាំងយុត្តាធិការ

ការរារាំងយុត្តាធិការសំដៅលើគោលការណ៍ ឬកាលៈទេសៈគតិយុត្ត ដែលរារាំងតុលាការមិនឱ្យបើកសវនាការរឿងក្តីមួយ ឬអនុវត្តសមត្ថកិច្ចរបស់ខ្លួនលើបញ្ហាជាក់លាក់មួយ។ ឧទាហរណ៍ *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលត្រូវបានស្គាល់នៅក្នុងប្រព័ន្ធច្បាប់ជាច្រើន មានន័យថា បុគ្គលម្នាក់មិនអាចត្រូវបានកាត់ក្តី ឬផ្តន្ទាទោសពីរដងចំពោះបទល្មើសតែមួយនោះឡើយ។ ស្រដៀងគ្នានេះ ការលើកលែងទោស និងការអនុគ្រោះទោស គឺជាយន្តការគតិយុត្ត ដែលប្រើដើម្បីផ្តល់ការលើកលែងចំពោះបទល្មើស ឬអភ័យឯកសិទ្ធិសម្រាប់បទល្មើស។

សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានដោះស្រាយម្តងហើយម្តងទៀតជាមួយនឹងកាលៈទេសៈទាំងឡាយ ដែល *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*អនុវត្តនៅ អ.វ.ត.ក. និងវិសាលភាពដែលការលើកលែងទោស និងការអនុគ្រោះទោសដែលបានផ្តល់ឱ្យ រារាំងយុត្តាធិការ នៅពេលដែលធ្វើការសម្រេចលើអានុភាពនៃការផ្តន្ទាទោសក្នុងឆ្នាំ១៩៧៩ របស់ អៀង សារី ដោយតុលាការប្រជាជនបដិវត្តន៍ និងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសគាត់ក្នុងឆ្នាំ១៩៩៦។

ក្នុងសំណុំរឿង ០០២ អៀង សារី បានតវ៉ាថា យុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការចោទប្រកាន់គាត់ត្រូវបានរារាំងដោយ *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដោយសារតែរូបគាត់ត្រូវបានកាត់ទោស និងផ្តន្ទាទោស*ដោយកំបាំងមុខ* ចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងដោយសារព្រះរាជក្រឹត្យដែលបានផ្តល់ឱ្យគាត់ ដែលលើកឡើងបញ្ហាចោទអំពីភាពអាចអនុវត្តបាននៃការរារាំងយុត្តាធិការទាំងអស់នេះនៅ អ.វ.ត.ក.។ បញ្ហាទាំងអស់នេះត្រូវបានពិភាក្សាក្នុងផ្នែកខាងក្រោម។

---

[133] ដូចខាងលើ កថាខណ្ឌ ៦៦៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦០។
[134] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៩៧០។
[135] សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226 កថាខណ្ឌ ១១។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ D302/3 កថាខណ្ឌ ១០-១១។
[136] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ D302/3 កថាខណ្ឌ ១១។
[137] ដូចខាងលើ កថាខណ្ឌ ១២។

### ១.៣.១. គោលការណ៍ស្តីពី*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*

គោលការណ៍ស្តីពី*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ចែងថា ពុំមាននរណាម្នាក់ត្រូវបានកាត់ទោសពីរដងចំពោះបទល្មើសតែមួយនោះឡើយ[138]។ គោលការណ៍នេះចេញមកពីប្រព័ន្ធច្បាប់ស៊ីវិល និងស្រដៀងគ្នាទៅនឹងវិធានប្រឆាំងនឹងការកាត់ទោសពីរដង ដែលជាផ្នែកមួយនៃប្រព័ន្ធគតិយុត្តទូទាំងសាកលលោក[139]។ គេអាចមើលឃើញថាវាមានភាពពាក់ព័ន្ធតិចតួចទៅនឹងគោលការណ៍*អាជ្ញាអស់ជំនុំ* ដែលចែងថា តុលាការពុំគួរដោះស្រាយជាថ្មីម្តងទៀតនូវរឿងក្តីដែលត្រូវបានវិនិច្ឆ័យរួចហើយនោះទេ[140]។ គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅ អ.វ.ត.ក. ក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង អៀង សារី ដោយសារតែគាត់ត្រូវបាន "កាត់ទោស" *ដោយកំបាំងមុខ* ដោយតុលាការប្រជាជនបដិវត្តន៍ក្នុងឆ្នាំ១៩៧៩។

#### ១.៣.១.១. ក្របខ័ណ្ឌ អ.វ.ត.ក.

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. និង វិធានផ្ទៃក្នុង មិនបានផ្តល់ការការពារប្រឆាំងនឹងការកាត់ទោសពីរដងនោះទេ ហើយក៏ពុំលើកឡើងអំពីអានុភាពនៃការផ្តន្ទាទោសពីមុនលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. នោះដែរ ដោយសារតែមិនមានឯកសារណាក្នុងចំណោមឯកសារទាំងអស់នេះបានចែងដោយផ្ទាល់ អំពីគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះឡើយ[141]។ ដូច្នេះ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក. ពួកគេត្រូវស្វែងរកការណែនាំនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ[142]។

បទប្បញ្ញត្តិដែលចែងអំពីគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នៅកម្រិតជាតិ និងអន្តរជាតិ បង្ហាញទស្សនៈខុសគ្នាតិចតួចទៅលើវិសាលភាពនៃការការពារនេះ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*ត្រូវបានកំណត់និយមន័យផ្សេងគ្នានៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលឆ្លុះបញ្ចាំងទៅលើការពិចារណាថាតើអ្វីទៅដែលបង្កើតជា "បទល្មើសតែមួយ"[143]។ យោងតាមច្បាប់ជាតិ "បទល្មើសតែមួយ" ដូចគ្នាទៅនឹង "អង្គហេតុតែមួយ" ចំណែកកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ហាមឃាត់ការកាត់ទោសលើកក្រោយចំពោះ "បទល្មើសតែមួយ[144]។ ដោយកត់សម្គាល់ថា អៀង សារី មិនត្រូវបានចោទប្រកាន់ជាក់លាក់ចំពោះបទប្រល័យពូជសាសន៍ អង្គបុរេជំនុំជម្រះបានសម្រេចថា ការកំណត់បទចោទរបស់សហចៅក្រមស៊ើបអង្កេតមានលក្ខណៈមិនច្បាស់លាស់ខ្លាំង ដែលមិនអាចអនុញ្ញាតឱ្យមានការកំណត់ច្បាស់លាស់លើបញ្ហាចោទថាតើការចោទប្រកាន់បច្ចុប្បន្នគឺសម្រាប់ "អង្គហេតុតែមួយ" ដែលដូចគ្នាទៅនឹង

---

[138] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) សម្គាល់ជើងទំព័រ ២៩។

[139] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៤១។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) សម្គាល់ជើងទំព័រ ២៩។

[140] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៤៧។

[141] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១១៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៤២។

[142] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១១៨ *និងកថាខណ្ឌបន្តបន្ទាប់*។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៤១-៤៧។ សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ២៣ *និងកថាខណ្ឌបន្តបន្ទាប់*។

[143] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៤៣។

[144] ដូចខាងលើ កថាខណ្ឌ ៤៣។

អង្គហេតុដែលការចោទប្រកាន់ក្នុងឆ្នាំ១៩៧៩ បានផ្អែកលើឬ យ៉ាងណា។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា វិសាលភាពនៃការការពារដែលផ្តល់ឱ្យដោយគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* បានប្រែប្រួលអាស្រ័យលើវិធីដែលវាត្រូវបានអនុវត្ត[145]។

#### ១.៣.១.២. ច្បាប់កម្ពុជា

គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់កម្ពុជា នៅក្នុងគោលការណ៍*អាជ្ញាអស់ជំនុំ* ក្នុងមាត្រា ៧ និង ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ("CCP") និងបាន អនុវត្តទៅលើរាល់សេចក្តីសម្រេចទាំងអស់ មិនថាសាលក្រមសម្រេចឱ្យរួចទោស ឬផ្តន្ទាទោសនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌគ្រាន់តែលើកឧទាហរណ៍មួយអំពី*អាជ្ញាអស់ជំនុំ*ប៉ុណ្ណោះ និងថាមាត្រា ៧ ដាក់បញ្ចូល "*អាជ្ញាអស់ជំនុំ*" ជាមូលហេតុមួយក្នុងចំណោម "មូលហេតុនៃការរំលត់បណ្តឹងអាជ្ញា ដែលលទ្ធផលនោះគឺ "ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ចប់"[146]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា គោលការណ៍នេះ អនុវត្តតែករណីដែលរឿងក្តីដំបូងត្រូវបានឈានទៅដល់សេចក្តីសម្រេចស្ថាពរពាក់ព័ន្ធនឹងភាគី និងអង្គហេតុដូចគ្នាប៉ុណ្ណោះ និងថាអនុលោមតាមមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គោលការណ៍នេះអនុវត្តបានតែចំពោះ*អំពើតែមួយ* គឺពុំមែន*បទល្មើសតែមួយ*ឡើយ[147]។

#### ១.៣.១.៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

យោងតាម ICCPR មិនមានការការពារជាអន្តរជាតិដោយគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នោះទេ[148]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មាត្រា ១៤ នៃ ICCPR អនុវត្តតែទៅលើកិច្ចដំណើរការនីតិវិធីនៅក្នុងប្រព័ន្ធច្បាប់ជាតិប៉ុណ្ណោះ និង "មិនមែនអនុវត្តចំពោះ អ.វ.ត.ក. ដែលជាតុលាការអន្តរជាតូបនីយកម្មឡើយ"[149]។

អង្គជំនុំជម្រះសាលាដំបូងបានសង្កត់ធ្ងន់ថា មូលហេតុនៃការកំណត់គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នេះកើតចេញពី "លក្ខណៈពិសេសនៃអន្តរទំនាក់ទំនងរវាងកិច្ចដំណើរការនីតិវិធីតុលាការជាតិ និងអន្តរជាតិនៅក្នុងស្ថានការណ៍ប្រភេទនេះ"[150]។ អង្គជំនុំជម្រះបានសម្រេចថា "ក្នុងករណីដែលតុលាការអន្តរជាតិមានយុត្តាធិការលើបទល្មើស ដែលតុលាការជាតិធ្លាប់បានកាត់សេចក្តីម្តងរួចហើយដែលមានវិការជាក់ស្តែង គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*ត្រូវ

---

[145] ដូចខាងលើ កថាខណ្ឌ ៥៣។

[146] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ១៩ សម្គាល់ជើងទំព័រ ៤៣។ សូមមើល ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧ ("មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ៖ [...] ៥. អាជ្ញាអស់ជំនុំ។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់")។

[147] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១២ ("ដោយអនុវត្តគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ")។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ 27.

[148] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១២៨-១៣១។

[149] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣២។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១២៨-១៣១។

[150] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣៣។

បានថ្លឹងថ្លែងជាមួយផលប្រយោជន៍របស់សហគមន៍អន្តរជាតិ និងជនរងគ្រោះ ដើម្បីធានាបានថាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ពិតជាត្រូវបានជំនុំជម្រះដោយត្រឹមត្រូវ”[151]។

### ១.៣.១.៤. វិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ

វិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិចែងថា តុលាការអន្តរជាតិមិនត្រូវអនុវត្តយុត្តាធិការពាក់ព័ន្ធទៅនឹងបុគ្គលដែលត្រូវបានកាត់សេចក្ដីរួចហើយ ចំពោះអំពើតែមួយដោយអាជ្ញាធរជាតិនោះទេ “លើកលែងតែត្រូវបានរកឃើញថា ដំណើរការនីតិវិធីដោយតុលាការជាតិមិនត្រូវបានដំណើរការដោយឯករាជ្យ ឬអនាគតិ ស្របតាមបទដ្ឋាននីតិវិធីទេនោះ”។ មានតែកំហុសជាសារវន្តនៅក្នុងកិច្ចដំណើរការនីតិវិធីជាតិប៉ុណ្ណោះដែលអាចធ្វើយុត្តិកម្មការអនុវត្តយុត្តាធិការរបស់ អ.វ.ត.ក. ចំណែកឯ “ការគ្រាន់តែពិចារណាថា ការស៊ើបអង្កេត [...] ‘មិនបានធ្វើឡើងឱ្យបានគ្រប់ជ្រុងជ្រោយ និងធ្វើឡើងតែទៅលើភាគីម្ខាង’ ឬនាំឱ្យមាន ‘ការសម្រេចរួចផុតពីការចោទប្រកាន់ ទាំងកំហុស’” គឺមិនគ្រប់គ្រាន់នោះឡើយ[152]។

អង្គបុរេជំនុំជម្រះបានវិភាគសនិទានភាពពីក្រោយគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងបានវាយតម្លៃច្បាប់ និងយុត្តិសាស្ត្រអន្តរជាតិ មតិយោបល់របស់អ្នកស្រាវជ្រាវជាន់ខ្ពស់ និងមតិយោបល់ដែលបានលើកឡើងក្នុងអំឡុងពេលចរចាស្ដីពីលក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការ ICC។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានចែងដោយផ្ទាល់នៅក្នុងមាត្រា ១០(២)(ខ) នៃលក្ខន្តិកៈរបស់តុលាការ ICTY ដែលចែងថា បុគ្គលដែលត្រូវបានកាត់សេចក្ដីរួចហើយដោយតុលាការជាតិ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ អាចត្រូវបានកាត់សេចក្ដីដោយតុលាការ លុះត្រាតែ “ដំណើរការនីតិវិធីដោយតុលាការជាតិមិនមានអនាគតិ ឬឯករាជ្យ ដែលត្រូវបានរៀបចំឡើងដើម្បីការពារជនជាប់ចោទឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ ឬរឿងក្ដីនោះមិនត្រូវបានចោទប្រកាន់ប្រកបដោយវិរិយភាពតែប៉ុណ្ណោះ”[153]។

អង្គបុរេជំនុំជម្រះបានពិចារណាបន្ថែមទៀតថា វិធានសមាមាត្រ ឬស្រដៀងគ្នាទាំងនេះ មាននៅក្នុងលក្ខន្តិកៈរបស់តុលាការ ICTR, SCSL តុលាការពិសេសសម្រាប់ប្រទេសឡេបាណន និងលក្ខន្តិកៈទីក្រុងរ៉ូម[154]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា បើទោះជាបទប្បញ្ញត្តិទាំងអស់នេះខុសគ្នាក្នុងទិដ្ឋភាពខ្លះក្ដី ក៏ពួកវាទាំងអស់បង្ហាញថា តុលាការអន្តរជាតិបានបដិសេធមិនអនុវត្តយុត្តាធិការលើបុគ្គលដែលត្រូវបានផ្ដន្ទាទោសរួចហើយនៅចំពោះមុខតុលាការជាតិ ប្រសិនបើកិច្ចដំណើរការនីតិវិធីជាតិបំពេញតាមលក្ខខណ្ឌជាក់លាក់។ អង្គបុរេជំនុំជម្រះបានរកឃើញថា បើទោះជាការលើកលែងនេះត្រូវបានរៀបរាប់ដោយពាក្យពេចន៍ផ្សេងគ្នា ក៏បទប្បញ្ញត្តិទាំងអស់មានការលើកលែងចំនួនពីរចំពោះការអនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ៖ (១) ការពារបុគ្គល ឬ (២) ដំណើរការនីតិវិធីមិនបានធ្វើឡើងដោយឯករាជ្យ ឬអនាគតិ[155]។ អង្គបុរេបានពិចារណាថា ការអនុម័តប្រើបទប្បញ្ញត្តិ*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅក្នុងលក្ខន្តិកៈតុលាការអន្តរជាតិ និងតុលាការ *មិនអចិន្ត្រៃយ៍* មានគោលបំណងថ្លឹងថ្លែងសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ និងសច្ចភាពគតិយុត្ត ជាមួយនឹងផលប្រយោជន៍របស់សហគមន៍អន្តរជាតិ ក្នុងការកាត់ទោសចារីនៃឧក្រិដ្ឋកម្មអន្តរជាតិ និងការផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះ[156]។

អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ការយល់ឃើញនេះក៏ត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សជាច្រើនផងដែរ[157]។ ឧទាហរណ៍ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង ផ្ដល់ការណែនាំជាទូទៅ ក្នុងករណីដែលការផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដែលជាលទ្ធផលមិនមាន

---

[151] ដូចខាងលើ។
[152] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៥៧, ១៦០។
[153] ដូចខាងលើ កថាខណ្ឌ ១៣២, ១៤៨-១៥៣។
[154] ដូចខាងលើ កថាខណ្ឌ ១៣៣-១៣៤។
[155] ដូចខាងលើ កថាខណ្ឌ ១៣៨។
[156] ដូចខាងលើ កថាខណ្ឌ ១៤២ *និងកថាខណ្ឌបន្តបន្ទាប់*។
[157] ដូចខាងលើ កថាខណ្ឌ ១៥៤ *និងកថាខណ្ឌបន្តបន្ទាប់*។

ការដាក់ទោស ថាតើដោយការសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ឬការខកខានក្នុងការអនុវត្តទោស[158]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "ការមិនឱ្យមានការកាត់សេចក្ដីពីរដងលើបទល្មើសតែមួយ ពុំផ្ដួយទៅនឹងកាតព្វកិច្ចទទួលខុសត្រូវជាអន្តរជាតិរបស់រដ្ឋពាក់ព័ន្ធនឹងចារីនៃបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ"[159]។

អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិបានផ្ដល់ការណែនាំជាទូទៅនៅក្នុងករណី "ការផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដែលជាលទ្ធផលមិនមានការដាក់ទោស ថាតើដោយការសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ឬការខកខានក្នុងការអនុវត្តទោស"។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា នៅក្នុងរឿងក្ដីទាំងអស់នេះ គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនបានបដិសេធការចោទប្រកាន់ទេ ដោយសារវាមិនអាច "ផ្ដួយទៅនឹងកាតព្វកិច្ចទទួលខុសត្រូវជាអន្តរជាតិរបស់រដ្ឋពាក់ព័ន្ធនឹងចារីនៃបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ"[160]

### ១.៣.១.៥. ការវាយតម្លៃអំពី "តុលាការប្រជាជនបដិវត្តន៍" ឆ្នាំ១៩៧៩

តុលាការប្រជាជនបដិវត្តន៍ក្នុងទីក្រុងភ្នំពេញ ត្រូវបានរៀបចំឡើងនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ ដើម្បី "ជំនុំជម្រះអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តដោយបន ប៉ុល ពត-អៀង សារី" ពោលគឺ អំពើសម្លាប់រង្គាលដែលមានគម្រោងផែនការ ការបណ្ដេញប្រជាជនចេញពីទីក្រុង ការបង្ខំឱ្យធ្វើការជាទម្ងន់ ការលុបបំបាត់សាសនា និងការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធនយោបាយ វប្បធម៌ និងសង្គម និងទំនាក់ទំនងគ្រួសារ និងសង្គម[161]។ មិនយូរប៉ុន្មានបន្ទាប់ពីការបង្កើតរបស់ខ្លួន ពីថ្ងៃទី១៥ ដល់ទី១៩ ខែសីហា ឆ្នាំ១៩៧៩ តុលាការប្រជាជនបដិវត្តន៍បានធ្វើការជំនុំជម្រះក្ដី*ដោយកំបាំងមុខ* ប្រឆាំងនឹង ប៉ុល ពត និង អៀង សារី ចំពោះការចូលរួមរបស់ពួកគេក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយខ្មែរក្រហម។ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ ជនជាប់ចោទទាំងពីររូបត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះបទប្រល័យពូជសាសន៍ និងត្រូវបានកាត់ទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេទាំងអស់[162]។

ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានសម្រេចថា ភាពខ្វះចន្លោះនៅក្នុងកិច្ចដំណើរការនីតិវិធីឆ្នាំ១៩៧៩ របស់តុលាការប្រជាជនបដិវត្តន៍ មានសារៈសំខាន់ខ្លាំងដែលថា ការផ្ដន្ទាទោសមិនអាចត្រូវបានពិចារណាថាជា "សេចក្ដីសម្រេចមួយត្រឹមត្រូវតាមច្បាប់" នោះទេ[163]។ ហេតុដូច្នេះ

---

[158] ដូចខាងលើ កថាខណ្ឌ ១៥៤-១៥៥។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣៥។

[159] សំណុំរឿង ០០២ សេចក្ដីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣៥។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៥៤។

[160] សំណុំរឿង ០០២ សេចក្ដីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣៥។

[161] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្ដោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ២៤។ សូមមើលផងដែរ ក្រឹត្យច្បាប់លេខ ១៖ ស្ដីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញ ដើម្បីកាត់ទោសបន ប៉ុល ពត-អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឯកសារ E9/9.3 មាត្រា ១។

[162] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្ដោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ២៥។ ឯកសារតុលាការប្រជាជនបដិវត្តន៍ត្រូវបានទទួលយកធ្វើជាភស្តុតាងនៅពេលជំនុំជម្រះ ជាវត្ថុតាងលេខ E3/2144។

[163] ការវាយតម្លៃរបស់ការជំនុំជម្រះឆ្នាំ១៩៧៩ ជាដំបូងត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០២ និងអង្គបុរេជំនុំជម្រះ ក្នុងអំឡុងពេលស៊ើបអង្កេតប្រឆាំងនឹង អៀង សារី។ វាត្រូវបានបញ្ជាក់ឡើងវិញដោយអង្គបុរេជំនុំជម្រះ និងត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង នៅពេលធ្វើការសម្រេចលើអញ្ញត្រកម្ម ក្នុងអំឡុងពេលសវនាការលើផ្លូវការក្នុងសំណុំរឿង ០០២/០១។ សូមមើល សំណុំរឿង ០០២ សេចក្ដីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ

មិនមានការចោទប្រកាន់ ការផ្តន្ទាទោសជាក់ស្តែង ឬការកាត់ទោសណារបស់ អៀង សារី ដោយតុលាការប្រជាជនបដិវត្តន៍បានរារាំងយុត្តាធិការរបស់ អ.វ.ត.ក. លើរូបគាត់ឡើយ[164]។

អង្គបុរេជំនុំជម្រះបានវាយតម្លៃកិច្ចដំណើរការនីតិវិធី ដែលបានធ្វើឡើងដោយតុលាការប្រជាជនបដិវត្តន៍ជាលម្អិត និងបានសន្និដ្ឋានថា "មិនបានប្រព្រឹត្តទៅដោយឯករាជ្យ និងអនាគតិ ស្របតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋាននីតិវិធីនោះទេ"[165]។ អង្គបុរេផ្អែកការសន្និដ្ឋាននេះលើ៖ (១) មូលដ្ឋានគតិយុត្តដែលអាចចោទជាបញ្ហាសម្រាប់ការបង្កើតតុលាការប្រជាជនបដិវត្តន៍ (២) ភាពខ្វះចន្លោះការធានាដើម្បីធានាថាចៅក្រមមិនទទួលរងសម្ពាធ និងការជ្រៀតជ្រែកពីខាងក្រៅ (៣) ភាពអនាគតិរបស់សមាជិកតុលាការ (៤) ការការពារខ្លួន និងការការពារផ្នែកភស្តុតាងមិនសមស្រប និង (៥) លក្ខណៈសង្ខេបជារួមនៃកិច្ចដំណើរការនីតិវិធី និងកាលវិភាគការងាររបស់តុលាការ ដែល "គេអាចសន្និដ្ឋានថា ជនជាប់ចោទត្រូវបានគេពិចារណាថាមានពិរុទ្ធភាពជាមុនរួចទៅហើយ"[166]។

អង្គជំនុំជម្រះសាលាដំបូងបានអនុម័តយ៉ាងទូលំទូលាយនូវការសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងភាពខ្វះចន្លោះរបស់ការជំនុំជម្រះឆ្នាំ១៩៧៩ និងបានកំណត់ការសម្រេចរបស់ខ្លួនត្រឹមការវិភាគលើផលវិបាកនៃភាពខ្វះចន្លោះទាំងអស់នេះ ដោយសន្និដ្ឋានថា សេចក្តីសម្រេចដែលកើតចេញពី "ការជំនុំជម្រះ" នេះ មិនអាចត្រូវបានកំណត់ប្រភេទថាជាសេចក្តីសម្រេចត្រឹមត្រូវរបស់តុលាការនោះទេ[167]។

### ១.៣.២. ការលើកលែងទោស និងការអនុគ្រោះទោសយោងតាមព្រះរាជក្រឹត្យឆ្នាំ ១៩៩៦

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ បន្ទាប់ពី "ក្រុម 'កម្ពុជាប្រជាធិបតេយ្យ'" ត្រូវបានចោទថាខកខានក្នុងការគោរពតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលមានគោលបំណងនាំយកសន្តិភាព និងការផ្សះផ្សាជាតិមកកាន់ប្រទេស[168] រដ្ឋសភាជាតិនៃរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់[169]។ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ សម្តេច សីហនុ បានចេញព្រះរាជក្រឹត្យទៅកាន់ អៀង សារី ដែលមានពីរផ្នែក៖ (១) ការអនុគ្រោះទោសទាក់ទងនឹងកិច្ចដំណើរការនិតិវិធីរបស់តុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩ និង (២) ការលើកលែងទោសយោងតាមច្បាប់ឆ្នាំ១៩៩៤ ស្តីពីការដាក់

E51/15 កថាខណ្ឌ ២៣, ៣០។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៦១-១៧៥។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣២-១៣៣៣។

[164] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣១។សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៧៥។

[165] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៦៣-១៧៥។

[166] ដូចខាងលើ កថាខណ្ឌ ១៦៥-១៧៣។

[167] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ២៣, ៣០។

[168] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៩៦។

[169] ដូចខាងលើ កថាខណ្ឌ ១៨៤។ ច្បាប់ស្តីពីការដាក់ក្រុមខ្មែរក្រហមឱ្យនៅក្រៅច្បាប់ ព្រះរាជក្រមលេខ ០១.នស.៩៤ (១៩៩៤)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ២៦។

ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់[170]។ ជាលទ្ធផល អៀង សារី និងសមាជិកយុទ្ធជនមួយចំនួនធំត្រូវបានធ្វើសមាហរណកម្មទៅក្នុងរដ្ឋាភិបាល និងសង្គមកម្ពុជា[171]។

យោងតាមច្បាប់កម្ពុជា មានភាពខុសគ្នារវាងការអនុគ្រោះទោសដែលផ្តល់ដោយព្រះមហាក្សត្រ និងការលើកលែងទោសដែលអនុម័តដោយរដ្ឋសភាជាតិ៖ ការអនុគ្រោះទោសដែលផ្តល់ដោយព្រះមហាក្សត្រ យោងតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ធ្វើឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអាចអនុវត្តបាន ចំណែកផលវិបាកផ្សេងទៀតនៃការផ្តន្ទាទោសព្រហ្មទណ្ឌនៅមានបន្ត[172]។ ការលើកលែងទោសដែលផ្តល់ឱ្យដោយរដ្ឋសភាជាតិអនុលោមតាមមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញ បញ្ឈប់ការចោទប្រកាន់ និងបង្កើតអភ័យឯកសិទ្ធិ*តាមព្រឹត្តន័យ* សម្រាប់បទល្មើសទាំងឡាយដែលបានប្រព្រឹត្តមុនការលើកលែងទោសចូលជាធរមាន[173]
។

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការវាយតម្លៃថាតើព្រះមហាក្សត្រមានអំណាចតាមរដ្ឋធម្មនុញ្ញ ក្នុងការផ្តល់ការលើកលែងទោសតាមរយៈព្រះរាជក្រឹត្យដែរ ឬយ៉ាងណានោះគឺ "ជាបុព្វសិទ្ធិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ"[174]។

### ១.៣.២.១. ការអនុគ្រោះទោសចំពោះ "ការផ្តន្ទាទោស" ដោយតុលាការប្រជាជនបដិវត្តន៍

នៅក្នុងដីកាដំណោះស្រាយបញ្ជូន អៀង សារី ទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា អានុភាពនៃការអនុគ្រោះទោសត្រូវបានកម្រិតត្រឹមតែការមោឃភាពការកាត់ទោស ដែលបានប្រកាសក្រោយ "ការផ្តន្ទាទោស" ក្នុងឆ្នាំ១៩៧៩ "ដោយមិនបានលើកឡើងនូវបញ្ហាណាមួយទាក់ទងនឹងសាលក្រមផ្តន្ទាទោសផ្ទាល់នោះឡើយ"[175]។

អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ព្រះរាជក្រឹត្យឆ្នាំ១៩៩៦ មិនបានរារាំងយុត្តាធិការរបស់ អ.វ.ត.ក. ប្រឆាំងនឹង អៀង សារី ឡើយ ដោយហេតុថា ការជំនុំជម្រះឆ្នាំ១៩៧៩ "ពុំមានអានុភាពគតិយុត្ត" ។ ការអនុគ្រោះទោសចំពោះការកាត់ទោសដែលមិនមានសុពលភាពតាមច្បាប់ មិនមានអានុភាពទេ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ភាពខ្វះចន្លោះដែលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីតុលាការប្រជាជនបដិវត្តន៍ ប្រឆាំងនឹង អៀង សារី មានសារៈសំខាន់ខ្លាំង ដែលសេចក្តីសម្រេចចេញពីការជំនុំជម្រះនេះមិនអាចកំណត់ប្រភេទថាជា "សេចក្តីសម្រេចតុលាការដែលត្រឹមត្រូវ អាចអនុវត្តបាន និងស្ថាពរ"ឡើយ ដូច្នេះមិនអាចស្ថិតក្រោមការអនុគ្រោះទោសនោះទេ[176]។

### ១.៣.២.២. វិសាលភាពនៃការលើកលែងទោស

---

[170] ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ២៧, ៥៥។ ដោយសារតែមានការបកប្រែក្រៅផ្លូវការខុសគ្នាចំពោះព្រះរាជក្រឹត្យដែលមានស្រាប់នេះ ការបកប្រែថ្មីត្រូវបានធ្វើឡើងដោយអង្គភាពបកប្រែភាសារបស់ អ.វ.ត.ក. ត្រូវបានបង្ហាញជូនតាមសំណើរបស់អង្គជំនុំជម្រះ។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ១១។

[171] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ២, ៥៤។

[172] ដូចខាងលើ កថាខណ្ឌ ២៥។

[173] ដូចខាងលើ ថាខណ្ឌ ២៦។

[174] ដូចខាងលើ កថាខណ្ឌ ២៩។

[175] សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៩-១៣៣១ (បញ្ជាក់ឡើងវិញលើការវាយតម្លៃដែលបានធ្វើឡើងក្នុងសំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C22 កថាខណ្ឌ ១២)។

[176] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ៣០។

មានការបកស្រាយ និងភាពមិនច្បាស់លាស់ជាច្រើននៅក្នុងព្រះរាជក្រឹត្យឆ្នាំ១៩៩៦ រួមបញ្ចូលទាំងបញ្ហាចោទថាតើ ការលើកលែងទោសយោងតាមច្បាប់ឆ្នាំ១៩៩៤ គ្របដណ្តប់លើបទចោទណាមួយ ឬបទចោទទាំងអស់ នៅក្នុងដីកាដំណោះស្រាយដែរ ឬយ៉ាងណា។ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ផ្នែកទីពីរនៃព្រះរាជក្រឹត្យឆ្នាំ១៩៩៦ នេះ មិនបានរារាំងការចោទប្រកាន់របស់ អ.វ.ត.ក. លើ អៀង សារី ឡើយ បើទោះជាមានសំអាងហេតុខុសគ្នាទាក់ទងនឹងវិសាលភាព និងសុពលភាពនៃការលើកលែងទោសក៏ដោយ[177]។

អង្គបុរេជំនុំជម្រះបានសម្រេចថា ផ្នែកទីពីរនៃការលើកលែងទោសនេះ សំដៅទៅលើតែបទល្មើសដែលមានរៀបរាប់ក្នុងច្បាប់ឆ្នាំ១៩៩៤ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ[178]។ អង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុថា ច្បាប់នេះបានបង្កើតបទល្មើសថ្មីៗ និងការផ្តន្ទាទោសនានា ដែលត្រូវបានពិចារណាលើបរិបទជាក់ស្តែងនៅពេលនោះ ទោះជាយ៉ាងណាច្បាប់នេះមិនមានបំណងបង្កើតនូវរបបក្រមព្រហ្មទណ្ឌស្វយ័តមួយ ដើម្បីចោទប្រកាន់លើសមាជិកក្រុមកម្ពុជាប្រជាធិបតេយ្យ ចំពោះបទឧក្រិដ្ឋណាមួយដែលស្ថិតក្រោមក្រមព្រហ្មទណ្ឌដែលនៅជាធរមាននោះទេ[179]។ អង្គបុរេយល់ឃើញថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ខុសគ្នាពីឧក្រិដ្ឋកម្មដែលបានកំណត់ក្នុងច្បាប់ឆ្នាំ១៩៩៤ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ហេតុដូច្នេះ ការលើកលែងទោសមិនមានអានុភាពលើយុត្តាធិការឡើយ។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា ការពង្រីកវិសាលភាពនៃការលើកលែងទោសលើសពីវិសាលភាពតាមវាយ្យាករណ៍ នឹងមិនត្រឹមតែផ្ទុយទៅនឹងភាសានៃព្រះរាជក្រឹត្យប៉ុណ្ណោះទេ ថែមទាំងរំលោភលើកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាក្រោម ICCPR ក្នុងការផ្តន្ទាទោសអ្នករំលោភសិទ្ធិមនុស្ស ដោយពិចារណាថា "មិនមានចំណុចណាមួយដែលបង្ហាញ" ថាព្រះមហាក្សត្រ ឬបុគ្គលផ្សេងទៀត មានព្រះរាជបំណង/បំណង ធ្វើដូច្នេះឡើយ[180]។

ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនមិនអាចបដិសេធលទ្ធភាពដែលថា ព្រះរាជក្រឹត្យមានបំណង "លើកលែងទោស [អៀង សារី] ពីការអនុវត្តទោស និងការចោទប្រកាន់ពីបទល្មើសទាំងឡាយដែលបានប្រព្រឹត្តមុនឆ្នាំ១៩៩៦ និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់កោះហៅសាក្សីណាម្នាក់មកបញ្ជាក់បំភ្លឺអំពីគោលបំណងនៃព្រះរាជក្រឹត្យនេះឡើយ[181]។

### ១.៣.២.៣. សុពលភាពនៃការលើកលែងទោស

អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា កាតព្វកិច្ចរបស់កម្ពុជាទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍ ឬការធ្វើទារុណកម្ម បានរារាំង អ.វ.ត.ក. ក្នុងការ "ធ្វើការបកស្រាយព្រះរាជក្រឹត្យឆ្នាំ១៩៩៦ ថាជាការផ្តល់អភ័យឯកសិទ្ធិរួចពីការកាត់ទោសជនជាប់ចោទ"[182]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សន្ធិសញ្ញាមួយចំនួនដែលកម្ពុជាជាភាគីហត្ថលេខី ដូចជាអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ចំនួនបួន អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម បានដាក់កាតព្វកិច្ចដាច់ខាត ក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួន

---

[177] ដូចខាងលើ កថាខណ្ឌ ២៨ *និងកថាខណ្ឌបន្តបន្ទាប់*។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៩៥ *និងកថាខណ្ឌបន្តបន្ទាប់*។

[178] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៩៥ *និងកថាខណ្ឌបន្តបន្ទាប់*។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៦១។ គោលជំហរស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងដីកាដំណោះស្រាយ និងក្នុងកិច្ចដំណើរការនីតិវិធីលើការឃុំខ្លួន អៀង សារី បណ្តោះអាសន្ន។ សូមមើល សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣១។ សំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C22 កថាខណ្ឌ ១២។

[179] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៩៧។

[180] ដូចខាងលើ កថាខណ្ឌ ២០០-២០១។

[181] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មតាមវិធាន ៨៩ របស់ អៀង សារី (គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ២៩។

[182] ដូចខាងលើ កថាខណ្ឌ ៣៩។

និងថា “តុលាការអន្តរជាតិ និងស្ថាប័នសន្ធិសញ្ញា បានធ្វើការពិចារណាជាច្រើនដងអំពីការអនុគ្រោះទោសចំពោះចារីនៃអំពើការធ្វើទារុណកម្ម ដែលមានវិសមិតភាពទៅនឹងកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងក្នុងការចោទប្រកាន់អំពើទាំងអស់នោះ” ហើយដូច្នេះទុកជាមោឃៈ[183]។

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បើទោះជាច្បាប់អន្តរជាតិជាទូទៅមិនបានហាមឃាត់ការលើកលែងទោស ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតយ៉ាងណាក្តី ក៏តុលាការអន្តរជាតិមានសិទ្ធិជាប្រតិសកម្ម “ក្នុងការវាយតម្លៃទៅលើការអនុគ្រោះទោស និងទុកការលើកលែងទោសដោយឡែក ឬកំហិតវិសាលភាពនៃការអនុគ្រោះទោស ប្រសិនបើការអនុគ្រោះទោសនោះពុំស្របទៅនឹងនិយាមអន្តរជាតិ”[184]។ អង្គជំនុំជម្រះសាលាដំបូងបានសិក្សាអំពីសច្ចធារណ៍ធម្មានុរូប (*opinion juris*) និងការអនុវត្តរបស់រដ្ឋដើម្បីបញ្ជាក់ថាតើ និយាមទំនៀមទម្លាប់តម្រូវឱ្យមានការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិដែលនៅសល់ ឬហាមឃាត់ការអនុវត្តបែបប្រតិសកម្មចំពោះការអនុគ្រោះទោស ឬយ៉ាងណា ដោយសារមិនមានសន្ធិសញ្ញាអន្តរជាតិដែលចែងច្បាស់អំពីការហាមឃាត់ការអនុគ្រោះទោស[185]។ ដើមឡើយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា និយមន័យពីមុននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដោយមិនគិតអំពីច្បាប់ជាតិ ដូចដែលបានបញ្ជាក់ឡើងវិញនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដែលកម្ពុជាបានផ្តល់សច្ចាប័ន[186]។

អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា ស្ថាប័នសិទ្ធិមនុស្សតំបន់និងអន្តរជាតិបានលើកឡើងយ៉ាងស៊ីចង្វាក់ប្រឆាំងនឹងការលើកលែងទោសរបស់តុលាការជាតិ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ សំដៅទៅលើការរំលោភបំពានសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព[187]។ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង បានសម្រេចយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនអាចស្ថិតក្រោមការលើកលែងទោសនោះទេ ដូច្នេះច្បាប់ស្តីពីការលើកលែងទោសនៅក្នុងប្រទេសក្នុងទ្វីបអាមេរិកមួយចំនួនមានវិសមិតភាពជាមួយនឹងអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស[188]។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ការលើកលែងទោសមិនត្រូវអនុញ្ញាតចំពោះបទល្មើស ដូចជា ការធ្វើមនុស្សឃាត និងការធ្វើទារុណកម្ម ឡើយ និងថា តតិយប្រទេសមិនជាប់កាតព្វកិច្ចចំពោះបញ្ញត្តិស្តីពីការលើកលែងទោស ដែលរំលោភកាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើស*វិធានអាជ្ញាបញ្ញា*[189]។ ស្រដៀងគ្នានេះដែរ គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន បានប្រកាសថា ការលើកលែងទោសដែលធ្វើឱ្យចារីរួចផុតពីការទទួលខុសត្រូវលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ គឺជាការរំលោភសិទ្ធិរបស់ជនរងគ្រោះ និងកាតព្វកិច្ចរបស់រដ្ឋ ក្នុងការការពារអនុលោមតាមធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន[190]។

អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា យុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិ ដូចជា តុលាការ ICTY និង SCSL បញ្ជាក់កាតព្វកិច្ចរបស់រដ្ឋក្នុងការចោទប្រកាន់បទល្មើស*វិធានអាជ្ញាបញ្ញា* ដោយបដិសេធការលើកលែងទោសទាំងស្រុង[191]។ អង្គជំនុំជម្រះបានធ្វើការវិភាគបន្ថែមទៀតទៅលើ ការអនុម័ត វិសាលភាព និងការអនុវត្តការលើកលែងទោសនៅក្នុងប្រទេសមានជម្លោះ ឬប្រទេសក្រោយជម្លោះមួយចំនួន និងបានកំណត់និន្នាការអន្តរជាតិឆ្ពោះទៅការកំណត់វិសាលភាពនៃការលើកលែងទោស ដែលបានបង្ហាញតាមរយៈឧទាហរណ៍នានាពីប្រទេស សូរីណាម នីការ៉ាហ្គា កូឡុំប៊ី ហ្វីលីពីន សាធារណរដ្ឋប្រជាធិបតេយ្យកុង

---

[183] ដូចខាងលើ កថាខណ្ឌ ៣៨។
[184] ដូចខាងលើ កថាខណ្ឌ៤០, ៥៣។
[185] ដូចខាងលើ កថាខណ្ឌ ៤០។
[186] ដូចខាងលើ កថាខណ្ឌ ៤១។
[187] ដូចខាងលើ កថាខណ្ឌ ៤២។
[188] ដូចខាងលើ កថាខណ្ឌ ៤៣។
[189] ដូចខាងលើ កថាខណ្ឌ ៤៤។
[190] ដូចខាងលើ កថាខណ្ឌ ៤៥។
[191] ដូចខាងលើ កថាខណ្ឌ ៤៦-៤៧។

ហ្គោ ទុយនេស៊ី និង ប៉ូឡូញ ដែលបច្ចុប្បន្នការលើកលែងទោសមិនរាប់បញ្ចូលបទល្មើសអន្តរជាតិធ្ងន់ធ្ងរមួយចំនួន[192]។

ផ្អែកលើការវិភាគនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខណៈដែលការលើកលែងទោសទាំងអស់ពុំត្រូវបានចាត់ទុកជាមោឃៈ ជាវិធានការមួយនៅក្នុងដំណើរការផ្សះផ្សា ប្រសិនបើការលើកលែងទោសផ្តល់នូវការទទួលខុសត្រូវក្នុងកម្រិតណាមួយ និងឱកាសសម្រាប់ជនរងគ្រោះដើម្បីលាតត្រដាងការពិត ការលើកលែងទោសគប្បីត្រូវបានអនុវត្តទៅតាមករណីនីមួយៗ ដោយផ្អែកលើកត្តាមួយចំនួន ដូចជាដំណើរការដែលអនុវត្តការអនុវត្តការលើកលែងទោសនោះ ខ្លឹមសារ និងវិសាលភាពរបស់វា និងថាតើការលើកលែងទោសនោះមានចែងពីការទទួលខុសត្រូវក្នុងទម្រង់ផ្សេងណាមួយដែរឬទេ[193]។

នៅពេលវាយតម្លៃការលើកលែងទោសដែលផ្តល់ឱ្យ អៀង សារី យោងតាមបទដ្ឋានទាំងនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការលើកលែងទោសនេះអមទៅដោយទម្រង់នៃការទទួលខុសត្រូវ ឬដំណោះស្រាយណាមួយ សម្រាប់ជនរងគ្រោះ ហើយដូច្នេះ "មិនពិចារណាទៅលើការលើកលែងទោសនេះដែលខ្លួនយល់ថាផ្ទុយទៅនឹងដំណើរការវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[194]។

## ១.៣.២.៤. ការលើកលែងទោសចំពោះបទល្មើសក្រោមច្បាប់ជាតិ

អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា បញ្ហាចោទអំពីវិសាលភាពនៃការលើកលែងទោសទាក់ទងនឹងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពុំយកមកពិភាក្សាទេ ដោយសារអង្គជំនុំជម្រះមិនបានទទួលសំណុំរឿងដែលមានសុពលភាពពាក់ព័ន្ធនឹងបទល្មើសទាំងអស់នេះទេ[195]។ ពីមុនអង្គជំនុំជម្រះសាលាដំបូងធ្លាប់សម្រេចថា ដោយសារតែវិការៈនៅក្នុងដីកាដំណោះស្រាយ បទចោទដែលទាក់ទងទៅនឹងបទល្មើសនានាក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចបង្កើតបានជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក. បានទេ[196]។

---

[192] ដូចខាងលើ កថាខណ្ឌ ៤៩-៥១។
[193] ដូចខាងលើ កថាខណ្ឌ ៥២។
[194] ដូចខាងលើ កថាខណ្ឌ ៥៤។
[195] ដូចខាងលើ កថាខណ្ឌ ៣៧។
[196] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E122 កថាខណ្ឌ ២៣។

# ២. ឧក្រិដ្ឋកម្ម

## ២.១. ឧក្រិដ្ឋកម្មស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក.

យុត្តាធិការលើរឿងក្ដីរបស់ អ.វ.ត.ក. មានចែងនៅក្នុងមាត្រា ១, ២ និង ៩ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ១ ដល់ ៨ នៃច្បាប់ អ.វ.ត.ក.[197]។ ឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រាទាំងអស់នេះគឺ៖

i. មនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦
ii. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
iii. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[198]
iv. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ
v. ការបំផ្លិចបំផ្លាញទៅលើទ្រព្យសម្បត្តិវប្បធម៌ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងឡាអេ ស្ដីពីការការពារសម្បត្តិវប្បធម៌ក្នុងព្រឹត្តិការណ៍ជម្លោះប្រដាប់អាវុធ និង
vi. ឧក្រិដ្ឋកម្មប្រឆាំងបុគ្គលដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុសញ្ញាទីក្រុងវីយែន ស្ដីពីទំនាក់ទំនងការទូត។

ប្រភេទចុងក្រោយពីរនៃឧក្រិដ្ឋកម្មនេះ មិនត្រូវបានដោះស្រាយនៅចំពោះមុខ អ.វ.ត.ក. ទេ។

## ២.២. ឧក្រិដ្ឋកម្មដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

មាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. ចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ មករា ឆ្នាំ១៩៧៩៖
>
> - មនុស្សឃាត មាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និងមាត្រា ៥០៨
> - ទារុណកម្ម មាត្រា ៥០០
> - ការវាយប្រហារលើសាសនា មាត្រា ២០៩ និងមាត្រា ២១០។
>
> អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ។
>
> ទោសបញ្ញត្តិចែងក្នុងមាត្រា ២០៩, ៥០០, ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ត្រូវកំណត់ជាអតិបរិមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា ៣៨ និងមាត្រា ៣៩ ថ្មី នៃច្បាប់នេះ។

### ២.២.១. យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ (សំណុំរឿង ០០១ និង ០០២)

[197] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១-២, ១០។ ច្បាប់ អ.វ.ត.ក. មាត្រា ១-៨។
[198] ទោះបីជាមាត្រា ២ នៃកិច្ចព្រមព្រៀង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា អ.វ.ត.ក. មានយុត្តាធិការលើរឿងក្ដីស្របជាមួយនឹងយុត្តាធិការលើរឿងក្ដីដែលមានចែងក្នុងច្បាប់ អ.វ.ត.ក. ក៏មាត្រា ៩ នៃច្បាប់ អ.វ.ត.ក. ចែងថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" គឺដូចបានកំណត់និយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

អង្គបុរេជំនុំជម្រះបានសន្និដ្ឋានយ៉ាងស៊ីចង្វាក់គ្នាថា បទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ អាចអនុវត្តបាននៅ អ.វ.ត.ក.[199]។

ក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានពិនិត្យមើលភាពខុសគ្នារវាងការធ្វើទារុណកម្ម និងការធ្វើមនុស្សឃាត ដែលមានចែងក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដោយបានធ្វើការប្រៀបធៀបធាតុផ្សំបង្កើតរបស់ឧក្រិដ្ឋកម្មនៅក្នុងរបបគតិយុត្តទាំងពីរ។ បន្ទាប់ពីធ្វើការវាយតម្លៃនិយមន័យនៃការធ្វើទារុណកម្មដែលមានចែងក្នុងសេចក្តីប្រកាស អ.ស.ប. ស្តីពីទារុណកម្ម អនុសញ្ញាប្រឆាំងទារុណកម្ម និងយុត្តិសាស្ត្ររបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") និងនិយមន័យនៃការធ្វើមនុស្សឃាតដែលមានចែងក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR") អង្គបុរេបានសន្និដ្ឋានថាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានធាតុផ្សំបង្កើត ដែលមិនមាននៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិ ដូច្នេះបទល្មើសស្ថិតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនត្រូវបានស្រូបបញ្ចូលដោយឧក្រិដ្ឋកម្មអន្តរជាតិទេ[200]។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិនិត្យលើបញ្ហាថាតើ៖ (១) ការអនុវត្តមាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. បានរំលោភលើគោលការណ៍អប្រតិសកម្មនៃច្បាប់ដែរ ឬយ៉ាងណា (២) ឧក្រិដ្ឋកម្មក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានរារាំងដោយសារពេលវេលាកន្លងផុត នៅពេលដែលអាជ្ញាយុកាលត្រូវបានពន្យារក្នុងឆ្នាំ២០០១ ដោយការអនុម័តច្បាប់ អ.វ.ត.ក. ដែរ ឬយ៉ាងណា និង (៣) ការអនុវត្តមាត្រា ៣ (ថ្មី) បានរំលោភលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការប្រព្រឹត្តិស្មើភាពគ្នានៅចំពោះមុខច្បាប់ដែរ ឬយ៉ាងណា[201]។

i. *ថាតើការអនុវត្តមាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. បានរំលោភលើគោលការណ៍អប្រតិសកម្មនៃច្បាប់ដែរ ឬយ៉ាងណា*។ អង្គបុរេជំនុំជម្រះបានសម្រេចថា ការពន្យារអាជ្ញាយុកាលក្នុងមាត្រា ៣(ថ្មី) មិនបង្កើតឱ្យមានបញ្ហាណាមួយទាក់ទងនឹងគោលការណ៍នីត្យានុកូលភាពនោះទេ ដោយពិចារណាលើការពន្យារអាជ្ញាយុកាលមុនពេលផុតកំណត់របស់វាថាជា "បញ្ហាគោលនយោបាយថ្នាក់ជាតិ"។ អង្គបុរេបានកត់សម្គាល់ថា មាត្រា ១៥(១) នៃ ICCPR មិនសំដៅដោយផ្ទាល់ចំពោះថិរវេលាកំណត់ ឬ "ពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃគោលការណ៍ នៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ជាអន្តរជាតិ ដែលទាក់ទិននឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬការលុបចោលអាជ្ញាយុកាលនោះទេ"។ អង្គបុរេក៏បានពិចារណាលើយុត្តិសាស្ត្រតុលាការសិទ្ធិមនុស្សអឺរ៉ុបផងដែរ ដែលសម្រេចថា *ការដំណើរការឡើងវិញ* នៃបណ្តឹងអាជ្ញាដែលបានក្លាយជាកម្មវត្ថុនៃអាជ្ញាយុកាលនោះអាចនឹងរំលោភដល់គោលការណ៍នីត្យានុកូលភាព ប៉ុន្តែយល់ឃើញថាការណ៍នេះមិនពាក់ព័ន្ធទៅនឹងការពន្យារថិរវេលាអាជ្ញាយុកាល *មុន*ពេលផុតកំណត់របស់វានោះទេ[202]។

ii. *ថាតើឧក្រិដ្ឋកម្មក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានរារាំងដោយពេលវេលាដែរ ឬយ៉ាងណា*។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ការពន្យារពេលអាជ្ញាយុកាល មិនបានរំលោភលើគោលការណ៍នីត្យានុកូលភាពទេ ដោយសារតែរយៈពេលអាជ្ញាយុកាល ១០ ឆ្នាំ ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលចាប់ផ្តើមដំណើរការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មិនបានផុតរយៈពេលកំណត់ក្នុងឆ្នាំ២០០១ នោះទេ[203]។ អង្គបុរេបានពិចារណាថា ចាប់ពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ១៩៨២ ប្រព័ន្ធតុលាការកម្ពុជាមិនមានដំណើរការទេ និងថាព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ "បញ្ហាប្រវត្តិសាស្ត្រ

[199] សំណុំរឿង០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ២៨៧, ២៩២។

[200] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦០-៧២, ៧៣-៨៤, ១០៧។

[201] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ២៧៨-២៩២។

[202] ដូចខាងលើ កថាខណ្ឌ ២៨២។

[203] ដូចខាងលើ កថាខណ្ឌ ២៨៦។

និងបរិការណ៍បានរារាំងយ៉ាងខ្លាំងដល់លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរ"[204]។ ជាពិសេស អង្គបុរេបានយោងទៅលើសង្គ្រាមស៊ីវិល ដែលបង្កឡើងដោយខ្មែរក្រហម ដែលកំពុងគ្រប់គ្រងទឹកដីកម្ពុជាមួយផ្នែក ហើយសហគមន៍អន្តរជាតិនៅចាត់ទុកក្រុមនេះ ជាតំណាងមួយរបស់ខ្លួន[205]។ អង្គបុរេបន្ថែមទៀតថា ជនជាប់ចោទមិនអាចទទួលបាន ផលប្រយោជន៍ពីការកន្លងផុតនៃចិរវេលាទេ "ដែលនៅពេលនោះគាត់ត្រូវបានចោទប្រកាន់ ថាទទួលខុសត្រូវមួយផ្នែក ចំពោះការមិនមានដំណើរការរបស់តុលាការក្នុងការស៊ើប អង្កេត និងជំនុំជម្រះ"។

iii. *ថាតើការអនុវត្តមាត្រា ៣(ថ្មី) បានរំលោភលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាន ការប្រព្រឹត្តិស្មើភាពគ្នាចំពោះមុខច្បាប់ដែរ ឬយ៉ាងណា៖* អង្គបុរេជំនុំជម្រះមិនយល់ឃើញ ថាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក. ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានរំលោភ លើសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការប្រព្រឹត្តិស្មើភាពគ្នាចំពោះមុខច្បាប់នោះទេ ដោយសារតែការពន្យារអាជ្ញាយុកាលរបស់មាត្រា ៣(ថ្មី) អនុវត្តតែនៅ អ.វ.ត.ក. ប៉ុណ្ណោះ ហើយមិនអនុវត្តចំពោះតុលាការជាតិទេ[206]។ ក្នុងការបដិសេធអំណះអំណាង ដែលថាការអនុវត្តមាត្រា ៣(ថ្មី) នេះ បង្កើតបានជាការប្រព្រឹត្តិមិនស្មើភាពគ្នា អង្គបុរេជំនុំ ជម្រះបានកត់សម្គាល់ថា គណៈកម្មាធិការសិទ្ធិមនុស្ស មិនយល់ឃើញថា តុលាការ "វិសាមញ្ញ" ឬ តុលាការ "ពិសេស" ដែលមានយុត្តាធិការមានកំណត់ ជាធម្មតា នឹង រំលោភមាត្រា ១៤(១) នៃ ICCPR[207]នោះឡើយ។ ផ្ទុយទៅវិញ គណៈកម្មាធិការសិទ្ធិ មនុស្សបានលើកឡើងថា "មូលដ្ឋានដែលមានភាពសត្យានុម័ត និងសមស្របត្រូវតែផ្តល់ ជូនដើម្បីពន្យល់អំពីភាពដាច់ដោយឡែកពីគ្នានេះ" នៅពេលដែលនីតិវិធីព្រហ្មទណ្ឌពិសេស ត្រូវបានអនុវត្តទៅលើការសម្រេចលើរឿងក្តីប្រភេទមួយចំនួន។ អង្គបុរេជំនុំជម្រះបាន សន្និដ្ឋានថា សេចក្តីសម្រេចកំណត់យុត្តាធិការរបស់ អ.វ.ត.ក. មិនត្រូវបានធ្វើឡើងដោយ បំពាននោះឡើយ និងថាវាមានភាពសមហេតុផលក្នុងការរៀបចំតុលាការដែលបានបង្កើត ឡើងយ៉ាងពិសេស ដើម្បីវិនិច្ឆ័យចារីជាន់ខ្ពស់ ចំពោះឧក្រិដ្ឋកម្មប្រភេទនេះ ដែលប្រព័ន្ធ តុលាការធម្មតាមិនមានសមត្ថភាព និងដោយពិចារណាលើធនធានដ៏មានកម្រិតផងដែរ[208] ។

## ២.២.២. យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង (សំណុំរឿង ០០១ និង ០០២)

ផ្ទុយទៅនឹងអង្គបុរេជំនុំជម្រះ ដោយសារតែអសមត្ថភាពរបស់ខ្លួនក្នុងការទទួលបានសំឡេងគាំទ្រ ភាគច្រើនលើសលប់ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អង្គជំនុំជម្រះ សាលាដំបូងបានសន្និដ្ឋានថា ការចោទប្រកាន់ជនជាប់ចោទចំពោះបទល្មើសក្រោមច្បាប់ជាតិ ត្រូវបានរារាំង ក្នុងសំណុំរឿង ០០១[209]។

បើទោះជាអង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាឯកច្ឆន្ទថា មិនមានប្រព័ន្ធច្បាប់ ឬប្រព័ន្ធ តុលាការក្នុងប្រទេសកម្ពុជា និងថាពុំមានការស៊ើបអង្កេតនិងការចោទប្រកាន់ព្រហ្មទណ្ឌអាចធ្វើទៅបាន ចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ យ៉ាងណាក្តី ក៏អង្គជំនុំជម្រះមិនអាចឯកភាពគ្នាលើបញ្ហាចោទថាតើ ចិរវេលាអាជ្ញាយុកាលដែលអាចអនុវត្តបាន ត្រូវបានកាត់ផ្តាច់ ឬឡើងចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៩៣ ឬយ៉ាង

---

204 ដូចខាងលើ (ដកស្រង់ សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទ ល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 យោបល់របស់ចៅក្រម និល ណុន, យ៉ា សុខន និង ធូ មុន្នី កថាខណ្ឌ ១៩-២០)។

205 ដូចខាងលើ កថាខណ្ឌ ២៨៦។

206 ដូចខាងលើ កថាខណ្ឌ ២៨៨-២៨៩។

207 ដូចខាងលើ កថាខណ្ឌ២៩០។

208 ដូចខាងលើ កថាខណ្ឌ ២៩១។

209 សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើង ដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ១៤, ៥៦។

ណា ហើយដូច្នេះថាតើថិរវេលានេះត្រូវបានផុតរលត់មុនពេលដែលមាត្រា ៣ និង មាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. ត្រូវបានប្រកាសឱ្យប្រើដែរ ឬយ៉ាងណា[210]។

i. *មតិយោបល់របស់ចៅក្រមជាតិ៖* ចៅក្រមជាតិបានពិចារណាថា ថិរវេលាអាជ្ញាយុកាលបានចាប់ផ្តើមរាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ នៅពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង[211]។ ពួកគាត់ផ្តល់សំអាងហេតុថា "បញ្ហាប្រវត្តិសាស្ត្រ និងបរិការណ៍បានរារាំងយ៉ាងខ្លាំងដល់លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរ" ពោលគឺ៖ (១) សង្គ្រាមស៊ីវិលដែលកំពុងកើតមាន ដែលក្នុងអំឡុងពេលនោះ ពួកខ្មែរក្រហមបានគ្រប់គ្រងផ្នែកខ្លះនៃទឹកដីរបស់ប្រទេសកម្ពុជា (២) ការទទួលស្គាល់របស់សហគមន៍អន្តរជាតិចំពោះរបបខ្មែរក្រហម និងសម្ព័ន្ធមិត្តកម្ពុជារបស់ពួកគេ ថាជារដ្ឋាភិបាលកម្ពុជា (៣) ភាពទន់ខ្សោយ និងកង្វះឯករាជភាពនៃប្រព័ន្ធតុលាការកម្ពុជា (៤) ការពិតដែលថាជនជាប់ចោទបន្តបម្រើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់គាត់បាត់ទំនាក់ទំនងជាមួយមេបញ្ជាការរបស់គាត់ក្នុងឆ្នាំ១៩៩៣[212]។ ចៅក្រមជាតិយល់ឃើញថាមិនមានភាពចាំបាច់ក្នុងការសម្រេចថាតើ អាជ្ញាយុកាលត្រូវបានកាត់ផ្តាច់ ឬព្យួរនោះទេ "ដោយហេតុថាអានុភាពគតិយុត្តិនៃជម្រើសទាំងពីរនេះនាំឱ្យមានលទ្ធភាពដូចគ្នា៖ ថិរវេលានៃអាជ្ញាយុកាល បានចាប់ផ្តើមរាប់ពីឆ្នាំ១៩៩៣"[213]។

ii. *មតិយោបល់របស់ចៅក្រមអន្តរជាតិ៖* ចៅក្រមអន្តរជាតិមិនអាចសន្និដ្ឋានថា ថិរវេលាអាជ្ញាយុកាលត្រូវបានព្យួរ ចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៩៣ នោះបានទេ[214]។ ពួកគាត់យល់ឃើញថា បើទោះជាភស្តុតាងបង្ហាញប្រព័ន្ធតុលាការទន់ខ្សោយខ្លាំង និងដំណើរការដោយមិនមានលក្ខណ:ពេញលេញ ផ្អែកតាមអង្គហេតុជាក់ស្តែង វាមិនបានបង្ហាញថា ការចោទប្រកាន់ ឬការស៊ើបអង្កេតណាមួយមិនអាចនឹងធ្វើទៅបាននៅក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ នោះទេ។ ពួកគាត់បានកត់សម្គាល់ថា ពីឆ្នាំ១៩៧៩ ឡើងមក ច្បាប់ និង ក្រឹត្យ-ច្បាប់នានា ត្រូវបានអនុម័តជាបន្តបន្ទាប់ ឧទាហរណ៍ ស្តីពីការរៀបចំតុលាការ ការបង្កើតតុលាការកំពូល និងច្បាប់ព្រហ្មទណ្ឌពាក់ព័ន្ធ[215]។ ទោះបីជាកត់សម្គាល់ថាសង្គ្រាមស៊ីវិលនិងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្មែរក្រហមទៅលើតំបន់មួយចំនួនក្នុងប្រទេសបង្ហាញនូវឧបសគ្គយ៉ាងពិតប្រាកដនៅក្នុងការផ្តួចផ្តើមការចោទប្រកាន់ ឬការស៊ើបអង្កេតយ៉ាងណាក៏ដោយ ក៏ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ការចោទប្រកាន់ និងការស៊ើបសួរមិនអាចបង្អាក់*គ្រប់*កន្លែងនៅក្នុងប្រទេសនោះទេ ដោយកត់សម្គាល់ថាសម្ភារៈឯកសារជាច្រើនដែលត្រូវបានរកឃើញនៅមន្ទីរ ស២១ ត្រូវបានប្រមូល និងរក្សាទុកនៅមន្ទីរ ស២១ និងក្រោយមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដូច្នេះសម្ភារៈឯកសារទាំងនេះអាចយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេត និងជំនុំជម្រះក្នុងអំឡុងពេលនោះ[216]។ ចុងក្រោយ ចៅក្រមអន្តរជាតិយល់ឃើញថា ទោះបីជាការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជាចំណុចរបត់ដ៏សំខាន់សម្រាប់កម្ពុជាក៏ដោយ ក៏វាមិនបានស្តារសមត្ថភាពប្រកបដោយសត្យានុម័ត ក្នុងការស៊ើបសួរ ឬចោទប្រកាន់នោះទេ ឬបានលុបបំបាត់នូវភាពទន់ខ្សោយដែលភាគច្រើនបញ្ហាទាំងនោះ បន្តមានហួសឆ្នាំ១៩៩៣ ទៅទៀត[217]។

អនុវត្តមានសំឡេងភាគច្រើនលើសលប់ បានរារាំងការបន្តការចោទប្រកាន់ជនជាប់ចោទក្នុងសំណុំរឿង ០០១ ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ពោលគឺ មនុស្សឃាត និង

---

[210] ដូចខាងលើ កថាខណ្ឌ ១៤។
[211] ដូចខាងលើ យោបល់របស់ចៅក្រម និល ណុន, យ៉ា សុខន និង ធូ មុន្នី កថាខណ្ឌ ២៥។
[212] ដូចខាងលើ យោបល់របស់ចៅក្រម និល ណុន, យ៉ា សុខន និង ធូ មុន្នី កថាខណ្ឌ ២០។
[213] ដូចខាងលើ យោបល់របស់ចៅក្រម និល ណុន, យ៉ា សុខន និង ធូ មុន្នី កថាខណ្ឌ ២៥។
[214] ដូចខាងលើ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne កថាខណ្ឌ ២៧។
[215] ដូចខាងលើ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne កថាខណ្ឌ ៣២។
[216] ដូចខាងលើ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne កថាខណ្ឌ ៣៣។
[217] ដូចខាងលើ កថាខណ្ឌ ៣៤។

ទារុណកម្ម) ខណៈដែលការចោទប្រកាន់ប្រឆាំងរូបគាត់ចំពោះអំពើដូចគ្នា ដែលជាឧក្រិដ្ឋកម្មអន្តរជាតិបានបន្ត (ក្នុងរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)[218]។

ផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០២ ទុកបញ្ហានេះឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច ថាតើត្រូវចាត់វិធានការនីតិវិធីណា ទាក់ទងនឹងបទល្មើសក្រោមច្បាប់ជាតិ បន្ទាប់ពីពួកគាត់ជាប់គាំងក្នុងការសម្រេចថាតើ បទឧក្រិដ្ឋដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អាចត្រូវបានអនុវត្តដែរ ឬយ៉ាងណា[219]។ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ជាតិនៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា[220]។

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ផ្នែកមួយចំនួននៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងបទល្មើសក្រោមច្បាប់ជាតិ "មិនមានរៀបរាប់ពីអង្គហេតុពាក់ព័ន្ធសំខាន់ៗ ដែលនាំទៅដល់ការចោទប្រកាន់ទាំងអស់នោះឡើយ ហើយក៏មិនបានបង្ហាញប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងអស់នោះទៀតផង"[221]។ ដោយយល់ឃើញថា ទាំងដីកាដំណោះស្រាយ និងទាំងអង្គបុរេជំនុំជម្រះសុទ្ធតែមិនបានពន្យល់ថាតើជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងអស់នេះ ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ឬក្នុងនាមជាថ្នាក់លើដោយរបៀបណានោះ ទើបអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា វិការៈទាំងអស់នេះធ្វើឱ្យអង្គជំនុំជម្រះមិនអាចធ្វើការកំណត់ខ្លឹមសារនៃការចោទប្រកាន់ទាំងអស់នេះ មូលដ្ឋានសំអាងហេតុរបស់ពួកវា និងមូលដ្ឋានគតិយុត្តនៃការកំណត់បទចោទរបស់វាបានឡើយ[222]។ ដោយសង្កេតឃើញថា ក្របខ័ណ្ឌ អ.វ.ត.ក. មិនបានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកែប្រែដីកាដំណោះស្រាយ ឬបញ្ជូនដីកាដំណោះស្រាយទៅឱ្យសហចៅក្រមស៊ើបអង្កេតវិញនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួន "គ្មានជម្រើសអ្វីក្រៅពីប្រកាសថា អង្គជំនុំជម្រះបានទទួលសំណុំរឿងដែលពុំមានសុពលភាព ពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានាដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដូចមានរៀបរាប់ក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២"[223]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយប្រកាសថា ខ្លួនបាន "ទទួលសំណុំរឿងដែលពុំមានសុពលភាពពាក់ព័ន្ធនឹងការចោទប្រកាន់លើបទល្មើសនានាតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦" ហើយសម្រេចថា "អង្គជំនុំជម្រះពុំមានមូលដ្ឋានក្នុងការជំនុំជម្រះជនជាប់ចោទពីបទឧក្រិដ្ឋតាមច្បាប់ជាតិ ហើយការជំនុំជម្រះលើបទឧក្រិដ្ឋទាំងអស់នេះពុំអាចប្រព្រឹត្តទៅបានឡើយ"[224]។

### ២.២.៣. យុត្តិសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត (សំណុំរឿង ០០៣ និង ០០៤)

ក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់ឡើងវិញអំពីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ លើធាតុផ្សំនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ ដោយពុំបានលើកឡើងច្បាស់ថាតើ បទឧក្រិដ្ឋទាំងអស់នេះអាចត្រូវបានអនុវត្តចំពោះ អ៊ឹម ចែម ដែរ ឬយ៉ាងណា។ យ៉ាងណាមិញ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងរឿងក្តីរបស់ អ៊ឹម ចែម ដោយបានបដិសេធរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងគាត់[225]។

---

218 ដូចខាងលើ កថាខណ្ឌ ៥៦។
219 សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧៤។
220 ដូចខាងលើ កថាខណ្ឌ ១៥៧៦។
221 សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E122 កថាខណ្ឌ ១៥។
222 ដូចខាងលើ កថាខណ្ឌ ២១-២២។
223 ដូចខាងលើ កថាខណ្ឌ ២២។
224 ដូចខាងលើ ផ្នែកសម្រេចសេចក្តី។
225 សូមមើល សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់។

ក្នុងសំណុំរឿង ០០៤/០២, ០០៣, និង ០០៤ សហចៅក្រមស៊ើបអង្កេតជាតិ មិនបានវិភាគភាពអាចអនុវត្តបាននៃបទឧក្រិដ្ឋតាមច្បាប់ជាតិ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួនទេ[226]។ ផ្ទុយទៅវិញ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/០២, ០០៣, និង ០០៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថា "បញ្ហាអាជ្ញាយុកាលត្រូវបាន[អង្គបុរេជំនុំជម្រះ]ដោះស្រាយយ៉ាងច្បាស់ និងដោយឯកច្ឆន្ទរួចហើយ ហេតុនេះ ច្បាស់លាស់ណាស់គឺថា ឧក្រិដ្ឋកម្មជាតិ" ដែល អោ អាន, មាស មុត និង យឹម ទិត្យ ត្រូវបានចោទប្រកាន់ "មិនមានផុតរលត់អាជ្ញាយុកាលទេ"[227]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ អោ អាន, មាស មុត និង យឹម ទិត្យ ចំពោះបទមនុស្សឃាតគិតទុកជាមុន យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[228]។ យ៉ាងណាមិញ ដោយសារតែមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់សំណុំរឿង ០០៤/០២, ០០៣ និង ០០៤[229]។

ជាលទ្ធផលនៃការខ្វែងយោបល់គ្នារបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីកង្វះភាពច្បាស់លាស់ នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ និងការបញ្ចប់សំណុំរឿង ០០៤/០២, ០០៣ និង ០០៤ របស់អង្គជំនុំជម្រះតុលាការកំពូល ដូច្នេះមិនមានបទឧក្រិដ្ឋដែលចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានអនុវត្តដោយ អ.វ.ត.ក. នោះទេ[230]។

## ២.២.៤. ធាតុផ្សំនៃបទឧក្រិដ្ឋដែលចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

### ២.២.៤.១. មនុស្សឃាត

មាត្រា ៥០១ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖

ជនណាធ្វើឱ្យគេស្លាប់, ជននោះ មានពិរុទ្ធក្នុងបទមនុស្សឃាត។ បើស្លាប់នោះ បណ្តាលមកពីអំពើឥតចេតនាទេ, អំពើនោះឈ្មោះថា មនុស្សឃាត ដោយអចេតនា។ បើស្លាប់បណ្តាលមកពីអំពើប្រកបដោយចេតនា ចង់សម្លាប់គេ, អំពើនោះឈ្មោះថា មនុស្សឃាដោយចេតនា។[231]"

---

226 សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់។

227 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩១។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៩។

228 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ផ្នែកសម្រេចសេចក្តី (បទចោទទី៣)។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ផ្នែកសម្រេចសេចក្តី (បទចោទទី៤)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ផ្នែកសម្រេចសេចក្តី (បទចោទទី៤)។

229 សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៧១ ផ្នែកសម្រេចសេចក្តី។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1 កថាខណ្ឌ ៤៤។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ 2/1/1/1 កថាខណ្ឌ ៣២។

230 សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៣.៣.១.១.១។

231 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ៥០១។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៤។

យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មនុស្សឃាតមានពីរប្រភេទគឺ៖ (១) មនុស្សឃាតគ្មានមរណចេតនា និង (២) មនុស្សឃាតគិតទុកជាមុន[232]។

***មនុស្សឃាតគ្មានមរណចេតនា៖*** មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖

> កាលបើមនុស្សឃាដ បណ្តាលមកពីអំពើដែលប្រព្រឹត្តដោយចេតនា ត្រឹមចង់តែឱ្យឈឺរូបកាយបុគ្គលណាម្នាក់ប៉ុណ្ណោះទេ មិនចង់ឱ្យបុគ្គលនោះស្លាប់ទេ, ប៉ុន្តែអំពើនោះបណ្តាលឱ្យស្លាប់បុគ្គលនោះវិញ, មនុស្សឃាដនេះត្រូវចាត់ទុកជាបទមនុស្សឃាដគ្មានមរណចេតនាទេ។ អ្នកមានពិរុទ្ធ ក្នុងបទនេះ ត្រូវមានទោសឧក្រិដ្ឋ ថ្នាក់ទីមួយ[233]។

i. ***ធាតុផ្សំសត្យានុម័ត៖*** ចារីត្រូវជាអ្នកដែលបណ្តាលឱ្យបុគ្គលម្នាក់ទៀតស្លាប់[234]។
ii. ***ធាតុផ្សំអត្តនោម័ត៖*** ចារីត្រូវតែបានធ្វើសកម្មភាព "ក្នុងគោលបំណងបង្កគ្រោះថ្នាក់ដល់បុគ្គលម្នាក់" ប៉ុន្តែពុំមាន "ចេតនាបណ្តាលឱ្យស្លាប់នោះទេ"[235]។ ប្រសិនបើអំពើប្រព្រឹត្តិរបស់បុគ្គលម្នាក់ ដែលបានបណ្តាលឱ្យជនរងគ្រោះស្លាប់នោះ ត្រូវបានធ្វើឡើងដោយពុំមានចេតនាសម្លាប់ទេ ប៉ុន្តែមានចេតនាធ្វើឱ្យបុគ្គលម្នាក់នោះឈឺចាប់ គឺគ្រប់គ្រាន់ក្នុងការរកពិរុទ្ធភាពរបស់បុគ្គលម្នាក់ ចំពោះបទមនុស្សឃាដដោយអចេតនា អនុលោមតាមមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[236]។

***មនុស្សឃាតគិតទុកជាមុន៖*** មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖

> កាលណាបើមនុស្សឃាដ បណ្តាលមកពី ឬអាចបណ្តាលមកពីអំពើដោយចេតនា ឬពីបំណងដោយចេតនា ហើយចេតនានោះបានសម្រេចជាដាច់ខាតជាមុនផង, មនុស្សឃាដនេះ ឱ្យឈ្មោះថា ហនកម្ម ឬបំណងនៃហនកម្ម។ អ្នកមានពិរុទ្ធ ក្នុងបទនេះ ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី[237]។

i. ***ធាតុផ្សំសត្យានុម័ត៖*** ចារីត្រូវជាអ្នកដែលបណ្តាលឱ្យបុគ្គលម្នាក់ទៀតស្លាប់[238]។
ii. ***ធាតុផ្សំអត្តនោម័ត៖*** ចារីបានធ្វើសកម្មភាព "ដោយគិតទុកជាមុន" និង "មានចេតនាបណ្តាលឱ្យស្លាប់"[239]។ ការគិតទុកជាមុនត្រូវបានកំណត់និយមន័យថា "ការតាំងចិត្តជា

---

[232] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៤។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩០។

[233] ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ៥០៣។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៥។

[234] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៥(ក)។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦១(ក)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៤។

[235] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៥(ខ)(i)។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦១(ខ)(i)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៥។

[236] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៣។

[237] ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ៥០៦។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៦។

[238] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៥(ក)។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦១(ក)។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២(ក)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩០(ក)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៤។

[239] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៥(ខ)(ii)។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦១(ខ)(ii)។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២(ខ)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩០(ខ)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៦។

> ស្រេចថា នឹងប្រព្រឹត្តនូវអំពើណាមួយ មុនពេលដែលប្រព្រឹត្តនូវអំពើនោះគឺថា ពេលសម្រេចចិត្តនិងពេលដែលប្រព្រឹត្តមានចន្លោះឃ្លាតពីគ្នាល្មមឱ្យចារីរៀបចំដំណើរការនោះបាន[240]។

អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បទមនុស្សឃាតដែលមិនមានចេតនាសម្លាប់ ត្រូវបានស្រូបបញ្ចូលដោយឧក្រិដ្ឋកម្មអន្តរជាតិនៃការធ្វើមនុស្សឃាត ក្នុងរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែនិយមន័យក្នុងច្បាប់ជាតិនៃបទឧក្រិដ្ឋនេះ ទាមទារឱ្យមានធាតុផ្សំអត្តនោម័ត ដែលមានទម្រង់ចេតនាស្រាលជាងលក្ខខណ្ឌដែលតម្រូវនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ[241]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បទមនុស្សឃាតគិតទុកជាមុន មិនត្រូវបានស្រូបបញ្ចូលក្រោមឧក្រិដ្ឋកម្មអន្តរជាតិនៃការធ្វើមនុស្សឃាតនោះទេ ដោយហេតុថាបទមនុស្សឃាតគិតទុកជាមុនទាមទារធាតុផ្សំជាក់លាក់នៃការគិតទុកជាមុន ដែលធាតុផ្សំនេះមិនទាមទារនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ។ អង្គបុរេយល់ឃើញថា បទមនុស្សឃាតគិតទុកជាមុនទាមទារ “ចេតនាធ្វើឱ្យស្លាប់” ចំណែកចេតនា “ធ្វើឱ្យខូចខាតធ្ងន់ធ្ងរលើរូបរាងកាយ ឬបង្កព្យសនកម្មធ្ងន់ធ្ងរដោយដឹងច្បាស់ថា ការវាយប្រហារនោះនឹងនាំដល់ស្លាប់” គ្រប់គ្រាន់អនុលោមតាមច្បាប់អន្តរជាតិចំពោះបទល្មើសនៃការធ្វើមនុស្សឃាត[242]។ អង្គបុរេបានសន្និដ្ឋានថា ហេតុដូច្នេះខ្លួនមិនចាំបាច់បញ្ចូលបទមនុស្សឃាដដោយមិនមានចេតនាធ្វើឱ្យស្លាប់ ដូចមានចែងក្នុងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌនោះទេ[243]។

ក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំលឹកឡើងវិញនូវយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ថា បទមនុស្សឃាតគិតទុកជាមុន មិនត្រូវបានស្រូបបញ្ចូលក្នុងនិយមន័យអន្តរជាតិនៃបទមនុស្សឃាតនោះទេ ដោយសារវាទាមទារ *ធាតុផ្សំអត្តនោម័ត* ខ្ពស់ជាងនោះ ពោលគឺ ចេតនាសម្លាប់ ជាជាងចេតនាត្រឹមតែបង្កការខូចខាតធ្ងន់ធ្ងរលើរូបរាងកាយ[244]។ សហចៅក្រមស៊ើបអង្កេតជាតិមិនបានធ្វើការវិភាគធាតុផ្សំនៃឧក្រិដ្ឋកម្មជាតិ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់ទេ[245]។

### ២.២.៤.២. ការធ្វើទារុណកម្ម

មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖

> ជនណាធ្វើទារុណកម្មអ្នកដទៃ ដើម្បីឱ្យអ្នកនោះឈឺជាខ្លាំង ហើយផ្ដាយប្រាប់ព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬមជ្ឈមកម្មណាមួយក្ដី, ដើម្បីសងសឹក ឬដោយអំពើចិត្តព្រៃរបស់ខ្លួនក្ដី, ជននោះត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី៣[246]។

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបានប្រព្រឹត្ត “អំពើទារុណកម្មលើបុគ្គលម្នាក់ទៀត”[247]។ ទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនបានបញ្ជាក់ច្បាស់នូវអ្វីដែលបង្កើតបានជា

---

[240] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៥(ខ)(ii)។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦១(ខ)(ii)។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២(ខ)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩០(ខ)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៨។

[241] សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៣។

[242] ដូចខាងលើ  កថាខណ្ឌ ៨៤។

[243] ដូចខាងលើ  កថាខណ្ឌ ៨៣។

[244] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩១។

[245] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់។

[246] ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ៥០០។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦១។

[247] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៧(ក)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦១-៦២។

"ទារុណកម្ម"[248] ក៏អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០១ បានសន្និដ្ឋានថា មិនឃើញមានចំណុចបញ្ជាក់ថា *ធាតុផ្សំសត្យានុម័ត* ខុសពីបទឧក្រិដ្ឋអន្តរជាតិនៃការធ្វើទារុណកម្មនោះទេ[249]។

ii. ធាតុផ្សំអត្តនោម័ត៖ ចារីបានប្រព្រឹត្តអំពើបែបនេះ៖ (១) ក្នុងគោលបំណងទទួលបានព័ត៌មាន "មានប្រយោជន៍សម្រាប់ការប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិម" (២) "ដើម្បីសងសឹក" ឬ (៣) "ដោយសារអំពើព្រៃផ្សៃ"[250]។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានធ្វើការប្រៀបធៀបទម្រង់ធាតុផ្សំអត្តនោម័តដែលជាជម្រើសចំនួនបី យោងតាមមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទៅនឹងនិយមន័យអន្តរជាតិនៃបទទារុណកម្ម ដើម្បីកំណត់ថាតើ ទម្រង់ណាមួយត្រូវបានស្របបញ្ចូលដោយឧក្រិដ្ឋកម្មអន្តរជាតិ។ អង្គបុរេបានសន្និដ្ឋានថា មានធាតុផ្សំអត្តនោម័តចំនួនពីរ ដែលមិនបានបញ្ចូលនៅក្នុងនិយមន័យអន្តរជាតិ ពោលគឺគោលបំណងនៃ "ការធ្វើទារុណកម្ម ដើម្បីឱ្យឈឺជាខ្លាំងហើយ ផ្តាយប្រាប់ព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬមជ្ឈិមកម្មណាមួយក្តី" និង "ការធ្វើទារុណកម្មដោយអំពើចិត្តព្រៃ"[251]។ អង្គបុរេបានផ្តល់សំអាងហេតុថា៖

i. "ដើម្បីឱ្យអ្នកនោះឈឺជាខ្លាំង ហើយផ្តាយប្រាប់ព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬមជ្ឈិមកម្មណាមួយក្តី" គឺខុសពីនិយមន័យក្រោមច្បាប់អន្តរជាតិ [នៃការធ្វើទារុណកម្ម] ដោយសារតែ និយមន័យក្រោមច្បាប់ជាតិ មិនត្រឹមតែទាមទារឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងគោលបំណងយកព័ត៌មានប៉ុណ្ណោះទេ វាថែមទាំងទាមទារលក្ខខណ្ឌថា ព័ត៌មាននោះចាំបាច់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមជ្ឈិមកម្ម។ វានឹងមិនគ្រប់គ្រាន់ឡើយក្នុងការផ្តន្ទាទោសអនុលោមតាមមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដើម្បីបញ្ជាក់ថាជនជាប់ចោទ "បានធ្វើទារុណកម្ម ក្នុងគោលបំណងយកព័ត៌មាន ឬចម្លើយសារភាព ដោយសារធាតុផ្សំនេះគឺជាលក្ខខណ្ឌកំណត់នៅក្នុងនិយមន័យក្រោមច្បាប់អន្តរជាតិ"[252]។

ii. "[ការ]ធ្វើទារុណកម្មដើម្បីសងសឹក" គឺមានស្រដៀងគ្នាទៅនឹងគោលបំណងនៃ "ការដាក់ទណ្ឌកម្ម" នៅក្នុងនិយមន័យក្រោមច្បាប់អន្តរជាតិ។ នៅពេលដែលយកតែគោលបំណងជាកំលាក់មួយនេះមកពិចារណា ធាតុផ្សំនៃបទល្មើសក្រោមច្បាប់ជាតិ និងអន្តរជាតិ គឺដូចតែគ្នា[253]។

iii. "[ការ]ធ្វើទារុណកម្មដោយអំពើចិត្តព្រៃ" មិនមានលក្ខខណ្ឌស្មើគ្នាទៅនឹងនិយមន័យក្រោមច្បាប់អន្តរជាតិឡើយ ដោយធាតុផ្សំនេះហាក់ដូចជាមានលក្ខណៈទូលាយជាងធាតុផ្សំទាំងឡាយដែលមាននៅក្នុងនិយមន័យអន្តរជាតិ[254]។ ទោះបីជាអង្គបុរេជំនុំជម្រះមិនបានពិនិត្យជាក់លាក់លើអត្ថន័យនៃពាក្យ "ដោយអំពើចិត្តព្រៃ" ក៏អង្គបុរេបានសន្និដ្ឋានថា មិនមានភស្តុតាងគ្រប់គ្រាន់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០១ ដើម្បីបញ្ជាក់ថា ការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ត្រូវបានប្រព្រឹត្តឡើងដោយសារអំពើព្រៃផ្សៃនោះទេ[255]។

ក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតបានរំលឹកឡើងវិញអំពីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះថា ទម្រង់ទីពីរនៃ*ធាតុផ្សំអត្តនោម័ត* (ការសងសឹក) "ត្រូវបានស្របបញ្ចូលនៅក្នុងឧក្រិដ្ឋកម្ម

---

[248] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៨។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៨។

[249] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៨។

[250] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦២។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៧(ខ)។

[251] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧២។

[252] ដូចខាងលើ កថាខណ្ឌ ៦៩។

[253] ដូចខាងលើ កថាខណ្ឌ ៧០។

[254] ដូចខាងលើ កថាខណ្ឌ ៧១។

[255] ដូចខាងលើ កថាខណ្ឌ ៦០-៧២, ១០១។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥០។

នៃការធ្វើទារុណកម្មក្រោមច្បាប់អន្តរជាតិ ចំណែក ចំណុចទីមួយ (ការទទួលបានព័ត៌មានដែលមានប្រយោជន៍សម្រាប់ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ” និងចំណុចទីបី (អំពើព្រៃផ្សៃ) ពុំត្រូវបានស្របបញ្ចូលនោះទេ[256]។ ដូច្នេះពួកគេពុំចាត់ទុកបទឧក្រិដ្ឋនៃការធ្វើទារុណកម្ម ដែលមានចែងក្នុងមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ថា “ត្រូវបានស្របបញ្ចូលក្រោមបទទារុណកម្ម ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ឡើយ[257]។ បទល្មើសក្រោមច្បាប់ជាតិនៃការធ្វើទារុណកម្មមិនត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០៤/០២, ០០៣, ឬ ០០៤ នោះទេ ដូច្នេះមិនត្រូវបានវិភាគដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយរបស់ពួកគេនោះទេ[258]។

### ២.២.៤.៣. ការធ្វើទុក្ខបុកម្នេញលើសាសនា

មាត្រា ២០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖

> ការព្យាបាទដល់ជីវិតរបស់បព្វជិតក្នុងសាសនារបស់រដ្ឋ នៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬ នៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិតាមច្បាប់សាសនា ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី[259]។

ជាងនេះទៀត មាត្រា ១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖

> ការព្យាបាទដល់រូបកាយរបស់បព្វជិតក្នុងសាសនារបស់រដ្ឋ នៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬនៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិតាមច្បាប់សាសនា ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីពីរ[260]។

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវប្រព្រឹត្តការវាយប្រហារប្រឆាំងនឹងជីវិត ឬបុគ្គលនៃ “គ្រូប្រតិបត្តិសាសនាដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជាក្នុងពេលប្រតិបត្តិ ឬក្នុងបរិបទជុំវិញការបំពេញមុខងារសាសនារបស់គាត់”[261]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពុំចែងជាក់លាក់នូវ*ធាតុផ្សំអត្តនោម័ត*ចាំបាច់ក៏ដោយ ក៏គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាកំណត់ថា ចារីត្រូវមានចេតនាប្រព្រឹត្ត*ធាតុផ្សំសត្យានុម័ត*នោះ[262]។

ក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការធ្វើទុក្ខបុកម្នេញលើសាសនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ កំណត់ត្រឹមតែព្រះសង្ឃពុទ្ធសាសនាប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុថា ក្រមព្រហ្មទណ្ឌបានបញ្ជាក់ច្បាស់ថា “ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ” ហើយបានសង្កេតឃើញថា កំណត់សម្គាល់នៅក្រោមមាត្រា ២០៩ និង ២១០ ប្រាប់អ្នកអានឱ្យយោងទៅមាត្រា ៤៩៥ (ការវាយប្រហារលើបុគ្គល) និង មាត្រា ៥០១ (អំពើមនុស្សឃាត) ចំពោះការវាយប្រហារលើជីវិតបុគ្គលដែលពុំមែនជាអ្នកប្រតិបត្តិពុទ្ធសាសនានោះ[263]។ បទល្មើសក្រោមច្បាប់ជាតិនៃការធ្វើទុក្ខបុកម្នេញលើសាសនាមិនត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០៤/០២, ០០៣, ឬ ០០៤

---

256 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៩។
257 ដូចខាងលើ កថាខណ្ឌ ៤៩។
258 សូមមើលមើល សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤។ សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩-១១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤។
259 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ២០៩។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥២។
260 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា ២១០។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៤។
261 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥(ក)។
262 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥(ខ)។
263 ដូចខាងលើ កថាខណ្ឌ ៥៦។

នោះទេ ដូច្នេះមិនត្រូវបានវិភាគដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយរបស់ពួកគេនោះទេ[264]។

## ២.៣. អំពើប្រល័យពូជសាសន៍

មាត្រា ៤ នៃច្បាប់ អ.វ.ត.ក. កំណត់និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ថាជា "អំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា"៖

i. ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
ii. ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម
iii. ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
iv. ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្ដល់កំណើតទារក
v. ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

បន្ថែមលើការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មាត្រា ៤ ក៏ដាក់ទណ្ឌកម្មផងដែរចំពោះ "ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និង ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍"។ និយមន័យនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ក្នុងមាត្រា ៤ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីនិយមន័យដែលមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្ដីពីការបង្ការ និងផ្ដន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍ ("អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍") លើកលែងតែចំណុចខុសគ្នាមួយចំនួន (សូមមើលផ្នែក ២.៣.២.១.៤)។

### ២.៣.១. ភាពអាចអនុវត្តបាននៅ អ.វ.ត.ក.

សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះយល់ឃើញស្របគ្នាថា អំពើប្រល័យពូជសាសន៍ ត្រូវបានបង្ហាញថាជាបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥[265]។

អង្គបុរេជំនុំជម្រះបានបដិសេធអំណះអំណាងដែលថា កង្វះការអនុវត្តអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ នៅក្នុងច្បាប់ជាតិ មានន័យថា លក្ខណៈឧក្រិដ្ឋនៃអំពើប្រព្រឹត្តិមិនត្រូវបានជនត្រូវចោទដឹងមុនថាជាបទល្មើស និងមិនអាចដឹងជាមុនថាជាបទឧក្រិដ្ឋ។ អង្គបុរេជំនុំជម្រះយល់ឃើញថា អំណះអំណាងនេះ "ច្រានចោលការពិតដែលថា ទោះបីជាដើមបណ្ដឹងឧទ្ធរណ៍មិនអាចដឹងថា លក្ខណៈព្រហ្មទណ្ឌនៃអំពើដែលបានចោទប្រកាន់ មានចែងនៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួនក៏ដោយ សូម្បីនៅក្នុងឆ្នាំ១៩៧៥ ក៏ដើមបណ្ដឹងឧទ្ធរណ៍អាចដឹងអំពីករណីនេះ តាមរយៈស្មារតីនៃសន្ធិសញ្ញាទាំងឡាយ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា"[266]។ អង្គបុរេជំនុំជម្រះបានផ្ដល់សំអាងហេតុបន្ថែមទៀតថា ទោះបីជាពាក្យពេចន៍ច្បាស់លាស់នៃសន្ធិសញ្ញាទាំងអស់នេះអាចបង្ហាញថា ការហាមឃាត់នៅក្នុងអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ អនុវត្តចំពោះរដ្ឋ ជាជាងទៅលើបុគ្គលយ៉ាងណាក្ដី ក៏អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ ចែងយ៉ាងច្បាស់ថា "ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើណាមួយដទៃទៀត ដូចបានរៀបរាប់ក្នុងមាត្រា III ត្រូវទទួលទោស មិនថាជនទាំងនោះ តាមរដ្ឋធម្មនុញ្ញ ជាមេដឹកនាំដែលមានការទទួលខុស

---

[264] សូមមើល សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩-១១។ សំណុំរឿង០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤។

[265] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៨៨។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៩។

[266] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១០៨-១១០។

ត្រូវ មន្ត្រីសាធារណៈ ឬបុគ្គលឯកជនឡើយ”។ ច្បាប់ស្ដីពីសន្ធិសញ្ញា “បញ្ជាក់យ៉ាងច្បាស់ថា បុគ្គលម្នាក់ៗ អាចទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលប្រព្រឹត្តអំពើប្រល័យពូជសាសន៍”[267]។

អង្គជំនុំជម្រះតុលាការកំពូលក៏បានបដិសេធអំណះអំណាងថា ប្រព័ន្ធច្បាប់ទ្វិកនិយមរបស់កម្ពុជា បានរារាំងការអនុវត្តបទដ្ឋានអន្តរជាតិផ្ទាល់ទៅលើច្បាប់ក្នុងស្រុក អាស្រ័យហេតុនេះ ប្រជាជនកម្ពុជាក្នុងឆ្នាំ ១៩៧០ គ្រាន់តែអាចរំពឹងនូវការអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ប៉ុណ្ណោះ ដែលពុំបានរួមបញ្ចូលបទប្បញ្ញត្តិ សម្រាប់អំពើប្រល័យពូជសាសន៍ទេ[268]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុថា ការទទួល ស្គាល់ជាផ្លូវការរបស់កម្ពុជានូវអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ ១៩៥០ “បានធ្វើឱ្យមានការហាមឃាត់នូវអំពើប្រល័យពូជសាសន៍ដែលអាចអនុវត្តបាន និងចងកាតព្វកិច្ច លើកម្ពុជា”[269]។ អង្គជំនុំជម្រះក៏បានដកស្រង់សាលក្រមសំណុំរឿង ០០១ និងយុត្តិសាស្ត្រពីអង្គជំនុំជម្រះ ពិសេសនៃតុលាការកូសូវ៉ូ ស្ដីពីគោលការណ៍នីត្យានុកូលភាព ក្នុងការពិចារណាថា “‘ច្បាប់’ មានច្បាប់ ជាតិ ឬអន្តរជាតិ និងពន្លាតដល់ច្បាប់ជាលក្ខណ៍អក្សរ និងគ្មានជាលាយលក្ខណ៍អក្សរ”[270]។ ស្រដៀងគ្នានេះ ដែរ អង្គជំនុំជម្រះក៏ផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលថាច្បាប់ទំនៀមទម្លាប់ផ្ដល់នូវការ ណែនាំគ្រប់គ្រាន់ដល់បុគ្គលណាមួយ ចំពោះបទដ្ឋាននៃការរំលោភបំពាន ដែលអាចដាក់ឱ្យទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌ ជាពិសេសនៅពេលដែលបទឧក្រិដ្ឋដែលរងការចោទនោះមានលក្ខណៈគួរឱ្យរន្ធត់។ ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា បទឧក្រិដ្ឋប្រល័យពូជសាសន៍ និងធាតុផ្សំរបស់វាមានអត្ថិភាព ដែលជនជាប់ ចោទ អាចដឹងជាមុនបានគ្រប់គ្រាន់ថាមានច្បាប់ចែង និងជាបទល្មើស ក្នុងនាមជាសមាជិកនៃរដ្ឋអំណាច គ្រប់គ្រងកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥[271]។

អំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញថាជាបទឧក្រិដ្ឋមួយ ស្ថិតក្រោមច្បាប់ទំនៀមទម្លាប់អន្តរ ជាតិ ហើយជនជាប់ចោទអាចដឹងជាមុនថាមានច្បាប់ចែង និងជាបទល្មើស គិតត្រឹមឆ្នាំ១៩៧៥។ ក្នុងការ សន្និដ្ឋានថា “ក្របខ័ណ្ឌច្បាប់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ការផ្ដល់សច្ចាប័ន របស់កម្ពុជាលើអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៥០ ដោយមិនមានការដាក់លក្ខខណ្ឌ និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា”[272] អង្គជំនុំជម្រះ សាលាដំបូងបានពិចារណាថា៖

i. ក្នុងឆ្នាំ១៩៤៦ មហាសន្និបាត អ.ស.ប. បានអនុម័តជាឯកច្ឆន្ទនូវសេចក្ដីសម្រេចមួយ ដែលបញ្ជាក់ថា “អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ”[273]។
ii. ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ ក្នុងឆ្នាំ១៩៥០ ដោយមិនមានដាក់លក្ខខណ្ឌ ដែលបានចូលជាធរមានក្នុងឆ្នាំ១៩៥១ ហេតុដូច្នេះ បានទទួល ស្គាល់ថា “អំពើប្រល័យពូជសាសន៍មិនថាត្រូវបានប្រព្រឹត្តនៅក្នុងពេលមានសន្តិភាព ឬនៅ ក្នុងពេលសង្គ្រាមនោះទេ គឺជាឧក្រិដ្ឋកម្មនៅក្នុងច្បាប់អន្តរជាតិ”[274]។
iii. អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍តម្រូវឱ្យភាគីអត្តលេខា បង្កើតច្បាប់ដើម្បីអនុវត្ត បទប្បញ្ញត្តិទាំងឡាយនៃអនុញ្ញាឱ្យមានប្រសិទ្ធភាព និងដើម្បីផ្ដន្ទាទោសជនដែលបាន ប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ ជាលទ្ធផល មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ “ការអនុ វត្តរបស់រដ្ឋមួយចំនួនធំបានទទួលស្គាល់ថា អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មអន្តរ ជាតិ ដោយផ្អែកដូចគ្នាស្ទើរតែទាំងស្រុងលើនិយមន័យនៃអនុសញ្ញាស្ដីពីអំពើប្រល័យពូជ សាសន៍”[275]។

---

[267] ដូចខាងលើ កថាខណ្ឌ ១១១។
[268] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៨៨, ៩២-៩៣។
[269] ដូចខាងលើ កថាខណ្ឌ ៩៣។
[270] ដូចខាងលើ កថាខណ្ឌ ៩២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១។
[271] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៩២-៩៣។
[272] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៨៩។
[273] ដូចខាងលើ កថាខណ្ឌ ៧៨៥។
[274] ដូចខាងលើ កថាខណ្ឌ ៧៨៥។
[275] ដូចខាងលើ កថាខណ្ឌ ៧៨៦។

iv. ក្នុងឆ្នាំ១៩៥១ តុលាការយុត្តិធម៌អន្តរជាតិ ("ICJ") បានសម្រេចថា អ.ស.ប. មានគោលបំណងថ្កោលទោស និងដាក់ទណ្ឌកម្មអំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ "ដែលជាប់ពាក់ព័ន្ធនឹងការបដិសេធនូវអត្ថិភាពសិទ្ធិរបស់ក្រុមមនុស្សនានា"[276]។ ហេតុដូច្នេះ តុលាការ ICJ បានសម្រេចថា គោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ "ពិតណាស់មានវិសាលភាពគ្របដណ្តប់ជាសាកល" និងថាគោលការណ៍របស់វា "ត្រូវបានទទួលស្គាល់ដោយបណ្តាអរិយប្រទេសថា បានចងកាតព្វកិច្ចរបស់រដ្ឋ បើទោះបីជាមិនមានកាតព្វកិច្ចចងដោយអនុសញ្ញាក៏ដោយ"[277]។

v. ជាលទ្ធផល ក្នុងឆ្នាំ១៩៧០ តុលាការ ICJ បានបញ្ជាក់ថា "គ្រប់រដ្ឋមាន*កាតព្វកិច្ចក្នុងការប្រឆាំងនឹងអំពើប្រល័យពូជសាសន៍* (erga omnes) *ហើយកាតព្វកិច្ចនេះ "បានក្លាយទៅជាផ្នែកនៃច្បាប់អន្តរជាតិទូទៅ*""[278]។

vi. ក្នុងឆ្នាំ១៩៦៨ មហាសន្និបាត អ.ស.ប. បានអនុម័តអនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលទៅលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលចែងថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនមានអាជ្ញាយុកាលទេ "បើទោះបីជាអំពើទាំងនេះមិនមែនជាការរំលោភបំពាននៃច្បាប់នៅក្នុងប្រទេសដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តក៏ដោយ"[279]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ជនត្រូវចោទពីបទប្រល័យពូជសាសន៍ ដោយដកស្រង់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថា អំពើប្រល័យពូជសាសន៍គឺជា "ផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"[280]។

### ២.៣.២. ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍

មាត្រា ៤ នៃច្បាប់ អ.វ.ត.ក. ចែងអំពីធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ដែលត្រូវការខាងក្រោម៖

i. លក្ខខណ្ឌតម្រូវចេតនាប្រល័យពូជសាសន៍ (*ធាតុផ្សំអត្តនោម័ត*) ដែលមាន "គោលបំណង"៖
   - បំផ្លិចបំផ្លាញ
   - ទាំងស្រុង ឬមួយផ្នែក
   - ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាមួយ
   - "ដោយមានចេតនាបែបនោះ"[281] និង

ii. អំពើជាមូលដ្ឋាននៃអំពើប្រល័យពូជសាសន៍ (*ធាតុផ្សំសត្យានុម័ត*) រាប់បញ្ចូលយ៉ាងល្អិតល្អន់៖
   - ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
   - ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម
   - ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
   - ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក

---

[276] ដូចខាងលើ កថាខណ្ឌ ៧៨៧-៧៨៨។
[277] ដូចខាងលើ កថាខណ្ឌ ៧៨៨។
[278] ដូចខាងលើ។
[279] ដូចខាងលើ។
[280] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៩។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១០៨។
[281] ចំពោះការបកស្រាយធាតុផ្សំនេះ និងភាពខុសគ្នារវាងអត្ថបទជាភាសាអង់គ្លេស បារាំង និងខ្មែរ នៃមាត្រា ៤ នៃច្បាប់ អ.វ.ត.ក. សូមមល ផ្នែក ២.៣.២.១.៤។

- ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ នៅក្នុងសំណុំរឿង ០០២/០២[282]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តធាតុផ្សំដូចគ្នានេះនៅក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ ដោយគូសបញ្ជាក់ថា ផ្ទុយទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត មិនមានលក្ខខណ្ឌតម្រូវៈ (១) ថាអំពើដែលបានចោទនោះបានកើតឡើងក្នុងបរិបទដែលបង្ហាញឱ្យឃើញច្បាស់អំពីលំនាំអំពើស្រដៀងគ្នា (២) អំពើដែលបានចោទនោះបានបង្កើតបានជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ មកលើប្រជាជនស៊ីវិល ឬ (៣) ជាផែនការ ឬជាគោលនយោបាយរបស់រដ្ឋ[283]។

### ២.៣.២.១. ចេតនាប្រល័យពូជសាសន៍

ធាតុផ្សំអត្តនោម័តនៃអំពើប្រល័យពូជសាសន៍ គឺ “ចេតនាក្នុងការបំផ្លាញទាំងមូល ឬផ្នែកខ្លះនៃក្រុមសាសនា ពូជសាសន៍ ឬជាតិពន្ធនោះ”[284]។ អំពើប្រល័យពូជសាសន៍ “មិនត្រឹមតែតម្រូវឱ្យមានភស្តុតាងនៃចេតនាក្នុងការប្រព្រឹត្តអំពើមូលដ្ឋានប៉ុណ្ណោះទេ ថែមទាំងភស្តុតាងនៃចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមនោះទាំងមូល ឬផ្នែកខ្លះ”។ យុត្តិសាស្ត្រ អ.វ.ត.ក. បានសំដៅទៅលើលក្ខខណ្ឌតម្រូវ*ធាតុផ្សំអត្តនោម័ត*នេះថាជា “ចេតនាប្រល័យពូជសាសន៍” “ចេតនាពិសេស” “*dolus specialis*” ឬ ចេតនាជាក់លាក់[285]។

ដើម្បីធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងចេតនាប្រល័យពូជសាសន៍ជាក់លាក់ អង្គជំនុំជម្រះត្រូវពិចារណា “ថាតើភស្តុតាងទាំងអស់រួមគ្នាអាចបង្ហាញពីស្ថានភាពផ្លូវចិត្តនៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរឬទេ”។ ទោះបីជាមានការធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងចេតនាជាក់លាក់ក្តី វាត្រូវតែជាការសន្និដ្ឋានមួយដែលធ្វើឡើងដោយមានហេតុផលសមរម្យនឹងផ្អែកលើភស្តុតាង។ កត្តាពាក់ព័ន្ធនានារួមមាន បរិបទទូទៅ ការប្រព្រឹត្តិបទល្មើសផ្សេងៗដែលបានប្រព្រឹត្តឡើងជាប្រព័ន្ធសំដៅប្រឆាំងនឹងក្រុមតែមួយ  ទំហំនៃអំពើឃោរឃៅដែលបានប្រព្រឹត្ត ការកំណត់ជនរងគ្រោះធ្វើជាគោលដៅជាលក្ខណៈប្រព័ន្ធដោយសារសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមណាមួយ ឬការប្រព្រឹត្តិជាបន្តបន្ទាប់នូវសកម្មភាពបំផ្លិចបំផ្លាញនិងរើសអើង។ ជាងនេះទៀត អង្គជំនុំជម្រះក៏អាចពិចារណាលើសុន្ទរកថានានា ដែលបានធ្វើឡើងជាសាធារណៈឬនៅក្នុងកិច្ចប្រជុំ ដើម្បីគាំទ្រដល់ការយល់ឃើញពាក់ព័ន្ធនឹងចេតនាជាក់លាក់។ ទោះបីជាពុំមែនជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍យ៉ាងណាក៏ដោយ ក៏អត្ថិភាពនៃផែនការ ឬគោលនយោបាយនេះ អាចគាំទ្រដល់សេចក្តីសន្និដ្ឋានដែលថា ចារីមានចេតនាជាក់លាក់[286]។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា លក្ខខណ្ឌតម្រូវចេតនាជាក់លាក់មានសង្គតិភាពជាមួយនឹងនិយមន័យស្តីពីអំពើប្រល័យពូជសាសន៍ ដែលចែងថា ចារីត្រូវតែមានចេតនាបំផ្លាញក្រុមដែលត្រូវបានការពារ “បែបនោះ”[287]។ ក្នុងសំណុំរឿង ០០៤/០២, ០០៣, និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចស្រដៀងគ្នាថា ចារីត្រូវតែមានចេនាជាក់លាក់ដើម្បីបំផ្លិចបំផ្លាញ ទាំងស្រុង ឬមួយ

---

282 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩០-៨០៤។
283 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៦-៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៤-៧៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦-៧២។
284 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៧១០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩៧។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៨។
285 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦០៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩៧។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៨។
286 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៨០៣, ៣៣៤៤-៣៣៤៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦០។
287 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ១៦០៧។

ផ្នែក មកលើក្រុមដែលត្រូវបានការពារនោះ បន្ថែមលើការមាន*ធាតុផ្សំអត្តនោម័ត*ដែលត្រូវការ ទាក់ទងទៅនឹងអំពើពាក់ព័ន្ធជាមូលដ្ឋាន[288]។

ចារីផ្ទាល់មិនចាំបាច់មានចេតនាជាក់លាក់ នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដើម្បីគាំទ្រការដាក់ពិរុទ្ធភាពលើសមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួមនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុងរឿងក្ដី Karadžić បានបញ្ជាក់ថា ចំណុចសំខាន់ដែលគួរផ្ដោតនោះគឺទៅលើស្ថានភាពផ្លូវចិត្តរបស់*ជនជាប់ចោទ* និងសមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម និងបានសម្រេចថា មិនមែនចេតនារបស់ "ចារីផ្ទាល់នៃអំពើទាំងឡាយណាដែលអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់ គឺជាមូលដ្ឋានកំណត់នោះទេ"[289]។

### ២.៣.២.១.១. *"បំផ្លិចបំផ្លាញ"*

អំពើប្រល័យពូជសាសន៍មានវិសាលភាពកម្រិតត្រឹម អំពើដែលមានបំណងបង្កើតបានជាការបំផ្លិចបំផ្លាញផ្នែករូបរាងកាយ ឬជីវសាស្ត្ររបស់ក្រុមដែលត្រូវបានការពារ ទាំងស្រុង ឬមួយផ្នែក[290]។ ទោះបីជាអំពើជាមូលដ្ឋាននៃអំពើប្រល័យពូជសាសន៍មិនមែនធ្វើឡើង "សំដៅចំពោះការបំផ្លិចបំផ្លាញផ្នែករូបរាងកាយឬជីវសាស្ត្ររបស់សមាជិកក្រុមណាក្ដី" ប៉ុន្តែអំពើទាំងនោះត្រូវតែប្រព្រឹត្តឡើង "ដោយចេតនានៅក្នុងការសម្រេចឱ្យបាននូវការបំផ្លិចបំផ្លាញផ្នែករូបរាងកាយ ឬជីវសាស្ត្ររបស់ក្រុមណាមួយដោយផ្នែក ឬទាំងស្រុង"។ ហេតុដូច្នេះ អំពើដែលវាយប្រហារតែទៅលើលក្ខណៈវប្បធម៌ ឬសង្គមរបស់ក្រុមត្រូវការពារ ដើម្បីកុំឱ្យក្រុមនោះមានអត្តសញ្ញាណផ្ទាល់ខ្លួន (ឧទាហរណ៍ ការបំផ្លាញអគារសាសនា ឬផ្ទះរបស់សមាជិកក្រុមនោះ) មិនស្ថិតក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍ទេ។ "ប៉ុន្តែ អំពើបែបនេះអាចជាភ័ស្តុតាង ដែលអាចទាញសេចក្ដីសន្និដ្ឋានបញ្ជាក់ពីចេតនាបំផ្លិចបំផ្លាញផ្នែកជីវសាស្ត្រ និងរូបរាងកាយ"[291]។

ទាក់ទងនឹងយុត្តិសាស្ត្ររបស់តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ការបំផ្លិចបំផ្លាញផ្នែករូបរាងកាយឬជីវសាស្ត្ររបស់ក្រុមមួយ មិនចាំបាច់ត្រូវតែជាការស្លាប់របស់សមាជិកក្រុមនោះទេ" ហើយ "ការបំផ្លិចបំផ្លាញផ្នែករូបរាងកាយឬជីវសាស្ត្ររបស់ក្រុម គឺជាលទ្ធផលដែលអាចមាននៃការផ្លាស់ទីប្រជាជនដោយបង្ខំ ដែលការផ្លាស់ទីនោះត្រូវបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌមួយដែលធ្វើឱ្យក្រុមនោះមិនអាចមានឡើងវិញបាន" ជាពិសេសនៅពេលដែលវាពាក់ព័ន្ធទៅនឹងការបំបែកសមាជិករបស់ក្រុម។ អង្គជំនុំជម្រះបានផ្ដល់សំអាងហេតុថា "ការផ្លាស់ទីមនុស្សដោយបង្ខំអាចបណ្ដាលឱ្យមានការបំផ្លិចបំផ្លាញផ្នែកសម្ភាររបស់ក្រុម ព្រោះថាក្រុមនោះមិនមានអត្ថិភាពជាក្រុម ឬយ៉ាងហោចណាស់វាមិនមានអត្ថិភាពជាក្រុមដូចមុនទៀត"[292]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថា អំពើដែលផ្ដោតគោលដៅតែទៅលើលក្ខណៈវប្បធម៌ និងសង្គមរបស់ក្រុមត្រូវការពារ អាចត្រូវបានប្រើប្រាស់ដើម្បីទាញសេចក្ដីសន្និដ្ឋានបញ្ជាក់ពីចេតនាបំផ្លិចបំផ្លាញផ្នែកជីវសាស្ត្រ និងរូបរាងកាយរបស់ក្រុមនោះ[293]។

---

[288] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៨។

[289] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៨០៤។

[290] ដូចខាងលើ កថាខណ្ឌ ៨០០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។

[291] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៨០០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។

[292] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៨០១។

[293] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។

### ២.៣.២.១.២. *"ទាំងស្រុង ឬមួយផ្នែក"*

ឃ្លា "ទាំងស្រុង ឬមួយផ្នែក" សំដៅលើចេតនាបំផ្លិចបំផ្លាញ*ទាំងស្រុង ឬមួយផ្នែក*មកលើក្រុមត្រូវការពារ៖ ការបំផ្លិចបំផ្លាញក្រុមមួយផ្នែក មិនចាំបាច់ទាល់តែមានចេតនាបំផ្លិចបំផ្លាញក្រុមទាំងស្រុងទេ[294]។ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មិនកំណត់ចំនួនតួលេខពិតប្រាកដដែលត្រូវតែបំពេញនោះទេ[295]។ ក្នុងករណីដែលការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផ្អែកលើចេតនាក្នុងការបំផ្លិចបំផ្លាញ "មួយផ្នែក" នៃក្រុមត្រូវការពារ ផ្នែកដែលត្រូវបានបំផ្លិចបំផ្លាញនោះ ត្រូវតែជា "ផ្នែកសំខាន់មួយរបស់ក្រុមដែលត្រូវទទួលបានការការពារ ហើយផ្នែកដែលត្រូវបានកំណត់គោលដៅនោះ ត្រូវមានសារៈសំខាន់គ្រប់គ្រាន់ដើម្បីអាចមានឥទ្ធិពលទៅលើក្រុមនោះទាំងមូល"[296]។

ការបំផ្លិចបំផ្លាញក្រុមមួយពុំតម្រូវឱ្យបទល្មើសត្រូវតែមានលក្ខណៈដូចអំពើប្រល័យពូជសាសន៍នោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ក្នុងការវាយតម្លៃលើ*ធាតុផ្សំអត្តនោម័ត* សម្រាប់អំពើប្រល័យពូជសាសន៍ ឃ្លា "ទាំងស្រុង ឬមួយផ្នែក" សំដៅទៅលើចេតនារបស់ចារីក្នុងការបំផ្លាញក្រុមមួយជាជាងលទ្ធផលដែលទទួលបានជាក់ស្តែងនៃអំពើរបស់ពួកវា។ អង្គជំនុំជម្រះពុំជឿជាក់លើការអះអាងដែលថា ចំនួនសរុបជនជាតិវៀតណាមដែលត្រូវបានសម្លាប់ក្នុងប្រទេសកម្ពុជានោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា "ផ្នែកដ៏សំខាន់នៃក្រុមជនជាតិពន្ធុវៀតណាមត្រូវបានកំណត់គោលដៅ"។ ផ្ទុយទៅវិញ អង្គជំនុំជម្រះយល់ឃើញថា ជនរងគ្រោះក្នុងចំនួនដ៏ច្រើនអាចបង្ហាញចេតនាតម្រូវនោះ ទោះបីជាពុំមានលក្ខខណ្ឌតម្រូវស្តីពីចំនួនតួលេខពិតប្រាកដដែលត្រូវតែបំពេញក៏ដោយ[297]។

"មួយផ្នែក" មានន័យថា "ផ្នែកសំខាន់មួយរបស់ក្រុមដែលត្រូវទទួលបានការការពារ" ដែល "ត្រូវមានសារៈសំខាន់គ្រប់គ្រាន់ដែលអាចមានឥទ្ធិពលទៅលើក្រុមនោះទាំងមូល"[298]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅយុត្តិសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍ ដែល "ដោយសារមិនមានសេចក្តីណែនាំនៅក្នុងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ [...] បានបង្កើតនិយមន័យថា ចេតនាបំផ្លិចបំផ្លាញក្រុមមួយផ្នែក គឺជាចេតនាបំផ្លិចបំផ្លាញក្រុមយ៉ាងហោចណាស់មួយផ្នែក "ធំ" ល្មមអាចមានផលប៉ះពាល់មកលើក្រុមទាំងមូល ដោយគិតពីបរិបទដែលអំពើដែលបានចោទនោះបានប្រព្រឹត្តឡើយ"[299]។

### ២.៣.២.១.៣. *"ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាមួយ"*

អ.វ.ត.ក. មានយុត្តាធិការទាក់ទងនឹងអំពើប្រល័យពូជសាសន៍ដែលសំដៅប្រឆាំងនឹង ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាមួយ[300]។ មានតែក្រុមទាំងបួនដែលបានបញ្ជាក់យ៉ាងច្បាស់នេះទេ ដែលជាក្រុមត្រូវការពារ[301]។ ក្រុមត្រូវតែមានអត្តសញ្ញាណជាក់លាក់ខុសពីគេ និងត្រូវបានកំណត់ "ដោយមានចេ

---

[294] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦៣៦។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧០។

[295] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦៣៦។

[296] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៨០២។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧០។

[297] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦៣៦។

[298] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៨០២។

[299] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧០។

[300] ច្បាប់ អ.វ.ត.ក. មាត្រា ៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦១។

[301] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)

នាបែបនោះ” ដោយផ្អែកទៅលើលក្ខណៈវិជ្ជមានទូទៅរបស់ក្រុមនោះ[302]។ យ៉ាងណាមិញ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ មិនបានកំណត់និយមន័យជាក់លាក់នៃក្រុមដែលត្រូវទទួលបានការការពារទាំងបួននេះនោះទេ[303]។

នៅពេលដែលមិនមាននិយមន័យច្បាស់លាស់ និងត្រូវបានទទួលយកជាទូទៅ ការវាយតម្លៃទៅតាមករណីនីមួយៗថា តើក្រុមជាក់លាក់មួយត្រូវបានចាត់ទុកថាជាក្រុមដែលត្រូវទទួលបានការការពារដែរឬយ៉ាងណានោះ ចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើបរិបទជាក់លាក់នៃនយោបាយ សង្គម និងវប្បធម៌[304]។ ដោយផ្អែកលើយុត្តិសាស្ត្រសាលាក្តីមិនអចិន្ត្រៃយ៍ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធីសាស្ត្រនេះស្របជាមួយនឹងគោលដៅ និងគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទាក់ទងនឹង “ការបំផ្លិចបំផ្លាញពូជសាសន៍ កុលសម្ព័ន្ធ ជាតិ ឬក្រុមដទៃទៀត ដែលមានអត្តសញ្ញាណវិជ្ជមានជាក់លាក់” និង “ការបដិសេធអត្ថិភាពសិទ្ធិរបស់ក្រុមមនុស្សទាំងមូល”[305]។

ធាតុផ្សំអត្តនោម័តតែម្យ៉ាងមិនគ្រប់គ្រាន់នៅក្នុងការកំណត់និយមន័យក្រុមនោះទេ។ លក្ខណៈវិនិច្ឆ័យសត្យានុម័តក៏ត្រូវតែពិចារណាផងដែរ ដែលស្របតាមគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដើម្បីការពារក្រុមដែលស្ថិតស្ថេរនិងអចិន្ត្រៃយ៍។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ក្នុងការកំណត់ថា អ្វីទៅជាក្រុមដែលទទួលបានការការពារ តុលាការមិនអចិន្ត្រៃយ៍បានពិចារណាលើធាតុផ្សំអត្តនោម័តនានា រួមមាន វិធីដែលចារីធ្វើឱ្យសមាជិកនៃក្រុមនោះក្លាយទៅជាជនរងគ្រោះ ឬវិធីដែលជនរងគ្រោះយល់ឃើញចំពោះខ្លួនឯង[306]។ ទោះបីជាអង្គជំនុំជម្រះសម្រេចថា វិធីសាស្ត្រនេះស្របជាមួយនឹងគោលដៅ និងគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍យ៉ាងណាក្តី ក៏អង្គជំនុំជម្រះយល់ឃើញថា “ធាតុផ្សំអត្តនោម័តតែម្យ៉ាងមិនគ្រប់គ្រាន់នៅក្នុងការកំណត់សមាជិកភាពនៃក្រុមដែលត្រូវទទួលបានការការពារនោះឡើយ”[307]។

អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ជនជាតិវៀតណាមក្នុងប្រទេសកម្ពុជាគឺជា ក្រុមជាតិពន្ធ ក្រុមជាតិសាសន៍ និងក្រុមពូជសាសន៍ ផ្អែកលើអត្ថិភាពនៃភាសាវៀតណាម ម្ហូបអាហារ ការប្រតិបត្តិវប្បធម៌និងសម្លៀកបំពាក់ប្រពៃណី និងបេតិកភណ្ឌប្រវត្តិសាស្ត្រដោយឡែក។ ជាងនេះទៀត ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា “ត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់ខ្លួនឯងបែបនោះដោយសារតែសាច់ញាតិចាស់ៗមួយឬច្រើន ក្នុងគ្រួសាររបស់ពួកគេជាជនជាតិវៀតណាម”[308]។ អង្គជំនុំជម្រះក៏បានទទួលស្គាល់ជនជាតិចាមថាជាក្រុមសាសនា និងជាក្រុមជាតិពន្ធមួយដាច់ដោយឡែកក្នុងប្រទេសកម្ពុជាផងដែរ ដោយសារតែពួកគេមានភាសា វប្បធម៌មួយ ហើយប្រតិបត្តិសាសនាអ៊ីស្លាមបែបហ៊ិនឌូ និងមានប្រពៃណី ខុសពីប្រពៃណីរបស់ប្រជាជនខ្មែរដែលជាជនជាតិភាគច្រើន[309]។

អង្គហេតុដែលថា មានតែសមាជិកនៃក្រុមដែលទទួលបានការការពារដែលស្ថិតក្នុងតំបន់ឬប្រទេសជាក់លាក់មួយប៉ុណ្ណោះ ត្រូវបានកំណត់គោលដៅនោះ ពុំបានកម្រិតវិសាលភាពនៃក្រុមដែលត្រូវទទួលបានការការពារនោះឡើយ ប៉ុន្តែអាចមានផលប៉ះពាល់លើបញ្ហាថាតើ ចារីមានចេតនាបំផ្លាញក្រុមនោះ “ទាំង

កថាខណ្ឌ ៦១។ ធៀបទៅនឹង សំណុំរឿង ០០២/០២ សាលក្រម យោបល់ដាច់ដោយឡែករបស់ចៅក្រម យូរ ឧត្តរា ស្តីពីអំពើប្រល័យពូជសាសន៍។ សូមមើល ផ្នែក ២.៣.២.២។

302 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩៣។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣។

303 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦២។

304 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩២។

305 ដូចខាងលើ កថាខណ្ឌ ៧៩២។

306 ដូចខាងលើ កថាខណ្ឌ ៧៩៥។

307 ដូចខាងលើ។

308 ដូចខាងលើ។

309 ដូចខាងលើ កថាខណ្ឌ ៣៤១៩។

ស្រេង ឬមួយផ្នែក"[310] ដែរ ឬយ៉ាងណា[311]។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ក្រុមដែលទទួលបានការការពាររួមបញ្ចូល ជនជាតិវៀតណាមទាំងអស់ *ដោយពុំគិតពីការតាំងទីលំនៅអចិន្ត្រៃយ៍[របស់ពួកគេ]*ឡើយ[312]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងដែលថា ជនជាតិវៀតណាមដែលត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែមានទីលំនៅក្នុងប្រទេសវៀតណាម ពុំស្ថិតក្នុងក្រុមដែលទទួលបានការការពារ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យក្រុមដែលទទួលបានការការពារថាជា "ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា"[313]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថា ជនជាតិវៀតណាម "ដែលរស់នៅក្នុងប្រទេសកម្ពុជា" គឺស្ថិតក្នុងក្រុមដែលទទួលបានការការពារនោះ *តាមការជាក់ស្តែង*ពុំបានកម្រិតវិសាលភាពនៃក្រុមដែលទទួលបានការការពារនោះឡើយ។ ផ្ទុយទៅវិញអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មានការបង្ហាញដោយប្រយោលនៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកជនជាតិវៀតណាមទាំងអស់ *ដែលស្ថិតក្នុងប្រទេសកម្ពុជា* ដោយពុំគិតថាមានទីលំនៅអចិន្ត្រៃយ៍ ថាជាសមាជិកនៃក្រុមដែលទទួលបានការការពារ ដោយផ្អែកលើលក្ខណៈពូជសាសន៍ ជាតិសាសន៍ និងជាតិពន្ធរបស់ពួកគេ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុទៀតថា ការដែលក្រុមដែលទទួលបានការការពារត្រូវបានកំណត់តាមរយៈលក្ខណៈពូជសាសន៍ ជាតិសាសន៍ និងជាតិពន្ធនៃសមាជិកនោះ "អាចមានផលវិបាក ពីព្រោះអាចបង្ហាញថា ក្រុមដែលទទួលបានការការពារនេះអាចរួមបញ្ចូលជនជាតិវៀតណាមទាំងអស់ រួមទាំងជនជាតិវៀតណាមដែលរស់នៅក្រៅប្រទេសកម្ពុជាផងដែរ"[314]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣, និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្អែកលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ នៅក្នុងការសម្រេចថា ទាំងធាតុផ្សំអត្តនោម័ត និងទាំងធាតុផ្សំសត្យានុម័ត គប្បីត្រូវបានពិចារណាក្នុងការកំណត់អត្តសញ្ញាណក្រុមដែលទទួលបានការការពារ[315]។ យុត្តិសាស្ត្រនេះបានបង្កើត "លក្ខខណ្ឌចម្រុះតាមករណីនីមួយៗ" ដើម្បីកំណត់ថាតើ ជនរងគ្រោះ (ឬក្រុមគោលដៅ) ស្ថិតក្នុងចំណោមក្រុមណាមួយក្នុងចំណោមក្រុមដែលទទួលបានការការពារដែរឬអត់។ យោងតាមតេស្តនេះ៖ (១) "គួរយោងលើលក្ខណៈសត្យានុម័តនៃបរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលជាប់ពាក់ព័ន្ធ" (២) "គួរពិចារណាផងដែរទៅលើការយល់ឃើញអត្តនោម័តរបស់ជនរងគ្រោះ និងចារី" ដោយសារតែក្រុមនោះអាចមិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ឬអាចត្រូវចារីធ្វើការកំណត់ចរិតលក្ខណៈក្នុងរបៀបផ្សេងខុសពីការយល់ឃើញរបស់មនុស្សទាំងឡាយនៅក្នុងក្រុមជាទូទៅ[316]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចផងដែរនៅក្នុងរឿងក្តីទាំងបីនេះថា ក្រុមដែលត្រូវបានកំណត់គោលដៅត្រូវតែមានអត្តសញ្ញាណវិជ្ជមានជាក់លាក់ ហេតុនេះមិនអាចត្រូវបានកំណត់និយមន័យដោយអវិជ្ជមានបានឡើយ។ ប្រសិនបើមានក្រុមលើសពីមួយត្រូវបានដាក់ជាគោលដៅដែលត្រូវបំផ្លាញ នោះធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ត្រូវតែបានបំពេញចំពោះក្រុមនីមួយៗ[317]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាបន្ថែមទៀតថា ក្រុមដែលជាគោលដៅនោះអាចរួមបញ្ចូលបុគ្គលិកយោធា

[310] ដូចខាងលើ កថាខណ្ឌ ៣២០៣-៣២០៤។
[311] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៥៩៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៤១៦។
[312] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦១៦។
[313] ដូចខាងលើ កថាខណ្ឌ ១៥៩៦។
[314] ដូចខាងលើ កថាខណ្ឌ ១៥៩៧។
[315] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦២។
[316] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦២។
[317] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣។

ដរាបណាបុគ្គលិកឃោធានោះត្រូវបានចាត់ទុកថាជាគោលដៅ ដោយសារពួកគេជាសមាជិកក្នុងក្រុមដែលទទួលបានការការពារ[318]។

#### ២.៣.២.១.៤. *"ដោយមានចេតនាបែបនោះ"*

និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ របស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍តម្រូវថា ចារីមានចេតនាបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារ *"[ដោយមានចេតនា]បែបនោះ"*[319]។ អត្ថបទច្បាប់ អ.វ.ត.ក. ហាក់ដូចជាបន្ទាប*ធាតុផ្សំអត្តនោម័ត*សម្រាប់អំពើប្រល័យពូជសាសន៍ ដោយសារតែមាត្រា ៤ នៃអត្ថបទជាភាសាអង់គ្លេសចែងថា អំពើប្រល័យពូជសាសន៍គឺជា "អំពើ [...] ដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ *ដូចជា៖*" ពោលគឺបង្ហាញពីបញ្ជីអំពើប្រព្រឹត្តដែលពុំមានលក្ខណៈលម្អិត[320]។ ផ្ទុយទៅវិញអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ផ្តល់នូវពាក្យពេចន៍មានលក្ខណៈរឹតត្បិតជាងនេះ៖ *"ដោយមានចេតនាបែបនោះ"*។ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានអនុវត្តយ៉ាងស៊ីចង្វាក់គ្នានូវនិយមន័យនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដោយបានគូសបញ្ជាក់ថា "ជនរងគ្រោះនៃបទប្រល័យពូជសាសន៍ពុំមែនត្រឹមតែជាបុគ្គលប៉ុណ្ណោះទេ ថែមទាំងជាក្រុមនោះផ្ទាល់ផងដែរ"[321]។ អង្គជំនុំជម្រះសាលាដំបូងបកស្រាយឃ្លា "ដោយមានចេតនាបែបនោះ" ដើម្បីតម្រូវថា ក្រុមនោះត្រូវបានបំផ្លិចបំផ្លាញ គឺជាក្រុមអង្គភាពមួយផ្សេងដោយឡែកនិងខុសប្លែកពីគេ និងថាបើទោះបីជាសមាជិកមួយចំនួននៅក្នុងក្រុមនោះអាចនៅរស់រានមានជីវិតក៏ដោយ ក៏ប៉ុន្តែ "អត្តសញ្ញាណរបស់ក្រុមនោះ" ត្រូវបានបំផ្លិចបំផ្លាញ[322]។ អង្គជំនុំជម្រះបានសម្រេចថា ការបកស្រាយនេះស្របទៅនឹងគោលដៅ និងគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដែលក្នុងនោះឃ្លា "ដោយមានចេតនាបែបនោះ" សង្កត់ធ្ងន់ថា ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍មិនមែនតែបុគ្គលនោះទេ ប៉ុន្តែអត្តសញ្ញាណក្រុមនោះក៏ជាជនរងគ្រោះដោយអំពើនេះផងដែរ ហើយយុត្តិសាស្ត្រកន្លងមកបានលើកឡើងថា ចេតនាដែលពាក់ព័ន្ធគឺដើម្បី "បំផ្លិចបំផ្លាញបណ្តុំនៃមនុស្សដែលមានអត្តសញ្ញាណក្រុមជាក់លាក់"[323]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ទោះបីជាអំពើប្រល័យពូជសាសន៍អាចត្រូវបានកំណត់និយមន័យ ថាជាចេតនាក្នុងការបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារ ទោះទាំងស្រុង ឬមួយផ្នែកក៏ដោយ ក៏ធាតុផ្សំទូទៅនោះគឺ ចេតនាបំផ្លិចបំផ្លាញត្រូវតែសំដៅផ្ទាល់ទៅលើក្រុម *"ដោយមានចេតនាបែបនោះ"*[324]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា អត្ថបទជាភាសាអង់គ្លេសនៃមាត្រា ៤ នៃច្បាប់ អ.វ.ត.ក. អាចត្រូវបានបកស្រាយថារៀបរាប់មិនចេះអស់អំពីអំពើប្រល័យពូជសាសន៍។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា បើទោះបីជាឃ្លា "ដោយមានចេតនាបែបនោះ" មានលក្ខណៈដាច់ស្រេចជាង - គឺការសង្កត់ធ្ងន់លើចេតនាក្នុងការបំផ្លិចបំផ្លាញត្រូវតែផ្តោតលើក្រុមនោះជាពិសេស ដោយសារតែអត្តសញ្ញាណរបស់ក្រុមនោះជាក្រុមជាតិ ក្រុមជាតិពន្ធុ ក្រុមពូជ

[318] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧១។

[319] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦០៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩៨។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។

[320] សូមមើល សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៥ ជើងទំព័រ ១៨៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣ ជើងទំព័រ ១២៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៩ ជើងទំព័រ ១៤៣។

[321] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦០៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៨៤-៧៨៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៥, ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣, ៧៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៩, ៧២។

[322] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩៨។

[323] ដូចខាងលើ។

[324] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦០៩។

សាសន៍ ឬក្រុមសាសនា - ឃ្លា "ដូចជា" បង្ហាញពីបញ្ជីអំពើប្រព្រឹត្តដែលពុំមានលក្ខណៈលម្អិត ដែលបើក ចំហឱ្យនិយមន័យនេះមានអំពើប្រព្រឹត្តទូលំទូលាយច្រើន។ យ៉ាងណាមិញ ដោយកត់សម្គាល់ថា មាត្រា ៩ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា អ.វ.ត.ក. មានយុត្តាធិការលើឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ "ដូចដែលបានកំណត់" ក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នោះ សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ បានសម្រេចអនុវត្តនិយមន័យដែលមានលក្ខណៈដាច់ស្រេចជាងរបស់អនុសញ្ញាស្តីពី អំពើប្រល័យពូជសាសន៍ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន[325]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏ពិចារណាផងដែរថា អំពើជាមូលដ្ឋាននៃអំពើប្រល័យពូជ សាសន៍ត្រូវតែបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លិចបំផ្លាញក្រុមដែលជាគោលដៅ គឺជាក្រុមអង្គភាព មួយដាច់ដោយឡែក និងខុសគេរបស់បុគ្គលជាជនរងគ្រោះ៖ ជនរងគ្រោះចុងក្រោយបំផុត ដោយសារ ឧក្រិដ្ឋកម្មនេះគឺជាក្រុម។ គាត់បានផ្តល់សំអាងហេតុថា បុគ្គលជាជនរងគ្រោះត្រូវតែជាគោលដៅ ដោយសារថាពួកគេជាសមាជិកនៅក្នុងក្រុម (ប៉ុន្តែ មិនចាំបាច់ទាល់តែថា ពួកគេជាសមាជិកបែបនេះទេ) ហេតុនេះ ការគ្រាន់តែដឹងអំពីសមាជិកភាពបែបនេះតែមួយមុខនោះ គឺមិនគ្រប់គ្រាន់នោះទេ[326]។

### ២.៣.២.២. និយមន័យទូលំទូលាយនៃអំពើប្រល័យពូជសាសន៍

ក្នុងសំណុំរឿង ០០២/០២ ចៅក្រម យូរ ឧត្តរា បានភ្ជាប់មតិយោបល់ដាច់ដោយឡែកស្តីពីអំពើ ប្រល័យពូជសាសន៍ ដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង និងសហចៅក្រមស៊ើបអង្កេតបានអនុម័ តយកវិធីសាស្ត្រ "ចង្អៀត" ចំពោះនិយមន័យអំពើប្រល័យពូជសាសន៍[327]។ ចៅក្រម យូរ ឧត្តរា យល់ឃើញ ថា ការបកស្រាយនិយមន័យអំពើប្រល័យពូជសាសន៍ យោងតាមមាត្រា ២ នៃអនុសញ្ញាស្តីពីអំពើប្រល័យ ពូជសាសន៍ផ្សេងពីនេះ និងផ្តល់នូវមូលដ្ឋានរឹងមាំក្នុងការពិនិត្យមើលកាលៈទេសៈទូលំទូលាយ ក្នុងប្រទេស កម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជាពិសេសក្នុងការកំណត់ថាតើមានចេតនាក្នុងការបំផ្លាញផ្នែកសំខាន់ មួយនៃក្រុមជនជាតិខ្មែរដែលមានអត្ថិភាពនាពេលនោះដែរ ឬយ៉ាងណា[328]។ គាត់បានបង្កើតការបកស្រាយ ផ្សេង និងមានលក្ខណៈទូលាយជាងចំពោះនិយមន័យអំពើប្រល័យពូជសាសន៍ ជាពិសេសទាក់ទងនឹង*ធាតុ ផ្សំអត្តនោម័ត* ដែលយោងតាមនិយមន័យនេះ៖

i. មិនមានលក្ខខណ្ឌតម្រូវឱ្យចារី និងជនរងគ្រោះ នៃអំពើប្រល័យពូជសាសន៍ត្រូវតែចេញ មកពីក្រុមផ្សេងគ្នាទាំងស្រុងនោះទេ។ ក្នុងករណីបកស្រាយមាត្រា ២ ផ្ទុយពីនេះ នោះគឺជា ការបកស្រាយក្នុងលក្ខខណ្ឌចង្អៀត ដែលជាការមិនសមស្របទេ។
ii. មានក្រុមដែលត្រូវបានការពារតែបួនក្រុមប៉ុណ្ណោះ ប៉ុន្តែការកំណត់អត្តសញ្ញាណរបស់ពួក គេអាស្រ័យលើកត្តា (សត្យានុម័ត និងអត្តនោម័ត) ជាច្រើន ហើយការពិចារណាត្រូវផ្តោត លើបរិបទនយោបាយ សង្គម និងវប្បធម៌។
iii. អំពើមួយចំនួនអាចមិនត្រូវបានហាមឃាត់ដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ប៉ុន្តែវាអាចពាក់ព័ន្ធទៅនឹងការវាយតម្លៃបានអំពីចេតនានៃការបំផ្លិចបំផ្លាញក្រុមដែលត្រូវ បានការពារទាំងស្រុង ឬមួយផ្នែក។
iv. យើងពុំចាំបាច់បង្ហាញចេតនាបំផ្លិចបំផ្លាញទាំងស្រុង ចំពោះក្រុមដែលត្រូវបានការពារនោះ ទេ។
v. ចេតនាអាចសំដៅលើផ្នែកមួយនៃក្រុម ប្រសិនបើផ្នែកនោះមានលក្ខណៈសំខាន់ ហើយការ វាយតម្លៃលើចំណុចនេះពាក់ព័ន្ធនឹងកត្តាបរិមាណ និងគុណវិស័យ។

---

325 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៥ ជើងទំព័រ ១៨៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៣ ជើងទំព័រ ១២៣។ សំណុំរឿង ០០៤ ដីកាដំណោះ ស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៩ សម្គាល់ជើងទំព័រ ១៤៣។

326 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៨។ សំណុំរឿង ០០៣ ដីកាដំណោះ ស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។

327 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦៨-៤៤៦៩។

328 ដូចខាងលើ កថាខណ្ឌ ៤៥១៧។

vi. ត្រូវតែបង្ហាញថា គឺក្រុមទាំងមូល ឬមួយផ្នែកដែលជាកម្មវត្ថុនៃការបំផ្លិចបំផ្លាញ ពុំមែនបុគ្គលម្នាក់ៗនោះឡើយ[329]។

ចៅក្រម យូរ ឧត្តរា បានផ្តល់សំអាងហេតុខាងក្រោមចំពោះការលើកឡើងនេះ៖

i. លក្ខខណ្ឌតម្រូវថាចារី និងជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ត្រូវតែមកពីក្រុមខុសគ្នាទាំងស្រុង គឺជា “ការកម្រិតបែបសប្បនិម្មិត”។ ដើម្បីបកស្រាយមាត្រា ២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ថាអនុវត្តបានចំពោះតែអំពើប្រល័យពូជសាសន៍នៃក្រុមកំណត់មួយ ដែលប្រព្រឹត្តដោយក្រុមមួយផ្សេងទៀត គឺជាការមិនបានពិចារណាទៅលើភាពស្មុគស្មាញរបស់មនុស្សជាតិ។ វាក៏ជាការមិនគិតគូរដល់លទ្ធភាពដែលថា ចារីអាចមានជំនឿខុស ឬរើសអើង ចំពោះភាពបរិសុទ្ធនៃក្រុមខ្លួនឯង ធៀបជាមួយនឹងជនរងគ្រោះរបស់ខ្លួន[330]។
ii. អង្គជំនុំជម្រះសាលាដំបូងមានភាពត្រឹមត្រូវ ក្នុងការពិនិត្យមើលទាំងធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តក្នុងការកំណត់និយមន័យក្រុមដែលត្រូវការពារ។ ទោះបីជាមាត្រា ២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មិនការពារក្រុមដែលមានអត្ថិភាពបណ្តោះអាសន្ន ការពិនិត្យមើលទាំងលក្ខណៈសត្យានុម័ត និងអត្តនោម័ត - ក៏ដូចជាការមើលទៅលើបរិបទនយោបាយ សង្គម និងវប្បធម៌ នៅពេលកំណត់អត្តសញ្ញាណក្រុមត្រូវការពារ - ស្របគ្នាទៅនឹងគោលដៅ និងគោលបំណងរបស់អនុសញ្ញា និងចៀសវាងបាននូវវិធីសាស្ត្រមួយដែលមានលក្ខណៈតឹងរ៉ឹង និងចង្អៀតពេក[331]។
iii. វាមិនជាការចាំបាច់ និងមិនសមស្របក្នុងការព្យាយាមកំណត់ជាមុននូវអំពើប្រព្រឹត្តិដែលពាក់ព័ន្ធ ដើម្បីសម្រេចលើ “ភស្តុតាងនៃចេតនាបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែក លើក្រុមដែលត្រូវបានការពារ”នោះទេ។ នៅពេលធ្វើការវាយតម្លៃលើចេតនាប្រល័យពូជសាសន៍ គេគប្បីពិចារណាទៅលើកាលៈទេសៈទូលំទូលាយ រួមទាំង ការប្រព្រឹត្តិដែលមិនចាំបាច់ថាជាការបំផ្លិចបំផ្លាញរូបកាយ ឬជីវសាស្ត្ររបស់បុគ្គលម្នាក់ៗទេ[332]។
iv. ទោះបីជាចំនួនមនុស្សចូលរួមគឺជាអង្គហេតុដែលពាក់ព័ន្ធខ្លាំង នៅពេលវាយតម្លៃលើចេតនាប្រល័យពូជសាសន៍យ៉ាងណាក្តី ក៏វិធីសាស្ត្ររបស់ចៅក្រមភាគច្រើនក្នុងការវាយតម្លៃតែទៅលើកត្តាគុណវិស័យ បានកម្រិតលក្ខខណ្ឌដោយមិនសមហេតុផលសម្រាប់អត្ថន័យនៃពាក្យ “មួយផ្នែក”[333]។ នៅក្នុងយុត្តិសាស្ត្រតុលាការ ICTY និង តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (“ECtHR”) មាត្រា ២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មិនរួមបញ្ចូលធាតុផ្សំគុណវិស័យសម្រាប់ការវាយតម្លៃអត្ថន័យនៃឃ្លា “មួយផ្នែក”ទេ[334]។
v. ចៅក្រមភាគច្រើនបានបកស្រាយយ៉ាងត្រឹមត្រូវនូវឃ្លា “បែបនេះ[ដោយមានចេតនាបែបនោះ]” ដែលបានបញ្ជាក់ថា ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ មិនគ្រាន់តែជាបុគ្គលនោះទេ តែត្រូវតែជាក្រុមមួយ។ ទោះបីជាផ្នែកមួយនៃក្រុមនេះត្រូវបានបំផ្លិចបំផ្លាញ “បែបនេះ” ហើយអាចមានហេតុផលផ្សេងៗទៀត ដូចជា ចេតនាប្រល័យពូជសាសន៍ ក៏នៅតែមានលក្ខខណ្ឌតម្រូវថាជនរងគ្រោះត្រូវតែជាក្រុមមួយ។ នៅក្នុងបរិបទបច្ចុប្បន្ននេះ ក្រុមរងគ្រោះរួមបញ្ចូល “(ផ្នែកសំខាន់នៃ)ក្រុមជាតិសាសន៍ខ្មែរ “ដែលត្រូវបានកំណត់គោលដៅដោយសារហេតុផលរាប់មិនអស់ ដើម្បីបោសសំអាតអ្វីដែលនៅសល់នៅក្នុងក្រុមនោះ”[335]។

---

[329] ដូចខាងលើ កថាខណ្ឌ ៤៥១៦។
[330] ដូចខាងលើ កថាខណ្ឌ ៤៤៧៨។
[331] ដូចខាងលើ កថាខណ្ឌ ៤៤៧៩-៤៤៨២។
[332] ដូចខាងលើ កថាខណ្ឌ ៤៤៩១។
[333] ដូចខាងលើ កថាខណ្ឌ ៤៥០៤។
[334] ដូចខាងលើ កថាខណ្ឌ ៤៤៩២-៤៥០៣។
[335] ដូចខាងលើ កថាខណ្ឌ ៤៥១២។

បន្ថែមលើនេះទៀត ចៅក្រម យូរ ឧត្តរា បានយល់ស្របជាមួយនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ICTY និង ICJ ថា ក្រុមជាគោលដៅត្រូវតែកំណត់អត្តន័យដោយផ្អែកលើមូលដ្ឋានវិជ្ជមានមួយចំនួន។ ទោះជាយ៉ាងណា គាត់យល់ឃើញថា យោបល់ជំទាស់របស់ចៅក្រម Shahabuddeen នៅក្នុងសាលដីកាក្នុងរឿងក្តី Stakić នៃតុលាការ ICTY មានភាពស៊ីចង្វាក់គ្នា និងប្រាកដនិយមជាង ក្នុងលក្ខខណ្ឌដែលថា វាសម្រេចថា ក្រុមដែលទទួលបានការការពារក៏អាចត្រូវបានកំណត់អត្តសញ្ញាណផ្អែកលើលក្ខណៈរបស់ខ្លួនតាមលក្ខណៈអវិជ្ជមានផងដែរ[336]។

### ២.៣.២.៣. អំពើជាមូលដ្ឋាននៃអំពើប្រល័យពូជសាសន៍

មាត្រា ៤ នៃច្បាប់ អ.វ.ត.ក. ចែងអំពីអំពើជាមូលដ្ឋាននៃអំពើប្រល័យពូជសាសន៍ ទាក់ទងទៅនឹងចំណុចដែលថា ទាំងធាតុផ្សំអត្តនោម័ត និងធាតុផ្សំសត្យានុម័ត ត្រូវតែធ្វើការបញ្ជាក់ (បន្ថែមលើចេតនាជាក់លាក់ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍) ដែលរួមមានដូចខាងក្រោម[337]៖

i. ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
ii. ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម
iii. ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
iv. ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក
v. ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

#### ២.៣.២.៣.១. ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

យុត្តិសាស្ត្រ អ.វ.ត.ក. បានសម្រេចថា ធាតុផ្សំអំពើជាមូលដ្ឋានៃការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម មានលក្ខណៈដូចគ្នាទៅនឹងធាតុផ្សំនៃការធ្វើមនុស្សឃាតដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀតដែរ[338]។'

i. ធាតុផ្សំសត្យានុម័ត៖ ចារីត្រូវតែបានបណ្តាលឱ្យបាត់បង់ជីវិតជនរងគ្រោះតាមរយៈអំពើសកម្មឬអកម្ម ពោលគឺដោយ "រួមចំណែកយ៉ាងពិតប្រាកដក្នុងការធ្វើឱ្យបាត់បង់ជីវិតជនរងគ្រោះ"[339]។ ការស្វែងរកសាកសពរបស់ជនរងគ្រោះមិនចាំបាច់បញ្ជាក់ធាតុផ្សំនៃការធ្វើមនុស្សឃាតនោះទេ។ ការស្លាប់របស់ជនរងគ្រោះអាចត្រូវបានសន្និដ្ឋានតាមកាលៈទេសៈពីភស្តុតាងដែលបានបង្ហាញ[340]។ អ្វីដែលតម្រូវឱ្យបង្ហាញនោះ "គឺការទាញសេចក្តីសន្និដ្ឋានដ៏សមហេតុផលតែមួយគត់ដែលថា ជនរងគ្រោះស្លាប់ដោយសារអំពើសកម្មឬអកម្មរបស់ជនជាប់ចោទ ឬ របស់ជនណាម្នាក់ឬច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើនោះ"[341]។ មិនមាន "ចំនួនកំណត់" សម្រាប់ចំនួនមនុស្សដែលត្រូវ

---

[336] ដូចខាងលើ កថាខណ្ឌ ៤៥១៣-៤៥១៥។
[337] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៤។
[338] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។
[339] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥១(ក)។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៣(ក)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៦(ក)។
[340] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។
[341] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៨។

បានសម្លាប់នោះឡើយ ដើម្បីកំណត់*ធាតុផ្សំសត្យានុម័ត*[342]។ យ៉ាងណាមិញ ជាក់ស្តែង វាត្រូវតែសំដៅលើសមាជិកម្នាក់ ឬច្រើននាក់នៃក្រុមមួយ ដោយផ្អែកលើសមាជិកភាពនៃក្រុមនោះ[343]។

ii. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែមានចេតនា "ចំពោះការសម្លាប់ ឬការបង្កឱ្យមានព្យសនកម្មលើរូបកាយធ្ងន់ធ្ងរ ដោយមានហេតុផលសមស្របដែលនាំឱ្យដឹងថា អំពើសកម្មឬអកម្មនោះ អាចធ្វើឱ្យមានការបាត់បង់ជីវិតមនុស្ស"[344]។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវថា មានភស្តុតាងគ្រប់គ្រាន់គាំទ្រការសន្និដ្ឋានរបស់ខ្លួនថា សមាជិកនៃក្រុមជនជាតិវៀតណាមដែលទទួលបានការការពារ ត្រូវបានសម្លាប់នៅក្នុងបរិបទនៃបទចោទប្រល័យពូជសាសន៍[345]។ អង្គជំនុំជម្រះតុលាការកំពូលច្រានចោលអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានមិនត្រឹមត្រូវថា *ធាតុផ្សំសត្យានុម័ត*នៃអំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យក្រុមដែលទទួលបានការការពារថាជា "ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា" ប៉ុន្តែបានពិចារណាលើការស្លាប់របស់ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសវៀតណាម។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថា ជនជាតិវៀតណាម "ដែលរស់នៅក្នុងប្រទេសកម្ពុជា" គឺជាក្រុមដែលទទួលបានការការពារនោះ *តាមការជាក់ស្តែង*មិនបានកម្រិតវិសាលភាពនៃក្រុមដែលទទួលបានការការពារនោះទេ[346]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ បានសម្រេចថា ការស្លាប់របស់ជនរងគ្រោះអាចត្រូវបានបញ្ជាក់តាមរយៈភស្តុតាងតាមកាលៈទេសៈ ដែលផ្តល់ឱ្យ ដរាបណាមានតែសេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ ដែលអាចទាញចេញបានពីភស្តុតាងបែបនោះ គឺសេចក្តីសន្និដ្ឋានដែលថា ជនរងគ្រោះបានស្លាប់ហើយ[347]។

### ២.៣.២.៣.២. ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយអំពើជាមូលដ្ឋាននៃការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា ក្នុងសំណុំរឿង ០០៤/០២ និង ០០៤ ថាជា៖

i. *ធាតុផ្សំសត្យានុម័ត៖* ចារីត្រូវតែបានបង្កព្យសនកម្មដែលលើសពីការបាត់បង់សមត្ថភាពរាងកាយ ឬសតិបញ្ញាតិចតួច ឬជាបណ្តោះអាសន្ន ហើយនាំឱ្យមានការខូចខាតរយៈពេលវែង និងធ្ងន់ធ្ងរ ចំពោះសមត្ថភាពរបស់ក្រុមដែលទទួលបានការការពារ ក្នុងការរស់នៅ និងប្រកបកិច្ចការក្នុងជីវិតធម្មតា។ ការណ៍នេះត្រូវបានវាយតម្លៃតាមករណីជាក់ស្តែងទាក់ទងនឹងកាលៈទេសៈនានា។ តម្រូវឱ្យមានភស្តុតាងបញ្ជាក់លទ្ធផល។ ព្យសនកម្មធ្ងន់ធ្ងរមិនចាំបាច់មានលក្ខណៈអចិន្ត្រៃយ៍ ឬមិនអាចជួសជុលបាននោះឡើយ ប៉ុន្តែត្រូវតែលើសពីការបាត់បង់សមត្ថភាពរាងកាយ ឬសតិបញ្ញាតិចតួច ឬជាបណ្តោះអាសន្ន ហើយនាំឱ្យមានការខូចខាតរយៈពេលវែង និងធ្ងន់ធ្ងរ ចំពោះសមត្ថភាពរបស់បុគ្គលក្នុងការរស់នៅ និង

---

[342] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩១។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។

[343] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៩១។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។

[344] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៣០។

[345] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៦០៣-១៦០៥។

[346] ដូចខាងលើ កថាខណ្ឌ ១៥៩៧។

[347] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។

ប្រកបកិច្ចការក្នុងជីវិតធម្មតា។ មិនមានលក្ខខណ្ឌតម្រូវថា ព្យសនកម្មដែលបានបង្កឡើងនោះត្រូវតែមានលក្ខណៈធ្ងន់ធ្ងរល្មម អាចបណ្តាលឱ្យមានការបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្តើកដល់ក្រុមដែលទទួលបានការការពារនោះទេ ប៉ុន្តែកម្រិតនៃការគំរាមកំហែងទៅលើការបំផ្លិចបំផ្លាញរបស់ក្រុម អាចចាត់ទុកថាជារង្វាស់ដើម្បីវាស់វែងភាពធ្ងន់ធ្ងរនៃព្យសនកម្មដែលបានបង្កឡើង។ ការប្រព្រឹត្តដោយអមនុស្សធម៌ ឬដោយបន្ថោកបន្ទាបទារុណកម្មផ្លូវចិត្ត ឬរាងកាយ ការរំលោភសេពសន្ថវៈ ការបំពារបំពានផ្លូវភេទ ការនិរទេសការសួរចម្លើយ ឬករួមនឹងការវាយដំ និង/ឬការគំរាមសម្លាប់ អំពើហិង្សាលើរាងកាយមិនដល់ស្លាប់ដែលធ្វើឱ្យខូចសុខភាព ឬបណ្តាលឱ្យខូចរូបរាង ឬរបួសធ្ងន់ធ្ងរដល់សមាជិកក្រុមត្រូវការពារ និងការធ្វើទុក្ខបុកម្នេញ គឺជាអំពើដែលអាចធ្វើឱ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា។ ការប៉ះទង្គិចផ្លូវចិត្ត និងរបួសរបស់ជនរងគ្រោះដែលនៅមានជីវិត ក្រោយពីការសម្លាប់រង្គាល គឺជារបួសធ្ងន់ធ្ងរខាងសតិបញ្ញា (និងរាងកាយ)។ ការផ្លាស់ទីលំនៅដោយបង្ខំ មិនមែនជាអំពើប្រល័យពូជសាសន៍ទេ។ យ៉ាងណាមិញ វាអាចជាអំពើមួយ ដែលអាចធ្វើឱ្យរបួសធ្ងន់ធ្ងរដល់រូបរាងកាយ និងសតិបញ្ញា ជាពិសេសប្រសិនបើកាលៈទេសៈនៃការផ្លាស់ទីលំនៅនោះ នាំឱ្យអ្នកផ្លាស់ទីលំនៅស្លាប់ទាំងអស់ ឬស្លាប់មួយចំនួន[348]។ *ធាតុផ្សំសត្យានុម័ត*នៃការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយតម្រូវថា បុគ្គលជាជនរងគ្រោះត្រូវតែនៅមានជីវិត និងមិនអាចអនុវត្តត្រួតលើគ្នា នៅពេលដែលជនរងគ្រោះត្រូវបានសម្លាប់ឡើយ[349]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែបានប្រព្រឹត្តដោយចេតនានូវអំពើសកម្មឬអកម្ម ដោយមានបំណងធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា[350]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាបន្ថែមទៀតថា អំពើដែលធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ មិនមែនជាអំពើល្មើសដែលមិនសូវធ្ងន់ធ្ងរ ក្នុងការ “សម្លាប់សមាជិកនៃក្រុម”ទេ។ គាត់បានកត់សម្គាល់ថា សាលាក្តីមិនអចិន្ត្រៃយ៍បានបកស្រាយអំពីជាមូលដ្ឋាននៃការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ថាជាការខូចខាតរយៈពេលវែង និងធ្ងន់ធ្ងរ ចំពោះសមត្ថភាពរបស់បុគ្គលក្នុងការរស់នៅ និងប្រកបកិច្ចការក្នុងជីវិតធម្មតា។ គាត់បានពិចារណាថា ការណ៍នេះមិនស្របជាមួយនឹងករណីទាំងឡាយដែលលទ្ធផលដែលមានចេតនានិងសម្រេចបាន គឺត្រូវសម្លាប់សមាជិកក្រុមត្រូវការពារឱ្យបានឆាប់រហ័ស ទោះបីជាថា ពួកគេអាចទទួលរងការរំលោភបំពានផ្នែករាងកាយ និងផ្លូវចិត្ត មុនពេលអំពើសម្លាប់កើតឡើងក៏ដោយ។ ដោយសារតែការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មិនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងទាំងអស់នេះ គាត់បានសម្រេចថា មិនមានហេតុផលណាត្រូវពិភាក្សាអំពីទំនាក់ទំនងរវាងអំពើប្រល័យពូជសាសន៍ប្រភេទនេះ ជាមួយនឹងការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ[351]។

### ***២.៣.២.៣.៣. ការធ្វើដោយចេតនាឱ្យក្រុមទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញរាងកាយរបស់ក្រុម***

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយអំពីជាមូលដ្ឋាននៃការធ្វើដោយចេតនាឱ្យក្រុមទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញរាងកាយរបស់ក្រុមដូចខាងក្រោម៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែចូលរួមក្នុងអំពើប្រព្រឹត្តិ ដែលមិនសម្លាប់សមាជិកនៃក្រុមដែលទទួលបានការការពារភ្លាមៗទេ ប៉ុន្តែ ជាចុងក្រោយ ព្យាយាមបំផ្លិចបំផ្លាញរូបរាង

[348] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២(ក)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦(ក)។
[349] ដូចខាងលើ។
[350] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២(ខ)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦(ខ)។
[351] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦។

កាយរបស់ពួកគេ។ ភស្តុតាងបញ្ជាក់ពីលទ្ធផលមិនតម្រូវឱ្យមានទេ។ ឧទាហរណ៍រួមមាន ការរំលោភសេពសន្ថវៈ ការបដិសេធមិនផ្តល់សេវាសុខភាព ការផ្តល់របបអាហារសម្រាប់តែរស់រាន ការបង្កើតកាលៈទេសៈដែលនាំឱ្យជនរងគ្រោះស្លាប់បន្តិចម្តងៗ ដូចជាកង្វះអាហារ ទឹក កន្លែងស្នាក់នៅ សម្លៀកបំពាក់ អនាម័យ ការដាក់ឱ្យមនុស្សធ្វើការហួសហេតុ ឬប្រើកម្លាំងហួសហេតុ និងការបណ្តេញចេញជាប្រព័ន្ធឱ្យមនុស្សចេញពីផ្ទះរបស់ខ្លួន។ ស្ថានភាពនានាត្រូវតែបានរៀបចំឡើង ដើម្បីបំផ្លិចបំផ្លាញរាងកាយក្រុមនោះទាំងស្រុង ឬមួយផ្នែក មិនមែនរៀបចំឡើង ដើម្បីរំលាយក្រុមនោះទេ។ ប្រសិនបើមិនមានភស្តុតាងផ្ទាល់បញ្ជាក់ថា ស្ថានភាពនានាត្រូវបានរៀបចំឡើងដើម្បីបំផ្លិចបំផ្លាញក្រុមនោះទេ នោះត្រូវផ្តោតលើ "ភវនិយភាពសត្យានុម័ត" នៃស្ថានភាពបែបនោះដែលនាំឱ្យបំផ្លិចបំផ្លាញរាងកាយក្រុមនោះ ហើយកត្តាពាក់ព័ន្ធ រួមមានលក្ខណៈនៃស្ថានភាពបែបនោះ រយៈពេលដែលជនរងគ្រោះទទួលរងស្ថានភាពបែបនោះ និងលក្ខណៈនៃមាជិកក្រុមគោលដៅនោះ ឧទាហរណ៍ ភាពងាយរងគ្រោះរបស់សមាជិកនោះ។ ស្ថានភាពដែលមិនមានលក្ខណៈគ្រប់គ្រាន់ ទោះជាតាមបទដ្ឋានណាក៏ដោយ ប៉ុន្តែនៅតែមានលក្ខណៈគ្រប់គ្រាន់អាចឱ្យក្រុមនោះរស់រានបាន ហើយមិនបានចូលរួមចំណែកបំផ្លិចបំផ្លាញក្រុមនោះទេ គឺជាស្ថានភាពដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ *ធាតុផ្សំសត្យានុម័ត* នេះទេ[352]។

ii. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានបង្កនូវស្ថានភាពនានា ដោយចេតនាធ្វើឱ្យមានការបំផ្លិចបំផ្លាញរាងកាយរបស់ក្រុមទាំងស្រុង ឬមួយផ្នែក[353]។

#### ***២.៣.២.៣.៤. ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក***

ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារកនៅក្នុងក្រុម មិនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងណាមួយ នៅចំពោះមុខ អ.វ.ត.ក. នោះទេ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះមិនបានវិភាគអំពើជាមូលដ្ឋាននៃអំពើប្រល័យពូជសាសន៍នេះទេ។

#### ***២.៣.២.៣.៥. ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត***

ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត មិនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងណាមួយ នៅចំពោះមុខ អ.វ.ត.ក. នោះទេ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះមិនបានវិភាគអំពើជាមូលដ្ឋាននៃអំពើប្រល័យពូជសាសន៍នេះទេ។

### **២.៤. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ជា "អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា [និង] អំពើអមនុស្សធម៌ផ្សេងៗទៀត"[354]។

ទោះបីជាមាត្រា ២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ចែងថា យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. មានភាពស្របគ្នាទៅនឹងច្បាប់ អ.វ.ត.ក. យ៉ាងណាក្តី[355] ក៏មានលក្ខណៈខុសគ្នាសំខាន់ៗ

---

[352] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៣(ក)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៧(ក)។

[353] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៣(ខ)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៧(ខ)។

[354] ច្បាប់ អ.វ.ត.ក. មាត្រា ៥។

[355] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២។

មួយចំនួនរវាងនិយមន័យ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងកិច្ចព្រមព្រៀង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ អ.វ.ត.ក.។ ជាពិសេស ខណៈដែលមាត្រា ៩ នៃកិច្ចព្រមព្រៀង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការយោងទៅលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") មាត្រា ៥ នៃច្បាប់ អ.វ.ត.ក. មិនបានយោងបែបនោះទេ។ ភាពមិនស្របគ្នារវាងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. និងមាត្រា ៩ នៃកិច្ចព្រមព្រៀង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាបានបន្តមានបន្ទាប់ពីវិសោធនកម្មក្នុងឆ្នាំ២០០៤។ ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ក៏មានលក្ខណៈតឹងរឹងជាងមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមផងដែរ ដែលតម្រូវថា ការវាយប្រហារដ៏រីករាលដាល ឬជាលក្ខណៈប្រព័ន្ធត្រូវធ្វើឡើងប្រឆាំងផ្ទាល់ទៅនឹងប្រជាជនស៊ីវិល "ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"[356]។

បន្ថែមលើធាតុផ្សំទូទៅ លក្ខន្តិកៈទីក្រុងរ៉ូមមានចែងអំពីអំពើជាមូលដ្ឋាន ដែលមិនត្រូវបានរួមបញ្ចូលក្នុងច្បាប់ អ.វ.ត.ក. - ជាពិសេស ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ការដកហូតសេរីភាពខាងរូបរាងកាយ ដែលជាការបំពានលើវិធានជាមូលដ្ឋាននៃច្បាប់អន្តរជាតិ ការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការមានគភ៌ដោយបង្ខំ វន្ធ្យកម្មដោយបង្ខំ ឬការបំពានផ្លូវភេទក្នុងទម្រង់ទ្រាយផ្សេងទៀត ដែលមានភាពធ្ងន់ធ្ងរប្រហែលគ្នានេះ ការបាត់ខ្លួនមនុស្សដោយបង្ខំ បទល្មើសព្រហ្មទណ្ឌអាប៉ាថេដ[357]។ យ៉ាងណាមិញ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា យុត្តិសាស្ត្ររបស់ អ.វ.ត.ក. លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំហិតដោយនិយមន័យនៃឧក្រិដ្ឋកម្ម ដូចដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលដែលអំពើល្មើសត្រូវបានចោទប្រកាន់បានប្រព្រឹត្តឡើង[358]។

### ២.៤.១. ភាពអាចអនុវត្តបាននៅ អ.វ.ត.ក.

សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានយ៉ាងស៊ីចង្វាក់គ្នាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជាចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[359]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានវាយតម្លៃបញ្ហាចោទនៃភាពអាចអនុវត្តបាននេះដោយអង្គជំនុំជម្រះបានសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បង្កើតបានជាទម្រង់មួយយ៉ាងស៊ីចង្វាក់គ្នានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់តាំងពីធម្មនុញ្ញរបស់តុលាការ Nuremberg ឆ្នាំ១៩៤៥ មកម្ល៉េះ[360]។ ដោយកត់សម្គាល់ថា ប្រទេសកម្ពុជាមិនមែនជាភាគីហត្ថលេខាទៅនឹងអនុសញ្ញាណាមួយ ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងថាមិនមានបទប្បញ្ញត្តិណានៅក្នុងច្បាប់ជាតិកម្ពុជាដែលដោះស្រាយចំពោះបទល្មើសទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការសម្រេចថាតើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្ថិតក្នុងវិសាលភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងរយៈពេលនោះដែរ ឬយ៉ាងណា[361]។ ក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៤៥ និងថា ធាតុផ្សំគតិយុត្តិត្រូវបានកែលម្អ ចាប់តាំងពីពេលនោះមក អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យការវិវឌ្ឍផ្នែកប្រវត្តិសាស្ត្រនៃទស្សនៈតុលាការចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ៖

i. ធម្មនុញ្ញ Nuremberg ឆ្នាំ១៩៤៥
ii. ធម្មនុញ្ញតូក្យូ ឆ្នាំ១៩៤៦

---

[356] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១០៦។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៥។
[357] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៧។
[358] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៩៩-១០០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩។
[359] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៩៨-១១៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៨៣, ២៩៦។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៧-៣៨។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៣។
[360] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៨៣-២៩៦ (ជាពិសេស កថាខណ្ឌ ២៩០)។
[361] ដូចខាងលើ កថាខណ្ឌ ២៨៤។

iii. សេចក្តីបញ្ជាក់របស់មហាសន្និបាតឆ្នាំ១៩៤៦
iv. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨
v. គោលការណ៍ Nuremberg ឆ្នាំ១៩៥០ របស់គណៈកម្មការច្បាប់អន្តរជាតិ ("ILC")
vi. អនុសញ្ញាអាប៉ាថេដឆ្នាំ១៩៧៣
vii. ការចោទប្រកាន់ព្រហ្មទណ្ឌក្នុងប្រទេស ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង
viii. លក្ខន្តិកៈតុលាការ ICTY, ICTR តុលាការពិសេសសម្រាប់សេរ៉ាឡេអូន ("SCSL") និងតុលាការ ICC[362]។

នៅដំណាក់កាលបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានវិភាគភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អ.វ.ត.ក. ដោយមានការយោងទៅគោលការណ៍នីត្យានុកូលភាព ដែលបានបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជា ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[363]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា បើទោះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ដែលផ្តល់ឱ្យ អ.វ.ត.ក. នូវ*យុត្តាធិការដែលសន្មតទុកជាមុន*យ៉ាងណាក្តី ក៏ការណ៍នេះមិនគ្រប់គ្រាន់ក្នុងការសម្រេចដាក់ពិរុទ្ធភាពនោះដែរ[364]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ចាំបាច់ត្រូវសម្រេចលើនិយមន័យដែលអាចអនុវត្តបានរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "នៅពេលដែលមានការប្រព្រឹត្តិអំពើឧក្រិដ្ឋត្រូវបានចោទប្រកាន់" ដោយបានផ្តល់សំអាងហេតុថា*យុត្តាធិការដែលសន្មតទុកជាមុន*របស់ អ.វ.ត.ក. អាចមិនត្រូវបានបកស្រាយថា ជាវិសោធនកម្មច្បាប់ដែលមានអានុភាពប្រតិសកម្មចំពោះនិយមន័យ នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. នោះឡើយ[365]។ ដោយបន្ថែមទៅលើឯកសារសំអាងផ្លូវច្បាប់ ដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ បានពិចារណាលើ៖

i. ប្រភពទាក់ទងនឹងសេចក្តីប្រកាសទីក្រុង St. Petersburg ឆ្នាំ១៨៦៨
ii. សៀវភៅនិពន្ធដោយ Hugo Grotius
iii. អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៨៩៩ និង ១៩០៧
iv. សេចក្តីប្រកាសឆ្នាំ១៩១៥ របស់បារាំង អង់គ្លេស និងរុស្ស៊ី ទាក់ទងនឹងការសម្លាប់រង្គាលលើជនជាតិអាមេនី
v. គណៈកម្មការទទួលបន្ទុកដោះស្រាយការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងការដាក់ទណ្ឌកម្ម ឆ្នាំ១៩១៩
vi. រឿងក្តីរបស់តុលាការយោធា Nuremberg ដែលបានបង្កើតឡើងក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង
vii. អនុសញ្ញាសន្តិភាពក្រោយសង្គ្រាមលោកលើកទី២ និង
viii. ការជ្រើសរើសបន្ថែមទៀត នៃការដាកក់ពិរុទ្ធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងតុលាការជាតិ[366]។

នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលអាចអនុវត្តបាននៅប្រទេសកម្ពុជា ក្នុងអំឡុងរយៈពេលដែលជាក់ព័ន្ធត្រូវបានជនជាប់ចោទ អាចដឹងជាមុនបានគ្រប់គ្រាន់ថាមានច្បាប់ចែង និងជាបទល្មើស ដែលពួកគេអាចត្រូវ

[362] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៨៥-២៨៩។
[363] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៩៨-១១៦។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានលក្ខណៈគ្រប់គ្រាន់ចំពោះជនជាប់ចោទក្នុងការដឹងថាជាបទល្មើស និងមានច្បាប់ចែង ដែលពួកគេអាចត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋបែបនោះ ។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៣១-១៣៣។
[364] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៩៩។
[365] ដូចខាងលើ កថាខណ្ឌ ១០០។
[366] ដូចខាងលើ កថាខណ្ឌ ១០១-១០៣។

បានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មបែបអស់ទាំងនោះ[367]។ ចំពោះគោលបំណងនៃភាពអាចដឹងជាមុនថាមានច្បាប់ចែង និងជាបទល្មើស អង្គបុរេជំនុំជម្រះបានសម្រេចថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមាននៅក្នុងគោលការណ៍ Nuremberg គឺមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ក្នុងរយៈកាលឆ្នាំ១៩៧៥ ដល់ ១៩៧៩ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[368]។ ក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា គណៈកម្មការច្បាប់អន្តរជាតិ មិនអាចអនុម័តព្រមព្រៀងលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងរយៈពេលពីឆ្នាំ១៩៥៤ ដល់ ១៩៩៦ បានទេ[369]។ យ៉ាងណាមិញ ការណ៍នេះមិនមានន័យថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនទាន់មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលពាក់ព័ន្ធនោះឡើយ[370]។ អង្គបុរេជំនុំជម្រះបានពិចារណាថា បើទោះបីជាយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ "បានដើរតួនាទីយ៉ាងច្បាស់ ក្នុងការកំណត់ពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមានចែងនៅក្នុងគោលការណ៍ Nuremberg" យ៉ាងណាក្តី ក៏ការណ៍នេះមិនមានន័យថា និយមន័យក្រោយសង្គ្រាមលោកលើកទី២ មិនច្បាស់លាស់គ្រប់គ្រាន់នោះដែរ[371]។

ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានធ្វើការកត់សម្គាល់ជាពិសេសទៅលើ ការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទី២ ដែលបានធ្វើឡើងក្នុងទីក្រុង Nuremberg និង តូក្យូ នៅក្នុងការសម្រេចរបស់ខ្លួន ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលថាជនត្រូវចោទមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹងជាមុនថា មានការហាមឃាត់របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[372]។

ក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតទាំងពីររូប បានសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើកលែងតែការរំលោភសេពសន្ថវៈ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា ទោះបីជាយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ដែលបានបង្កើតតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មិនកំណត់កាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. យ៉ាងណាក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការពឹងផ្អែកលើសេចក្តីសម្រេចទាំងអស់នោះ ក្នុងកម្រិតដែលសេចក្តីសម្រេចរបស់ពួកគាត់លើធាតុផ្សំឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលឆ្លុះបញ្ចាំងពីច្បាប់ ដែលវាមានអត្ថិភាពក្នុងអំឡុងពេលយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក.[373]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុម័តសំអាងហេតុដូចគ្នានេះដែរ នៅក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤[374]។ សហចៅក្រមស៊ើបអង្កេតជាតិមិនបានលើកអំពីភាពអាចអនុវត្តបាន ឬ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួន នៅក្នុងរឿងក្តីទាំងអស់នេះទេ[375]។

### ២.៤.២. ធាតុផ្សំ *ទូទៅ*

ធាតុផ្សំ "*ទូទៅ*" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបញ្ជាក់នៅក្នុងលិខិតុបករណ៍ច្បាប់ជាតិ និងអន្តរជាតិក្រោយសង្គ្រាមលោកជាច្រើន ដូច្នេះត្រឹមឆ្នាំ១៩៧៥ ពួកវាបង្កើតបានជាផ្នែកមួយនៃច្បាប់

---

367 ដូចខាងលើ កថាខណ្ឌ ១២៥-១៣៣។
368 ដូចខាងលើ កថាខណ្ឌ ១៣៣។
369 ដូចខាងលើ កថាខណ្ឌ ១៣១។
370 ដូចខាងលើ កថាខណ្ឌ ១៣១-១៣២។
371 ដូចខាងលើ កថាខណ្ឌ ១៣២-១៣៣។
372 សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៦។
373 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៧។
374 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៨។
375 សម្រាប់ព័ត៌មានបន្ថែមស្តីពីដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សូមមើលផងដែរ *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.៣.២.៧, ៥.៣.៣.៦.២, ៥.៣.៣.៧.៣.

ទំនៀមទម្លាប់អន្តរជាតិ[376]។ ដើម្បីបង្កើតបានជាបទល្មើសមួយក្នុងចំណោមបទល្មើសនានា ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ធាតុផ្សំ *ទូទៅ*ខាងក្រោមត្រូវបានបង្ហាញ៖

i. ការវាយប្រហារជាទូទៅ និងមានការរៀបចំជាប្រព័ន្ធ
ii. សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល
iii. ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា
iv. ចំណងទាក់ទងរវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារ និង
v. ការដឹងឮដែលត្រូវការរបស់ជនជាប់ចោទ ទាក់ទងនឹងធាតុផ្សំ *ទូទៅ*[377]។

នៅ អ.វ.ត.ក. មិនមានលក្ខខណ្ឌតម្រូវ *ទូទៅ*ដើម្បីបញ្ជាក់ពី "ផែនការ ឬគោលនយោបាយ" របស់រដ្ឋ ឬអង្គការនោះទេ[378]។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានសន្និដ្ឋានយ៉ាងស៊ីចង្វាក់គ្នាថា ពុំមានធាតុផ្សំបែបនេះបង្ហាញនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ គិតត្រឹមឆ្នាំ១៩៧៥[379]។ ទោះជាយ៉ាងណា អត្ថិភាពនៃផែនការ ឬគោលនយោបាយបែបនេះអាចពាក់ព័ន្ធទៅនឹងការបង្ហាញអំពីលក្ខណៈនៃការវាយប្រហារជាទូទៅ និងមានការរៀបចំជាប្រព័ន្ធ[380]។

### ២.៤.២.១. "ការវាយប្រហារជាទូទៅ និងមានការរៀបចំជាប្រព័ន្ធ"

យុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានបកស្រាយធាតុផ្សំ "ការវាយប្រហារ" ថាមានន័យថាជា "ដំណើរការនៃអំពើ" ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តនូវអំពើហិង្សាច្រើន[381]។ ទោះបីជាការប្រើកម្លាំងប្រដាប់អាវុធ អាចបង្ហាញពីអត្ថិភាពនៃការវាយប្រហារដែលមានលក្ខណៈគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏ទម្រង់នៃការធ្វើបាបផ្សេងទៀតលើប្រជាជនស៊ីវិល អាចមានលក្ខណៈគ្រប់គ្រាន់ រួមទាំងអំពើទាំងឡាយដែលមាននៅក្នុងបទល្មើសជាមូលដ្ឋានក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក.[382]។

គឺ *ការវាយប្រហារ* ដែលត្រូវតែមានលក្ខណៈទូទៅ និងជាប្រព័ន្ធ (មិនមែនអំពើដាច់ដោយឡែកដែលជនជាប់ចោទទទួលខុសត្រូវនោះទេ)[383]។ លក្ខណៈទូទៅឬជាប្រព័ន្ធ គឺជាលក្ខខណ្ឌតម្រូវបែបជ្រើស

---

[376] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៩៣។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៦៤។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៦-១៩២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៨១-៣១៩។

[377] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១០៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០១។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦០-៦៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦-៧២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៤-៥០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៩-៤៥។

[378] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៣២។

[379] ដូចខាងលើ។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០១។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦០-៦៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៦-៧២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៤-៥០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៩-៤៥។

[380] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៣២។

[381] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩៨។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៩។

[382] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩៨។

[383] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០១។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦១។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤០។

រើសនៅ អ.វ.ត.ក. គឺៈ ការវាយប្រហារត្រូវតែមានលក្ខណៈទូទៅ *ឬ* ជាប្រព័ន្ធ[384]។ ជាគោលការណ៍ អំពើតែមួយអាចមានលក្ខណៈគ្រប់គ្រាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[385]។

ការវាយប្រហារមួយអាចត្រូវបានចាត់ទុកថា "មានលក្ខណៈទូទៅ" ផ្អែកលើលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន[386]។ ការវាយប្រហារជាទូទៅអាចសំដៅទៅលើទាំង "អានុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ទាំងអានុភាពនៃអំពើអមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ"[387]។ "ការវាយប្រហារ "ជាប្រព័ន្ធ" ត្រូវបានកំណត់លក្ខណៈដោយអំពើហិង្សាដែលមានការរៀបចំ ហើយអំពើនោះមិនមែនកើតឡើងដោយចៃដន្យនោះទេ[388]។

សញ្ញាណនៃ "ការវាយប្រហារលើប្រជាជនស៊ីវិល" សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែចែកឱ្យដាច់ពីសញ្ញាណដាច់ដោយឡែកនៃជម្លោះប្រដាប់អាវុធ[389]។ "ការវាយប្រហារ" សំដៅទៅលើប្រជាជនស៊ីវិល "អាចកើតឡើងមុន អាចអូសបន្លាយពេលយូរឬបន្តកើតមានរហូតនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ដោយមិនចាំបាច់ថា ការវាយប្រហារនេះជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធនោះឡើយ"[390]។

### ២.៤.២.២. "សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល"

លក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារត្រូវបានសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល មានន័យថា ប្រជាជនស៊ីវិលនោះត្រូវតែជាគោលដៅចម្បង មិនមែនជាគោលដៅនៃការវាយប្រហារដោយចៃដន្យនោះទេ[391]។ មិនចាំបាច់មានការបង្ហាញថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រពាក់ព័ន្ធណាមួយ ដែលមានការវាយប្រហារ ទើបចាត់ទុកថាជាគោលដៅនៃការវាយប្រហារនោះឡើយ[392]។ វាមានលក្ខណៈគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថា "បុគ្គលមួយចំនួន" ត្រូវបានកំណត់ថាជាគោលដៅនៃការវាយប្រហារ ឬបុគ្គលទាំងឡាយត្រូវបានកំណត់តាមវិធីដែលការវាយប្រហារមានគោលដៅប្រឆាំងទៅលើ "ប្រជាជនស៊ីវិល" មិនមែនមានគោលដៅប្រឆាំងទៅលើបុគ្គលមួយចំនួនដែលបានកំណត់ និងត្រូវបានជ្រើសរើសខ្លះៗនោះទេ[393]។ ជនរងគ្រោះមិនចាំបាច់ជាប់ទាក់ទងជាមួយក្រុមជាក់លាក់ណាមួយទេ[394]។

"ប្រជាជនស៊ីវិល" នៅក្នុងបរិបទនេះ រួមបញ្ចូលបុគ្គលទាំងអស់ ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬម្យ៉ាងវិញទៀត ត្រូវបានទទួលស្គាល់ថាជាយុទ្ធជន[395]។ ទាហាន *ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* មិនមានលក្ខណៈគ្រប់គ្រាន់ជា "ជនស៊ីវិល" សម្រាប់គោលបំណងនៃមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. នោះទេ[396]។ ទោះបីជាមានលក្ខខណ្ឌតម្រូវ *ទូទៅ* ក្នុងការបញ្ជាក់ថា *ការវាយប្រហារ* គឺប្រឆាំងទៅលើ

---

[384] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០០។
[385] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៩។
[386] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០០។
[387] ដូចខាងលើ។
[388] ដូចខាងលើ។
[389] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៧៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩៩។
[390] ដូចខាងលើ។
[391] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០៥-៣១១។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤១។
[392] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០៣។
[393] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨២។
[394] ដូចខាងលើ កថាខណ្ឌ ១៨៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១២។
[395] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៧។
[396] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៣៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣០៤។

“ប្រជាជនស៊ីវិល” ក៏ដោយ ក៏លក្ខខណ្ឌនេះមិនចាំបាច់តម្រូវឱ្យមានការបញ្ជាក់ភ័ស្តុតាងថា ជនរងគ្រោះម្នាក់ៗនៃឧក្រិដ្ឋកម្មជាមូលដ្ឋាននោះ គឺជាជនស៊ីវិលនោះដែរ[397]។ ដូច្នេះ ទាហាន *ដែលបោះបង់សមត្ថភាពប្រយុទ្ធ* អាចជាជនរងគ្រោះពិតប្រាកដ នៃអំពើដែលអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[398]។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គិតត្រឹមឆ្នាំ១៩៧៥ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន មិនអាចចាត់ទុកជា “ការវាយប្រហារទៅលើប្រជាជនស៊ីវិលនោះទេ” យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុថា សមាជិកនៃអង្គភាពប្រដាប់អាវុធមិនត្រូវបានទទួលឋានៈជាជនស៊ីវិលនោះទេ ដោយផ្អែកលើអង្គហេតុដែលថាពួកគេ “មិនកាន់អាវុធ ឬមិនបានចូលរួមនៅក្នុងការប្រយុទ្ធ នៅពេលដែលមានការប្រព្រឹត្តិបទឧក្រិដ្ឋ”។ អង្គជំនុំជម្រះបដិសេធអំណះអំណាងដែលថា ការការពារដែលផ្តល់ឱ្យដោយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលកងកម្លាំងប្រដាប់អាវុធក្នុងស្រុក។ ទោះបីជាការបកស្រាយបែបនេះ “អាចចាត់ទុកថាជាការប្រសើរក្តី” អង្គជំនុំជម្រះបានសន្និដ្ឋានថា វាមិនត្រូវបានគាំទ្រដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ នោះទេ[399]។

យ៉ាងណាមិញ ក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន គឺជាការវាយប្រហារប្រឆាំងលើប្រជាជនស៊ីវិល ក្នុងករណីដែលកងកម្លាំងទាំងអស់នោះតាមពិតមិនមានសម្ព័ន្ធភាព ឬផ្តល់ការគាំទ្រពាក់ព័ន្ធទៅខាងកងទ័ពប្រឆាំង[400]។ គាត់ពិចារណាថា គោលបំណងនៃច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនអាចត្រូវបានកំណត់ថាជា ការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដែលបានប្រព្រឹត្តជាទ្រង់ទ្រាយធំ ប្រឆាំងនឹងបុគ្គលនានា រួមបញ្ចូលទាំងប្រជាជនរបស់រដ្ឋខ្លួនឯងផ្ទាល់ដែលពុំត្រូវបានការពារដោយច្បាប់ និងទំនៀមទម្លាប់សង្គ្រាមដើម្បីមានស្រាប់នោះទេ[401]។ ហេតុដូច្នេះ គាត់យល់ឃើញថា “ប្រជាជនស៊ីវិល” នៅក្នុងលក្ខខណ្ឌតម្រូវ *ទូទៅ* នៃមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ត្រូវតែកំណត់ថាជាប្រជាជនទាំងមូលនៃប្រទេសណាមួយជាក់លាក់[402]។

ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សំអាងហេតុថា វាត្រូវបានប្រមើលមើលយ៉ាងគ្រប់គ្រាន់បានថា នៅឆ្នាំ១៩៧៥ ការប្រព្រឹត្តអំពើរំលោភបំពានសិទ្ធិមនុស្សជាទ្រង់ទ្រាយធំដោយរដ្ឋ ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបាន[403]។ ការដកកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋខ្លួនឯងផ្ទាល់ ចេញពីការការពារប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងរារាំងដល់គោលបំណងរបស់ច្បាប់ និងបណ្តាលឱ្យមានលទ្ធផលមិនសមហេតុផល[404]។ ជាងនេះទៀត គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយតាមន័យចង្អៀតមិនរារាំងការបកស្រាយថា ការវាយប្រហារដោយរដ្ឋ ឬអង្គការ ទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន គឺជាការវាយប្រហារទៅលើប្រជាជនស៊ីវិលនោះទេ ក្នុងករណីដែលកងកម្លាំងទាំងអស់នោះ តាមពិតមិនមានសម្ព័ន្ធភាព ឬផ្តល់ការគាំទ្រពាក់ព័ន្ធទៅខាងកងទ័ពបដិបក្ខ[405]។

#### ២.៤.២.៣. “ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា”

[397] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៤០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១១

[398] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១១។

[399] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០៩។

[400] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការបកស្រាយអំពី “ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល” ក្នុងបរិបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងផ្ទាល់របស់រដ្ឋ ឬរបប ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D191/18 កថាខណ្ឌ ៦៩។

[401] ដូចខាងលើ កថាខណ្ឌ ៥៥។

[402] ដូចខាងលើ កថាខណ្ឌ ៥៥-៥៦, ៥៩។

[403] ដូចខាងលើ កថាខណ្ឌ ៦០-៦២។

[404] ដូចខាងលើ កថាខណ្ឌ ៦៣។

[405] ដូចខាងលើ កថាខណ្ឌ ៦៧-៦៨។

ការវាយប្រហារត្រូវតែប្រព្រឹត្តឡើង ដោយផ្អែកលើមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[406]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បើទោះបីជាការវាយប្រហារត្រូវតែផ្អែកលើមូលដ្ឋានមួយ ឬច្រើន ក្នុងចំណោមមូលដ្ឋាននានាដែលរៀបរាប់យ៉ាងណាក្តី ក៏ធាតុផ្សំនេះមិនចាំមានលក្ខណៈ "រើសអើង" នោះទេ[407]។ "លើមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា" ដែលជាលក្ខខណ្ឌតម្រូវ *ទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមានតម្លៃស្មើគ្នាទៅនឹងពាក្យពេចន៍ដែលប្រើក្នុងការកំណត់និយមន័យលក្ខខណ្ឌតម្រូវនៃការរើសអើង នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញនោះទេ[408]។ លក្ខខណ្ឌតម្រូវឱ្យមានមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា គឺជាផ្នែកមួយនៃធាតុផ្សំ *ទូទៅ* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមិនតម្រូវឱ្យមានសម្រាប់ឧក្រិដ្ឋកម្មជាមូលដ្ឋាននីមួយៗនោះទេ[409]។

អំពើមួយត្រូវបានចាត់ទុកថាជាការរើសអើង នៅពេលដែលជនរងគ្រោះត្រូវបានកំណត់ជាគោលដៅ ដោយសារតែសមាជិកភាពរបស់ខ្លួន ឬសមាជិកភាពតាមការសន្មត់ នៅក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ[410]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ក្រុមដែលត្រូវបានកំណត់ជាគោលដៅនោះ "អាចត្រូវបានចារីកំណត់យ៉ាងទូលំទូលាយ ដូច្នេះ ក្រុមនេះអាចត្រូវបានកំណត់ក្នុងន័យអវិជ្ជមាន និងរួមបញ្ចូលអ្នកជាប់ពាក់ព័ន្ធជិតស្និទ្ធ ឬអ្នកគាំទ្រ"[411]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការកំណត់និយមន័យក្រុមគោលដៅនេះ គឺ "អាចយកមកអនុវត្តបានដូចគ្នានៅក្នុងការកំណត់និយមន័យនៃក្រុមជាក់លាក់ណាមួយ ដែលជាគោលដៅនៃការវាយប្រហារ"[412]។

ក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេត បានអនុវត្តតាមសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលសម្រេចថា វាមិនចាំបាច់បង្ហាញភស្តុតាងអំពីចេតនារើសអើងសម្រាប់គ្រប់ឧក្រិដ្ឋកម្មទាំងអស់ប្រឆាំងមនុស្សជាតិឡើយ។ ចេតនារើសអើងបែបនេះគឺគ្រាន់តែជាលក្ខខណ្ឌទាក់ទិននឹងឧក្រិដ្ឋកម្មការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ[413]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្តអនុវត្តសំអាងហេតុនេះ នៅក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤[414]។

### ២.៤.២.៤. ចំណងទាក់ទងរវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារ

ចំណងទាក់ទងរវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ សំដៅទៅលើប្រជាជនស៊ីវិលគឺជាលក្ខខណ្ឌតម្រូវ[415]។ អំពើរបស់ចារីផ្ទាល់ត្រូវតែជាផ្នែកមួយនៃការវាយប្រហារ

---

[406] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៤៤-៧៤៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៣-៣១៤។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៣។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤២។

[407] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៤៤-៧៤៩។

[408] ដូចខាងលើ កថាខណ្ឌ ៧៤៤។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៨។

[409] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៨។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤២។

[410] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៦-៣១៧

[411] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៧២។

[412] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៨៩។

[413] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៣។

[414] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤២។

[415] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៥៣-៧៥៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩០, ១៩៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៨។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៤។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅ

មានន័យថា តាមលក្ខណៈ ឬផលវិបាករបស់ពួកវា អំពើដែលជាបញ្ហាចោទនោះ ជាសត្យានុម័តត្រូវតែជាផ្នែកមួយនៃការវាយប្រហារ[416]។ ជាងនេះទៀត ក្នុងករណីដែលជនជាប់ចោទមិនមែនជាចារីផ្ទាល់ អំពើរបស់ពួកគេត្រូវតែបង្កើតបានជាផ្នែកមួយនៃការវាយប្រហារ[417]។

សូម្បីតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងមុន ក្រោយ ឬនៅឆ្ងាយពីការវាយប្រហារជាចម្បងលើប្រជាជនស៊ីវិលនោះ ក៏អាចនៅតែត្រូវបានពិចារណាថាគ្រប់គ្រាន់ក្នុងការបញ្ជាក់ធាតុផ្សំនេះដែរ ប្រសិនបើឧក្រិដ្ឋកម្មនោះមានទំនាក់ទំនងគ្នាគ្រប់គ្រាន់ទៅនឹងការវាយប្រហារនោះ[418]។ យ៉ាងណាមិញ ឧក្រិដ្ឋកម្មមិនអាចជាអំពើដាច់ដោយឡែកនោះទេ ពោលគឺឧក្រិដ្ឋកម្មមួយអាច "ចាត់ទុកថាជាអំពើដាច់ដោយឡែកបាននៅពេលដែលឧក្រិដ្ឋកម្មនោះនៅដាច់ឆ្ងាយពីការវាយប្រហារណាមួយ អាចនិយាយបានថា ឧក្រិដ្ឋកម្មនោះគឺជាផ្នែកមួយនៃការវាយប្រហារ ក្រោយពីបានពិចារណាលើបរិបទ និងកាលៈទេសៈដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើង"[419]។

### ២.៤.២.៥. ការដឹងឮដែលត្រូវការរបស់ជនជាប់ចោទ ទាក់ទងនឹងធាតុផ្សំ *ទូទៅ*

ជនជាប់ចោទត្រូវតែបានដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល និងដឹងថាអំពើរបស់ខ្លួនបង្កើតបានជាផ្នែកមួយនៃការវាយប្រហារនោះ[420]។ លក្ខខណ្ឌតម្រូវនៃការដឹងឮនេះផ្តោតការយកចិត្តទុកដាក់លើការដឹងឮរបស់ជនជាប់ចោទ បើទោះជាក្នុងកាលៈទេសៈនានាដែលពួកគេមិនមែនជាចារីផ្ទាល់ក៏ដោយ[421]។

ជនជាប់ចោទមិនចាំបាច់បានដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារនោះទេ[422]។ ភស្តុតាងអំពីការដឹងនេះអាស្រ័យលើអង្គហេតុនៃករណីជាក់លាក់នីមួយៗ។ លក្ខណៈដែលលក្ខខណ្ឌតម្រូវនៃការដឹងឮនេះអាចត្រូវបានបញ្ជាក់ភស្តុតាងយ៉ាងណានោះ អាចប្រែប្រួលតាមកាលៈទេសៈជាក់ស្តែង[423]។

### ២.៤.៦. ចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ

អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូង សហចៅក្រមស៊ើបអង្កេត បានសម្រេចយ៉ាងស៊ីចង្វាក់គ្នាថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់អន្តរជាតិ ចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ មិនតម្រូវឱ្យមានចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនោះទេ[424]។ ក្នុងសំណុំរឿង ០០១

ជំនុំជម្រះ) កថាខណ្ឌ ៧០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៣។

[416] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៥៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៨។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៣។

[417] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៥៤។

[418] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១៥។

[419] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៨។

[420] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៩។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៥។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៤។

[421] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១៦ សម្គាល់ជើងទំព័រ ៨៥៨។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៤។

[422] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៩។

[423] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣១៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១៩១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣១៩។

[424] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧២១។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣០១។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១៧៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី២៦ ខែតុលារ ឆ្នាំ ២០១១ ឯកសារ E95/8 កថាខណ្ឌ ៣៣។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកា

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធមិនទាមទារឱ្យមាននោះទេ (ទោះបីជាធម្មនុញ្ញ Nuremberg ឆ្នាំ១៩៤៥ តម្រូវឱ្យមានចំណងទាក់ទងនេះក៏ដោយ)[425]។ អង្គជំនុំជម្រះបានទទួលស្គាល់ថា តុលាការ ICTY បានយល់ឃើញថា សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានអត្ថិភាពដាច់ដោយឡែកពីសញ្ញាណនៃជម្លោះប្រដាប់អាវុធ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មុនឆ្នាំ១៩៧៥ ហើយលក្ខន្តិកៈតុលាការ ICTY, ICTR, SCSL និង ICC មិនតម្រូវឱ្យមានចំណងទាក់ទងនេះទេ[426]។ ជាងនេះទៀត ការសន្និដ្ឋានរបស់ ECtHR និងក្រុមអ្នកជំនាញសម្រាប់កម្ពុជា បានបង្ហាញថា មិនមានលក្ខខណ្ឌតម្រូវចំណងទាក់ទងនោះទេគិតត្រឹមឆ្នាំ១៩៧៥[427]។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់គាំទ្រការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គិតត្រឹមឆ្នាំ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លែងដាក់បញ្ចូលលក្ខខណ្ឌតម្រូវចំណងទាក់ទងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពទៀតហើយ[428]។

ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះបានអនុម័តយកគោលជំហរផ្ទុយពីនេះ ដោយសម្រេចថា ចំណងទាក់ទងបែបនេះត្រូវការនៅ អ.វ.ត.ក.។ អង្គបុរេជំនុំជម្រះបានវិភាគភ័ស្តុតាងនៃការអនុវត្តរបស់រដ្ឋមុន ក្នុងអំឡុងពេល និងក្រោយរយៈពេលយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. *ទស្សនៈច្បាប់* យុត្តិសាស្ត្ររបស់តុលាការ ICTY និងអនុសាសន៍របស់ ICL លើបញ្ហានេះ និងប្រភពនានាទាក់ទងនឹងប្រភពដើមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម[429]។

អង្គបុរេជំនុំជម្រះ ជាបឋម បានធ្វើការវិភាគបញ្ញត្តិនានាមុនឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាបុព្វកថានៃសេចក្តីប្រកាសនៅទីក្រុង St. Petersburg នាឆ្នាំ១៨៦៨ និង Martens Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៨៩៩ និងឆ្នាំ១៩០៧ "ដែលបានអំពាវនាវឱ្យមាន "ច្បាប់មនុស្សធម៌" ជាការការពារបន្ទាប់បន្សំបន្ថែមទៀត ប្រឆាំងនឹងអំពើដែលមិនត្រូវបានហាមឃាត់ជាក់លាក់ នៅក្នុងអត្ថបទនៃអនុសញ្ញាទីក្រុងឡាអេ នីមួយៗ ដែលផ្អែកជាសំខាន់ទៅលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម"[430]។

នៅក្នុងការវិភាគរបស់អង្គបុរេជំនុំជម្រះ អ្នករៀបរៀងសេចក្តីព្រាងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ ("IMT") "បានធានាឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ដើម្បីបញ្ចៀសការចោទប្រកាន់ដែលបណ្តាលឱ្យការផ្តន្ទាទោសចេញហួសឆ្ងាយពីអ្វីដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញា។ អាស្រ័យហេតុនេះ ចាប់ពីពេលដែលបង្កើតបញ្ញត្តិនេះមក ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ"[431]។ ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងបានលុបចោលចំណងទាក់ទងនេះ។ យ៉ាងណាមិញ "ករណីបន្តបន្ទាប់ដែលត្រូវបានយកមកជំនុំជម្រះ និងសម្រេចតាមច្បាប់របស់ក្រុមប្រឹក្សាចាប់ពីខែតុលា ឆ្នាំ១៩៤៦ រហូតដល់ខែ មេសា ឆ្នាំ១៩៤៩ មុនពេលមានយុត្តិសាស្ត្ររបស់តុលាការយោធា Nuremberg [...] នៅបន្តយកមកអនុវត្តដដែល"[432]។

អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា បើទោះបីជាអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨ ត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តជាឯកច្ឆន្ទយ៉ាងណាក៏ដោយ ក៏និយមន័យនៃ

---

សម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៦។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៥។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ឯកសារ D87/2/1.7/1 កថាខណ្ឌ ៧៨។

[425] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩១។

[426] ដូចខាងលើ កថាខណ្ឌ ២៩២។

[427] ដូចខាងលើ។

[428] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧២១។

[429] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៣៥-១៤៣, ៣០៣, ៣០៦។

[430] ដូចខាងលើ កថាខណ្ឌ ១៣៩។

[431] ដូចខាងលើ។

[432] ដូចខាងលើ កថាខណ្ឌ ១៤០។

អំពើប្រល័យពូជសាសន៍ដែលមាននៅក្នុងនោះ ដែលមិនបានបញ្ចូលលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ "ចេញឆ្ងាយពីលំនាំដើមរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើប្រល័យពូជសាសន៍ ដោយតម្រូវឱ្យមានចេតនាយ៉ាងពិសេសមួយ ដែលមិនមានចែងនៅក្នុងធម្មនុញ្ញតុលាការ IMT"[433]។ សេចក្តីព្រាងនិយមន័យរបស់ ILC អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពុំមានលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ នៅក្នុងសេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ១៩៥៤ មិនត្រូវបានទទួលយកដោយមហាសន្និបាតអង្គការសហប្រជាជាតិទេ[434]។

អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខន្តិកៈនៃអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ១៩៦៨ មិនបានឈានដល់កម្រិតនៃការទទួលយកមួយដើម្បីមានលក្ខណៈគ្រប់គ្រាន់ជាការអនុវត្តទូទៅឡើយ។ ជាងនេះទៀត ក្នុងឆ្នាំ១៩៦៨ "អ្នកតំណាងដែលបានចូលរួមអនុម័តអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ១៩៦៨ ត្រូវបានបែងចែកស្ទើរតែស្មើគ្នា រវាងអ្នកគាំទ្រមិនឱ្យបញ្ចូលចំណងពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធ និងអ្នកប្រឆាំងនឹងទង្វើបែបនេះ"។ អនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ១៩៦៨ ដែលមិនបានយោងលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងទៅនឹងជម្លោះ ត្រូវបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគី ដោយប្រទេសចំនួនតែ ១៨ ប៉ុណ្ណោះ ក្នុងចំណោមរដ្ឋសមាជិកចំនួន ១៣៤ របស់ អ.ស.ប. គិតត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងដោយរដ្ឋចំនួនមួយបន្ថែមទៀតប៉ុណ្ណោះ ក្នុងអំឡុងពេលយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. សរុបគឺមានរដ្ឋសមាជិកចំនួន ១៩ ក្នុងចំណោមរដ្ឋសមាជិកចំនួន ១៤៨[435]។

អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា អនុសញ្ញាអាប៉ាថេដ ឆ្នាំ១៩៧៤ កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអាប៉ាថេដ ដោយពុំមានលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងនឹងជម្លោះប្រដាប់អាវុធ។ វាត្រូវបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគីដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួនតែ ២៥ ប៉ុណ្ណោះ ក្នុងចំណោមរដ្ឋសមាជិកចំនួន ១៣៤ គិតត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងដោយរដ្ឋសមាជិកចំនួន ៥៧ ក្នុងចំណោមរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន ១៤៨ គិតត្រឹមពេលបិទបញ្ចប់យុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក.។ បើតាមអ្វីដែលអង្គបុរេជំនុំជម្រះអាចស្វែងរកបានគឺថា "មានឧទាហរណ៍មួយចំនួនតូចនៅក្នុងច្បាប់ជាតិ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់មានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនេះ"[436]។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលដែល ILC ជាថ្មីម្តងទៀតបានផ្តល់អនុសាសន៍ឱ្យអនុម័តនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមិនមានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ក្នុងឆ្នាំ១៩៨៤ នោះមក "ការពិភាក្សាដេញដោលក្នុងចំណោមអ្នកតំណាងរដ្ឋជាសមាជិកបង្ហាញឱ្យឃើញថា ទំនងជានឹងមានចរន្តនៃទស្សនៈរបស់រដ្ឋជាសមាជិកឱ្យដកចេញនូវលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធ"។ ទោះជាយ៉ាងណា មហាសន្និបាតអង្គការសហប្រជាជាតិមិនបានអនុម័តយកសេចក្តីព្រាងនិយមន័យនេះទេ[437]។

អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានលុបចោលលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធក្នុងលក្ខន្តិកៈតុលាការ ICTR ឆ្នាំ១៩៩៤ ក៏ដោយ ក៏ "ក្រុមប្រឹក្សានេះបានបញ្ចូលចំណុចនេះនៅក្នុងនិយមន័យដំបូងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានចងក្រងជាបញ្ញាមួយនៃច្បាប់អន្តរជាតិនៅក្នុងលក្ខន្តិកៈតុលាការ ICTY ឆ្នាំ១៩៩៣"។ ការខ្វែងយោបល់គ្នាទៅលើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅមាន រហូតដល់មានសន្និសីទដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងឆ្នាំ១៩៩៨[438]។

អង្គបុរេជំនុំជម្រះ "មិនអាចកំណត់បានពីដំណាក់កាលដែលមានបញ្ហាចន្លោះពីឆ្នាំ១៩៦៨ រហូតដល់ឆ្នាំ១៩៨៤ នៅពេលដែលដំណាក់កាលអន្តរកាល [ការដកលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងចេញ] បានកើតឡើង"នោះទេ។ អង្គបុរេបានសន្និដ្ឋានថា យោងតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់*

433 ដូចខាងលើ។
434 ដូចខាងលើ កថាខណ្ឌ ១៤១។
435 ដូចខាងលើ។
436 ដូចខាងលើ កថាខណ្ឌ ១៤២។
437 ដូចខាងលើ កថាខណ្ឌ ១៤៣។
438 ដូចខាងលើ។

*ជនជាប់ចោទ* (in dubio pro reo) ភាពមិនច្បាស់លាស់នេះ នឹងត្រូវដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ[439]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានសម្រេចថាមានលក្ខខណ្ឌតម្រូវនៃចំណងទាក់ទង។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា គាត់មិនជាប់កាតព្វកិច្ចតាមករណីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ត្រង់ចំណុចនេះនោះទេ ក្រោយពីបានធ្វើការវិភាគឯករាជ្យលើច្បាប់ទំនៀមទម្លាប់អន្តរជាតិរួចមក[440]។

ទោះបីជាគោលជំហរពីមុនរបស់ខ្លួន អង្គបុរេជំនុំជម្រះក្រោយមកបានអនុម័តយកទស្សនៈថា មិនចាំបាច់មានចំណងទាក់ទងនោះឡើយ[441]។ អង្គបុរេជំនុំជម្រះបានគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា យុត្តិសាស្ត្ររបស់ ECtHR ក៏ដូចជាច្បាប់ជាតិដែលបានអនុម័តមុនឆ្នាំ១៩៧៥ និងសេចក្តីសម្រេចរបស់តុលាការជាតិមួយចំនួន បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងជាមួយនឹងអំពើប្រព្រឹត្តដែលកើតឡើងមុនឆ្នាំ១៩៧៥ ដោយមិនមានចំណងទាក់ទង[442]។ នៅក្នុងសំអាងហេតុរបស់ខ្លួន អង្គបុរេជំនុំជម្រះបានយោងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ការដកចេញនូវលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងក្រោយឆ្នាំ១៩៤៥ "ស្របតាមទស្សនៈវិវឌ្ឍន៍ថ្មីៗដែលលើកឡើងថា ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺក្នុងគោលបំណងដើម្បីការពារមនុស្សជាតិពីការប្រព្រឹត្តអំពើឃោរឃៅ"[443]។

សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/០១ បានឯកភាពតាមសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនតម្រូវឱ្យមានចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ[444]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្តអនុវត្តតាមសំអាងហេតុនេះ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួនក្នុងសំណុំរឿង ០០៤/០២, ០០៣, និង ០០៤[445]។

### ២.៤.៣. ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយោងតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. តម្រូវឱ្យ "អំពើ" ជាមូលដ្ឋាន បានប្រព្រឹត្តក្នុងបរិបទនៃការវាយប្រហារសំដៅលើប្រជាជនស៊ីវិល[446]។ អំពើនីមួយៗក្នុងចំណោមអំពើជាមូលដ្ឋានទាំងអស់នេះ កើតឡើងពី*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត* ហើយធាតុផ្សំទាំងអស់នេះ ត្រូវបានបកស្រាយ និងអនុវត្តដោយសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ។ ផ្នែកខាងក្រោមនេះបង្ហាញពីនិយមន័យដែលបានបង្កើតឡើង នៃធាតុផ្សំគតិយុត្តិរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកពីគ្នានីមួយៗ។

#### ២.៤.៣.១. ការធ្វើមនុស្សឃាត

---

[439] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣១០។
[440] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ឯកសារ D87/2/1.7/1 កថាខណ្ឌ ៧៨។
[441] សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ឯកសារ D87/2/1.7/1/1/7 កថាខណ្ឌ ៦៣-៦៥។
[442] ដូចខាងលើ កថាខណ្ឌ ៥៨។
[443] ដូចខាងលើ កថាខណ្ឌ ៦៥។
[444] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៦។
[445] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៥។
[446] ច្បាប់ អ.វ.ត.ក. មាត្រា ៥។

ការធ្វើមនុស្សឃាតគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក.[447] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. ធាតុផ្សំសត្យានុម័ត៖ ចារីត្រូវតែបានបណ្តាលឱ្យមានការបាត់បង់ជីវិតជនរងគ្រោះ ដោយអំពើសកម្មឬអកម្ម។ អំពើសកម្មឬអកម្មត្រូវតែបានប្រព្រឹត្តឡើងដោយជនជាប់ចោទ ឬដោយបុគ្គលម្នាក់ ឬច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើសកម្មឬអកម្មនោះ[448]។ បន្ថែមលើនេះ ការរួមចំណែកនេះត្រូវមានលក្ខណៈពិតប្រាកដ[449]។ មិនមានលក្ខខណ្ឌតម្រូវឱ្យធ្វើការរកឱ្យឃើញសាកសពរបស់ជនរងគ្រោះដើម្បីបញ្ជាក់ពីការធ្វើមនុស្សឃាតនោះទេ[450]។ អង្គជំនុំជម្រះអាចពឹងផ្អែកលើភស្តុតាងកាលៈទេសៈក្នុងការធ្វើការសម្រេច ប្រសិនបើការទាញការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់នោះគឺថា ការបាត់បង់ជីវិតជនរងគ្រោះបណ្តាលមកពីអំពើសកម្មឬអកម្មរបស់ជនជាប់ចោទ ឬបុគ្គលម្នាក់(ច្រើន) ដែលជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌ[451]។ ទោះបីជាវាមិនចាំបាច់បញ្ជាក់ច្បាស់លាស់នូវចំនួនមនុស្សស្លាប់សរុប ឬពុំចាំបាច់បញ្ជាក់អត្តសញ្ញាណចារីផ្ទាល់ និងជនរងគ្រោះរបស់ពួកគេសម្រាប់ការសម្លាប់នីមួយៗយ៉ាងណាក៏ដោយ ក៏ហេតុការណ៍ជាក់លាក់នៃការសម្លាប់ត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ[452]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាសម្លាប់ ឬបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយដោយមានការដឹងសមស្រប់ថា អំពើសកម្មឬអកម្មនោះទំនងជាបណ្តាលឱ្យមានការស្លាប់[453]។ *ធាតុផ្សំអត្តនោម័ត*សម្រាប់ការធ្វើមនុស្សឃាតអាចត្រូវបានបំពេញតាមរយៈការបង្ហាញពីចេតនារបស់ជនជាប់ចោទ (ឬចេតនារបស់បុគ្គលដែលជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌ) ក្នុងការសម្លាប់ ឬចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយដោយមានការដឹងសមស្របថា អំពើសកម្មឬអកម្មនោះទំនងជាបណ្តាលឱ្យមានការស្លាប់ *(ចេតនាប្រយោល)*[454]។ អំពើមនុស្សឃាតគិតទុកជាមុនពុំតម្រូវនោះទេ[455]។

ការប្រព្រឹត្តិអំពើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *តាមរយៈអំពើអកម្ម* គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥[456]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ចំណុចនេះផ្អែកលើការអនុវត្តគោលការណ៍ទូទៅ ដែលដាក់ទោសព្រហ្មទណ្ឌចំពោះអំពើអកម្មដែលនាំឱ្យមានពិរុទ្ធក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ[457]។ អង្គជំនុំជម្រះសាលាដំបូងបានពង្រីកការអនុវត្តគោលការណ៍នេះ ចាប់ពីការទទួលខុសត្រូវជាលក្ខណៈបុគ្គល រហូតដល់ *ធាតុផ្សំសត្យានុម័ត*នៃការធ្វើមនុស្សឃាត ដោយលើកឡើងថា គោលការណ៍នេះអនុវត្តបានចំពោះអំពើអកម្មទាំងអស់ដែលនាំឱ្យមានពិរុទ្ធ[458]។

---

447 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩៣។
448 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៧។
449 ដូចខាងលើ។
450 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៤២០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៨។
451 ដូចខាងលើ។
452 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៤២០-៤២១។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៨។
453 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៦៨៧-៦៨៨, ៧១៨។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៦៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៦-៦២៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤១១-៤១២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៣៣។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨១។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៧។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៦។
454 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៤១០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៣០។
455 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៤២០-៤២១។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៣០។
456 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៣ សម្គាល់ជើងទំព័រ ២១៥៩។
457 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៧។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៣ សម្គាល់ជើងទំព័រ ២១៥៩។
458 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៧។

អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការវាយតម្លៃដោយខ្លួនឯងលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ហើយបានសន្និដ្ឋានថាវារួមបញ្ចូលសញ្ញាណនៃ *ចេតនាប្រយោល* សម្រាប់ការធ្វើមនុស្សឃាត[459]។ អង្គជំនុំជម្រះតុលាការកំពូលផ្អែកលើនិយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY *ក្នុងរឿងក្តី Stakić* អំពី *ចេតនាប្រយោល* ដូចខាងក្រោម៖

> ប្រសិនបើចារីបង្ហាញពីអកប្បកិរិយា ដែលបង្កឱ្យបាត់បង់ជីវិត ចារីមានចេតនាសម្លាប់ ដោយសារចារី "សម្របសម្រួលខ្លួនទទួលយក" ឬ "ស្រះស្រលទទួលយក" បើទោះបីទំនងជានឹងមានការស្លាប់ក៏ដោយ។ ដូច្នេះ ប្រសិនបើការសម្លាប់ត្រូវបានប្រព្រឹត្តឡើងដោយ "មិនអើពើអំពីតម្លៃជីវិតរបស់មនុស្ស" បើទោះបីអំពើនោះមានហានិភ័យតិចតួចយ៉ាងណាក៏ដោយ ក៏អាចកំណត់បានជាការសម្លាប់មនុស្សដោយចេតនា។ ការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាការធ្វើមនុស្សឃាតដោយប្រយោលនៅក្នុងសហរដ្ឋអាមេរិក អាចបំពេញតាមលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធច្បាប់ស៊ីវិលស្តីពី *ចេតនាប្រយោល* (dolus eventualis) ។ អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា គោលគំនិតនៃ *ចេតនាប្រយោល* (dolus eventualis) ពុំបានរួមបញ្ចូលនូវបទដ្ឋាននៃការធ្វេសប្រហែស ឬធ្វេសប្រហែសទាំងស្រុងឡើយ[460]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបែងចែកគោលការណ៍នៃ *ចេតនាប្រយោល* (dolus eventualis) ដែលរួមបញ្ចូលសញ្ញាណនៃ "ការបង្ហាញពីភាពមិនអើពើ" ដាច់ដោយឡែកពីគោលការណ៍នៃការធ្វេសប្រហែស (*Recklessness*) ដែលពាក់ព័ន្ធជាមួយនឹង "ការសន្និដ្ឋានអំពីចេតនា"[461]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលឯកភាពថា លក្ខណៈវិនិច្ឆ័យភស្តុតាងសម្រាប់គោលការណ៍ទាំងពីរនេះទំនងជាមានលក្ខណៈដូចគ្នា[462]។ អង្គជំនុំជម្រះបន្តពិចារណាលើវិធីសាស្ត្រមួយចំនួនចំពោះ *ចេតនាប្រយោល* នៅក្នុងយុត្តិសាស្ត្រផ្សេងៗ មុនពេលសន្និដ្ឋានថា *ធាតុផ្សំអត្តនោម័ត* នៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលវាមានអត្ថិភាពក្នុងឆ្នាំ១៩៧៥ នោះ ត្រូវតែកំណត់និយមន័យក្នុងន័យទូលាយដើម្បីរួមបញ្ចូល *ចេតនាប្រយោល*[463]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់យុត្តាធិការនេះ[464]។ អង្គជំនុំជម្រះបានបដិសេធនិយមន័យ *ធាតុផ្សំអត្តនោម័ត*របស់លក្ខន្តិកៈទីក្រុងរ៉ូម សម្រាប់ការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដែលនៅក្នុងនោះ "ការដឹងឮ" មានន័យថា "ការដឹងថាព្រឹត្តិការណ៍កើតមានឡើង ឬផលវិបាកនឹងកើតមាននៅក្នុងពេលវេលាធម្មតានៃព្រឹត្តិការណ៍")។ អង្គជំនុំជម្រះបានពិចារណាថា លក្ខន្តិកៈទីក្រុងរ៉ូម ពុំចងភ្ជាប់កាតព្វកិច្ចចំពោះច្បាប់នៅ អ.វ.ត.ក. ទេ ហើយដូច្នេះ គោលការណ៍នៃ *ច្បាប់ស្រាលជាង* ពុំអាចអនុវត្តដើម្បីឱ្យជនជាប់ចោទទទួលបានប្រយោជន៍ ពីការអនុវត្តលក្ខន្តិកៈទីក្រុងរ៉ូមបានឡើយ[465]។ អង្គជំនុំជម្រះបានសម្រេចថា បទដ្ឋាននេះត្រូវបានបំពេញ នៅពេលដែលអាជ្ញាធរកំណត់លក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារនៅក្នុងការដ្ឋាន "ដោយមានការដឹងថា ប្រជាជនទំនងជាឈានទៅរកការស្លាប់ *ឬ* ដោយទទួលយកនូវភវនីយភាពនៃផលវិបាកនៃការស្លាប់នោះ"[466]។

#### ២.៤.៣.២. ការសម្លាប់រង្គាល

[459] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣៨៧-៤១០។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៣៥-៦៥០។
[460] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣៩០។
[461] ដូចខាងលើ កថាខណ្ឌ ៣៩១។
[462] ដូចខាងលើ។
[463] ដូចខាងលើ កថាខណ្ឌ ៣៩២-៤១០។
[464] ដូចខាងលើ កថាខណ្ឌ ៦៨៧-៦៨៨។
[465] ដូចខាងលើ កថាខណ្ឌ ៦៨៩-៦៩០។
[466] ដូចខាងលើ កថាខណ្ឌ ៧១៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ១១៤៥។

បទសម្លាប់រង្គាលគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋានដែលអាចអនុវត្តបាននៅ អ.វ.ត.ក.[467] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបានបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ តាមរយៈអំពើសកម្ម អំពើអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ[468]។ ពុំតម្រូវឱ្យមានចំនួនជនរងគ្រោះក្នុងកម្រិតអប្បបរមានោះទេ ហើយកត្តាមួយចំនួនមានភាពជាក់ព័ន្ធក្នុងការបង្ហាញអំពីលក្ខខណ្ឌតម្រូវនៃទំហំនោះ រួមមានពេលវេលា ទីកន្លែងនៃការសម្លាប់ និងការជ្រើសរើសជនរងគ្រោះ[469]។ បន្ថែមលើនេះ ការសម្លាប់នៅក្នុងហេតុការណ៍ដាច់ដោយឡែកពីគ្នា អាចត្រូវបានបង្ហាញដើម្បីបំពេញធាតុផ្សំទំហំ ប៉ុន្តែហេតុការណ៍ទាំងនោះចាំបាច់ត្រូវតែជាផ្នែកមួយនៃប្រតិបត្តិការតែមួយ[470]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាដើម្បីសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ[471]។ *ធាតុផ្សំអត្តនោម័ត* មានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ[472]។ ផ្ទុយពីឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត សញ្ញាណនៃ*ចេតនាប្រយោល*មិនបំពេញ*ធាតុផ្សំអត្តនោម័ត*សម្រាប់ឧក្រិដ្ឋកម្មនេះទេ[473]។ ចេតនាក្នុងការបង្កើតលក្ខខណ្ឌនៃការរស់នៅ ដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សជាទ្រង់ទ្រាយធំមានលក្ខណៈគ្រប់គ្រាន់ មិនមានលក្ខខណ្ឌតម្រូវក្នុងការបង្ហាញថា លក្ខខណ្ឌទាំងអស់នេះនឹងនាំឱ្យមានការស្លាប់មនុស្សទាំងអស់ *មិនអាចចៀសផុតបាន*នោះឡើយ[474]។

### ២.៤.៣. ការធ្វើឱ្យទៅជាទាសករ

បទឧក្រិដ្ឋនៃការធ្វើឱ្យទៅជាទាសករគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅ អ.វ.ត.ក.[475] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបានប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស[476]។ តម្រូវឱ្យមានភស្តុតាងសត្យានុម័តក្នុងការបង្ហាញអវត្តមាននៃជម្រើស និងការព្រមព្រៀង[477]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាប្រើអំណាចនោះលើមនុស្ស[478]។

467 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៦៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៣៤។
468 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៥។
469 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៧៧៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៥។
470 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៦។
471 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៧៧៧-៧៧៨។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥២២។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៣៨។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៧។
472 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៧។
473 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥២០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៧។
474 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥២០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៥៨។
475 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៦១-១៦២។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៦១។
476 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៥២-១៥៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៦២។
477 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៦៦។
478 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៥២។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៤៥។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៨។

ទោះបីជាមានស្ថានភាពតិចតួចនៃករណីមានអាសន្ន ឬគ្រោះមហន្តរាយ ដែលមនុស្សអាចត្រូវបានបង្ខំឱ្យធ្វើការយ៉ាងណាក៏ដោយ យោងតាមអង្គជំនុំជម្រះសាលាដំបូង "ប្រសិនបើលក្ខខណ្ឌនានាហួសពីការងារត្រឹមត្រូវតាមច្បាប់ និងរួមបញ្ចូលនូវការប្រើប្រាស់អំណាចណាមួយឬទាំងអស់ ក្នុងនាមជាម្ចាស់លើមនុស្ស អំពើបែបនេះបង្កើតបានជាការធ្វើឱ្យទៅជាទាសករ ដូច្នេះមិនមានយុត្តិកម្មឡើយ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ"[479]។

### ២.៤.៣.៤. ការនិរទេស

បទឧក្រិដ្ឋនៃការនិរទេសគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅ អ.វ.ត.ក.[480] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. *ធាតុផ្សំសម្ភារៈ*៖ មានលក្ខខណ្ឌតម្រូវចំនួនបួន៖
- ការផ្លាស់ទីលំនៅមនុស្សដោយបង្ខំតាមរយៈការបណ្តេញចេញ ឬអំពើបង្ខិតបង្ខំផ្សេងៗទៀត
- ពីតំបន់ដែលពួកគេកំពុងមានវត្តមានដោយស្របច្បាប់
- ឱ្យឆ្លងកាត់ព្រំដែន
- ដោយមិនមានមូលដ្ឋានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ[481]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាក្នុងការផ្លាស់ទីលំនៅជនរងគ្រោះដោយបង្ខំឱ្យឆ្លងកាត់ព្រំដែនប្រទេសមួយ[482]។ ចេតនាក្នុងការផ្លាស់ទីលំនៅបុគ្គលឆ្លងកាត់ព្រំដែន មិនចាំបាច់ជាអចិន្ត្រៃយ៍ទេ[483]។ ភស្តុតាងបង្ហាញពីចេតនាក្នុងការនិរទេសមនុស្សនៃក្រុមជាតិសាសន៍ណាមួយ អាចបង្ហាញអំពីចេតនាក្នុងការនិរទេសមនុស្សពីក្រុមនេះតាមតំបន់[484]។

មានកាលៈទេសៈតិចតួចនៅក្នុងច្បាប់អន្តរជាតិ ដែលអនុញ្ញាតឱ្យមានការផ្លាស់ទីមនុស្សដោយពុំស្ម័គ្រចិត្ត ដូចជា ការផ្លាស់ទីមនុស្សដើម្បីសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ ឬដោយសារហេតុផលយោធាចាំបាច់[485]។ មិនមានលក្ខខណ្ឌតម្រូវចាំបាច់ត្រូវបង្ហាញឋានៈផ្លូវច្បាប់របស់ជនរងគ្រោះឡើយ[486]។ ការបង្ហាញពីអវត្តមានជម្រើសពិតប្រាកដអាចត្រូវបានធ្វើឡើងតាមរយៈ ការបង្ខំខាងរាងកាយ ការគំរាម ការភ័យខ្លាចដោយអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំខ្លួន ការគាបសង្កត់ផ្លូវចិត្ត[487]។ មិនមានការកំណត់ចំនួនតួលេខដើម្បីបំពេញធាតុផ្សំនៃការនិរទេសឡើយ[488]។

ការនិរទេសតម្រូវឱ្យមានការផ្លាស់ទីឆ្លងកាត់ព្រំដែន*ប្រទេស*មួយ[489]។ ចំពោះភាពខុសគ្នារវាងប្រភេទទាំងពីរនៃការផ្លាស់ទីដោយបង្ខំ ពោលគឺ ការនិរទេស និងការផ្លាស់ទីលំនៅដោយបង្ខំ អ.វ.ត.ក. អនុវត្តតាមនិយមន័យគោលនៃការនិរទេស នៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិតួបនីយកម្ម គឺជាការផ្លាស់ទីលំនៅដោយបង្ខំនៃមនុស្សដែលទទួលបានការការពារ ចេញពីទីកន្លែងមួយដែលពួកគេកំពុងរស់នៅដោយស្របច្បាប់ ឆ្លងកាត់ព្រំដែនអន្តរជាតិ*តាមព្រឹត្តិហេតុ* ឬ*តាមផ្លូវច្បាប់*[490]។

---

[479] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៦៩។
[480] ដូចខាងលើ កថាខណ្ឌ ៦៧២។
[481] ដូចខាងលើ កថាខណ្ឌ ៦៧៤។
[482] ដូចខាងលើ កថាខណ្ឌ ៦៨៦។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៤៩។
[483] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៨៦។
[484] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៨៦១។
[485] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៨៣។
[486] ដូចខាងលើ កថាខណ្ឌ ៦៧៧។
[487] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៩៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៨២។
[488] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៨៥២។
[489] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៨១។
[490] ដូចខាងលើ កថាខណ្ឌ ៦៨១។

### ២.៤.៣.៥. ការដាក់ក្នុងមន្ទីរឃុំឃាំង

បទឧក្រិដ្ឋនៃការដាក់ក្នុងមន្ទីរឃុំឃាំងគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅ អ.វ.ត.ក.[491] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. *ធាតុផ្សំសន្យានុម័ត*៖ ចារីត្រូវតែបានដកហូតសេរីភាពបុគ្គលតាមទំនើងចិត្ត ដោយពុំមានដំណើរការច្បាប់ត្រឹមត្រូវ[492]។ ប្រសិនបើការដកហូតសេរីភាពដំបូង ត្រូវបានផ្តល់យុត្តិកម្មដោយមូលដ្ឋានគតិយុត្តិ វាអាចក្លាយជាអំពើតាមទំនើងចិត្ត ប្រសិនបើមូលដ្ឋានស្របច្បាប់លែងមានអត្ថិភាព[493]។
ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាដកហូតសេរីភាពបុគ្គលតាមទំនើងចិត្ត ឬចារីបានប្រព្រឹត្តដោយដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឱ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល[494]។

### ២.៤.៣.៦. ការធ្វើទារុណកម្ម

បទឧក្រិដ្ឋនៃការធ្វើទារុណកម្មគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅ អ.វ.ត.ក.[495] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. *ធាតុផ្សំសន្យានុម័ត*៖ ចារីត្រូវតែបានបណ្តាលឱ្យមានការឈឺចាប់ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរ មិនចំពោះថាតើផ្នែករាងកាយឬស្មារតីនោះទេ ដោយឬតាមការញុះញង់ពីមន្ត្រីសាធារណៈ ក្នុងគោលបំណងដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ។ ធាតុផ្សំសត្យានុម័តនៃការបណ្តាលឱ្យមានការរងទុក្ខ ឬការឈឺចាប់ធ្ងន់ធ្ងរ ត្រូវបានបង្ហាញដោយលក្ខណៈវិនិច្ឆ័យសត្យានុម័ត ដូចជាភាពធ្ងន់ធ្ងរនៃព្យសនកម្ម ដែលបានបង្កឡើង លក្ខណៈនិងគោលបំណងនៃព្យសនកម្ម និងដោយលក្ខណៈវិនិច្ឆ័យអត្តនោម័ត ដែលរួមមានលក្ខណៈរូបរាងកាយឬផ្លូវចិត្តរបស់ជនរងគ្រោះ និងផលប៉ះពាល់នៃការប្រព្រឹត្តិ[496]។ ទោះបីជាការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយចំនួន រួមបញ្ចូលការឈឺចាប់ *ធ្ងន់ធ្ងរ* ដល់រាងកាយ ឬស្មារតី បទល្មើសនៃការធ្វើទារុណកម្មទាមទារឱ្យមានការឈឺចាប់ *ធ្ងន់ធ្ងរ* ដល់រាងកាយ និងស្មារតី[497]។ ធាតុផ្សំសត្យានុម័តអាចត្រូវបានបង្ហាញតាមរយៈអំពើអកម្មដែលនាំឱ្យមានពិរុទ្ធភាព[498]។
ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាប្រព្រឹត្តអំពើលើបុគ្គលណាមួយ[499]។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា និយមន័យការធ្វើទារុណកម្មដែលមាននៅក្នុងសេចក្តីប្រកាសឆ្នាំ១៩៧៥ ស្តីពីទារុណកម្ម គឺជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ដល់

---

[491] ដូចខាងលើ កថាខណ្ឌ ៦៨៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩៣-២៩៦, ៣៤៧។
[492] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៨៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៤៨។
[493] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧៤ *ff*។
[494] ដូចខាងលើ កថាខណ្ឌ ៦៩៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៥០។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥០។
[495] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧០០។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៣-៦៧។
[496] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧០៣។
[497] ដូចខាងលើ កថាខណ្ឌ ៧០៥។
[498] ដូចខាងលើ កថាខណ្ឌ ៧០៨។
[499] សំណុំរឿង ០០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧១។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៥-៥៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥១។

ឆ្នាំ១៩៧៩[500]។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនមានការបង្ហាញណាមួយថា *ធាតុផ្សំសត្យានុម័ត* នៃឧក្រិដ្ឋកម្មអន្តរជាតិនៃការធ្វើទារុណកម្ម ខុសពីច្បាប់ជាតិកម្ពុជានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នោះទេ[501]។

លក្ខខណ្ឌតម្រូវថាការធ្វើទារុណកម្ម "ដោយឬតាមការញុះញង់ពីមន្ត្រីសាធារណៈ" នៅតែជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា បើទោះជាតុលាការ ICTY និង ICTR បានបដិសេធធាតុផ្សំនេះសម្រាប់ឧក្រិដ្ឋកម្មនានាដែលបានកើតឡើងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ យ៉ាងណាក៏ដោយ ក៏វាគឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងរយៈពេលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[502]។

ទោះបីជាសេចក្តីប្រកាសឆ្នាំ១៩៧៥ ស្តីពីទារុណកម្ម មិនបានរួមបញ្ចូលដោយផ្ទាល់នូវ "អំពើអកម្ម" ដែលបណ្តាលឱ្យមានទុក្ខសោក និងការឈឺចាប់ធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានទទួលយក "គោលការណ៍ទូទៅដែលត្រូវបានអនុវត្តយ៉ាងស៊ីចង្វាក់គ្នាដោយតុលាការមិនអចិន្ត្រៃយ៍ផ្សេងៗថា "បទឧក្រិដ្ឋមួយអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលអាចនាំឱ្យមានពិរុទ្ធភាព ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ""[503]។

### ២.៤.៣.៧. ការរំលោភសេពសន្ថវៈ

ការរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅ អ.វ.ត.ក. នោះទេ[504]។ អ.វ.ត.ក. មានយុត្តាធិការលើការរំលោភសេពសន្ថវៈក្នុងនាមជាអំពើទារុណកម្ម នៅពេលដែលធាតុផ្សំទាំងអស់ផ្សេងទៀតនៃការធ្វើទារុណកម្មត្រូវបានបំពេញ[505]។

អង្គជំនុំជម្រះសាលាដំបូងដើមឡើយបានសម្រេចថា ការរំលោភសេពសន្ថវៈ គឺជាបទឧក្រិដ្ឋដាច់ដោយឡែក ប្រឆាំងនឹងមនុស្សជាតិ នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដោយកត់សម្គាល់ថា វាត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់លាស់ទៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[506]។ នៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង *ធាតុផ្សំសត្យានុម័ត* គឺជាការបញ្ចូលអង្គជាត ទោះបីជាមិនបានស៊ីជម្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារី នៅពេលដែលការបញ្ចូលអង្គជាតនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ[507]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា *ធាតុផ្សំអត្តនោម័ត* នៃការរំលោភសេពសន្ថវៈនោះគឺថា ចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការបញ្ចូលអង្គជាត និងដឹងថាការបញ្ចូលអង្គជាត កើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ[508]។

---

500 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២០៥

501 សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៨។

502 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៩៥-២០១។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧០៩។

503 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧០៨។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៣ សម្គាល់ជើងទំព័រ ២១៥៩។

504 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៨០-១៨៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣៧១-៣៧២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៥៤។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥២។

505 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២០៧-២០៨, ២១៣។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៨, ៥២។

506 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ២៩៣, ៣៦១-៣៦៦។

507 ដូចខាងលើ កថាខណ្ឌ ៣៦២។

508 ដូចខាងលើ កថាខណ្ឌ ៣៦៥។

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធ ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង និងបានសម្រេចថា ការរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[509]។ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការវិភាគច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់សន្ធិសញ្ញា នៅមុន និងក្នុងអំឡុងពេលយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក.[510]។ អង្គជំនុំជម្រះបានសម្រេចថា ការហាមឃាត់ប្រឆាំងនឹងការរំលោភសេពសន្ថវៈនៅក្នុងច្បាប់ជាតិ មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីការលេចឡើងនូវការរំលោភសេពសន្ថវៈ ដែលជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ[511]។ អង្គបុរេជំនុំជម្រះក៏បានអនុម័តគាំទ្រទស្សនៈដែលថា ការរំលោភសេពសន្ថវៈ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក ក្នុងអំឡុងរយៈពេលដែលពាក់ព័ន្ធ[512]។

### ២.៤.៣.៨. ការធ្វើទុក្ខបុកម្នេញ

ការធ្វើទុក្ខបុកម្នេញគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមូលដ្ឋាន ដែលអាចអនុវត្តបាននៅ អ.វ.ត.ក.[513] ដែលបានកំណត់និយមន័យដូចខាងក្រោម៖

i. *ធាតុផ្សំសន្យានុម័ត*៖ ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្មឬអកម្ម ដែលជាការរើសអើងជាក់ស្តែង និងដែលបដិសេធ ឬដកហូតសិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា។ លក្ខខណ្ឌតម្រូវសម្រាប់ ការរើសអើងពិតប្រាកដ ("ជាក់ស្តែង") មានន័យថា វាត្រូវតែបង្ហាញថា ជនរងគ្រោះត្រូវគេកំណត់ជាគោលដៅ *ដោយសារតែ* ជនរងគ្រោះជាសមាជិកនៃក្រុមណាមួយ ដែលត្រូវបានកំណត់ ដោយចារីផ្អែកលើមូលហេតុជាក់លាក់ (ពោលគឺ មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា)។ ទោះបីជាចារីគឺជាអ្នកកំណត់ក្រុមនោះក៏ដោយ ក៏ជនរងគ្រោះជាសត្យានុម័តត្រូវតែស្ថិតក្នុងក្រុម នយោបាយ ពូជសាសន៍ ឬសាសនាណាមួយដែល "ស្តែងឱ្យឃើញគ្រប់គ្រាន់" ថា ផលវិបាកនៃការធ្វើទុក្ខបុកម្នេញដែលត្រូវការ កើតឡើងចំពោះក្រុមនោះ[514]។ ជាពិសេស អំពើជាក់លាក់ដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញ ត្រូវតែធ្វើការចោទប្រកាន់ឱ្យបានច្បាស់លាស់។ ដូច្នេះ វាមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់មួយក្នុងការកំណត់ឧក្រិដ្ឋកម្មតែមួយនោះថាជា "ការធ្វើទុកបុកម្នេញ"នោះទេ[515]។ អំពើធ្វើទុក្ខបុកម្នេញអាចរួមបញ្ចូលបទល្មើសជាមូលដ្ឋានផ្សេងទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧទាហរណ៍ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម ឬពួកវាអាចរួមបញ្ចូល "អំពើផ្សេងទៀតដែលមានកម្រិតស្ថានទម្ងន់ឬភាពធ្ងន់ធ្ងរស្មើគ្នា រួមបញ្ចូលទាំងអំពើនានាដែលមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះផងដែរ"[516]។

---

[509] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៨០។

[510] ដូចខាងលើ កថាខណ្ឌ ១៧៤-១៨០។

[511] ដូចខាងលើ កថាខណ្ឌ ១៨២។

[512] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣៧១។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៥៤។

[513] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤២៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៧៤-៣៧៦។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៦៩៤។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៥៧។

[514] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៦៦៧។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៧២, ២៧៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១៣-៧១៤។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤២៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៧៧។ ផ្ទុយទៅវិញ ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិនៃការធ្វើទុក្ខបុកម្នេញលើសាសនា យោងតាមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាន*ធាតុផ្សំសត្យានុម័ត* តឹងរឹងជាងអំពីការវាយប្រហារលើជីវិត ឬលើបុគ្គលនៃ "បព្វជិតដែលប្រតិបត្តិសាសនាដែលទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា"។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥។

[515] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៣១។

[516] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១៦។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៥៦-២៥៩, ២៦១។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនាជាក់លាក់ក្នុងការរើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងត្រូវមានចេតនាប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ[517]។ គេត្រូវបង្ហាញថាជនជាប់ចោទខ្លួនឯងផ្ទាល់មានចេតនារើសអើងជាក់លាក់ លើកលែងតែការចោទប្រកាន់អំពីការជួយ នឹងជម្រុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលជនជាប់ចោទ មិនចាំបាច់មានចេតនាជាក់លាក់[518]។ លក្ខខណ្ឌតម្រូវចេតនាជាក់លាក់នៃ*ធាតុផ្សំអត្តនោម័ត* មិនអាចត្រូវបានសន្និដ្ឋានតែតាមរយៈការយោងទៅលក្ខណៈរើសអើងជាទូទៅនៃការវាយប្រហារនោះទេ[519]។ ទោះជាយ៉ាងណា ចេតនាជាក់លាក់អាចត្រូវបានទាញចេញពីបរិបទដែលនៅក្នុងនោះឧក្រិដ្ឋកម្មកើតឡើង ដោយពិចារណាលើកាលៈទេសៈនានា ដូចជា លក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តប្រឆាំងនឹងក្រុមមួយ ឬចរិតលក្ខណៈទូទៅរបស់ចារី ដែលត្រូវបានចោទប្រកាន់ ដែលស្តែងឡើងតាមរយៈអាកប្បកិរិយារបស់ចារី[520]។ អាកប្បកិរិយាភ្លាមៗនៅមុនពេលនិងក្រោយពេលអំពើប្រព្រឹត្ត គប្បីត្រូវបានយកមកពិចារណា ដោយសារតែវាអាចបង្ហាញឱ្យឃើញពីស្ថានភាពផ្លូវចិត្តរបស់ចារី នៅក្នុងអំឡុងពេលនៃអង្គហេតុដែលបានកើតឡើង[521]។

អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើភាពប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែង ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពិចារណាលើក្របខ័ណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា[522]។ បន្ទាប់ពីបានថ្លឹងថ្លែងកត្តាទាំងអស់នេះជាសត្យានុម័ត អង្គជំនុំជម្រះបានសន្និដ្ឋានថា "ជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថា ការធ្វើទុក្ខបុកម្នេញអាចត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រឹមឆ្នាំ១៩៧៥"[523]។

### ២.៤.៣.៩. អំពើអមនុស្សធម៌ផ្សេងៗទៀត

ប្រភេទសេសសល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺអំពើអមនុស្សធម៌ផ្សេងៗទៀត គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥[524]។ ប្រភេទនោះជាប្រភេទសេសសល់ក្នុងន័យដែលអំពើប្រព្រឹត្តិមិនស្ថិតក្រោមបទល្មើសជាមូលដ្ឋានមួយ ក្នុងចំណោមបទល្មើសជាមូលដ្ឋានទាំងឡាយ ប៉ុន្តែបំពេញតាមលក្ខណៈវិនិច្ឆ័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[525]។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានកំណត់លក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត* ទាក់ទងទៅនឹងប្រភេទទូទៅនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ហើយធាតុផ្សំទាំងអស់នេះ ក្រោយមកត្រូវបានអនុវត្តទៅលើទម្រង់ជាក់លាក់នៃអំពើអមនុស្សធម៌ (ដូចជា ការផ្លាស់ទីលំនៅដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ។ល។)[526]៖

---

[517] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៣៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៧៩។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៦៩៤-៦៩៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤២៧។

[518] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១៥។

[519] ដូចខាងលើ។

[520] ដូចខាងលើ។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤២៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៨០។

[521] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៦៩៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១៥។

[522] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១២។

[523] ដូចខាងលើ។

[524] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៧៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៣៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៦៧។

[525] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៧៦-៥៧៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៣៧។

[526] សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២២-៧២៧។ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១២៤៦។

i. *ធាតុផ្សំសត្យានុម័តៈ* ចារីត្រូវតែប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដែលបណ្តាលឱ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

ii. *ធាតុផ្សំអត្តនោម័តៈ* ចារីត្រូវតែប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយចេតនា[527]។

ដើម្បីគោរពតាមលក្ខខណ្ឌតម្រូវនៃសច្ចភាពគតិយុត្តិ អំពើប្រព្រឹត្តិត្រូវតែមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដែលមានចែងក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតម្រូវឱ្យមានការវិភាគដោយផ្អែកតាមករណីជាក់ស្តែងនីមួយៗ នៃផលប៉ះពាល់លើជនរងគ្រោះ និងការកំណត់ថាតើអំពើនេះអាចប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា[528]។ ក្នុងការវាយតម្លៃថាតើ អំពើនេះអាចមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះអាចពិចារណាថាតើ អំពើប្រព្រឹត្តិរំលោភបំពានលើ “សិទ្ធិជាសារវន្តរបស់មនុស្សជាតិ ដូចបានបញ្ជាក់នៅក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិ” ដែលជាវិធីមួយផងដែរក្នុងការណែនាំអំពីលក្ខខណ្ឌតម្រូវនៃ អនីត្យានុកូលភាពអន្តរជាតិផ្លូវការ[529]។ ពុំមានលក្ខខណ្ឌតម្រូវថាអំពើប្រព្រឹត្តិជាមូលដ្ឋាន ត្រូវតែជាបទល្មើសព្រហ្មទណ្ឌច្បាស់លាស់តាមច្បាប់អន្តរជាតិនោះទេ[530]។

### ២.៤.៣.៩.១. ការជម្លៀសដោយបង្ខំ និងការនិរទេស

ធាតុផ្សំនៃការនិរទេស និងការជម្លៀសដោយបង្ខំ ដែលជា “អំពើអមនុស្សធម៌ផ្សេងៗទៀត” មានលក្ខណៈស្រដៀងគ្នាច្រើន គឺធាតុផ្សំទាំងពីរនេះតម្រូវឱ្យមានការផ្លាស់ទីមនុស្សដោយបង្ខំតាមរយៈការបណ្តេញចេញ ឬអំពើបង្ខិតបង្ខំផ្សេងៗទៀត ពីតំបន់ដែលពួកគេកំពុងមានវត្តមានដោយស្របច្បាប់ ឱ្យឆ្លងកាត់ព្រំដែន ដោយមិនមានមូលដ្ឋានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ[531]។ ទាំងការជម្លៀសដោយបង្ខំ និងការនិរទេស អាចត្រូវបានកំណត់បទឧក្រិដ្ឋជា “អំពើអមនុស្សធម៌ផ្សេងៗទៀត” ប៉ុន្តែការនិរទេសក៏ជាឧក្រិដ្ឋកម្មដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[532]។

ភាពខុសគ្នាតែមួយគត់រវាងឧក្រិដ្ឋកម្មទាំងពីរនេះ គឺថាការជម្លៀសដោយបង្ខំអាចកើតឡើងនៅក្នុងទឹកដីនៃប្រទេសមួយ ដោយមិនមានលក្ខខណ្ឌតម្រូវឱ្យឆ្លងកាត់ព្រំដែនអន្តរជាតិនោះទេ[533]។ នៅក្នុងការវាយតម្លៃអង្គហេតុនៃបទចោទនៅចំពោះមុខ អ.វ.ត.ក. ទាក់ទងនឹងអំពើដែលមានតម្លៃស្មើទៅនឹងការជម្លៀសដោយបង្ខំ និងការនិរទេស អំពើប្រព្រឹត្តិត្រូវតែមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ បានកំណត់ប្រភេទការផ្លាស់ទីលំនៅប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការជម្លៀសដោយបង្ខំ[534]។

### ២.៤.៣.៩.២. ការបាត់ខ្លួនដោយបង្ខំ

---

[527] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៣៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៦៨, ៣៧១។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៤-៧៥។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៤។

[528] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៣៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៦៧, ៣៦៩។

[529] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨៥។

[530] ដូចខាងលើ។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៣៦។

[531] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥១។

[532] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨៩។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥១។

[533] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥១។

[534] សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៤៨–១៤៦៩។

ការបាត់ខ្លួនដោយបង្ខំអាចជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ប៉ុន្តែអំពើជាមូលដ្ឋានមិនបង្កើតបានជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែក នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ គិតត្រឹមឆ្នាំ១៩៧៥[535]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វា "ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់" ក្នុងការកំណត់ពីធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ ថាជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែក[536]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធធាតុផ្សំជាក់លាក់ នៃអំពើប្រព្រឹត្តិដែលត្រូវបានទទួលស្គាល់ថាជាការបាត់ខ្លួនដោយបង្ខំ ដែលត្រូវបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង ពោលគឺ (១) ការដកហូតសេរីភាព (២) ការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនាឬទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬមិនទទួលស្គាល់ការដកហូតសេរីភាពនេះ ដោយបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់និងការធានាផ្នែកនីតិវិធីចំពោះបុគ្គលនោះ និង (៣) ធាតុផ្សំទាំងពីរខាងលើនេះត្រូវបានអនុវត្តដោយអាជ្ញាធររដ្ឋ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ឬអង្គការនយោបាយណាមួយ[537]។ ក្នុងសំណុំរឿង ០០៤/០១ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានអនុវត្តតាមវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដោយបានផ្តល់ជាយោបល់ថា បទល្មើសជាមូលដ្ឋាននៃការបាត់ខ្លួនដោយបង្ខំ មិនមានធាតុផ្សំជាក់លាក់ណាមួយ និងថា វាត្រូវបានបង្ហាញភ័ស្តុតាងដោយលក្ខខណ្ឌតម្រូវទូទៅនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[538]។

## ២.៤.៣.៩.៣. ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស

អំពើអមនុស្សធម៌ផ្សេងៗទៀត អាចរួមបញ្ចូលការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលបណ្តាលមកពីការមិនផ្តល់ឱ្យប្រជាជននូវអាហារគ្រប់គ្រាន់ ទីជម្រក ជំនួយវេជ្ជសាស្ត្រ លក្ខខណ្ឌអនាម័យអប្បបរមា[539]។ ដើម្បីកំណត់ថាតើការមិនផ្តល់ឱ្យនោះ មានតម្លៃស្មើទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែរ ឬយ៉ាងណា ចាំបាច់ត្រូវវាយតម្លៃថាតើការមិនផ្តល់ឱ្យនោះមានកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទល្មើសជាក់លាក់ដែលមានចែងក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថាតើការមិនផ្តល់ឱ្យនោះបានបណ្តាលឱ្យមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងថាតើការមិនផ្តល់ឱ្យនោះធ្វើឡើងដោយចេតនាឬទេ[540]។

ទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលកើតចេញពីលក្ខខណ្ឌនៃការឃុំឃាំង អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីធ្វើការវាយតម្លៃករណីយុត្តិសាស្ត្ររបស់តុលាការ ICTY បានសន្និដ្ឋានថា មានបទដ្ឋាននៃការប្រព្រឹត្តិអប្បបរមាចំពោះបុគ្គលដែលត្រូវបានឃុំខ្លួន ដែលគប្បីត្រូវបានធានាក្នុងកាលៈទេសៈណាក៏ដោយ[541]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជាកាលៈទេសៈ "លំបាកដោយសារខ្វះមធ្យោបាយនានា" គេចាំបាច់ត្រូវផ្តល់ឱ្យអ្នកជាប់ឃុំនូវមធ្យោបាយដែលមានទាំងអស់នោះ និងត្រូវចាត់វិធានការឆ្លើយតបចាំបាច់ ដើម្បីសម្រាលផលប៉ះពាល់នៃកាលៈទេសៈនោះ ទៅលើអ្នកជាប់ឃុំ[542]។

## ២.៤.៣.៩.៤. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការមានគភ៌ដោយបង្ខំ

---

[535] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨៩, ៦៤៧-៦៥៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥៣-៧៥៥។

[536] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨៩

[537] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៤៨។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៨៨-៥៨៩។

[538] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧២-២៧៤។

[539] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៣៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៥៧-៤៥៨។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣៥។

[540] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៣៤។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៤៥៧-៤៥៨។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣៥, ១៤៣៩។

[541] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៣៩។

[542] ដូចខាងលើ។

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការមានគភ៌ដោយបង្ខំ គឺជាទម្រង់នៃអំពើប្រព្រឹត្តិជាមូលដ្ឋានដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[543]។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា មិនមានលក្ខខណ្ឌតម្រូវថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានទទួលស្គាល់ជាប្រភេទជាក់លាក់មួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬសូម្បីតែជាប្រភេទជាក់លាក់មួយនៃអំពើប្រព្រឹត្តិជាមូលដ្ឋាននោះទេ[544]។ អង្គជំនុំជម្រះបានសម្រេចថា មិនមានការយល់ឃើញជារួមពាក់ព័ន្ធនឹងពាក្យ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ដូច្នេះតម្រូវឱ្យមានការវាយតម្លៃទៅតាមករណីនីមួយៗ[545]។

ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយល់ឃើញថា ការមានគភ៌ដោយបង្ខំបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នោះទេ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ គាត់យល់ឃើញថា "ត្រូវតែមានបទដ្ឋានដែលទទួលស្គាល់ជាទំនៀមទម្លាប់មួយ ដែលភ្ជាប់ទៅនឹងសិទ្ធិសមស្របរបស់មនុស្សជាតិ ដែលភាព "អមនុស្សធម៌" នៃអំពើនោះនឹងត្រូវវិនិច្ឆ័យ"[546]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្តតាមអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើវិធីសាស្ត្រដ៏ប្រុងប្រយ័ត្នមួយ ក្នុងការវាយតម្លៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដើម្បីធានាថាគោលការណ៍នីត្យានុកូលភាពមិនត្រូវបានរំលោភបំពាន[547]។

## ២.៥. ការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

មាត្រា ៦ នៃច្បាប់ អ.វ.ត.ក. បានផ្តល់ឱ្យ អ.វ.ត.ក. មានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ("អនុសញ្ញាទីក្រុងហ្សឺណែវ") "ដូចជាអំពើប្រឆាំងមនុស្ស ឬទ្រព្យសម្បត្តិ ដែលត្រូវការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"៖

i. ការធ្វើមនុស្សឃាតដោយចេតនា
ii. ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
iii. ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
iv. ការបំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមានហេតុផលចាំបាច់ខាងយោធាដែល ធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
v. ការបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
vi. ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់
vii. ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និង
viii. ការយកជនស៊ីវិលជាចំណាប់ខ្មាំង[548]។

មាត្រា ៦ នៃច្បាប់ អ.វ.ត.ក. បានឆ្លុះបញ្ចាំងជាពិសេសពីបទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុញ្ញាទីក្រុងហ្សឺណែវ ដោយមានការលើកលែងពីរករណី ដោយសារបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវចែងថា៖'(១) "រួមបញ្ចូលយ៉ាងច្បាស់អំពី 'ការពិសោធន៍ជីវសាស្ត្រ' ថាជាទម្រង់នៃការធ្វើទារុណកម្ម ឬការប្រព្រឹត្តិអមនុស្សធម៌" និង (២) "តម្រូវថា ការបំផ្លិចបំផ្លាញ និងការដកហូតទ្រព្យសម្បត្តិ 'ត្រូវបានគ្របដណ្តប់ផងដែរ'"[549]។ ដោយសារតែប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៥៨ ទាំងបួន បទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ព្រមទាំងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខ

[543] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១១៣៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៤១។
[544] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៤១។
[545] ដូចខាងលើ កថាខណ្ឌ ៧៤៣, ៧៤៩។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ផ្នែក VII(ឆ)(៣)(ក)(i)។
[546] សំណុំរឿង ០០៤ ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និង បង្កឱ្យមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D301/5 កថាខណ្ឌ ៦៤។
[547] ដូចខាងលើ កថាខណ្ឌ ៥៧-៦៥។
[548] សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០០។
[549] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០០ សម្គាល់ជើងទំព័រ ៧៣២។

ណៈបុគ្គលដែលមានចែងក្នុងនោះ ក៏ចងភ្ជាប់កាតព្វកិច្ចលើប្រទេសកម្ពុជាផងដែរ[550]។ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានសម្រេចយ៉ាងស៊ីចង្វាក់ថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[551]។

បទល្មើសទាំងឡាយដែលមានរៀបរាប់ក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក. បង្កើតបានជាការបំពារបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដរាបណាធាតុផ្សំ *ទូទៅ* ត្រូវបានបង្ហាញ៖ (១) អត្ថិភាពនៃជម្លោះប្រដាប់អាវុធ (២) លក្ខណៈអន្តរជាតិនៃជម្លោះប្រដាប់អាវុធ (៣) ចំណងទាក់ទងរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ (៤) “ឋានៈជាបុគ្គលដែលទទួលបានការការពារ” របស់ជនរងគ្រោះ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ និង (៥) ជនជាប់ចោទមានការដឹងឮគ្រប់គ្រាន់ថាជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ និងថាជនរងគ្រោះមានឋានៈជាបុគ្គលដែលទទួលបានការការពារ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ[552]។

### ២.៥.១. ភាពអាចអនុវត្តបាននៅ អ.វ.ត.ក.

សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ បានសម្រេចយ៉ាងស៊ីចង្វាក់ថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានបង្ហាញថាជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលចងភ្ជាប់កាតព្វកិច្ចលើប្រទេសកម្ពុជា ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[553]។ បទប្បញ្ញត្តិនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរចងភ្ជាប់កាតព្វកិច្ចលើប្រទេសកម្ពុជា ដោយសារតែប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ទាំងបួន នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨[554]។ ជាងនេះទៀត បទប្បញ្ញត្តិទាំងអស់នេះបានចងក្រងនូវគោលការណ៍សំខាន់ៗនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ហេតុដូច្នេះ ការកំណត់អាជ្ញាយុកាលជាធរមាន និងនិយមន័យការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺផ្អែកទាំងស្រុងលើច្បាប់អន្តរជាតិ[555]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគលើភាពអាចអនុវត្តបាននៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ដោយបានសម្រេចថា អ.វ.ត.ក. មានយុត្តាធិការលើរឿងក្ដីចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អនុលោមតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក.[556]។ អង្គជំនុំជម្រះបានផ្ដល់សំអាងហេតុថា ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨ និងថា អនុសញ្ញាទីក្រុងហ្សឺណែវចងក្រងគោលការណ៍សំខា

---

[550] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០៥។
[551] ដូចខាងលើ។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ២៥៦-២៥៨។ សំណុំរឿង ០០២ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១១៧-១១៨។ សំណុំរឿង ០០២ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។
[552] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១០។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៨០-១៤៩០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨-៨៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៧-៨៣។
[553] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០៣។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ២៥៦-២៥៨។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៦។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១១៧-១១៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។
[554] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០៣។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។
[555] សំណុំរឿង ០០២ សេចក្ដីសម្រេចលើអញ្ញត្តកម្មរបស់មេធាវីការពារក្ដី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ E306/6 កថាខណ្ឌ ៨។
[556] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០០។

ន់ៗនៃច្បាប់មនុស្សធម៌អន្តរជាតិ[557]។ អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញទៀតថា គេអាចប្រមើលដឹងនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនោះថា ជនជាប់ចោទអាចនឹងត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះអំពើទាំងឡាយដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដោយយោងទៅលើមូលដ្ឋាននៃអនុសញ្ញាអន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិរបស់វា[558]។ អង្គជំនុំជម្រះក៏បានពិចារណាថា "លក្ខណៈឃោរឃៅនៃឧក្រិដ្ឋកម្មដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរ [...] អាចបដិសេធចំពោះការអះអាងរបស់ជនជាប់ចោទ ដែលថាខ្លួនមិនបានដឹងអំពីប្រភេទនៃបទឧក្រិដ្ឋទាំងនោះ"[559]។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ ក៏បានដោះស្រាយភាពអាចអនុវត្តបាននៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ នៅពេលធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាដំណោះស្រាយ។ ទោះបីជាអង្គបុរេជំនុំជម្រះបានបដិសេធការជំទាស់របស់ អៀង សារី ផ្អែកលើរយៈពេលអាជ្ញាយុកាលតាមច្បាប់ជាតិយ៉ាងណាក្តី ក៏អង្គបុរេបានពិនិត្យប្រភពនានារបស់សហចៅក្រមស៊ើបអង្កេត ដើម្បីគាំទ្រការសន្និដ្ឋានរបស់ខ្លួន និងបានសន្និដ្ឋានថាការបំពារបំពានយ៉ាងធ្ងន់ធ្ងរ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[560]។ អង្គបុរេបានពិចារណាឃើញថា អនុសញ្ញាទីក្រុងហ្សឺណែវពិតជា "ចងកាតព្វកិច្ចចំពោះកម្ពុជា" និងថា អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន មានចែងនូវបទប្បញ្ញត្តិយ៉ាងច្បាស់ដែលថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា បង្កើតជាយុត្តាធិការព្រហ្មទណ្ឌជាសកល និងចាំបាច់ ក្នុងចំណោមរដ្ឋសមាជិក។ បន្ថែមលើនេះទៀត អង្គបុរេបានយល់ឃើញថា លក្ខណៈ*អាជ្ញាបញ្ញា* នៃបទឧក្រិដ្ឋលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ គឺមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការធ្វើយុត្តិកម្មការជំនុំជម្រះដោយមិនចាំបាច់គិតដល់បទប្បញ្ញត្តិជាក់លាក់ណាមួយនៃច្បាប់ក្នុងស្រុករបស់កម្ពុជានោះឡើយ[561]។ ស្រដៀងគ្នានេះដែរ នៅក្នុងការសម្រេចលើការជំទាស់របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ អង្គបុរេជំនុំជម្រះបានបង្ហាញថា ការទទួលខុសត្រូវយោងតាមការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានជនជាប់ចោទអាចដឹងជាមុនថាមានច្បាប់ចែង និងជាបទល្មើស "ដោយហេតុថា មានសន្ធិសញ្ញាទាំងឡាយ ដែលប្រទេសកម្ពុជាចូលជាភាគី លក្ខណៈនៃច្បាប់ទំនៀមទម្លាប់ដែលមានតាំងពីមុនរួចមកហើយ ដែលបានយកមកដាក់បញ្ចូលនៅក្នុងសន្ធិសញ្ញាទាំងនោះ និងលក្ខណៈនៃសិទ្ធិនីមួយៗ ដែលត្រូវបានគេចោទប្រកាន់ថាបានរំលោភបំពាន"[562]។

អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យភាពអាចអនុវត្តបាននៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទាំងនេះនៅក្នុងសំណុំរឿង ០០២ នៅពេលធ្វើការសម្រេចលើអញ្ញត្រកម្មរបស់ជនជាប់ចោទ ដែលថាការអនុវត្តបទល្មើសនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវបានហាមឃាត់ដោយអាជ្ញាយុកាលក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយនឹងរំលោភលើគោលការណ៍*គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង*[563]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មិនមានអាជ្ញាយុកាលដែលអាចអនុវត្តបាន ចំពោះបទប្បញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ នៅក្នុងច្បាប់ អ.វ.ត.ក. ឡើយ[564]។ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុថា មាត្រា ៦ នៃច្បាប់ អ.វ.ត.ក. មិនបានបង្កើតបទឧក្រិដ្ឋថ្មីនោះទេ ប៉ុន្តែគ្រាន់តែបានផ្តល់យុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក. តែប៉ុណ្ណោះ[565]។ ដោយរំលឹកថា អ.វ.ត.ក. អាចអនុវត្តតែបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលមានចែងជាក់លាក់ក្នុងច្បាប់ អ.វ.ត.ក. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការយោងតែមួយគត់ទៅក្រមព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. មិនអនុញ្ញាត

---

[557] ដូចខាងលើ កថាខណ្ឌ ៤០៣-៤០៥។

[558] ដូចខាងលើ កថាខណ្ឌ ៤០៦។

[559] ដូចខាងលើ កថាខណ្ឌ ៤០៧។

[560] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៧៣, ២៥៦។

[561] ដូចខាងលើ កថាខណ្ឌ ២៥៦។

[562] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១០៩-១១១។

[563] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ E306/6 កថាខណ្ឌ ១។

[564] ដូចខាងលើ កថាខណ្ឌ ១២។

[565] ដូចខាងលើ កថាខណ្ឌ ៧។

ឱ្យអនុវត្តដោយផ្ទាល់នូវក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទាំងស្រុងនោះឡើយ ប៉ុន្តែបានដាក់បញ្ចូលបទល្មើសជាតិជាក់លាក់មួយចំនួនទៅក្នុងក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ឥ.ក.។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ក្រមព្រហ្មទណ្ឌ "មិនបានកម្រិត ឬមិនបានអះអាងថាបានកម្រិត" ការចោទប្រកាន់ចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ នោះទេ[566]។

អង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលភាគច្រើននៃការវិភាគទាំងអស់នេះ ទៅក្នុងសាលក្រមសំណុំរឿង ០០២/០២[567]។ ដោយសារតែភាគីមិនបានប្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការបំពារបំពានយ៉ាងធ្ងន់ធ្ងរ អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលមិនបានពិនិត្យ ឬពិភាក្សាបញ្ហានេះបន្ថែមទៀតឡើយ។

ក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយោងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះ នៅក្នុងការសម្រេចថា "ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"[568]។ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១, ០០៤/០១ ឬ ០០៤/០២ នោះទេ។

### ២.៥.២. ធាតុផ្សំទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ

មាត្រា៦ នៃច្បាប់ អ.វ.ត.ក. រួមបញ្ចូលលក្ខខណ្ឌនានានៃភាពអាចអនុវត្តបាន ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ។ បទល្មើសដែលមានចែងក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក. បង្កើតបានជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដរាបណាលក្ខខណ្ឌតម្រូវ*ទូទៅ*ខាងក្រោមត្រូវបានបង្ហាញ៖

i. អត្ថិភាពនៃជម្លោះប្រដាប់អាវុធ[569]
ii. លក្ខណៈអន្តរជាតិនៃជម្លោះប្រដាប់អាវុធ[570]
iii. ចំណងទាក់ទងរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ[571]
iv. "ឋានៈជាបុគ្គលដែលទទួលបានការការពារ" របស់ជនរងគ្រោះ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ[572]

---

[566] ដូចខាងលើ កថាខណ្ឌ ៨។
[567] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៥-៣២៦។
[568] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៤។
[569] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១១-៤១២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៧។
[570] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៣-៤១៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៧។
[571] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៦។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៩។
[572] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៧។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨១។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨០។

v. ជនជាប់ចោទមានការដឹងឮគ្រប់គ្រាន់ថាជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ និងថាជនរងគ្រោះមានឋានៈជាបុគ្គលដែលទទួលបានការការពារ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ[573]។

ក្នុងការបង្ហាញធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនប្រាំ ដែលអនុវត្តដោយតុលាការ ICTY "ដែលលក្ខន្តិកៈរបស់តុលាការនេះ[បាន]ផ្តល់យុត្តាធិការស្រដៀងគ្នាទៅលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ"[574]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការ ICTY "មានលក្ខណៈទូលាយជាងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ផ្សេងទៀត ស្តីពីបញ្ហានៅពេលដែលលក្ខន្តិកៈរបស់តុលាការ ICTR និងតុលាការ SCSL មិនបានផ្តល់ដល់តុលាការទាំងអស់នោះនូវយុត្តាធិការលើបទល្មើសនានា ដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលបានផ្តល់នូវលក្ខណៈមិនមែនអន្តរជាតិនៃជម្លោះនានាដែលពាក់ព័ន្ធនឹងជម្លោះទាំងនោះ"[575]។

### ២.៥.២.១. អត្ថិភាពនៃជម្លោះប្រដាប់អាវុធ

មាត្រា២ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវចែងថា បទប្បញ្ញត្តិរបស់អនុសញ្ញា (រួមបញ្ចូលទាំងបទប្បញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ) អនុវត្តចំពោះ "គ្រប់ករណីដែលសង្គ្រាមត្រូវបានប្រកាស ឬក្នុងករណីជម្លោះប្រដាប់អាវុធផ្សេងទៀតដែលអាចកើតមានឡើងរវាងរដ្ឋជាភាគីចំនួនពីរឬច្រើន ទោះបីជាស្ថានភាពនៃសង្គ្រាមមិនត្រូវបានទទួលស្គាល់ដោយរដ្ឋជាភាគីទាំងនោះក៏ដោយ"[576]។ ជម្លោះប្រដាប់អាវុធមានអត្ថិភាពនៅពេលណាក៏ដោយដែលមាន៖

i. ការដោះស្រាយដោយប្រើកម្លាំងប្រដាប់អាវុធរវាងរដ្ឋនានា (នៅពេលដែលជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ) ឬ
ii. អំពើហិង្សាប្រដាប់អាវុធអូសបន្លាយរវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធ ឬរវាងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធទាំងនោះនៅក្នុងរដ្ឋមួយ (នៅពេលដែលជម្លោះប្រដាប់អាវុធជាជម្លោះផ្ទៃក្នុង)[577]។

### ២.៥.២.២. លក្ខណៈអន្តរជាតិនៃជម្លោះប្រដាប់អាវុធ

មាត្រា ៦ នៃច្បាប់ អ.វ.ត.ក. អនុវត្តតែទៅលើជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិតែប៉ុណ្ណោះ។ ជម្លោះប្រដាប់អាវុធមួយមានលក្ខណៈអន្តរជាតិ ប្រសិនបើវាកើតឡើងរវាងរដ្ឋចំនួនពីរឬច្រើន[578]។ ដើម្បីអនុវត្តការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ការទទួលស្គាល់ជាផ្លូវការពីរដ្ឋដែលមានសង្គ្រាមមិនមែនជាលក្ខខណ្ឌតម្រូវនោះទេ[579]។ ការប្រយុទ្ធដែលកើតមានឡើង*តាមព្រឹត្តិហេតុ* (de facto) រវាងរដ្ឋអាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវលក្ខខណ្ឌជាអន្តរជាតិ ក្នុងករណីដែលការប្រយុទ្ធគ្នានោះកើតមានឡើងរវាងកងកម្លាំងរបស់រដ្ឋរៀងៗខ្លួន។ បទប្បញ្ញត្តិអនុសញ្ញាទីក្រុងហ្សឺណែវ អនុវត្តនៅលើដែនដីទាំងមូលរបស់រដ្ឋដែលជាប់ពាក់ព័ន្ធ ទោះបីជាការប្រយុទ្ធគ្នានោះកើតមានឡើង

---

573 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២១-៤២២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៣។
574 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១០។
575 ដូចខាងលើ សម្គាល់ជើងទំព័រ ៧៤៨។
576 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៨។
577 ដូចខាងលើ។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១២។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៧។
578 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៧។
579 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៤។

នៅទីនោះឬ មិនមានក៏ដោយ ហើយច្បាប់នេះបន្តអនុវត្តក្រោយពេលនៃការឈប់បាញ់គ្នារហូតទទួលបាន សន្តិភាពជាទូទៅ[580]។

### ២.៥.២.៣. ចំណងទាក់ទងរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះ

ត្រូវតែមានចំណងទាក់ទងជិតស្និទ្ធរវាងអំពើរបស់ជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ ដែលនាំឱ្យមានការអនុវត្តការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[581]។ ដើម្បីបំពេញចំណងទាក់ទងនេះ អំពើរបស់ជនជាប់ចោទត្រូវតែមាន "ភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធ" ទៅនឹងជម្លោះប្រដាប់អាវុធទាំងមូល[582]។ "បទល្មើសអាច 'ស្ថិតនៅឆ្ងាយពីការវាយប្រយុទ្ធគ្នាជាក់ស្តែង បើគិតទាំងពេលវេលានិងទីតាំងភូមិសាស្ត្រ' ហើយវានឹងមានលក្ខណៈគ្រប់គ្រាន់ ក្នុងករណីដែលបទល្មើសនោះពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការប្រយុទ្ធគ្នាដែលកើតឡើងនៅកន្លែងផ្សេងៗទៀតនៃទឹកដី ដែលត្រួតត្រាដោយភាគីនៃជម្លោះ"[583]។ ទោះបីជាចំណងទាក់ទងនោះ ពុំចាំបាច់ជាទំនាក់ទំនងហេតុនិងបច្ច័យក៏ដោយ យ៉ាងហោចណាស់ អត្ថិភាពនៃជម្លោះប្រដាប់អាវុធត្រូវរួមចំណែកយ៉ាងសំខាន់នៅក្នុងសមត្ថភាពរបស់ចារី ក្នុងការប្រព្រឹត្តិបទល្មើស នៅក្នុងការសម្រេចចិត្តរបស់ខ្លួនក្នុងការប្រព្រឹត្តបទល្មើស របៀបដែលបទល្មើសត្រូវបានប្រព្រឹត្ត ឬគោលបំណងដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង[584]។ ក្នុងករណីដែលការប្រព្រឹត្តិបានកើតឡើងនៅក្នុងជំរំអ្នកទោសដោយគ្មានការអើពើ ឬការអនុញ្ញាតពីអាជ្ញាធរដែលគ្រប់គ្រងជំរំនោះ ហើយការប្រព្រឹត្តិនោះគឺជាផ្នែកមួយនៃគោលនយោបាយដែលគេបានទទួលស្គាល់យកមកអនុវត្តចំពោះអ្នកទោស "អំពើទាំងនោះនឹងត្រូវមើលឃើញថាមានទំនាក់ទំនង 'យ៉ាងជិតស្និទ្ធ' ទៅនឹងជម្លោះប្រដាប់អាវុធ"[585]។

### ២.៥.២.៤. បុគ្គលដែលត្រូវទទួលបានការការពារ

"បុគ្គលដែលត្រូវទទួលបានការការពារ" មានចែងក្នុងមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III (ពាក់ព័ន្ធនឹងឈ្លើយសឹក) និងអនុសញ្ញាទីក្រុងហ្សឺណែវ IV (ពាក់ព័ន្ធនឹងជនស៊ីវិល)៖

i. ឈ្លើយសឹក (ពោលគឺ "សមាជិកនានានៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីដែលមានជម្លោះ ព្រមទាំងសមាជិកនៃកងជីវពលឬទាហានស្ម័គ្រចិត្តដែលជាផ្នែកនៃកងកម្លាំងប្រដាប់អាវុធនោះ ដែលបានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ") និង
ii. ប្រជាជនស៊ីវិលដែល "ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះឬដែលកាន់កាប់អំណាចដែលពួកគេមិនមែនជាប្រជាជាតិដូចគ្នា"[586]។

ប្រជាជនស៊ីវិលអាចត្រូវបានចាត់ទុកថាជា "បុគ្គលដែលត្រូវទទួលបានការការពារ" ដោយអនុសញ្ញានៃទីក្រុងហ្សឺណែវ IV ក្នុងករណីដែលពួកគេត្រូវបានយល់ឃើញពីសំណាក់រដ្ឋដែលពួកគេស្ថិតនៅក្នុងកណ្តាប់ដៃ "ថាជាកម្មសិទ្ធិរបស់ភាគីប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធ និងដែលបានដាក់ការគំរាមកំហែងដល់រដ្ឋនោះ"[587]។ ដោយអនុម័តតាម "ការបកស្រាយដែលមានលក្ខណៈទន់ភ្លន់" របស់តុលាការ ICTY អំពីលក្ខខណ្ឌកំណត់សញ្ជាតិដែលមានចែងក្នុងមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV អង្គជំនុំ

---

[580] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣២៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៨។

[581] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣០។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៧៩។

[582] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៦។

[583] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣០។

[584] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៦។

[585] ដូចខាងលើ។

[586] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៨។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)កថាខណ្ឌ ៨១-៨៣។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨០-៨២។

[587] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១៩។

ជម្រះសាលាដំបូងបានពិចារណាថា បុគ្គលម្នាក់អាចត្រូវបានចាត់ទុកថាជាជនដែលត្រូវទទួលបានការការពារ ទោះបីជាគាត់មានសញ្ជាតិដូចគ្នានឹងភាគីដែលមានជម្លោះក៏ដោយ។ យោងតាមវិធីសាស្ត្រនេះ "ការពិចារណាដ៏សំខាន់" គឺភក្តីភាព ឬការខ្វះភក្តីភាព ដែលបុគ្គលមានចំពោះភាគីដែលមានជម្លោះ[588]។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងដែលថា បុគ្គលដែលត្រូវទទួលបានការការពារ មិនរាប់បញ្ចូល ពួកចារកម្ម ពោលគឺ សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីនៃជម្លោះ ដែលស្ថិតក្នុងអំណាចរបស់ភាគីបដិបក្ខ ខណៈពេលកំពុងឈ្លបយកការណ៍[589]។ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុថា ពិធីសារបន្ថែម I មិនបានដកពួកចារកម្មចេញពីការការពាររបស់អនុសញ្ញាទីក្រុងហ្សឺណែវទេ។ បុគ្គលដែលពាក់ព័ន្ធនៅក្នុងការស៊ើបការណ៍ ដែលបាត់បង់ឋានៈជាឈ្លើយសឹក នៅតែទទួលបានការធានាជាមូលដ្ឋាន ដែលមានចែងនៅក្នុងមាត្រា ៧៥ នៃពិធីសារបន្ថែមទី ១។ ក្នុងន័យនេះ សេចក្តីអត្ថាធិប្បាយរបស់ ICRC ទៅលើពិធីសារបន្ថែមទី១ កត់សម្គាល់ថា "ការដកហូតឋានៈជាឈ្លើយសឹក គឺជាការដាក់ទណ្ឌកម្មរួចទៅហើយ ដូច្នេះហើយ ការដកហូតនេះអាចកើតមានឡើងតែក្រោយពីមានសេចក្តីសម្រេចរបស់តុលាការប៉ុណ្ណោះ" និងថា "សច្ចធារណ៍នៃឋានៈជាឈ្លើយសឹកគួរតែមានលើសលប់ នៅគ្រប់ករណីទាំងអស់ នៅពេលដែលបុគ្គលពាក់ព័ន្ធមិនទាន់ត្រូវបានចោទប្រកាន់ដោយផ្អែកលើភ័ស្តុតាង*បឋម*"[590]។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធបន្ថែមទៀតទៅនឹងការអះអាងថា និយមន័យនៃជនដែលត្រូវទទួលបានការការពារគ្របដណ្តប់លើជនជាតិវៀតណាម ដែលមានសញ្ជាតិកម្ពុជា ប៉ុន្តែត្រូវបានគេចាត់ទុកថាជាខ្មាំងដែលមានសម្ព័ន្ធភាពជាមួយវៀតណាម។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា ដីកាដំណោះស្រាយបានកម្រិតយ៉ាងច្បាស់លាស់ នូវប្រភេទបុគ្គលដែលត្រូវទទួលបានការការពារ ត្រឹមតែសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម និងជនស៊ីវិលដែលជាពលរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង "មិនត្រូវមានការពិចារណាលើថា តើជនជាតិវៀតណាមដែលជាពលរដ្ឋខ្មែរ ប៉ុន្តែមានភក្តីភាពចំពោះវៀតណាមអាចត្រូវបានចាត់ទុកថាជាបុគ្គលដែលត្រូវទទួលបានការការពារដែរ ឬទេនោះឡើយ"[591]។

### ២.៥.២.៥. លក្ខខណ្ឌតម្រូវនៃការដឹងឮ

ជនជាប់ចោទត្រូវមានការដឹងឮគ្រប់គ្រាន់អំពីលក្ខណៈជាអន្តរជាតិនៃជម្លោះប្រដាប់អាវុធ និងអំពីឋានៈដែលត្រូវទទួលបានការការពាររបស់ជនរងគ្រោះ ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ[592]។ ការដឹងឮរបស់ជនជាប់ចោទថា រដ្ឋបរទេសជាប់ពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ និងដឹងថាជនរងគ្រោះត្រូវបានគ្រប់គ្រងដោយភាគីបដិបក្ខក្នុងជម្លោះប្រដាប់អាវុធ នឹងមានលក្ខណៈគ្រប់គ្រាន់សម្រាប់បំពេញនូវលក្ខខណ្ឌនៃការដឹងឮនេះ[593]។ ការដឹងឮរបស់ជនជាប់ចោទចំពោះហេតុការណ៍ទាំងពីរនេះ កើតចេញពីការអនុវត្តនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូច្នេះត្រូវតែអនុវត្តដូចគ្នាចំពោះរយៈពេលចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[594]។ អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិមិនគ្រាន់តែជាបុរេលក្ខខណ្ឌតែមួយនៃយុត្តាធិការនោះទេ ប៉ុន្តែថែមទាំងជាធាតុផ្សំដ៏សំខាន់នៃបទល្មើសនានាដែលបានចោទប្រកាន់ផងដែរ[595]។ ដូច្នេះ ជនជាប់ចោទត្រូវតែដឹងថា អំពើប្រព្រឹត្តិរបស់ខ្លួនមានចំណងទាក់

[588] ដូចខាងលើ។
[589] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣៣-៣៣៤។
[590] ដូចខាងលើ កថាខណ្ឌ ៣៣៤ (អក្សរទ្រេតត្រូវបានលុប) ។
[591] ដូចខាងលើ កថាខណ្ឌ ៣៣២។
[592] ដូចខាងលើ កថាខណ្ឌ ៣៣៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២០-៤២២។ សូមមើលផងដែរ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៣។
[593] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២០-៤២២។
[594] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២១។
[595] ដូចខាងលើ កថាខណ្ឌ ៤២០។

ទងទៅនឹងជម្លោះប្រដាប់អាវុធលក្ខណៈជាអន្តរជាតិ ឬយ៉ាងហោចណាស់ "ខ្លួនបានដឹងអំពីកាលៈទេសៈជាក់ស្តែងដែលនឹងនាំឱ្យចៅក្រមធ្វើការសន្និដ្ឋានថា ជម្លោះប្រដាប់អាវុធនោះគឺជាជម្លោះអន្តរជាតិ"[596]។

### ២.៥.៣. ធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរជាមូលដ្ឋាន

#### ២.៥.៣.១. ការធ្វើមនុស្សឃាតដោយចេតនា

ធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃការធ្វើមនុស្សឃាតដោយចេតនាគឺ "ដូចគ្នាទៅនឹងធាតុផ្សំនៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបានបណ្តាលឱ្យមានការបាត់បង់ជីវិតជនរងគ្រោះ តាមរយៈអំពើសកម្ម ឬអកម្មដែលខុសច្បាប់។
ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនា "សម្លាប់ ឬបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនេះមុខជានាំឱ្យមានការបាត់បង់ជីវិតមនុស្ស"[597]។

អង្គហេតុនៃការស្លាប់អាចទាញសន្និដ្ឋានតាមកាលៈទេសៈ រួមមានពីភ័ស្តុតាងខាងក្រោម៖

i. ហេតុការណ៍នៃការធ្វើបាបសំដៅទៅលើជនរងគ្រោះ
ii. លំនាំនៃការធ្វើបាប និងការបាត់ខ្លួននៃបុគ្គលផ្សេងទៀត
iii. បរិយាកាសទូទៅនៃភាពគ្មានច្បាប់នៅទីកន្លែងដែលអំពើត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង
iv. រយៈពេលដែលកន្លងទៅ ចាប់តាំងពីបុគ្គលនោះបានបាត់ខ្លួន និង
v. អង្គហេតុដែលថា ជនរងគ្រោះខកខានមិនបានទាក់ទងមកបុគ្គលផ្សេងទៀត ដែលគាត់អាចត្រូវបានរំពឹងថាមានទំនាក់ទំនង ដូចជាសមាជិកគ្រួសារ[598]។

ការបាត់បង់ជីវិតរបស់ជនរងគ្រោះ ដែលបណ្តាលមកពីអំពើសកម្ម ឬអកម្មរបស់ចារី ត្រូវតែជាការទាញការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់ពីភ័ស្តុតាង[599]។

#### ២.៥.៣.២. ការធ្វើទារុណកម្ម ឬអំពើអមនុស្សធម៌ផ្សេងៗទៀត

##### ២.៥.៣.២.១. *ការធ្វើទារុណកម្ម*

ធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃការធ្វើទារុណកម្មគឺ "ដូចគ្នាទៅនឹងធាតុផ្សំនៃការធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបាន "ប្រព្រឹត្តអំពើដែលបណ្តាលឱ្យមានការឈឺចាប់ ឬទុក្ខវេទនាធ្ងន់ធ្ងរ ទោះជាខាងផ្លូវកាយក្តី ឬផ្លូវចិត្តក្តី"។

---

[596] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៣៥។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៣។
[597] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥៧ និងផ្នែក ៩.១.១.។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៣១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨០។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៥។
[598] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦២៨, ៧៥៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៣១។
[599] ដូចខាងលើ។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែបានប្រព្រឹត្ត "ដោយចេតនា" ឬ "ដោយឬតាមការញុះញង់ពីមន្ត្រីសាធារណៈ ក្នុងគោលបំណងដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ"[600]។

ក្នុងការវាយតម្លៃការឈឺចាប់ ឬទុក្ខវេទនា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាសត្យានុម័ត និងកត្តាអត្តនោម័ត។ កត្តាសត្យានុម័តរួមមានភាពធ្ងន់ធ្ងរនៃព្យសនកម្មដែលបានបង្កឡើង លក្ខណៈ គោលបំណង និងសង្គតិភាពនៃអំពើដែលបានប្រព្រឹត្ត។ កត្តាអត្តនោម័តរួមមានលក្ខខណ្ឌរាងកាយ ឬផ្លូវចិត្តរបស់ជនរងគ្រោះ ផលប៉ះពាល់នៃការប្រព្រឹត្ត និងក្នុងករណីខ្លះ កត្តានានាដូចជា អាយុរបស់ជនរងគ្រោះ ភេទ ស្ថានភាពសុខភាព និងតួនាទីក្នុងនាមជាថ្នាក់ក្រោម[601]។ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាផងដែរលើលក្ខណៈ និងបរិបទនៃការបង្កឱ្យមានការឈឺចាប់ ការគិតទុកជាមុន និងការបង្កើតនូវការធ្វើបាបលក្ខណៈរាងកាយរបស់ជនរងគ្រោះ របៀប និងវិធីសាស្ត្រដែលត្រូវបានប្រើ និងភាពទន់ខ្សោយរបស់ជនរងគ្រោះ[602]។

### ២.៥.៣.២.២. ការធ្វើបាបដោយអមនុស្សធម៌

ការធ្វើបាបដោយអមនុស្សធម៌គឺជាបទល្មើសដាច់ដោយឡែកពីការធ្វើទារុណកម្ម៖[603]

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបាន "ប្រព្រឹត្តដោយចេតនានូវអំពើសកម្ម ឬអកម្ម ប្រឆាំងនឹងបុគ្គលដែលទទួលបានការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអំពើនេះអាចបណ្តាលឱ្យមានព្យសនកម្ម ផ្លូវចិត្ត ការឈឺចាប់ ឬការរងរបួសរាងកាយ ឬជាអំពើដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ"[604]។

ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនា "ប្រព្រឹត្តនូវអំពើសកម្ម ឬអកម្ម ដោយធ្វើឱ្យមានការឈឺចាប់ដល់រាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ"[605]។

ការធ្វើបាបដោយអមនុស្សធម៌មានលក្ខណៈខុសពីការធ្វើទារុណកម្ម ក្នុងន័យដែលថា ការធ្វើបាបដោយអមនុស្សធម៌ មិនចាំបាច់ត្រូវបានធ្វើឡើងដោយមានគោលបំណងណាមួយជាក់លាក់ឡើយ ហើយកម្រិតនៃភាពធ្ងន់ធ្ងរមិនចាំបាច់ស្មើនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសការធ្វើទារុណកម្មឡើយ[606]។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម ("ICRC") ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ IV ជួយសម្រួលដល់ការបកស្រាយបទល្មើសនេះ៖

> [ការធ្វើបាបដោយអមនុស្សធម៌] មិនមែនមានន័យត្រឹមតែជាការប្រព្រឹត្តិដែលបង្កើតជាការវាយប្រហារ ដែលកំណត់តែទៅលើរាងកាយ ឬសុខភាពប៉ុណ្ណោះនោះឡើយ។ ពិតណាស់ គោលបំណងនៃអនុសញ្ញានេះគឺដើម្បីផ្តល់ឲ្យជនស៊ីវិលនូវការការពារមួយ ដែលនឹងការពារសេចក្តីថ្លៃថ្នូរ ភាពជាមនុស្សជាតិរបស់ពួកគេ និងការពារពួកគេមិនឲ្យទទួលនូវការប្រមាថ ដូចសត្វធាតុ នៅពេលដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់សត្រូវនោះ។ គោលបំណងនេះនាំឲ្យមានការសន្និដ្ឋានថា តាមរយៈ "ការធ្វើបាបដោយអមនុស្សធម៌ អនុសញ្ញានេះមិនមែនកំណត់អត្ថន័យត្រឹមតែការរងរបួសដល់រាងកាយ ឬដល់សុខភាពប៉ុណ្ណោះទេ។ ឧទាហរណ៍ វិធានការមួយចំនួនដែល

---

[600] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៥៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៣៩។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៧។
[601] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧០៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៥៥។
[602] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៥៥។
[603] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦៤-៧៦៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៣៨។
[604] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៤០។
[605] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៤៥។
[606] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៤៣។

អាចកាត់ផ្តាច់ទាំងស្រុងរវាងអ្នកជាប់ឃុំឃាំងជាជនស៊ីវិលនឹងពិភពខាងក្រៅ និងជាពិសេសពីក្រុមគ្រួសាររបស់ពួកគេ ឬដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរ អាចត្រូវបានចាត់ទុកថាជាការធ្វើបាបដោយអមនុស្សធម៌[607]។

អំពើដែលត្រូវបានចាត់ទុកជាការធ្វើទារុណកម្ម ឬការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយឬសុខភាព នឹងត្រូវចាត់ទុកជាការធ្វើបាបដោយអមនុស្សធម៌ផងដែរក្នុងពេលពេលតែមួយ[608]។ បទល្មើសនេះក៏មានវិសាលភាពគ្របដណ្តប់លើអំពើដទៃទៀតផងដែរ ដែលរំលោភលើគោលការណ៍នៃការប្រព្រឹត្តិដោយអមនុស្សធម៌ ជាពិសេស ការគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ការវាយតម្លៃនេះគឺជាបញ្ហាអង្គហេតុ ដែលត្រូវយកមកពិចារណានូវកាលៈទេសៈទាំងអស់តាមករណីនីមួយៗ។ "អំពើទាំងឡាយ ដូចជា កាយវិកលកម្ម និងប្រភេទផ្សេងទៀតនៃព្យសនកម្មដល់រាងកាយយ៉ាងធ្ងន់ធ្ងរ ត្រូវបានចាត់ទុកថាជាអំពើអមនុស្សធម៌"[609]។

### ២.៥.៣.៣. ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការធ្វើឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយឬសុខភាព

ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការធ្វើឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយឬសុខភាព ផ្តោតលើភាពធ្ងន់ធ្ងរនៃការឈឺចាប់ ឬការរងរបួស ហើយមិនរួមបញ្ចូលអំពើដែលនាំឱ្យមានព្យសនកម្មដែលគ្រាន់តែទាក់ទងទៅនឹងសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់បុគ្គលនោះឡើយ[610]។

i. *ធាតុផ្សំសត្យានុម័ត៖* ចារីត្រូវតែបានប្រព្រឹត្ត "ដោយចេតនានូវអំពើសកម្ម ឬអកម្ម ដែលបង្កឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ដែលនេះរួមបញ្ចូលទាំងសុខភាពផ្លូវចិត្តផងដែរ"[611]។
ii. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានប្រព្រឹត្ត "ដោយចេតនានូវអំពើសកម្ម ឬអកម្ម" ឬ "ការធ្វេសប្រហែស"[612]។

អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមការវិភាគនៃសេចក្តីអធិប្បាយរបស់ ICRC ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ IV នៅក្នុងការបកស្រាយបទល្មើសនេះ៖

> ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង សំដៅទៅលើការឈឺចាប់ ដែលបានបង្កឡើងដោយគ្មានទីបញ្ចប់ ដែលក្នុងន័យនេះការធ្វើទារុណកម្មត្រូវបានបង្កឱ្យមានឡើង ការពិសោធជីវសាស្ត្រក៏ត្រូវបានគេអនុវត្តផងដែរ។ ដូច្នេះ អំពើនោះអាចនឹងត្រូវបានធ្វើឡើង ជាការដាក់ទណ្ឌកម្ម ជាការសងសឹក ឬដោយសារហេតុផលផ្សេងទៀត ដូចជាភាពសប្បាយរីករាយពេលឃើញអ្នកដទៃឈឺចាប់។ ដោយយល់ឃើញថា ការឈឺចាប់នៅក្នុងករណីនេះ បើតាមការប្រើប្រាស់ពាក្យពេចន៍ ហាក់បីដូចជាមិនសំដៅទៅលើការរងរបួសដល់រាងកាយ ឬ សុខភាពនោះទេ វាអាចជាការមន្ទិលសង្ស័យប្រសិនបើបទល្មើសនេះ មិនមែនជាបទល្មើសពិសេស ដែលមិនត្រូវបានដោះស្រាយតាមច្បាប់ជាតិ។ ដោយសារតែអនុសញ្ញានេះមិនបានបញ្ជាក់ឱ្យច្បាស់ថា ចង់សំដៅតែទៅលើការឈឺចាប់ដល់រាងកាយតែប៉ុណ្ណោះនោះ ដូចនេះអនុសញ្ញានេះត្រូវបានគេយល់ឃើញថាអាចគ្របដណ្តប់លើការឈឺចាប់ផ្លូវចិត្តផងដែរ។ ការបង្កឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព គឺជាទស្សនទានមួយ ដែលធម្ម

[607] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៤១។
[608] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៤២។
[609] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៤២។
[610] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥៣។
[611] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦១។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥១។
[612] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦២-៧៦៣។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៨។

តាមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ដែលជាទូទៅប្រើជាលក្ខខណ្ឌវិនិច្ឆ័យមួយអំពីភាពធ្ងន់ធ្ងរ ដែលជនរងគ្រោះបាត់បង់សមត្ថភាពបំពេញការងាររយៈពេលយូរ[613]។

ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការធ្វើឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយឬសុខភាពមានលក្ខណៈខុសគ្នាពីការធ្វើទារុណកម្ម ដោយសារតែអំពើសកម្ម ឬអកម្ម ដែលត្រូវបានចោទប្រកាន់មិនចាំបាច់ត្រូវបានប្រព្រឹត្តឡើងដោយមានគោលបំណងជាក់លាក់ណាមួយនោះឡើយ[614]។ វាក៏ខុសគ្នាពីការប្រព្រឹត្តិដោយអមនុស្សធម៌ ដែលតម្រូវឱ្យមានព្យសនកម្មដល់រាងកាយ ឬសុខភាពធ្ងន់ធ្ងរ។ ព្យសនកម្មដែលកើតមានលើជនរងគ្រោះនៃការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការធ្វើឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយឬសុខភាព មិនចាំបាច់តែជាផលប៉ះពាល់ធ្ងន់ធ្ងរ ដែលមិនអាចព្យាបាលបានឬជាផលប៉ះពាល់ជាអចិន្ត្រៃយ៍នោះទេ ប៉ុន្តែព្យសនកម្មនេះបានធ្វើឱ្យជនរងគ្រោះមានការពិបាកចិត្តរយៈពេលយូរ មានភាពអាម៉ាស់ ឬមានការអាប់ឱន ហើយត្រូវបណ្តាលឱ្យមានផលវិបាករយៈពេលយូរ និងធ្ងន់ធ្ងរដល់លទ្ធភាពរបស់មនុស្សក្នុងជីវភាពធម្មតា[615]។

### ២.៥.៣.៤. ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀតទាត់

ធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀតទាត់ គឺ៖

i. *ធាតុផ្សំសត្យានុម័ត៖* ចារីតាមរយៈអំពើសកម្ម ឬអកម្ម "ដែលដកហូតសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ពីឈ្លើយសឹកឬប្រជាជនស៊ីវិល ដោយមិនផ្តល់នូវការធានាតាមផ្លូវតុលាការ ដូចដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ III"[616] ដែលរួមមាន[617]៖
  - ទទួលបានការកាត់ទោសដោយយុត្តិធម៌ ដោយតុលាការឯករាជ្យ និងអនាគតិ
  - ទទួលបានការជូនដំណឹងយ៉ាងឆាប់រហ័សអំពីបទចោទប្រកាន់
  - ការការពារប្រឆាំងនឹងការផ្តន្ទាទោសជាសមូហភាព
  - ការការពារអនុលោមតាមគោលការណ៍នីត្យានុកូលភាព
  - មិនត្រូវទទួលបានការផ្តន្ទាទោសលើសពីម្តងចំពោះអំពើដដែល ឬបទចោទដដែល
  - ទទួលបានព័ត៌មានអំពីសិទ្ធិឧបាស្រ័យ
  - មិនត្រូវបានផ្តន្ទាទោស ឬប្រហារជីវិតដោយគ្មានសាលក្រមជាមុន ដែលប្រកាសដោយតុលាការដែលបានបង្កើតឡើងតាមច្បាប់។

ii. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានប្រព្រឹត្តដោយ "ចេតនានូវអំពើសកម្ម ឬអកម្ម" ឬ "ការធ្វេសប្រហែស"[618]។

ទោះបីជារដ្ឋនៅក្នុងកាលៈទេសៈមួយចំនួន ដូចជា ក្នុងអំឡុងពេលប្រទេសមានអាសន្ន អាចធ្វើបដិប្បញ្ញត្តិចំពោះកាតព្វកិច្ចរបស់ខ្លួនមួយចំនួនពាក់ព័ន្ធនឹងការជំនុំជម្រះដោយយុត្តិធម៌ បទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV បញ្ជាក់ថា ការដកហូតសេរីភាពអាចអនុញ្ញាតធ្វើទៅបានតែក្នុងករណីដែលមានមូលដ្ឋានសមហេតុផលជឿជាក់ថា សន្តិសុខរបស់ប្រទេសមានហានិភ័យ។ អង្គជំនុំជម្រះសាលាដំបូងបានប្រើលក្ខណៈវិនិច្ឆ័យនេះ នៅពេលធ្វើការវាយតម្លៃថាតើ ផ្អែកលើអង្គហេតុនៃរឿងក្តី ការធ្វើបដិប្បញ្ញត្តិពាក់

[613] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥២ (អក្សរលែងទ្រេត)។
[614] ដូចខាងលើ កថាខណ្ឌ ៤៥៣។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៨(c)។
[615] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៦១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥៤។
[616] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥៩។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៧០។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ សូមមើល ជំពូក ៤។
[617] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៧០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥៩។
[618] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៧១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៦០។

ព័ន្ធទៅនឹងសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ ត្រូវបានធ្វើឡើងដោយស្របច្បាប់និងស្របតាមកាតព្វកិច្ចរបស់រដ្ឋ ក្រោមច្បាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធដែរ ឬយ៉ាងណា[619]។

### ២.៥.៣.៥. ការនិរទេសជនស៊ីវិលដោយខុសច្បាប់

ធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃការនិរទេសគឺ "ភាគច្រើនដូចគ្នាជាមួយនឹងធាតុផ្សំនៃការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបានផ្លាស់ទីមនុស្សដោយបង្ខំ "តាមរយៈការបណ្ដេញចេញ ឬអំពើបង្ខិតបង្ខំផ្សេងៗទៀត ពីតំបន់ដែលពួកគេកំពុងមានវត្តមានដោយស្របច្បាប់ ឱ្យឆ្លងកាត់ព្រំដែន ដោយមិនមានមូលដ្ឋានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ"។
ii. *ធាតុផ្សំអត្តនោម័ត*៖ ចារីត្រូវតែមានចេតនា "ផ្លាស់ទីជនរងគ្រោះដោយបង្ខំ ឱ្យឆ្លងកាត់ព្រំដែនប្រទេស"[620]។

ចំណុចខុសគ្នាតែមួយគត់ជាមួយនឹងការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺថា បទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV និងជាពិសេសគឺមាត្រា ៤៩(១) ដែលចែងថា "ការនិរទេសបុគ្គលដែលត្រូវទទួលបានការការពារ *ចេញពីទឹកដីដែលស្ថិតក្រោមការកាន់កាប់* ទៅកាន់ទឹកដីនៃប្រទេសកាន់កាប់សិទ្ធិអំណាចឬទៅកាន់ទឹកដីប្រទេសផ្សេងទៀត"[621]។ ទោះបីជាអនុសញ្ញាទីក្រុងហ្សឺណែវមិនបានកំណត់និយមន័យ "ទឹកដីដែលស្ថិតក្រោមការកាន់កាប់"ក៏ដោយ ក៏មាត្រា ៤២ នៃបទបញ្ញាទីក្រុងឡាអេ ចែងថា "ទឹកដីដែលត្រូវបានចាត់ទុកថាស្ថិតនៅក្រោមការកាន់កាប់ គឺនៅពេលដែលទឹកដីនោះត្រូវបានស្ថិតក្រោមការគ្រប់គ្រងជាក់ស្ដែងរបស់កងទ័ពដែលកំពុងប្រយុទ្ធ។ ការកាន់កាប់ទឹកដីត្រូវបានធ្វើឡើងនៅលើទឹកដីដែលសិទ្ធិអំណាចនៅក្នុងការកាន់កាប់បានបង្កើតឡើងនិងត្រូវបានអនុវត្ត"[622]។

អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងវិធីសាស្ត្រដែលប្រើដោយ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Naletilić* និង *Martinović* នៅតុលាការ ICTY ដែលបានសន្និដ្ឋានថា "ដោយសារវាជាប់ពាក់ព័ន្ធនឹង "បុគ្គលនានា" ជាជនស៊ីវិលដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ IV ច្បាប់នៃការកាន់កាប់ត្រូវបានអនុវត្តដោយមិនតម្រូវឱ្យប្រទេសកាន់កាប់ទឹកដីនោះ មានសិទ្ធិអំណាចគ្រប់គ្រងជាក់ស្ដែងនោះឡើយ"។ នៅពេលដោះស្រាយជាមួយនឹងឧក្រិដ្ឋកម្ម ដែលប៉ះពាល់ដល់ជនស៊ីវិល ការប្រព្រឹត្តិបែបនោះ "ត្រូវបានហាមឃាត់ចាប់តាំងពីពេលដែលពួកគេត្រូវធ្លាក់ចូលទៅក្នុងដៃរបស់ភាគីជម្លោះ ដោយមិនគិតពីដំណាក់កាលនៃការប្រយុទ្ធគ្នានោះទេ"[623]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មិនចាំបាច់មានការបង្ហាញបន្ថែមថា ស្ថានភាពជាក់ស្ដែងនៃការកាន់កាប់ទឹកដី ដូចដែលបានកំណត់នៅក្នុងមាត្រា ៤២ នៃបទបញ្ញាទីក្រុងឡាអេ មានអត្ថិភាពនោះឡើយ។

### ២.៥.៣.៦. ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

ធាតុផ្សំនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់គឺ "ដូចគ្នាជាមួយនឹងធាតុផ្សំនៃការដាក់ក្នុងមន្ទីរឃុំឃាំងដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ"៖

i. *ធាតុផ្សំសត្យានុម័ត*៖ ចារីត្រូវតែបានដកហូតសេរីភាពបុគ្គលតាមទំនើងចិត្ត ដោយពុំមានដំណើរការច្បាប់ត្រឹមត្រូវ។

[619] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៧២។
[620] ដូចខាងលើ កថាខណ្ឌ ៧៧៥។
[621] ដូចខាងលើ កថាខណ្ឌ ៧៧៥ (អក្សរទ្រេតក្នុងច្បាប់ដើម)។
[622] ដូចខាងលើ កថាខណ្ឌ ៧៧៦។
[623] ដូចខាងលើ កថាខណ្ឌ ៧៧៧។

ii. *ធាតុផ្សំអត្តនោម័តៈ* ចារីត្រូវតែ "មានចេតនាដកហូតសេរីភាពបុគ្គលតាមទំនើងចិត្ត" ឬ "បានប្រព្រឹត្តដោយដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឱ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល"[624]។

ការដកហូតសេរីភាពមានលក្ខណៈតាមទំនើងចិត្ត ប្រសិនបើពុំមានមូលដ្ឋានច្បាប់ផ្តល់យុត្តិកម្មដល់ការធ្វើបែបនោះ[625]។ ច្បាប់ជាតិដែលមានបំណងផ្តល់យុត្តិកម្មការដកហូតសេរីភាព មិនត្រូវរំលោភលើច្បាប់អន្តរជាតិនោះទេ។ ប្រសិនបើមូលដ្ឋានច្បាប់សម្រាប់ការដកហូតដំបូងមានអត្ថិភាព មូលដ្ឋានច្បាប់នេះត្រូវតែមាននៅទូទាំងរយៈពេលទាំងមូលនៃការឃុំខ្លួនខុសច្បាប់។ ប្រសិនបើមូលដ្ឋានច្បាប់នោះលែងមានអត្ថិភាពហើយ ការឃុំខ្លួនត្រូវចាត់ទុកថាជាការឃុំខ្លួនខុសច្បាប់។ ការឃុំខ្លួនត្រឹមត្រូវដោយស្របច្បាប់ពីដំបូង ក្លាយទៅជាការឃុំខ្លួនដោយខុសច្បាប់ ប្រសិនបើភាគីឃុំខ្លួននោះខកខានក្នុងការគោរពសិទ្ធិនីតិវិធីជាមូលដ្ឋានរបស់អ្នកជាប់ឃុំ ឬក្នុងការបង្កើតតុលាការ ឬក្រុមប្រឹក្សារដ្ឋបាលសមស្រប ដូចដែលមានចែងក្នុងមាត្រា ៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV[626]។

ទោះបីជាការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ក្នុងពេលជម្លោះប្រដាប់អាវុធ អាចអនុញ្ញាតទៅបានក្នុងករណីមានកម្រិតក៏ដោយ ក៏បទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV បញ្ជាក់ថា ការដកហូតសេរីភាពអាចត្រូវបានអនុញ្ញាតធ្វើទៅបាន តែក្នុងករណីដែលមានមូលហេតុសមស្របគួរឱ្យជឿជាក់ថាស្ថានភាពសន្តិសុខរបស់ប្រទេសកំពុងតែប្រឈមនឹងបញ្ហា[627]។

---

[624] ដូចខាងលើ កថាខណ្ឌ ៧៨០-៧៨១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៤៧-៣៥០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨៩។
[625] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៨១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៤៨។
[626] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៦៥។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៨១។
[627] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៨១។

## ៣. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

### ៣.១. ទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់ អ.វ.ត.ក.

មាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. ចែងអំពីទម្រង់នៃការទទួលខុសត្រូវ ដែលជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក.។ មាត្រា ២៩(ថ្មី) បានផ្អែកលើបទប្បញ្ញត្តិនៃការទទួលខុសត្រូវរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍ និងមានប្រភពនៅក្នុងគោលការណ៍ច្បាប់អន្តរជាតិ។ មាត្រានេះចែងថា៖

> ជនសង្ស័យណាមួយ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គល ចំពោះឧក្រិដ្ឋកម្មនេះ ។
>
> តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។
>
> ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ឬមាន អំណាច និងការត្រួតពិនិត្យទៅលើអ្នក នៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាព បែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ។
>
> ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ។

អនុលោមតាមគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានពិនិត្យថាតើ ទម្រង់នៃការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់ក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ដែរឬទេ ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[628]។ អង្គជំនុំជម្រះសម្រេចថា ទម្រង់នៃការទទួលខុសត្រូវដែលមានចែងក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. មានមូលដ្ឋានទាំងក្នុងច្បាប់ជាតិកម្ពុជា និងទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥[629]។

ក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវក្នុងមាត្រា ២៩(ថ្មី) "ក៏មានចែងដែរនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ [របស់កម្ពុជា] ក្នុងអំឡុងពេលនោះ លើកលែងតែការទទួលខុសត្រូវចំពោះការរៀបចំផែនការ និងការទទួលខុសត្រូវរបស់ថ្នាក់លើ"[630]។ យ៉ាងណាមិញ អង្គជំនុំជម្រះបានកត់សម្គាល់ថា ការរៀបចំផែនការត្រូវបានផ្តន្ទាទោសដោយមាត្រា ២២៣, ២៣៩ និង ២៩០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហេតុដូច្នេះ ធ្វើឱ្យការផ្តន្ទាទោសអំពើប្រព្រឹត្តិបែបនេះ អាចប្រមើលដឹងជាមុនបាន ថាតើជាទម្រង់នៃការទទួលខុសត្រូវ ឬជាបទឧក្រិដ្ឋ។ អង្គជំនុំជម្រះបានបន្តសន្និដ្ឋានថា ទម្រង់នៃការទទួលខុសត្រូវក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. ក៏មានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរ ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះយល់ឃើញថា៖ (១) សាលក្រមក្រោយសង្គ្រាមលោកលើកទី២ បានបញ្ជាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល លាតសន្ធឹង

---

[628] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៣។
[629] ដូចខាងលើ កថាខណ្ឌ ៤៧៤, ៤៧៨។
[630] ដូចខាងលើ កថាខណ្ឌ ៤៧៤។

ហួសពីអ្នកទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទៅទៀត ដោយរួមបញ្ចូលទាំងអ្នកដែលបានបញ្ជា ឬបានជួយក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និង (២) យុត្តិសាស្ត្រជាបន្តបន្ទាប់ និងកម្រិតច្បាប់នៅកម្រិតអន្តរជាតិ "បានបញ្ជាក់ជាថ្មីអំពីប្រភេទទំនៀមទម្លាប់" នៃទម្រង់នៃការទទួលខុសត្រូវនីមួយៗក្នុងមាត្រា ២៩(ថ្មី) "ព្រមទាំងការអនុវត្តទម្រង់នេះទៅលើឧក្រិដ្ឋកម្មអន្តរជាតិជាច្រើន" រួមមាន ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[631]។

អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានបញ្ជាក់ជាថ្មីថា ទម្រង់ទាំងអស់នៃការទទួលខុសត្រូវដែលមានរៀបរាប់ក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក. មានមូលដ្ឋានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[632]។ អង្គជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់ផងដែរថា ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់មួយនៃ "ការប្រព្រឹត្ត" ដែលមានចែងក្នុងមាត្រា ២៩(ថ្មី)[633] ដែលត្រូវបានពិភាក្សាខាងក្រោម ក្នុងផ្នែក ៣.៤។

## ៣.២. ការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយ និងការជំរុញ

ធាតុផ្សំទម្រង់នៃការទទួលខុសត្រូវ នៃការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយ និងការជំរុញ ត្រូវបានកំណត់ជាដំបូងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ ដែលក្រោយមកត្រូវបានបញ្ជាក់ជាថ្មីដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២។ អង្គជំនុំជម្រះតុលាការកំពូល មិនបានពិនិត្យធាតុផ្សំនៃទម្រង់ទទួលខុសត្រូវទាំងអស់នេះទេ។ ទាំងសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៤/០១ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ បានអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គបុរេជំនុំជម្រះមិនបានពិនិត្យទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះទេ។

### ៣.២.១. ការប្រព្រឹត្តិតាមរយៈអំពើសកម្ម ឬអកម្ម

ការប្រព្រឹត្តរួមបញ្ចូលការប្រព្រឹត្តិតាមរយៈអំពើសកម្ម ឬអកម្ម។ ជនជាប់ចោទត្រូវតែមានចេតនា ឬបានដឹងពីភាវនីយភាពសំខាន់ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលកើតមានឡើងដោយសារតែផលវិបាកនៃអំពើដែលបានចោទប្រកាន់[634]។ ការប្រព្រឹត្តក៏រួមបញ្ចូល ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមផងដែរ ដែលមានពិភាក្សាខាងក្រោម ក្នុងផ្នែក ៣.៤។

### ៣.២.២. ការរៀបចំផែនការ

ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ការរៀបចំផែនការថាជា ទម្រង់មួយនៃការទទួលខុសត្រូវត្រឹមឆ្នាំ១៩៧៥[635]។ លិខិតុបករណ៍អន្តរជាតិមួយចំនួនបានចងក្រងការទទួលខុសត្រូវតាមរយៈការរៀបចំផែនការ ដែលរួមមាន៖ (១) មាត្រា ៦ នៃធម្មនុញ្ញ Nuremberg (២) មាត្រា ៥ នៃធម្មនុញ្ញតូក្យូ (៣) មាត្រា II(២)(ឃ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង (៤) គោលការណ៍ VI នៃគោលការណ៍ Nuremberg និង (៥) មាត្រា ៤(ក) នៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ("អនុសញ្ញាស្តីពីចំណាប់ខ្មាំង")[636]។ តុលាការក្រោយសង្គ្រាមលោកលើកទី២ បានធ្វើការដាក់ពិរុទ្ធភាពប្រឆាំងនឹងជន

---

631 ដូចខាងលើ កថាខណ្ឌ ៤៧៥-៤៧៨។

632 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៧, ៦៩៩, ៧០១, ៧០៣, ៧១៤។

633 ដូចខាងលើ កថាខណ្ឌ ៦៩០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១១។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២១។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៣។

634 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៩-៤៨១។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៣។

635 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៥, ៤៧៨។

636 សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ២១៧៣។

ជាប់ចោទ ដែលត្រូវបានរកឃើញថាបានរៀបចំផែនការឧក្រិដ្ឋកម្មអន្តរជាតិ[637]។ ការរៀបចំផែនការក៏ត្រូវបានផ្តន្ទាទោសជាបទល្មើសផងដែរតាមមាត្រា ២២៣, ២៣៩ និង ២៩០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[638]។

ចំពោះទម្រង់នៃការទទួលខុសត្រូវតាមរយៈការរៀបចំផែនការ បុគ្គលម្នាក់ ឬច្រើន បានរៀបចំការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលក្រោយមកត្រូវបានប្រព្រឹត្ត។ ការរៀបចំផែនការត្រូវតែកើតឡើងមុន និងចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[639]។

ជនជាប់ចោទត្រូវតែមានចេតនា ឬបានដឹងអំពីភវនីយភាពសំខាន់ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម បន្ទាប់ពីការអនុវត្តផែនការ[640]។ ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជា ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ ជនជាប់ចោទត្រូវតែមានចេតនាពិសេសដែលតម្រូវ[641]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ការរៀបចំផែនការ ដែលជាទម្រង់មួយនៃការទទួលខុសត្រូវ ត្រូវបានជនជាប់ចោទអាចប្រមើលឃើញ ដោយសារតែតួនាទីជាន់ខ្ពស់របស់ពួកគេ និងថាការរៀបចំផែនការត្រូវបានទទួលស្គាល់ថាជាទម្រង់មួយនៃការទទួលខុសត្រូវ ទាំងនៅក្នុងប្រទេសកម្ពុជា និងទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥[642]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ការរៀបចំផែនការគឺជាទម្រង់មួយនៃការទទួលខុសត្រូវ ដែលទាមទារឱ្យមានអំពើសកម្មមួយកើតមានឡើងជាក់ស្តែង[643]។ ដូច្នេះ ការទទួលខុសត្រូវចំពោះការរៀបចំផែនការ មិនអាចកើតមានឡើងតាមរយៈអំពើអកម្មនោះឡើយ។

### ៣.២.៣. ការញុះញង់

ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ការញុះញង់ថាជាទម្រង់មួយនៃការទទួលខុសត្រូវត្រឹមឆ្នាំ១៩៧៥[644]។ ខណៈដែលសំណៅជាភាសាខ្មែរ និងបារាំងនៃមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. បានសំដៅទៅការញុះញង់ (“inciter”) ក៏ដោយ សញ្ញាណនៃពាក្យថា ការជំរុញ និងការញុះញង់ ត្រូវបានចាត់ទុកថាជាពាក្យមានន័យដូចគ្នា[645]។ ការជំរុញ និងការញុះញង់ត្រូវបានចងក្រងនៅក្នុងលិខិតុបករណ៍អន្តរជាតិជាច្រើន ដែលរួមមាន៖ (១) មាត្រា ៦ នៃធម្មនុញ្ញ Nuremberg (២) មាត្រា ៣ នៃអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (“អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍”) (៣) មាត្រា ៦ នៃអនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់អំពើទាសភាព ពាណិជ្ជកម្មទាសករ និងស្ថាប័ននិងការអនុវត្តស្រដៀងគ្នាទៅនឹងទាសភាព (“អនុសញ្ញាបន្ថែមស្តីពីទាសភាព”) (៤) មាត្រា ២០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) (៥) មាត្រា ៤ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (៦) មាត្រា II នៃអនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាល

---

[637] ដូចខាងលើ។

[638] ដូចខាងលើ សម្គាល់ជើងទំព័រ ២១៧៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៤ សម្គាល់ជើងទំព័រ ៨៣៧។

[639] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១៨។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៤។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៤។

[640] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១៩។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៤។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៤។

[641] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៧។

[642] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៧។

[643] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៧។

[644] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៥។

[645] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៨។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៩។

ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“អនុសញ្ញាស្ដីពីអាជ្ញាយុកាល”) (៧) មាត្រា III(ក) នៃអនុសញ្ញាអន្តរជាតិស្ដីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មអាប៉ាថេដ (“អនុសញ្ញាអាប៉ាថេដ”) និង (៨) មាត្រា ៤(ក) នៃអនុសញ្ញាស្ដីពីចំណាប់ខ្មាំង។ តុលាការក្រោយសង្គ្រាមលោកលើកទី២ ក៏បានធ្វើការដាក់ពិរុទ្ធភាពជនជាប់ចោទ ដែលបានញុះញង់ និងជំរុញឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[646] ។ ការជំរុញក៏ត្រូវបានផ្ដន្ទាទោសដោយមាត្រា ៨៣ និង ៨៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ផងដែរ[647]។

ចំពោះការទទួលខុសត្រូវតាមរយៈការញុះញង់ បុគ្គលម្នាក់ តាមរយៈអំពើសកម្ម ឬអកម្ម ត្រូវតែបានជំរុញបុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ការទទួលខុសត្រូវអាចកើតឡើងតាមរយៈការជំរុញជាលាយលក្ខណ៍អក្សរ ឬការជំរុញដោយផ្ទាល់មាត់ផ្សេងទៀត និងអាចស្វែងឱ្យឃើញ ឬជាទម្រង់ស្ងៀមស្ងាត់ផ្សេងទៀត។ ផ្ទុយទៅនឹងការបញ្ជា និងការទទួលខុសត្រូវរបស់ថ្នាក់លើ ការញុះញង់មិនតម្រូវថា ជនជាប់ចោទមានសិទ្ធិអំណាចណាមួយលើចារីនោះឡើយ។ ការញុះញង់ក៏តម្រូវឱ្យមានមិនត្រឹមតែការជួយសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋប៉ុណ្ណោះនោះទេ ដែលម្យ៉ាងវិញទៀតនោះ អាចគ្រប់គ្រាន់សម្រាប់ការជួយ និងការជំរុញរបស់វា។ អំពើសកម្ម ឬអកម្ម ត្រូវតែកើតឡើងមុន ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការឈានទៅប្រព្រឹត្តឧក្រិដ្ឋកម្ម មិនមែនត្រឹមតែការជួយសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋប៉ុណ្ណោះនោះទេ[648]។

ជនជាប់ចោទត្រូវតែមានចេតនា ឬបានដឹងពីភវនីយភាពសំខាន់ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជាលទ្ធផលនៃការញុះញង់[649]។ ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជា ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ ជនជាប់ចោទត្រូវតែមានចេតនាពិសេសដែលតម្រូវ[650]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងពិចារណាថា ការខកខានជាដដែលៗរបស់ថ្នាក់លើក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មរបស់ចារី ក្នុងកាលៈទេសៈខ្លះ អាចជាការញុះញង់ចារីឱ្យប្រព្រឹត្តបទឧក្រិដ្ឋបន្ថែមទៀត[651]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការញុះញង់ដែលជាទម្រង់មួយនៃការទទួលខុសត្រូវ ត្រូវបានប្រមើលដឹងដោយជនជាប់ចោទ ដោយយោងទៅលើតួនាទីជាន់ខ្ពស់របស់ពួកគេ និងថាវាត្រូវបានទទួលស្គាល់ថាជាទម្រង់មួយនៃការទទួលខុសត្រូវ ទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់ជាតិកម្ពុជា ត្រឹមឆ្នាំ១៩៧៥[652]។

### ៣.២.៤. ការបញ្ជា

ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ ការបញ្ជាថាជាទម្រង់មួយនៃការទទួលខុសត្រូវ ត្រឹមឆ្នាំ១៩៧៥[653]។ ការបញ្ជាត្រូវបានចងក្រងនៅក្នុងលិខិតុបករណ៍អន្តរជាតិ មុនឆ្នាំ១៩៧៥ ដែលរួមមានមាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV និង មាត្រា II(២)(ខ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ តុលាការក្រោយសង្គ្រាមលោកលើកទី២ ក៏បានដាក់ពិរុទ្ធភាពជនជាប់ចោទចំពោះការបញ្ជាឱ្យមានឧក្រិដ្ឋ

---

646 សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ២១៧៨។

647 ដូចខាងលើ សម្គាល់ជើងទំព័រ ២១៨០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៤ សម្គាល់ជើងទំព័រ ៨៣៦។

648 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៩។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥២២។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៧។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨១។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។

649 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៩។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥២៤។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៧។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨១។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។

650 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៩។

651 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥២៣។

652 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៩។

653 ដូចខាងលើ កថាខណ្ឌ ៧០១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៥។

កម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[654]។ ការបញ្ជាក៏ត្រូវបានផ្តន្ទាទោសដោយមាត្រា ៨៣ និង ៨៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ផងដែរ[655]។

ចំពោះការទទួលខុសត្រូវតាមរយៈការបញ្ជា ជនជាប់ចោទ ដែលស្ថិតក្នុងឋានៈជាអ្នកមានអំណាច *តាមព្រឹត្តិហេតុ* (អំណាចជាក់ស្តែង) ឬ *តាមផ្លូវច្បាប់* (នៅក្នុងច្បាប់) ត្រូវតែបានបង្គាប់បុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ មិនតម្រូវឱ្យមានទំនាក់ទំនងថ្នាក់លើ និងថ្នាក់ក្រោមបង្គាប់ រវាងបុគ្គលទាំងពីរនោះទេ។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអាចកើតមាន នៅពេលដែលជនជាប់ចោទចេញបញ្ជា ឬផ្ទេរការបញ្ជាដែលរួមទាំងតាមរយៈអន្តរការី។ ពុំមានលក្ខខណ្ឌតម្រូវថា ការបញ្ជានោះត្រូវតែចេញក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់ពិសេសណាមួយនោះទេ ហើយអត្ថិភាពនៃបញ្ជាអាចត្រូវបានបញ្ជាក់តាមរយៈភ័ស្តុតាងតាមស្ថានភាព។ ការបញ្ជាត្រូវតែធ្វើឡើងមុន ហើយចូលរួមចំណែកយ៉ាងសំខាន់មួយដល់ការប្រព្រឹត្តបទឧក្រិដ្ឋ[656]។

ជនជាប់ចោទត្រូវតែមានចេតនា ឬបានដឹងអំពីលទ្ធភាពខ្ពស់ថា ការអនុវត្តតាមការបញ្ជានេះ នឹងបណ្តាលឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ[657]។ ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជា ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ ជនជាប់ចោទត្រូវតែមានចេតនាពិសេសដែលតម្រូវ[658]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការបញ្ជាដែលជាទម្រង់មួយនៃការទទួលខុសត្រូវ ត្រូវបានប្រមើលដឹងដោយជនជាប់ចោទ ដោយយោងទៅលើតួនាទីជាន់ខ្ពស់របស់ពួកគេ និងថាវាត្រូវបានទទួលស្គាល់ថាជាទម្រង់មួយនៃការទទួលខុសត្រូវ ទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់ជាតិកម្ពុជា ត្រឹមឆ្នាំ១៩៧៥[659]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ការបញ្ជាគឺជាទម្រង់នៃការទទួលខុសត្រូវ ដែលទាមទារឱ្យមានអំពើសកម្មមួយកើតមានឡើងជាក់ស្តែង។ ដូច្នេះ ការទទួលខុសត្រូវចំពោះការបញ្ជា មិនអាចកើតមានឡើងតាមរយៈអំពើអកម្មនោះឡើយ[660]។

### ៣.២.៥. ការជួយ និងការជំរុញ

ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ថា ការជួយ និងការជំរុញ គឺជាទម្រង់នៃការទទួលខុសត្រូវ ត្រឹមឆ្នាំ១៩៧៥[661]។ ការទទួលខុសត្រូវលើបទសមគំនិត រួមទាំងការជួយ និងការជំរុញ ត្រូវបានទទួលស្គាល់ថាជាគោលការណ៍ច្បាប់អន្តរជាតិ ហើយត្រូវបានចងក្រងនៅក្នុងលិខិតុបករណ៍អន្តរជាតិមួយចំនួន ដែលរួមមាន៖ (១) មាត្រា ៦ នៃធម្មនុញ្ញ Nuremberg (២) មាត្រា (II)(២)(ខ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង (៣) គោលការណ៍ VII នៃគោលការណ៍ Nuremberg (៤) មាត្រា ៣, ៥ និង ៦ នៃអនុសញ្ញាបន្ថែមស្តីពីទាសភាព (៥) មាត្រា II នៃអនុសញ្ញាស្តីពីអាជ្ញាយុកាល (៦) មាត្រា III(ខ) នៃ

---

[654] សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ២១៨៦។

[655] ដូចខាងលើ កថាខណ្ឌ ៧០១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៤ សម្គាល់ជើងទំព័រ ៨៣៦។

[656] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥២៧។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៣។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។

[657] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥២៨។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៣។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៦។

[658] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២០។

[659] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០១។

[660] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២០។

[661] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៥។

អនុសញ្ញាអាប៉ាថេដ (៧) មាត្រា ១(២)(ខ) និង (៤)(ក) នៃអនុសញ្ញាស្ដីពីចំណាប់ខ្មាំង និង (៨) មាត្រា ២ (១)(ង) នៃអនុសញ្ញាស្ដីពីការទប់ស្កាត់ និងការដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយណាប្រឆាំងនឹងបុគ្គលដែលទទួលបានការការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូត។ តុលាការក្រោយសង្គ្រាមលោកលើកទី២ ក៏បានដាក់ពិរុទ្ធភាពចំពោះការជួយ និងការជំរុញឱ្យមានឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[662]។ ការជួយ និងការជំរុញក៏ត្រូវបានផ្ដន្ទាទោសដោយមាត្រា ៨៣ និង ៨៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ផងដែរ[663]។

ការជួយ និងការជំរុញ រួមមានការជួយជាក់ស្ដែង ការលើកទឹកចិត្ត ឬការគាំទ្រខាងស្មារតី ដែលមានឥទ្ធិពលយ៉ាងខ្លាំងចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយចារី[664]។ ទោះបីជា ជាញឹកញាប់ត្រូវបានពិចារណារួមគ្នា នៅក្នុងយុត្តិសាស្ត្ររបស់សាលាក្ដីអន្តរជាតិយ៉ាងណាក៏ដោយ ក៏ពាក្យ “ការជួយ” និង “ការជំរុញ” មិនមានន័យដូចគ្នាទេ៖ “ការជួយ” រួមមានការផ្ដល់ជំនួយ ចំណែកឯ “ការជំរុញ” វិញ រួមមាន “ការជួយសម្រួលឱ្យការប្រព្រឹត្តិអំពើណាមួយដោយសារតែការលើកទឹកចិត្ត”[665]។ អំពើសកម្មនិងអកម្មទាំងពីរអាចបង្កើតបានជាការជួយ និងការជំរុញ[666]។

ពុំតម្រូវឱ្យមានភស្តុតាងអំពីផែនការ ឬការព្រមព្រៀងរវាងអ្នកជួយនិងអ្នកជំរុញ ជាមួយនឹងចារីនោះឡើយ។ ជនជាប់ចោទមិនអាចត្រូវបានផ្ដន្ទាទោសចំពោះការជួយនិងការជំរុញ ចំពោះឧក្រិដ្ឋកម្ម ដែលមិនបានប្រព្រឹត្តឡើងនោះទេ[667]។ ចារីនៃបទឧក្រិដ្ឋមួយមិនចាំបាច់ត្រូវបានជំនុំជម្រះ ឬកំណត់អត្តសញ្ញាណនោះទេ[668]។

ធាតុផ្សំសត្យានុម័តនៃការជួយ និងការជំរុញដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម អាចកើតឡើងមុន នៅក្នុងអំឡុងពេល ឬ*ក្រោយពេល* ឧក្រិដ្ឋកម្មសំខាន់ត្រូវបានប្រព្រឹត្តឡើង[669]។ លក្ខខណ្ឌតម្រូវសំខាន់បំផុតគឺថា ការជួយជ្រោមជ្រែង ការលើកទឹកចិត្ត ឬការគាំទ្រខាងផ្នែកស្មារតី ត្រូវតែមានអានុភាពផងលើការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ។ ហេតុដូច្នេះ នៅពេលមិនមានទម្រង់នៃការជួយជ្រោមជ្រែង ការលើកទឹកចិត្តឬការគាំទ្រខាងផ្នែកស្មារតីជាមុនណាមួយនោះ ការជួយជ្រោមជ្រែងដែលផ្ដល់ឱ្យក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចបំពេញលក្ខខណ្ឌតម្រូវនេះឡើយ។ ទំនាក់ទំនងហេតុនិងផលមានអត្ថិភាពតែនៅពេលដែលអានុភាពនៃការលើកទឹកចិត្ត ឬការគាំទ្រផ្នែកស្មារតីកើតមានឡើងតែប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនចាំបាច់កំណត់អត្តសញ្ញាណតាមទ្រឹស្ដីចំពោះការប្រព្រឹត្តិទាំងអស់ ដែលអាចមានអានុភាពយ៉ាងខ្លាំងលើការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ។ ប៉ុន្តែចំណុចនេះអាស្រ័យទៅលើការវាយតម្លៃលើភស្តុតាងទៅតាមករណីនីមួយៗតែប៉ុណ្ណោះ[670]។

ដើម្បីផ្ដន្ទាទោសលើការទទួលខុសត្រូវចំពោះការជួយនិងការជំរុញ ជនជាប់ចោទត្រូវតែបានដឹងថា បទឧក្រិដ្ឋមួយអាចនឹងត្រូវបានប្រព្រឹត្តឡើង ហើយអំពើរបស់ខ្លួនបានជួយ ឬបានសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនោះ។ ជនជាប់ចោទក៏ត្រូវដឹងអំពីធាតុផ្សំសំខាន់ៗនៃបទល្មើស ដែលត្រូវបានប្រព្រឹត្តឡើងដោយចារី។ យ៉ាងណាមិញ ជនជាប់ចោទមិនចាំបាច់មានចេតនាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដូចចារីទេ រួមទាំងចេតនាជាក់

---

662 សំណុំរឿង ០០២/០១ សាលក្រម សម្គាល់ជើងទំព័រ ២១៩៣។

663 ដូចខាងលើ សម្គាល់ជើងទំព័រ ២១៩៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៤ សម្គាល់ជើងទំព័រ ៨៣៦។

664 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣៣។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥០។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៣។

665 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣៣។

666 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៦។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥០។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៣។

667 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣៤។

668 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣៤។

669 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៣។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥០។

670 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៣។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៣។

លាក់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនានា ដូចជា ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[671]។ ការដឹងឮនេះអាចទាញការសន្និដ្ឋានចេញពីកាលៈទេសៈនានា។

ក្នុងសំណុំរឿង ០០១, ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា សំណៅជាភាសាបារាំង នៃមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. បានប្រដូច "ការជួយ និងការជំរុញ" ទៅនឹងសញ្ញាណនៃពាក្យ *"complicité"* (ការសមគំនិត)[672]។ ផ្ទុយទៅវិញ សំណៅជាភាសាបារាំងនៃលក្ខន្តិកៈរបស់សាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR") បានប្រដូចឃ្លា "ការជួយ និងការជំរុញ" ទៅនឹងឃ្លា *"aidé et encouragé"* (ជួយនិងលើកទឹកចិត្ត)។ ដោយសារតែមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. យកគំរូតាមបទប្បញ្ញត្តិស្ដីពីការទទួលខុសត្រូវរបស់សាលាក្ដីព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍ ហើយត្រូវបានទាញចេញពីសញ្ញាណរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឃ្លា *"aidé et encouragé"* ឆ្លុះបញ្ចាំងកាន់តែច្បាស់អំពីលក្ខណៈទម្រង់នៃការទទួលខុសត្រូវ ជាងសញ្ញាណនៃពាក្យ *"complicité"* ដែលអាចគ្របដណ្ដប់លើអំពើប្រព្រឹត្តិកាន់តែទូលំទូលាយ។ អង្គជំនុំជម្រះក៏បានផ្ដល់សំអាងហេតុដែរថា សំណៅជាភាសាខ្មែរនៃមាត្រា ២៩(ថ្មី) បានគាំទ្រការបកស្រាយនេះ[673]។

ការជួយ និងការជំរុញពុំតម្រូវឱ្យមានអំពើវិជ្ជមានណាមួយទេ។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានកត់សម្គាល់ថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ បានទទួលស្គាល់ថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើអកម្ម ដែលជួយ និងជំរុញដល់ការប្រព្រឹត្តិបទឧក្រិដ្ឋ។ អង្គជំនុំជម្រះបានសន្និដ្ឋានបន្ថែមទៀតថា ថាតើអំពើអកម្មបាន ឬមិនបានជួយ ឬជំរុញឱ្យមានបទឧក្រិដ្ឋនោះ ត្រូវយកមកកំណត់ទៅតាមករណីនីមួយៗ ហើយទំនងជាត្រូវពិនិត្យទៅលើតួនាទី និងសិទ្ធិអំណាចរបស់ជនជាប់ចោទ[674]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ បានបញ្ជាក់ជាថ្មីលើវិធីសាស្ត្រនេះ[675]។

អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានបដិសេធថា ការផ្ដន្ទាទោសចំពោះការជួយ និងការជំរុញអាចធ្វើទៅបាន ដរាបណាជំនួយ ឬការគាំទ្ររបស់ជនជាប់ចោទ "មានគោលដៅជាក់លាក់" ដើម្បីជួយសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋ (ដែលហៅជាទូទៅថា "គោលដៅជាក់លាក់" ដូចដែលត្រូវបានអនុវត្តនៅក្នុងសាលដីកាក្នុងរឿងក្ដី *Perišić* នៃតុលាការ ICTY)[676]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *Šainović* នៃតុលាការ ICTY បានបដិសេធទាំងស្រុងនូវវិធីសាស្ត្រដែលបានអនុវត្តក្នុងរឿងក្ដី *Perišić* ដោយបានធ្វើ "សេចក្ដីសន្និដ្ឋានគួរឱ្យជឿជាក់" មួយថា "គោលដៅជាក់លាក់" មិនមែនជាធាតុផ្សំសំខាន់នៃធាតុផ្សំសត្យានុម័តនៃការជួយ និងការជំរុញនោះទេ[677]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ យល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *Šainović* បានធ្វើការវិភាគដ៏ទូលំទូលាយមួយលើយុត្តិសាស្ត្ររបស់សាលាក្ដីមិនអចិន្ត្រៃយ៍ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អង្គជំនុំជម្រះក៏បានពិចារណាទៀតថា សាលដីកាក្នុងរឿងក្ដី *Taylor* នៃតុលាការពិសេសសម្រាប់សៀរ៉ាលេអូន ("SCSL") ក៏បានធ្វើការពិនិត្យដ៏គួរឱ្យជឿជាក់ស្រដៀងគ្នានេះលើយុត្តិសាស្ត្រ និងលិខិតុបករណ៍អន្តរជាតិ រួមទាំងយុត្តិសាស្ត្រ និងលិខិតុបករណ៍អន្តរជាតិដែលបានបញ្ចប់មុនឆ្នាំ១៩៧៥ ហើយបានសម្រេចថា បញ្ហាគន្លឹះនោះគឺ ថាតើអំពើរបស់ជនជាប់ចោទមានអានុភាពធំធេងទៅលើបទឧក្រិដ្ឋ

---

[671] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣២។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥០។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៤។

[672] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២១។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣២។

[673] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២១។

[674] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៦។

[675] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៤។

[676] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧០៧-៧១០។

[677] ដូចខាងលើ កថាខណ្ឌ ៧០៩។

ដែរ ឬទេ[678]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ បានបញ្ជាក់ជាថ្មីលើវិធីសាស្ត្រនេះ[679] ក៏ដូចគ្នានឹងសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/០១ ដែរ[680]។

អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ក៏បានបដិសេធអំណះអំណាងដែលថា អ្នកដែលជួយក្រោយអង្គហេតុ មិនអាចទទួលខុសត្រូវចំពោះការជួយ និងការជំរុញទេ[681]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូល ICTY បានសន្និដ្ឋានយ៉ាងច្បាស់ថា *ធាតុផ្សំសត្យានុម័ត*នៃការជួយ និងការជំរុញ "អាចកើតឡើងនៅមុន នៅក្នុងអំឡុងពេល ឬ*ក្រោយ* បទឧក្រិដ្ឋសំខាន់ត្រូវបានប្រព្រឹត្តឡើង"។ អង្គជំនុំជម្រះបានពិចារណាឃើញថា ' វិធីសាស្ត្រនេះឆ្លុះបញ្ចាំងពីការយល់ឃើញមួយថា ការផ្តល់ការសន្យាដែលធ្វើឡើងនៅមុន ឬនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តិបទឧក្រិដ្ឋដែលនឹងជួយជ្រោមជ្រែងក្រោយពីការប្រព្រឹត្តិបទឧក្រិដ្ឋ អាចជំរុញឱ្យ ឬផ្តល់ការគាំទ្រខាងស្មារតីដល់ចារី ហេតុដូច្នេះហើយមានអានុភាពធំធេងលើការប្រព្រឹត្តិបទឧក្រិដ្ឋ ហើយវិធីសាស្ត្រនេះក៏ត្រូវបានទទួលយកច្រើននៅក្នុងយុត្តិសាស្ត្រនាសម័យក្រោយសង្គ្រាមលោកលើកទី២ ផងដែរ[682]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីលើវិធីសាស្ត្រនេះនៅក្នុងសំណុំរឿង ០០២/០២[683]។

## ៣.៣. ការទទួលខុសត្រូវរបស់ថ្នាក់លើ

ការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាទម្រង់នៃការទទួលខុសត្រូវ ដែលក្នុងនោះជនជាប់ចោទអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការខកខានក្នុងការទប់ស្កាត់ និង/ឬ ដាក់ទណ្ឌកម្ម បទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយអ្នកក្រោមបង្គាប់របស់ខ្លួន។ ហេតុដូច្នេះ ការទទួលខុសត្រូវរបស់ថ្នាក់លើគឺជា "ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដោយអំពើអកម្មដែលមានពិរុទ្ធភាព"[684]។

ទ្រឹស្តីនេះត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនានានៃតុលាការយោធា ក្រោយសង្គ្រាមលោកលើកទីពីរ[685] និងក្រោយមកត្រូវបានចែងជាបន្តបន្ទាប់នៅក្នុងលក្ខន្តិកៈ និងច្បាប់យុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិ(អន្តរជាតូបនីយកម្ម) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")[686]។ ទស្សនៈនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានបញ្ចូលក្នុងការពិភាក្សាដំបូងបង្អស់អំពីការបង្កើត អ.វ.ត.ក.។ របាយការណ៍ឆ្នាំ

---

[678] ដូចខាងលើ កថាខណ្ឌ ៧១០។
[679] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៣។
[680] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៣។
[681] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១១-៧១៣។
[682] ដូចខាងលើ កថាខណ្ឌ ៧១២។
[683] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៣។
[684] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៧។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។
[685] សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៩៦-២៣០ (យោងទៅអង្គហេតុ និងសំអាងហេតុរបស់ការជំនុំជម្រះក្តីនៃតុលាការយោធានៅក្នុងរឿងក្តី *Yamashita*, *High Command*, *Hostage*, *Medical*, *Ministries*, *Roechling* និង *Toyoda* ក៏ដូចជាសាលក្រមរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា)។
[686] សូមមើល ឧទាហរណ៍ លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ *ចូលជាធរមាន* ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ មាត្រា។ លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់សៀរ៉ាលេអូន *ចូលជាធរមាន* ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២ មាត្រា ៦(៣)។ លក្ខន្តិកៈរបស់សាលាក្តីអន្តរជាតិសម្រាប់រ្វ៉ាន់ដា *អនុម័ត* ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ មាត្រា ៦(៣)។ លក្ខន្តិកៈរបស់សាលាក្តីអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី *អនុម័ត* ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ មាត្រា ៧(៣)។ សូមមើលផងដែរ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* អង្គជំនុំជម្រះសាលាដំបូង II (ICC), ICC-01/05-01/08, សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៤០៣-៤៤៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sesayនិងគូកន* អង្គជំនុំជម្រះសាលាដំបូង I (SCSL), SCSL-04-15-T, សាលក្រម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២៨១-៣១៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Aleksovski*, អង្គជំនុំជម្រះសាលាដំបូង (ICTY), IT-95/1-T, ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៦-៨១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucićនិងគូកន* អង្គជំនុំជម្រះសាលាដំបូង (ICTY), IT-96-21-T, សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៣៤៤-៤០១។

១៩៩៩ របស់ក្រុមអ្នកជំនាញ បានលើកឡើងថា “ច្បាប់អន្តរជាតិបានទទួលស្គាល់យូរមកហើយថា បុគ្គលត្រូវទទួលខុសត្រូវចំពោះអំពើ បើទោះបីជាពួកគេមិនបានប្រព្រឹត្តអំពើទាំងនោះដោយផ្ទាល់ក៏ដោយ”[687]។

មាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. ចែងអំពីមូលដ្ឋានគតិយុត្តិសម្រាប់ការចោទប្រកាន់បុគ្គលនានាតាមទ្រឹស្ដីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ មាត្រានេះចែងថា ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តក្នុងករណីដែល៖

i. មានទំនាក់ទំនងរវាងអ្នកនៅក្រោមបង្គាប់និងថ្នាក់លើ ដែលថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់
ii. ថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាព[ឧក្រិដ្ឋ] ហើយ
iii. [ថ្នាក់លើ]មិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋនេះ។

ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០១, ០០២, ០០៣ និង ០០៤[688]។ ភាពអាចអនុវត្តបាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានដោះស្រាយសង្ខេបដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១, ០០២/០១ និង ០០២/០២[689] និងត្រូវបានពិចារណាកាន់តែទូលំទូលាយដោយអង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០២[690]។ ដោយផ្អែកជាចម្បងលើច្បាប់យុត្តិសាស្ត្ររបស់សាលាក្តីយោធាក្រោយសង្គ្រាមលោកលើកទី២ ការសម្រេចទាំងអស់នេះបានបង្ហាញថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ដល់១៩៧៩[691]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងសំណុំរឿង ០០១, ០០២/០១, និង ០០២/០០២[692] បន្ទាប់ពីបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក.[693]។ សហចៅក្រមស៊ើបអង្កេតបានអនុម័តយកធាតុផ្សំដូចគ្នានេះ[694]។

---

687 UNGA/UNSC, លិខិតដូចគ្នា ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ពីអគ្គលេខាធិការទៅកាន់ប្រធានមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩, UN Doc. No. A/53/850-S/1999/231, ឧបសម្ព័ន្ធ របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់កម្ពុជា ដែលត្រូវបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ ៥២/១៣៥ កថាខណ្ឌ ៨០។

688 សំណុំរឿង ០០១ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧-១៥៨។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៧-១៥៦៣។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៨, ៨៥-៨៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៥៧៤-៥៧៥។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៣៣-១០៣៤។

689 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៤, ៧១៨-៧១៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៣-៤៧៨។

690 សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៨៥-២៣២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣៩៩-៤៦០។

691 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៤, ៧១៨-៧១៩។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៨៥-២៣២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣៩៩-៤៦០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៣-៤៧៨។

692 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥-៣៧២៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥-៧១៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣៨, ៥៤០-៥៤៧។

693 ច្បាប់ អ.វ.ត.ក. មាត្រា ២៩ (ថ្មី)។

694 សំណុំរឿង ០០១ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧-១៥៨ (សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ ឌុច ចំពោះការធ្វើការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព*តាមច្បាប់* ឬ*តាមជាក់ស្តែង* លើបុគ្គលិកមន្ទីរ ស-២១ ក្នុងចំណងជើងថា “ការទទួលខុសត្រូវរបស់មេបញ្ជាការ” ប៉ុន្តែដីកាដំណោះស្រាយមិនបានរៀបរាប់លម្អិត ឬស្វែងយល់អំពីធាតុផ្សំគតិយុត្តិនៃទ្រឹស្តីនេះទេ)។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩, ១៥៥៧-១៥៥៨។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៥-៨៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ កថាខណ្ឌ ១០៤-១០៩។ សំណុំរឿង

ក្នុងសំណុំរឿង ០០១ (ឌុច) និង ០០២/០១ (នួន ជា) ជនជាប់ចោទត្រូវបានរកឃើញថា ទទួលខុសត្រូវតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយការសន្និដ្ឋានទាំងនេះ ត្រូវបានពិចារណាក្នុងការកំណត់ទោស ដោយសារតែជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាពតាមគោលការណ៍នៃការទទួលខុសត្រូវផ្ទាល់[695]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានសន្និដ្ឋានថា ខៀវ សំផន មិនបានអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើចារីនោះទេ ហេតុដូច្នេះ មិនទទួលខុសត្រូវតាមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះឡើយ[696]។ អង្គជំនុំជម្រះតុលាការកំពូលពុំបានធ្វើការសន្និដ្ឋានសំខាន់ណាលើការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងរឿងក្តីណាមួយនោះឡើយ។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ លើការទទួលខុសត្រូវរបស់ថ្នាក់លើ មិនត្រូវបានប្តឹងសាទុក្ខទេ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការជំទាស់ភ័ស្តុតាងអំពីការសន្និដ្ឋានលើការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលបានលើកឡើងដោយ នួន ជា (សំណុំរឿង ០០២/០១) និង ខៀវ សំផន (សំណុំរឿង ០០២/០២) ផ្អែកលើមូលដ្ឋានថា ជនជាប់ចោទមិនត្រូវបានដាក់ពិរុទ្ធភាព ផ្អែកតាមការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ[697]។

### ៣.៣.១. ភាពអាចអនុវត្តបាននៅ អ.វ.ត.ក.

អ.វ.ត.ក. បានសម្រេចយ៉ាងស៊ីចង្វាក់គ្នាថា ត្រឹមឆ្នាំ១៩៧៥ ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបង្ហាញថាជាទ្រឹស្តីដែលត្រូវបានទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[698]។

ទោះបីជាភាពអាចអនុវត្តបាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ បានអនុវត្តដោយមិនមានការជំទាស់ក្នុងសំណុំរឿង ០០១ យ៉ាងណាក្តី ក៏អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយសង្ខេប ថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ឬទេ ក្នុងអំឡុងពេលឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដោយគោរពទៅតាមគោលការណ៍នីត្យានុកូលភាព[699]។ ដោយយោងរឿងក្តី *Yamashita*, *High Command* និង *Pohl* អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា រឿងក្តីក្រោយសង្គ្រាមលោកលើកទី២ បានបង្ហាញថា ការខកខានរបស់ថ្នាក់លើក្នុងការអនុវត្តកាតព្វកិច្ចត្រួតពិនិត្យអំពើឧក្រិដ្ឋរបស់ថ្នាក់ក្រោមបង្គាប់ខ្លួន អាចនាំឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ[700]។ អង្គជំនុំជម្រះសាលាដំបូងក៏បានឯកភាពផងដែរជាមួយនឹងការសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងរឿងក្តី*រដ្ឋអាជ្ញា* ទល់នឹង *Hadžihasanović និងគូកន* ដែលថា មាត្រា ៨៦ និង ៨៧ នៃពិធីសារបន្ថែម I ឆ្នាំ១៩៧៧ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បានឆ្លុះបញ្ចាំងពីការព្រមព្រៀងបុរេអត្ថិភាព ទាក់ទងនឹងទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[701]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើមានមូលដ្ឋានរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[702]។

---

០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨-១០៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៧-១០២។

[695] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៨៩២-៨៩៨, ៩៣២-៩៣៩, ៩៤០-៩៤១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៨-៥៤៩។

[696] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០១៦-១០២២។

[697] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៧៤៥។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៤១-៤២, ៤៩។

[698] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៤។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៩៦-២៣០។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤២១-៤៦០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៣-៤៧៨។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៨។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៧, ១៣១៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៤។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។

[699] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៣។

[700] ដូចខាងលើ កថាខណ្ឌ ៤៧៥-៤៧៦។

[701] ដូចខាងលើ កថាខណ្ឌ ៤៧៦។

[702] ដូចខាងលើ។

ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់វិធីសាស្ត្រនេះ ដោយសម្រេចថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានជនជាប់ចោទដឹងថាជាបទល្មើស និងមានច្បាប់ចែង នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង/ឬច្បាប់ជាតិកម្ពុជា[703]។ ដោយពិចារណាលើអំណះអំណាងរបស់ នួន ជា ថាមានភាពខុសគ្នានៅក្នុងបទដ្ឋាន*ធាតុផ្សំអត្តនោម័ត*រវាងតុលាការកំពូលសហរដ្ឋអាមេរិក (*Yamashita*) និងការសម្រេចដោយចៅក្រមសាលាដំបូងនៃតុលាការយោធាសហរដ្ឋ (*Medina*) ដែលបង្ហាញពី "ការខ្វះភាពច្បាស់លាស់នៅក្នុងនិយមន័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើ"នោះ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានបញ្ជាក់ថា "ភាពមិនស៊ីចង្វាក់គ្នារវាងរឿងក្តីទាំងពីរនៅក្នុងរដ្ឋតែមួយនេះ មិនអាចត្រូវបានយកមកធ្វើជាសំអាងថា ទម្រង់នៃការទទួលខុសត្រូវ មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះបានឡើយ"[704]។

អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០២ បានធ្វើការវាយតម្លៃយ៉ាងម៉ត់ចត់បំផុតលើការទទួលខុសត្រូវរបស់ថ្នាក់លើ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ នៅពេលធ្វើការសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ និង អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២[705]។ ការវិវឌ្ឍន៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ "មានភាពអវិជ្ជមាន" ដោយសារព្រឹត្តិការណ៍នានាក្រោយសង្គ្រាមលោកលើកទីមួយ ជាពិសេស គណៈកម្មការទីក្រុងប៉ារីស និងការជំនុំជម្រះក្តីបុគ្គល ១២ រូប នៅចំពោះមុខតុលាការកំពូល Reich របស់អាល្លឺម៉ង់[706]។ ទោះជាយ៉ាងណា វា "មានតែក្រោយពេលសង្គ្រាមលោកលើកទី២រួចប៉ុណ្ណោះ ទើបការកាត់សេចក្តីជាអន្តរជាតិដែលផ្អែកលើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានធ្វើឡើងពិតប្រាកដ"[707]។ អង្គបុរេជំនុំជម្រះបានពិនិត្យអង្គហេតុ និងការរកឃើញនានារបស់ការជំនុំជម្រះក្នុងរឿងក្តី *Yamashita* រឿងក្តីនៅចំពោះមុខសាលាក្តីយោធា Nuremberg (រឿងក្តី *High Command*, *Hostage*, *Medical*, *Ministries* និង *Roechling*) សាលក្រមនៃសាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMTFE") និងការសម្រេចរបស់សាលាក្តីយោធាអូស្ត្រាលី/ស.រ.អ ក្នុងរឿងក្តី *Toyoda*[708]។ ជារួម អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ទោះបីជា "ការបញ្ជាក់អំពីទម្រង់នៃធាតុផ្សំជាមូលដ្ឋាននៃទ្រឹស្តីនេះ មិនតែងតែមានលក្ខណៈច្បាស់លាស់ ឬ

[703] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៤។

[704] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៩។ អង្គជំនុំជម្រះសាលាដំបូងក៏ច្រានចោលការជំទាស់របស់ នួន ជា ភ្លាមៗទៅនឹងការអនុវត្តជារួមនៃទ្រឹស្តីនេះ ដោយផ្អែកលើមូលដ្ឋានថា រូបគាត់ធ្វើតាមអំណះអំណាងពីមុនរបស់ អៀង សារី និង អៀង ធីរិទ្ធ ដែលត្រូវបានពិចារណា និងច្រានចោលរួចហើយដោយអង្គបុរេជំនុំជម្រះ។ សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៨។

[705] សហចៅក្រមស៊ើបអង្កេតបានសង្កេតឃើញថា មាត្រា ២៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក. បានបង្កើតបទប្បញ្ញត្តិនានាអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយបានយោងទៅធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលបានគូសបញ្ជាក់ក្នុងសាលក្រមនៃសំណុំរឿង។ បន្ថែមលើទម្រង់នៃការទទួលខុសត្រូវដែលមិនមានបង្ហាញច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ពោលគឺ សហឧក្រិដ្ឋកម្មរួម ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ) ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ បានសន្និដ្ឋានថា ទ្រឹស្តីទាំងអស់នេះ "ត្រូវបានទទួលស្គាល់ផងដែរដោយច្បាប់អន្តរជាតិ ឆ្លងតាមរយៈការជំនុំជម្រះនានា ដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ"។ សូមមើល សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៧, ១៣១៨។ ទោះបីជាសហចៅក្រមស៊ើបអង្កេតយោងទៅលើការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទីពីរ នៅក្នុងការសម្រេចផ្អែកតាមអត្ថបទយ៉ាងណាក្តី ក៏ការយោងសំអាងមិនបានសំដៅទៅលើច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរនោះទេ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានយោងទៅសាលក្រមសំណុំរឿង ០០១ និង ការសម្រេចរបស់តុលាការ ICTY ដែលបានបង្ហាញគោលការណ៍ដែល "អំពើដែលគ្មានសីលធម៌ ឬឃោរឃៅ" អាចដើរតួនាទីក្នុងការបង្កើតឧក្រិដ្ឋភាព។ សូមមើល សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៥, ១៣០៧។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣២, ២៩៥, ៤០៧។

[706] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៩៣-១៩៤។

[707] ដូចខាងលើ កថាខណ្ឌ ១៩៥។

[708] ដូចខាងលើ កថាខណ្ឌ ១៩៦-២៣០។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤២១-៤៦០។

ពេញលេញ” ក៏គោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ រួមជាមួយនឹងធាតុផ្សំសំខាន់របស់វា ត្រូវបានបញ្ជាក់ដោយរឿងក្តីក្រោយសង្គ្រាមលោកលើកទី២[709]។

នៅក្នុងការច្រានចោលបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា រឿងក្តីពីសាលាក្តីយោធាក្រោយសង្គ្រាមលោកលើកទី២ បានបង្ហាញពីការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ដូចជាឧក្រិដ្ឋកម្មសង្គ្រាម[710]។ នៅក្នុងការច្រានចោលបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អង្គបុរេជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា ទម្រង់នៃការទទួលខុសត្រូវ “តាមបទដ្ឋានអន្តរជាតិ” ពោលគឺ សហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ អនុវត្តតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ[711]។

ក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតបានលើកឡើងយ៉ាងសង្ខេបអំពីនីត្យានុកូលភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយអនុវត្តតាមវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងបានសម្រេចថា ទ្រឹស្តីនេះត្រូវបានបង្កើតឡើងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក.[712]។ សហចៅក្រមស៊ើបអង្កេតបានអនុម័តយកវិធីសាស្ត្រដូចគ្នា ក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤[713]។ ក្នុងការច្រានចោលអំណះអំណាងរបស់ មាស មុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានថា មាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. បានចែងយ៉ាងច្បាស់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើ បានអនុវត្តទៅលើអំពើប្រល័យពូជសាសន៍[714] ហើយបានសន្និដ្ឋានទៀតថា ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តយ៉ាងច្បាស់លាស់ចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិ និងជម្លោះប្រដាប់អាវុធមិនមានលក្ខណៈអន្តរជាតិ[715]។ សហចៅក្រមស៊ើបអង្កេតជាតិ មិនបានធ្វើការប្រកាសណាមួយទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវនេះទេ។

## ៣.៣.២. ធាតុផ្សំ

មាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. គូសបញ្ជាក់ធាតុផ្សំសំខាន់ចំនួនបី នៃទ្រឹស្តីអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលត្រូវបានអភិវឌ្ឍបន្ថែមទៀតដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១, ០០២/០១ និង ០០២/០២។ ធាតុផ្សំសំខាន់ៗទាំងនេះមាន៖

i. ទំនាក់ទំនងរវាងអ្នកនៅក្រោមបង្គាប់និងថ្នាក់លើ ដោយមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យ
ii. ថ្នាក់លើបានដឹង និងមានហេតុផលដឹងថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តឡើង ឬបានប្រព្រឹត្តឡើងហើយ និង

[709] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ២៣០។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥៨, ៤៦០។
[710] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ២៣១។
[711] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ២៩៦។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១២១។
[712] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៨។
[713] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៣។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។
[714] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៣។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅ “មាត្រា ២៩” ជាជាងមាត្រា ២៩(ថ្មី) ដែលហាក់ដូចជាការធ្វេសប្រហែស។
[715] សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩ ដែលមិនមានការបែបចែកដាច់ពីគ្នាត្រូវបានធ្វើឡើងរវាងជម្លោះប្រដាប់អាវុធជាតិ និងអន្តរជាតិ។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៤។

iii. ថ្នាក់លើមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ[716]។

### ៣.៣.២.១. ទំនាក់ទំនងរវាងអ្នកនៅក្រោមបង្គាប់និងថ្នាក់លើ ដោយមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យ

ខុសពីលក្ខន្តិកៈតុលាការ ICTY, ICTR និង SCSL មាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. រួមបញ្ចូលសញ្ញាណនៃការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពនៅក្នុងទម្រង់លក្ខន្តិកៈ ដោយចែងថា ថ្នាក់លើត្រូវតែ "មានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់"។ ម្យ៉ាងវិញទៀត អ.វ.ត.ក. បានអនុវត្តយ៉ាងម៉ត់ចត់តាមវិធីសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍ ក្នុងការអនុវត្ត និងការបកស្រាយ ធាតុផ្សំនៃការគ្រប់គ្រងដ៏មានប្រសិទ្ធភាព នៅក្នុងទំនាក់ទំនងរវាងថ្នាក់លើនឹងថ្នាក់ក្រោម[717]។ អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងច្បាស់លាស់ថា ការគ្រប់គ្រងរបស់ថ្នាក់លើ អាច*តាមព្រឹត្តិហេតុ* និង*តាមផ្លូវច្បាប់* នោះទេ នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២ បើទោះបីជាការសន្និដ្ឋាននេះមាននៅក្នុងការសម្រេច ក្នុងសាលក្រមទាំងពីរដែលថា "ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព" ដែលមានន័យថា ការមានលទ្ធភាពជាក់ស្តែងក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មបទឧក្រិដ្ឋ ត្រូវតែបញ្ជាក់ភ័ស្តុតាង[718]។

មិនមានលក្ខខណ្ឌតម្រូវឱ្យមានការចាត់តាំងផ្លូវការ ជាមេបញ្ជាការ ឬជាថ្នាក់លើ ដើម្បីឱ្យមានការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលកើតឡើងដោយសារអំណាចរបស់ថ្នាក់លើ *តាមច្បាប់* ឬ*តាមជាក់ស្តែង* ទៅលើអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋនោះឡើយ[719]។ ថាតើថ្នាក់លើមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពឬយ៉ាងណានោះ គឺជាបញ្ហាភ័ស្តុតាង មិនមែនជាបញ្ហាអង្គច្បាប់នោះទេ ហើយដូច្នេះ បញ្ហានេះត្រូវតែវាយតម្លៃដោយផ្អែកលើករណីជាក់ស្តែងនីមួយៗ[720]។ គោលការណ៍សំខាន់នៃវិធីសាស្ត្រនេះគឺលទ្ធភាពជាក់ស្តែងក្នុងការទប់ស្កាត់ និងដាក់ទណ្ឌកម្មការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ថ្នាក់ក្រោម[721]។ កត្តានានាដែលបង្ហាញពីការគ្រប់គ្រងដ៏មានប្រសិទ្ធភាព រួមមាន ប្រភេទនៃតួនាទីរបស់ជនជាប់ចោទ សមត្ថភាពក្នុងការចេញបញ្ជា

[716] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥-៣៧២៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៣៨, ៥៤០-៥៤៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៨។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៧, ១៣១៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៧-១០៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨-១០៣។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៤-១០៩។

[717] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥, ៧២០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤០។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។

[718] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។

[719] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤០។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥៩។

[720] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥, ៧២០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤១។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥៩។

[721] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤០។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។

អំណាចក្នុងការប្រើប្រាស់វិធានការវិន័យ និងអំណាចដោះលែង ឬផ្ទេរអ្នកទោស[722]។ ផ្ទុយទៅវិញ "ឥទ្ធិពលជាសារធាតុតែមួយមុខ គឺមិនបង្កើតឱ្យមានប្រសិទ្ធភាពនៃការគ្រប់គ្រង នៅក្នុងរចនាសម្ព័ន្ធនៃការបញ្ជាឡើយ"[723]។

ពាក្យ "ថ្នាក់លើ" សម្រាប់គោលបំណងនេះ រួមបញ្ចូល ថ្នាក់លើជាស៊ីវិល ព្រមទាំង ថ្នាក់លើជាយោធា[724]។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ នៅពេលធ្វើការដោះស្រាយការជំទាស់ដាច់ដោយឡែករបស់ អៀង ធីរិទ្ធ និង អៀង សារី បានសង្កេតថា សាលក្រម IMTFE និងសាលក្រមក្រោយសង្គ្រាមលោកលើកទី២ បានអនុម័តប្រើសញ្ញាណនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដែល "ពុំមានការវិវឌ្ឍន៍" ដូចនិយមន័យបច្ចុប្បន្ន ដោយយោងទៅលើការវិភាគពីការគ្រប់គ្រងដ៏មានប្រសិទ្ធភាព[725]។ ជាពិសេស សាលក្រម IMTFE "ពុំបានបញ្ជាក់នូវសំអាងហេតុឱ្យបានច្បាស់ ដែលបង្ហាញអំពីទំនាក់ទំនងបែបនោះ ប៉ុន្តែទំនងជាធ្វើការសន្និដ្ឋាន ដោយផ្អែកលើតួនាទីរបស់ជនជាប់ចោទ"[726]។ ជាលទ្ធផលសាលាក្តី IMTFE មិនមានភាពដាច់ស្រេចចំពោះបញ្ហាចោទថាតើ ទ្រឹស្តីនេះពង្រីកវិសាលភាពទៅដល់ថ្នាក់លើដែលពុំមែនជាយោធា ឬយ៉ាងណា ពីព្រោះតុលាការនេះពុំបានបញ្ជាក់សំអាងហេតុ ថាមានទំនាក់ទំនងថ្នាក់លើនិងថ្នាក់ក្រោមបង្គាប់ *តាមច្បាប់* ឬ *តាមជាក់ស្តែង* ដែរឬទេ រវាងមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកយោធាដែលពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋ[727]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ទ្រឹស្តីនេះពង្រីកវិសាលភាពទៅដល់ថ្នាក់លើដែលជាយោធា និងថ្នាក់លើដែលមិនមែនជាយោធា[728]។

បទដ្ឋានដូចគ្នានៃការគ្រប់គ្រងដ៏មានប្រសិទ្ធភាពអនុវត្ត មិនចំពោះថាថ្នាក់លើមានសាវតារជាស៊ីវិល ឬជាយោធានោះទេ។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការលើកឡើងរបស់ នួន ជា ដែលថា ថ្នាក់លើជាស៊ីវិលអាចទទួលខុសត្រូវតែក្នុងកម្រិតដែលថា ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្លួនលើថ្នាក់ក្រោមបង្គាប់ មានលក្ខណៈស្រដៀងគ្នាទៅនឹងការគ្រប់គ្រងដែលធ្វើឡើងដោយថ្នាក់លើជាយោធាតែប៉ុណ្ណោះ[729]។ កាតព្វកិច្ចក្នុងការចាត់វិធានការកើតចេញពីសញ្ញាណនៃការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ដោយមិនគិតថាតើ ជនជាប់ចោទជាថ្នាក់លើនៅក្នុងជួរស៊ីវិល ឬថ្នាក់លើនៅក្នុងជួរយោធានោះទេ[730]។

ការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តទៅលើទាំងទំនាក់ទំនងផ្ទាល់ និងទំនាក់ទំនងដោយប្រយោលរបស់ថ្នាក់ក្រោមបង្គាប់[731]។ បុគ្គលម្នាក់ៗនៅក្នុងខ្សែចង្វាក់នៃការបញ្ជា ដែលបានអនុវត្តការ

---

[722] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤១។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥៩ ("បញ្ហានេះគឺសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់អំពីតួនាទីពិតប្រាកដ និងអំពីកម្រិតនៃការគ្រប់គ្រងលើអ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរចនាសម្ព័ន្ធនៃរបបខ្មែរក្រហមស្របតាមអង្គហេតុនៃរឿងក្តីនេះ ហើយផ្អែកលើមូលដ្ឋាននេះ ថាតើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តចំពោះជនជាប់ចោទទាំងនោះ ឬមិនអនុវត្ត")។

[723] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០២១។

[724] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩, ១៥៥៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៧-៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។

[725] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥៤។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ២២៥។

[726] ដូចខាងលើ។

[727] ដូចខាងលើ។

[728] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥៩។ នៅក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះបានបដិសេធមិនពិចារណាលើបញ្ហាថាតើ ទ្រឹស្តីនេះអនុវត្តលើថ្នាក់លើផ្នែកស៊ីវិល ឬទេ ដោយសារថាបញ្ហានេះមិនត្រូវបានលើកឡើងច្បាស់លាស់ដោយ អៀង ធីរិទ្ធ។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៩២, ២៣០។

[729] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧២០។

[730] ដូចខាងលើ។

[731] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧២១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤២។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៩។

គ្រប់គ្រងដ៏មានប្រសិទ្ធភាពលើថ្នាក់ក្រោមបង្គាប់ អាចត្រូវបានចាត់ទុកថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម របស់ថ្នាក់ក្រោមបង្គាប់ ក្នុងលក្ខខណ្ឌដែលថាធាតុផ្សំផ្សេងទៀត នៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបង្ហាញ[732]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងរបស់ នួន ជា ដែលថា យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ថ្នាក់លើអាចទទួលខុសត្រូវចំពោះតែអំពើរបស់ថ្នាក់ក្រោមបង្គាប់ផ្ទាល់ប៉ុណ្ណោះ ផ្ទុយទៅវិញយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ បានបង្ហាញយ៉ាងច្បាស់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើ "មិនកម្រិតត្រឹមការគ្រប់គ្រងលើអង្គភាពនៅក្រោមការបញ្ជាផ្ទាល់របស់ថ្នាក់លើនោះឡើយ"[733]។

### ៣.៣.២.២. ថ្នាក់លើបានដឹង ឬមានហេតុដឹងថាបទឧក្រិដ្ឋបម្រុងនឹងត្រូវបានប្រព្រឹត្តឡើង ឬត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន

លក្ខខណ្ឌតម្រូវដែលថា ថ្នាក់លើត្រូវតែបានដឹង ឬមានហេតុដឹងថាបទឧក្រិដ្ឋបម្រុងនឹងត្រូវបានប្រព្រឹត្តឡើង ឬត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន គឺជាលក្ខខណ្ឌតម្រូវ*ធាតុផ្សំអត្តនោម័ត*សម្រាប់ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[734]។

មានសេណារីយ៉ូពីរដែលអាចបំពេញធាតុផ្សំនេះ៖ ស្ថានភាពដែលបទឧក្រិដ្ឋបានកើតឡើងរួចហើយ និងស្ថានភាពដែលបទឧក្រិដ្ឋមិនទាន់បានកើតឡើង ហើយអាចទប់ស្កាត់បាន។ ការដឹងអំពីបទឧក្រិដ្ឋ ដែលបានកើតឡើងហើយនោះ មិនអាចសន្មតជាមុននោះទេ ហើយអាចបង្ហាញតាមរយៈភស្តុតាងផ្ទាល់ ឬភស្តុតាងប្រយោល[735]។ ថ្នាក់លើត្រូវតែបានដឹងអំពីអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន និងមិនមែនគ្រាន់តែដឹងអំពីការកើតមានឡើងនូវឧក្រិដ្ឋកម្មប៉ុណ្ណោះទេ[736]។

បទដ្ឋាននៃ "ការខកខានក្នុងការដឹង" នឹងអនុវត្តនៅពេលដែល នៅក្នុងកាលៈទេសៈនៃសំណុំរឿង ថ្នាក់លើមានព័ត៌មាន "គ្រប់គ្រាន់" ដែលតម្រូវឱ្យធ្វើការស៊ើបអង្កេតថែមទៀត[737]។ ព័ត៌មានអាចមានលក្ខណៈទូទៅ ហើយមិនចាំបាច់មានព័ត៌មានលម្អិតជាក់លាក់អំពីបទឧក្រិដ្ឋនោះទេ[738]។ ថ្នាក់លើពុំចាំបាច់ដឹងអំពីអត្តសញ្ញាណច្បាស់លាស់របស់ចារីដែលជាអ្នកក្រោមបង្គាប់របស់ខ្លួនឡើយ ប៉ុន្តែអត្ថិភាពនៃអត្ត

---

សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៨។

[732] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧២១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤២។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៩។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០២។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៨។

[733] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧២១ (ដកស្រង់ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤២)។

[734] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៣។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៧។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៦, ១០៩។

[735] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៣។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥។

[736] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៣។

[737] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៤។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៦។

[738] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៤។

សញ្ញាណនេះត្រូវតែបញ្ជាក់[739]។ ថ្នាក់លើមិនទទួលខុសត្រូវ ចំពោះការខកខានមិនបានស្វែងរកព័ត៌មានតាំងពីដំបូងនោះទេ ប៉ុន្តែមិនអាចមានចេតនាមិនព្រមទទួលព័ត៌មាននោះទេ នៅពេលដែលមានមធ្យោបាយក្នុងការទទួលព័ត៌មាននោះ[740]។

### ៣.៣.២.៣. ការខកខានក្នុងការចាត់វិធានការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម

យុត្តិសាស្ត្ររបស់ អ.វ.ត.ក. តម្រូវឱ្យថ្នាក់លើខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្របក្នុងការទប់ស្កាត់បទឧក្រិដ្ឋ ឬ ដាក់ទណ្ឌកម្មចារី[741]។ លក្ខខណ្ឌតម្រូវក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មនេះឆ្លុះបញ្ចាំងពី "កាតព្វកិច្ច"[742]។ មិនមានកាតព្វកិច្ចនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ដើម្បីឱ្យមានកាតព្វកិច្ចក្នុងការចាត់វិធានការ ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិឡើយ[743]។

ការខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មមានភាពដាច់ដោយឡែកពីគ្នាខាងអង្គហេតុ និងអង្គច្បាប់ ទាក់ទងនឹងប្រភេទនៃការដឹងឮដែលមាន៖ កាតព្វកិច្ចក្នុងការទប់ស្កាត់កើតឡើងនៅមុនពេលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង ចំណែកឯកាតព្វកិច្ចក្នុងការដាក់ទណ្ឌកម្មវិញ កើតឡើងក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួន[744]។ ថ្នាក់លើអាចត្រូវទទួលខុសត្រូវចំពោះការខកខានទាំងពីរនេះ[745]។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា *ធាតុផ្សំសត្យានុម័ត* នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវតែកើតមុនបទឧក្រិដ្ឋ ដោយផ្អែកលើការសន្និដ្ឋានថា ការទទួលខុសត្រូវក្នុងការដាក់ទណ្ឌកម្មចារី អាចកើតឡើងក្រោយបទឧក្រិដ្ឋ[746]។ មិនចាំបាច់បង្ហាញពីចំណងទាក់ទងហេតុនឹងបច្ច័យ រវាងការខកខានរបស់ថ្នាក់លើក្នុងការទប់ស្កាត់បទឧក្រិដ្ឋរបស់ថ្នាក់ក្រោម និង ការកើតឡើងនៃបទឧក្រិដ្ឋនោះទេ[747]។

---

[739] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០០។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៦។

[740] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៤។

[741] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៥។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩, ១៥៥៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។

[742] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧២០។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៥៧-១៥៥៨។

[743] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧២០។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៧៧។

[744] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៦-៥៤៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៨។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៧។

[745] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៦។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៨។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០០។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០១។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៧។

[746] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៦។

[747] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៦ សម្គាល់ជើងទំព័រ ១២៤៣៨ (យោងទៅ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៦ (នៅពេលដកស្រង់រឿងក្តីតុលាការ ICTY អង្គជំនុំជម្រះសាលាដំបូងយោងទៅ ការខកខានក្នុងការដាក់ទណ្ឌកម្ម ជាជាងការទប់ស្កាត់បទឧក្រិដ្ឋ ដែលទំនងជាការធ្វេសប្រហែស) ។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៦។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៩។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៥។

បញ្ហាចោទដែលថាអ្វីទៅជាវិធានការចាំបាច់ និងសមហេតុផលនោះ ត្រូវតែពិចារណាតាមករណីជាក់ស្តែងនីមួយៗ[748]។ បញ្ហានេះមិនមែនជាបញ្ហាអង្គច្បាប់ទេ ប៉ុន្តែគឺជាបញ្ហាភស្តុតាង[749]។ វិធានការចាំបាច់គឺជាវិធានការទាំងឡាយណាដែលសមស្រប នៅក្នុងកាលៈទេសៈនានា ដើម្បីឱ្យថ្នាក់លើអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលបង្ហាញនូវការខិតខំប្រឹងប្រែងពិតប្រាកដក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម[750]។ វិធានការសមស្របគឺជាវិធានការណ៍ទាំងឡាយណា ដែលស្ថិតក្នុងអំណាចជាក់ស្តែងរបស់ថ្នាក់លើ[751]។

## ៣.៤. សហឧក្រិដ្ឋកម្មរួម

សហឧក្រិដ្ឋកម្មរួម (“JCE”) គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយស្ថានភាពនៃការប្រព្រឹត្តបទឧក្រិដ្ឋជាសមូហភាព ដែលបុគ្គលពីរឬច្រើននាក់ធ្វើសកម្មភាពរួមគ្នា ដើម្បីសម្រេចបានគោលបំណងឧក្រិដ្ឋរួម។ យោងតាមទម្រង់នៃការទទួលខុសត្រូវនេះ បុគ្គលទាំងឡាយអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលពួកគេបានចូលរួម និងបានរួមចំណែកយ៉ាងសំខាន់ ជាមួយនឹងបុគ្គលផ្សេងទៀត ទោះបីជាក្នុងករណីដែលពួកគេស្ថិតនៅឆ្ងាយពីការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយផ្ទាល់ក៏ដោយ[752]។

JCE មិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុងច្បាប់ជាតិកម្ពុជានោះទេ ហើយក៏មិនមានចែងច្បាស់នៅក្នុងច្បាប់ អ.វ.ត.ក. ដែរ។ ទោះជាយ៉ាងណា វាត្រូវបានចាត់ទុកថាជាទម្រង់មួយនៃ “ការប្រព្រឹត្តិ” ដែលស្ថិតនៅក្នុងវិសាលភាពនៃមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក.[753]។

ទោះបីជាទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវបានចាត់ទុកថាបានមានអត្ថិភាព នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាំងពីពេលជំនុំជម្រះក្តីរបស់តុលាការ Nuremberg យ៉ាងណាក៏ដោយ ក៏វាត្រូវបានប្រកាសជាលើកដំបូងថាជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយដាច់ដោយឡែក ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុងរឿងក្តី *Tadić* ក្នុងខែកក្កដា ឆ្នាំ១៩៩៩ ដែលបានរៀបរាប់ថាវាមានបីទម្រង់គឺ៖ JCE I, JCE II និង JCE III[754]។ ធាតុផ្សំសត្យានុម័តសម្រាប់ទម្រង់នីមួយៗគឺដូចគ្នា ពោលគឺត្រូវមានមនុស្សច្រើន គោលបំណងរួម (ពេលខ្លះត្រូវបានហៅថាផងដែរថាផែនការរួម) និង ការចូលរួមចំណែកជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទក្នុងការអនុវត្តគោលបំណងរួម[755]។ គឺធាតុផ្សំអត្តនោម័តដែលញែកប្រភេទទាំងអស់នេះឱ្យដាច់ពីគ្នា។ JCE I ដែលត្រូវបានស្គាល់ថាជា “ទម្រង់មូលដ្ឋាន” តម្រូវឱ្យមានចេតនាចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបង្កើតបានជាផ្នែកមួយនៃគោលបំណងរួម។ JCE II ដែលត្រូវបានស្គាល់ថាជា “ទម្រង់ជាប្រព័ន្ធ” ត្រូវបានចាត់ទុកថាជាទម្រង់មួយនៃ JCE I[756]។ វាតម្រូវឱ្យមានការដឹងឮជាបុគ្គលអំពី

---

[748] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៥។
[749] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៥។
[750] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧២៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៧១៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៤៥។
[751] ដូចខាងលើ។
[752] សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ១០១។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៤។
[753] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៤៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៩៥, ១១៦។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៨, ១៥២១។
[754] សូមមើល សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៧៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៤-៥០៧។
[755] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៨។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១០។ សម្រាប់ព័ត៌មានបន្ថែមស្តីពីធាតុផ្សំសត្យានុម័តរបស់ JCE សូមមើលផ្នែក ៣.៤.២.១។
[756] សូមមើល សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៧៥ សម្គាល់ជើងទំព័រ ២០៣០។

ប្រព័ន្ធនៃការធ្វើបាប និងចេតនាក្នុងការជំរុញវា[757]។ JCE III ដែលត្រូវបានគេស្គាល់ថាជា "ទម្រង់ទូលាយ" តម្រូវឱ្យមានចេតនាចូលរួមក្នុងគោលបំណងរួម និងបានរួមចំណែកក្នុងការអនុវត្តគោលបំណងរួមនោះ ដោយមានការទទួលខុសត្រូវកើតឡើងចំពោះឧក្រិដ្ឋកម្មផ្សេងៗ ដែលស្ថិតនៅក្រៅគោលបំណងរួម ដែលជនជាប់ចោទបានប្រមើលដឹងជាមុនអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ហើយមានចេតនាទទួលយកហានិភ័យនោះ[758]។

ទោះបីជា JCE ត្រូវបានអនុវត្តនៅក្នុងរឿងក្តីជាច្រើននៅសាលាក្តីមិនអចិន្ត្រៃយ៍នៅមុនការចាប់ផ្តើមប្រតិបត្តិការរបស់ អ.វ.ត.ក. គឺនៅពេលដែលច្បាប់ អ.វ.ត.ក. ត្រូវបានអនុម័តលើកដំបូងដោយសភាជាតិនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០១ យ៉ាងណាក៏ដោយ ក៏ JCE ត្រូវបានអនុវត្តដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ប៉ុណ្ណោះ។ ហេតុដូច្នេះ មានបញ្ហាចោទមួយចំនួន មិនត្រឹមតែពាក់ព័ន្ធនឹងឋានៈរបស់ JCE នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថាតើគេមានបំណងដាក់បញ្ចូលទម្រង់នៃការទទួលខុសត្រូវនេះក្នុងច្បាប់ អ.វ.ត.ក. ដែរឬទេ ដែលច្បាប់នេះមិនមានចែងច្បាស់លាស់អំពីទម្រង់នេះឡើយ។

### ៣.៤.១. ភាពអាចអនុវត្តបាននៅ អ.វ.ត.ក.

JCE I និង JCE II ត្រូវបានសម្រេចថាអាចអនុវត្តបាននៅ អ.វ.ត.ក. ជាពិសេសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ[759]។ JCE III ត្រូវបានពិចារណាថាមិនអាចអនុវត្តបាននៅ អ.វ.ត.ក. ទេ[760]។

អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន ក្នុងការដោះស្រាយឧក្រិដ្ឋកម្មដែលស្ថិត*ក្នុង*គោលបំណងរួម (JCE I និង II)[761]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា JCE មិនអាចត្រូវបានអនុវត្តទៅលើបុគ្គលដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងឡាយ ដែលស្ថិត*នៅក្រៅ*គោលបំណងរួម (JCE III) នោះឡើយ[762]។ អង្គជំនុំជម្រះតុលាការកំពូលមិនចង់ប្រើឈ្មោះ JCE I, II និង III ទេ ដោយសារតែឈ្មោះទាំងនេះមិនត្រូវបានប្រើនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ទេ និងពុំមានការកំណត់និយមន័យច្បាស់លាស់ផ្នែកច្បាប់ដាច់ដោយឡែក

---

[757] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៏នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្ម ទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៥។

[758] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧៦៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៏នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្ម ទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៦។ សម្រាប់ព័ត៌មានបន្ថែមស្តីពីធាតុផ្សំអត្តនោម័តរបស់ JCE III សូមមើល ផ្នែក ៣.៤.២.២។

[759] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៤-៥១៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៥៣-៦៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៏នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្ម ទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់ថា JCE I និង II អាចអនុវត្តបាន តែ JCE III មិនអាចអនុវត្តបានទេ ដោយបានតម្កល់ការផ្តន្ទាទោស នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តតាមរយៈ JCE I ក្នុងសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើការកំណត់ឡើងវិញនូវបទល្មើសការជួយ និងការជំរុញរបស់ ខៀវ សំផន ទៅជាការទទួលខុសត្រូវតាមរយៈ JCE វិញ នៅក្នុងសំណុំរឿង ០០២/០២។ សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៤៦-១៩៧៦។ សំណុំរឿង ០០២/០១ សាលដីកា ផ្នែក VI។

[760] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨០៧។ សំណុំរឿង ០០២ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E100/6 កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៨៧-៨៨។

[761] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨០៧។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៦១។

[762] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨០៧។

ពុំត្រូវគ្នានោះឡើយ[763]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាមូលដ្ឋានរបស់ JCE យ៉ាងទូលំទូលាយនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយធ្វើការពិនិត្យមើលយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ដែលបានយោងដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* និងដោយសហព្រះរាជអាជ្ញា ក៏ដូចជារឿងក្តីមួយចំនួនទៀត[764]។ រឿងក្តីផ្សេងទៀត ដែលត្រូវបានពិចារណាគឺ *Rüsselsheim* គណៈកម្មការយោធា ស.រ.អា. ក្នុងរឿងក្តីអាល្លឺម៉ង់ *Tashiro* គណៈកម្មការយោធា ស.រ.អា. ក្នុងរឿងក្តីជប៉ុន និងរឿងក្តីយោធាអូស្ត្រាលីចំនួនបីគឺ៖ *Hatakeyama*, *Matsumoto* និង *Ishiyama* និង*Yasusaka*។ អង្គជំនុំជម្រះតុលាការកំពូលមិនអាចសន្និដ្ឋានបានថា ទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានអនុវត្តនៅក្នុងរឿងក្តីទាំងអស់នោះគឺជាទម្រង់ JCE III នោះឡើយ[765]។ អង្គជំនុំជម្រះយល់ឃើញថា រឿងក្តី និងបណ្តឹងវិវាទមួយចំនួនធំ ដែលត្រូវបានលើកឡើងថាគាំទ្រ JCE III មិនមានធាតុផ្សំអន្តរជាតិទេ ហេតុដូច្នេះមិនអាចជាមូលដ្ឋានសម្រាប់ការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[766]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានពន្យល់ផងដែរថា ឧទាហរណ៍នានាអំពីច្បាប់ក្នុងស្រុក មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីអត្ថិភាពនៃគោលការណ៍ទូទៅនៃច្បាប់ ដែលបទឧក្រិដ្ឋរបស់អ្នកដទៃអាចត្រូវបានដាក់ការទទួលខុសត្រូវទៅលើជនជាប់ចោទ ដែលមិនបានអនុវត្ត*ធាតុផ្សំសត្យានុម័ត* ដោយផ្ទាល់នោះឡើយ នៅពេលដែលបទឧក្រិដ្ឋទាំងអស់នេះមិនមានគ្របដណ្តប់នៅក្នុងគោលបំណងរួម[767]។

អង្គបុរេជំនុំជម្រះបានធ្វើការវិភាគយ៉ាងស៊ីជម្រៅបំផុតលើ JCE I និង II នៅពេលធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, អៀង សារី, ខៀវ សំផន និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលថា JCE នៅក្នុងទម្រង់នីមួយៗរបស់ខ្លួន អាចត្រូវបានអនុវត្តនៅ អ.វ.ត.ក.[768]។ អង្គបុរេជំនុំជម្រះបានសម្រេចថា JCE I និង II អាចអនុវត្តបាន ប៉ុន្តែថា JCE III មិនអាចត្រូវបានអនុវត្តនៅ អ.វ.ត.ក. ទេ[769]។ អង្គបុរេបានពិនិត្យមើលយុត្តិសាស្ត្រអន្តរជាតិ និងអនុសញ្ញានិងការប្រកាសដ៏គួរឱ្យជឿជាក់មួយចំនួន ហើយបានសន្និដ្ឋានថា JCE I និង II ត្រូវបានទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥[770]។ អង្គបុរេមិនបានកំហិតខ្លួនឯងត្រឹមការវិភាគរឿងក្តីនានា ដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* នោះទេ (ដូចគ្នានឹងសហចៅក្រមស៊ើបអង្កេត ក្នុងការប្រកាសថាទម្រង់ទាំងអស់របស់ JCE អាចអនុវត្តបាននៅ អ.វ.ត.ក.)។ អង្គបុរេបានសន្និដ្ឋានថា បន្ថែមលើយុត្តិសាស្ត្រនោះ ការអនុវត្ត “សញ្ញាណនៃគោលបំណងរួម” ត្រូវបានគាំទ្រដោយមាត្រា ៦ នៃធម្មនុញ្ញ London របស់តុលាការយោធាអន្តរជាតិ និងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[771] និងរឿងក្តី *Justice* និង *RuSHA* [772]។

យ៉ាងណាមិញ អង្គបុរេជំនុំជម្រះមិនអាចសន្និដ្ឋានបានថា JCE III បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធនោះទេ[773]។ អង្គបុរេមិនយល់ឃើញថាឯកសារសំអាងផ្លូវច្បាប់ដែលបានផ្អែកលើដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ផ្តល់ភ័ស្តុតាងគ្រប់គ្រាន់អំពីការអនុវត្តដ៏ស៊ីចង្វាក់គ្នារបស់រដ្ឋ ឬ*ទស្សនៈច្បាប់*នៅក្នុងពេលវេលាដែលពាក់ព័ន្ធឡើយ ហើយបានកត់សម្គាល់ថា ធម្មនុញ្ញ *Nuremberg* និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ពុំផ្តល់ការគាំទ្រជាក់លាក់

[763] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៧៥។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៤៧។
[764] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៨០-៨០៤។
[765] ដូចខាងលើ កថាខណ្ឌ ៧៩៩-៨០៤។
[766] ដូចខាងលើ កថាខណ្ឌ ៨០៥។
[767] ដូចខាងលើ កថាខណ្ឌ ៨០៦។
[768] សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្ម ទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13។
[769] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៧២-៧៣, ៨៧-៨៨។
[770] ដូចខាងលើ កថាខណ្ឌ ៦៩។
[771] ដូចខាងលើ កថាខណ្ឌ ៥៧-៥៨។
[772] ដូចខាងលើ កថាខណ្ឌ ៦៥-៦៨។
[773] ដូចខាងលើ កថាខណ្ឌ ៨៣។

ចំពោះ JCE III នោះទេ[774]។ អង្គបុរេក៏បានសន្និដ្ឋានទៀតថា ទោះបីជាអង្គហេតុនៃរឿងក្តីចំនួនពីរត្រូវបានផ្អែកលើដោយអង្គជំនុំជម្រះតុលាការកំពូល គឺរឿងក្តី *Essen Lynching* និង *Borkum Island* អាចជាក់ព័ន្ធទៅនឹង JCE III យ៉ាងណាក្តី ក៏កង្វះសាលក្រមមានសំអាងហេតុនៅក្នុងរឿងក្តីទាំងអស់នេះ បានធ្វើឱ្យមានភាពមិនច្បាស់លាស់ចំពោះទម្រង់នៃការទទួលខុសត្រូវដែលត្រូវអនុវត្ត[775]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានផ្អែកលើរឿងក្តីប្រទេសអ៊ីតាលីមួយចំនួន ប៉ុន្តែមិនបានសន្និដ្ឋានថា យុត្តិសាស្ត្រជាតិអាចជាករណីយុត្តិសាស្ត្រសមស្របសម្រាប់ទម្រង់នៃការទទួលខុសត្រូវនោះទេ[776]។ អង្គបុរេបានពិភាក្សាថាតើ JCE III អាចចាត់ទុកជាគោលការណ៍ទូទៅនៃច្បាប់ដែរឬទេ ប៉ុន្តែអង្គបុរេបានសម្រេចថា ខ្លួនមិនចាំបាច់ធ្វើការសម្រេចលើបញ្ហានេះទេ ដោយសារតែអង្គបុរេមិនជឿជាក់ថា ការទទួលខុសត្រូវបែបនេះអាចត្រូវបានប្រមើលដឹងជាមុនដោយជនត្រូវចោទនោះឡើយ ព្រោះថាវាមិនមានមូលដ្ឋាននៅក្នុងច្បាប់ជាតិកម្ពុជាក្នុងឆ្នាំ១៩៧៥ នោះទេ[777]។ នៅក្នុងកាលៈទេសៈបែបនេះ អង្គបុរេយល់ឃើញថា គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យ អ.វ.ត.ក. មិនផ្អែកទៅលើ JCE III នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ខ្លួន។

បន្ទាប់ពីសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ក៏បានសន្និដ្ឋានផងដែរថា JCE I និង II អាចអនុវត្តនៅ អ.វ.ត.ក.។ អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើភាពអាចអនុវត្តបាននៃ JCE III នោះទេ ដោយសារតែទម្រង់នោះត្រូវបានស្នើសុំឡើងដោយសហព្រះរាជអាជ្ញាឱ្យអនុវត្តជាជម្រើសតែប៉ុណ្ណោះ[778]។ ទាក់ទងនឹងបញ្ហាថាតើ JCE I និង II អាចអនុវត្តបានតាមមាត្រា ២៩(ថ្មី) នៃលក្ខន្តិកៈ អ.វ.ត.ក. ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បទប្បញ្ញត្តិនេះបានឆ្លុះបញ្ចាំងពីលក្ខន្តិកៈតុលាការ ICTY និងថា យុត្តិសាស្ត្ររបស់ ICTY បានសម្រេចថា ពាក្យ "បានប្រព្រឹត្ត" រួមបញ្ចូលការចូលរួមក្នុង JCE។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សញ្ញាណនៃ JCE ត្រូវបានរួមបញ្ចូលក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក.[779]។ ដោយផ្អែកលើធម្មនុញ្ញ Nuremberg ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងយុត្តិសាស្ត្រអន្តរជាតិដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Tadić* អង្គជំនុំជម្រះសាលាដំបូងក៏សម្រេចផងដែរថា JCE I និង II គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលឆ្នាំ១៩៧៥ ដល់ ១៩៧៩[780]។

ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យសម្រេចថា JCE III អាចអនុវត្តបាននៅ អ.វ.ត.ក. ដោយបានធ្វើការបញ្ជាក់ជាថ្មីលើសេចក្តីសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០១ ថា JCE I និង II គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ និងការសម្រេចថា JCE III មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះ ហើយក៏មិនមែនជាគោលការណ៍ទូទៅនៃច្បាប់នោះដែរ[781]។ ដោយកត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យយ៉ាងទូលំទូលាយរួចហើយលើលិខិតុបករណ៍ច្បាប់មុនឆ្នាំ១៩៧៥ និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានផ្អែកលើ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះនឹងមិន "ចេញសេចក្តីសម្រេចដែលវែងនោះទេ ក្នុងកាលៈទេសៈទាំងឡាយដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចរកឃើញមូលហេតុរឹងមាំ ដើម្បីងាកចេញពីការវិភាគរបស់អង្គបុរេជំនុំជម្រះ និងក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងលទ្ធផលរបស់អង្គបុរេជំនុំជម្រះ"[782]។

---

[774] ដូចខាងលើ កថាខណ្ឌ ៧៧-៨៣។
[775] ដូចខាងលើ កថាខណ្ឌ ៧៩។
[776] ដូចខាងលើ កថាខណ្ឌ ៨២។
[777] ដូចខាងលើ កថាខណ្ឌ ៨៤-៨៧។
[778] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១៣។
[779] ដូចខាងលើ កថាខណ្ឌ ៥១១។
[780] ដូចខាងលើ កថាខណ្ឌ ៥០៥-៥០៦, ៥១២។
[781] សំណុំរឿង ០០២ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E100/6។
[782] ដូចខាងលើ កថាខណ្ឌ ២៦។

អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើរឿងក្ដីក្រោយសង្គ្រាមលោកលើកទី២ ដែលបានយោងនៅក្នុងសាលដីកាក្នុងរឿងក្ដី *Tadić* ក៏ដូចជា រឿងក្ដីពីរបន្ថែមទៀតក្រោយសង្គ្រាមលោកលើកទី២ គឺ រឿងក្ដី *ស.រ.អា. ទល់នឹង* Ulrich *និង* Merkle និង *ស.រ.អា. ទល់នឹង* Wuelfert ដែលបានយោងនៅក្នុងសេចក្ដីសម្រេចថ្មីៗលើ JCE ដែលធ្វើឡើងដោយសាលាក្ដីពិសេសសម្រាប់លីបង់("STL")[783]។ ទាំងរឿងក្ដី *ស.រ.អា. ទល់នឹង* Ulrich *និង* Merkle និងរឿងក្ដី *ស.រ.អា. ទល់នឹង* Wuelfert ពាក់ព័ន្ធនឹងអ្នកជំនួញ ដែលត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះការធ្វើបាបអ្នកទោសនៅតាមរោងចក្ររបស់ខ្លួន និងជំរំប្រមូលផ្ដុំ Dachau។ ផ្អែកលើការពិនិត្យឡើងវិញលើសាលក្រមទាំងនោះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា រឿងក្ដីទាំងនេះទំនងជាគាំទ្រ JCE I និង II ដោយសារតែជនជាប់ចោទគឺជាផ្នែកមួយនៃរចនាសម្ព័ន្ធជំរំប្រមូលផ្ដុំ និងបានចូលរួមដោយផ្ទាល់ក្នុងការធ្វើបាបអ្នកទោស ប៉ុន្តែមិនបានគាំទ្រចំពោះសំអាងហេតុនៃពិរុទ្ធភាពដែលផ្អែកលើ JCE III នោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា សេចក្ដីសម្រេចរបស់តុលាការ STL "សំអាងលើការពិនិត្យសាលក្រមឡើងវិញដែលមិនផ្ដល់មូលដ្ឋានគតិយុត្ដិ ចំពោះការផ្ដន្ទាទោសដែលបានបញ្ជាក់រួចហើយនោះទេ"[784]។ ដោយសារតែមូលដ្ឋានគតិយុត្ដិសម្រាប់ការផ្ដន្ទាទោស មិនច្បាស់លាស់នៅក្នុងរឿងក្ដីណាមួយទាំងអស់នោះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា រឿងក្ដីទាំងនោះមិនអាចគាំទ្រការសន្និដ្ឋានថា JCE III មានអត្ថិភាពជាគោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥ ដល់១៩៧៩ នោះឡើយ[785]។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង បានធ្វើការស្រាវជ្រាវទៅលើប្រព័ន្ធច្បាប់របស់ចក្រភពអង់គ្លេស អាល្លឺម៉ង់ សហភាពសូវៀត ហូឡង់ បារាំង និង កម្ពុជា ហើយបានសន្និដ្ឋានថា មាន "ភាពខុសពីគ្នាជាច្រើន អំពីវិធីសាស្ត្រក្នុងចំណោមយុត្តាធិការជាតិផ្សេងៗគ្នា"។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចសន្និដ្ឋានថា JCE III គឺជាគោលការណ៍ទូទៅនៃច្បាប់នោះទេ[786]។

### ៣.៤.១.១. ភាពអាចអនុវត្តបានដែលកម្រិតត្រឹមតែឧក្រិដ្ឋកម្មអន្តរជាតិ

JCE I និង JCE II អាចអនុវត្តបានតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ ហើយក៏មិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្មក្នុងច្បាប់កម្ពុជាដែលមានចែងក្នុងមាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. នោះដែរ។ សហចៅក្រមស៊ើបអង្កេតបានពន្យល់ថា អនុលោមតាមគោលការណ៍នៃការបកស្រាយ*របប*គតិយុត្តិពិសេស ក្នុងច្បាប់បារាំង - ដែលនៅក្នុងនោះឧក្រិដ្ឋកម្មអន្តរជាតិស្ថិតក្រោម*របប* គតិយុត្តិពិសេស ដែលខុសពីនីតិព្រហ្មទណ្ឌក្នុងស្រុក - ទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិ អាចអនុវត្តបានតែទៅលើឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ [787]។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន បានប្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងការដាក់កម្រិតនេះ ហើយសហព្រះរាជអាជ្ញាវិញនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធទៅនឹងភាពអាចអនុវត្តបាននៃ JCE ក៏បានតវ៉ាថា ការដាក់កម្រិតបែបនេះមិនមានអត្ថិភាពឡើយ ប៉ុន្តែអង្គបុរេជំនុំជម្រះយល់ឃើញថា ដោយមិនគិតថាតើ ការយោងទៅទស្សនៈបារាំងស្ដីពី*របប*គតិយុត្តិពិសេសមានការភាន់ច្រឡំដែរ ឬទេនោះ "គ្មានទង្វើករណ៍ណាមួយក្នុងចំណោមទង្វើករណ៍ដែលបានលើកឡើងដោយភាគីនានា [...] បង្ហាញថា ដីកាដែលត្រូវបានជំទាស់ ភាន់ច្រឡំក្នុងការពិចារណាថា ទម្រង់ JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងឡាយ ជាជាងអនុវត្តចំពោះបទល្មើសជាតិនោះទេ"[788]។ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ពុំដែលបានពិចារណាលើបញ្ហានេះទេ ដោយសារតែពុំមានជនជាប់ចោទណាម្នាក់ត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋកម្មជាតិតាមមាត្រា ៣ (ថ្មី) ទេ។

### ៣.៤.២. ធាតុផ្សំ

[783] ដូចខាងលើ កថាខណ្ឌ ៣០-៣៤។
[784] ដូចខាងលើ កថាខណ្ឌ ៣៤។
[785] ដូចខាងលើ កថាខណ្ឌ ៣៥។
[786] ដូចខាងលើ កថាខណ្ឌ ៣៧។
[787] សំណុំរឿង ០០២ ដីកាសម្រេចស្ដីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថាសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ២២-២៣។"
[788] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ១០២។

យុត្តិសាស្ត្រ អ.វ.ត.ក. បានសម្រេចថា ធាតុផ្សំសត្យានុម័តសម្រាប់ទម្រង់នីមួយៗនៃ JCE គឺមានលក្ខណៈដូចគ្នា៖ ត្រូវមានមនុស្សច្រើន គោលបំណងរួម និង ការចូលរួមចំណែកជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទក្នុងការអនុវត្តគោលបំណងរួម[789]។ គឺធាតុផ្សំអត្តនោម័តដែលញែកប្រភេទទាំងអស់នេះឱ្យដាច់ពីគ្នា។ JCE I តម្រូវឱ្យមានចេតនាចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបង្កើតបានជាផ្នែកមួយនៃគោលបំណងរួម[790]។ JCE II តម្រូវឱ្យមានការដឹងឮជាបុគ្គលអំពីប្រព័ន្ធនៃការធ្វើបាប និងចេតនាក្នុងការជំរុញវា[791]។ JCE III តម្រូវឱ្យមានចេតនាចូលរួមក្នុងគោលបំណងរួម និងបានរួមចំណែកក្នុងការអនុវត្តគោលបំណងរួមនោះ ដោយមានការទទួលខុសត្រូវកើតឡើងចំពោះឧក្រិដ្ឋកម្មផ្សេងៗ ដែលស្ថិតនៅក្រៅគោលបំណងរួម ដែលជនជាប់ចោទបានប្រមើលដឹងជាមុនអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ហើយមានចេតនាទទួលយកហានិភ័យនោះ[792]។

### ៣.៤.២.១. ធាតុផ្សំសត្យានុម័ត

#### ៣.៤.២.១.១. *មានមនុស្សច្រើន*

យុត្តិសាស្ត្រ អ.វ.ត.ក. តម្រូវឱ្យមានមនុស្សច្រើន ប៉ុន្តែបុគ្គលទាំងនេះពុំចាំបាច់ត្រូវបានរៀបចំនៅក្នុងរចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលនោះទេ[793]។ មនុស្សច្រើនដែលស្ថិតក្នុងទម្រង់ JCE ចាំបាច់ត្រូវតែកំណត់អត្តសញ្ញាណ ប៉ុន្តែពុំចាំបាច់កំណត់អត្តសញ្ញាណឈ្មោះបុគ្គលម្នាក់ៗដែលចូលរួមនោះទេ[794]។ វាអាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការសំដៅលើប្រភេទ ឬក្រុមមនុស្ស[795]។ សមាជិក JCE អាចប្រែប្រួល ឬវិវឌ្ឍតាមពេលវេលា[796]។

អ្នកចូលរួមក្នុង JCE អាចមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយចារីផ្ទាល់ដែលមិនមែនជាសមាជិក JCE ប្រសិនបើត្រូវបានរកឃើញថា ឧក្រិដ្ឋកម្មទាំងនោះ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ យ៉ាងហោចណាស់ទៅលើអ្នកចូលរួមណាម្នាក់នៃ JCE ហើយអ្នកចូលរួមនេះ នៅពេលប្រើប្រាស់ចារីផ្ទាល់ បានធ្វើសកម្មភាពដើម្បីជំរុញគោលបំណងរួម[797]។ ការបង្ហាញចំណងទាក់ទងរវាងសមាជិក JCE និងចារីផ្ទាល់ គឺជាបញ្ហាត្រូវវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ[798]។ វាមិនត្រូវបានកំណត់ថាតើ ចារីផ្ទាល់មានធាតុផ្សំអត្តនោម័តរបស់សមាជិក JCE ឬបានដឹងពីអត្ថិភាពនៃ JCE ឬយ៉ាងណានោះទេ អ្វីដែលជាបញ្ហាចោទនោះត្រង់ថាតើ សមាជិក JCE បានប្រើប្រាស់ចារីផ្ទាល់ឱ្យប្រព្រឹត្តអំពើដែលជា

---

[789] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៨។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៏នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្ម ទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៤។

[790] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៧, ៥០៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។

[791] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។

[792] ដូចខាងលើ។

[793] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១០។

[794] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៨។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។

[795] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១០។

[796] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៥។

[797] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៧៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១១។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៥.

[798] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១១។

ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋ ដែលជាផ្នែកនៃគោលបំណងរួមដែរ ឬទេ[799]។ ទោះបីជាអត្ថិភាពនៃការព្រមព្រៀងច្បាស់លាស់រវាងសមាជិក JCE និងចារី អាចយកមកប្រើប្រាស់ក្នុងការបង្ហាញថា ឧក្រិដ្ឋកម្មជាក់លាក់ណាមួយបង្កើតបានជាផ្នែកនៃគោលបំណងរួមក៏ដោយ ក៏អត្ថិភាពនៃការព្រមព្រៀងច្បាស់លាស់នេះមិនមែនជាលក្ខខណ្ឌតម្រូវនោះទេ[800]។ វាក៏មិនមែនជាលក្ខខណ្ឌតម្រូវដែលថា សមាជិក JCE បានគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនោះឡើយ[801]។

### ៣.៤.២.១.២. *គោលបំណងរួម*

យុត្តិសាស្ត្រ អ.វ.ត.ក. តម្រូវឱ្យមានអត្ថិភាពនៃគោលបំណងរួម ដែលជាបទឧក្រិដ្ឋ ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលអង្គជំនុំជម្រះមានយុត្តាធិការ[802]។ គោលបំណងរួមគឺជាចំណុចស្នូលនៃទម្រង់នៃការទទួលខុសត្រូវនេះ ដោយសារតែវាគឺជាធាតុផ្សំដែលចងភ្ជាប់សមាជិក JCE រួមគ្នា និងផ្តល់យុត្តិកម្មសម្រាប់ការដាក់ឱ្យទទួលខុសត្រូវរួមចំពោះអំពើរបស់សមាជិកទាំងនេះ ដែលនាំឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[803]។ គោលបំណងរួមត្រូវតែមានលក្ខណៈឧក្រិដ្ឋ[804]។

គោលបំណងរួម "គឺជា" ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រសិនបើ ការប្រព្រឹត្តិឧក្រិដ្ឋកម្មគឺជា ឬក្នុងចំណោមគោលដៅចម្បងមួយ(ច្រើន) នៃគោលបំណងរួម[805]។ ឧទាហរណ៍ដូចជាក្នុងស្ថានភាពមួយដែលគោលបំណងរួមនោះ គឺត្រូវសម្លាប់ក្រុមសត្រូវនយោបាយមួយ។ "ក្នុងកាលៈទេសៈនោះ បង្ហាញច្បាស់ថាសមាជិកនៃសហឧក្រិដ្ឋកម្មរួមបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់នោះ"[806]។

គោលបំណងរួម "ជាប់ពាក់ព័ន្ធ" ទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ប្រសិនបើឧក្រិដ្ឋកម្មនោះគឺជាមធ្យោបាយក្នុងការសម្រេចបានគោលដៅចុងក្រោយមួយ ដែលគោលដៅនេះអាចពុំមែនជាបទល្មើស៖

> នៅក្នុងកាលៈទេសៈបែបនេះ ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែមានចេតនាចង់ឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងចុងក្រោយនេះ អាចរួមបញ្ចូលបទឧក្រិដ្ឋដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយនោះ បើទោះបីជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ។ ឧទាហរណ៍ ប្រសិនបើក្រុមមួយបានព្រមព្រៀងគ្នាចូលលួចក្នុងផ្ទះមួយ ហើយក្នុងករណីចាំបាច់ត្រូវសម្លាប់មនុស្សប្រសិនបើចៅផ្ទះមានការតដៃ។ នេះជាការពុំសមស្របទាំងស្រុងក្នុងការសន្និដ្ឋានថា ការធ្វើមនុស្សឃាតជាយថាហេតុនោះ ពុំមែនរួមបញ្ចូលនៅក្នុងគោលបំណងរួម ដោយសារពុំមានភាពច្បាស់លាស់ ថាមានការសម្លាប់មនុស្សនឹងកើតជាក់ស្តែង នៅក្នុងអំឡុងពេលនៃការចូលលួចនោះ។ ផ្ទុយទៅវិញ ក្នុងកាលៈទេសៈនេះ បទមនុស្សឃាត គឺជាធាតុផ្សំនៃផែនការដែលបានគ្រោងទុក បើទោះបីជាសមាជិកនៃក្រុមនោះពុំបានដឹងថាតើ មានការសម្លាប់មនុស្សជាក់ស្តែងដែរ ឬយ៉ាងណានោះក៏ដោយ[807]។

ដោយសារតែការទទួលខុសត្រូវក្រោមទម្រង់ JCE អាចកើតឡើងចំពោះតែបទឧក្រិដ្ឋដែលស្ថិតក្នុងគោលបំណងរួមនោះ ដូច្នេះលក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេចថាតើបទឧក្រិដ្ឋមួយណាត្រូវបានរួមបញ្ចូល

---

[799] ដូចខាងលើ។

[800] ដូចខាងលើ។

[801] ដូចខាងលើ។

[802] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៧។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩២។

[803] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៧៨៩។

[804] ដូចខាងលើ។

[805] ដូចខាងលើ កថាខណ្ឌ ៨០៧។

[806] ដូចខាងលើ។

[807] ដូចខាងលើ កថាខណ្ឌ ៨០៨។

នៅក្នុងគោលបំណងរួមនោះ មានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំង[808]។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា ប្រសិនបើការសម្រេចបានគោលដៅនៃគោលបំណងរួម អាចនាំឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ (ពោលគឺ "ជាប់ពាក់ព័ន្ធ" ការប្រព្រឹត្តិបទឧក្រិដ្ឋ) ប៉ុន្តែបានព្រមព្រៀងគ្នាបន្តសម្រេចគោលដៅនេះដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ បទឧក្រិដ្ឋទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ព្រោះ បើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏បទឧក្រិដ្ឋនេះត្រូវបានគ្រោងទុកដោយគោលបំណងរួម[809]។

ការព្រមព្រៀងច្បាស់លាស់ពុំតម្រូវទេ[810]។ គោលបំណងរួមអាចកើតឡើងដោយឥតព្រាងទុកជាមុន និងអាចត្រូវបានទាញសេចក្តីសន្និដ្ឋាន[811]។ វាក៏អាចប្រែប្រួល និងផ្លាស់ប្តូរទៅតាមពេលវេលា ដើម្បីរួមបញ្ចូលបទឧក្រិដ្ឋបន្ថែម[812]។ "ការទទួលខុសត្រូវកើតឡើង នៅពេលដែលសមាជិកនៃសហឧក្រិដ្ឋកម្មរួមមិនបានចាត់វិធានការទប់ស្កាត់ឱ្យមានប្រសិទ្ធភាពចំពោះការកើតឡើងនៃបទឧក្រិដ្ឋថ្មី ហើយពួកគេនៅតែបន្តអនុវត្តគោលបំណងរួមនេះ បើទោះបីជាពួកគេបានដឹងហើយថា បទឧក្រិដ្ឋថ្មីត្រូវបានដាក់បញ្ចូលបន្ថែមនៅក្នុងការអនុវត្តផែនការរួមក៏ដោយ"[813]។

### ៣.៤.២.១.៣. *ការចូលរួមក្នុងគោលបំណងរួម*

យុត្តិសាស្ត្រ អ.វ.ត.ក. តម្រូវឱ្យមានការចូលរួម ឬការជ្រោមជ្រែងជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទនៅក្នុងគោលបំណងរួម[814]។ ការចូលរួមក្នុងគោលបំណងរួមអាចជាអំពើសកម្ម ឬអកម្ម[815]។

ការចូលរួមនេះមិនចាំបាច់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ណាមួយទេ ប៉ុន្តែអាចជាទម្រង់នៃការជួយ ឬការជ្រោមជ្រែង ដល់ការអនុវត្តគោលបំណងរួម[816]។ ម្យ៉ាងវិញទៀត វាត្រូវតែជំរុញគោលបំណងរួមត្រង់ចំណុចស្នូលនៃ JCE[817]។ ការចូលរួមចំណែកពុំចាំបាច់ (មានលក្ខណៈចាំបាច់) ឬសំខាន់នោះទេ ប៉ុន្តែគួរតែយ៉ាងហោចណាស់ជាការចូលរួមចំណែកដ៏មានសារៈសំខាន់មួយក្នុងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានរកឃើញថាទទួលខុសត្រូវ[818]។ ការជាប់ពាក់ព័ន្ធរបស់សមាជិក JCE ក្នុងឧក្រិដ្ឋកម្មត្រូវតែបង្កើតឡើងនូវទំនាក់ទំនងនៅក្នុងចំណងនៃហេតុនិងផល[819]។ សារៈសំខាន់នៃការរួមចំណែកក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងគោលបំណងរួម នឹងត្រូវកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាទៅលើកត្តាផ្សេងៗ រួមទាំងតួនាទីរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ព្រមទាំងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់បទឧក្រិដ្ឋ[820]។ សារៈសំខាន់នេះគឺពាក់ព័ន្ធនឹងការកំណត់ថាតើ

---

[808] ដូចខាងលើ កថាខណ្ឌ ៨០៧។
[809] ដូចខាងលើ កថាខណ្ឌ ៨០៨។
[810] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៩។
[811] ដូចខាងលើ។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១០៩។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៤។
[812] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៩។
[813] ដូចខាងលើ។
[814] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៨។
[815] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១១។
[816] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១២។
[817] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៨។
[818] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៨។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១២។
[819] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១០។
[820] ដូចខាងលើ។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១២។

ទំនាក់ទំនងនៅក្នុងចំណោងនៃហេតុនិងផលមានអត្ថិភាពដែរ ឬទេ[821]។ វាក៏ពាក់ព័ន្ធផងដែរក្នុងការកំណត់ថា តើ ជនជាប់ចោទមាន*ធាតុផ្សំអត្តនោម័ត*ដែលត្រូវការ ឬទេ[822]។ សកម្មភាពរបស់ជនជាប់ចោទគប្បីត្រូវបានវាយតម្លៃជារួម ហើយការរួមចំណែកជាក់លាក់ ពុំគួរត្រូវបានវាយតម្លៃដាច់ដោយឡែកពីគ្នានោះទេ[823]។

### ៣.៤.២.២. ធាតុផ្សំសត្យានុម័ត

ចំពោះ JCE I ជនជាប់ចោទត្រូវតែមានចេតនាចូលរួមក្នុងគោលបំណងរួម ហើយអ្នកចូលរួមផ្សេងទៀតត្រូវតែមានចេតនានេះផងដែរ[824]។

JCE II ត្រូវបានចាត់ទុកថាជាទម្រង់មួយនៃ JCE I[825]។ ចំពោះ JCE II ជនជាប់ចោទត្រូវដឹងឮអំពីប្រព័ន្ធនៃការធ្វើបាប និងចេតនាក្នុងការជំរុញប្រព័ន្ធរួមនៃការធ្វើបាបបែបនោះ[826]។

ចំពោះ JCE III ដែលមិនត្រូវបានអនុវត្តនៅ អ.វ.ត.ក.[827] ជនជាប់ចោទត្រូវដឹងថា ឧក្រិដ្ឋកម្មនៅក្រៅគោលបំណងរួមគឺជាផលវិបាកធម្មជាតិ និងដែលអាចប្រមើលដឹងជាមុនអំពីគោលបំណងរួម ហើយមានចេតនាទទួលយកហានិភ័យដែលថាឧក្រិដ្ឋកម្មទាំងនោះនឹងត្រូវបានប្រព្រឹត្តឡើង[828]។

អ្នកចូលរួមក្នុង JCE I ឬ II ត្រូវតែបង្ហាញថាមានចេតនាដែលតម្រូវដូចគ្នានឹងចារីដែរ ដែលរួមបញ្ចូលចេតនាជាក់លាក់ សម្រាប់ឧក្រិដ្ឋកម្មដែលត្រូវការ រួមមានការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍[829]។ ដូច្នេះ ចេតនាក្នុងទម្រង់ JCE ត្រូវតែរួមបញ្ចូលទាំងគោលបំណងរួម និងឧក្រិដ្ឋកម្មដែលវាគ្របដណ្ដប់[830]។

---

[821] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១០។
[822] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៤។
[823] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១២.
[824] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៥។
[825] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៧។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៥, ១៧។
[826] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៥។
[827] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨០៧។ សំណុំរឿង ០០២ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E100/6។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៨៧-៨៨។ សម្រាប់ព័ត៌មានបន្ថែមស្តីពីភាពអាចអនុវត្តបាននៃ JCE III នៅ អ.វ.ត.ក. សូមមើល ផ្នែក ៣.៤.១។
[828] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៦។
[829] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៩៤។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១២។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៣។
[830] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១២។

កម្រិតចេតនាដែលត្រូវការសម្រាប់ JCE I បានក្លាយជាបញ្ហាចោទបន្ទាប់ពីសាលដីកាសំណុំរឿង ០០២/០១។ នៅក្នុងសាលដីកានេះ អង្គជំនុំជម្រះតុលាការកំពូល នៅពេលពិភាក្សាថាតើខ្លួនមានន័យដូចម្តេចចំពោះគោលបំណងរួមក្នុងការ "ជាប់ពាក់ព័ន្ធ" ជាជាង "គឺជា" ឧក្រិដ្ឋកម្មនោះ បានពន្យល់ថា៖

> គោលបំណងរួមមានការ "ជាប់ពាក់ព័ន្ធ" ទៅនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះ គឺជា*មធ្យោបាយ*ដើម្បីសម្រេចគោលដៅចុងក្រោយ (ដែលគោលដៅនេះអាចពុំមែនជាបទល្មើស)។ នៅក្នុងកាលៈទេសៈបែបនេះ ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែមាន *ចេតនា*ចង់ឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងចុងក្រោយនេះ អាចរួមបញ្ចូលបទឧក្រិដ្ឋដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយនោះ ទោះបីជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ[831]។

អង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើការកំណត់ឡើងវិញនូវអង្គហេតុមួយចំនួនពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ឱ្យទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ដែលត្រូវបានប្រព្រឹត្តដោយមាន*ចេតនាប្រយោល*។ ចេតនាប្រយោល សំដៅលើឧក្រិដ្ឋកម្មដែលពុំមានគោលបំណងផ្ទាល់ ប៉ុន្តែជនសង្ស័យដឹងអំពីហានិភ័យដែលថាផាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្ម អាចបណ្តាលមកពីអំពើសកម្ម ឬអំពើអកម្មរបស់ខ្លួន ហើយទទួលយកលទ្ធផលបែបនោះ ដោយសម្របខ្លួនទៅនឹងវា ឬព្រមព្រៀងជាមួយនឹងវា[832]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានគ្របដណ្តប់ដោយគោលបំណងរួម និងថា ជនជាប់ចោទមានការទទួលខុសត្រូវតាម JCE ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ[833]។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា៖

> ប្រសិនបើបទមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ជនជាប់ចោទមានគោលដៅអនុវត្តគោលបំណងរួមនាំឱ្យជនរងគ្រោះស្លាប់ ឬបានដឹងថា ការស្លាប់មនុស្សប្រាកដជាកើតមានជាក់លាក់ ដោយសារការអនុវត្តន៍គោលបំណងរួមនោះ (ចេតនាផ្ទាល់) ឬថា ជនជាប់ចោទបានដឹងថា ការស្លាប់ជនរងគ្រោះ គឺជាផលវិបាកដែលអាចកើតមាន ដោយសារការអនុវត្តន៍គោលបំណងរួមនោះ ប៉ុន្តែនៅតែបន្តអនុវត្តបើទោះបីជាយ៉ាងនេះក្តី ដោយទទួលយកលទ្ធភាពនៃការស្លាប់ដែលអាចកើតឡើង (ចេតនាប្រយោល)[834]។

ក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតបានពន្យល់ការបកស្រាយរបស់ខ្លួនចំពោះយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលត្រង់ចំណុចនេះថា៖

> [អង្គជំនុំជម្រះតុលាការកំពូល] បានបញ្ជាក់បំភ្លឺនាពេលថ្មីៗនេះថា នៅក្នុងករណីដែលគោលបំណងរួមពាក់ព័ន្ធ ទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើននោះ មិនចាំបាច់ថាអ្នកដែលឯកភាពលើគោលបំណងរួម ពិតជាមានបំណងចង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលដៅចុងក្រោយ។ [អង្គជំនុំជម្រះតុលាការកំពូល] បានបន្ថែមថា ករណីនេះអាចរួមបញ្ចូលនូវឧក្រិដ្ឋកម្ម ដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយ ដើម្បីសម្រេចនូវគោលបំណងរួមណាមួយនោះ បើទោះបីជាការប្រព្រឹត្តិពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ។ ប្រសិនបើគោលដៅនៃគោលបំណងរួម អាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងមានការព្រមព្រៀងគ្នាបន្តសម្រេចគោលដៅនេះ ដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ ទើបកំណត់ថា ឧក្រិដ្ឋកម្មទាំងនេះ មានរួមបញ្ចូលនៅក្នុងគោលបំណងរួម ព្រោះបើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏ឧក្រិដ្ឋកម្មនេះត្រូវបានគ្រោងទុកក្នុងគោលបំណងរួម។ យើងបកស្រាយការសម្រេចនាពេលថ្មីៗ របស់អង្គជំនុំជម្រះតុលាការកំពូលនេះ ដោយផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់ ពាក្យ "*បំណង*" ដែលជាការបញ្ជាក់បំភ្លឺថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនចាំបាច់ត្រូវតែជា គោលដៅចម្បង

---

[831] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨០៨។

[832] សូមមើល ដូចខាងលើ កថាខណ្ឌ ៣៩០-៣៩១។

[833] ដូចខាងលើ កថាខណ្ឌ ៥៦១-៥៦២, ៨៦៨, ១០៨៨-១០៨៩។

[834] ដូចខាងលើ កថាខណ្ឌ ១០៥៤ (គូសបញ្ជាក់បន្ថែម)។

> របស់សមាជិកសហឧក្រិដ្ឋកម្មរួមឡើយ។ ទោះជាយ៉ាងនេះក្ដី វាចាំបាច់ត្រូវតែបង្ហាញពីចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម ដែលជាលក្ខខណ្ឌតម្រូវមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមប្រភេទទីមួយ[835]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើតាមការលើកឡើងនេះ នៅក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤[836]។

អង្គជំនុំជម្រះតុលាការកំពូលមានឱកាសដោះស្រាយបញ្ហានេះជាថ្មីម្ដងទៀត នៅក្នុងសំណុំរឿង ០០២/០២។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងចម្លើយតបទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ថា JCE I តម្រូវឱ្យមានភ័ស្តុតាងបញ្ជាក់ពីចេតនាផ្ទាល់ ទាក់ទងនឹងទាំងគោលបំណងរួម និងទាំងឧក្រិដ្ឋកម្មជាមូលដ្ឋាននោះ បានសន្និដ្ឋានថា "កម្រិតនៃធាតុផ្សំចេតនាដែលតម្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទី I គឺជាចេតនាដោយចំពោះ"[837]។ ការណ៍នេះបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ដោយមានចេតនាដោយប្រយោល ស្ថិតនៅក្រៅគោលបំណងរួមនៃ JCE។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាលើការទទួលខុសត្រូវរបស់ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មនេះ ក្រោមការជួយ និងការជំរុញវិញ ជាជាងក្រោមទម្រង់ JCE[838]។

នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន បានសម្រេចដោះស្រាយចំណុចនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានមើលរំលងយុត្តិសាស្ត្ររបស់ខ្លួន ហើយបែរជាផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ ICTY ទៅវិញ ក្នុងការសម្រេចថា ដោយសារតែឧក្រិដ្ឋកម្មបែបនោះមិនមានចេតនាផ្ទាល់ ប៉ុន្តែគ្រាន់តែប្រមើលដឹងជាមុនពួកវាត្រូវតែស្ថិតនៅក្រៅគោលបំណងរួម[839]។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល ការណ៍នេះមើលរំលងស្ថានការណ៍ដែលភវនីយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ត្រូវបានយល់ព្រមជារួម និងដោយចេតនាពីសំណាក់អ្នកចូលរួមក្នុង JCE ទាំងអស់ ដូចបានលើកឡើងក្នុងឧទាហរណ៍ដែលខ្លួនបានផ្ដល់ក្នុងសំណុំរឿង ០០២/០១ អំពីក្រុមមួយដែលបានចូលលួចក្នុងផ្ទះមួយ និងបានយល់ព្រមប្រើប្រាស់អំពើគ្រោះថ្នាក់ដល់អាយុជីវិតក្នុងករណីចាំបាច់[840]។ អង្គជំនុំជម្រះតុលាការកំពូល បានពន្យល់ថា ក្នុងស្ថានភាពនេះ ដោយសារតែអ្នកចូលរួមក្នុង JCE ទាំងអស់បានរួមចំណែកការឯកភាពរបស់ខ្លួន ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មជាសក្ដានុពលដោយ *ចេតនាប្រយោល*ក្នុងការជំរុញគោលបំណងរួម ឧក្រិដ្ឋកម្មនោះត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម ហើយជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវតាមរយៈ JCE[841]។

យោងតាមអង្គជំនុំជម្រះតុលាការកំពូល ជាការពុំត្រឹមត្រូវក្នុងការតម្រូវឱ្យមានកម្រិតធាតុផ្សំអត្តនោម័តសម្រាប់ទម្រង់នៃការចូលរួម ខ្ពស់ជាងឧក្រិដ្ឋកម្មមូលដ្ឋាន ដូច្នេះប្រសិនបើបុគ្គលម្នាក់ទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់ការប្រព្រឹត្តិដោយចេតនាប្រយោល នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត បុគ្គលនោះគប្បីត្រូវដាក់ឱ្យទទួលខុសត្រូវដូចគ្នាសម្រាប់ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលបានប្រព្រឹត្តបទឧក្រិដ្ឋតែមួយដូចគ្នានោះ[842]។ អង្គជំនុំជម្រះតុលាការកំពូលពុំបានចាត់ទុកវិធីសាស្ត្រនេះថាជា "ការកែប្រែគោលគំនិតនៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់អំពើល្មើសជារួម"នោះទេ ហើយបានកត់សម្គាល់ថា លក្ខខណ្ឌសម្រាប់ការទទួលខុសត្រូវពុំត្រូវបានបន្ទាបចុះតាមរយៈការពិចារណា

---

[835] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៩។

[836] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៩។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៣។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៤។

[837] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧១៥។

[838] ដូចខាងលើ កថាខណ្ឌ ៤៣១១។

[839] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៥០-១៩៥២។

[840] ដូចខាងលើ កថាខណ្ឌ ១៩៥២។

[841] ដូចខាងលើ។

[842] ដូចខាងលើ កថាខណ្ឌ ១៩៥៩។

ថា បុគ្គលម្នាក់អាចទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្ម*ណាមួយ* ក្នុងផែនការរួម ដរាបណាការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះគ្រាន់តែត្រូវបានប្រមើលមើលដឹងជាមុននោះឡើយ[843]។

### ៣.៥. ការការពារខ្លួនចំពោះការទទួលខុសត្រូវលើឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល

ការការពារខ្លួនចំពោះការទទួលខុសត្រូវលើឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល ត្រូវបានពិនិត្យនៅក្នុងសំណុំរឿង០០១។ នៅចំពោះមុខអង្គជំនុំជម្រះ ឌុច បានជំទាស់ថា សកម្មភាពរបស់គាត់នៅ ស-២១ ត្រូវបានធ្វើឡើងអនុលោមតាមបញ្ជាថ្នាក់លើ និងស្ថិតក្រោមការបង្ខិតបង្ខំ។ គាត់បានអះអាងថា គាត់គ្មានជម្រើសណាក្រៅពីធ្វើតាមបញ្ជាពីថ្នាក់លើរបស់គាត់ប៉ុណ្ណោះ និងថាគាត់បានប្រព្រឹត្តក្រោមការគំរាមកំហែងដល់អាយុជីវិត និងសុវត្ថិភាពផ្ទាល់ខ្លួនគាត់ ដោយអះអាងថាចំណុចនេះគប្បីត្រូវបានដកចេញពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ហើយជាលទ្ធផលគួរសម្រេចឱ្យគាត់រួចខ្លួនពីបទចោទទាំងស្រុង ឬជាជម្រើសម្យ៉ាងទៀត គឺជាស្ថានសម្រាលទោស សម្រាប់គោលបំណងនៃការផ្តន្ទាទោស[844]។

#### ៣.៥.១. បញ្ជាថ្នាក់លើ

បញ្ជាថ្នាក់លើមិនមែនជាការការពារពេញលេញ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៅចំពោះមុខ អ.វ.ត.ក. ឡើយ។ យ៉ាងណាមិញ យុត្តិសាស្ត្រ អ.វ.ត.ក. មិនបានដោះស្រាយថាតើបញ្ជាថ្នាក់លើអាចសម្រាលទណ្ឌកម្ម ឬទេ ក្នុងលក្ខខណ្ឌដូចដែលមានចែងនៅក្នុងមាត្រា ៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម ពោលគឺ ប្រសិនបើ៖ “(ក) ជននោះមានកាតព្វកិច្ចផ្លូវច្បាប់ត្រូវគោរពបញ្ជារបស់រដ្ឋាភិបាល ឬរបស់ថ្នាក់លើនោះ (ខ) ជននោះមិនដឹងថាបញ្ជានោះខុសច្បាប់ និង (គ) បញ្ជានោះមិនបានបង្ហាញជាក់ស្តែងថាខុសច្បាប់”[845]។

ក្នុងការពិនិត្យលើការការពារខ្លួនដោយផ្អែកលើបញ្ជាថ្នាក់លើ អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ បានយោងមាត្រា ២៩(ថ្មី)(៤) នៃច្បាប់ អ.វ.ត.ក. ដែលចែងថា អង្គហេតុដែលថា ជនសង្ស័យបានប្រព្រឹត្តតាមបញ្ជាពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬពីថ្នាក់លើណាម្នាក់ មិនធ្វើឱ្យពួកគេរួចខ្លួនពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនោះទេ។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា លិខិតុបករណ៍ច្បាប់អន្តរជាតិ ដូចជា ធម្មនុញ្ញ Nuremberg និងលក្ខន្តិកៈសាលាក្តីមិនអចិន្ត្រៃយ៍ ក៏ចែងផងដែរថា ការប្រព្រឹត្តិអនុលោមតាមបញ្ជាថ្នាក់លើ មិនបង្កើតបានជាការការពារខ្លួនស្របច្បាប់ ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ។ ក្រោយមកអង្គជំនុំជម្រះបានបង្ហាញថា មាត្រា ៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម “ច្រានចោលការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មសង្គ្រាមជាលក្ខណៈបុគ្គល ប្រសិនបើ ជនជាប់ចោទ មិនបានដឹងថាបញ្ជានោះខុសច្បាប់ ហើយមិនមានអ្វីមកបង្ហាញថាបញ្ជានោះគឺជាបញ្ជាខុសច្បាប់នោះទេ”[846]។ យ៉ាងណាមិញ អង្គជំនុំជម្រះបានយល់ឃើញថា ឌុច បានដឹងថាបទបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាអំពើខុសច្បាប់ ដែលធ្វើឱ្យវាមានភាពមិនច្បាស់លាស់ថាតើគោលការណ៍ជាមូលដ្ឋាននៃមាត្រា ៣៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម អាចអនុវត្តនៅ អ.វ.ត.ក. ដែរ ឬយ៉ាងណា។

#### ៣.៥.២. ការបង្ខិតបង្ខំ

ការបង្ខិតបង្ខំមិនមែនជាការការពារពេញលេញ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៅចំពោះមុខ អ.វ.ត.ក. ឡើយ។ យ៉ាងណាមិញ វាអាចត្រូវបានពិចារណាជាស្ថានសម្រាលនៃការផ្តន្ទាទោស[847]។

---

[843] ដូចខាងលើ កថាខណ្ឌ ១៩៦០។
[844] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៥០។
[845] សូមមើល ដូចខាងលើ កថាខណ្ឌ ៥៥១-៥៥២ សម្គាល់ជើងទំព័រ ៩៦៤។
[846] ដូចខាងលើ កថាខណ្ឌ ៥៥២។
[847] ដូចខាងលើ កថាខណ្ឌ ៥៥៣-៥៥៨។

ពុំមានបទប្បញ្ញត្តិ អ.វ.ត.ក. ណាលើកឡើងច្បាស់លាស់ថាតើ ការបង្ខិតបង្ខំអាចឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ឬទេ[848]។ មាត្រា ៩៧(២) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ចែងថា "គ្រោះថ្នាក់យ៉ាងធំបំផុត នឹងត្រូវធ្លាក់មកលើអ្នកណាម្នាក់ ក្នុងពេលជាបន្ទាន់ក្រៃពេក មិនអាចនឹងចៀសបានដោយងាយ ហើយអ្នកមានគ្រោះនោះ នឹងដោះខ្លួនឱ្យរួចពីគ្រោះនេះបាន ក៏លុះត្រាតែបានប្រព្រឹត្តបទល្មើសណាមួយ ទើបរួច ម្យ៉ាងទៀតគ្រោះថ្នាក់នោះកាលកើតមក ក៏មិនមែនកើតមានឡើងមកពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះដែរ នឹងមិនមែនខ្លួនចារីនោះជាអ្នកបង្កបង្កើត បណ្តាលឱ្យមានគ្រោះថ្នាក់នោះដែរ"។

អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ បានកត់សម្គាល់ថា សាលាក្តីអន្តរជាតិបានសម្រេចថា ការបង្ខិតបង្ខំមិនផ្តល់ការការពារខ្លួនពេញលេញទៅនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមនោះទេ បើទោះបីជាវាត្រូវបានទទួលយកនៅក្នុងស្ថានសម្រាលនៃការផ្តន្ទាទោសក៏ដោយ[849]។ ទោះបីជាអង្គជំនុំជម្រះទទួលយកថា "មកទល់ចុងបញ្ចប់នៃអត្ថិភាពមន្ទីរសន្តិសុខ ស-២១ ឌុច អាចមានការភ័យខ្លាចចំពោះការបាត់បង់ជីវិតរបស់គាត់ (ក៏ដូចជាសាច់ញាតិជិតស្និទ្ធរបស់គាត់) ប្រសិនបើថ្នាក់លើគាត់មិនពេញចិត្តនឹងអំពើរបស់គាត់ អង្គជំនុំជម្រះបានសម្រេចថា ការបង្ខិតបង្ខំមិនអាចត្រូវបានយកមកសំអាងបានទេ នៅពេលដែលការគំរាមកំហែងនោះកើតចេញមកពីការអនុវត្តគោលនយោបាយដែលធ្វើឱ្យមានភាពភ័យរន្ធត់ ដែលជនជាប់ចោទខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត[850]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឌុច មិនបានប្រព្រឹត្តក្រោមការបង្ខិតបង្ខំ ក្នុងនាមគាត់ជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរ ស-២១ ឡើយ ដែលនាំឱ្យការបង្ខិតបង្ខំមិនមានការពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទនិងស្ថានសម្រាលនៃការផ្តន្ទាទោសនោះទេ[851]។

---

848 ដូចខាងលើ កថាខណ្ឌ ៥៥៣។
849 ដូចខាងលើ កថាខណ្ឌ ៥៥៤។
850 ដូចខាងលើ កថាខណ្ឌ ៥៥៧។
851 ដូចខាងលើ កថាខណ្ឌ ៥៥៨។

## ៤. សិទ្ធិជំនុំជម្រះដោយត្រឹមត្រូវ

### ៤.១. ប្រភពនៃសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវ

ច្បាប់ អ.វ.ត.ក. មិនត្រឹមតែផ្ដល់សិទ្ធិដល់ អ.វ.ត.ក. ឱ្យអនុវត្តនីតិវិធីព្រហ្មទណ្ឌក្នុងស្រុកប៉ុណ្ណោះទេ តែក៏បាន "តម្រូវឱ្យ អ.វ.ត.ក. បកស្រាយវិធានទាំងនេះ និងកំណត់អំពីភាពស្របគ្នានៃវិធានទាំងអស់នោះ ទៅនឹងបទដ្ឋានអន្តរជាតិ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីសិទ្ធិមនុស្ស និងត្រូវបានអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ"[852]។ ជាងនេះទៀត អ.វ.ត.ក. ត្រូវពិចារណាលើមាត្រា ៣១ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់នឹងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស"[853]។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងដូចខាងក្រោម អំពីសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវ៖

i. ច្បាប់រាំងរាំងមិនឱ្យមានការរំលោភបំពានលើរាងកាយបុគ្គលណាមួយឡើយ។
ii. ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។
iii. ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
iv. ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ [...]។
v. ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
vi. វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
vii. ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
viii. ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ[854]។

អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ មាត្រា ១២(២) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ចែងថា អ.វ.ត.ក. អនុវត្តយុត្តាធិការ "ស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់" ដូចមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ICCPR")[855]។ កម្ពុជាបានផ្ដល់សច្ចាប័ន ICCPR នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ១៩៩២[856]។

ដើម្បីធានាបានថាបុគ្គលគ្រប់រូបមានសមភាពចំពោះមុខតុលាការ និងសាលាជម្រះក្ដី មាត្រា ១៤(១) នៃ ICCPR ចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្ដីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្ដីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ"។ មាត្រា ១៤(២) ចែងថា ជនគ្រប់រូបដែលជាប់ចោទពីបទព្រហ្មទណ្ឌ "ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"។ មាត្រា ១៤(៣) រៀបរាប់អំពីការធានាជាក់លាក់ដែលត្រូវអនុវត្តតាម នៅក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងមកលើបុគ្គលណាម្នាក់៖

---

[852] សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E39/5 កថាខណ្ឌ ១៥។
[853] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣១។
[854] ដូចខាងលើ មាត្រា ៣៨។
[855] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១២(២)។
[856] សូមមើលសំណុំរឿង ០០២ សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និង ការលើកលែងទោស និងការអនុគ្រោះទោស ចុះថ្ងៃទី៣ វិច្ឆិកា ឆ្នាំ២០១១ E51/15 សម្គាល់ជើងទំព័រ ១៣។

i. ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។
ii. ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។
iii. ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស។
iv. ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន ដោយឥតបង់ថ្លៃ ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។
v. ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។
vi. ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ មិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។ និង
vii. មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។

ដើម្បីគោរពតាមរដ្ឋធម្មនុញ្ញ មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣៥(ថ្មី) នៃច្បាប់ អ.វ.ត.ក. ឆ្លុះបញ្ចាំងមាត្រា ១៤(៣) នៃ ICCPR។ វិធាន ២១(១) នៃវិធានផ្ទៃក្នុងក៏តម្រូវឱ្យគ្រប់ខ័ណ្ឌ អ.វ.ត.ក. ត្រូវតែបកស្រាយ "ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"។ ជាពិសេស វិធាន ២១ ចែងថា៖

i. ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នា រវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ នឹងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។
ii. បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និង ត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។
iii. អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។ ហើយ
iv. ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាព របស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

យុត្តិសាស្ត្រភាគច្រើនដែលទាក់ទងទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ ត្រូវបានចេញក្រោមវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលជាចំណុចផ្តោតនៃផ្នែកខាងក្រោមនេះ។

## ៤.២. សិទ្ធិទទួលបានសមភាពរវាងគូក្តី

សិទ្ធិទទួលបានសមភាពរវាងគូក្តីនៅក្នុងវិធាន ២១(១)(ក) តម្រូវឱ្យកិច្ចដំណើរការនីតិវិធី "ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"[857]។ សិទ្ធិនេះត្រូវបានពិចារណាទាក់ទងទៅនឹង ការបែងចែកពេលវេលាសម្រាប់ការសួរសំណួរសាក្សី ការធានាសិទ្ធិចូលរួមក្នុងការស៊ើបអង្កេត និងការចូលពិនិត្យមើលសំណុំរឿង និងការផ្តល់ជំនួយផ្នែកច្បាប់ និងពេលវេលាគ្រប់គ្រាន់សម្រាប់ក្រុមការពារក្តីត្រៀមរៀបចំសម្រាប់ការជំនុំជម្រះ។

[857] វិធានផ្ទៃក្នុង វិធានទី២១ (១)(ក)។

### ៤.២.១. ការបែងចែកពេលវេលាសម្រាប់ការសួរសំណួរសាក្សី

គោលការណ៍នៃសមភាពរវាងគូក្តី មិនតម្រូវថា ត្រូវតែផ្តល់ពេលវេលាស្មើគ្នាជានិច្ចទៅឱ្យក្រុមការពារក្តីផង និងទៅឱ្យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរនោះទេ[858]។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធមិនផ្តល់ពេលវេលាបន្ថែម ទៅឱ្យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើការសួរសំណួរសាក្សី។ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ពីភាពផ្សេងគ្នារវាង ជនជាប់ចោទនៅក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌដែលសេរីភាពរបស់ខ្លួនស្ថិតក្នុងហានិភ័យ ហើយដែលទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ អនុលោមតាមមាត្រា ១៤(២) និង (៣) នៃ ICCPR ហើយនឹងតំណាងអយ្យការ ដែលតំណាងឱ្យផលប្រយោជន៍សាធារណៈក្នុងការធានាយុត្តិធម៌ស្របតាមច្បាប់។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាបន្ថែមទៀតថា ទោះបីជាភាគីដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិជំនុំជ្រះក្តីដោយត្រឹមត្រូវក្រោមមាត្រា ១៤(១) នៃ ICCPR យ៉ាងណាក្តី ក៏ពួកគេមាន "តួនាទីជាក់លាក់ និងមានកម្រិតនៅក្នុងកិច្ចដំណើរការនីតិវិធី ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក." ដែលស្របតាមបទដ្ឋានអន្តរជាតិ[859]។

### ៤.២.២. សិទ្ធិចូលរួមក្នុងការស៊ើបអង្កេត និងចូលពិនិត្យសំណុំរឿង

យុត្តិសាស្ត្ររបស់ អ.វ.ត.ក. មិនបានដោះស្រាយឱ្យបានច្បាស់លាស់ ថាតើនៅពេលណាដែលជនសង្ស័យ ឬជនត្រូវចោទមានសិទ្ធិចូលរួមក្នុងការស៊ើបអង្កេត និងចូលពិនិត្យសំណុំរឿងនោះទេ។

ក្នុងសំណុំរឿង០០២ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា បុគ្គលណាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទទួលបានឋានៈជា "ជនត្រូវចោទ" ដោយផ្អែកលើសន្ទានុក្រមនៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់ប្រទេសបារាំង[860]។ ក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ពីឋានៈរបស់ "ជនត្រូវចោទ" ដោយលើកឡើងថា បុគ្គលនោះត្រូវមានសិទ្ធិចូលពិនិត្យសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេត ប៉ុន្តែសិទ្ធិនេះអនុវត្តបានតែនៅពេលដែលត្រូវបានចោទប្រកាន់ផ្លូវការនៅពេលបង្ហាញខ្លួនលើកដំបូងប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតបានបែងចែករវាង "ជនសង្ស័យ" និង "ជនត្រូវចោទ" ផ្អែកតាមដំណើរការចោទប្រកាន់ជាផ្លូវការដែលមានចែងក្នុងមាត្រា ៥៥(៤) និង ៥៧ នៃវិធានផ្ទៃក្នុង[861]។

ក្នុងសំណុំរឿង ០០៤ អង្គបុរេជំនុំជម្រះខកខានក្នុងការទទួលបានសំឡេងគាំទ្រដែលត្រូវការ ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើរបស់គាត់ស្នើសុំចូលពិនិត្យសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ[862]។ ចៅក្រមនៃអង្គបុរេជំនុំជម្រះមានការខ្វែងយោបល់គ្នារវាង "ការបកស្រាយផ្ទុយគ្នា" នៃពាក្យ "ជនត្រូវចោទ"

---

[858] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ F26/2/2 កថាខណ្ឌ ៦-៧។

[859] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ F26/2/2 កថាខណ្ឌ ៦-៧។

[860] សំណុំរឿង ០០២ ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបន្ថែម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ D298/2 សម្គាល់ជើងទំព័រ ៦។ សូមមើល វិធានផ្ទៃក្នុង សន្ទានុក្រម ("ជនត្រូវចោទសំដៅទៅលើបុគ្គលណាម្នាក់ ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រហូតដល់ដីកាដំណោះស្រាយ")។

[861] សូមមើលសំណុំរឿង ០០៤ ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ D121/4/1/4 យោបល់ចៅក្រម Chang-Ho Chung និង Rowan Downing កថាខណ្ឌ ១៦ (យោងសំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ D121/4 កថាខណ្ឌ ៣៦-៣៧ និងកថាខណ្ឌ ៤០-៤៤)។

[862] សំណុំរឿង ០០៤ ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ D121/4/1/4 កថាខណ្ឌ ១ ផ្នែកសម្រេចសេចក្តី។

ដែលបានអនុម័តយកដោយសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០២ និងបន្ទាប់មកក្នុងសំណុំរឿង ០០៣ និង ០០៤[863]។

ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤ បានទទួលយកការបកស្រាយពីមុនរបស់សហចៅក្រមស៊ើបអង្កេតនៃពាក្យ "ជនត្រូវចោទ" ក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេត "ពុំទាន់បានធ្វើការចោទប្រកាន់ ឬដាក់ឱ្យស្ថិតក្រោមការពិនិត្យជនណាម្នាក់ជាផ្លូវការនៅឡើយ ក្នុងសំណុំរឿង ០០៤"[864]។ ចៅក្រមជាតិបានសន្និដ្ឋានថា អោ អាន មិនមែនជាភាគីមួយនៅក្នុងដំណើរការនីតិវិធីឡើយ ហើយមិនមែនជាជនត្រូវចោទទេ ដូច្នេះ "មិនមែនជាភាគីណាមួយឡើយ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី"[865]។

ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់ អោ អាន អាចទទួលយកបាន និងបានទទួលយកការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតនៃពាក្យ "ជនត្រូវចោទ" ក្នុងសំណុំរឿង ០០២[866]។ ចៅក្រមអន្តរជាតិបានសង្កេតឃើញថា អង្គបុរេជំនុំជម្រះបានកត់សម្គាល់ពីមុនមកថា គោលការណ៍ជាសារវន្តដែលចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្រោមក្របខ័ណ្ឌ អ.វ.ត.ក. និង ICCPR អាចតម្រូវឱ្យធ្វើការបកស្រាយលើសិទ្ធិប្តឹងឧទ្ធរណ៍។ ចៅក្រមអន្តរជាតិបានពិចារណាថា ការបកស្រាយទូលំទូលាយបែបនេះ ចាំបាច់ក្នុងរឿងក្តី អោ អាន "ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងអាចតទល់គ្នាក្នុងរឿងក្តី ហើយត្រូវរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី"[867]។

ផ្នែកអង្គសេចក្តី ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ដោយសារតែពួកគេជាកម្មវត្ថុនៃការចោទប្រកាន់ បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គប្បីទទួលបានសិទ្ធិដែលជនត្រូវចោទទទួលបាន "ដោយមិនគិតថា ពួកគេមិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ ពីសំណាក់សហចៅក្រមស៊ើបអង្កេត និងមិនទាន់ត្រូវបានកោះហៅឱ្យចូលមកបង្ហាញខ្លួនជាលើកដំបូងនោះទេ"[868]។ ដូច្នេះ ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា អ៊ោ អាន គប្បីទទួលបានការអនុញ្ញាតឱ្យអនុវត្តសិទ្ធិនានាដែលជនត្រូវចោទមានក្រោមវិធានផ្ទៃក្នុង ដើម្បីការពារសិទ្ធិរបស់គាត់ក្នុងការត្រៀមរៀបចំការការពារក្តី និងដើម្បីធានាបាននូវការប្រកាន់ខ្ជាប់នូវគោលការណ៍សមភាពរវាងគូក្តី[869]។

ក្រោយមកនៅក្នុងសំណុំរឿង ០០៣ អង្គបុរេជំនុំជម្រះបានងាកចេញពីសេចក្តីសម្រេចពីមុនរបស់ខ្លួន ហើយបានបង្គាប់ជាឯកច្ឆន្ទឱ្យសហចៅក្រមស៊ើបអង្កេត អនុញ្ញាតឱ្យសហមេធាវីរបស់ មាស មុត ចូលពិនិត្យសំណុំរឿង ក្នុងគោលបំណងដើម្បីប្តឹងឧទ្ធរណ៍សេចក្តីសម្រេចស្តីពីតំណាងផ្នែកច្បាប់[870]។ អង្គបុរេជំនុំជម្រះបានពិចារណាថា សហមេធាវី "មិនអាចធ្វើការតតាំងប្រកបដោយអត្ថន័យលើសេចក្តីសន្និដ្ឋាននានា" នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់បានទេ "បើមិនមានសិទ្ធិចូលមើលឯកសារភស្តុតាងនានា ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រើជាមូលដ្ឋានសំអាង"[871]។ ជាពិសេស សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានថា ទំនាស់ផលប្រយោជន៍មួយបានកើតមាន ផ្អែកលើការពិនិត្យរបស់គាត់លើឯកសារក្នុងសំណុំរឿង ០០២ និង ០០៣ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម រវាង មាស មុត និង អៀង សារី។ អាស្រ័យហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានសម្រេចថា ការផ្តល់ការអនុញ្ញាតឱ្យសហមេធាវីចូលពិនិត្យសំណុំរឿង ក្នុងសំណុំរឿង ០០៣ មានសារៈសំខាន់ណាស់ ដើម្បីជៀសវាងស្ថាន

[863] ដូចខាងលើ យោបល់ចៅក្រម Chang-Ho Chung និង Rowan Downing កថាខណ្ឌ ១៥។
[864] ដូចខាងលើ យោបល់ចៅក្រម ប្រាក់ គឹមសាន, ន័យ ថុល និង ហួត វុទ្ធី កថាខណ្ឌ ៧។
[865] ដូចខាងលើ យោបល់ចៅក្រម ប្រាក់ គឹមសាន, ន័យ ថុល និង ហួត វុទ្ធី កថាខណ្ឌ ៧-៨។
[866] ដូចខាងលើ យោបល់ចៅក្រម Chang-Ho Chung និង Rowan Downing កថាខណ្ឌ ៦។
[867] ដូចខាងលើ យោបល់ចៅក្រម Chang-Ho Chung និង Rowan Downing កថាខណ្ឌ ៤-៥។
[868] ដូចខាងលើ យោបល់ចៅក្រម Chang-Ho Chung និង Rowan Downing កថាខណ្ឌ ២១។
[869] ដូចខាងលើ យោបល់ចៅក្រម Chang-Ho Chung និង Rowan Downing កថាខណ្ឌ ២៧។
[870] ដូចខាងលើ កថាខណ្ឌ ១៥-១៦។
[871] ដូចខាងលើ កថាខណ្ឌ ១៥។

ភាពមួយ ដែលសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចដែលរងការជំទាស់ ក្លាយទៅជាឥតន័យ និងដើម្បីធានាភាពត្រឹមត្រូវក្នុងដំណើរការឧទ្ធរណ៍ តាមរយៈសមភាពរវាងគូក្ដី[872]។

### ៤.២.៣. ការបែងចែកជំនួយផ្នែកច្បាប់ និងពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្ដី

សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ ដើម្បីរៀបចំការការពារក្ដីនៅ អ.វ.ត.ក. តម្រូវថា "ភាគីនីមួយៗត្រូវទទួលបានឱកាសសមស្រប ដើម្បីបង្ហាញសំណុំរឿងរបស់ខ្លួន ក្រោមលក្ខខណ្ឌនានាដែលពុំដាក់ឱ្យខ្លួនចាញ់ប្រៀបគូប្រជែងរបស់ខ្លួន"[873]។ អ្វីដែលបង្កើតបានជា "ពេលវេលាគ្រប់គ្រាន់" អាស្រ័យលើកាលៈទេសៈនៃរឿងក្ដី[874]។ ទាក់ទងនឹងសម្ភារៈរូបវន្តគ្រប់គ្រាន់ គោលការណ៍នៃសមភាពរវាងគូក្ដីមិនតម្រូវឱ្យមាន "សមភាពផ្នែកសម្ភារៈ" ក្នុងចំនួនមន្ត្រីបុគ្គលិក ឬធនធានសម្រាប់ផ្នែកការពារក្ដី និងសហព្រះរាជអាជ្ញាឡើយ[875]។ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតយល់ឃើញថា សំណើសុំធនធានធ្វើឡើងដោយមេធាវីការពារក្ដី ដែលមិនធ្វើឱ្យ អ.វ.ត.ក. ខាតបង់ គប្បីបដិសេធតែក្នុង "ករណីដែលវាមានការរំលោភបំពានវិធានជាក់លាក់ណាមួយ ដែលសំខាន់ស្មើនឹងសិទ្ធិជាមូលដ្ឋានដែលត្រូវគាំទ្រ និងការពារដោយបញ្ញត្តិពាក់ព័ន្ធនឹងធនធានដែលបានដោយឥតចំណាយប្រាក់" ប៉ុណ្ណោះ[876]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសំណើបន្ទាន់របស់មេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យរក្សាសមាជិកក្រុមមេធាវីការពារក្ដីទាំងអស់ បន្ទាប់ពីបញ្ចប់រឿងក្ដីក្រោយមរណភាពរបស់ នួន ជា។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការគ្រប់គ្រងជំនួយផ្នែកច្បាប់នៅចំពោះមុខ អ.វ.ត.ក. គឺជាការទទួលខុសត្រូវរបស់ផ្នែកគាំពារការពារក្ដី អនុលោមតាមវិធាន ១១ នៃវិធានផ្ទៃក្នុង ដូច្នេះហើយ អង្គជំនុំជម្រះ "មិនមានយុត្តាធិការធ្វើអន្តរាគមន៍ក្នុងការបែងចែកប្រាក់សាធារណៈ បន្ទាប់ពីការស្លាប់របស់បុគ្គលណាម្នាក់ ដែលម្យ៉ាងទៀតនោះ មានសិទ្ធិទទួលជំនួយផ្នែកច្បាប់នោះទេ"[877]។

ក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយយោងទៅអង្គជំនុំជម្រះតុលាការកំពូល នៃសាលាក្ដីអន្តរជាតិសម្រាប់រ្វ៉ាន់ដា ("ICTR") ក្នុងរឿងក្ដី *Kayishema* និង *Ruzindana* បានសម្រេចថា គោលការណ៍នៃសមភាពរវាងគូក្ដី "ពុំតម្រូវជាចាំបាច់ឱ្យមានសមភាពក្នុងចំនួនមន្ត្រីបុគ្គលិករបស់មេធាវីការពារក្ដី និងភាគីអយ្យការឡើយ"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា "ក្នុងយុត្តាធិការទាំងអស់ អយ្យការជាទូទៅមានការិយាល័យធំជាងមេធាវីការពារក្ដី ពីព្រោះអយ្យការត្រូវតែមានលទ្ធភាពធ្វើកិច្ចការជាមួយការទទួលខុសត្រូវធំជាងមេធាវីការពារក្ដី" និងមានចំនួនសំណុំរឿងច្រើនជាង[878]។

ក្នុងសំណុំរឿង ០០៤/០២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្នើសុំឱ្យផ្នែកគាំពារការការពារក្ដី "ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីតែងតាំង [...] ឱ្យបានឆាប់បំផុតតាមការជាក់ស្ដែង" នូវបុគ្គលិកបន្ថែម ដែលក្រុមមេធាវីការពារក្ដី អោ អាន បានស្នើសុំ[879]។ នៅក្នុងសេចក្ដីសម្រេចពីមុនលើបញ្ហានេះ សហ

[872] សំណុំរឿង ០០៣ សេចក្ដីសម្រេចទីពីរលើសំណើសុំវិធានការបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ D56/19/16 កថាខណ្ឌ ១៥។
[873] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើបន្ទាន់របស់ មាស មុត សុំជួលទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិចំនួន២រូបបន្ថែមទៀត ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦ D200/1 កថាខណ្ឌ ២២។
[874] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ D304/1 កថាខណ្ឌ ៨។
[875] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើបន្ទាន់របស់ មាស មុត សុំជួលទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិចំនួន២រូបបន្ថែមទៀត ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦ D200/1 កថាខណ្ឌ ២២។
[876] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ពាក់ព័ន្ធនឹងធនធានរបស់មេធាវីការពារក្ដី ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ D321/1 កថាខណ្ឌ ៧។
[877] សំណុំរឿង ០០២/០២ ចម្លើយតបទៅនឹងសំណើសុំឱ្យរក្សាក្រុមមេធាវីការពារក្ដី នួន ជា ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ F46/6។
[878] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើបន្ទាន់របស់ មាស មុត សុំជួលទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិចំនួន២រូបបន្ថែមទៀតចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦ D200/1 កថាខណ្ឌ ២២។
[879] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ D304/7 កថាខណ្ឌ ៦-៧។

ចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា សិទ្ធិទទួលបានពេលវេលា និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្ដីរបស់ខ្លួន "គឺជាធាតុផ្សំមួយជាសារវន្តនៃការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ និងជាផ្នែកមួយចាំបាច់នៃគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្ដី" ហើយបានរំលឹកថា វាត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់នៅកម្រិតអន្តរជាតិថា ស្ថាប័នតុលាការមានអំណាចជាប់មកជាមួយក្នុងការពិនិត្យសើរើសេចក្ដីសម្រេចរដ្ឋបាល ដែលអាចប៉ះពាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[880]។ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្នើសុំព័ត៌មានលម្អិតបន្ថែមទៀត ទាក់ទងទៅនឹងមូលហេតុដែលចាំបាច់ត្រូវការសមាជិកក្រុមមេធាវីការពារក្ដីបន្ថែមទៀត ដោយយល់ឃើញថាសំណើនោះពុំមានការគាំទ្រគ្រប់គ្រាន់[881]។ ក្រោយពីបានទទួលព័ត៌មានលម្អិតបន្ថែមទៀត គាត់បានទទួលយកសំណើនោះ ដោយកត់សម្គាល់ថា "មេធាវីការពារក្ដីស្ថិតក្នុងតួនាទីល្អបំផុត ដើម្បីសម្រេចលើរបៀបបែងចែកធនធានរបស់ខ្លួនដើម្បីធានាថា កូនក្ដីរបស់ខ្លួនមានតំណាងរឹងមាំ"។ គាត់ក៏បានផ្ដល់សំអាងហេតុទៀតថា បទបញ្ញត្តិរដ្ឋបាល ត្រូវតែបកស្រាយយោងតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ក្នុងន័យ "ការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ" មិនមែនជាការរារាំងនោះទេ[882]។

បន្ទាប់ពីភាគីបានដាក់សារណាជាលាយលក្ខណ៍អក្សរ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ រួចមក ផ្នែកគាំពារការការពារក្ដីបានកាត់បន្ថយថវិការបស់ក្រុមមេធាវីការពារក្ដី អោ អាន ដែលនាំឱ្យមានសំណើសុំឱ្យរក្សាទុកថវិកាក្រុមមេធាវីការពារក្ដីឱ្យនៅពេញលេញដដែល រហូតដល់អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើរនេះមិនអាចទទួលយកបាន ដោយសង្កេតឃើញថា វិវាទស្ថិត "ក្នុងវិសាលភាពនៃនីតិវិធីនៃការដោះស្រាយវិវាទយ៉ាងត្រឹមត្រូវ" ក្នុងគម្រោងជំនួយផ្នែកច្បាប់។ ដោយកត់សម្គាល់ថា ផ្នែកគាំពារការការពារក្ដី ត្រូវតពិនិត្យកិច្ចសន្យាការងាររបស់សហមេធាវីជាមួយនឹងជនជាប់ចោទនោះ អង្គបុរេជំនុំជម្រះពិចារណាថា ការធានានៅក្នុងក្របខ័ណ្ឌច្បាប់មានលក្ខណៈគ្រប់គ្រាន់ ក្នុងការការពារសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ អោ អាន[883]។ ទោះជាយ៉ាងណា អង្គបុរេកត់សម្គាល់ថា ផ្នែកគាំពារការការពារក្ដីមានកំហុសក្នុងការផ្អែកលើគម្រោងបញ្ចប់ផែនការជាយុត្តិកម្មសម្រាប់ការកាត់បន្ថយថវិកានេះ។ ផ្ទុយទៅវិញ សេចក្ដីសម្រេចចុងក្រោយរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ នឹងបានកំណត់ថាតើសំណុំរឿង ០០៤/០២ បានដំណើរការទៅជំនុំជម្រះដែរ ឬយ៉ាងណា[884]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ "ដាស់តឿនដល់អង្គភាពនេះឱ្យគិតដល់សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ យ៉ាងយកចិត្តទុកដាក់ និងជាបន្តបន្ទាប់នៅក្នុងផែនការថវិកា និងការវាយតម្លៃរបស់ខ្លួន ទៅលើការទាមទារប្រាក់កម្រៃរបស់មេធាវីការពារក្ដី"[885]។

ក្នុងសំណុំរឿង ០០៤ នៅពេលសម្រេចលើសំណើរបស់ យឹម ទិត្យ សុំតែងតាំងអ្នកជំនាញប្រឹក្សាយោបល់*ស្ម័គ្រចិត្ត* សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា សំណើសុំធនធានរបស់ក្រុមមេធាវីការពារក្ដី ដែលមិនធ្វើឱ្យ អ.វ.ត.ក. ខាតបង់អ្វី "មិនគួរត្រូវបានបដិសេធ លើកលែងតែវាមានការរំលោភបំពានវិធានជាក់លាក់ណាមួយ ដែលសំខាន់ស្មើនឹងសិទ្ធិជាមូលដ្ឋានដែលត្រូវគាំទ្រ និងការពារដោយបញ្ញត្តិពាក់ព័ន្ធនឹងធនធានដែលបានដោយឥតចំណាយប្រាក់"[886]។ សហចៅក្រមស៊ើបអង្កេតបានយោងការ

---

[880] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ D304/1 កថាខណ្ឌ ៧-៨។ សំណុំរឿង ០០៤/០២ បន្ថែមលើ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ D304/4 កថាខណ្ឌ១៨។
[881] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ D304/1 កថាខណ្ឌ១០។
[882] សំណុំរឿង ០០៤/០២ Further ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ធនធានបន្ថែម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ D304/4 កថាខណ្ឌ ១៦។
[883] សំណុំរឿង ០០៤/០២ សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្ដីលោក អោ អាន ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ D359/17 កថាខណ្ឌ ៨។
[884] សំណុំរឿង ០០៤/០២ សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្ដីលោក អោ អាន, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ D359/17 កថាខណ្ឌ១៣។
[885] ដូចខាងលើ កថាខណ្ឌ ១៤។
[886] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ពាក់ព័ន្ធនឹងធនធានរបស់មេធាវីការពារក្ដី ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ D312/1 កថាខណ្ឌ ៧។

សម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា មាត្រា ១៤ នៃ ICCPR "ផ្តល់នូវសិទ្ធិមានអធិកភាពដែលនឹងធ្វើជាយុត្តិសាស្ត្រសម្រាប់កិច្ចដំណើរការនីតិវិធីជាតិ" ហើយបានពិចារណាថា ICCPR "មានឋានានុក្រមខ្ពស់ជាងវិធានផ្ទៃក្នុង និងបញ្ញត្តិរដ្ឋបាល" ក្នុងករណីនេះ[887]។

### ៤.៣. សិទ្ធិទទួលបានការប្រព្រឹត្តិស្មើភាពគ្នា

សិទ្ធិទទួលបានការប្រព្រឹត្តិស្មើភាពគ្នាត្រូវបានចែងក្នុងវិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង ដែលតម្រូវថា បុគ្គលដែល "រកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និង ត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត"។ សិទ្ធិនេះត្រូវបានបកស្រាយ ជាការផ្តល់សិទ្ធិដល់ផ្នែកការពារក្តីក្នុងការឆ្លើយតបទៅនឹង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ផ្អែកលើការអនុវត្តពីមុន ទោះបីជាមិនមានសិទ្ធិច្បាស់លាស់ក្នុងការដាក់ចម្លើយតបនៅក្នុងក្របខ័ណ្ឌ អ.វ.ត.ក. យ៉ាងណាក្តី[888]។

អង្គបុរេជំនុំជម្រះយល់ឃើញថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនទទួលយកចម្លើយតបរបស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា បានរំលោភលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ ដោយការខកខានក្នុងការគោរពសិទ្ធិទទួលបានការប្រព្រឹត្តិដោយស្មើភាពគ្នា និងគោលការណ៍នៃសមភាពរវាងគូភាគី[889]។ សហចៅក្រមស៊ើបអង្កេតពីមុនបានទទួលយកចម្លើយតបរបស់ ឌុច ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០១ បើទោះបីជា វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ ("CCP") មិនបានចែងច្បាស់លាស់សម្រាប់សិទ្ធិបែបនេះក្តី។ ទោះបីជាអង្គបុរេជំនុំជម្រះលើកឡើងថា ការប្រព្រឹត្តិស្មើភាពគ្នាចំពោះមុខច្បាប់ "មិនអាចត្រូវបានបកស្រាយដើម្បីកំណត់ថា ការភាន់ច្រឡំនៅក្នុងរឿងក្តីមួយនឹងត្រូវអនុវត្តតាម នៅក្នុងរឿងក្តីមួយទៀតនាពេលអនាគតទេ" បើទោះបីជាវាផ្តល់អត្ថប្រយោជន៍ដល់ជនត្រូវចោទ អង្គបុរេយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនមានកំហុសក្នុងការទទួលយកចម្លើយតបរបស់ ឌុច នោះឡើយ[890]។ អង្គបុរេបានពិនិត្យមាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាភាសាបារាំង ដែលជាគំរូសម្រាប់មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ អង្គបុរេបានផ្តល់សំអាងហេតុថា វិសោធនកម្មមាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាភាសាបារាំង អនុញ្ញាតឱ្យជនត្រូវចោទឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ដែលផ្តល់នូវ "តុល្យភាពរវាងភាគីនានានៅក្នុងដំណាក់កាលស៊ើបសួរ"។ ដោយយល់ឃើញថាមិនមានកំហុសក្នុងការទទួលយកចម្លើយតបរបស់ ឌុច នោះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "ការបដិសេធជាគោលការណ៍" របស់សហចៅក្រមស៊ើបអង្កេត ទៅនឹងការដាក់ចម្លើយតបរបស់ អៀង សារី បាននាំឱ្យមាន "ការប្រព្រឹត្តិមិនស្មើភាពគ្នានៅចំពោះមុខច្បាប់ ដែលធ្វើឱ្យមានការខូចខាតដល់ជនត្រូវចោទ អៀង សារី"[891]។

ក្នុងសំណុំរឿង ០០៤/០១ និងក្រោយមកទៀតក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតបានបន្តផ្តល់សិទ្ធិឱ្យមេធាវីការពារក្តីដាក់ចម្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ផ្អែកលើគោលការណ៍នៃការប្រព្រឹត្តិស្មើភាពគ្នា[892]។

### ៤.៤. សច្ចធារណ៍និរទោស

[887] ដូចខាងលើ កថាខណ្ឌ ៦ យោងសំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ D264/2/6 កថាខណ្ឌ ១៣។

[888] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ D390/1/2/4 កថាខណ្ឌ ២២។

[889] ដូចខាងលើ កថាខណ្ឌ ៩-២៣។

[890] ដូចខាងលើ កថាខណ្ឌ ៧-១៥។

[891] ដូចខាងលើ កថាខណ្ឌ ១៩។

[892] សូមមើលឧទាហរណ៍ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម ទាក់ទងនឹងការបិទកិច្ចការស៊ើបសួរ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ D286/6 កថាខណ្ឌ ១១-១២ សំណុំរឿង ០០៣ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦ (៤) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ D256 កថាខណ្ឌ ១៤។

វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងសម្រាប់សច្ចធារណ៍និរទោសថា៖ “ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ”។ គោលការណ៍សច្ចធារណ៍និរទោសអនុវត្ត “រហូតដល់មានសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខដែលថាតើ ត្រូវតម្កល់ ឬបដិសេធការសម្រេចដាក់ពិរុទ្ធភាព” និងចំពោះបទដ្ឋាននៃការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូល[893]។ ទោះជាយ៉ាងណា ការសន្មតនេះមិនមែនជាការប្រកាសពីឋានៈថាឥតទោស ដែលថាម្ចាស់បណ្តឹងសាទុក្ខអាចចាប់ផ្តើមបណ្តឹងសាទុក្ខរបស់ខ្លួនបាន ក្នុងឋានៈដូចគ្នាជាជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះឡើយ[894]។ ផ្ទុយទៅវិញ គោលការណ៍សច្ចធារណ៍និរទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ “គឺជាលក្ខខណ្ឌតម្រូវដាច់ខាត” ចំពោះអង្គជំនុំជម្រះតុលាការកំពូល “ក្នុងការវាយតម្លៃរាល់សារណាដែលបានធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដោយមានការបើកចិត្តឱ្យទូលាយ”[895]។

ក្នុងករណីដែលថា ម្ចាស់បណ្តឹងសាទុក្ខបានស្លាប់មុនការសម្រេចលើបណ្តឹងសាទុក្ខរបស់ខ្លួន មរណភាពរបស់ពួកគេបានរំលត់បណ្តឹងសាទុក្ខ និងសិទ្ធិជាបុគ្គលផ្សេងៗជាធរមាននៅដំណាក់កាលបណ្តឹងសាទុក្ខ[896]។ ដោយអនុវត្តបទដ្ឋានអន្តរជាតិ និងការប្រកាន់យក “វិធីសាស្ត្រដែលមានលក្ខណៈទូលាយជាង” អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា សច្ចធារណ៍និរទោសអនុវត្តចំពោះបទដ្ឋាននៃការពិនិត្យរបស់ខ្លួន។ យ៉ាងណាមិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា “សច្ចធារណ៍និរទោសពុំមែនក្នុងគោលបំណងប្រើប្រាស់តាមអត្ថន័យច្បាប់ដោយឥតខ្លឹមសារ”នោះទេ។ អង្គជំនុំជម្រះតុលាការកំពូលពុំឯកភាពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី *Delić* នៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (“ICTY”) ដែលបានសម្រេចថា សច្ចធារណ៍និរទោស *មិនអនុវត្ត* លើទណ្ឌិតដែលរង់ចាំបណ្តឹងសាទុក្ខនោះឡើយ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលឯកភាពជាមួយនឹងសេចក្តីសង្កេតរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី *Delić* ដែលថា នៅដំណាក់កាលបណ្តឹងសាទុក្ខ ភាគីប្តឹងសាទុក្ខត្រូវតែបង្ហាញកំហុសនានា ជាជាងព្យាយាមផ្តួចផ្តើមការជំនុំជម្រះ*សាជាថ្មី*។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សច្ចធារណ៍និរទោសនៅដំណាក់កាលបណ្តឹងសាទុក្ខគឺជា “លក្ខខណ្ឌតម្រូវដាច់ខាត [...] ក្នុងការវាយតម្លៃរាល់សារណាដែលបានធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដោយមានការបើកចិត្តឱ្យទូលាយផ្អែកតាមបទដ្ឋានសមស្របក្នុងកម្រិតខ្ពស់”[897]។

សេចក្តីថ្លែងការណ៍ជាសាធារណៈអំពីពិរុទ្ធភាពរបស់ជនជាប់ចោទអាច “មិនស្របទៅនឹងគោលការណ៍នៃការសន្មតថាគ្មានទោស”។ អង្គជំនុំជម្រះសាលាដំបូងសង្កត់ធ្ងន់ថា សច្ចធារណ៍និរទោសគឺជា “គោលការណ៍សារវន្តនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ” និងជាធាតុផ្សំចាំបាច់មួយនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងវិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ មាត្រា ១៤(២) នៃ ICCPR មាត្រា ៦២ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងមាត្រា ៧(១)(ខ) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន[898]។ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាថា ដោយមិនគិតពីចេតនាក្នុងការធ្វើសេចក្តីថ្លែងការណ៍ សេចក្តីថ្លែងការណ៍ជាសាធារណៈអំពីពិរុទ្ធភាពដែលបានចោទប្រកាន់នោះ មានហានិភ័យដែលអាចត្រូវបានគេយកទៅបកស្រាយថា មានការប៉ុនប៉ងដាក់សម្ពាធដោយមិនសមរម្យមកលើចៅក្រម ហេតុដូច្នេះ ”ស្ថិតក្នុងវិធានការណ៍ណាមួយដែលមានចែងក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង[899]។

---

[893] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្រោយមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ F46/2/4/2 កថាខណ្ឌ ៦៩។
[894] ដូចខាងលើ កថាខណ្ឌ ៦៨-៦៩។
[895] ដូចខាងលើ កថាខណ្ឌ ៦៥។
[896] ដូចខាងលើ កថាខណ្ឌ ៦៩។
[897] ដូចខាងលើ កថាខណ្ឌ ៦៥។
[898] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ E176/2 កថាខណ្ឌ ១៦-១៨។
[899] ដូចខាងលើ កថាខណ្ឌ ២៩។

### ៤.៥. គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ (*in dubio pro reo*)

ស្របគ្នានឹងគោលការណ៍សច្ចធារណ៍និរទោស គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* កំណត់ថា ការសង្ស័យត្រូវតែដោះស្រាយជាប្រយោជន៍របស់ជនជាប់ចោទ[900]។ ដោយត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ មុខងារចម្បងនៃគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*នេះគឺត្រូវ "បង្ហាញឱ្យឃើញនូវការយល់ដឹងជាស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ"[901]។ គោលការណ៍នេះបានអនុវត្តចំពោះរាល់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលបុរេជំនុំជម្រះផង[902]។ វាក៏អនុវត្តចំពោះ "ស្ថានភាពលំបាកនៃអត្ថន័យច្បាប់" ដែលមន្ទិលសង្ស័យនៅតែមានបន្ទាប់ពីការអនុវត្តវិធាននៃការបកស្រាយច្បាប់ស៊ីវិល ពោលគឺ ពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ និងគោលបំណងរបស់វា[903]។

គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះ "ភាពមន្ទិលសង្ស័យអំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តិដែលនៅតែមាន ក្រោយការអនុវត្តនូវវិធាននៃការបកស្រាយតាមប្រព័ន្ធនៃច្បាប់ស៊ីវិល ដោយធ្វើការពិចារណាលើពាក្យពេចន៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ"[904]។ តាមការអនុវត្តជាក់ស្តែង គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*នឹងមិនមានភាពចាំបាច់ នៅពេលដោះស្រាយទៅលើ *កង្វះចន្លោះ*នៃច្បាប់ឡើយ ប៉ុន្តែ អាចនឹងពាក់ព័ន្ធក្នុងករណីដែលមានវិវាទបទដ្ឋានច្បាប់នានា[905]។

ក្នុងសំណុំរឿង ០០២/០១ អង្គបុរេជំនុំជម្រះបានអនុវត្តគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅដំណាក់កាលបុរេជំនុំជម្រះ ចំពោះភាពមន្ទិលសង្ស័យអំពីអត្ថន័យនៃច្បាប់ នៅពេលធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[906]។ ក្នុងការពិចារណាលើការសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងទាក់ទងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ អង្គបុរេជំនុំជម្រះយល់ឃើញថា វានៅតែមិនច្បាស់លាស់ ថាតើនៅពេលណាដែលការបំបែកលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងនេះ ត្រូវបានប៉ះពាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ក្នុងករណីដែលមិនមានការអនុវត្តរបស់រដ្ឋច្បាស់លាស់ និង *ទស្សនៈច្បាប់*នោះ អង្គបុរេជំនុំជម្រះមិនអាចកំណត់បានពីដំណាក់កាលដែលមានបញ្ហា ចន្លោះពីឆ្នាំ១៩៦៨ រហូតដល់ឆ្នាំ១៩៨៤ នៅពេលដែលដំណាក់កាលអន្តរកាលបានកើតឡើង។ អង្គបុរេជំនុំជម្រះយល់ឃើញថា យោងតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* "ភាពមិនច្បាស់លាស់បែបនេះ នឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ"[907]។

### ៤.៦. សិទ្ធិទទួលបានការជូនដំណឹងអំពីការចោទប្រកាន់

វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងថាជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន។ សិទ្ធិនេះត្រូវបាន

---

[900] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣១០ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៤៤។

[901] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១ E50/3/1/4 កថាខណ្ឌ ៣១។ សូមមើលសំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦។

[902] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣១០ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៤៤។

[903] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១ E50/3/1/4 កថាខណ្ឌ ៣១។

[904] ដូចខាងលើ។

[905] ដូចខាងលើ។

[906] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣១០ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ១៤៤។

[907] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៣១០។

ដោះស្រាយនៅពេលកំណត់លក្ខខណ្ឌតម្រូវជាក់លាក់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ និងសិទ្ធិទទួលបានការបកប្រែភាសារបស់ភាគី។ សិទ្ធិទាំងនេះត្រូវបានពិភាក្សាខាងក្រោម។

### ៤.៦.១. លក្ខខណ្ឌតម្រូវជាក់លាក់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ

សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់ គឺជាសិទ្ធិជាសារវន្តរបស់ជនត្រូវចោទ។ សិទ្ធិនេះកើតឡើងនៅពេលចាប់ខ្លួន និងធានាថាជនត្រូវចោទមានលទ្ធភាពចូលរួមពេញលេញក្នុងការស៊ើបអង្កេត[908]។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក. មិនបានដោះស្រាយដាច់ស្រេចថាអ្វីទៅជា "ការជូនដំណឹងគ្រប់គ្រាន់" នោះឡើយ។

ក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានសម្រេចថា កង្វះភាពច្បាស់លាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អំពីលក្ខណៈនៃការចូលរួមរបស់ជនជាប់ចោទ ក្នុង JCE បានបង្កើតជាកង្វះការជូនដំណឹងអំពីបទចោទ[909]។ អង្គបុរេបានកត់សម្គាល់ថា វិធានផ្ទៃក្នុងបង្កើតឡើងក្នុងគោលបំណងធានានូវភាពយុត្តិធម៌ដល់ជនត្រូវចោទ តាមរយៈការតម្រូវឱ្យមានការជូនដំណឹងអំពី "វិសាលភាពនិងលក្ខណៈនៃអំពើដែលស្ថិតនៅក្រោមការស៊ើបអង្កេត"[910]។ អង្គបុរេក៏ពិចារណាផងដែរថា វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ណាមួយ ប្រឆាំងនឹងពួកគេ នៅពេលចាប់ខ្លួន និងនៅដំណាក់កាលស៊ើបអង្កេត ដូចដែលមានចែងក្នុងវិធាន ៥១ (១) នៃវិធានផ្ទៃក្នុង[911]។ ក្នុងការសម្រេចថាតើ ការចោទប្រកាន់តាមទម្រង់ JCE នៅ ស-២១ ប្រឆាំងនឹង ឌុច បង្កើតបានជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុ សម្រាប់ការស៊ើបអង្កេតដែរ ឬយ៉ាងណានោះ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ធាតុផ្សំគតិយុត្តិនៃការទទួលខុសត្រូវតាម JCE ហើយបានសន្និដ្ឋានថា ការចោទប្រកាន់តាមទម្រង់ JCE បានពង្រីកប្រភេទនៃការប្រព្រឹត្តិដែលជាប់ពាក់ព័ន្ធនឹង ឌុច នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[912]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ទោះបីជាធាតុផ្សំមួយចំនួននៃ JCE នៅ ស-២១ ត្រូវបានស៊ើបអង្កេត ក៏ធាតុផ្សំផ្សេងទៀតមិនត្រូវបានស៊ើបអង្កេតទេ។ ដូច្នេះ បញ្ហានេះមិនមែនត្រឹមតែជាការកំណត់បទចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថាតើមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ ក្នុងការគាំទ្រការកំណត់បទចោទនោះដែរ ឬទេ[913]។ អង្គបុរេបានសន្និដ្ឋានថា ឌុច មិនទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ ទាក់ទងទៅនឹងការចូលរួមរបស់គាត់ក្នុង JCE នៅ ស-២១ មុនពេលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ ហើយអង្គបុរេបានសម្រេចមិនបញ្ចូលពួកវា ទៅក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែឡើយ[914]។

ផ្ទុយទៅវិញ ក្នុងសំណុំរឿង ០០២/០១ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា មានតែសេចក្តីសង្ខេបអង្គហេតុ និងប្រភេទនៃបទល្មើសដែលស្ថិតក្រោមការស៊ើបអង្កេតប៉ុណ្ណោះ ដែលត្រូវការនៅដំណាក់កាលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការរៀបរាប់លម្អិតជាងនេះអំពីអង្គហេតុសំខាន់ៗ និងការកំណត់បទចោទរបស់ពួកវា ត្រូវការនៅក្នុងដីកាដំណោះស្រាយ[915]។ អង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុថា សហព្រះរាជអាជ្ញាបានធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន ដោយមិនមានអត្ថប្រយោជន៍ពីការស៊ើបអង្កេតពេញលេញ ហេតុដូច្នេះហើយមិនទាមទារឱ្យមានភាពជាក់លាក់នោះទេ។ អង្គបុរេបានសម្រេចទៀតថា សហព្រះរាជអាជ្ញាមិនត្រូវបានរារាំងមិនឱ្យចោទប្រកាន់អំពីការទទួលខុសត្រូវរបស់ជនត្រូវចោទ ក្នុងនាមជាអ្នកចូលរួមក្នុង JCE ឡើយ និងក្នុងការយោងទៅទម្រង់ជាក់លាក់មួយ(ច្រើន) (ទម្រង់មូលដ្ឋាន) ជាលើកដំបូងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ដោយសារតែសហចៅក្រមស៊ើបអង្កេតអាច

---

[908] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ D97/15/9 កថាខណ្ឌ ៩២។
[909] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣១-១៤១។
[910] ដូចខាងលើ កថាខណ្ឌ ១៣៨។
[911] ដូចខាងលើ កថាខណ្ឌ ១៣៨-១៤០។
[912] ដូចខាងលើ កថាខណ្ឌ ១៣១-១៣៦។
[913] ដូចខាងលើ កថាខណ្ឌ ១៣៧។
[914] ដូចខាងលើ កថាខណ្ឌ ១៤១។
[915] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ D97/15/9 កថាខណ្ឌ ៩២។

ធ្វើដូច្នោះបាននៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន[916]។ អង្គបុរេបានសន្និដ្ឋានថា កង្វះភាពលម្អិតអំពីតួនាទីនីមួយៗរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ នៅក្នុងទម្រង់ JCE ដែលត្រូវបានចោទប្រកាន់ មិនបង្កើតបានជាការជូនដំណឹងមិនគ្រប់គ្រាន់អំពីការចោទប្រកាន់នោះទេ ដរាបណាដីកាដំណោះស្រាយ បានបញ្ចូលទិដ្ឋភាពជាក់លាក់នៃអំពើរបស់ជនជាប់ចោទ ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតទាញការសន្និដ្ឋានអំពីការចូលរួមចំណែករបស់ពួកគេនៅក្នុង JCE និង*ធាតុផ្សំអត្តនោម័ត*ចាំបាច់[917]។

អង្គបុរេជំនុំជម្រះមិនបានពិភាក្សាលក្ខខណ្ឌតម្រូវភាពជាក់លាក់ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ និង ០០៤។

### ៤.៦.២. សិទ្ធិទទួលបានការបកប្រែភាសារបស់ភាគី

ទោះបីជាជនត្រូវចោទមានសិទ្ធិទទួលបានព័ត៌មាន អំពីការចោទប្រកាន់ក្រោមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ពួកគេមិនមានសិទ្ធិជាក់លាក់ក្នុងការទទួលបានឯកសារទាំងអស់នៅក្នុងសំណុំរឿងតាមភាសារបស់ខ្លួននោះទេ ឬតាមភាសារបស់សហមេធាវីរបស់ពួកគេឡើយ[918]។ ដូច្នេះ អង្គហេតុដែលថាភាសាគឺជាភាសាមួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក. មិនមែនជាសិទ្ធិសម្រាប់ជនត្រូវចោទក្នុងការមានឯកសារទាំងអស់នៅក្នុងសំណុំរឿងបកប្រែជាភាសារបស់ខ្លួននោះទេ[919]។ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះបានសម្រេចថា អាស្រ័យលើកាលៈទេសៈជាក់លាក់នៃរឿងក្ដី ការបកប្រែឯកសារអាចចាំបាច់ដើម្បីធានាថា ជនត្រូវចោទអាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេលស៊ើបអង្កេត[920]។ "លក្ខខណ្ឌសំខាន់ៗ" គឺត្រូវធានាថា ជនត្រូវចោទដឹងអំពីរឿងក្ដីប្រឆាំងនឹងខ្លួន ហើយអាចការពារខ្លួនឯងបាន ជាពិសេសតាមរយៈការបង្ហាញអំពីអង្គហេតុនានាជូនតុលាការបាន[921]។

អង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រនេះស៊ីចង្វាក់គ្នាទៅនឹងយុត្តិសាស្ត្ររបស់សាលាក្ដីអន្តរជាតិ ដែលបានបដិសេធសំណើសុំបកប្រែឯកសារទាំងអស់ក្នុងសំណុំរឿង។ យុត្តិសាស្ត្រនេះពិចារណាថា ការបកប្រែរាល់ឯកសារនីមួយៗជាមុនទៅជាភាសារបស់ជនជាប់ចោទ អាច "ប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលមួយឆាប់រហ័ស"[922]។ អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា យុត្តិសាស្ត្រអន្តរជាតិបានទទួលស្គាល់ថា "ការផ្ដល់អ្នកបកប្រែផ្ទាល់មាត់មួយរូបដល់ចុងចោទ គឺជាយន្តការជំនួសគ្រប់គ្រាន់ចំពោះការផ្ដល់ការបកប្រែលើឯកសារជាក់លាក់មួយចំនួន"[923]។

### ៤.៧. សិទ្ធិទទួលបានមេធាវី

---

[916] ដូចខាងលើ កថាខណ្ឌ ៩៥។
[917] ដូចខាងលើ កថាខណ្ឌ ៩៧។
[918] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/II/9 កថាខណ្ឌ ៣៤ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/I/20 កថាខណ្ឌ ៤០។
[919] ដូចខាងលើ។
[920] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/II/9 កថាខណ្ឌ ៣៦ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/I/20 កថាខណ្ឌ ៤៣។
[921] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/II/9 កថាខណ្ឌ ៣៥ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/I/20 កថាខណ្ឌ ៤១។
[922] ដូចខាងលើ។
[923] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/II/9 កថាខណ្ឌ ៤១ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/I/20 កថាខណ្ឌ ៤៧។

វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងផ្តល់ឱ្យបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ នូវសិទ្ធិការពារខ្លួនដោយមានមេធាវីតាមការជ្រើសរើសរបស់ខ្លួន។ ជាពិសេសបំផុតនោះ សិទ្ធិនេះត្រូវបានដោះស្រាយនៅពេលពិចារណាបញ្ហានានាដូចជា ការចូលពិនិត្យសំណុំរឿង និងការចូលរួមក្នុងការស៊ើបអង្កេត ការដកមេធាវីការពារក្តីចេញ ដោយមូលហេតុទំនាស់ផលប្រយោជន៍ និងសិទ្ធិមានមេធាវីនៅដំណាក់កាលសវនាការដេញដោល លើបញ្ហាឃុំខ្លួនបណ្តោះអាសន្ន។ សិទ្ធិទាំងនេះត្រូវបានពិភាក្សាខាងក្រោម។

### ៤.៧.១. សិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវីក្នុងអំឡុងពេលស៊ើបអង្កេត

យុត្តិសាស្ត្ររបស់ អ.វ.ត.ក. មិនបានដោះស្រាយដាច់ស្រេចថាតើ ជនសង្ស័យមានសិទ្ធិមានមេធាវីមុនពេលត្រូវបានចោទប្រកាន់ជាផ្លូវការក្រោមវិធាន ៥៧ នៃវិធានផ្ទៃក្នុងដែរ ឬយ៉ាងណានោះឡើយ។

ក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ជនសង្ស័យដែលមិនត្រូវបានកំណត់ឈ្មោះ មិនមានសិទ្ធិមានមេធាវីការពារក្តីទេ[924]។ សហចៅក្រមយល់ឃើញថា ជនសង្ស័យដែលមិនត្រូវបានកំណត់ឈ្មោះ មិនទទួលបានការជូនដំណឹងជាផ្លូវការអំពីកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអនុលោមតាមវិធាន ៥៧ ឡើយ ហេតុដូច្នេះមិនត្រូវបានប៉ះពាល់ខ្លាំងដោយការស៊ើបអង្កេតនោះទេ ឧទាហរណ៍ ដោយការទៅជួប ការសួរចម្លើយ ស្ថិតក្រោមវិធានការឆែកឆេរ និងរឹបអូស ឬការឃុំខ្លួន ឬស្ថិតក្នុងរបៀបណាមួយដែលប៉ះពាល់ដោយការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះទេ[925]។

ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (បម្រុង) បានជូនដំណឹង "ជនសង្ស័យដែលបានកំណត់ឈ្មោះ" អំពីការចោទប្រកាន់ប្រឆាំងនឹងគាត់ និងបានជូនដំណឹងគាត់អំពីសិទ្ធិតាមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងក្នុងការទទួលបានការការពារខ្លួន ដោយមេធាវី និងមានសិទ្ធិចូលពិនិត្យសំណុំរឿង[926]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (បម្រុង) ពិចារណាឃើញថា ជនសង្ស័យទទួលបានសិទ្ធិតាមវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង "ក្នុងកាលៈទេសៈពិសេសនៃរឿងក្តីនេះ" ទោះបីជាមិនត្រូវបានចោទប្រកាន់ជាផ្លូវការតាមវិធាន ៥៥(៤) និង ៥៧ នៃវិធានផ្ទៃក្នុង[927]។ ការជូនដំណឹងនេះបានបង្កើតកាលៈទេសៈពិសេស តាមរយៈការផ្តល់ឱ្យជនសង្ស័យនូវឋានៈរបស់បុគ្គល ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ[928]។

### ៤.៧.២. សិទ្ធិទទួលបានមេធាវីនៅពេលសវនាការដេញដោលលើការឃុំខ្លួនបណ្តោះអាសន្ន

យោងតាមមាត្រា ៦៣(១) ជនត្រូវចោទត្រូវទទួលបានការណែនាំអំពីសិទ្ធិរបស់ខ្លួន ក្នុងការមានមេធាវី និងថាសិទ្ធិនេះអាចលះបង់បានក្នុងអំឡុងពេលសវនាការដេញដោលលើការឃុំខ្លួនបណ្តោះអាសន្ន[929]។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះយល់ឃើញថា នួន ជា បានលះបង់ដោយស្ម័គ្រចិត្ត និងយ៉ាងច្បាស់លាស់នូវសិទ្ធិរបស់គាត់ក្នុងការមានមេធាវី ក្នុងអំឡុងពេលសវនាការដេញដោល និងថាហេតុដូច្នេះការលះបង់សិទ្ធិរបស់គាត់នេះមានសុពលភាព[930]។

### ៤.៨. សិទ្ធិនៅស្ងៀម

---

[924] សំណុំរឿង ០០៣/០០៤ ដីកាសម្រេចលើពាក្យសុំពិនិត្យសំណុំរឿងលេខ០០៣ និង០០៤ ដោយលោកមេធាវីគង់ សំអុន ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ D3/1 កថាខណ្ឌ ២។

[925] ដូចខាងលើ កថាខណ្ឌ ៣-៦។

[926] សំណុំរឿង០០៤ ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ D122/6 កថាខណ្ឌ ២២។

[927] ដូចខាងលើ កថាខណ្ឌ ៩៥។

[928] ដូចខាងលើ កថាខណ្ឌ ២៣។

[929] សំណុំរឿង ០០២/០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/54 កថាខណ្ឌ ១៨។

[930] ដូចខាងលើ កថាខណ្ឌ ៣៩។

វិធាន ២១(១)(ឃ) ធានាសិទ្ធិនៅស្ងៀម។ សិទ្ធិនៅស្ងៀមត្រូវបានពិភាក្សាយ៉ាងគួរឱ្យកត់សម្គាល់បំផុត៖ (១) ក្នុងសំណុំរឿង ០០១ ដោយសារតែជនជាប់ចោទបានជ្រើសរើសសហការជាមួយសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត និងក្នុងការផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការ និង (២) ក្នុងសំណុំរឿង ០០២ ទោះបីជាការប្រើប្រាស់សិទ្ធិរបស់ ខៀវ សំផន ក្នុងការនៅស្ងៀម ក៏អង្គជំនុំជម្រះសាលាដំបូងតាំងសំណួរទៅកាន់គាត់ ឬសួរគាត់ឱ្យ "បញ្ជាក់" បញ្ចេញមតិលើ និងប្រតិកម្មតបទៅនឹងឯកសារដាក់នៅចំពោះមុខគាត់។

ក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានពិនិត្យដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ដោយធ្វើការពិនិត្យនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត មុនពេលដីកានោះត្រូវបានចេញ។ អង្គបុរេជំនុំជម្រះបានសង្កេត*ជាអាទិ៍* ថា៖ (១) សហមេធាវីមានវត្តមានក្នុងអំឡុងពេលសវនាការ និងពេលសួរចម្លើយ ឌុច នីមួយៗ (២) ឌុច បានដឹងពីសិទ្ធិតាមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង ក្នុងការនៅស្ងៀម ក្នុងអំឡុងពេលសវនាការ និងការសួរចម្លើយនីមួយៗ និង (៣) ទោះជាយ៉ាងណា ឌុច បានស្ម័គ្រចិត្តផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរទៅឱ្យសហចៅក្រមស៊ើបអង្កេត[931]។ ទោះបីជាអង្គបុរេជំនុំជម្រះសន្និដ្ឋានថា វាច្បាស់ណាស់ថា ឌុច ទើបតែទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀម នៅពេលចាប់ផ្តើមសវនាការបឋមក៏ដោយ - ដែលករណីនេះអាចលើកឡើងជាបញ្ហាចោទថាតើអ្វីទៅជាអត្ថន័យនៃឃ្លា "គ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី" - ក៏អង្គជំនុំជម្រះមិនយល់ឃើញថាខ្លួនចាំបាច់ត្រូវសម្រេចលើអត្ថន័យនៃឃ្លានេះឡើយ។ សហមេធាវីឯកភាពថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តតាមល័ក្ខខណ្ឌតម្រូវក្នុងការជូនដំណឹងដល់ ឌុច អំពីសិទ្ធិនៅស្ងៀមរបស់គាត់[932]។

នៅដំណាក់កាលសវនាការ ឌុច បានជ្រើសរើសឆ្លើយតបទៅនឹងសំណួរ នៅពេលជំនុំជម្រះ និងបានបញ្ជាក់លើអង្គហេតុជាច្រើននៅក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែ បើទោះបីជាគាត់ទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ចម្លើយតបរបស់ ឌុច "បង្កើតបានជាភស្តុតាង ដែលតម្លៃនៃភស្តុតាងនេះ ត្រូវបានយកមកពិចារណាដោយអង្គជំនុំជម្រះ"[933]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភសិទ្ធិរបស់គាត់ តាមរយៈការស្នើសុំឱ្យគាត់បញ្ចេញមតិលើបញ្ហានានា បើទោះជាការបញ្ជាក់យ៉ាងច្បាស់របស់គាត់ថា គាត់មានបំណងអនុវត្តសិទ្ធិនៅស្ងៀមក្តី[934]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន មិនបានពន្យល់ពីមូលហេតុដែលករណីនេះគឺជាកំហុសអង្គច្បាប់ និងថាតើគាត់ទទួលរងផលប៉ះពាល់បែបណានោះឡើយ ដោយកត់សម្គាល់ថា ខៀវ សំផន ត្រូវបានតំណាងដោយស្របច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា មិនមានសញ្ញាណាមួយបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងធ្វើការដាក់សម្ពាធលើគាត់ឱ្យលះបង់សិទ្ធិនៅស្ងៀមរបស់ខ្លួននោះទេ ប៉ុន្តែ "អង្គជំនុំជម្រះគ្រាន់តែអញ្ជើញ ខៀវ សំផន ឱ្យបញ្ចេញយោបល់លើបញ្ហាមួយចំនួននៅក្នុងអំឡុងពេលនៃការជំនុំជម្រះដ៏វែងអន្លាយនេះតែប៉ុណ្ណោះ"[935]។

## **៤.៩. សិទ្ធិទទួលបានការជំនុំជម្រះយ៉ាងឆាប់រហ័ស**

វិធាន ២១(៤) នៃវិធានផ្ទៃក្នុងតម្រូវឱ្យកិច្ចដំណើរការនីតិវិធី "ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"។ យុត្តិសាស្ត្រ អ.វ.ត.ក. មិនបានដោះស្រាយឱ្យបានដាច់ស្រេចថាតើអ្វីទៅបង្កើតបានជា "រយៈពេលសមស្រប" នោះទេ។ យ៉ាងណាមិញ ដូចបានរៀបរាប់ខាងក្រោម អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤, ០០៤/០១ និង ០០៤ បានយល់ឃើញជាឯកច្ឆន្ទថា សហចៅក្រមស៊ើបអង្កេតបានបណ្តាលឱ្យមាន

---

[931] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ C5/45 កថាខណ្ឌ ៨-១០។
[932] ដូចខាងលើ កថាខណ្ឌ ១០។
[933] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០។
[934] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១៩៧។
[935] ដូចខាងលើ។ សូមមើលសំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៧-២៩។

ការពន្យារពេលមិនសមស្រប ទៅលើកិច្ចដំណើរការនីតិវិធី ដោយការចំណាយពេលចន្លោះពី១៦ ទៅ ២១ ខែ ក្នុងការចេញដីកាដំណោះស្រាយ បន្ទាប់ពីការបិទបញ្ចប់កិច្ចស៊ើបសួរ។

ក្នុងសំណុំរឿង ០០៤/០១ អង្គបុរេជំនុំជម្រះបានយល់ឃើញជាឯកច្ឆន្ទថា ការពន្យារពេល ១៨ ខែ របស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយមានសំអាងហេតុ ក្រោយពេលបិទបញ្ចប់ការស៊ើបអង្កេត គឺមិនសមាមាត្រ និងបង្កើតបានជាការពន្យារពេលមិនសមស្រប[936]។ អង្គបុរេយល់ឃើញថា ដំណើរការរៀបចំចំនួន ១៨ ខែ គឺមិនសមហេតុផលទេ នៅពេលដែលពិចារណាលើ៖ (១) ភាពស្មុគស្មាញដ៏មានកម្រិតនៃរឿងក្តី (២) ការណ៍ដែលការស៊ើបអង្កេតត្រូវបានបញ្ចប់ក្នុងរយៈពេលប្រាំបួនខែកន្លះ ចាប់តាំងពីការជូនដំណឹងអំពីបទចោទ (៣) ការណ៍ដែលសហចៅក្រមស៊ើបអង្កេតទាំងពីរបានបង្ហាញចេតនាលើកលែងចោទប្រកាន់ និង (៤) អាយុ និងស្ថានភាពសុខភាពរបស់ជនត្រូវចោទ សាក្សី និងជនរងគ្រោះ[937]។ យ៉ាងណាមិញ អង្គបុរេជំនុំជម្រះមិនបានប្រកាសពីផលប៉ះពាល់នៃការពន្យារពេលនេះមានចំពោះសិទ្ធិក្នុងការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ អ៊ឹម ចែម នោះទេ។

ក្នុងសំណុំរឿង ០០៤/០២ អង្គបុរេជំនុំជម្រះបានយល់ឃើញជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងភាសាផ្លូវការតែមួយរបស់ អ.វ.ត.ក. ដោយមិនមានការបង្ហាញមូលហេតុច្បាស់លាស់អំពីកាលៈទេសៈលើកលែងនានានោះ “ធ្វើឱ្យមានការពន្យារពេលហួសហេតុនៅក្នុងកិច្ចដំណើរការលើសំណុំរឿង ០០៤/០២”។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា ដំណើរការរៀបចំសេចក្តីព្រាងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ (១៦ ខែ) មានរយៈពេលខ្លីជាងក្នុងសំណុំរឿង ០០៤/០១ (១៨ ខែ) បើទោះបីជារឿងក្តី និងបរិមាណឯកសារក្នុងសំណុំរឿង ០០៤/០២ មានចំនួនច្រើនជាងក៏ដោយ។ ទោះជាយ៉ាងណា អង្គបុរេយល់ឃើញថា រយៈពេលនេះ “ច្រើនហួស បើប្រៀបធៀបជាមួយនឹងដីកាដំណោះស្រាយដែលបានចេញក្នុងសំណុំរឿង ០០១ និង ០០២ ដែលមានចីរវេលាតែបីខែ សម្រាប់សំណុំរឿង ០០១ និង ប្រាំបីខែ សម្រាប់សំណុំរឿង ០០២ ក្រោយពីការបញ្ចប់កិច្ចស៊ើបសួររួចមក”[938]។

ក្នុងសំណុំរឿង ០០៣ ផ្ទុយទៅនឹងការអនុវត្តក្នុងសំណុំរឿង ០០៤/០១ និង ០០៤/០២ អង្គបុរេជំនុំជម្រះមិនបានសន្និដ្ឋានជាឯកច្ឆន្ទ លើការពន្យារពេលមិនសមស្រប ទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតទេ បើទោះបីជាសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយរបស់ខ្លួនរយៈពេលជាង ២២ ខែ ក្រោយការជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរក៏ដោយ[939]។ ផ្អែកលើការសន្និដ្ឋានពីមុនរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/០១ និង ០០៤/០២ និងការពិនិត្យមើលភាពស្មុគស្មាញ និងវិសាលភាពនៃសំណុំរឿង ០០៣ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតខកខានក្នុងការចេញដីកាដំណោះស្រាយក្នុងពេលវេលាសមស្រប។ ពួកគាត់យល់ឃើញថា បញ្ហាលំបាកដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានផ្តល់យុត្តិកម្មដល់ការពន្យារពេលនេះទេ ដោយសារតែបញ្ហាទាក់ទងនឹងបុគ្គលិក និងការបកប្រែភាសាត្រូវបានប្រមើលដឹងជាមុន ផ្អែកលើរឿងក្តីមុនៗ ហើយដូច្នេះអាចបន្ធូរបន្ថយបាន[940]។

ក្នុងសំណុំរឿង ០០៤ អង្គបុរេជំនុំជម្រះបានយល់ឃើញជាឯកច្ឆន្ទថា សហចៅក្រមស៊ើបអង្កេតខកខានក្នុងការចេញដីកាដំណោះស្រាយក្នុងពេលវេលាសមស្រប ដោយចំណាយពេលច្រើនជាង ២១ ខែ ក្រោយការជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ[941]។ យ៉ាងណាមិញ អង្គបុរជំនុំជម្រះមិនជឿជាក់ថា

---

936 សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣១។
937 ដូចខាងលើ កថាខណ្ឌ ៣០។
938 សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧០-៧២។
939 សូមមើលសំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣-២២។
940 ដូចខាងលើ យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ១៤៦-១៤៧។
941 សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៤-៧៦។

ការពន្យារពេលក្នុងសំណុំរឿងនេះ "ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីដែលត្រូវបានដំណើរការបន្តទៅមុខ"[942]នោះទេ។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានរៀបចំការធ្វើតេស្តមួយ សម្រាប់វាយតម្លៃសិទ្ធិក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីបញ្ចប់ក្នុងថិរវេលាសមស្រប។ ពួកគាត់បានពិចារណាឃើញថា "ចំណុចចាប់ផ្តើមនៃការវាយតម្លៃលើរយៈពេលសមហេតុផលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺនៅពេលជនសង្ស័យត្រូវបានជូនដំណឹងជាផ្លូវការថា ជនសង្ស័យនឹងត្រូវចោទប្រកាន់ បើទោះជាជនសង្ស័យមិនត្រូវបានចោទប្រកាន់ជាផ្លូវការរហូតដល់ដំណាក់កាលក្រោយមកក៏ដោយ"[943]។ យោងតាមចៅក្រមអន្តរជាតិ ការកំណត់ថាតើសិទ្ធិនេះត្រូវបានរំលោភបំពាន ឬអត់ ជាប់ពាក់ព័ន្ធនឹងការវាយតម្លៃ៖ (១) ភាពស្មុគស្មាញនៃរឿងក្តី (២) ការប្រព្រឹត្តិរបស់ជនជាប់ចោទ និង (៣) ការប្រព្រឹត្តិរបស់អាជ្ញាធរពាក់ព័ន្ធ[944]។

ក្នុងការរៀបចំតេស្តនេះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាលើយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECtHR") ដែលសម្រេចថាពាក្យ "ចោទប្រកាន់" សម្រាប់គោលបំណងនៃមាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស អាចត្រូវបានកំណត់និយមន័យថាជា "ការជូនដំណឹងផ្លូវការដល់បុគ្គលណាមួយដោយអាជ្ញាធរមានសមត្ថកិច្ចអំពីការចោទប្រកាន់ថា បុគ្គលរូបនេះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ និយមន័យនេះក៏ត្រូវនឹងលក្ខខណ្ឌតេស្តថាតើស្ថានភាពរបស់ជនសង្ស័យត្រូវបានប៉ះពាល់ដែរឬទេ"[945]។ ចៅក្រមក៏បានយោងយុត្តិសាស្ត្រ ECtHR ដែលសម្រេចថា ការវាយតម្លៃថាតើនរណាម្នាក់ត្រូវបានកាត់ទោសក្នុងរយៈពេលសមស្រប ឬទេនោះ ត្រូវតែធ្វើឡើង "ដោយពិនិត្យមើលកាលៈទេសៈនៃរឿងក្តី និងដោយពិនិត្យមើល [...] ជាពិសេស ភាពស្មុគស្មាញនៃរឿងក្តី ទង្វើរបស់ម្ចាស់បណ្តឹង និងទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច"[946]។ យោងតាមតេស្តនេះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា តាមការយល់ឃើញរបស់ពួកគាត់ ការកំណត់បទចោទថ្មីលើអង្គហេតុដែលបានចោទប្រកាន់ និងការស៊ើបអង្កេតបន្ថែមទៀតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង ០០៣ មានកម្រិតតិចតួច និងមិនបណ្តាលឱ្យមានការពន្យារពេលមិនសមស្រប ក្នុងការបិទបញ្ចប់ការស៊ើបអង្កេតនោះទេ[947]។

### ៤.១០. ផលប៉ះពាល់នៃការពន្យារពេលមិនសមស្រប ពីរឿងក្តីក្រៅ អ.វ.ត.ក.

ក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ការឃុំខ្លួនពីមុនរបស់ ឌុច នៅតុលាការយោធាកម្ពុជា បានរំលោភច្បាប់ជាតិជាធរមាននាពេលនោះ និងបានបំពានលើសិទ្ធិដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប និងការឃុំខ្លួនត្រឹមត្រូវតាមច្បាប់នោះឡើយ[948]។ ទោះបីជាការរំលោភបំពានទាំងអស់នេះ មិនជាប់ពាក់ព័ន្ធនឹង អ.វ.ត.ក. ក្តី ក៏អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឌុច ប្រសិនបើត្រូវបានផ្តន្ទាទោសនោះ នឹងទទួលបានការទូទាត់ ដែលនឹងត្រូវសម្រេចនៅដំណាក់កាលសម្រេចអំពីទោស ចំពោះពេលវេលាដែលបានចំណាយដោយខុសច្បាប់នៅក្នុងការឃុំខ្លួន នៅតុលាការយោធា រវាងថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ប្រសិនបើគាត់ត្រូវបានសម្រេចឱ្យរួចខ្លួនពីបទចោទប្រកាន់វិញនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គាត់មានសិទ្ធិទាមទារសំណងដែលមានចំពោះគាត់តាមច្បាប់ជាតិ[949]។ យ៉ាងណាមិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្រអន្តរ

---

[942] ដូចខាងលើ កថាខណ្ឌ ៧៨។
[943] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៦ D120/3/1/8 យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៣៥។
[944] ដូចខាងលើ យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៣៧។
[945] ដូចខាងលើ យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៣៦ សម្គាល់ជើងទំព័រ១៣៤។
[946] ដូចខាងលើ យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៣៧ សម្គាល់ជើងទំព័រ ១៣៩។
[947] ដូចខាងលើ យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៤៩។
[948] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ E39/5 កថាខណ្ឌ ២១។
[949] ដូចខាងលើ កថាខណ្ឌ ៣៧-៣៧។

ជាតិដែលពាក់ព័ន្ធ ត្រង់ចំណុចដែលមានខ្លឹមសារថា ការរំលោភបំពានទៅលើសិទ្ធិរបស់ ឌុច ដោយស្ថាប័នមួយផ្សេងទៀត គប្បីត្រូវទទួលបានការទូទាត់ពី អ.វ.ត.ក.[950]។

ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្តោតលើ ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាននាពេលនោះ ដែលកំណត់រយៈពេលឃុំខ្លួនបណ្តោះអាសន្នចំនួនបីឆ្នាំជាអតិបរមា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយកត់សម្គាល់ថា ឌុច ត្រូវបានឃុំខ្លួនតាមច្បាប់នេះ អស់រយៈពេលជិតប្រាំបីឆ្នាំ ដូច្នេះវាជាការឃុំខ្លួនខុសច្បាប់ រហូតដល់ពេលបញ្ជូនគាត់ទៅកាន់ អ.វ.ត.ក.[951]។ អង្គជំនុំជម្រះយល់ឃើញថា មិនមានការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងជាស៊ីជម្រៅនៅក្នុងរយៈពេលទាំងមូលនៃការឃុំខ្លួននេះទេ និងថា មិនមានសំអាងហេតុទូទៅបង្ហាញពីមូលដ្ឋាននៃការឃុំខ្លួនឯនានារបស់ ឌុច នោះឡើយ[952]។

ដោយយោងយុត្តិសាស្ត្រសាលាក្តី ICTR ក្នុងរឿងក្តី *Barayagwiza* និង *Rwamakuba* អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា រឿងក្តីទាំងអស់នេះបញ្ជាក់ថា បើទោះជាក្នុងករណីដែលការរំលោភបំពាននានាមិនអាចជាប់ពាក់ព័ន្ធនឹងតុលាការអន្តរជាតិ ឬមិនទុកថាជាការរំលោភលើដំណើរការនីតិវិធីក៏ដោយ "ក៏ជនជាប់ចោទអាចមានសិទ្ធិស្នើសុំការទូទាត់សំណងចំពោះការរំលោភលើសិទ្ធិរបស់គាត់ដោយសមត្ថកិច្ចជាតិបាន"។ យោងតាមច្បាប់យុត្តិសាស្ត្រនេះ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព "ជនជាប់ចោទមិនត្រឹមតែមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេល ដែលត្រូវបានជាប់ឃុំឃាំងប៉ុណ្ណោះទេ ថែមទាំងមានសិទ្ធទទួលបាននូវការកាត់បន្ថយទោសថែមទៀតផង ដោយសារតែការរំលោភលើសិទ្ធិរបស់ជនជាប់ចោទកាលពីមុន"[953]។

ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ថា មុនពេលអាចទទួលបានសំណង ទណ្ឌិតត្រូវតែអាចភ្ជាប់ការរំលោភសិទ្ធិរបស់ខ្លួនទៅនឹងស្ថាប័នណាមួយរបស់តុលាការ ឬត្រូវបង្ហាញថា យ៉ាងហោចណាស់ ការទទួលខុសត្រូវមួយចំនួនចំពោះការរំលោភបំពាន ជាប់ពាក់ព័ន្ធនឹងតុលាការនោះ។ ដោយសារតែការឃុំខ្លួនរបស់ ឌុច ដោយតុលាការយោធាកម្ពុជាមិនជាប់ពាក់ព័ន្ធទៅនឹង អ.វ.ត.ក. ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូងគប្បីបដិសេធសំណើសុំសំណងរបស់ ឌុច នេះ[954]។

## ៤.១១. សិទ្ធិប្តឹងឧទ្ធរណ៍

វិធាន ២១(១) នៃវិធានផ្ទៃក្នុងតម្រូវថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ"។ ជាញឹកញាប់ អង្គបុរេជំនុំជម្រះបានអនុវត្តវិធាន ២១ នៃវិធានផ្ទៃក្នុងដើម្បីពង្រីកសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ក្នុងករណីដែលស្ថានភាពដែលជាបញ្ហាចោទ មិនត្រូវបានប្រមើលទុកដោយវិធាន នៅពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ បានលើកឡើងពីបញ្ហានានាដែលមិនអាចត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះ និងនៅពេលដែលកាលៈទេសៈជាក់លាក់នៃរឿងក្តីតម្រូវឱ្យមានអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះ ដើម្បីជៀសវាងព្យសនកម្មដែលមិនអាចជួសជុលបានទៅលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ជនត្រូវចោទ[955]។

---

[950] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៩០។
[951] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ E39/5 កថាខណ្ឌ ១៩។
[952] ដូចខាងលើ កថាខណ្ឌ ២០។
[953] ដូចខាងលើ កថាខណ្ឌ ៣៥។
[954] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៩២-៣៩៦។ សម្រាប់ព័ត៌មានបន្ថែមអំពីការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយបញ្ជូនខ្លួន ឌុច ទៅជំនុំជម្រះក្នុង សំណុំរឿង ០០១ សូមមើលផ្នែក ៦.៦។
[955] ចំពោះព័ត៌មានបន្ថែមអំពីបទដ្ឋាននៃភាពអាចទទួលយកបានរបស់អង្គបុរេជំនុំជម្រះ សូមមើលផ្នែក ៥.៥.៣.៤។

### ៤.១២. សិទ្ធិក្នុងការជួយដល់ការការពាររបស់ខ្លួន សិទ្ធិក្នុងការមានវត្តមាននៅសវនាការ និងសិទ្ធិមានសម្បទាចូលរួមក្នុងការជំនុំជម្រះ

វិធាន ៨១ នៃវិធានផ្ទៃក្នុងផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន លើកលែងតែក្នុងករណីដែលជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់ ដោយយោងទៅលើហេតុផលសុខភាពធ្ងន់ធ្ងរ។ វិធាន ៣២ នៃវិធានផ្ទៃក្នុងក៏ផ្តល់ឱ្យអង្គជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតនូវឆន្ទានុសិទ្ធិក្នុងការបង្គាប់ឱ្យមានការត្រួតពិនិត្យដោយអ្នកជំនាញចិត្តសាស្ត្រ និងផ្នែកចិត្តវិទ្យា ដើម្បីកំណត់អំពីសម្បទាក្នុងការចូលរួមការជំនុំជម្រះរបស់ជនត្រូវចោទ ឬជនជាប់ចោទ។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានពិនិត្យសិទ្ធិទាំងអស់នេះនៅក្នុងបរិបទនៃសិទ្ធិក្នុងការទទួលបានការវាយតម្លៃផ្នែកចិត្តសាស្ត្រ ការវាយតម្លៃលើសម្បទាក្នុងការចូលរួមការជំនុំជម្រះ និងផលវិបាកនៃការរកឃើញថាមិនមានសម្បទាក្នុងការចូលរួមការជំនុំជម្រះ។

#### ៤.១២.១. សិទ្ធិទទួលបានការវាយតម្លៃផ្នែកចិត្តសាស្ត្រ

ជនត្រូវចោទមានសិទ្ធិទទួលបានការវាយតម្លៃដោយអ្នកជំនាញអំពីសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តសិទ្ធិនីតិវិធីរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ក្នុងអំឡុងពេលស៊ើបអង្កេត និងដំណាក់កាលបុរេជំនុំជម្រះ ប្រសិនបើសំណើរបស់ពួកគេមានយុត្តិកម្មសមស្រប[956]។ បញ្ហាទាក់ទងនឹងសមត្ថភាពរបស់ជនត្រូវចោទក្នុងការចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងកិច្ចដំណើរការនីតិវិធី កើតឡើងភ្លាមៗនៅពេលដែលត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋនៅចំពោះមុខ អ.វ.ត.ក.។ សមត្ថភាពរបស់ជនត្រូវចោទក្នុងការសហការជាមួយមេធាវីរបស់ខ្លួនក៏ពាក់ព័ន្ធពិសេសផងដែរ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេត នៃកិច្ចដំណើរការនីតិវិធី[957]។

ក្នុងការធ្វើការសម្រេចទាំងអស់នេះ អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០២ បានសង្កេតឃើញថា ឯកសារបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង និងច្បាប់កម្ពុជា មិនបានកំណត់ឱ្យបានច្បាស់លាស់ពីអត្ថន័យនៃឃ្លា "សម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ" ឬបញ្ជាក់ថានៅពេលណាដែលការវាយតម្លៃផ្នែកចិត្តសាស្ត្រអាចត្រូវបានស្នើឡើង ឬថាតើបញ្ហាសមត្ថភាពស្មារតីរបស់ជនត្រូវចោទអាចត្រូវបានលើកឡើង នៅដំណាក់កាលបុរេជំនុំជម្រះដែរ ឬយ៉ាងណា[958]។ ដោយងាកទៅប្រើវិធាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ តាមមាត្រា ១២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា អង្គបុរេជំនុំជម្រះបានផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Strugar* នៃតុលាការ ICTY ក្នុងការកត់សម្គាល់ថា ជនត្រូវចោទទទួលបានសិទ្ធិនីតិវិធីតាំងពីចាប់ផ្តើមកិច្ចស៊ើបសួរ នៅចំពោះមុខ អ.វ.ត.ក. និងក្នុងការការពារខ្លួនឯងផ្ទាល់ ដែលការទទួលបានសិទ្ធិនេះតម្រូវឱ្យជនត្រូវចោទមានសមត្ថភាពខាងផ្លូវកាយ និងផ្លូវចិត្ត[959]។

#### ៤.១២.២. ការវាយតម្លៃលើសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ

បទដ្ឋានក្នុងការកំណត់សម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះគឺ "ការចូលរួមប្រកបដោយអត្ថន័យ"៖ ពោលគឺ ថាតើជនជាប់ចោទប្រើប្រាស់សិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ខ្លួន ក្នុងកម្រិតមួយដែលអនុញ្ញាតឱ្យពួកគេចូលរួមប្រកបដោយអត្ថន័យ និងយ៉ាងមានប្រសិទ្ធភាពនៅក្នុងការជំនុំជម្រះក្តីរបស់ពួកគេ និងយល់ដឹងពីទិដ្ឋភាពសំខាន់ៗនៃកិច្ចដំណើរការនីតិវិធីដែរ ឬយ៉ាងណា[960]។ អង្គជំនុំជម្រះសាលា

[956] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ A189/I/8 កថាខណ្ឌ ៣៥។

[957] ដូចខាងលើ កថាខណ្ឌ ៣៤។

[958] ដូចខាងលើ កថាខណ្ឌ ២៨។

[959] ដូចខាងលើ កថាខណ្ឌ ២៨-៣៤។

[960] សូមមើលសំណុំរឿង ០០២ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១១ E138 កថាខណ្ឌ ២៧។ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌដោយពុំបានធ្វើការពិនិត្យឡើងវិញ ឬបានច្រានចោលលក្ខខណៈវិនិច្ឆ័យគតិយុត្តិរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការធ្វើការវាយតម្លៃសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ។ សូមមើលសំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះ

ដំបូងត្រូវពិចារណាលើសម្ភារៈ និងកត្តាពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងការសង្កេតរបស់ខ្លួនផ្ទាល់ ក្នុងករណីដែលសមស្រប[961]។ លទ្ធភាពអាចរកបាននៃវង្វាយតម្លៃជាក់ស្តែង ដែលសម្រាប់ផលប៉ះពាល់អវិជ្ជមាននៃការខូចខាតណាមួយនោះ ក៏ត្រូវពិចារណាផងដែរ[962]។

ក្នុងការកំណត់បទដ្ឋានសម្រាប់ការកំណត់លើសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY ក្នុងរឿងក្តី *Strugar* ដែលថា សម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះគឺត្រូវបានវាយតម្លៃ លើសមត្ថភាពរបស់ជនជាប់ចោទ "គឺត្រូវពិនិត្យមើលជារួមពីអាកប្បកិរិយាទូទៅ និងក្នុងលក្ខណៈសមហេតុផល" ពោលគឺស្ថិតនៅកម្រិតមួយដើលអាចឱ្យជនជាប់ចោទ អាចចូលរួមក្នុងដំណើរការនីតិវិធី និងអនុវត្តសិទ្ធិដែលបានកំណត់ក្នុងការ៖ (១) ឆ្លើយតបទៅនឹងបទចោទ (២) យល់ដឹងអំពីលក្ខណៈនៃការចោទប្រកាន់ (៣) យល់ដឹងអំពីសេចក្តីពិស្តារនៃភស្តុតាង (៤)ណែនាំមេធាវីការពារក្តីរបស់ខ្លួន (៥) យល់ដឹងពីផលវិបាកនៃដំណើរការនីតិវិធី និង (៦) ធ្វើសក្ខីកម្ម[963]។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុងរឿងក្តី *Strugar* បានសង្កត់ធ្ងន់ថា ជនជាប់ចោទដែលតំណាងដោយមេធាវី មិនអាចត្រូវបានរំពឹងថាដឹងអំពីសម្ភារៈនៃសំណុំរឿង ដូចមេធាវីដែលមានបទពិសោធន៍ និងមានសមត្ថភាពនោះទេ និងថា សូម្បីតែបុគ្គលដែលមានសុខភាពល្អ ក៏ទាមទារឱ្យមានជំនួយផ្នែកច្បាប់ច្រើនផងដែរ ជាពិសេសនៅចំពោះមុខសាលាក្តីអន្តរជាតិ។ អង្គជំនុំជម្រះបានផ្តល់ហេតុផលបន្ថែមទៀតថា ទោះបីជាការមានមេធាវីអាចបំពេញបន្ថែមភាពខ្វះខាតជាក់លាក់យ៉ាងណាក្តី ក៏ការប្រើប្រាស់មេធាវីតម្រូវថា ជនជាប់ចោទមានសមត្ថភាពគ្រប់គ្រាន់ក្នុងការ*ណែនាំ*មេធាវីការពារក្តីរបស់ខ្លួន[964]។

ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា អៀង ធីរិទ្ធ មានជំងឺមួយដែលចេះតែវិវឌ្ឍទៅមុខ និងធ្លាក់ចុះដុនដាបជាលំដាប់ ហើយផ្អែកលើយោបល់ជាឯកច្ឆន្ទថា ស្ថានភាពរបស់គាត់ទំនងជាបន្តចុះខ្សោយជាលំដាប់ក្នុងអំឡុងពេលជំនុំជម្រះនោះ អង្គជំនុំជម្រះសម្រេចថាដើម្បីផលប្រយោជន៍យុត្តិធម៌ ត្រូវបំបែកបទចោទប្រកាន់ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំង អៀង ធីរិទ្ធ[965]។ បើទោះជាការព្រមព្រៀងជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះខកខានក្នុងការចេញសេចក្តីសម្រេចមួយដោយសំឡេងភាគច្រើនលើបញ្ហាថាតើ អង្គជំនុំជម្រះគប្បីបង្គាប់ឱ្យ អៀង ធីរិទ្ធ ស្វែងរកការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬថាតើគាត់គួរតែត្រូវបានដោះលែងដោយឥតលក្ខខណ្ឌ ឬយ៉ាងណា។ ដោយពិចារណាលើករណីខ្វែងយោបល់គ្នារវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ នៃអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យដោះលែងគាត់ចេញពីមន្ទីរឃុំឃាំង អ.វ.ត.ក.[966]។ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌដោយពុំបានធ្វើការពិនិត្យឡើងវិញ ឬបានច្រានចោលលក្ខណៈវិនិច្ឆ័យគតិយុត្តិរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការធ្វើការវាយតម្លៃសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ[967]។

---

លែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ E138/1/7។ សូមមើលសំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ E238/9 កថាខណ្ឌ ១៨។

[961] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១២ E238/9 កថាខណ្ឌ ១៨។

[962] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ E138/1/7 កថាខណ្ឌ ២៩ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ E238/9 កថាខណ្ឌ ១៨។

[963] សំណុំរឿង ០០២ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ E138 កថាខណ្ឌ ២៦-២៧។

[964] ដូចខាងលើ កថាខណ្ឌ ២៨។

[965] ដូចខាងលើ។

[966] ដូចខាងលើ ផ្នែកសម្រេចសេចក្តី។

[967] សូមមើលសំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ E138/1/7។

ក្នុងករណីដាច់ដោយឡែកមួយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់គាំទ្រសំអាងហេតុរបស់ខ្លួនថា អៀង សារី មានសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ និងថា អៀង សារី មិនអាចត្រូវបានបង្គាប់ឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈមធ្យោបាយសោតទស្សន៍ ពីបន្ទប់ឃុំខ្លួនខាងក្រោយសាលសវនាការរបស់គាត់ឡើយ ហើយបានផ្តល់ការកត់សម្គាល់ថា អង្គជំនុំជម្រះនឹងបង្គាប់ដូច្នោះ ក្នុងករណីដែល អៀង សារី "ត្រូវបានយល់ឃើញថា មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ប៉ុន្តែនៅពេលដែលវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ អាចនឹងផ្ទុយពីស្ថានភាពផ្នែកវេជ្ជសាស្ត្ររបស់គាត់ និង/ឬ ផ្ទុយពីការប្រព្រឹត្តិទៅឱ្យបានឆាប់រហ័សនៃការជំនុំជម្រះនោះ"[968]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំជាបន្តបន្ទាប់ពី សំណាក់មេធាវីការពារក្តី អៀង សារី ឱ្យធ្វើការថតខ្សែអាត់សំឡេង និង/ឬវីដេអូ អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោយសាលសវនាការ ដោយយល់ឃើញថា ពុំមែនជាសិទ្ធិមួយដែលត្រូវបានធានាដោយ ICCPR ឱ្យធ្វើដូច្នោះនោះឡើយ។ អង្គជំនុំជម្រះបានពិចារណាឃើញទៀតថា ការសម្រេចនេះមិនបានបដិសេធមិនឱ្យ អៀង សារី មានកំណត់ហេតុគ្រប់គ្រាន់ អំពីថាតើគាត់មាន ឬពុំមានសម្បទាក្នុងការចូលរួមសវនាការនោះឡើយ ដោយសារគាត់ត្រូវបានវាយតម្លៃដោយអ្នកជំនាញ ដែលត្រូវបានតែងតាំងដោយតុលាការថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបាន និងត្រូវបានវាយតម្លៃជាទៀងទាត់ដោយគ្រូពេទ្យដែលផ្តល់នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរជូនដល់អង្គជំនុំជម្រះសាលាដំបូង ជារៀងរាល់ថ្ងៃ[969]។

## ៤.១២.៣. ផលវិបាកនៃការរកឃើញថាពុំមានសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ

បន្ទាប់ពីរកឃើញថាពុំមានសម្បទា វិធានការដោះស្រាយត្រូវតែធ្វើឡើងដោយផ្អែកលើលទ្ធភាពដែលអាចមាន ទោះបីតិចតួចក៏ដោយ ក្នុងការធ្វើឱ្យមានភាពប្រសើរឡើងដោយពិតប្រាកដនោះ ដោយពិចារណាលើអត្ថប្រយោជន៍នៃយុត្តិធម៌ក្នុងការជំនុំជម្រះក្តីជនជាប់ចោទ[970]។ មុនពេលដោះលែងជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវតែវាយតម្លៃលើវិធានការសន្តិសុខ យោងតាមកាលៈទេសៈជាក់លាក់នៃរឿងក្តី និងនៅក្នុងក្របខ័ណ្ឌច្បាប់ជាធរមាន ដោយវាយតម្លៃយ៉ាងប្រុងប្រយ័ត្នលើរាល់ផលប្រយោជន៍ទាំងអស់ដែលពាក់ព័ន្ធ និងផ្តល់នូវការថ្លឹងថ្លែងសមស្របចំពោះកត្តាពាក់ព័ន្ធទាំងអស់[971]។ អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវតែប្រុងប្រយ័ត្នផងដែរថា ការបន្តឃុំខ្លួនណាមួយមិនត្រូវធ្វើឡើងក្នុងរយៈពេលវែងមិនសមហេតុផល ដែលរំលោភសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនោះទេ[972]។

ក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសម្រេចឱ្យផ្អាកដំណើរការព្រហ្មទណ្ឌ និងឱ្យដោះលែង អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ដោយសារពុំមានសម្បទាក្នុងការចូលរួមការជំនុំជម្រះនោះ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ការដោះលែងដោយឥតលក្ខខណ្ឌគឺពុំស្របគ្នានឹងផលប្រយោជន៍នៃយុត្តិធម៌ឡើយ និងមិនត្រូវបានគាំទ្រដោយការអនុវត្តនៅកម្រិតជាតិ និងអន្តរជាតិនោះទេ[973]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិបាន "ខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីធានាថា ត្រូវធ្វើឱ្យអស់ពីលទ្ធភាពដើម្បីកាត់សេចក្តីលើជនជាប់ចោទ" និងថា នៅតុលាការ ICTY វិធានការដែលធានាវត្តមានរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ ត្រូវបានអនុវត្ត ដោយមិនគិតពីបញ្ហាសុខភាពទ្រុឌទ្រោមរបស់ពួកគេឡើយ[974]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានយោងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC ក្នុងរឿងក្តី *Lubanga* ផងដែរ ក្នុងការសន្និដ្ឋានថា យុត្តិសាស្ត្រអន្តរជាតិបញ្ជាក់ថា ការដោះលែងដោយឥតលក្ខខណ្ឌ មិនមែនជាជម្រើសដែល

---

[968] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើសុំថតខ្សែអាត់សំឡេង និង/ឬ វីដេអូ នៅពេល អៀង សារី ស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ E254/3 កថាខណ្ឌ ២។

[969] ដូចខាងលើ កថាខណ្ឌ ១៤។

[970] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ E138/1/7 កថាខណ្ឌ ២៩។

[971] ដូចខាងលើ កថាខណ្ឌ ៣០។

[972] ដូចខាងលើ។

[973] ដូចខាងលើ កថាខណ្ឌ ២៨-៣០។

[974] ដូចខាងលើ កថាខណ្ឌ ១៩-២០។

មានតែមួយគត់របស់ខ្លួននោះឡើយ ក្នុងករណីដែលខ្លួនបានផ្អាក ឬពន្យារកិច្ចដំណើរការនីតិវិធី ដោយសារឧបសគ្គមួយដែលអាចដោះស្រាយបាននាពេលខាងមុខ[975]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ចំពោះករណី អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូងគប្បីបានវាយតម្លៃលើវិធានការសន្តិសុខ យោងតាមកាលៈទេសៈជាក់លាក់នៃរឿងក្តី ហើយមុនពេលដោះលែងគាត់ គួរតែបានធ្វើការវាយតម្លៃយ៉ាងប្រុងប្រយ័ត្ននូវរាល់ផលប្រយោជន៍ទាំងអស់ដែលពាក់ព័ន្ធ និងផ្តល់នូវការថ្លឹងថ្លែងសមស្របលើកត្តាពាក់ព័ន្ធទាំងអស់[976]។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូង រៀបចំឱ្យមានការព្យាបាលបន្ថែមទៀត និងត្រួតពិនិត្យស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ ឡើងវិញ និងត្រូវឃុំខ្លួនគាត់នៅក្នុងមន្ទីរពេទ្យ ឬនៅទីកន្លែងដ៏សមស្របណាផ្សេងទៀត ដូចដែលអង្គជំនុំជម្រះសាលាដំបូងកំណត់[977]។

### ៤.១៣. សិទ្ធិទទួលបានការសួរសុខទុក្ខ

វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានចែងច្បាស់លាស់សម្រាប់សិទ្ធិសួរសុខទុក្ខទេ។ ទោះបីជាវិធាន ៥៥ នៃវិធានផ្ទៃក្នុងផ្តល់យុត្តាធិការឱ្យសហចៅក្រមស៊ើបអង្កេត កំហិតការទាក់ទងរវាងអ្នកជាប់ឃុំ ដោយផ្អែកលើផលប្រយោជន៍នៃការស៊ើបអង្កេតនោះ ការដាក់កំហិតលើការទំនាក់ទំនងអាច ត្រូវបានដាក់កម្រិតក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ដើម្បីការពារការដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ តែប៉ុណ្ណោះ។[978]។ ដោយពុំមានការចែងផ្លូវច្បាប់ណាផ្សេងទៀត សហចៅក្រមស៊ើបអង្កេតមិនមានអំណាចលើលក្ខខណ្ឌនានានៅ មន្ទីរឃុំឃាំង អ.វ.ត.ក. ដែលនៅតែស្ថិតក្រោមសិទ្ធិអំណាចរបស់ប្រធានមន្ទីរឃុំឃាំង[979] *ពោលគឺ* ស្ថិតក្រោមអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ។

នៅក្នុងការបដិសេធដីកាសម្រេចលើលក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្ន ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានយោងយុត្តិសាស្ត្រតុលាការ ICC នឹង ECtHR ក្នុងការសន្និដ្ឋានថា ការដាក់កម្រិតលើការទំនាក់ទំនងអាច “ត្រូវបានដាក់កម្រិត ដើម្បីការពារការដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះនៅពេលដែលមានភស្តុតាងសមរម្យ ដែលអាចបង្ហាញថា ពិតជាមានហានិភ័យដែលថា ជនត្រូវចោទអាចត្រូវរួតគ្នាជាមួយជនត្រូវចោទដទៃទៀត ដើម្បីដាក់សម្ពាធបែបនេះ ខណៈពេលខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួន”[980]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា “នៅក្នុងរឿងក្តីទាំងប្រាំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលសហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន គ្មានការលើកឡើងថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ក្នុងការរារាំងការត្រូវរួតគ្នារវាងជនជាប់ចោទឡើយ”[981]។ អង្គជំនុំជម្រះក៏បានផ្តល់ហេតុផលផងដែរថា មន្ទីរឃុំឃាំង អ.វ.ត.ក. ស្ថិតក្រោមយុត្តាធិការរបស់អាជ្ញាធរពន្ធនាគារជាតិ និងស្ថិតក្រោមច្បាប់កម្ពុជា[982]។

ក្នុងការសម្រេចថា អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានអនុញ្ញាតឱ្យជួបស្របតាមវិធានស្តីពីការឃុំខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលរារាំង

---

[975] ដូចខាងលើ កថាខណ្ឌ ២៥។

[976] ដូចខាងលើ កថាខណ្ឌ ៣០។

[977] ដូចខាងលើ កថាខណ្ឌ ៤២-៤៣ និង ៤៩ ផ្នែកសម្រេចសេចក្តី។

[978] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ C33/I/7 កថាខណ្ឌ ២៨-២១។ សូមមើលសំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ A104/II/7 កថាខណ្ឌ ១៤-២០។

[979] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ C33/I/7 កថាខណ្ឌ ២៨ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ A104/II/7 កថាខណ្ឌ ១០-១៤-២១។

[980] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ C33/I/7 កថាខណ្ឌ ២៨-២១។ សូមមើលសំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ A104/II/7 កថាខណ្ឌ ១៤-២០។

[981] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ C33/I/7 កថាខណ្ឌ ២៣។

[982] ដូចខាងលើ កថាខណ្ឌ ២៦។

ពួកគេពីការធ្វើដូច្នោះ មិនមានសំអាងហេតុគ្រប់គ្រាន់ ដោយខកខានក្នុងការពន្យល់ថាតើការដាក់កម្រិតលើការទំនាក់ទំនងមានភាពចាំបាច់ និងសមាមាត្រដោយរបៀបណា ក្នុងការការពារផលប្រយោជន៍ការស៊ើបអង្កេត[983]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា អៀង សារី និង អៀង ធីរិទ្ធ បានរៀបការជាប្ដីប្រពន្ធអស់រយៈពេល ៥៧ ឆ្នាំហើយ បទឧក្រិដ្ឋដែលបានចោទប្រកាន់បានប្រព្រឹត្តឡើងកាលពី ៣០ មុន ហេតុដូច្នេះជនត្រូវចោទមាន "ពេលពិភាក្សាអំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ក្នុងរយៈពេលនេះ"[984]។

## ៤.១៤. សិទ្ធិអំណាចក្នុងការបង្គាប់ឱ្យផ្អាកកិច្ចដំណើរការនីតិវិធី នៅពេលដែលការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌មិនអាចធ្វើទៅបាន

ទោះបីជាកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុងមិនមានចែងអំពី "ការផ្អាកកិច្ចដំណើរការនីតិវិធី" ក៏នីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្ដល់អំណាចឱ្យ "ព្យួរ" ឬ "ផ្អាក" កិច្ចដំណើរការនីតិវិធីក្នុងកាលៈទេសៈមួយចំនួន ដែលជាឧបសគ្គដល់ការបន្តកិច្ចដំណើរការនីតិវិធី[985]។ ទោះជាយ៉ាងណា ការដោះលែងដោយឥតលក្ខខណ្ឌពុំមែនជាជម្រើសតែមួយគត់ដែល អ.វ.ត.ក. ផ្អាក ឬ ព្យួរ កិច្ចដំណើរការនីតិវិធី ដោយសារតែឧបសគ្គដែលអាចត្រូវបានដោះស្រាយនៅពេលខាងមុខនោះឡើយ[986]។ ក្នុងករណីដែលអង្គជំនុំជម្រះបានសម្រេចចិត្តផ្អាកកិច្ចដំណើរការនីតិវិធី ហើយឧបសគ្គនោះមានលក្ខខណ្ឌ និងអាចបដិសេធចោលបាននោះ អ.វ.ត.ក. នៅមានយុត្តាធិការលើជនជាប់ចោទ[987]។

ក្នុងការធ្វើសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយពាក្យ "ការផ្អាក" សំដៅដល់ "ការពន្យារ ឬការព្យួរកិច្ចដំណើរការនីតិវិធី សាលក្រម ដែលមានលក្ខណៈប្រហាក់ប្រហែល" ឬសំដៅដល់ "ការបង្គាប់ឱ្យបង្អង់ទាំងស្រុង ឬផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីតុលាការ ឬសាលក្រមដែលចេញមកពីកិច្ចដំណើរការនីតិវិធីនោះ" ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុថា នៅពេលដែលការផ្អាកកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុញ្ញាត ការផ្អាកនេះមានមុខងារជាចម្លើយតបទៅនឹងឧបសគ្គរយៈពេលយូរចំពោះការបន្តកិច្ចដំណើរការនីតិវិធី និងថា ប្រសិនបើឧបសគ្គនោះមិនត្រូវបានដោះស្រាយទេនោះ ស្ថានភាពនៃការផ្អាកនេះអាចត្រូវបានដកចេញវិញតាមរយៈការបញ្ចប់កិច្ចដំណើរការនីតិវិធី បន្ទាប់ពីមរណភាពរបស់ជនជាប់ចោទ ឬការផុតអាជ្ញាយុកាល ឬនៅពេលដែលប្រព័ន្ធច្បាប់អនុញ្ញាតឱ្យធ្វើដូច្នោះ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុបន្ថែមទៀតថា ការផ្អាកមិនរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ដែលមានគោលបំណងដោះស្រាយឧបសគ្គនោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ថាបញ្ហានេះ គឺជាកាតព្វកិច្ចរបស់អាជ្ញាធរក្នុងការអនុវត្តយុត្តាធិការរឿងក្ដី "ផ្អែកលើតួនាទីក្នុងការចោទប្រកាន់ ការសន្មតទុកជាមុនថាគ្មានទោស ភាពយុត្តិធម៌ ទាក់ទងនឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្ដីនៅក្នុងពេលវេលាសមស្រប និងការសន្សំសំចៃការចំណាយលើកិច្ចដំណើរការនីតិវិធី" [988]។

អង្គជំនុំជម្រះតុលាការកំពូលក៏សម្រេចទៀតថា វាពុំជាប់ពាក់ព័ន្ធ និងពុំសមស្របសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការពឹងផ្អែកលើស្ថានភាពហិរញ្ញវត្ថុរបស់ អ.វ.ត.ក. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនក្នុងការបំបែកបទចោទប្រកាន់ក្នុងសំណុំរឿង ០០២[989]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុថា "ចៅក្រម នៅគ្រប់ពេលទាំងអស់ ជាក់ច្បាស់ណាស់ ត្រូវមានកាតព្វកិច្ចពិចារណាលើប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ដូច្នេះ ចៅក្រមជានិច្ចកាលត្រូវអនុវត្តទៅតាមវិសាលភាពនៃច្បាប់ ដែលជាគោលការណ៍

---

[983] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ A104/II/7 កថាខណ្ឌ ១៨។
[984] ដូចខាងលើ កថាខណ្ឌ ១៩។
[985] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ E138/1/7 កថាខណ្ឌ ១៧-១៨។
[986] ដូចខាងលើ កថាខណ្ឌ ២៥។
[987] ដូចខាងលើ កថាខណ្ឌ ២៤។
[988] ដូចខាងលើ កថាខណ្ឌ ១៨។
[989] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ E284/4/8 កថាខណ្ឌ ៤៥-៤៩-៧៥។

ដែលមានលក្ខណៈសំខាន់ជាងការសន្សំសំចៃផ្នែកថវិកា”[990]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្រៅពីការកំណត់ទ្រង់ទ្រាយយុត្តាធិការលើរឿងក្តី សេចក្តីសម្រេចរបស់អយ្យការដែលជំរុញឡើងដោយប្រសិទ្ធភាព លើរឿងក្តីដែលត្រូវចោទប្រកាន់ និង សេចក្តីសម្រេចដែលជំរុញឡើងដោយប្រសិទ្ធភាពទៅលើការដកចេញបទចោទប្រកាន់នោះ “ចៅក្រមជំនុំជម្រះមិនអាចកែប្រែការយល់ឃើញរបស់ខ្លួនអំពីបញ្ហាដែលពុំទាន់បានសម្រេច ទៅតាមការសន្សំសំចៃថវិកាឡើយ”។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា “ប្រសិនបើពុំមានថវិកាគ្រប់គ្រាន់ ក្នុងការធានាការជំនុំជម្រះដែលច្បាប់បានតម្រូវនោះទេ រាល់កិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក. ត្រូវតែបញ្ចប់ ហើយតុលាការត្រូវបិទទ្វារ”[991]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ ដោយពិចារណាថា ថវិការបស់ អ.វ.ត.ក. បានឈានដល់ចំណុច “វិបត្តិ” និងថាទស្សនៈឆ្ពោះទៅមុខប្រែជាមិនស្របទៅនឹងគោលការណ៍ជាមូលដ្ឋាននៃការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ នីតិរដ្ឋ និងឯករាជ្យភាពតុលាការ សហចៅក្រមស៊ើបអង្កេតបានប្រមើលទុកការចេញដីកាផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុង[992]។ ដូច្នេះ ពួកគេបានស្នើសុំភាគី និងការិយាល័យរដ្ឋបាលឱ្យដាក់សារណា ស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និងផលប៉ះពាល់របស់វាលើសំណុំរឿង ០០៤/០២, ០០៣ និង ០០៤។ បន្ទាប់ពីបានធ្វើការពិនិត្យយ៉ាងទូលំទូលាយលើច្បាប់ជាតិ និងអន្តរជាតិរួចមក ពួកគេបានសន្និដ្ឋានថា ខ្លួនមានអំណាចបញ្ឈប់ការស៊ើបអង្កេតទាំងអស់ ដោយសារតែការរំលោភជាសារវន្តលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌[993]។ ទោះជាយ៉ាងណា ក្រុមម្ចាស់ជំនួយសំខាន់ៗបានផ្តល់ការធានាចំពោះ “ការប្តេជ្ញាចិត្តយ៉ាងមុតមាំ” ហើយការផ្គត់ផ្គង់ថវិការបស់ អ.វ.ត.ក. មានការកើនឡើងយ៉ាងឆាប់រហ័ស។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបានពន្យារពេលចេញដីកាផ្អាកកិច្ចដំណើរការនីតិវិធី ប៉ុន្តែ “នៅតែពិនិត្យបញ្ហានេះយ៉ាងសកម្ម រហូតដល់ពេល[បាន]ចេញដីកាដំណោះស្រាយចុងក្រោយ”[994]។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតមិនបានបង្គាប់ឱ្យផ្អាកកិច្ចដំណើរការនីតិវិធីទេ ផ្ទុយទៅវិញបានបន្តចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងរឿងក្តីនីមួយៗ[995]។

---

990 ដូចខាងលើ កថាខណ្ឌ ៧៥។
991 ដូចខាងលើ ៧៥។
992 សំណុំរឿង ០០៣, សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ D349 កថាខណ្ឌ ៧៥-៨២។
993 សំណុំរឿង ០០៣, សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/០២ ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ D349/6 កថាខណ្ឌ ៦៩។ សំណុំរឿង ០០៣, សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និងផលប៉ះពាល់មកលើសំណុំរឿង ០០៣, សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ D349 កថាខណ្ឌ ៧៥-៨៧។
994 សំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/០២ ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ D349/6 កថាខណ្ឌ ៦៩។
995 សម្រាប់ព័ត៌មានបន្ថែមស្តីពីសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ ដីកាដំណោះស្រាយ និងការបញ្ចប់រឿងក្តីទាំងអស់នេះ សូមមើល សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១) ផ្នែក ៥.៣។ ច្បាប់ អ.វ.ត.ក. មាត្រា ១៦។ សូមមើលផងដែរ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា។

## ៥. នីតិវិធី

វិធានផ្ទៃក្នុងបានចែងយ៉ាងច្រើនអំពីរចនាសម្ព័ន្ធនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. ដោយចងក្រងនីតិវិធីកម្ពុជា និងការសម្របវាទៅក្នុងលក្ខណៈអន្តរជាតិរបស់ អ.វ.ត.ក. ដោយបានអនុម័តយកវិធានបន្ថែមទៀត ក្នុងករណីដែលនីតិវិធីដែលមានស្រាប់មិនមានលក្ខណៈគ្រប់គ្រាន់។ វិធានផ្ទៃក្នុងក៏បានដាក់បញ្ចូលបទប្បញ្ញត្តិទូទៅ ដែលដោះស្រាយបញ្ហានានាដូចជា ការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី វិធានៃការការពារដែលអាចអនុវត្តលើសាក្សីដែលចូលរួម ការបញ្ចូលភ័ស្តុតាងអ្នកជំនាញ របបអនុវត្តចំពោះ *អ្នកមិនមែនជាភាគីនៃរឿងក្តី* និងអន្តរាគមន៍ផ្សេងៗទៀត ក៏ដូចជានីតិវិធីសម្រាប់ការដាក់ឯកសារពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី។

### ៥.១. លក្ខណៈទូទៅ

#### ៥.១.១. រចនាសម្ព័ន្ធនៃកិច្ចដំណើរការនីតិវិធី

យោងតាមមាត្រា ១៦ នៃច្បាប់ អ.វ.ត.ក. សហព្រះរាជអាជ្ញា (កម្ពុជាម្នាក់ បរទេសម្នាក់) "ធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ"[996]។ ប្រសិនបើសហព្រះរាជអាជ្ញាមានមូលហេតុជឿជាក់ថា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានប្រព្រឹត្តឡើង សហព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេត តាមរយៈការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅកាន់សហចៅក្រមស៊ើបអង្កេត[997]។ ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាទាំងពីរនាក់ ឬម្នាក់ក្នុងចំណោមអ្នកទាំងពីរអាចដាក់អង្គហេតុ និងសំអាងហេតុគាំទ្រការខ្វែងយោបល់របស់ពួកគេទៅកាន់អង្គបុរេជំនុំជម្រះឱ្យធ្វើការវិនិច្ឆ័យ[998]។ សហព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[999] និងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[1000]។ សេចក្តីសម្រេចទាំងឡាយរបស់សហព្រះរាជអាជ្ញា បិទផ្លូវប្តឹងតវ៉ា[1001]។

ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជាការិយាល័យឯករាជ្យ[1002]។ យោងតាមមាត្រា ២៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេត (ម្នាក់ជាកម្ពុជា ម្នាក់ជាបរទេស) ទទួលខុសត្រូវចំពោះការស៊ើបអង្កេត និងមានអំណាចសួរចម្លើយជនសង្ស័យ និងស្តាប់ចម្លើយជនរងគ្រោះ ស្តាប់សក្ខីកម្មសាក្សី និងប្រមូលភ័ស្តុតាង[1003]។ ពួកគេក៏ធ្វើសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងការស៊ើបអង្កេតផងដែរ[1004]។ លើកលែងតែកិច្ចណាដែលត្រូវបំពេញរួមគ្នាតាមច្បាប់ អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ចទៅឱ្យសហចៅក្រមស៊ើបអង្កេត ណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ (តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ) ឬ ទៅឱ្យអ្នកស៊ើបអង្កេតរបស់ខ្លួន (តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស)[1005]។

សហចៅក្រមស៊ើបអង្កេតមានអំណាចចោទប្រកាន់ជនសង្ស័យណាក៏ដោយ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1006]។ នៅពេលបិទបញ្ចប់ការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត

---

[996] ច្បាប់ អ.វ.ត.ក. មាត្រា ១៦ សូមមើល កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៦។
[997] ច្បាប់ អ.វ.ត.ក. មាត្រា ១៦។ វិធានផ្ទៃក្នុង វិធាន ៥៣(១)។
[998] ច្បាប់ អ.វ.ត.ក. មាត្រា ២០ ថ្មី។ សូមមើល វិធានផ្ទៃក្នុង វធាន ១៣(៥) និងវិធាន ៧១។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៦ (៤) និងមាត្រា ៧។
[999] វិធានផ្ទៃក្នុង វិធាន ៧៤(២)។
[1000] ច្បាប់ អ.វ.ត.ក. មាត្រា ១៧ ថ្មី។
[1001] វិធានផ្ទៃក្នុង វិធាន ១៣(៦)។
[1002] វិធានផ្ទៃក្នុង វិធាន ១៤(១)។ កិច្ចព្រមព្រៀងរវាង អ..ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៥(៣)។
[1003] ច្បាប់ អ.វ.ត.ក. មាត្រា ២៣ ថ្មី។ សូមមើល កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៥(១)។
[1004] វិធានផ្ទៃក្នុង ២៣ *ស្ទួន*។
[1005] វិធានផ្ទៃក្នុង វិធាន ១៤(៤) និង(៥)។
[1006] វិធានផ្ទៃក្នុង វិធាន ៥៥(៤)។

ចេញដីកាដំណោះស្រាយ ដែលអាចជាដីកាចោទប្រកាន់ជងសង្ស័យ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ឬជាដីកាសម្រេចលើកលែងចោទប្រកាន់[1007]។

អនុលោមតាមមាត្រា២០(ថ្មី) និង ២៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. អង្គបុរេជំនុំជម្រះមានយុត្តាធិការដោះស្រាយករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត (ប្រសិនបើពួកគេជ្រើសរើសបញ្ជូនករណីខ្វែងយោបល់របស់ខ្លួន ទៅអង្គបុរេជំនុំជម្រះ)[1008]។ អង្គបុរេជំនុំជម្រះក៏មានយុត្តាធិការដោះស្រាយបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេច និងដីការបស់សហចៅក្រមស៊ើបអង្កេត លើមូលដ្ឋានមានកម្រិតមួយចំនួន និងដោះស្រាយពាក្យសុំមោឃភាពកិច្ចស៊ើបសួរ[1009]។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់ចំនួនបួនរូប[1010]។

អង្គជំនុំជម្រះសាលាដំបូងមានសមាសភាពចៅក្រមចំនួនប្រាំរូប ក្នុងចំណោមនោះចៅក្រមកម្ពុជាបីរូប (រួមទាំងម្នាក់ជាប្រធាន) និងចៅក្រមបរទេសពីររូប[1011]។ នៅពេលទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងជំនុំជម្រះក្ដី និងសម្រេចថាតើ មានភ័ស្ដុតាងបញ្ជាក់ពិរុទ្ធភាពរបស់ជនជាប់ចោទហួសពីវិមតិសង្ស័យ ឬទេ[1012]។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងក៏តម្រូវឱ្យមានការឯកភាពគ្នាជាឯកច្ឆន្ទនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនផងដែរ[1013]។ ប្រសិនបើការឯកភាពជាឯកច្ឆន្ទមិនអាចធ្វើទៅបានទេ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់បួនរូប[1014]។ ក្នុងករណីដែលមិនមានការឯកភាពគ្នាជាឯកច្ឆន្ទ សេចក្ដីសម្រេចតុលាការនឹងមានយោបល់របស់ចៅក្រមភាគច្រើន និងភាគតិច[1015]។

អង្គជំនុំជម្រះតុលាការកំពូល ដែលដើរតួជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និងសាលាកំពូល មានសមាសភាពចៅក្រមចំនួនប្រាំពីររូប។ ក្នុងចំណោមចៅក្រមទាំងនេះ មានចៅក្រមកម្ពុជាបួនរូប (ម្នាក់ជាប្រធាន) និងចៅក្រមបរទេសបីរូប[1016]។ សេចក្ដីសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលតម្រូវឱ្យមានការឯកភាពជាឯកច្ឆន្ទ ឬសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់ចំនួនប្រាំរូប[1017]។ អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើមូលដ្ឋាននៃកំហុសអង្គច្បាប់ ដែលធ្វើឱ្យអសុពលភាពសាលក្រម ឬសេចក្ដីសម្រេច ឬលើមូលដ្ឋាននៃកំហុសអង្គហេតុ ដែលបណ្ដាលឱ្យមានភាពអយុត្តិធម៌[1018]។ អង្គជំនុំជម្រះតុលាការកំពូលអាចតម្កល់ទុកជាមោឃៈ ឬកែប្រែសេចក្ដីសម្រេចទាំងស្រុង ឬដោយផ្នែក[1019]។ បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម

---

1007 វិធានផ្ទៃក្នុង វិធាន ៦៧(១)។

1008 ច្បាប់ អ.វ.ត.ក. មាត្រា ២០ (ថ្មី) និង ២៣ (ថ្មី)។ សូមមើល កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៥(៤) និងមាត្រា ៦(៤) និងមាត្រា ៧។ វិធានផ្ទៃក្នុង វិធាន ១៤(៧) និងវិធាន ៧២។

1009 វិធានផ្ទៃក្នុង វិធាន៧៣ វិធាន៧៤ និងវិធាន៧៦។

1010 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៧(៤)។

1011 ច្បាប់ អ.វ.ត.ក. មាត្រា ៩ (ថ្មី)។

1012 វិធានផ្ទៃក្នុង វិធាន ៨៧(១)។

1013 ច្បាប់ អ.វ.ត.ក. មាត្រា ១៤(១) (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៤(១)។

1014 ច្បាប់ អ.វ.ត.ក. មាត្រា ១៤(១)(ក) (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៤(១)(ក)។

1015 ច្បាប់ អ.វ.ត.ក. មាត្រា ១៤(២) (ថ្មី)។

1016 ច្បាប់ អ.វ.ត.ក. មាត្រា ៩ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(២)(ខ)។

1017 ច្បាប់ អ.វ.ត.ក. មាត្រា ១៤(១)(ខ) (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៤(១)(ខ)។

1018 វិធានផ្ទៃក្នុង វិធាន១០៤(១)។ បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង អាចផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ។ សេចក្ដីសម្រេចដែលបើកផ្លូវឱ្យប្ដឹងសាទុក្ខភ្លាមៗគឺ៖ (១) សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី (២) សេចក្ដីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (៣) សេចក្ដីសម្រេចអំពីវិធានការការពារ (៤) សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ សូមមើល វិធានផ្ទៃក្នុង វិធាន ១០៤(៤)។ សូមមើលផងដែរ ច្បាប់ អ.វ.ត.ក. មាត្រា ៣៦ (ថ្មី)។

1019 វិធានផ្ទៃក្នុង វិធាន ១០៤(២)។

អាចត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា ឬជនជាប់ចោទ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខសេចក្តីសម្រេចលើសំណាង[1020]។

ផ្នែកគាំពារការការពារក្តីត្រូវបានដឹកនាំដោយប្រធានម្នាក់ រួមជាមួយអនុប្រធានជាតិមួយរូប និងអន្តរជាតិមួយរូប[1021]។ ផ្នែកគាំពារការការពារក្តីទទួលខុសត្រូវលើការរក្សាបញ្ជីមេធាវីដែលមានគុណវុឌ្ឍិ ការផ្តល់ជំនួយផ្នែកច្បាប់ និងការគាំទ្រជាមូលដ្ឋាន (រួមមានការស្រាវជ្រាវច្បាប់ និងឯកសារ) សម្រាប់មេធាវីការពារក្តី និងការធ្វើការសម្រេចអំពីជនណាមួយជាជនក្រីក្រ និងការចាត់តាំងមេធាវីការពារជនក្រីក្រ[1022]។ ក្នុងពេលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន និងជំនួយផ្នែកច្បាប់ ប្រសិនបើពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់ពឹងមេធាវី[1023]។

វិធានផ្ទៃក្នុងបានបង្កើតផ្នែកគាំពារជនរងគ្រោះ ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[1024]។ ផ្នែកគាំពារជនរងគ្រោះមានការទទួលខុសត្រូវនានា ដែលរួមមាន ការជួយជនរងគ្រោះក្នុងការដាក់បណ្តឹង ក្រោមការត្រួតពិនិត្យរបស់សហព្រះរាជអាជ្ញា ការជួយជនរងគ្រោះក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្រោមការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត[1025] និងថែរក្សាបញ្ជីឈ្មោះមេធាវីដើម្បីសម្រួលដល់ការតំណាងផ្នែកច្បាប់[1026]។ ផ្នែកគាំពារជនរងគ្រោះក៏មានការទទួលខុសត្រូវលើការបង្កើត និងការអនុវត្តសកម្មភាពមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ និងវិធានការនានា ដើម្បីផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះឱ្យកាន់តែទូលំទូលាយ[1027]។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានសមាសភាពមេធាវីកម្ពុជាមួយរូប និងមេធាវីបរទេសមួយរូប[1028]។ ពួកគេទទួលខុសត្រូវលើការរៀបចំតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលដំណាក់កាលជំនុំជម្រះ និងលើសពីនេះ "ធ្វើឱ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក."[1029]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមាន "ការទទួលខុសត្រូវជាចុងក្រោយទៅកាន់តុលាការ សម្រាប់ការផ្តល់ការអះអាង និងយុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការអំពីផលប្រយោជន៍ របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយនោះ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ"[1030]។ ពួកគេក៏ទទួលខុសត្រូវផងដែរចំពោះការសម្របសម្រួលសកម្មភាពរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[1031]។

### ៥.១.២. មូលដ្ឋានច្បាប់សម្រាប់វិធានផ្ទៃក្នុង

អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. បានសម្រេចយ៉ាងស៊ីចង្វាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ គ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. និងថាវិធានផ្ទៃក្នុងច្របាច់បញ្ចូលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្នុងពេលជាមួយគ្នានោះក៏ឆ្លុះបញ្ចាំងផងដែរពីតម្រូវការពិចារណាលើបទដ្ឋានអន្តរជាតិ នៅពេលដែលចាំបាច់ និងសមស្រប[1032]។ ដូច្នេះ "ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាគ្របដណ្តប់លើ

---

[1020] *វិធានផ្ទៃក្នុង* វិធាន ១០៥(១)។
[1021] *វិធានផ្ទៃក្នុង* វិធាន ១១(១)។
[1022] *វិធានផ្ទៃក្នុង* វិធាន ១១។
[1023] *ច្បាប់ អ.វ.ត.ក.* មាត្រា ២៤ (ថ្មី)។
[1024] *វិធានផ្ទៃក្នុង* វិធាន ១២ និង១២ *ស្ទួនពីរ*។
[1025] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួន* (១)(ក) និង(ខ)។
[1026] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួន* (១)(គ)-(ង) និង(ឆ) និង(២)។
[1027] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួន* (៤)។
[1028] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួនពីរ* (៤)។
[1029] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួនពីរ* (១)។
[1030] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួនពីរ* (៥)(ខ)។
[1031] *វិធានផ្ទៃក្នុង* វិធាន ១២ *ស្ទួនពីរ* (៦)។ សូមមើល *វិធានផ្ទៃក្នុង* វិធាន ២៣ *ស្ទួនពីរ* (១) ចែងថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវតំណាងដោយមេធាវីដើមតំណាងបណ្តឹងរដ្ឋប្បវេណី យ៉ាងយូរបំផុត ចាប់ពីពេលចេញដីកាដំណោះស្រាយតទៅ។
[1032] សំណុំរឿង ០០២/០២ និង *សាលក្រម* កថាខណ្ឌ ៣៥។ សំណុំរឿង ០០២/០១ *សាលក្រម* កថាខណ្ឌ ២១។ សំណុំរឿង ០០១ *សាលក្រម* កថាខណ្ឌ ៣៥។

នីតិវិធីចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏អាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតក្នុងកម្រិតអន្តរជាតិតាមករណីសមស្របផងដែរ”[1033]។

ក្នុងការធ្វើការសន្និដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានយោងមាត្រា ១២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ដែលចែងថា “នីតិវិធីត្រូវស្របជាមួយច្បាប់កម្ពុជា” ដែលគេអាចស្វែងរកការណែនាំក្នុងវិធាននីតិវិធីនៅកម្រិតអន្តរជាតិ នៅពេលដែលច្បាប់កម្ពុជាមិនបានដោះស្រាយចំពោះបញ្ហាពិសេសណាមួយ នៅពេលដែលមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពស៊ីចង្វាក់គ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ[1034]។ ច្បាប់ អ.វ.ត.ក. បានរួមបញ្ចូលពាក្យពេចន៍ដូចគ្នានៅក្នុងនីតិវិធីដែលចែងអំពីតួនាទីរបស់សហព្រះរាជអាជ្ញា[1035] សហចៅក្រមស៊ើបអង្កេត[1036] អង្គជំនុំជម្រះសាលាដំបូង[1037] និងអង្គជំនុំជម្រះតុលាការកំពូល[1038]។ បុព្វកថានៃវិធានផ្ទៃក្នុងក៏អនុវត្តតាមបទប្បញ្ញត្តិទាំងនេះដែរ[1039]។

អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគស៊ីជម្រៅលើនីត្យានុកូលភាពនៃវិធានផ្ទៃក្នុង នៅពេលដោះស្រាយអំណះអំណាងរបស់ នួន ជា ដែលថាវិធានផ្ទៃក្នុង “ផ្ទុយទៅនឹងធម្មនុញ្ញ”[1040]។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលការអះអាងដែលថា ចៅក្រមបានបំពេញតួនាទីលើសពីសមត្ថកិច្ច (*ultra vires*) ក្នុងការអនុម័តវិធានផ្ទៃក្នុង ដោយលើកឡើងថា “ពុំមានបញ្ញត្តិណាមួយនៅក្នុង [...] កិច្ចព្រមព្រៀង អ.វ.ត.ក. ហាមឃាត់មិនឱ្យមានការអនុម័តបទដ្ឋាននីតិវិធីនានាដែលធ្វើឡើងដោយកិច្ចប្រជុំពេញអង្គ ដែលត្រូវបានធ្វើឡើងដើម្បីគោលបំណងនេះឡើយ”[1041]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានបដិសេធអំណះអំណាងទាក់ទងនឹងអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងផងដែរ ដោយពិចារណាថាវិធានផ្ទៃក្នុងគឺជា “ការបង្ហាញអំពីការរួមបញ្ចូលគ្នានូវក្របខណ្ឌច្បាប់ជាធរមានដែលពុំមែនជាការដណ្តើមយកសិទ្ធិអំណាចនីតិបញ្ញត្តិនោះទេ”[1042]
។

### ៥.១.៣. ទំនាក់ទំនងរវាងនីតិវិធីច្បាប់ជាតិ

លក្ខណៈនៃទំនាក់ទំនងរវាងបទដ្ឋានជាតិ និងអន្តរជាតិត្រូវបានពិភាក្សាដេញដោល៖ ចៅក្រម អ.វ.ត.ក. បានរៀបរាប់យ៉ាងច្រើនអំពី អ.វ.ត.ក. ថាជា “តុលាការអន្តរជាតិថ្មីមួយដែលអនុវត្តបទដ្ឋាន និងនិយាមអន្តរជាតិ”[1043] “តុលាការកូនកាត់មួយមានសមត្ថកិច្ចជំនុំជម្រះទៅលើឧក្រិដ្ឋកម្មទាំងឡាយ ទាំងឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មជាតិ”[1044] និងជាតុលាការក្នុងស្រុកដែល “ត្រូវបានបង្កើតឡើងដោយប្រព័ន្ធច្បាប់

---

[1033] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៥។
[1034] សូមមើលសំណុំរឿង ០០២/០២ និង សាលក្រម កថាខណ្ឌ ៣៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៥ (យោង កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១២ (១)។
[1035] ច្បាប់ អ.វ.ត.ក. មាត្រា ២០ (ថ្មី)។
[1036] ច្បាប់ អ.វ.ត.ក. មាត្រា ២៣ (ថ្មី)។
[1037] ច្បាប់ អ.វ.ត.ក. មាត្រា ៣៣ (ថ្មី)។
[1038] ច្បាប់ អ.វ.ត.ក. មាត្រា ៣៧ (ថ្មី)។
[1039] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី០) បុព្វកថា។
[1040] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14 កថាខណ្ឌ ១ និង ៣។
[1041] ដូចខាងលើ កថាខណ្ឌ ៦។
[1042] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១០៦។
[1043] សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៣០។ សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ១៣-២៥។ សំណុំរឿង ០០៥ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១៣១។
[1044] សំណុំរឿង ០០១ មតិជំទាស់របស់ចៅក្រម Jean-Marc LAVERGNE ពាក់ព័ន្ធទៅនឹងការកំណត់ទោស ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188.1 កថាខណ្ឌ ៥។

ជាតិ ហើយស្ថិតក្រោមប្រព័ន្ធច្បាប់ជាតិ”[1045]។ បញ្ហានេះត្រូវបានពិចារណាជាពិសេសនៅក្នុងបរិបទរបបនីតិវិធីរបស់ អ.វ.ត.ក.។

អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា វិធានផ្ទៃក្នុងបានច្របាច់បញ្ចូលនីតិវិធីកម្ពុជានៅពេលធ្វើសេចក្តីព្រាង[1046]។ ហេតុដូច្នេះ វិធានផ្ទៃក្នុងមានឋានៈដោយខ្លួនឯង មានន័យថា វិធានផ្ទៃក្នុងមានឧត្តមភាពនៅក្នុងករណីដែលមានភាពខុសគ្នារវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[1047]។ យ៉ាងណាមិញ ការសម្រេចតាមផ្លូវតុលាការជាច្រើន បានបញ្ជាក់ថា នីតិវិធីព្រហ្មទណ្ឌកម្ពុជានឹងបន្តអនុវត្តក្នុងករណីមានការខ្វះចន្លោះនៅក្នុងវិធានផ្ទៃក្នុង[1048]។

វិធានផ្ទៃក្នុង “បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក.”[1049]។ តុលាការ និងសាលាក្តីអន្តរជាតិផ្សេងទៀតបានអនុម័តវិធាននីតិវិធី និងភ័ស្តុតាងដែល “ដោយកែសម្រួលឱ្យស្របទៅតាមលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះលើករណីព្រហ្មទណ្ឌអន្តរជាតិដ៏ស្មុគស្មាញ”[1050]។ កិច្ចប្រជុំពេញអង្គ អ.វ.ត.ក. បានអនុម័តវិធីសាស្ត្រស្រដៀងគ្នានេះ នៅពេលធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុង ដូចដែលចាំបាច់និងសមស្របដោយផ្អែកលើលក្ខណៈរបស់ អ.វ.ត.ក.[1051]។ ហេតុដូច្នេះ វិធានផ្ទៃក្នុងបានអនុវត្តក្នុងករណីដែលមានភាពខុសគ្នាណាមួយ រវាងនីតិវិធីដែលបានគូសបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ[1052]។

យ៉ាងណាមិញ នៅពេលមានការខ្វះចន្លោះនៅក្នុងវិធានផ្ទៃក្នុង គេអាចងាកទៅរកក្រមនីតិវិធីព្រហ្មទណ្ឌបាន[1053]។ នៅក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រឆាំងនឹងការឃុំ

---

[1045] សំណុំរឿង ០០១ សាលដីកា មតិជំទាស់រួមរបស់ចៅក្រម Agnieszka Klonowiecka-Milart និង Chandra Nihal Jayasinghe កថាខណ្ឌ ៩-១១។

[1046] សំណុំរឿង ០០២/០២ និង សាលក្រម កថាខណ្ឌ ៣៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៥។

[1047] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤។

[1048] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៤៧។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ១១៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៥។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៧។

[1049] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤។

[1050] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14 កថាខណ្ឌ ៧។ អង្គជំនុំជម្រះសាលាដំបូងក៏បានបំភ្លឺផងដែរថា អ.វ.ត.ក. មានសិទ្ធិអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួន ដោយអនុលោមតាមស្តង់ដារអន្តរជាតិ “ដែលពិចារណាទៅលើយន្តការពិសេសដែលចាំបាច់ដើម្បីវិនិច្ឆ័យសេចក្តីទៅលើឧក្រិដ្ឋកម្មធំៗ”។ សូមមើលសំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E39/5 កថាខណ្ឌ ១១។

[1051] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14 កថាខណ្ឌ ៧។

[1052] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤។

[1053] ដូចខាងលើ កថាខណ្ឌ ១៥។ សូមមើល វិធានផ្ទៃក្នុង វិធាន ២ (“នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ ថ្មី ២៣ ថ្មី ៣៣ថ្មី ឬមាត្រា ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និង ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។ ក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ត្រូវដាក់ជូនទៅគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងឱ្យបានឆាប់រហ័សតាម

ខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ពុំមានបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ឬច្បាប់ អ.វ.ត.ក. ដោះស្រាយផ្ទាល់ជាមួយនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នឡើយ និងបានសន្និដ្ឋានថា អង្គបុរេជំនុំជម្រះបំពេញតួនាទីជាសភាស៊ើបសួរកម្ពុជា នៅ អ.វ.ត.ក.[1054]។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាបន្ថែមទៀតលើក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលធ្វើការសម្រេចលើសំណើទាក់ទងនឹងការតែងតាំងអ្នកជំនាញ[1055]។ អង្គជំនុំជម្រះតុលាការកំពូល លើកលែងមតិជំទាស់របស់ចៅក្រម Noguchi ក៏បានពិចារណាលក្ខខណ្ឌតម្រូវក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងវិធានផ្ទៃក្នុងផងដែរ នៅពេលកំណត់ពីលក្ខណៈវិនិច្ឆ័យសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នតាមវិធាន ៨១ នៃវិធានផ្ទៃក្នុង[1056]។

យ៉ាងណាមិញ ការសម្រេចតាមផ្លូវតុលាការផ្សេងទៀត បានអនុម័តវិធីសាស្ត្រខុសៗគ្នាចំពោះការខ្វះចន្លោះនៅក្នុងវិធានផ្ទៃក្នុង។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា សំណើសុំឱ្យបកស្រាយសំណងដើម្បីបណ្តឹងរដ្ឋប្បវេណីពីប្រព័ន្ធអន្តរជាតិ មិនអាចអនុញ្ញាតផ្ទេរទៅបានទេ ដោយសារបច្ចុប្បន្នវាមិនត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង ដោយសម្រេចថា "ការដាក់កំហិតបែបនេះមិនអាចចៀសវាងបានដោយយុត្តាធិការនោះទេ ប៉ុន្តែទាមទារឱ្យធ្វើវិសោធនកម្មវិធានផ្ទៃក្នុង"[1057]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០២ បានផ្អែកលើវិធានអន្តរជាតិ និងបានពិនិត្យមើលយុត្តិសាស្ត្រតុលាការ ICTY ដើម្បីបំពេញការខ្វះចន្លោះនៅក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងអត្ថន័យច្បាស់លាស់នៃ "សម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ"[1058]។

## ៥.២. បទប្បញ្ញត្តិទូទៅនៃវិធានផ្ទៃក្នុង

### ៥.២.១. សក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី

របបគ្រប់គ្រងជាពិសេសលើភ័ស្តុតាងប្រឆាំងនឹងខ្លួនឯង មានចែងក្នុងវិធាន ២៨ នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ មិនត្រូវកោះហៅមកធ្វើជាសាក្សីចំពោះបុគ្គលណា ដែលមានភ័ស្តុតាងប្រឆាំងនឹងខ្លួនឯងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌ ក្រោមមាត្រា ២៤(៤) នៃវិធានផ្ទៃក្នុងឡើយ លើកលែងតែមានចែងក្នុងវិធាន ២៨ នៃវិធានផ្ទៃក្នុង[1059]។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង អនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមបញ្ចូលទាំងការស៊ើបអង្កេតបឋមដោយសហព្រះរាជអាជ្ញា ការស៊ើបអង្កេតដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ[1060]។

សាក្សីត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន ក្នុងការជំទាស់ទៅនឹងការផ្តល់ចម្លើយណាមួយដែលអាចប្រឆាំងនឹងខ្លួនឯង។ ប្រសិនបើសាក្សីមិនត្រូវបានជូនដំណឹងអំពីសិទ្ធិនេះទេ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ត្រូវតែជូនដំណឹងដល់ពួកគេមុនពេលការស្តាប់ចម្លើយ ឬការផ្តល់

---

ដែលអាចធ្វើទៅបាន")។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៦-៧។

[1054] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៦-៧។ សូមមើល សំណុំរឿង ០០៦ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៩១។

[1055] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២២។

[1056] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៤៧។

[1057] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦២។

[1058] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០៨ ឯកសារ D54/V/6 កថាខណ្ឌ ២០-២៧។

[1059] វិធានផ្ទៃក្នុង វិធាន ២៤(៤)។

[1060] វិធានផ្ទៃក្នុង វិធាន ២៨(១)។

សក្ខីកម្ម[1061]។ ក្នុងសំណុំរឿង ០០១, ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង សង្កេតឃើញថា សាក្សីត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ពួកគេចំពោះការមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ហើយទទួលបានជំនួយពីមេធាវី បន្ទាប់ពីមានការស្នើសុំ[1062]។

បុគ្គលដែលមានភ័ស្តុតាងដាក់បន្ទុកមកលើខ្លួនឯង អាចផ្តល់ភ័ស្តុតាងនៃអង្គហេតុ និងកាលៈទេសៈផ្សេងទៀតដែលបានឃើញ ឬស្តាប់ឮ ក្រៅពីអំពើផ្ទាល់ខ្លួនរបស់សាក្សីនោះ ប៉ុន្តែការភ័យខ្លាចនៃការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺជាកត្តាដែលអាចពាក់ព័ន្ធនៅពេលវាយតម្លៃភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់សាក្សី[1063]។ ជាងនេះទៀត ទណ្ឌិតអាចត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម ដោយមិនប្រឆាំងទៅនឹងបទប្បញ្ញត្តិស្តីពីការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងឡើយ[1064]។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ប្រសិនបើខ្លួនបានសម្រេចធ្វើដូច្នោះ អង្គជំនុំជម្រះអាចកោះហៅ ឌុច មកផ្តល់សក្ខីកម្មក្រោមសម្បថក្នុងនាមជាសាក្សីធម្មតា[1065]។ វិធាន ២៤(៤) នៃវិធានផ្ទៃក្នុងមិនរារាំងទណ្ឌិតក្នុងសំណុំរឿង ០០១ ពីការផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ក្នុងសំណុំរឿង ០០២ នោះទេ។ ប្រសិនបើកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ មិនទាន់បញ្ចប់ទេនោះ អង្គជំនុំជម្រះសាលាដំបូង យ៉ាងណាក៏ដោយ នៅតែអាចស្តាប់សក្ខីកម្ម ឌុច ក្នុងនាមជាសាក្សី បន្ទាប់ពីមានការណែនាំសមស្របពីអង្គជំនុំជម្រះទាក់ទងនឹងសិទ្ធិរបស់គាត់ចំពោះការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង[1066]។

បញ្ហាចោទអំពីការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង អាចត្រូវបានលើកឡើងដោយសាក្សី ឬភាគី[1067]។ ប្រសិនបើបញ្ហាអំពីការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងកើតមានឡើង ហើយសាក្សីមិនបានលះបង់សិទ្ធិនោះ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវបញ្ឈប់ការយកសក្ខីកម្មនោះ និងត្រូវផ្តល់មេធាវីឱ្យសាក្សីនោះ[1068]។ បន្ទាប់ពីការពិភាក្សាជាមួយសហព្រះរាជអាជ្ញារួចមក ស្ថាប័នតុលាការដែលសួរចម្លើយមានឆន្ទានុសិទ្ធិធានាដល់សាក្សីនោះថា ភ័ស្តុតាងនោះនឹងត្រូវរក្សាជាការសម្ងាត់ និងមិនត្រូវបានប្រើប្រឆាំងនឹងសាក្សីនោះឡើយ នៅក្នុងការចោទប្រកាន់បន្តទៀតដោយ អ.វ.ត.ក.[1069]។ ក្នុងការពិចារណាថាតើត្រូវបង្ខំឱ្យសាក្សីផ្តល់ភ័ស្តុតាង ឬយ៉ាងណានោះ ស្ថាប័នតុលាការត្រូវពិនិត្យសារៈសំខាន់ និងលក្ខណៈពិសេសនៃភ័ស្តុតាង លក្ខណៈដែលអាចមានការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង និងលក្ខណៈគ្រប់គ្រាន់នៃការការពារសម្រាប់សាក្សី[1070]។ ដោយពិចារណាលើបទប្បញ្ញត្តិទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ បានសម្រេចមិនកោះហៅ អ៊ឹម ចែម មកធ្វើជាសាក្សី ដោយសារការចោទប្រកាន់នានាស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ត្រួតគ្នាជាមួយនឹងការចោទប្រកាន់ប្រឆាំងនឹងគាត់នៅក្នុងកិច្ចស៊ើបសួរ[1071]។

---

[1061] វិធានផ្ទៃក្នុង វិធាន ២៨(២)។

[1062] សូមមើល សំណុំរឿង ០០២/០២ និង សាលក្រម កថាខណ្ឌ ៥០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០។ សូមមើលផងដែរ សំណុំរឿង ០០២/០១ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ឯកសារ E74 ទំព័រ ១-២។

[1063] សំណុំរឿង ០០២/០២ និង សាលក្រម កថាខណ្ឌ ៦២។

[1064] សូមមើល សំណុំរឿង ០០២/០១ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើក្រោយកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ២០១១ ឯកសារ E74 ទំព័រ ១-២។

[1065] សំណុំរឿង ០០២/០១ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ឯកសារ E74 ទំព័រ ១។

[1066] ដូចខាងលើ ទំព័រ ១-២។

[1067] វិធានផ្ទៃក្នុង វិធាន ២៨(៨)។

[1068] វិធានផ្ទៃក្នុង វិធាន ២៨(៩)។

[1069] វិធានផ្ទៃក្នុង វិធាន ២៨(៣)-(៤)។

[1070] វិធានផ្ទៃក្នុង វិធាន ២៨(៥)។

[1071] សំណុំរឿង ០០២/០២ សេចក្តីសម្រេចស្តីពីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៨ កក្កដា ឆ្នាំ២០១៧ ឯកសារ E459 កថាខណ្ឌ ៥៣-៥៤។

ប្រសិនបើភ័ស្តុតាងត្រូវបានផ្តល់ឱ្យ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចបង្គាប់ថា ភ័ស្តុតាងនោះត្រូវផ្តល់ដោយសម្ងាត់ ដោយមិនមានការបង្ហាញអត្តសញ្ញាណសាក្សីទៅសាធារណៈជនឡើយ ហើយអាចបង្គាប់ឱ្យប្រើវិធានការការពារបន្ថែមទៀត[1072]។

### ៥.២.២. វិធានការការពារ

អ.វ.ត.ក. បានបំពេញកាតព្វកិច្ចការពារជនរងគ្រោះ ដែលបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[1073] មិនថាជាអ្នកដាក់បណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីនោះទេ[1074]។ ការជំនុំជម្រះត្រូវតែត្រឹមត្រូវ និងឆាប់រហ័ស ដោយគោរពយ៉ាងពេញលេញមិនត្រឹមតែសិទ្ធិរបស់ជនជាប់ចោទប៉ុណ្ណោះទេ ថែមទាំងការការពារចំពោះ "ជនរងគ្រោះ និងសាក្សី"ផងដែរ[1075]។

វិធានការការពារអាចផ្តល់ឱ្យតាមសំណើរបស់ភាគី ឬមេធាវីរបស់ពួកគេ ឬដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតាមការផ្តួចផ្តើមរបស់ខ្លួន[1076]។ ការការពារជនរងគ្រោះត្រូវបានពិចារណាដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ នៅពេលធ្វើការបង្គាប់ណាមួយ ដោយកាតព្វកិច្ចនេះអនុវត្តដូចគ្នាចំពោះស្ថាប័នផ្សេងទៀត ដូចដែលអាចអនុវត្តបាន ក្នុងការបំពេញភារកិច្ចរបស់ខ្លួន[1077]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអង្គភាពគាំពារសមស្រប អាចបង្គាប់ឱ្យមានវិធានការការពារសមស្រប ដើម្បីការពារជនរងគ្រោះ និងសាក្សី[1078]។ ក្នុងការសម្រេចថាតើត្រូវបង្គាប់ឱ្យមានវិធានការការពារ ឬគ្មាននោះ សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះ អាចធ្វើការសវនាការដោយសម្ងាត់ ដែលអាចធ្វើពីចម្ងាយ ដើម្បីសម្រួលដល់ការចូលរួមរបស់ភាគីដែលចាប់អារម្មណ៍[1079]។

មុនពេលផ្តល់វិធានការការពារ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវថ្លឹងថ្លែងគោលការណ៍ជាសារវន្តចំនួនបី ដែលអាចអនុវត្តក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. "គឺ៖ តម្រូវការរបស់ជនរងគ្រោះ និងសាក្សី សិទ្ធិរបស់ជនសង្ស័យ ឬជនដែលត្រូវចោទ ឬជនជាប់ចោទ និងនីតិវិធីនៃការជំនុំជម្រះមួយដែលត្រឹមត្រូវ និងមិនលម្អៀង[1080]។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវពិចារណាថាតើស្ថានភាពនោះ "អាចធ្វើឱ្យអាយុជីវិត សុខមាលភាព ឬក្រុមគ្រួសារ ឬញាតិជិតស្និទ្ធរបស់ពួកគេ ត្រូវស្ថិត

---

[1072] វិធានផ្ទៃក្នុង វិធាន ២៨(៧)។

[1073] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៤។ ច្បាប់ អ.វ.ត.ក. មាត្រា ៣៣ (ថ្មី)។ វិធានផ្ទៃក្នុង វិធាន ២៩(១)។ ច្បាប់ អ.វ.ត.ក. បានដាក់កាតព្វកិច្ចនេះទៅលើ "តុលាការ"។ វិធាននេះសំដៅលើ "អ.វ.ត.ក." និងកិច្ចព្រមព្រៀង "រវាងសហចៅក្រមសើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញ"។

[1074] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៣។ ច្បាប់ អ.វ.ត.ក. មាត្រា ៣៣ (ថ្មី)។ វិធានផ្ទៃក្នុង វិធាន ២៩(១)។ ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលសំដៅលើ "ជនរងគ្រោះ និងសាក្សី"។ វិធានផ្ទៃក្នុងបានបញ្ជាក់ច្បាស់ថា បទប្បញ្ញត្តិអនុវត្តចំពោះ "ជនរងគ្រោះដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី មិនថាជាអ្នកដាក់បណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណី [ឬ]សាក្សីឡើយ"។ វិធានផ្ទៃក្នុងចែងថា "ជនរងគ្រោះ" សំដៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គល (ឧទាហរណ៍ សមាគមជនរងគ្រោះ សាលារៀន ឬព្រះវិហារ) ដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក.។ សូមមើល សទ្ទានុក្រម វិធានផ្ទៃក្នុង ("ជនរងគ្រោះ")។ រាជរដ្ឋាភិបាលកម្ពុជាក៏មានកាតព្វកិច្ចទទួលបន្ទុកចាត់វិធានការប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រាន់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងការការពារបុគ្គលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល។ សូមមើល កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៤។

[1075] ច្បាប់ អ.វ.ត.ក. មាត្រា ៣៣ (ថ្មី)។

[1076] វិធានផ្ទៃក្នុង វិធាន ២៩(៣)។ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ២.១។ ការប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដោយការិយាល័យណាមួយរបស់តុលាការគួត្រូវបានធ្វើឡើងតាមរយៈមេធាវីរបស់ពួកគេ ឬតាមរយៈសមាគមជនរងគ្រោះ ប្រសិនបើការទំនាក់ទំនងដោយផ្ទាល់នោះអាចបណ្តាលឱ្យបុគ្គលទាំងនេះមានគ្រោះថ្នាក់ដល់ជីវិត ឬដល់សុខមាលភាពរបស់ពួកគេ។ សូមមើល វិធានផ្ទៃក្នុង វិធាន ២៩(២)។ នៅពេលដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដាក់បណ្តឹង បានស្នើសុំវិធានការការពារ ឬបានជូនដំណឹងដល់មន្ត្រីតុលាការថា ពួកគេមានការព្រួយបារម្ភអំពីសុវត្ថិភាព ឬអំពីការសម្ងាត់ សំណើររបស់ពួកគេនឹងត្រូវបញ្ជូនទៅកាន់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឬអង្គភាពជនរងគ្រោះទៅតាមលក្ខខណ្ឌសមស្រប។ សូមមើល សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ២.២។

[1077] វិធានផ្ទៃក្នុង វិធាន ២៩(២)។ សូមមើល សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ១.៣។

[1078] វិធានផ្ទៃក្នុង វិធាន ២៩(៣)។

[1079] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ២.៤។

[1080] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ១.៣។

ក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ”[1081]។ ការវាយតម្លៃពេញលេញលើអង្គហេតុទាំងនេះ អាចត្រូវបានធ្វើឡើងដើម្បីកំណត់ថាតើ វិធានការបែបនោះសមស្របឬទេ និងអាចពិនិត្យមើលជាពិសេសលើភាពសមាមាត្រវាងវិធានការការពារ ដែលបានដាក់ចេញ និងហានិភ័យដែលអាចកើតមានឡើង[1082]។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះក៏ត្រូវស្វែងរកការយល់ព្រម ពីបុគ្គលដែលត្រូវការពារដោយវិធានការនោះផងដែរ[1083]។

អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យកម្រិតកំណត់អតិបរមាសម្រាប់វិធានការការពារ។ អង្គជំនុំជម្រះបានពិចារណាថា ច្បាប់យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ទោះបីជាផ្តោតលើការការពារសាក្សីជាជាងដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏អាចផ្តល់ការណែនាំសម្រាប់ការការពារដើមបណ្តឹងរដ្ឋប្បវេណី។ ច្បាប់យុត្តិសាស្ត្រនេះបានបង្ហាញថា “វិធានការការពារត្រូវបានផ្តល់ឱ្យតាមករណីនីមួយៗ នៅពេលដែលសំណើនោះមានព័ត៌មានគ្រប់គ្រាន់ស្តីអំពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ និងការបញ្ជាក់ដ៏លម្អិតអំពីគ្រោះថ្នាក់ ឬព្យសនកម្ម ដែលអ្នកដាក់ពាក្យសុំ ឬក្រុមគ្រួសាររបស់ពួកគេនឹងប្រឈម”[1084]។ អង្គជំនុំជម្រះសាលាដំបូងក៏ពិចារណាផងដែរលើ សេចក្តីសម្រេចដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលបានបង្ហាញថា វិធានការការពារ “តែងតែត្រូវបានផ្តល់ជូនដល់បុគ្គលដែលត្រូវបានកំណត់ដោយឈរលើមូលដ្ឋាននៃហានិភ័យដែលបានបញ្ជាក់ច្បាស់លាស់”[1085] និងថាការពិចារណាផ្សេងៗអាចអនុវត្តនៅដំណាក់កាលស៊ើបអង្កេត និងជំនុំជម្រះ ដោយសារតែ “ការរក្សាការសម្ងាត់នៃកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ គឺមានលក្ខណៈខុសគ្នាពីដំណើរការនីតិវិធីជំនុំជម្រះក្តី ដែលគេសន្មតថាដំណើរការនីតិវិធីជំនុំជម្រះក្តីមានលក្ខណៈជាសាធារណៈ”[1086]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានដូចគ្នា ដោយសន្និដ្ឋានថា វិធានការការពារមិនចាំបាច់ ក្នុងករណីមិនមានព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី កាលៈទេសៈជាក់លាក់ដែលចាំបាច់តម្រូវឱ្យមានវិធានការបែបនោះ ឬការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ពួកគេឡើយ[1087]។

វិធានការការពារដែលបង្គាប់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចរួមមាន តែមិនកម្រិតត្រឹមតែ កិច្ចដំណើរការនីតិវិធីដោយសម្ងាត់[1088] និងការអនុញ្ញាតឱ្យធ្វើការបង្ហាញភស្តុតាងតាមមធ្យោបាយអេឡិចត្រូនិក ឬមធ្យោបាយពិសេសណាមួយផ្សេងទៀត[1089]។ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ បានបញ្ជាក់ថា វិធានការតាមអេឡិចត្រូនិករួមមាន ការបំប្លែងសំឡេង និង/ឬ ទម្រង់រូបកាយរបស់បុគ្គលដែលត្រូវការពារ[1090] ការប្រើប្រាស់មធ្យោបាយសោតទស្សន៍ ដូចជាការធ្វើតាមវីដេអូពីចម្ងាយ (video-conferencing) ឬ ទូរទស្សន៍ CCTV (closed-circuit television)[1091] ការប្រើតែមធ្យោបាយ

[1081] វិធានផ្ទៃក្នុង វិធាន ២៩(៣)។
[1082] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ១.៤។
[1083] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ១.៥។
[1084] សំណុំរឿង ០០១ សេចក្តីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E71 កថាខណ្ឌ ៧។
[1085] ដូចខាងលើ កថាខណ្ឌ ៨។
[1086] ដូចខាងលើ កថាខណ្ឌ ៩។
[1087] ដូចខាងលើ កថាខណ្ឌ ១១-១២។
[1088] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៣។ ច្បាប់ អ.វ.ត.ក. មាត្រា ៣៣ (ថ្មី) វិធានផ្ទៃក្នុង វិធាន ២៩ (៤)(ង)។
[1089] វិធានផ្ទៃក្នុង វិធាន ២៩(៤)(ង)។ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ២.២(ឃ)។
[1090] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ៣.២ (ក) សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ២៩(៤)(ឃ)។ វិធានផ្ទៃក្នុងបញ្ជាក់ថា វិធានការនេះនឹងសមស្រប ប្រសិនបើជនត្រូវចោទ ឬជនជាប់ចោទ ស្នើសុំឱ្យមានការតទល់។ សេចក្តីណែនាំអនុវត្តមានលក្ខណៈទំលាយជាង ដោយចែងថា ការបំប្លែងអាចសមស្រប “ជាពិសេសក្នុងអំឡុងពេលនីតិវិធីតទល់ ឬសវនាការលើអង្គសេចក្តី”។
[1091] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ កថាខណ្ឌ ៣.២(ខ)។

សំឡេងក្នុងការទំនាក់ទំនង[1092] ឬ "មធ្យោបាយអេឡិចត្រូនិកដទៃទៀតទាំងអស់ ដែលអាចការពារបុគ្គលដែលត្រូវការពារនោះ"[1093]។

វិធានការបន្ថែមទៀតរួមមានការបង្គាប់ឱ្យធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ (ទាំងស្រុង ឬមួយផ្នែក) រក្សាទុកតាមរបៀបបិទស្លាកបោះត្រា[1094] ហាមឃាត់សាធារណៈជនចូលពិនិត្យឯកសារជាក់លាក់ណាមួយក្នុងសំណុំរឿង[1095] ការការពារផ្នែករូបវន្ត (រួមមាន ការផ្ដល់ជាកន្លែងស្នាក់នៅដែលមានសុវត្ថិភាព នៅក្នុង ឬក្រៅប្រទេសកម្ពុជា)[1096] និងការកោសលុបព័ត៌មានកំណត់អត្តសញ្ញាណ ឬទីតាំងរបស់បុគ្គលដែលត្រូវការពារ[1097]។ វិធានការបន្ថែមទៀត អាចរួមបញ្ចូលការបង្កើតទំនាក់ទំនងតាមរយៈតតិយជន ជាជាងការទាក់ទងទៅកាន់ជនរងគ្រោះដោយផ្ទាល់[1098] ការប្រើប្រាស់រហស្សនាម[1099] និងការអនុញ្ញាតឱ្យធ្វើកំណត់ហេតុដោយពុំចាំបាច់មានសរសេរអត្តសញ្ញាណនៅក្នុងសំណុំរឿង[1100]។

ព័ត៌មានលម្អិតនៃអត្តសញ្ញាណរបស់បុគ្គលដែលត្រូវការពារ ចាំបាច់ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយឡែកពីសំណុំរឿង[1101] ហើយការដាក់បង្ហាញអត្តសញ្ញាណ ឬអាសយដ្ឋានរបស់បុគ្គលណាម្នាក់ដែលស្ថិតក្រោមរបបការពារ អាចនឹងត្រូវទទួលទណ្ឌកម្មតាមច្បាប់កម្ពុជាជាធរមាន[1102]។ ជាទូទៅ ការអនុវត្តវិធានការការពារ អាចធ្វើឡើងយ៉ាងយូរ ១៥ ថ្ងៃ បន្ទាប់ពីសាលក្រមចូលជាស្ថាពរ ហើយវិធានការការពារសម្រាប់សាក្សី យ៉ាងយូរត្រឹមកាលបរិច្ឆេទកំណត់សម្រាប់ការដាក់បញ្ជីឈ្មោះសាក្សី[1103]។

ដើម្បីបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលទាក់ទងនឹងវិធានការការពារ ដែលផ្ដល់ឱ្យតាមវិធាន ២៩(៤)(គ) នៃវិធានផ្ទៃក្នុង[1104]។ នៅពេលដែលត្រូវបានផ្ដល់ឱ្យ វិធានការការពារត្រូវអនុវត្ត*បើមានការចាំបាច់* នៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូលក្នុងរឿងក្ដីពាក់ព័ន្ធ ក៏ដូចជាកិច្ចដំណើរការនីតិវិធីផ្សេងទៀត នៅចំពោះមុខអង្គជំនុំជម្រះ រហូតទាល់តែវិធានការការពារទាំងនោះត្រូវបានលុបចោល ឬអស់សុពលភាព[1105]។ ភាគីអាចស្នើសុំឱ្យកែប្រែវិធានការការពារ ឬសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចកែប្រែវិធានការការពារតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន[1106]។ ការកែប្រែ ឬការលុបចោលអាចធ្វើឡើង នៅពេលដែលអាចធ្វើទៅបាន ដោយមានការយល់ព្រមពីបុគ្គលដែលត្រូវការពារ[1107]។

### ៥.២.៣. សាក្សីជំនាញ

តួនាទីរបស់សាក្សីជំនាញគឺត្រូវ "ផ្ដោតទៅលើចំណេះដឹងផ្នែកជំនាញ ដែលវាជាជំនាញ ឬចំណេះដឹងដែលទទួលតាមរយៈការបណ្ដុះបណ្ដាល ឬតាមរយៈការស្រាវជ្រាវ ដែលមតិយោបល់របស់អ្នកជំនាញនេះ

---

[1092] ដូចខាងលើ កថាខណ្ឌ ៣.២(គ)។
[1093] ដូចខាងលើ កថាខណ្ឌ ៣.២(ឃ)។
[1094] ដូចខាងលើ កថាខណ្ឌ ៣.១(ក)។
[1095] ដូចខាងលើ កថាខណ្ឌ ៣.១(ខ)។
[1096] វិធានផ្ទៃក្នុង វិធាន ២៩(៧)។ សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ កថាខណ្ឌ ៣.១(ខ)។
[1097] សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ កថាខណ្ឌ ៣.១(ឃ)។ សូមមើល វិធានផ្ទៃក្នុង វិធាន ២៩(៤)(ខ)។
[1098] វិធានផ្ទៃក្នុង វិធាន ២៩(២) (៤)(ក)។
[1099] វិធានផ្ទៃក្នុង វិធាន ២៩(៤)(ខ)។
[1100] វិធានផ្ទៃក្នុង វិធាន ២៩(៤)(គ)។ ការផ្ដន្ទាទោសមិនអាចផ្អែកទាំងស្រុងលើចម្លើយដែលផ្ដល់ឱ្យដោយមិនមានអត្តសញ្ញាណនោះឡើយ។ សូមមើល វិធានផ្ទៃក្នុង វិធាន ២៩(៦)។
[1101] វិធានផ្ទៃក្នុង វិធាន ២៩(៥)។ សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ កថាខណ្ឌ ២.៦។
[1102] វិធានផ្ទៃក្នុង វិធាន ២៩(៥)។
[1103] វិធានផ្ទៃក្នុង វិធាន ២៩(៣) (យោងទៅកាន់ កាដាក់បញ្ជីសាក្សីនៅក្នុងវិធាន ៨០ នៃផ្ទៃក្នុង)។
[1104] វិធានផ្ទៃក្នុង វិធាន ៧៤(៤)។
[1105] សេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ កថាខណ្ឌ ៤.១។
[1106] ដូចខាងលើ កថាខណ្ឌ ៤.៣។
[1107] ដូចខាងលើ កថាខណ្ឌ ៤.៤។ សូមមើលឧទាហរណ៍ សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ សុំលុបវិធានការពារ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ឯកសារ F23/1 (ការលុបចោលវិធានការការពារសម្រាប់ E2/62 បន្ទាប់ពីការពិភាក្សារវាងបុគ្គលនោះជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

ជួយដល់អង្គជំនុំជម្រះឱ្យបានយល់ដឹងអំពីភ័ស្តុតាងនានាដែលបានបង្ហាញ”[1108]។ បទប្បញ្ញត្តិទូទៅដែលលើកឡើងអំពីភ័ស្តុតាងរបស់អ្នកជំនាញមានចែងនៅក្នុងវិធាន ៣១ នៃវិធានផ្ទៃក្នុង ដោយវិធាន ៣២ លើកឡើងអំពីការតែងតាំងអ្នកជំនាញវេជ្ជសាស្ត្រ ដើម្បីកំណត់ថាតើជនត្រូវចោទ ឬជនជាប់ចោទមានសម្បទាក្នុងការចូលរួមការជំនុំជម្រះឬទេ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចស្នើសុំមតិយោបល់របស់អ្នកជំនាញ លើប្រធានបទណាមួយ ដែលខ្លួនយល់ឃើញថាចាំបាច់ចំពោះការស៊ើបអង្កេត ឬកិច្ចដំណើរការនីតិវិធី[1109]។

អ្នកជំនាញត្រូវបានតែងតាំងតាមរយៈ ដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ[1110]។ អនុលោមតាមវិធាន ៨០*ស្ទួន*(២) នៃវិធានផ្ទៃក្នុង “នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ការស្តាប់ [...] អ្នកជំនាញដែលត្រូវបានស្នើសុំនឹងមិននាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឱ្យកោះហៅបុគ្គលនោះ” ។

អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភ័ស្តុតាងអ្នកជំនាញ ក្នុងសំណុំរឿង ០០១[1111] ០០២/០១[1112] និង ០០២/០២[1113] ដូចជា បរិបទប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធ និងគោលនយោបាយរដ្ឋ លក្ខខណ្ឌនៃការឃុំខ្លួន និងផលប៉ះពាល់ផ្នែកផ្លូវចិត្តនៃឧក្រិដ្ឋកម្ម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងភ័ស្តុតាងកោសល្យវិច្ច័យ[1114]។ អង្គជំនុំជម្រះសាលាដំបូងពិចារណាលើអង្គហេតុដែលថា នៅសាលាក្តីកូនកាត់ ឬសាលាក្តីអន្តរជាតិផ្សេងទៀត អ្នកជំនាញគឺជាបុគ្គលដែល “មានជំនាញពាក់ព័ន្ធ ឬមានចំណេះដឹងឯកទេស ដែលទទួលបានតាមរយៈការអប់រំ បទពិសោធន៍ ឬការបណ្តុះបណ្តាលនៅក្នុងវិស័យជំនាញដែលបានស្នើសុំ”។ ជាងនេះទៀត ការជាប់ពាក់ព័ន្ធពីមុនជាមួយនឹងអង្គការខាងក្រៅណាមួយនោះ ពុំមែនជាការរារាំងដល់ការកោះហៅបុគ្គលរូបនេះមកធ្វើជាអ្នកជំនាញនោះទេ[1115]។ ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភ័ស្តុតាងអ្នកជំនាញ ក្នុងការវាយតម្លៃលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ ដោយសន្និដ្ឋានផ្អែកលើមូលដ្ឋាននៃរបាយការណ៍របស់អ្នកជំនាញថា អៀង ធីរិទ្ធ មិនមានសម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះ ដោយបានផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ និងបានបង្គាប់ឱ្យដោះលែងគាត់ដោយឥតលក្ខខណ្ឌ[1116]។

សាក្សីជំនាញដែលត្រូវបានជ្រើសរើស ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមការសមស្រប[1117]។ ប្រសិនបើពួកគេមិនគោរពតាមពេលវេលាកំណត់ ដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះទេនោះ អ្នកជំនាញថ្មីអាចត្រូវបានតែងតាំងជំនួសពួកគេ[1118]។ ប្រសិនបើចាំបាច់ អ្នកជំនាញច្រើនអាចត្រូវបានតែងតាំង ដែលអ្នកជំនាញទាំងនោះត្រូវធ្វើរបាយការណ៍ដាច់ដោយឡែកពីគ្នា ក្នុងករណីដែលមានមតិយោបល់មិនស្របគ្នា[1119]។ ប្រសិនបើចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អ្នកជំនាញអាចចូលមើលភ័ស្តុតាងជាក់លាក់នៅក្នុងសំណុំរឿង លើកលែងតែក្នុងករណីដែលការចូលមើលបែបនេះ អាចបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ ឬសាក្សី ឬផ្ទុយទៅនឹងវិធានការការពារ ដែល

---

[1108] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៥។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ឯកសារ E215 កថាខណ្ឌ ១៦។
[1109] វិធានផ្ទៃក្នុង វិធាន ៣១(១)។
[1110] វិធានផ្ទៃក្នុង វិធាន ៣១(៣)។
[1111] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៥។
[1112] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣០។
[1113] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ១៣។
[1114] ដូចខាងលើ កថាខណ្ឌ ២៨៥ កថាខណ្ឌ ២៥៣០ និង កថាខណ្ឌ ២៥៣៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៥៧ កថាខណ្ឌ៣៤៨ និងកថាខណ្ឌ៨៣៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៨ កថាខណ្ឌ១០២-១០៣ និងកថាខណ្ឌ២៥៩។ សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៣១៩ កថាខណ្ឌ១៣២២-១៣២៤។
[1115] សំណុំរឿង ០០២ សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ឯកសារ E215 កថាខណ្ឌ ១៥។
[1116] សំណុំរឿង ០០២ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ E138 កថាខណ្ឌ ១ និងកថាខណ្ឌ៨០-៨១។
[1117] វិធានផ្ទៃក្នុង វិធាន ៣១(៤)។
[1118] វិធានផ្ទៃក្នុង វិធាន ៣១(៥)។
[1119] វិធានផ្ទៃក្នុង វិធាន ៣១(៩)។

ត្រូវបានបង្គាប់តាមវិធាន ២៩ នៃវិធានផ្ទៃក្នុង[1120]។ ប្រសិនបើចាំបាច់សម្រាប់ការបំពេញភារកិច្ចរបស់ខ្លួន អ្នកជំនាញក៏អាចអនុញ្ញាតឱ្យចូលរួមក្នុងការសម្ភាសសាក្សី ជនត្រូវចោទ ជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ[1121] ឬធ្វើការសម្ភាសបែបនោះ[1122]។

សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់ពួកគេ ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញបន្ថែម ដើម្បីធ្វើការត្រួតពិនិត្យជាថ្មី ឬធ្វើការត្រួតពិនិត្យឡើងវិញ លើបញ្ហាណាមួយដែលធ្វើរួចហើយ ដែលមានក្នុងរបាយការណ៍អ្នកជំនាញមុន[1123]។ សំណើនេះត្រូវសម្រេចឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និង ក្នុងករណីណាក៏ដោយ មុនពេលបញ្ចប់ការស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធី[1124]។

ប្រសិនបើសហចៅក្រមស៊ើបអង្កេតបដិសេធសំណើបែបនេះ សេចក្តីសម្រេចនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ[1125]។ នៅក្នុងការពិចារណាលើសំណើរបស់ អៀង សារី សុំឱ្យចាត់តាំងអ្នកជំនាញម្នាក់ដើម្បីវាយតម្លៃសម្បទារបស់គាត់ផ្ទាល់ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចលើសំណើនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បង្កើតបានជាការបដិសេធតាមការសន្និដ្ឋានលើសំណើសុំ ដែលការណ៍នេះបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍[1126]។

អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង ក្នុងគោលបំណងដើម្បីបញ្ជាក់ថា ជនត្រូវចោទ ឬជនជាប់ចោទមានសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តី ឬដោយសារហេតុផលផ្សេងទៀត ឬតាមការស្នើសុំរបស់ភាគី សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចបង្គាប់ឱ្យពួកគេទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ វិកលចរិត ចិត្តសាស្ត្រ ដោយអ្នកជំនាញ[1127]។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាលើសម្បទារបស់ជនត្រូវចោទ ក្នុងការចូលរួមការជំនុំជម្រះ និងបានសន្និដ្ឋានថា ពុំមានភស្តុតាងណាបង្ហាញថា ខ្លួនចាំបាច់ត្រូវចាត់តាំងអ្នកជំនាញផ្នែកវិកលចរិត ដើម្បីវាយតម្លៃ អៀង សារី[1128] ឬ នួន ជា នោះទេ[1129]។

### ៥.២.៤. *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* និង អន្តរាគមន៍

របបដែលអនុញ្ញាតឱ្យមានអន្តរាគមន៍ពី*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មានចែងនៅក្នុងវិធាន ៣៣ នៃវិធានផ្ទៃក្នុង។ វិធាន ៣៣ ចែងថា នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច “បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ” អញ្ជើញ ឬអនុញ្ញាតឱ្យអង្គការ ឬបុគ្គលណាម្នាក់ដាក់ជូននូវសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ជាលាយលក្ខណ៍

[1120] វិធានផ្ទៃក្នុង វិធាន ៣១(៣)។
[1121] វិធានផ្ទៃក្នុង វិធាន ៣១(៦)។
[1122] វិធានផ្ទៃក្នុង វិធាន ៣១(៦)។
[1123] វិធានផ្ទៃក្នុង វិធាន ៣១(១០)។
[1124] វិធានផ្ទៃក្នុង វិធាន ៣១(១០)។
[1125] វិធានផ្ទៃក្នុង វិធាន ៣១(១០)។
[1126] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២៣-២៤។
[1127] វិធានផ្ទៃក្នុង វិធាន ៣២។
[1128] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8។
[1129] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ ឯកសារ D54/V/6។

អក្សរ[1130]។ អន្តរាគមន៍បែបនេះត្រូវអនុញ្ញាត ប្រសិនបើកើតមាន ទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នោះ[1131]។

អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ពីភាពផ្សេងគ្នារវាង *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* និង អន្តរាគមន៍។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បំណងរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*គឺ "ដើម្បីមូលហេតុផលប្រយោជន៍អរូបីលើបញ្ហាជាក់លាក់ណាមួយ ជាជាងក្នុងន័យ ជំរុញ ឬបង្កើតឱ្យមាននូវលទ្ធផលជាក់លាក់ណាមួយទាក់ទងនឹងករណីព្រហ្មទណ្ឌ"[1132]។ ផ្ទុយទៅវិញ អ្នកចូលធ្វើអន្តរាគមន៍ គឺជាបុគ្គលដែលទទួលបានផលប្រយោជន៍បែបនោះ[1133]។ ហេតុដូច្នេះ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គប្បីមិនមានជាប់ពាក់ព័ន្ធជាមួយនឹង អ.វ.ត.ក. ឬការិយាល័យណាមួយរបស់ អ.វ.ត.ក. ឡើយ[1134]។

សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អាចត្រូវបានស្នើសុំលើបញ្ហាណាមួយ ហើយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការកំណត់ពេលវេលាឱ្យដាក់សារណាទាំងនេះ ប្រសិនបើត្រូវធ្វើ[1135]។ ដោយអនុវត្តតាមគោលការណ៍ស្រដៀងគ្នានេះទៅនឹងគោលការណ៍ដែលអនុម័តដោយសាលាក្តី *មិនអចិន្ត្រៃយ៍* អ.វ.ត.ក. បានបញ្ជាក់ថា បុគ្គល ឬស្ថាប័នជាច្រើនអាចដើរតួជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។ គោលបំណងចម្បងនៃ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*នៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ គឺត្រូវផ្តល់ជំនួយដល់ការធ្វើសេចក្តីសម្រេចនៅក្នុងរឿងក្តី និង "ជាពិសេសបញ្ហាច្បាប់ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន" ដែល*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*មានខ្លឹមសារបន្ថែមទៅលើអំណះអំណាងនានាដែលបានទទួលពីភាគីនៃកិច្ចដំណើរការនីតិវិធីទាំងអស់នោះ[1136]។

សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ត្រូវបានអញ្ជើញឱ្យដាក់ដោយសហចៅក្រមស៊ើបអង្កេត (ភាគច្រើនទៅលើនិយមន័យនៃ "ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល" សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក.)[1137] និងដោយអង្គបុរេជំនុំជម្រះ (លើបញ្ហានានាដូចជា សហឧក្រិដ្ឋកម្មរួម ("JCE"))[1138]។ អង្គជំនុំជម្រះសាលាដំបូងក៏បានអនុញ្ញាតឱ្យដាក់សារណាលើបញ្ហាវិនិច្ឆ័យនានា ដូចជា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[1139]។

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើមួយពីផ្នែកគាំពារការការពារក្តី សុំឱ្យមានសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* លើបញ្ហានានាដែលបានលើកឡើងដោយជនជាប់ចោទ និងសហ

---

[1130] វិធានផ្ទៃក្នុង វិធាន ៣៣ (១)។

[1131] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១២។

[1132] ដូចខាងលើ កថាខណ្ឌ ៩។

[1133] ដូចខាងលើ កថាខណ្ឌ ១១។

[1134] ដូចខាងលើ កថាខណ្ឌ ៩។ សូមមើល សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីសំណើរបស់អង្គភាពគាំពារការការពារក្តី សុំឱ្យអង្គជំនុំជម្រះតុលាការកំពូល អញ្ជើញភាគីទីបីដែលឯករាជ្យ ដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០១១ ឯកសារ F16/3 កថាខណ្ឌ ៩។

[1135] វិធានផ្ទៃក្នុង វិធាន ៣៣(១)។

[1136] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ F20/1 កថាខណ្ឌ ៨។

[1137] សូមមើលឧទាហរណ៍ សំណុំរឿង ០០៣ និងសំណុំរឿង ០០៤ សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D191។

[1138] សូមមើលឧទាហរណ៍ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សារណា របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/17។ សំណុំរឿង ០០១ សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ D99/3/12។

[1139] សូមមើលឧទាហរណ៍ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E418/3។

មេធាវីរបស់ខ្លួន ប៉ុន្តែតាមការយល់ឃើញរបស់ពួកគេមិនត្រូវបានដោះស្រាយត្រឹមត្រូវ[1140]។ អង្គបុរេជំនុំជម្រះបានបដិសេធសំណើមិនមានការអញ្ជើញ សុំដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទាក់ទងនឹងការជាប់ពាក់ព័ន្ធនៃការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក. ក្នុងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[1141]។

ជនត្រូវចោទមានបំណងដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* (ហៅម្យ៉ាងទៀត សារណា "អន្តរាគមន៍") នៅក្នុងរឿងក្តីផ្សេងទៀត។ មិនមានបទប្បញ្ញត្តិជាក់លាក់នៅក្នុងក្របខ័ណ្ឌ អ.វ.ត.ក. ឬនៅសាលាក្តី និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ទាក់ទងនឹងការទទួលយកជនត្រូវចោទជា "អ្នកធ្វើអន្តរាគមន៍" នៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ[1142]។

ក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានបដិសេធសំណើរបស់ជនត្រូវចោទ ក្នុងការធ្វើសេចក្តីសន្និដ្ឋានលើភាពអាចអនុវត្តបាននៃ JCE នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១[1143]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា វិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យមានសារណាអន្តរាគមន៍ពីតតិយជនលើបញ្ហានានា ដែលលើកឡើងនៅបណ្តឹងឧទ្ធរណ៍នោះឡើយ ដោយបានបដិសេធសំណើ ដោយសារតែជនត្រូវចោទមិនត្រូវបានចោទប្រកាន់ថាជាសមាជិក JCE ក្នុងសំណុំរឿង ០០១ ហើយសេចក្តីសម្រេចនឹងមិនអនុវត្តដោយផ្ទាល់លើជនត្រូវចោទនោះទេ[1144]។ ទោះបីជាការសម្រេចផ្លូវច្បាប់អាចផ្តល់ការណែនាំនៅក្នុងរឿងក្តីនាពេលខាងមុខ ក៏វាមិនមានន័យថាជនត្រូវចោទមានសិទ្ធិធ្វើអន្តរាគមន៍ក្នុងរឿងក្តី ដែលពួកគេមិនមែនជាភាគីនោះឡើយ[1145]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើចំនួនពីរ ក្នុងសំណុំរឿង ០០៣ និង ០០៤ ស្នើសុំអន្តរាគមន៍ លើបញ្ហាបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៥/០២[1146]។

### ៥.២.៥. ការដាក់ឯកសារ

[1140] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីសំណើរបសើអង្គភាពគាំពារការការពារក្តី សុំឱ្យអង្គជំនុំជម្រះតលាការកំពូល អញ្ជើញភាគីទីបីដែលឯករាជ្យ ដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០១១ ឯកសារ F16/3។

[1141] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/1/14។

[1142] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬសុំដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១០។

[1143] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ "ឌុច" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/19។ សូមមើល សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរួមរបស់ក្រុមមេធាវីការពារក្តី សុំចូលអន្តរាគមន៍ជាបន្ទាន់ចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ឌុច" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D99/3/31។

[1144] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ "ឌុច" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ៨-៩ និងកថាខណ្ឌ ១១-១៣។ សូមមើលសេចក្តីសម្រេចលើសំណើរួមរបស់ក្រុមមេធាវីការពារក្តី សុំចូលអន្តរាគមន៍ជាបន្ទាន់ចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ឌុច" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D99/3/31 កថាខណ្ឌ ៥-៦។

[1145] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ "ឌុច" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ១៤។ សូមមើលសេចក្តីសម្រេចលើសំណើរួមរបស់ក្រុមមេធាវីការពារក្តី សុំចូលអន្តរាគមន៍ជាបន្ទាន់ចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ឌុច" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D99/3/31 កថាខណ្ឌ ៨។

[1146] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ ស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ឯកសារ E004/2/4/1 ទំព័រ ២-៣។ សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ និងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើអានុភាពដែលនាំឱ្យបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ឯកសារ E004/2/2/1 ទំព័រ ២-៣។

បទប្បញ្ញត្តិនីតិវិធីដែលគ្រប់គ្រងលើការដាក់ឯកសារ មានចែងជាទូទៅនៅក្នុងសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ និងវិធាន ៣៩ នៃវិធានផ្ទៃក្នុង[1147]។ វិធាន ៧៥ ចែងដាក់លាក់អំពីកាលបរិច្ឆេទកំណត់សម្រាប់សារណា ដែលដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយវិធាន ១០៧ ចែងជាក់លាក់អំពីកាលបរិច្ឆេទកំណត់សម្រាប់សារណា ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[1148]។ ភាគីទៅនឹងកិច្ចដំណើរការនីតិវិធីតែងតែស្នើសុំបន្ថែមរយៈពេល និងចំនួនទំព័រកំណត់ ឬការអនុញ្ញាតដាក់ក្រៅកាលបរិច្ឆេទកំណត់ ដែលការណ៍នេះត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈមួយចំនួន[1149]។

### ៥.២.៦. ទម្រង់ ខ្លឹមសារ ភាសា និងការដាក់ឯកសារ

ការដាក់ឯកសារត្រូវតែធ្វើឡើងក្នុងទម្រង់ ដែលមានចែងនៅក្នុងសេចក្ដីណែនាំអនុវត្ត[1150]។ ឯកសារណាដែលត្រូវដាក់ត្រូវមានចំណាត់ប្រភេទត្រឹមត្រូវ ("សាធារណៈ" "សម្ងាត់" ឬ "សម្ងាត់បំផុត") ដូចដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលពាក់ព័ន្ធ[1151]។ ក្នុងករណីដែលការដាក់ឯកសារដែលបានកំណត់ប្រភេទជាឯកសារ "សាធារណៈ" ភាគីមានការទទួលខុសត្រូវលើការកំណត់ថាឯកសារនោះមិនមានព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុតនោះទេ និងត្រូវប្រាកដថាការដាក់ឯកសារដែលកំណត់ប្រភេទជាឯកសារ "សម្ងាត់" ភាគីមានការទទួលខុសត្រូវលើការកំណត់ថាឯកសារនោះមិនមានព័ត៌មានសម្ងាត់បំផុតនោះទេ[1152]។

ឯកសារដែលបានដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវមួយចំនួន ទាក់ទងនឹងខ្លឹមសារនៃការដាក់ឯកសារនោះ[1153]។ ឯកសារត្រូវរួមបញ្ចូលមូលដ្ឋានគតិយុត្តិ និងកម្មវត្ថុដែលស្នើសុំ សេចក្ដីសង្ខេបមូលដ្ឋាននៃអំណះអំណាង សេចក្ដីសង្ខេបអង្គហេតុ នីងកាលប្បវត្តិ សេចក្ដីសង្ខេបអត្ថបទគតិយុត្តិដែលពាក់ព័ន្ធ នឹងអំណះអំណាងច្បាប់លម្អិត[1154] ក៏ដូចជាបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលផ្អែកលើដោយអ្នកដាក់ឯកសារ[1155]។

ជាទូទៅ ឯកសារត្រូវដាក់ជាអេឡិចត្រូនិក លើកលែងតែក្នុងកាលៈទេសៈពិសេស[1156]។ ឯកសារជាទូទៅត្រូវដាក់ជាភាសាខ្មែរ ក៏ដូចជាភាសាអង់គ្លេស ឬបារាំង[1157]។ ក្នុងករណីពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះពាក់ព័ន្ធអាចអនុញ្ញាតឱ្យភាគី ដាក់ឯកសារជាភាសាបារាំង ឬអង់គ្លេសបាន ក្នុងលក្ខខណ្ឌដែលថាសំណៅបកប្រែជាភាសាខ្មែរត្រូវដាក់យ៉ាងឆាប់បំផុត[1158]។ យ៉ាងណាមិញ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចលើសំណើសុំបន្ថែមចំនួនពាក្យកំណត់ ដោយមិនមាន

---

[1147] វិធានផ្ទៃក្នុង វិធាន ៣៩។
[1148] វិធានផ្ទៃក្នុង វិធាន ៧៥ និង ១០៧។
[1149] សូមមើលឧទាហរណ៍ សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្ដឹងសារទុក្ខរបស់ខ្លួន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ F5/2។ សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច សុំពន្យារពេលកំណត់សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ F6/2។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រសារណាតបទៅនឹងសារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២០ ឯកសារ F55/3។
[1150] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ មាត្រា ៣.២ និង ឧបសម្ព័ន្ធ ខ។
[1151] ដូចខាងលើ មាត្រា ៣.១២-៣.១៤។
[1152] ដូចខាងលើ មាត្រា ៣.១៣។
[1153] សូមមើល ដូចខាងលើ មាត្រា ៤។
[1154] ដូចខាងលើ មាត្រា ៤.១។
[1155] ដូចខាងលើ មាត្រា ៤.២ និងមាត្រា ៦។
[1156] ដូចខាងលើ មាត្រា ២.៥។ ការដាក់ឯកសារដោយដៃ អាចធ្វើទៅបានលុះត្រាតែផ្នែកបច្ចេកទេសមានបញ្ហា ឬក្នុងករណីដាក់ឯកសារដូចជាផែនទី រូបថត ឬស៊ីឌីប៉ុណ្ណោះ។
[1157] ដូចខាងលើ មាត្រា ៧.១។
[1158] ដូចខាងលើ មាត្រា ៧.២។

ការបកប្រែជាភាសាខ្មែរ ឬអង់គ្លេស ដោយផ្អែកលើការបកប្រែក្រៅផ្លូវការ "ដើម្បីប្រយោជន៍នៃការពន្លឿននីតិវិធី និងភាពត្រឹមត្រូវយុត្តិធម៌ដល់ភាគីទាំងអស់"[1159]។

### ៥.២.៧. ពាក្យ និងទំព័រកំណត់ (កម្រាស់ឯកសារ)

ឯកសារដែលដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសាលាដំបូង ជាទូទៅមិនអាចលើសពី ១៥ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ឬ ៣០ ទំព័រ ជាភាសាខ្មែរ[1160]។ ទាក់ទងនឹងការដាក់ឯកសារតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ដែលចែងថាភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររហូតដល់សេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលនៅសវនាការ ចំនួនទំព័រមិនអាចលើស ១០០ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ឬ ២០០ ទំព័រជាភាសាខ្មែរ[1161]នោះទេ។ មិនមានការកំណត់ចំនួនទំព័រសម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម តាមវិធាន ៥៥ នៃវិធានផ្ទៃក្នុង ឬដីកាសន្និដ្ឋានស្ថាពរ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងនោះទេ[1162]។

តាមការស្នើសុំរបស់ភាគីចូលរួម សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុង "កាលៈទេសៈពិសេស"[1163]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "តុលាការព្រហ្មទណ្ឌអន្តរជាតិដែលកាត់សេចក្តីចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ និងទំហំស្រដៀងគ្នានឹង អ.វ.ត.ក. ក៏បានអនុញ្ញាតផ្តល់ចំនួនទំព័រ (ឬចំនួនពាក្យពេចន៍)ច្រើនជាង សម្រាប់បណ្តឹងប្រឆាំងនឹងសាលក្រមផងដែរ"[1164]។ ជាលទ្ធផល ដោយពិចារណាលើទំហំ និងភាពស្មុគស្មាញនៃសាលក្រមនៅ អ.វ.ត.ក. "កាលៈទេសៈពិសេសមានអត្ថិភាព ដែលតម្រូវឱ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រ"[1165]។ ទោះជាយ៉ាងណា កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅ អ.វ.ត.ក. មានលក្ខណៈខុសគ្នាពីសាលាក្តីអន្តរជាតិ(អន្តរជាតូបនីយកម្ម)ផ្សេងទៀត ដោយសារយុត្តាធិការបណ្តឹងសាទុក្ខមានលក្ខណៈរឹតត្បិតជាង[1166]។ ដោយពិចារណាលើកត្តានេះ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតផ្តល់ការបន្ថែមចំនួនទំព័រ ៣៥ ទំព័រជាអតិបរមា ទៅលើសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០១[1167] ប៉ុន្តែយល់ឃើញថា សំណើរបស់ ខៀវ សំផន ស្នើសុំការកំណត់ចំនួនទំព័របន្ថែមចំនួន ៩២០ ទំព័រ គឺមានលក្ខណៈច្រើនហួសហេតុពេក[1168]។

ក្នុងសំណុំរឿង ០០២/០២ ការប៉ុនប៉ងរបស់ ខៀវ សំផន ក្នុងការដាក់បញ្ចូលតាមរយៈការយោងទៅសេចក្តីសន្និដ្ឋាននានាដែលបានធ្វើនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ក្នុងសំណុំរឿង ០០២/០១ ត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើមូលហេតុថា "វិធីសាស្ត្រនេះ គឺជាការព្យាយាមដែលពុំត្រូវបានអនុញ្ញាតនោះឡើយ ព្រោះវាបានធ្វើឡើងដើម្បីរួចផុតពីការកម្រិតចំនួនទំព័រ ដែលអង្គជំនុំជម្រះបាន

---

[1159] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រសារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ឯកសារ F55/3 កថាខណ្ឌ ១៩។

[1160] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៥.១។

[1161] ដូចខាងលើ មាត្រា ៥.៣។

[1162] ដូចខាងលើ មាត្រា ៥.៥។

[1163] ដូចខាងលើ មាត្រា ៥.៤។

[1164] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ F5/2 កថាខណ្ឌ ៧។

[1165] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49 កថាខណ្ឌ ១៤។

[1166] ដូចខាងលើ កថាខណ្ឌ ១៦។

[1167] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ F5/2 កថាខណ្ឌ ៨។ សូមមើល សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រសារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ឯកសារ F55/3។

[1168] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49 កថាខណ្ឌ ១៥ និង ៣៦។

កំណត់ចំពោះសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីនានា”[1169]។ បន្ទាប់មក សេចក្តីសន្និដ្ឋានទាំងអស់នេះ ត្រូវបានដកចេញពីការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង[1170]។

### ៥.២.៨. ការកំណត់ពេលវេលា

លើកលែងតែមានចែងផ្សេងពីនេះ ពាក្យសុំ ឬសារណា ត្រូវដាក់យ៉ាងហោចណាស់ ៣០ ថ្ងៃ នៃប្រតិទិន មុនថ្ងៃសវនាការ[1171] ឬ ក្នុងករណីចម្លើយតបណាមួយទៅនឹងពាក្យសុំ ឬសារណា ក្នុងរយៈពេល ១០ ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃឯកសារ ដែលអ្នកចូលរួមត្រូវឆ្លើយតប[1172]។ ការឆ្លើយតបទៅនឹងចម្លើយតបអនុញ្ញាតឱ្យតែក្នុងករណីដែល អំណះអំណាងផ្ទាល់មាត់មិនត្រូវបានធ្វើឡើង ហើយត្រូវដាក់ក្នុងរយៈពេលប្រាំថ្ងៃនៃប្រតិទិន គិតចាប់ពីថ្ងៃជូនដំណឹងអំពីចម្លើយតប ដែលអ្នកចូលរួមត្រូវឆ្លើយតប[1173]។

ការកំណត់ពេលវេលាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ច្បាប់ជាធរមាន និងសេចក្តីណែនាំអនុវត្ត និងក្នុងករណីសមស្រប សេចក្តីសម្រេចតុលាការ ត្រូវតែគោរព[1174]។ លើកលែងតែមានចែងផ្សេងពីនេះដោយវិធានផ្ទៃក្នុង និងក្នុងការអនុវត្តតាមសេចក្តីណែនាំអនុវត្ត ចៅក្រមអាចកំណត់ពេលវេលាជាក់លាក់សម្រាប់ការដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារនានាទាក់ទងនឹងសំណើ ឬបណ្តឹងឧទ្ធរណ៍/សាទុក្ខ ដោយពិចារណាលើកាលៈទេសៈនៃរឿងក្តី ជាពិសេសថាតើជនត្រូវចោទ ឬ ជនជាប់ចោទស្ថិតក្នុងការឃុំខ្លួន ឬទេ[1175]។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមរយៈសំណើពីភាគីពាក់ព័ន្ធ ឬតាមរយៈគំនិតផ្តួចផ្តើមរបស់ខ្លួន អាចពន្យារពេលវេលាកំណត់ ឬទទួលស្គាល់សុពលភាពនៃកិច្ចទាំងឡាយដែលបានធ្វើឡើងក្រោយពេលវេលាកំណត់[1176]។

ក្នុងករណីដែលមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត តាមវិធាន ៧១ ឬ ៧២ នៃវិធានផ្ទៃក្នុង[1177] ការកំណត់ពេលវេលាអាចត្រូវពន្យារ រហូតដល់មានការព្រមព្រៀងគ្នាណាមួយ ក្នុងរយៈពេលពាក់ព័ន្ធ ៣០ ថ្ងៃ បានផុតរលត់ ឬ អង្គបុរេជំនុំជម្រះបានទទួលយកករណីខ្វែងយោបល់គ្នានេះ ហើយអង្គបុរេបានបញ្ចប់សេចក្តីពិចារណារបស់ខ្លួនលើបញ្ហានេះ ទៅតាមករណីសមស្រប[1178]។

វិធាន ៧៥ នៃវិធានផ្ទៃក្នុងគូសបញ្ជាក់ពេលវេលាសម្រាប់បណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អង្គបុរេជំនុំជម្រះ។ ជាទូទៅ ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេច ឬដីកា ដែលរងការជំទាស់[1179] ហើយសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៣០ ថ្ងៃ នៃកាលបរិច្ឆេទនោះ[1180]។ ការកំណត់ពេលវេលាអាចត្រូវបានពន្យារតាមកាលៈទេសៈពិសេស[1181]។ សេចក្តីសន្និដ្ឋានបណ្តឹងឧទ្ធរណ៍ត្រូវតែមានអំណះអំណាងអង្គហេតុ និងអង្គច្បាប់ ដែលបណ្តឹងឧទ្ធរណ៍ផ្អែកលើ ហើយ នៅក្នុងអំឡុងពេលសវនាការ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចលើកបញ្ហាអង្គហេតុ ឬអង្គច្បាប់ដែលមិនមាននៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបានឡើយ[1182]។ ក្នុងករណីសេចក្តីសម្រេចរបស់អង្គជំនុំ

---

[1169] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៧០៥។
[1170] ដូចខាងលើ។
[1171] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.២។
[1172] ដូចខាងលើ មាត្រា ៨.៣។
[1173] ដូចខាងលើ មាត្រា ៨.៤។
[1174] វិធានផ្ទៃក្នុង វិធាន ៣៩(១)។
[1175] វិធានផ្ទៃក្នុង វិធាន ៣៩(២)។
[1176] វិធានផ្ទៃក្នុង វិធាន ៣៩(៤)។
[1177] វិធានផ្ទៃក្នុងបង្ហាញអំពីនីតិវិធីដែលត្រូវអនុវត្តតាម ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (វិធាន៧១) និងសហចៅក្រមស៊ើបអង្កេត (វិធាន៧២)។
[1178] វិធានផ្ទៃក្នុង វិធាន ៣៩(៥)។
[1179] វិធានផ្ទៃក្នុង វិធាន ៧៥(១)។
[1180] វិធានផ្ទៃក្នុង វិធាន ៧៥(៣)។
[1181] វិធានផ្ទៃក្នុង វិធាន ៧៥(៣)។
[1182] វិធានផ្ទៃក្នុង វិធាន ៧៥(៤)។

ជម្រះសាលាដំបូងដែលអាចប្តឹងសាទុក្ខបានភ្លាមៗ បណ្តឹងសាទុក្ខនោះត្រូវដាក់ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទរបស់សេចក្តីសម្រេច ឬសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចនោះ[1183]។ ប្រសិនបើសេចក្តីសម្រេចស្ថិតក្រោមបណ្តឹងសាទុក្ខភ្លាមៗ និងទាក់ទងនឹងការឃុំខ្លួន ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬវិធានការការពារ បណ្តឹងសាទុក្ខភ្លាមៗនោះត្រូវដាក់ក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេច ឬសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេច[1184]។

អនុលោមតាមវិធាន ១០៧ នៃវិធានផ្ទៃក្នុង សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខទាក់ទងនឹងសាលក្រមជំនុំជម្រះ ត្រូវដាក់ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេចនោះ ឬការជូនដំណឹងអំពីសេចក្តីសម្រេច[1185]។ បន្ទាប់មក សារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល ៦០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីបណ្តឹងសាទុក្ខ[1186]។ នៅពេលដែលភាគីបានប្តឹងសាទុក្ខ ភាគីផ្សេងទៀតមានពេលបន្ថែមចំនួន ១៥ ថ្ងៃ ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[1187]។ ការកំណត់ពេលវេលាទាំងនេះក៏អាចត្រូវបានពន្យារពេលផងដែរ។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកសំណើរបស់មេធាវីការពារក្តី ស្នើសុំពន្យារពេលវេលាកំណត់ សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខមួយប្រឆាំងនឹងសាលក្រម រយៈពេល ៣០ ថ្ងៃ ដោយយោងទៅលើកម្រាស់ និងភាពស្មុគស្មាញនៃបញ្ហានានាដែលបានលើកឡើង[1188]។

### ៥.៣. ការចោទប្រកាន់

ការចោទប្រកាន់ណាមួយពីបទឧក្រិដ្ឋស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវតែផ្តួចផ្តើមឡើងដោយសហព្រះរាជអាជ្ញា តាមការផ្តួចផ្តើមរបស់ខ្លួន ឬក្រោយពីទទួលបានបណ្តឹងមួយ ឬច្រើន[1189]។ សហព្រះរាជអាជ្ញា "ទទួលខុសត្រូវតែម្នាក់ឯងគត់លើការដាក់បណ្តឹងអាជ្ញាចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. តាមឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមមូលដ្ឋាននៃពាក្យបណ្តឹង"[1190]។ បុគ្គល អង្គការ ឬប្រភពផ្សេងទៀតណាក៏ដោយ ដែលបានឃើញ ឬគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់ ឬបានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ អាចដាក់ពាក្យបណ្តឹងបាន[1191]។ មេធាវី ឬសមាគមជនរងគ្រោះអាចរៀបចំ និង/ឬ ដាក់ពាក្យបណ្តឹងតំណាងឱ្យជនរងគ្រោះ[1192]។

ពាក្យបណ្តឹងមិនផ្តួចផ្តើមជាស្វ័យប្រវត្តិឱ្យមានការចោទប្រកាន់ទេ។ វិធាន ៤៩(៤) នៃវិធានផ្ទៃក្នុងផ្តល់ឆន្ទានុសិទ្ធិឱ្យសហព្រះរាជអាជ្ញាបដិសេធពាក្យបណ្តឹង បញ្ចូលពាក្យបណ្តឹងនៅក្នុងការស៊ើបអង្កេតបឋមដែលកំពុងធ្វើ ធ្វើការស៊ើបអង្កេតបឋមថ្មី ឬបញ្ជូនបន្តនូវពាក្យបណ្តឹងនោះទៅសហចៅក្រមស៊ើបអង្កេត។ សហព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកដាក់បណ្តឹងអំពីការសម្រេចរបស់ខ្លួនទាក់ទងនឹងបញ្ហានេះ ឱ្យ

---

[1183] វិធានផ្ទៃក្នុង វិធាន ១០៧(១)។

[1184] វិធានផ្ទៃក្នុង វិធាន ១០៧(២)។

[1185] វិធានផ្ទៃក្នុង វិធាន ១០៧(៤)។

[1186] វិធានផ្ទៃក្នុង វិធាន ១០៧(៤)។

[1187] វិធានផ្ទៃក្នុង វិធាន ១០៧(៤)។

[1188] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច សុំពន្យារពេលកំណត់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ F6/2 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ១០។

[1189] វិធានផ្ទៃក្នុង វិធាន ៤៩(១)។

[1190] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ៥១។ សូមមើល ច្បាប់ អ.វ.ត.ក មាត្រា ១៦។ វិធានផ្ទៃក្នុង វិធាន ៤៩(១)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ៣៨។

[1191] វិធានផ្ទៃក្នុង វិធាន ៤៩(២)។ សូមមើល សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងក្រុងកែប ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ឯកសារ D392 កថាខណ្ឌ ៥។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តព្រះវិហារ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ឯកសារ D396 កថាខណ្ឌ ៤។

[1192] វិធានផ្ទៃក្នុង វិធាន ៤៩(៣)។

បានឆាប់តាមដែលអាចធ្វើទៅបាន ហើយក្នុងគ្រប់ករណីទាំងអស់ មិនត្រូវលើសរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីការចុះពាក្យបណ្តឹងឡើយ[1193]។

យ៉ាងណាមិញ សហព្រះរាជអាជ្ញា អាចកែប្រែសេចក្តីសម្រេចរបស់ខ្លួននៅពេលណាមួយក៏បាន ដែលក្នុងករណីនេះអ្នកដាក់ពាក្យបណ្តឹងត្រូវបានទទួលការជូនដំណឹងក្នុងរយៈពេល ៣០ ថ្ងៃ[1194]។ ការសម្រេចរបស់សហព្រះរាជអាជ្ញាតម្កល់ទុកឥតចាត់ការ មិនមានអានុភាពអាជ្ញាអស់ជំនុំទេ[1195]។ ពាក្យបណ្តឹងណាដែលដាក់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវតែបញ្ជូនភ្លាមៗទៅកាន់សហព្រះរាជអាជ្ញាដើម្បីធ្វើការពិចារណា[1196]។ ក្នុងករណីដែលសហព្រះរាជអាជ្ញាសម្រេចថាតម្កល់ទុកឥតចាត់ការបណ្តឹងណាមួយនៅចុងបញ្ចប់នៃការស៊ើបអង្កេតបឋម អ្នកប្តឹងដែលពាក់ព័ន្ធទាំងអស់ត្រូវតែទទួលបានការជូនដំណឹងអំពីការសម្រេចនេះក្នុងរយៈពេល ៣០ ថ្ងៃ[1197]។

តួនាទីរបស់សហព្រះរាជអាជ្ញាតាមវិធានផ្ទៃក្នុង ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងរឿងក្តី និងការស៊ើបអង្កេតដែលកំពុងធ្វើលើឧក្រិដ្ឋកម្មស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[1198]។ ហេតុដូច្នេះ តួនាទីរបស់ពួកគេមិនពង្រីកជាស្វ័យប្រវត្តិទៅលើបញ្ហានានា ដែលពាក់ព័ន្ធនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និង/ឬ ការប្រព្រឹត្តខុសវិជ្ជាជីវៈរបស់មេធាវីយោងតាមវិធាន ៣៥ និង ៣៨ នៃវិធានផ្ទៃក្នុងឡើយ[1199]។ នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬក៏ហុសវិជ្ជាជីវៈរបស់មេធាវី សហព្រះរាជអាជ្ញាអាចត្រូវបានចាត់តាំងជាអ្នកស៊ើបអង្កេត ប៉ុន្តែមិនមែនជាភាគីមួយដោយស្វ័យប្រវត្តិទៅនឹងបណ្តឹងឧទ្ធរណ៍ណាមួយទាក់ទងនឹងបញ្ហានោះទេ[1200]។

សហព្រះរាជអាជ្ញាមាន "ឆន្ទានុសិទ្ធិទូលំទូលាយក្នុងការបំពេញភារកិច្ចរបស់ខ្លួនទៅតាមច្បាប់"[1201]។ វិធាន ៥០(១) នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេតបឋម ដើម្បីកំណត់ថាតើភស្តុតាងបញ្ជាក់ថា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានប្រព្រឹត្តឡើងឬយ៉ាងណា និងដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីសក្តានុពល[1202]។ អង្គបុរេជំនុំជម្រះបានពិចារណាថា យោងតាមក្របខ័ណ្ឌរបស់ អ.វ.ត.ក. "ការផ្តោតជាចម្បងរបស់សហព្រះរាជអាជ្ញា អំពីការស៊ើបអង្កេតបឋម

---

1193 វិធានផ្ទៃក្នុង វិធាន ៤៩(៤)។

1194 វិធានផ្ទៃក្នុង វិធាន ៤៩(៥)។

1195 វិធានផ្ទៃក្នុង វិធាន ៤៩(៥)។

1196 វិធានផ្ទៃក្នុង វិធាន ៤៩(២)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៤ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/2/4/3 យោបល់ដោយឡែករបស់ចៅក្រម Rowan Downing និងចៅក្រម Katinka Lahuis កថាខណ្ឌ ២។

1197 វិធានផ្ទៃក្នុង វិធាន ៥៣(៦)។

1198 វិធានផ្ទៃក្នុង វិធាន ៤៩ វិធាន៥០ និងវិធាន៥៣។ សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយលបាននៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D138/1/8 កថាខណ្ឌ ១៤។

1199 វិធានផ្ទៃក្នុង វិធាន ៣៥ និង ៣៨។ សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយលបាននៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D138/1/8 កថាខណ្ឌ ១៣-១៤។

1200 សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយលបាននៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D138/1/8 កថាខណ្ឌ ២៥-២៦។

1201 សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ៣៨។

1202 វិធានផ្ទៃក្នុង វិធាន ៥០(១)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ៣៨។

របស់ខ្លួន គឺដើម្បីកំណត់ភ័ស្តុតាងដែលបង្ហាញអំពីការប្រព្រឹត្ត *ឧក្រិដ្ឋកម្ម* ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ចំណែកឯ *អត្តសញ្ញាណជនសង្ស័យ* គឺជាការផ្តោតបន្ទាប់ ឬជាជម្រើស”[1203]។

យោងតាមវិធាន ៥០(២) និង (៣) នៃវិធានផ្ទៃក្នុង នគរបាលយុត្តិធម៌ និង/ឬ អ្នកស៊ើបអង្កេត អ.វ.ត.ក. អាចឆែកឆេរ និងប្រមូលឯកសារ៖ (១) ដោយមានដីកាបង្គាប់ជាលាយលក្ខណ៍អក្សរពីសហព្រះរាជអាជ្ញា និងការព្រមព្រៀងពីម្ចាស់ ឬអ្នកកាន់កាប់ទីតាំង ឬ (២) ដោយមានការអនុញ្ញាតពីប្រធានអង្គបុរេជំនុំជម្រះ ដែលត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដាក់បញ្ចូលក្នុងសំណុំរឿង[1204]។ នៅក្នុងករណីបន្ទាន់ដែល “មិនអាចមានលទ្ធភាព” ផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរភ្លាមៗបាន ប្រធានអង្គបុរេជំនុំជម្រះអាចផ្តល់ការអនុញ្ញាតដោយផ្ទាល់មាត់បាន ដោយមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៤៨ ម៉ោង។ ការឆែកឆេរណាមួយត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ម្ចាស់ ឬអ្នកកាន់កាប់ទីតាំង ឬវត្តមានរបស់សាក្សីពីររូប ដែលបានជ្រើសរើសដោយសហព្រះរាជអាជ្ញា ដែលមិនមែនជាអ្នកស៊ើបអង្កេត ឬជាមន្ត្រីនគរបាលយុត្តិធម៌ ដែលពាក់ព័ន្ធក្នុងការឆែកឆេរនោះ[1205]។

សហព្រះរាជអាជ្ញា តាមរយៈនគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេត អ.វ.ត.ក. អាចកោះហៅ ឬសួរយកចម្លើយបុគ្គលណាម្នាក់ ដែលអាចផ្តល់ព័ត៌មានពាក់ព័ន្ធលើរឿងក្តី ដែលស្ថិតក្រោមការស៊ើបអង្កេត[1206]។ សហព្រះរាជអាជ្ញាត្រូវធ្វើបញ្ជីសារពើភ័ណ្ឌលើសម្ភារៈទាំងអស់ ដែលបានចាប់យក ហើយត្រូវប្រគល់បញ្ជីថតចម្លងមួយច្បាប់ទៅឱ្យបុគ្គលដែលត្រូវបានគេចាប់យកសម្ភារៈទាំងអស់នោះ។ សម្ភារៈទាំងឡាយណាដែលមិនមានតម្លៃជាភ័ស្តុតាង ត្រូវប្រគល់ទៅឱ្យម្ចាស់ដើមវិញ នៅចុងបញ្ចប់ការស៊ើបអង្កេតបឋម[1207]។ សហព្រះរាជអាជ្ញាមិនអាច “លួចស្តាប់ការសន្ទនា ឬ ចាប់យកព័ត៌មាន ឬ ថតយកនូវទំនាក់ទំនងតាមទូរស័ព្ទ ឬ អេឡិចត្រូនិក ដូចជាសារទូរសារ ឬ សារអេឡិចត្រូនិក” នៅក្នុងការធ្វើការស៊ើបអង្កេតរបស់ខ្លួនបានឡើយ[1208]។

សហព្រះរាជអាជ្ញាអាចបង្គាប់ឱ្យធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ ដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬ ជាអ្នកសមគំនិត។ បុគ្គលបែបនោះត្រូវតែបានជូនដំណឹងអំពីហេតុផលនៃការឃាត់ខ្លួន និងសិទ្ធិទាំងឡាយរបស់ពួកគេ[1209]។ ដីកាឃាត់ខ្លួនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយសហព្រះរាជអាជ្ញា និងប្រគល់ឱ្យបុគ្គលដែលត្រូវឃាត់ខ្លួន លើកលែងតែក្នុងស្ថានភាពបន្ទាន់ដែលមិនអាចសរសេរជាលាយលក្ខណ៍អក្សរបាន ទើបសហព្រះរាជអាជ្ញាអាចចេញដីកាដោយផ្ទាល់មាត់ ប៉ុន្តែត្រូវសរសេរតាមក្រោយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន[1210]។

នៅពេលដែលជនសង្ស័យត្រូវបានឃាត់ខ្លួន សហព្រះរាជអាជ្ញាអាចបង្គាប់ឱ្យមានការឃាត់ខ្លួនរហូតដល់ ៤៨ ម៉ោង ដែលអាចពន្យារពេលការឃាត់ខ្លួនបាន ២៤ ម៉ោងបន្ថែមទៀត[1211]។ នៅចុងបញ្ចប់នៃរយៈពេលនេះ ជនសង្ស័យត្រូវបានដោះលែង ឬនាំទៅចំពោះមុខសហចៅក្រមស៊ើបអង្កេតសម្រាប់ការ

---

1203 សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ៣៨ (យោងសំអាងខាងក្នុងត្រូវបានលុបចោល ទំរង់ដើមជាអក្សរទ្រេត)។ សូមមើល វិធានផ្ទៃក្នុង វិធាន ៥០(១) និង៥៣(១)(ឃ) (“ឈ្មោះបុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន”)។

1204 វិធានផ្ទៃក្នុង វិធាន ៥០(៣)។

1205 វិធានផ្ទៃក្នុង វិធាន ៥០(៣)។

1206 វិធានផ្ទៃក្នុង វិធាន ៥០(៤)។

1207 វិធានផ្ទៃក្នុង វិធាន ៥០(៥)។

1208 វិធានផ្ទៃក្នុង វិធាន ៥២។

1209 វិធានផ្ទៃក្នុង វិធាន ៥១(១)។

1210 វិធានផ្ទៃក្នុង វិធាន ៥១(២)។

1211 វិធានផ្ទៃក្នុង វិធាន ៥១(៣)។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សេចក្តីសម្រេចឃាត់ខ្លួន អៀង សារី ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C14 ទំព័រ ២។ សំណុំរឿង ០០២ សេចក្តីសម្រេចឃាត់ខ្លួន អៀង ធីរិទ្ធ ឯកសារ C15 ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ ២។

បង្ហាញខ្លួនលើកដំបូង[1212]។ ជនសង្ស័យអាចស្នើសុំជួបមេធាវីតាមការជ្រើសរើសរបស់ខ្លួន ហើយមេធាវីនោះត្រូវបានប្រាប់អំពីសំណើនេះភ្លាមៗ[1213]។ ជនសង្ស័យអាចជួបជាមួយមេធាវីរបស់ខ្លួន ឬប្រសិនបើការណ៍នេះមិនអាចធ្វើទៅបាន មេធាវីមួយរូបដែលត្រូវបានផ្តល់ឱ្យដោយផ្នែកគាំពារការការពារក្តី ក្នុងរយៈពេលយ៉ាងយូរបំផុត ៣០ នាទី មុនពេលជនសង្ស័យបង្ហាញខ្លួននៅចំពោះមុខសហព្រះរាជអាជ្ញា[1214]។ មេធាវីមានសិទ្ធិមានវត្តមានក្នុងអំឡុងរយៈពេលឃាត់ខ្លួន ដោយគោរពទៅតាមបទបញ្ជារដ្ឋបាលរបស់មន្ទីរឃុំឃាំង[1215]។

សហព្រះរាជអាជ្ញាអាចស្នើសុំវេជ្ជបណ្ឌិតឱ្យពិនិត្យជនសង្ស័យនៅគ្រប់ពេលវេលាបាន ហើយវេជ្ជបណ្ឌិតត្រូវពិនិត្យថាតើជនសង្ស័យមានបញ្ហាសុខភាពណាមួយ ដែលមិនមានភាពសមស្របដើម្បីបន្តឃុំខ្លួនតទៅទៀតបាន[1216]។ អង្គបុរេជំនុំជម្រះបានសម្រេចថា វិធាន ៥១(៦) នៃវិធានផ្ទៃក្នុង "ចែងយ៉ាងច្បាស់លាស់អំពីលទ្ធភាព ដែលជនសង្ស័យត្រូវបានដោះលែងឱ្យមានសេរីភាពចេញពីកន្លែងឃុំខ្លួនរបស់មន្ត្រីនគរបាល នៅពេលដែលគាត់ "មានលក្ខខណ្ឌសុខភាពដែលធ្វើឱ្យគាត់មិនមានភាពសមស្របដើម្បីធ្វើការឃុំខ្លួនបន្តទៀត" ទេនោះ[1217]។ សហព្រះរាជអាជ្ញាត្រូវធ្វើរបាយការណ៍ចុងក្រោយមួយសម្រាប់រាល់ការឃាត់ខ្លួន និងត្រូវមានព័ត៌មានដូចខាងក្រោម៖

i. ឈ្មោះ និងមុខងាររបស់មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាឃាត់ខ្លួន។
ii. អត្តសញ្ញាណរបស់ជនសង្ស័យ។
iii. មូលហេតុនៃការឃាត់ខ្លួន។
iv. ពេលវេលា និងថ្ងៃឃាត់ខ្លួន។
v. ឈ្មោះរបស់វេជ្ជបណ្ឌិតដែលបានពិនិត្យជនសង្ស័យ បើអាចធ្វើទៅបាន។
vi. អត្តសញ្ញាណរបស់មេធាវីដែលបានជួបជនសង្ស័យ។
vii. រយៈពេលសម្ភាសន៍ និង រយៈពេលសម្រាកចន្លោះពេលសម្ភាសន៍។
viii. ពេលវេលា និងថ្ងៃបញ្ចប់នៃការឃាត់ខ្លួន។
ix. ឧប្បត្តិហេតុណាមួយដែលកើតមានក្នុងអំឡុងពេលឃាត់ខ្លួន។
x. សេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា នៅពេលផុតកំណត់រយៈពេលឃាត់ខ្លួន[1218]។

ក្នុងអំឡុងពេលការស៊ើបអង្កេតបឋម សហព្រះរាជអាជ្ញាអាចកែតម្រូវរួមគ្នាដោយផ្ទាល់ ឬតាមរយៈផ្នែកកិច្ចការសាធារណៈនូវព័ត៌មានមិនពិត ឬព័ត៌មាននាំឱ្យមានការភ័ន្តច្រឡំ[1219]។ ការស៊ើបអង្កេតបឋមបញ្ចប់ដោយមានការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់សហចៅក្រមស៊ើបអង្កេត[1220]។

### ៥.៣.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ប្រសិនបើ នៅពេលបញ្ចប់ការស៊ើបអង្កេតបឋម សហព្រះរាជអាជ្ញាមាន "ហេតុផលជឿ" ថា ឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានប្រព្រឹត្តឡើង សហព្រះរាជអាជ្ញាត្រូវ "បើកការ

---

1212 វិធានផ្ទៃក្នុង វិធាន ៥១(៧) និង ៥៧។
1213 វិធានផ្ទៃក្នុង វិធាន ៥១(៥)។ សូមមើល សំណុំរឿង ០០៣ ដីកាបង្គាប់ឲ្យនាំខ្លួន មាស មុត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ C1 ទំព័រ ៣។
1214 វិធានផ្ទៃក្នុង វិធាន ៥១(៥)។
1215 វិធានផ្ទៃក្នុង វិធាន ៥១(៥)។ សូមមើល សំណុំរឿង ០០៣ ដីកាបង្គាប់ឲ្យនាំខ្លួន មាស មុត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ C1 ទំព័រ ៣។
1216 វិធានផ្ទៃក្នុង វិធាន ៥១(៦)។
1217 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៨១។
1218 វិធានផ្ទៃក្នុង វិធាន ៥១(៨)។
1219 វិធានផ្ទៃក្នុង វិធាន ៥៤។
1220 សំណុំរឿង ០០៣ ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ឯកសារ D14 កថាខណ្ឌ ៥។

ស៊ើបសួរដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងបុគ្គលមួយ ឬច្រើនរូប "ឬប្រឆាំងនឹងអញ្ញាតជន"[1221]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវមាន៖ (១) សេចក្តីសង្ខេបអំពីអង្គហេតុ (២) ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ (៣) បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ (៤) ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន និង (៥) កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ[1222]។ ការមិនអនុវត្តតាមលក្ខខណ្ឌផ្លូវការ ឬលក្ខខណ្ឌសំខាន់ណាមួយនៃវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង នាំឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅជាគ្មានសុពលភាពនិងទុកជាមោឃៈ[1223]។ ទោះជាយ៉ាងណា "មានតែសេចក្តីសង្ខេបនៃអង្គហេតុ និងប្រភេទនៃបទល្មើសត្រូវបានកំណត់លក្ខខណ្ឌនៅដំណាក់កាលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[1224]។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដើរតួនាទីជាការជូនដំណឹង[1225]។ ដីកានេះ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមផ្សេងទៀត ដែលបានធ្វើឡើងអនុលោមតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង កំណត់វិសាលភាពនៃការស៊ើបអង្កេតជាបន្តបន្ទាប់[1226]។ ទោះជាយ៉ាងណា "កម្រិតនៃលក្ខណៈពិសេសដែលបានទាមទារនៅក្នុងដីកាចោទប្រកាន់ មិនអាចត្រូវបានទទួលស្គាល់ដោយផ្ទាល់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ពីព្រោះ [សហព្រះរាជអាជ្ញា] ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយមិនមានប្រយោជន៍ពីកិច្ចស៊ើបសួរទាំងមូលនោះទេ"[1227]។ ជាឧទាហរណ៍ ទោះបីជាវាជាការប្រសើរសម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមួយ ក្នុងការចោទប្រភេទជាក់លាក់មួយ(ច្រើន) នៃសហឧក្រិដ្ឋកម្មរួមដែលរងការចោទប្រកាន់ វាមិនចាំបាច់ត្រូវធ្វើដូច្នោះទេ។ យ៉ាងណាមិញ នៅទីបំផុត សហចៅក្រមស៊ើបអង្កេតត្រូវយោងទៅទម្រង់ជាក់លាក់ណាមួយនៃសហឧក្រិដ្ឋកម្មរួម និង/ឬ ការចូលរួមផ្សេងទៀត នៅក្នុងដីកាដំណោះស្រាយ[1228]។

នៅពេលដែលសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កិច្ចស៊ើបសួរត្រូវតែធ្វើចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។ សហព្រះរាជអាជ្ញាមិនអាច "បន្ថយ ឬទម្លាក់ចោលការចោទប្រកាន់ផ្នែកណាមួយឬទាំងអស់ ដែលការកាត់បន្ថយ ឬទម្លាក់ចោលការចោទប្រកាន់នេះត្រូវតែកំណត់ដោយសេចក្តីសម្រេចរបស់តុលាការ"[1229]។

[1221] វិធានផ្ទៃក្នុង វិធាន ៥៣(១)។ សូមមើល សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ៣៨។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ៣៨។

[1222] វិធានផ្ទៃក្នុង វិធាន ៥២(១) និង៥៣(៣)។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣១។

[1223] វិធានផ្ទៃក្នុង វិធាន ៥៣(៣)។ សំណុំរឿង ០០៣ សាលដីការបស់អង្គជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 កថាខណ្ឌ ៣៦-៣៨។ សូមមើល សំណុំរឿង ០០២ ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D180/6 ជើងទំព័រលេខ ១៥។

[1224] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៩២។

[1225] ដូចខាងលើ កថាខណ្ឌ ៩៥។

[1226] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១៤។

[1227] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៩៥។

[1228] ដូចខាងលើ កថាខណ្ឌ ៩៥។

[1229] សំណុំរឿង ០០២/០១ សាលក្រម ជើងទំព័រ ១។

សហព្រះរាជអាជ្ញាអាចជូនដំណឹងដល់សាធារណៈជននូវសេចក្ដីសង្ខេបព័ត៌មាន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីធានាថាសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធីដែលកំពុងធ្វើ។ ក្នុងការធ្វើបែបនេះ សហព្រះរាជអាជ្ញាត្រូវគិតពិចារណាដល់សិទ្ធិរបស់ភាគីចុងចោទ និងផលប្រយោជន៍របស់ជនរងគ្រោះ សាក្សី និងបុគ្គលណាផ្សេងទៀត ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក៏ដូចជាតម្រូវការផ្នែកស៊ើបអង្កេត[1230]។ លទ្ធភាពនៃការផ្ដល់ព័ត៌មានដល់សាធារណៈជននេះអនុវត្តចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ និងដីកាសន្និដ្ឋានស្ថាពរ ប៉ុន្តែមិនគ្របដណ្ដប់លើកិច្ចស៊ើបសួរទាំងមូលនោះទេ[1231]។

### ៥.៣.២. កាតព្វកិច្ចដាក់បង្ហាញឯកសារ

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវអមដោយសំណុំរឿង និង "សម្ភារៈដទៃទៀតដែលបានចាត់ទុកជាភ័ស្តុតាង ដែលសហព្រះរាជអាជ្ញាមាន រួមទាំងអ្វីៗទាំងអស់ដែលសហព្រះរាជអាជ្ញាបានដឹងថា អាចជាភ័ស្តុតាងដោះបន្ទុកផងដែរ"[1232]។ សហព្រះរាជអាជ្ញាអាចដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមជាបន្តបន្ទាប់បាន[1233]។

សម្ភារៈដែលគ្រាន់តែដាក់ដោយសហព្រះរាជអាជ្ញានៅក្នុងឃ្លាំងផ្ទុកឯកសាររួម ដែលសហចៅក្រមស៊ើបអង្កេត និង/ឬ ភាគីអាចចូលពិនិត្យមើលបាននោះ មិនស្ថិតក្រោមវិធាន ៥៣(២) នៃវិធានផ្ទៃក្នុងទេ ហើយមិនបង្កើតបានជាកាតព្វកិច្ចសម្រាប់សហចៅក្រមស៊ើបអង្កេតធ្វើការពិនិត្យសម្ភារៈនោះឡើយ ដោយសារតែវាមិនមែនជាផ្នែកមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ[1234]។ សន្ទានុក្រមបានកំណត់និយមន័យ "សំណុំរឿង" សម្រាប់គោលបំណងនៃវិធាន ៥៣(២) នៃវិធានផ្ទៃក្នុងថា "សំដៅទៅដល់សំណុំឯកសារដែលរួមមាន កំណត់ហេតុនៃកិច្ចដែលបានបំពេញនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ក៏ដូចជាពាក្យសុំរបស់ភាគី សេចក្ដីសម្រេចទាំងឡាយដែលបានចេញ និងអ្វីដែលជាឧបសម្ព័ន្ធដែលមាននៅក្នុងគ្រប់ដំណាក់កាលនីតិវិធី រួមទាំងកំណត់ហេតុសវនាការផង[1235]"។ យោងតាមអង្គបុរេជំនុំជម្រះ "នៅពេលដែលបកស្រាយឱ្យស្របទៅនឹងនិយមន័យរបស់ពាក្យ "សំណុំរឿង" ដែលមានចែងនៅក្នុងសន្ទានុក្រមពាក្យ "សម្ភារៈដទៃទៀតដែលបានចាត់ទុកថា មានតម្លៃភស្តុតាងដែលសហព្រះរាជអាជ្ញាមាន" ដែលមានចែងនៅក្នុងវិធាន៥៣(២) នៃវិធានផ្ទៃក្នុង ហាក់ដូចជាសំដៅចំពោះឯកសារនានា ជាជាងឯកសារដែលមានរៀបរាប់នៅតាមនិយមន័យនៃពាក្យ "សំណុំរឿង" ដែលសហព្រះរាជអាជ្ញាពិចារណាថាជាភ័ស្តុតាង ដោយសារតែឯកសារទាំងនេះគាំទ្រចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផង ឬជាប្រភេទនៃឯកសារភ័ស្តុតាងដោះបន្ទុកផង"[1236]។

បន្ទាប់មក ក្នុងរយៈពេលយ៉ាងឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេតនូវសម្ភារៈទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាចនាំឱ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធភាពជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់នៃភ័ស្តុតាងចោទប្រកាន់[1237]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ភាពមិនស្របគ្នានៅក្នុងសំណៅភាសាផ្សេងគ្នានៃវិធានផ្ទៃក្នុង នៅក្នុងខ្លឹមសារនៃវិធាន ៥៣(៤) ដែលសំណៅជាភាសាបារាំង និងភាសាខ្មែរសំដៅលើសញ្ញាណនៃ "ភស្តុតាងដាក់បន្ទុក" មិនមែនសំដៅលើប្រភេទទូទៅនៃ "ភស្តុតាងក្នុងការចោទប្រកាន់" ដូច

---

[1230] វិធានផ្ទៃក្នុង វិធាន ៥៤។

[1231] សំណុំរឿង ០០៣ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្ដីប្រកាសព័ត៌មានជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ឯកសារ D14/1/3 កថាខណ្ឌ ២៣-២៤។

[1232] វិធានផ្ទៃក្នុង វិធាន ៥៣(២)។

[1233] សូមមើល វិធានផ្ទៃក្នុង វិធាន ៥៤ វិធាន ៥៥(២) វិធាន៥៥(៣) និងវិធាន ៥៥(៤)។

[1234] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៣៥។

[1235] វិធានផ្ទៃក្នុង សន្ទានុក្រម។

[1236] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ៣២។

[1237] វិធានផ្ទៃក្នុង វិធាន ៥៣(៤)។

ក្នុងសំណៅជាភាសាអង់គ្លេសនោះទេ[1238]។ កាតព្វកិច្ចក្នុងការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា គ្រប ដណ្ដប់លើសម្ភារៈដែល "សហព្រះរាជអាជ្ញាបានដឹង" ថាអាចជាភស្តុតាងដោះបន្ទុក[1239] ឬ ដែលប៉ះពាល់ ដល់ "ភាពអាចជឿទុកចិត្តបាននៃភស្តុតាងដាក់បន្ទុក ដែលធ្វើឱ្យភស្តុតាងទាំងនេះក្លាយជាភស្តុតាងដោះ បន្ទុកវិញ"[1240]។

សហព្រះរាជអាជ្ញាមិនចាំបាច់ធ្វើការសន្និដ្ឋានអំពីវិធីសាស្ត្ររបស់មេធាវីការពារក្ដីនោះទេ ហើយក៏ មិនចាំបាច់សន្និដ្ឋានអំពីភាពមិនច្បាស់លាស់អំពីវិធីសាស្ត្រជាក់លាក់របស់ក្រុមមេធាវីការពារក្ដី ដើម្បីផ្ដល់ ជាលេសក្នុងការអនុវត្តវិធីសាស្ត្រទូលំទូលាយនៅក្នុងការដាក់បង្ហាញឯកសារ ឬក៏ដាក់បញ្ចូលយ៉ាងច្បាស់ លាស់នូវភស្តុតាងដាក់បន្ទុកនៅក្នុងការដាក់បង្ហាញនានា ដែលធ្វើឡើងអនុលោមតាមវិធាន ៥៣(៤) នៃវិធាន ផ្ទៃក្នុងនោះទេ។ ផ្ទុយទៅវិញ វាជា "ការទទួលខុសត្រូវផ្ដាច់មុខរបស់សហព្រះរាជអាជ្ញា នៅក្នុងការសម្រេច ថា តើព័ត៌មានណាអាចជាព័ត៌មានដោះបន្ទុក"[1241]។ នេះគឺជាកាតព្វកិច្ចជាបន្តបន្ទាប់ដែលបន្តរហូតដល់ ដំណាក់កាលជំនុំជម្រះ ហើយក៏រួមបញ្ចូលភស្តុតាងដែលប្រមូលបានក្នុងសំណុំរឿងផ្សេងទៀត ដែលសហ ព្រះរាជអាជ្ញាជាប់ពាក់ព័ន្ធផងដែរ[1242]។ ដើម្បីផលប្រយោជន៍នៃការបញ្ជាក់ការពិតចៅក្រម នៅក្នុងរឿងក្ដី ពាក់ព័ន្ធ អាចចូលពិនិត្យមើលឯកសារទាំងអស់នេះ[1243]។

### ៥.៣.៣. ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា

ក្នុងករណីដែលសហព្រះរាជអាជ្ញាមិនអាចឈានដល់វិធីសាស្ត្ររួមគ្នា ទាក់ទងនឹងដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ មាត្រា ៦(៤) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ២៧ នៃច្បាប់ អ.វ.ត.ក. បានណែនាំថា "ការចោទប្រកាន់ត្រូវបន្ត" លើកលែងតែសហព្រះរាជអាជ្ញាទាំងពីរ ឬសហព្រះរាជអាជ្ញាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ស្នើសុំក្នុងរយៈពេល ៣០ ថ្ងៃ ឱ្យអង្គបុរេជំនុំជម្រះដោះ ស្រាយករណីខ្វែងយោបល់គ្នារបស់ពួកគេ[1244]។ ក្នុងករណីដែលការខ្វែងយោបល់នេះត្រូវបានប្ដឹងទៅអង្គ បុរេជំនុំជម្រះ ហើយប្រសិនបើមិនមានសំឡេងគាំទ្រភាគច្រើនដែលតម្រូវដើម្បីធ្វើសេចក្ដីសម្រេចទេនោះ មាត្រា ៧(៤) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ២០ នៃច្បាប់ អ.វ.ត.ក . បង្គាប់ថា ការស៊ើបអង្កេត ឬការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត។ ប្រសិនបើសហព្រះរាជអាជ្ញាមិនឯក ភាពគ្នាលើវិធីដែលត្រូវបន្តទេនោះ ជាលទ្ធផលនៃការខ្វែងយោបល់នេះគឺត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ[1245]។ នេះគឺជាអ្វីកើតឡើងក្នុងសំណុំរឿង

---

[1238] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ E363/3 ជើងទំព័រ៣៦។

[1239] ដូចខាងលើ កថាខណ្ឌ ២៤។

[1240] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយក កំណត់ហេតុស្ដាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E319/47/3 កថាខណ្ឌ ១៤។

[1241] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ E363/3 កថាខណ្ឌ ២៤។

[1242] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាង បន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ F2/4/2 កថាខណ្ឌ ១៧។ សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញ ឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ E363/3 កថាខណ្ឌ ១៦។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤ លិខិតរបស់សហចៅក្រមស៊ើបអង្កេត ពីការបន្តកាតព្វកិច្ចផ្លូវច្បាប់ ដោយអនុលោមតាមវិធាន ៥៣(៤) នៃវិធាន ផ្ទៃក្នុង ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D175។

[1243] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ E363/3 កថាខណ្ឌ ១៦។

[1244] សំណុំរឿង ០០៣ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ៤០។

[1245] ដូចខាងលើ កថាខណ្ឌ ៤១។

០០៣ បន្ទាប់ពីនីតិវិធីខ្វែងយោបល់នៅចំពោះមុខអង្គបុរេជំនុំជម្រះ[1246]។ មិនមាននីតិវិធីខ្វែងយោបល់គ្នាត្រូវបានផ្តួចផ្តើមឡើងក្នុងសំណុំរឿង ០០៤ ទេ ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ។

អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា មាត្រា ៦(១) និង ៦(៤) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ១៦ និង ២០ (ថ្មី) នៃច្បាប់ អ.វ.ត.ក. និង វិធាន ៧១(៣) នៃវិធានផ្ទៃក្នុងបានបញ្ជាក់ច្បាស់ថា សហព្រះរាជអាជ្ញាម្នាក់អាចបំពេញកិច្ច ដោយមិនចាំបាច់មានការយល់ព្រមពីសហព្រះរាជអាជ្ញាម្នាក់ទៀតនោះទេ ប្រសិនបើពុំមានសហព្រះរាជអាជ្ញាណាម្នាក់ក្នុងចំណោមពួកគេប្តឹងករណីខ្វែងយោបល់គ្នារបស់ខ្លួននេះទៅអង្គបុរេជំនុំជម្រះ ក្នុងពេលវេលាកំណត់ជាក់លាក់[1247]។ បញ្ហាខ្វែងយោបល់គ្នាទាក់ទងនឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានរាំងខ្ទប់សហព្រះរាជអាជ្ញាម្នាក់ក្នុងការបន្តកិច្ចនីតិវិធី រហូតទាល់តែបញ្ហាខ្វែងយោបល់នេះត្រូវបានដោះស្រាយ[1248]។ ដើម្បីរារាំងកិច្ចដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាម្នាក់បាន ចាំបាច់ត្រូវការសំឡេងគាំទ្រភាគច្រើនរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះចំនួនបួននាក់ ហើយប្រសិនបើលក្ខខណ្ឌនេះមិនអាចបំពេញបានទេនោះ គោលជំហរស្វ័យប្រវត្តិគឺត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ[1249]។

សហព្រះរាជអាជ្ញាដែលជំទាស់ទៅនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅសហចៅក្រមស៊ើបអង្កេត ត្រូវដាក់សេចក្តីថ្លែងអង្គហេតុជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅអង្គបុរេជំនុំជម្រះជាមុន។ បន្ទាប់មក សហព្រះរាជអាជ្ញាម្នាក់ទៀតមានឱកាសដាក់ចម្លើយតប[1250]។

វិសាលភាពនៃការពិនិត្យរបស់អង្គបុរេជំនុំជម្រះត្រូវបានកម្រិតត្រឹម "ចំណុចវិវាទដែលលើកឡើងដោយសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ"[1251]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះពិចារណាតែអង្គហេតុ និងសំអាងហេតុ ដែលលើកឡើងនៅក្នុងសេចក្តីថ្លែងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ[1252]។ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះអាចស្នើសុំសេចក្តីសន្និដ្ឋានបន្ថែមទៀតពីសហព្រះរាជអាជ្ញា[1253]។ សហព្រះរាជអាជ្ញាដែលស្វែងរកឱ្យមានការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅសហចៅក្រមស៊ើបអង្កេត មិនមានបន្ទុកណាមួយក្នុងការធ្វើឱ្យអង្គបុរេជំនុំជម្រះជឿជាក់នោះទេ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះវាយតម្លៃអំណះអំណាងរបស់សហព្រះរាជអាជ្ញា ដែលមានគោលជំហរបដិសេធការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយកំណត់ថាតើអំណះអំណាងទាំងនោះមានលក្ខណៈគ្រប់គ្រាន់ក្នុងការរារាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនឱ្យបញ្ជូនឬទេ[1254]។

ប្រធានការិយាល័យរដ្ឋបាលត្រូវជូនដំណឹងភ្លាមៗទៅសហព្រះរាជអាជ្ញា អំពីសេចក្តីសម្រេចលើករណីខ្វែងយោបល់ ហើយបន្ទាប់មកសហព្រះរាជអាជ្ញាបន្តធ្វើតាមសេចក្តីសម្រេចនោះភ្លាម[1255]។ ការផ្សព្វផ្សាយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺជាឆន្ទានុសិទ្ធិរបស់ប្រធានការិយាល័យរដ្ឋបាល[1256]។

### ៥.៤. ដំណាក់កាលស៊ើបអង្កេត

[1246] សូមមើល សំណុំរឿង ០០៣ ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3។
[1247] ដូចខាងលើ កថាខណ្ឌ ១៦។
[1248] ដូចខាងលើ កថាខណ្ឌ ១៦។
[1249] ដូចខាងលើ កថាខណ្ឌ ១៧។
[1250] ដូចខាងលើ កថាខណ្ឌ ២៧។
[1251] ដូចខាងលើ កថាខណ្ឌ ២៤។
[1252] ដូចខាងលើ កថាខណ្ឌ ២៣-២៤។
[1253] ដូចខាងលើ កថាខណ្ឌ ២៤។
[1254] ដូចខាងលើ កថាខណ្ឌ ២៦។
[1255] ដូចខាងលើ កថាខណ្ឌ ៥១។
[1256] ដូចខាងលើ កថាខណ្ឌ ៥៣។

កិច្ចស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[1257]។ វិធានផ្ទៃក្នុង "ចែងអំពីការប្រព្រឹត្តិទៅនៃដំណើរការស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក. ដែលប្រមូលផ្តុំច្បាប់កម្ពុជាជាធរមាន និងអនុម័តយកតាមវិធាននានាដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិបន្ថែមទៀត ក្នុងករណីសមស្រប"។ វិធានផ្ទៃក្នុងរួមបញ្ចូលបទប្បញ្ញត្តិនានាដែលមានគោលបំណងការពារសុចរិតភាពនៃការស៊ើបអង្កេត ភាពពិតជាក់ស្តែងនៃកំណត់ត្រា និងសិទ្ធិរបស់ភាគីទាំងអស់ រួមទាំងសិទ្ធិរបស់ជនជាប់ចោទ[1258]។

## ៥.៤.១. វិសាលភាពនៃការស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេតមានភារកិច្ចស៊ើបអង្កេត *លើ*គ្រប់អង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[1259]។ សហចៅក្រមស៊ើបអង្កេតត្រូវបានអនុញ្ញាតឱ្យស៊ើបអង្កេត *តែ* អង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម *ប៉ុណ្ណោះ*[1260]។ ជាផ្នែកមួយនៃការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតត្រូវកំណត់ថាតើ *តាមការពិនិត្យជាបឋម* ជនសង្ស័យស្ថិតក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ដែរ ឬទេ[1261]។

សហចៅក្រមស៊ើបអង្កេតមិនមានយុត្តាធិការក្នុងការស៊ើបអង្កេតអង្គហេតុឡើយ ប្រសិនបើពួកគេមិនត្រូវបានស្នើសុំឱ្យធ្វើដូច្នេះដោយសហព្រះរាជអាជ្ញា[1262]។ ប្រសិនបើ ក្នុងពេលស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតដឹងអំពីអង្គហេតុថ្មីនៅក្រៅវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬត្រូវបានស្នើសុំឱ្យស៊ើបអង្កេតលើអង្គហេតុបែបទាំងនោះ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងទៅសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេតមិនអាចស៊ើបអង្កេតលើអង្គហេតុថ្មីបានទេ លុះត្រាតែអង្គហេតុនោះក្លាយជាកម្មវត្ថុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[1263]។

សហចៅក្រមស៊ើបអង្កេតក៏ត្រូវស៊ើបអង្កេតកាលៈទេសៈជុំវិញអង្គហេតុ ដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដូចជាក្នុងករណីដែលអង្គហេតុថ្មីគឺជាស្ថានទម្ងន់ទោស ដែលទាក់ទងទៅនឹងដីកាសន្និដ្ឋានដែលមានស្រាប់[1264]។ កាលៈទេសៈនានា

---

[1257] វិធានផ្ទៃក្នុង វិធាន ៥៥(១)។ សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤។

[1258] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១២។

[1259] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥។ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៩។

[1260] វិធានផ្ទៃក្នុង វិធាន ៥៥(២)។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមានចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១៤។ សំណុំរឿង ០០២ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទី១១ របស់សហមេធាវី នួន ជា ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ឯកសារ D158/5 កថាខណ្ឌ ៩។

[1261] សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការលើរូបបុគ្គល និងគោលការណ៍នៃការស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១២ ឯកសារ D49 កថាខណ្ឌ ១៣។

[1262] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦។

[1263] វិធានផ្ទៃក្នុង វិធាន ៥៥(៣)។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមានចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ៣០។

[1264] វិធានផ្ទៃក្នុង វិធាន ៥៥(៣)។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេច

ដែលឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើង ដែលរួមចំណែកដល់ការកំណត់បទចោទ មិនត្រូវបានពិចារណាថាជាអង្គហេតុថ្មីទេ។ សហចៅក្រមស៊ើបអង្កេតប្រើការកំណត់បទចោទដែលស្នើឡើងដោយសហព្រះរាជអាជ្ញាជាគោលការណ៍ណែនាំ ក្នុងការកំណត់វិសាលភាពនៃការស៊ើបអង្កេតរបស់ខ្លួន[1265] ។ អង្គហេតុថ្មីដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរ មិនមែនជាផ្នែកមួយនៃកិច្ចស៊ើបសួរនោះទេ[1266]។

### ៥.៤.២. អំណាចក្នុងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវជនជាប់ចោទណាម្នាក់ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1267]។ ពួកគេក៏មានឆន្ទានុសិទ្ធិក្នុងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបុគ្គលទាំងឡាយណាផ្សេងទៀតដែលមាន "តម្រុយច្បាស់លាស់ និងស៊ីចង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ"[1268]។ ទោះជាយ៉ាងណា ប្រសិនបើបុគ្គលនោះមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដូច្នេះសហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញា មុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ[1269]។

### ៥.៤.៣. នីតិវិធីនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ជាដំបូងជនត្រូវចោទត្រូវនាំខ្លួនមកចំពោះមុខសហចៅក្រមស៊ើបអង្កេត សម្រាប់ការបង្ហាញខ្លួនលើកដំបូង[1270]។ នៅពេលបង្ហាញខ្លួនលើកដំបូង សហចៅក្រមស៊ើបអង្កេតកត់ត្រាអត្តសញ្ញាណរបស់ជនត្រូវចោទ និងជូនដំណឹងគាត់អំពីបទចោទប្រកាន់ សិទ្ធិរបស់គាត់ក្នុងការមានមេធាវី និងសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិនឆ្លើយតប[1271]។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលត្រូវបានសួរចម្លើយ និងមានសិទ្ធិមានវត្តមានមេធាវីក្នុងអំឡុងពេលសួរចម្លើយ[1272]។ ប្រសិនបើជនជាប់ចោទយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវសួរចម្លើយភ្លាមៗ ហើយកំណត់ហេតុនៃការសួរចម្លើយត្រូវដាក់ក្នុងសំណុំរឿង[1273] ។ ចាប់ពីពេលបុគ្គលណាម្នាក់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ការវាយតម្លៃពីសមត្ថភាពរបស់បុគ្គលនោះក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីត្រូវបានចាប់ផ្តើម[1274]។ ហេតុដូច្នេះ ប្រសិនបើមានយុត្តិកម្មត្រឹមត្រូវ ជនត្រូវចោទ "មានសិទ្ធិទទួលបានការវាយតម្លៃដោយអ្នកជំនាញ នូវលទ្ធភាពរបស់ខ្លួនក្នុងការ

---

បដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១១។

1265 សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥។

1266 ដូចខាងលើ កថាខណ្ឌ ៣៦។

1267 វិធានផ្ទៃក្នុង វិធាន ៥៥(៤)។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ D121/4 កថាខណ្ឌ ៤០។

1268 វិធានផ្ទៃក្នុង វិធាន ៥៥(៤)។ សូមមើល សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ D121/4 កថាខណ្ឌ ៤០។

1269 វិធានផ្ទៃក្នុង វិធាន ៥៥(៤)។

1270 វិធានផ្ទៃក្នុង វិធាន ៥៧(១)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៣ ដីកាកោះហៅ មាស មុត ដើម្បីបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ A66។ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធបណ្តឹងសុំមោឃភាពចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ឯកសារ D55/I កថាខណ្ឌ ២។

1271 វិធានផ្ទៃក្នុង វិធាន ៥៧(១)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធបណ្តឹងសុំមោឃភាពចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ឯកសារ D55/I កថាខណ្ឌ ២។

1272 ដូចខាងលើ។

1273 ដូចខាងលើ កថាខណ្ឌ ២-៣។

1274 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ ឯកសារ D54/V/6 កថាខណ្ឌ ២៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ៣៤។

អនុវត្តសិទ្ធទទួលបានតាមនីតិវិធីប្រកបដោយប្រសិទ្ធភាព ក្នុងអំឡុងពេលស៊ើបសួរ និងដំណាក់កាលមុនអង្គសេចក្តី"[1275]។

ជនត្រូវចោទស្ថិតក្នុងការឃុំខ្លួនមានសិទ្ធិលើកឡើងពីបញ្ហានានា ទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ ឬនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ហើយព័ត៌មានណាមួយបែបនេះត្រូវកត់ត្រាក្នុងសំណុំរឿង[1276]។ ប្រសិនបើជនត្រូវចោទមិនត្រូវបានឃុំខ្លួន បន្ទាប់ពីការបង្ហាញខ្លួនលើកដំបូង ពួកគេត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអំពីអាសយដ្ឋានរបស់ពួកគេ ដែលត្រូវកត់ត្រាទុកនៅក្នុងសំណុំរឿង[1277]។ ជនត្រូវចោទត្រូវបានជូនដំណឹងថា៖ (១) ខ្លួនត្រូវជូនព័ត៌មានដល់សហចៅក្រមស៊ើបអង្កេត នៅពេលណាមានការផ្លាស់ប្តូរអាសយដ្ឋាន និង(២) រាល់ការបញ្ជូនដីកា ឬការជូនដំណឹងទាំងអស់ដែលធ្វើឡើងចំពោះអាសយដ្ឋានចុងក្រោយដែលត្រូវបានផ្តល់ឱ្យ ត្រូវទុកថាមានសុពលភាព[1278]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ និង ០០៤ បានពិចារណាថា ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. អនុញ្ញាតឱ្យមានការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ នៅពេលដែលជនសង្ស័យបដិសេធមិនបង្ហាញខ្លួន សម្រាប់ការបង្ហាញខ្លួនលើកដំបូងអនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង និងនៅពេលដែលកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់មកទៀត ដើម្បីធានាថាជនសង្ស័យមានវត្តមាន មិនទទួលបានលទ្ធផល[1279]។ ទោះជាយ៉ាងណា នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះមិនបានសម្រេចដាច់ស្រេច ថាតើការអនុវត្តនេះអាចធ្វើទៅបានដែរ ឬយ៉ាងណា ដោយសារអង្គបុរេមិនអាចរកសំឡេងគាំទ្រភាគច្រើនដែលត្រូវការសម្រាប់ចេញសេចក្តីសម្រេចលើអង្គសេចក្តីបាន[1280]។

### ៥.៤.៤. អំណាច និងការធ្វើការស៊ើបអង្កេត

មានតែសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះមានអំណាចធ្វើការស៊ើបអង្កេត ហើយពួកគេមានឯករាជ្យភាពក្នុងការធ្វើការស៊ើបអង្កេត[1281]។ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតដោយអនាគតិ[1282]។ សច្ចធារណ៍នៃភាពអាចទុកចិត្តបាន ភ្ជាប់ទៅនឹងកិច្ចស៊ើបសួរ ដែលអាចត្រូវជំទាស់[1283]។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេត ពួកគាត់មានសិទ្ធិធ្វើការស៊ើបអង្កេតណាមួយ "ដែលនាំ

[1275] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ៣៥។

[1276] វិធានផ្ទៃក្នុង វិធាន ៥៧(២) និង៥៧(៤)។

[1277] វិធានផ្ទៃក្នុង វិធាន ៥៧(៣) និង៥៧(៤)។

[1278] វិធានផ្ទៃក្នុង វិធាន ៥៧(៣)។

[1279] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៥ ឯកសារ D128 កថាខណ្ឌ ៥៤។ សូមមើល សំណុំរឿង ០០៣ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុតចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៥ ឯកសារ D128.1។ សំណុំរឿង ០០៤ ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៥ ឯកសារ D239។

[1280] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១៦ ឯកសារ D128/1/9 កថាខណ្ឌ ៣៧-៣៨។

[1281] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី បានដែរឬអត់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D173/2.3 កថាខណ្ឌ ៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។

[1282] វិធានផ្ទៃក្នុង វិធាន ៥៥(៥)។

[1283] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៣។

ទៅរកការបង្ហាញការពិត” ហើយមានឆន្ទានុសិទ្ធិទូលំទូលាយទាក់ទងនឹងបញ្ហានេះ[1284]។ ទោះជាយ៉ាងណា ឆន្ទានុសិទ្ធិបែបនេះត្រូវបានកម្រិតដោយយុត្តាធិការរបស់ អ.វ.ត.ក.[1285]។

កិច្ចស៊ើបសួរដែលត្រូវបានអនុញ្ញាតរួមមានដូចជា៖ ការកោះហៅ និងការសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ការស្តាប់ចម្លើយជនរងគ្រោះ និងសាក្សី និងការកត់ត្រាទុកនូវចម្លើយរបស់ពួកគេ ការប្រមូលវត្ថុតាង ការស្វែងរកមតិយោបល់ពីអ្នកជំនាញ[1286]។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[1287]។ ការណ៍នេះតម្រូវឱ្យមានការពិនិត្យឯកសារ ឬសម្ភារៈផ្សេងទៀត នៅពេលដែលមានមូលហេតុជាបឋមនាំឱ្យជឿជាក់ថា ឯកសារទាំងនោះអាចមានភស្តុតាងដោះបន្ទុក[1288]។ សហចៅក្រមស៊ើបអង្កេតក៏ត្រូវស្វែងរកភាពផ្ទុយគ្នាទៅនឹងហេតុការណ៍ដែលចោទប្រកាន់ ដូចដែលអាចកំណត់យ៉ាងសមហេតុផលពីក្នុងសំណុំរឿងផងដែរ[1289]។

សហចៅក្រមស៊ើបអង្កេតអាចដឹកនាំការស៊ើបអង្កេត ចុះដល់កន្លែងកើតហេតុ ដែលខ្លួនយល់ថាមានប្រយោជន៍[1290]។ នៅពេលធ្វើដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវអមដោយក្រឡាបញ្ជីរបស់ខ្លួន ដែលត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ សម្រាប់រាល់សំណុំរឿងទាំងអស់[1291]។ កាតព្វកិច្ចនេះមិនគ្របដណ្តប់លើការធ្វើកំណត់ហេតុនៃការទំនាក់ទំនងដំបូងជាមួយសាក្សី ឬការជ្រើសរើសសំណួរនោះទេ[1292]។ សហចៅក្រមស៊ើបអង្កេតអាចជូនដំណឹងដល់ភាគីអំពីការចុះដល់ទីកន្លែងកើតហេតុ នៅពេលដែលសហចៅក្រម

---

[1284] វិធានផ្ទៃក្នុង វិធាន៥៥(៥)។ សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៣ និង ២៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២១។ សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៤០។

[1285] ច្បាប់ អ.វ.ត.ក. មាត្រា ២។ សំណុំរឿង ០០២ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទី១១របស់សហមេធាវី នួន ជា ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ២០០៩ ឯកសារ D158/5 កថាខណ្ឌ ៨។

[1286] វិធានផ្ទៃក្នុង វិធាន៥៥(៥)(ក)។ សូមមើល សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តី អាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី បានដែរឬអត់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D173/2.3 កថាខណ្ឌ ៨។

[1287] វិធានផ្ទៃក្នុង វិធាន៥៥(៥)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៣៦។ សូមមើលផងដែរ សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៤១។

[1288] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៤៣។

[1289] សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៤៣។

[1290] វិធានផ្ទៃក្នុង វិធាន៥៥(៥)(ក) និងវិធាន៥៥(៨)។ សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តី អាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី បានដែរឬអត់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D173/2.3 កថាខណ្ឌ ៨។ សូមមើលឧទាហរណ៍ សំណុំរឿង ០០១ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់ កន្លែងកើតហេតុ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/242 ទំព័រ ២។

[1291] វិធានផ្ទៃក្នុង វិធាន ៥៥(៨)។ សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ២១។ សូមមើលឧទាហរណ៍ សំណុំរឿង ០០១ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់ កន្លែងកើតហេតុ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/242។

[1292] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ២១។

ស៊ើបអង្កេតយល់ឃើញថាវត្តមានរបស់ខ្លួនអាចជាការចាំបាច់[1293]។ នៅពេលទទួលបានការជូនដំណឹងនេះ ភាគីអាចស្នើសុំទៅចូលរួមបាន[1294]។

សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិលើលក្ខណៈ និងទម្រង់នៃសំណួរដែលសួរក្នុងអំឡុងពេលស្ដាប់ចម្លើយសាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណី[1295]។ កំណត់ហេតុនៃកិច្ចសម្ភាសន៍ត្រូវអានទាំងស្រុង នៅពេលវាយតម្លៃលើភាពប្រក្រតីរបស់វា[1296]។ អ្នកស៊ើបអង្កេតអាចដាក់សាក្សីតទល់នឹងភស្តុតាង ' ឬការពិពណ៌នាណាមួយ[1297]។ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃការស្ដាប់ចម្លើយទាំងអស់[1298]។ កំណត់ហេតុជាលាយលក្ខណ៍អក្សរមិនចាំបាច់មាននោះទេ ចំពោះការពិភាក្សាបឋមជាមួយសាក្សីសក្ដានុពល ដើម្បីកំណត់ថាតើពួកគេមានព័ត៌មានពាក់ព័ន្ធ ឬទេ[1299]។ ការស្ដាប់ចម្លើយត្រូវចុះហត្ថលេខា និង/ឬ ផ្ដិតមេដៃលើគ្រប់ទំព័រនៃកំណត់ហេតុស្ដាប់ចម្លើយ បន្ទាប់ពីពួកគេបានអានរួចហើយ[1300]។ ប្រសិនបើចាំបាច់ ក្រឡាបញ្ជី ដោយមានជំនួយពីអ្នកបកប្រែ អានកំណត់ហេតុនោះឱ្យអ្នកផ្ដល់ចម្លើយស្ដាប់។ ប្រសិនបើអ្នកផ្ដល់ចម្លើយបដិសេធមិនចុះហត្ថលេខា ឬផ្ដិតមេដៃ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសនៅលើកំណត់ហេតុនោះ[1301]។

កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ឬតំណាងតាមការចាត់តាំងរបស់ខ្លួន មិនមែនជាកំណត់ហេតុនៃចម្លើយផ្ទាល់ ដែលធ្វើឡើងដោយជនរងគ្រោះ ឬសាក្សីនោះទេ ប៉ុន្តែវាជារបាយការណ៍សង្ខេប[1302]។ របាយការណ៍ត្រូវមានភាពពេញលេញ និងមិនលម្អៀងតាមដែលអាចធ្វើបាន ហើយហ្មត់ចត់គ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃអំពីភាពជឿជាក់ និងតម្លៃជាភស្តុតាង[1303]។ ទោះបីជាសំណួរបើកចំហត្រូវបានគេពេញចិត្ត ពេលខ្លះសំណួរនាំមុខត្រូវបានអនុញ្ញាត នៅពេលចាំបាច់

---

[1293] វិធានផ្ទៃក្នុង វិធាន ៥៥(៨)។
[1294] វិធានផ្ទៃក្នុង វិធាន ៥៥(៨)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០១ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់ កន្លែងកើតហេតុ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/242 ទំព័រ ២។
[1295] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៦។
[1296] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៦។
[1297] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៩។
[1298] វិធានផ្ទៃក្នុង វិធាន ៥៥(៧)។ សូមមើល សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ២១។ សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៦។
[1299] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D274/1 កថាខណ្ឌ ២៥។
[1300] វិធានផ្ទៃក្នុង វិធាន ៥៥(៧)។ សូមមើល សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣១។ សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៦។
[1301] វិធានផ្ទៃក្នុង វិធាន ៥៥(៧)។
[1302] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សីរបស់ក.ស.ច.ស ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១២ ឯកសារ E142/3 កថាខណ្ឌ ១១។
[1303] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៦។ សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D274/1 កថាខណ្ឌ ២០-២១។

ដើម្បីទទួលបានព័ត៌មានក្នុងដំណាក់កាលស៊ើបអង្កេត[1304]។ ការថតសំឡេង ឬថតវីដេអូការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់នោះទេ[1305]។

សហចៅក្រមស៊ើបអង្កេតអាចចេញដីកា ដែលចាំបាច់ក្នុងការធ្វើការស៊ើបអង្កេត រួមមាន ដីកាកោះ ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន[1306]។ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកព័ត៌មាន និងជំនួយពីរដ្ឋណាមួយ អង្គការសហប្រជាជាតិ "ឬអង្គការអន្តររដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល ឬប្រភពសមស្របដទៃទៀត"[1307]។ សហចៅក្រមស៊ើបអង្កេតក៏អាច "ចាត់វិធានការសមស្របដើម្បីផ្តល់សុវត្ថិភាព និងគាំទ្រដល់សាក្សីសំខាន់ៗ និងប្រភពដទៃទៀត"[1308]។

សហចៅក្រមស៊ើបអង្កេតអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ស្នើសុំឱ្យនគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេត អ.វ.ត.ក. ឱ្យបំពេញកិច្ចការទាំងនេះដែលចាំបាច់សម្រាប់ការស៊ើបអង្កេតរបស់ខ្លួន ដូចមានចែងក្នុងវិធានផ្ទៃក្នុង[1309]។ ប្រសិនបើត្រូវបានរកឃើញថាមាន ការរំលោភបំពានលើអនាគតិភាពដោយសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេត នឹងនាំឱ្យមាន "ការធ្វើមោឃភាពយ៉ាងជ្រាលជ្រៅ" នៃកិច្ចស៊ើបសួរដែលធ្វើឡើងដោយពួកគេ[1310]។ ស្រដៀងគ្នានេះដែរ ការខកខានជាច្រើនក្នុងការអនុវត្តតាមផ្នែកសំខាន់ៗនៃនីតិវិធីស៊ើបអង្កេតដែលតម្រូវ អាចនាំឱ្យមានការធ្វើមោឃភាពភ័ស្តុតាង[1311]។

កំណត់ហេតុទាំងអស់នៃកិច្ចស៊ើបសួរត្រូវដាក់នៅក្នុងសំណុំរឿង[1312]។ ការជូនដំណឹងទាន់ពេលវេលាអំពីបទចោទប្រកាន់ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវបានផ្តល់នៅទូទាំងរយៈពេលនៃការស៊ើបអង្កេត និងនៅក្នុងដីកាដំណោះស្រាយ[1313]។

### ៥.៤.៤.១. ការសួរចម្លើយជនត្រូវចោទ

នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរចម្លើយជនត្រូវចោទ ដែលមានមេធាវី មេធាវីនោះត្រូវកោះហៅយ៉ាងហោចណាស់ប្រាំថ្ងៃមុនពេលសួរចម្លើយ[1314]។ ជនត្រូវចោទត្រូវបានសួរចម្លើយតែក្នុងវត្តមាននរបស់ពួកគេប៉ុណ្ណោះ លើកលែងតែជនត្រូវចោទបោះបង់សិទ្ធិមានវត្តមានមេធាវីចោល នៅក្នុងកំណត់ហេតុ

---

[1304] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D274/1 កថាខណ្ឌ ២៤។

[1305] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស. ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១២ ឯកសារ E142/3 កថាខណ្ឌ ៦។

[1306] វិធានផ្ទៃក្នុង វិធាន៥៥(៥)(ឃ)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៣ ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ C1។ សំណុំរឿង ០០៤ ដីកាបង្គាប់ឱ្យនាំខ្លួន អ៊ឹម ចែម ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ C1។

[1307] វិធានផ្ទៃក្នុង វិធាន៥៥(៥)(គ)។ សូមមើល សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សំគាល់ជើងទំព័រ ២៧៤។

[1308] វិធានផ្ទៃក្នុង វិធាន៥៥(៥)(ខ)។

[1309] វិធានផ្ទៃក្នុង វិធាន ៥៥(៩) ទំព័រ ៨៥។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/II/9 កថាខណ្ឌ ២៣។

[1310] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ [អ្នកស៊ើបអង្កេត ក.ស.ច.ស.] ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៤។

[1311] ដូចខាងលើ កថាខណ្ឌ ៣៣។ ពត៌មានបន្ថែមអំពីនីតិវិធីនៃមោឃភាពសូមមើលផ្នែក ៥.៥.២។

[1312] សូមមើល សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ២២។

[1313] សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្ម ទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១០។

[1314] វិធានផ្ទៃក្នុង វិធាន ៥៨(១)។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ ដីកាសម្រេចបដិសេធបណ្តឹងសុំមោឃភាពចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ឯកសារ D55/I កថាខណ្ឌ ១៥។ សំណុំរឿង ០០២ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន (ព្រឹក) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ E3/37។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ឯកសារ E3/83។

ជាលាយលក្ខណ៍អក្សរដាច់ដោយឡែក ដែលចុះហត្ថលេខាដោយជនត្រូវចោទ ដាក់បញ្ចូលក្នុងសំណុំរឿង[1315]។ នៅពេលណាដែលអាចធ្វើទៅបាន ការបោះបង់សិទ្ធិបែបនេះ ត្រូវថតសំឡេង ឬថតវីដេអូ[1316]។ ប្រសិនបើមេធាវីនោះត្រូវបានកោះហៅដោយត្រឹមត្រូវ ប៉ុន្តែខកខានមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទកំណត់ សហចៅក្រមស៊ើបអង្កេតអាចស្នើសុំឱ្យ ផ្នែកគាំពារការការពារក្តីចាត់តាំងមេធាវីបណ្តោះអាសន្នជ្រើសរើសចេញពីបញ្ជីឈ្មោះដែលមានចែងក្នុងវិធាន ១១ នៃវិធានផ្ទៃក្នុង។ នៅពេលដែលមេធាវីដែលត្រូវបានចាត់តាំងនោះមានឱកាសពិនិត្យសំណុំរឿងក្នុងរយៈពេលមួយសមស្របហើយនោះ សហចៅក្រមស៊ើបអង្កេតអាចសួរចម្លើយជនត្រូវចោទក្នុងវត្តមានមេធាវីដែលបានចាត់តាំងនោះ។ វត្តមានរបស់មេធាវីដែលបានចាត់តាំងនេះ ត្រូវបានចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃការសួរចម្លើយ រួមជាមួយនឹងមូលហេតុអវត្តមាននៃមេធាវីដែលត្រូវបានជ្រើសរើសដោយជនត្រូវចោទ ប្រសិនបើដឹងមូលហេតុនោះ[1317]។

ក្នុងករណីបន្ទាន់ និងនៅពេលដែលជនត្រូវចោទយល់ព្រម សហចៅក្រមស៊ើបអង្កេតអាចសួរចម្លើយជនត្រូវចោទដោយមិនមានវត្តមានមេធាវីរបស់ពួកគេ។ ស្ថានភាពបន្ទាន់ណាមួយអាចកើតមាន នៅពេលដែលភវនីយភាពខ្ពស់នៃការបាត់បង់ភស្តុតាងជារឿងរហូត ខណៈពេលរង់ចាំមេធាវីមកដល់ ដូចជាជនត្រូវចោទជិតដល់ពេលស្លាប់ជាដើម។ មូលហេតុសម្រាប់ភាពបន្ទាន់នេះត្រូវសរសេរចូលឱ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុនៃការសួរចម្លើយ[1318]។

នៅពេលដែលជនត្រូវចោទត្រូវសួរចម្លើយ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់សហព្រះរាជអាជ្ញាអំពីការសួរចម្លើយនោះឱ្យទាន់ពេលវេលា។ សហព្រះរាជអាជ្ញាអាចចូលរួមការសួរចម្លើយនោះ និងអាចស្នើសុំឱ្យសួរសំណួរទៅកាន់ជនត្រូវចោទ ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ កំណត់ហេតុជាលាយលក្ខណ៍អក្សរ ចុះនិទ្ទេសការបដិសេធណាមួយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណួរណាមួយ។ ភាគីផ្សេងទៀតមិនអាចមានវត្តមាននៅក្នុងអំឡុងពេលសួរចម្លើយជនត្រូវចោទទេ លើកលែងតែសហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការតទល់ជនត្រូវចោទដោយផ្ទាល់ ជាមួយនឹងភាគី ឬសាក្សីផ្សេងទៀត។ ក្នុងអំឡុងពេលតទល់គ្នារវាងសាក្សី និងជនត្រូវចោទ និងអនុលោមតាមដីកាបង្គាប់ឱ្យមានវិធានការការពារ ទម្រង់នីតិវិធីពាក់ព័ន្ធនឹងការសួរចម្លើយជនត្រូវចោទ បន្តអនុវត្ត[1319]។

ក្នុងករណីតទល់គ្នា សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចសួរសំណួរបាន ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត[1320]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបដិសេធមិនអនុញ្ញាតឱ្យសួរសំណួរណាមួយ ការបដិសេធនេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយនោះ[1321]។

### ៥.៤.៤.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

[1315] វិធានផ្ទៃក្នុង វិធាន ៥៨(២)។
[1316] វិធានផ្ទៃក្នុង វិធាន ២៥ និង ៥៨(២)។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៧។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស. ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ឯកសារ E142/3 កថាខណ្ឌ ៦។
[1317] វិធានផ្ទៃក្នុង វិធាន ៥៨(២)។
[1318] វិធានផ្ទៃក្នុង វិធាន ៥៨(៣)។
[1319] វិធានផ្ទៃក្នុង វិធាន ៥៨(៤)។
[1320] វិធានផ្ទៃក្នុង វិធាន ៥៨(៥)។ សូមមើលផងដែរ សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ D121/4 កថាខណ្ឌ ៣៧។
[1321] វិធានផ្ទៃក្នុង វិធាន ៥៨(៥)។

សហចៅក្រមស៊ើបអង្កេតក៏អាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ[1322]។ នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីមានមេធាវី សហចៅក្រមស៊ើបអង្កេតត្រូវកោះហៅមេធាវីនោះ យ៉ាងហោចណាស់ប្រាំថ្ងៃមុនពេលធ្វើការស្ដាប់ចម្លើយ ហើយក្នុងរយៈពេលនោះ មេធាវីនោះអាចពិនិត្យមើលសំណុំរឿង[1323]។

សហចៅក្រមស៊ើបអង្កេតអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបាន តែក្នុងវត្តមានមេធាវីរបស់ពួកគេប៉ុណ្ណោះ លើកលែងតែដើមបណ្ដឹងរដ្ឋប្បវេណីបោះបង់សិទ្ធិមានវត្តមានមេធាវីចោល នៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរដាច់ដោយឡែក ដែលចុះហត្ថលេខាដោយដើមបណ្ដឹងរដ្ឋប្បវេណីនោះ ដាក់បញ្ចូលក្នុងសំណុំរឿង[1324]។ ទោះជាយ៉ាងណា ប្រសិនបើមេធាវីនោះត្រូវបានកោះហៅដោយត្រឹមត្រូវ ប៉ុន្តែខកខានមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទកំណត់ ការស្ដាប់ចម្លើយនោះត្រូវបានអនុញ្ញាតឱ្យធ្វើ ហើយអវត្តមានមេធាវីនោះត្រូវបានចុះនិទ្ទេសនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ[1325]។

នៅពេលដែលសហចៅក្រមស៊ើបអង្កេតស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ភាគីផ្សេងទៀតមិនអាចមានវត្តមានទេ លើកលែងតែសហចៅក្រមស៊ើបអង្កេតសម្រេចឱ្យមានការតទល់រវាងដើមបណ្ដឹងរដ្ឋប្បវេណីនោះដោយផ្ទាល់ជាមួយនឹងភាគី ឬសាក្សីផ្សេងទៀត[1326]។ វិធានទូទៅទាក់ទងនឹងការជូនដំណឹងអំពីមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានចែងនៅក្នុងវិធាន ៥៩(១) និង ៥៩(២) នៃវិធានផ្ទៃក្នុង ក៏អនុវត្តចំពោះការតទល់ណាមួយផងដែរ[1327]។ ក្នុងអំឡុងពេលនៃការតទល់ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីផ្សេងទៀតអាចសួរសំណួរបាន ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបដិសេធមិនអនុញ្ញាតឱ្យសួរ ការបដិសេធនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយ[1328]។

ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចត្រូវបានស្ដាប់ចម្លើយដោយអ្នកស៊ើបអង្កេត អ.វ.ត.ក. ផងដែរ បន្ទាប់ពីមានដីកាចាត់ឱ្យស៊ើបសួរជំនួស៖ (១) នៅពេលដែលពួកគេយល់ព្រមយ៉ាងច្បាស់លាស់ (ដែលការយល់ព្រមនេះត្រូវមានចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយ) (២) នៅពេលដែលពួកគេមានមេធាវី ហើយបានលះបង់ការមានវត្តមាននៃមេធាវីរបស់ខ្លួន នៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរដាច់ដោយឡែកមួយ ដូចមានចែងក្នុងវិធាន ៥៩(២) នៃវិធានផ្ទៃក្នុង និង (៣) ត្រូវបានស្ដាប់ចម្លើយដោយមិនមានវត្តមានភាគីដទៃទៀត[1329]។

### ៥.៤.៤.៣. ការស្ដាប់ចម្លើយសាក្សី

សហចៅក្រមស៊ើបអង្កេតអាចស្ដាប់ចម្លើយពីជនណា ដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍ក្នុងការសំដែងឱ្យឃើញការពិត អនុលោមតាមបទប្បញ្ញត្តិនៃវិធាន ២៨ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសិទ្ធិមិនផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង[1330]។ ការស្ដាប់ចម្លើយជនរងគ្រោះ និងសាក្សី គឺជាលក្ខណៈជាសារវន្តនៃការស៊ើបអង្កេត[1331]។

លើកលែងតែក្នុងករណីដែលការតទល់គ្នាត្រូវបានរៀបចំឡើង សហចៅក្រមស៊ើបអង្កេត ឬអ្នកដែលពួកគេចាត់តាំង ត្រូវស្ដាប់ចម្លើយសាក្សីដោយមិនមានវត្តមានជនត្រូវចោទ ភាគីណាផ្សេងទៀត ឬ

---

1322 វិធានផ្ទៃក្នុង វិធាន ៥៩(១)។ សូមមើល សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៣។

1323 វិធានផ្ទៃក្នុង វិធាន ៥៩(១)។

1324 វិធានផ្ទៃក្នុង វិធាន ២៥ និង ៥៩(២)។

1325 វិធានផ្ទៃក្នុង វិធាន ៥៩(២)។

1326 វិធានផ្ទៃក្នុង វិធាន ៥៩(២)។

1327 វិធានផ្ទៃក្នុង វិធាន ៥៩(៣)។

1328 វិធានផ្ទៃក្នុង វិធាន ៥៩(៤)។

1329 វិធានផ្ទៃក្នុង វិធាន ៥៩(៦)។

1330 វិធានផ្ទៃក្នុង វិធាន ២៨ និង ៦០(១)។

1331 សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៥។

មេធាវីរបស់ពួកគេ នៅទីកន្លែងណាមួយ និងតាមលក្ខណៈដែលការពារការសម្ងាត់[1332]។ អ្នកស៊ើបអង្កេតត្រូវចាត់វិធានការសមហេតុផល និងចាំបាច់ឱ្យបានទាន់ពេលវេលា ដើម្បីបញ្ឈប់ការជ្រៀតជ្រែកទៅក្នុងការស្តាប់ចម្លើយសាក្សី ហើយប្រសិនបើមានជំនឿថា ការជ្រៀតជ្រែកជះឥទ្ធិពលលើសាក្សី បញ្ហានោះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយនោះ[1333]។ មុនពេលត្រូវបានស្តាប់ចម្លើយសាក្សីត្រូវធ្វើសម្បថ[1334]។ ការថតសំឡេង ឬការថតវីដេអូការស្តាប់ចម្លើយសាក្សីត្រូវបានអនុញ្ញាត ប៉ុន្តែមិនមែនជាលក្ខខណ្ឌតម្រូវទេ[1335]។ ទោះជាយ៉ាងណា ក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានណែនាំអ្នកស៊ើបអង្កេត និងបុគ្គលិករបស់ខ្លួនឱ្យធ្វើការថតសំឡេងរាល់ការស្តាប់ចម្លើយទាំងអស់។ ទោះបីជាគាត់យល់ឃើញថា សហចៅក្រមស៊ើបអង្កេតពីមុនបានបំពេញកិច្ចតាមឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនតម្រូវឱ្យមានការថតសំឡេងការស្តាប់ចម្លើយយ៉ាងណាក៏ដោយ ក៏ការថតសំឡេងគឺជា "ការអនុវត្តល្អ"[1336]។

បុគ្គលណាដែលត្រូវបានកោះហៅដោយសហចៅក្រមស៊ើបអង្កេតក្នុងនាមជាសាក្សី ត្រូវតែមកបង្ហាញខ្លួន។ ប្រសិនបើសាក្សីបដិសេធមិនបង្ហាញខ្លួនទេនោះ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាស្នើសុំឱ្យនគរបាលយុត្តិធម៌បង្ខំឱ្យសាក្សីមកបង្ហាញខ្លួន។ ដីកាបែបនេះត្រូវមានអត្តសញ្ញាណសាក្សី កាលបរិច្ឆេទ និងត្រូវចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេត[1337]។

ការទូទាត់ប្រាក់ណាមួយទៅសាក្សីដោយអ្នកស៊ើបអង្កេត ក៏ដូចជាមូលហេតុ និងកាលបរិច្ឆេទនៃការទូទាត់ប្រាក់នោះ ត្រូវធ្វើកំណត់ហេតុ និងត្រូវពិនិត្យផ្ទៀងផ្ទាត់ដោយអង្គភាពសាក្សី និងអ្នកជំនាញ។ ការទូទាត់បែបនោះត្រូវកម្រិតត្រឹមតែការបាត់បង់ប្រាក់ខែ ថ្លៃអាហារ និងថ្លៃធ្វើដំណើរ និងត្រូវផ្អែកលើអត្រាដែលកំណត់ដោយសេចក្តីសម្រេចរដ្ឋបាល[1338]។

#### ៥.៤.៤.៤. ការឆែកឆេរ និងការចាប់យកវត្ថុតាង

សហចៅក្រមស៊ើបអង្កេត ឬអ្នកដែលខ្លួនចាត់តាំង ត្រូវឆែកឆេរទីតាំងលំនៅដ្ឋានណាមួយ ដោយមានវត្តមានអ្នកកាន់កាប់ បើពុំនោះទេ ត្រូវធ្វើឡើងដោយមានវត្តមានសាក្សីពីររូប ដែលជ្រើសរើសដោយសហចៅក្រមស៊ើបអង្កេត ឬអ្នកដែលខ្លួនចាត់តាំង។ សាក្សីទាំងពីររូបនេះមិនត្រូវជាមន្ត្រីនគរបាលឡើយ[1339]
។

---

[1332] វិធានផ្ទៃក្នុង វិធាន ៦០(២)។ សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៥។ សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D274/1 កថាខណ្ឌ ២៦។

[1333] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D274/1 កថាខណ្ឌ ២៧។

[1334] វិធានផ្ទៃក្នុង វិធាន ២៤។ សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៦។

[1335] វិធានផ្ទៃក្នុង វិធាន ២៥។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៧។

[1336] សូមមើល សំណុំរឿង ០០៤ អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះអ្នកស៊ើបអង្កេតស្តីអំពី "សេចក្តីណែនាំស្តីពីការថតការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D266។

[1337] វិធានផ្ទៃក្នុង វិធាន ៦០(៣)។

[1338] សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ២៨។

[1339] វិធានផ្ទៃក្នុង វិធាន ៦១(១)។

គ្រប់ការឆែកឆេរត្រូវកត់ត្រាទុកជាលាយលក្ខណ៍អក្សរ និងត្រូវមានរៀបរាប់អំពីទីតាំងលំនៅដ្ឋាន អត្តសញ្ញាណរបស់អ្នកកាន់កាប់ ឬសាក្សី តាមករណីសមស្រប។ សហចៅក្រមស៊ើបអង្កេត ឬអ្នកដែលខ្លួនចាត់តាំង និងអ្នកកាន់កាប់ ឬសាក្សី ត្រូវចុះហត្ថលេខាលើដំណត់ហេតុជាលាយលក្ខណ៍អក្សរ[1340]។

សហចៅក្រមស៊ើបអង្កេត ឬអ្នកដែលខ្លួនចាត់តាំងត្រូវបង្ហាញភ័ស្តុតាងដែលរឹបអូសបានទៅឱ្យអ្នកកាន់កាប់ ឬសាក្សីពិនិត្យមើល មុននឹងបិទស្លាកបោះត្រាលើភ័ស្តុតាង។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃភ័ស្តុតាងដែលរឹបអូសបាន ត្រូវភ្ជាប់នូវបញ្ជីសារពើភណ្ឌលម្អិតផង[1341]។

នៅពេលណាមួយ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគី សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឱ្យប្រគល់វត្ថុណាមួយទៅឱ្យបុគ្គល ដែលខ្លួនបានរឹបអូសយកវត្ថុតាងនោះ ដែលការប្រគល់វិញនេះមិនប៉ះពាល់ដល់ដំណើរការនីតិវិធីឡើយ។ ដីកាបែបនេះត្រូវជូនដំណឹងភ្លាមទៅដល់បុគ្គលនោះ[1342]។

នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានទទួលឯកសារ ពួកគេត្រូវបញ្ជាក់ពីដំណើរការនៃការរក្សាទុកឯកសារ រវាងប្រភពនៃឯកសារ និងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមាននៅក្នុងរបាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស[1343]។

### ៥.៤.៤.៥. ដីការចាត់ឱ្យស៊ើបសួរជំនួស

សហចៅក្រមស៊ើបអង្កេតអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលតម្រូវឱ្យអ្នកស៊ើបអង្កេតណាម្នាក់ពីការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ បំពេញកិច្ចស៊ើបសួរ[1344]។ យ៉ាងណាមិញ មានតែនគរបាលយុត្តិធម៌ប៉ុណ្ណោះ ដែលមានអំណាចអនុវត្តវិធានការចាប់បង្ខំ[1345]។

ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចចេញក្នុងទម្រង់ទូទៅឡើយ។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើការស៊ើបសួរ ដែលត្រូវជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងបទល្មើសណាមួយ ឬបទល្មើសដែលកំពុងស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតត្រូវកំណត់ពេលវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះហត្ថលេខា និងកាលបរិច្ឆេទដោយសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតអាចដកដីកាចាត់ឱ្យស៊ើបសួរជំនួសនៅពេលណាក៏បាន[1346]។

អ្នកទទួលការចាត់តាំងត្រូវធ្វើការងារក្រោមការដឹកនាំរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវរាយការណ៍ជូនទៅសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ទាក់ទងនឹងការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស[1347]។ នៅពេលដែលដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវប្រគល់ឱ្យទៅអ្នកស៊ើបអង្កេត ឬនគរបាលយុត្តិធម៌ ជននោះត្រូវអនុវត្តដូចខាងក្រោម៖ (១) នគរបាលយុត្តិធម៌ ឬ អ្នកស៊ើបអង្កេត ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួររបស់ខ្លួន ដែលត្រូវអនុលោមតាមបញ្ញត្តិនៃវិធាន ៥១(៨) នៃវិធានផ្ទៃក្នុង តាមករណីសមស្រប (២) នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតមិនត្រូវសួរចម្លើយជនត្រូវ

[1340] វិធានផ្ទៃក្នុង វិធាន ៦១(២)។
[1341] វិធានផ្ទៃក្នុង វិធាន ៦១(៣)។
[1342] វិធានផ្ទៃក្នុង វិធាន ៦១(៤)។
[1343] សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្ត្រអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៣៥។
[1344] វិធានផ្ទៃក្នុង វិធាន ៦២(១)។ សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៥។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ឯកសារ E142/3 កថាខណ្ឌ ៦។
[1345] វិធានផ្ទៃក្នុង វិធាន ៦២(១)។
[1346] វិធានផ្ទៃក្នុង វិធាន ៦២(២)។
[1347] វិធានផ្ទៃក្នុង វិធាន ៦២(៣)។

ចោទឡើយ ប៉ុន្តែអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមអនុវិធាន ៥៩(៦) នៃវិធានផ្ទៃក្នុង និង (៣) នគរបាលយុត្តិធម៌អាចឆែកឆេរ និងចាប់យកភស្តុតាងបាន ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត[1348]។

បទប្បញ្ញត្តិនៃវិធាន ៥១ នៃវិធានផ្ទៃក្នុង ស្តីពីការឃុំខ្លួន ត្រូវអនុវត្តចំពោះការស៊ើបសួរតាមដីកាចាត់ឱ្យស៊ើបសួរជំនួស[1349]។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតអនុវត្តអំណាចរបស់សហព្រះរាជអាជ្ញា[1350]។ ភស្តុតាងដែលប្រមូលបានដោយអ្នកស៊ើបអង្កេត ត្រូវបញ្ជូនទៅក្រឡាបញ្ជី ដែលត្រូវរក្សាទុកក្នុងសំណុំរឿង[1351]។

### ៥.៤.៥. ការចូលពិនិត្យសំណុំរឿង

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាទុកសំណុំរឿង រួមទាំងកំណត់ហេតុ និងរបាយការណ៍ស៊ើបអង្កេត[1352]។ សំណុំរឿងមានភស្តុតាងទាំងអស់ ទាំងដាក់បន្ទុក និងដោះបន្ទុក ដែលប្រមូលបានក្នុងអំឡុងពេលកិច្ចស៊ើបសួរ ហើយពាក់ព័ន្ធទៅនឹងបទចោទប្រឆាំងនឹងជនជាប់ចោទ រួមមានកំណត់ហេតុនៃកិច្ចស៊ើបសួរដែលត្រូវបានធ្វើឡើងក្នុងពេលស៊ើបសួរ កំណត់ហេតុជាលាយលក្ខណ៍អក្សរ និងការថតសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយ ក៏ដូចជាពាក្យសុំដែលភាគីនានានៃកិច្ចដំណើរការនីតិវិធីបានស្នើ[1353]។ ជនសង្ស័យ បន្ទាប់ពីត្រូវបានចោទប្រកាន់ និងមេធាវីរបស់ខ្លួន ត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងភ្លាម[1354]។

សហព្រះរាជអាជ្ញា និងមេធាវីដំណាងភាគីផ្សេងទៀត មានសិទ្ធិពិនិត្យសំណុំរឿងនៅគ្រប់ពេលវេលា ក្នុងអំឡុងពេលស៊ើបអង្កេត និងមានសិទ្ធិថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជី[1355]។ ការចូលពិនិត្យសំណុំរឿងនេះអាចធ្វើទៅបានតែក្នុងពេលម៉ោងធ្វើការប៉ុណ្ណោះ និង "ត្រូវគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ"[1356]។ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីផ្សេងទៀតក៏មានសិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម ប៉ុន្តែត្រូវគោរពទៅតាមពេលវេលាកំណត់សមស្រប ដើម្បីធានាដល់និរន្តរភាពនៃកិច្ចដំណើរការនីតិវិធី[1357]។

### ៥.៤.៦. តួនាទីរបស់ភាគីក្នុងអំឡុងពេលស៊ើបអង្កេត

---

[1348] វិធានផ្ទៃក្នុង វិធាន ៦២(៣)។ សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៥។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ឯកសារ E142/3 កថាខណ្ឌ ៦។

[1349] វិធានផ្ទៃក្នុង វិធាន ៦២(៤)។

[1350] វិធានផ្ទៃក្នុង វិធាន ៦២(៤)។

[1351] សំណុំរឿង ០០២ អនុស្សរណៈ៖ ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធដូចជាយុទ្ធសាស្រ្តអនុវត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D171/5 កថាខណ្ឌ ៣៥។

[1352] វិធានផ្ទៃក្នុង វិធាន ៥៥(៦)។

[1353] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៨។

[1354] ដូចខាងលើ។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់ជនសង្ស័យក្នុងការចូលមើលសំណុំរឿងមុនពេលត្រូវបានចោទប្រកាន់ សូមមើលផ្នែក ៤.២.២។

[1355] វិធានផ្ទៃក្នុង វិធាន ៥៥(៦) និង ៥៥(១១)។ សូមមើលផងដែរ សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ D121/4 កថាខណ្ឌ ៣៧។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ១៨។

[1356] វិធានផ្ទៃក្នុង វិធាន ៥៥(៦)។

[1357] វិធានផ្ទៃក្នុង វិធាន ៥៥(១១)។

នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1358] ទោះមិនមែនជាកាតព្វកិច្ច អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរ ដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍ដល់ការបញ្ជាក់ការពិត[1359]។ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការសម្រេចលើសារៈប្រយោជន៍ ឬឱកាសក្នុងការអនុវត្តកិច្ចស៊ើបសួរ ដែលស្នើឡើងដោយភាគីណាមួយ និងត្រូវពិចារណាលើផលប៉ះពាល់ ដែលការអនុញ្ញាតទទួលយកសំណើនោះ អាចមានលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី[1360]។ ពាក់ព័ន្ធនឹងការពិចារណានោះ គឺសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ ជាពិសេស សិទ្ធិជំនុំជម្រះក្នុងពេលវេលាសមស្រប និងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្តី[1361]។ សហចៅក្រមស៊ើបអង្កេតក៏ពិចារណាលើបញ្ហាថាតើភាគីដែលស្នើសុំនោះ បានបំពេញកិច្ចការប្រកបដោយការយកចិត្តទុកដាក់ត្រឹមត្រូវ ក្នុងការដាក់សំណើនៅដំណាក់កាលសមស្របនៃការស៊ើបអង្កេតដែរ ឬទេ[1362]។

ដើម្បីឱ្យមានសុពលភាព សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរត្រូវស្របទៅនឹងសកម្មភាពស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[1363]។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរក៏ជាសំណើសុំឱ្យបំពេញកិច្ចការណាមួយដោយសហចៅក្រមស៊ើបអង្កេត ឬ តាមការចាត់តាំង ដោយអ្នកស៊ើបអង្កេត ឬនគរបាលយុត្តិធម៌ ដោយមានគោលបំណងដើម្បីប្រមូលព័ត៌មាន ដែលមានប្រយោជន៍ដល់ការបញ្ជាក់ការពិត[1364]។

ដើម្បីទទួលបានការអនុញ្ញាត កម្មវត្ថុនៃសំណើនោះត្រូវស្ថិតក្នុងវិសាលភាពនៃការស៊ើបអង្កេត[1365]។ ភាគីដែលធ្វើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីកិច្ចស៊ើបសួរដែលកំពុងស្នើសុំនោះ និងត្រូវពន្យល់ពីមូលហេតុដែលខ្លួនយល់ឃើញថា កិច្ចការនោះចាំបាច់សម្រាប់កិច្ចស៊ើបសួរ[1366]។ លក្ខខណ្ឌតម្រូវពាក់ព័ន្ធមានលក្ខខណ្ឌតម្រូវរងចំនួនពីរគឺ៖ (១) សំណើនោះត្រូវមានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និង (២) សំណើនោះត្រូវរៀបរាប់លម្អិតអំពីមូល

---

[1358] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើសំណើបែបនេះបាន ដរាបណាពាក្យសុំរបស់ពួកគេមិនត្រូវបានបដិសេធដោយសេចក្តីសម្រេចចុងក្រោយ។

[1359] វិធានផ្ទៃក្នុង វិធាន ៥៥(១០)។ សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តី អាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី បានដែរឬអត់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D173/2.3 កថាខណ្ឌ ៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ១៩។

[1360] សំណុំរឿង ០០៤ ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និង បង្កឲ្យមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D301/5 កថាខណ្ឌ ៣៤។

[1361] ដូចខាងលើ កថាខណ្ឌ ៣៤ និង៣៦។

[1362] ដូចខាងលើ កថាខណ្ឌ ៩០។ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៩០។

[1363] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ នួនជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/3/15 កថាខណ្ឌ ២៤។

[1364] សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអ្នកអង្កេត សម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D130/9/21 កថាខណ្ឌ ១៨។

[1365] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមានចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១៤។ សំណុំរឿង ០០៤ ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៤ របស់ អោ អាន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D244/1 កថាខណ្ឌ ១៤។

[1366] សំណុំរឿង ០០២ សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៤៥ និង៥៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៤។

ហេតុដែលព័ត៌មានដែលបានស្នើសុំនោះ អាចនាំដល់ការបញ្ជាក់ការពិត[1367]។ សហចៅក្រមស៊ើបអង្កេតអាចវាយតម្លៃបានល្អបំផុតថាតើសំណើនេះពិតជាអាចនាំដល់ការស្វែងរកការពិតដែរ ឬយ៉ាងណា[1368]។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ត្រូវមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ដើម្បីបង្ហាញឱ្យបានច្បាស់លាស់ដល់សហចៅក្រមស៊ើបអង្កេត ចំពោះអ្វីដែលគួរស្រាវជ្រាវរក និងចង្អុលពីវត្តមាននៃភ័ស្តុតាងដែលបានស្វែងរក[1369]។

ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទេនោះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចបដិសេធ ឱ្យបានឆាប់ដូចដែលអាចធ្វើទៅបាន ហើយក្នុងករណីណាក៏ដោយ នៅមុនថ្ងៃបញ្ចប់នៃកិច្ចស៊ើបសួរ[1370]។ ដីកាដែលជូនដំណឹងដល់ភាគីនេះ ត្រូវមានសំអាងហេតុគាំទ្រការបដិសេធនោះ ហើយបើកផ្លូវប្តឹងឧទ្ធរណ៍[1371]។ ការបដិសេធអាចធ្វើឡើងផ្អែកលើមូលដ្ឋានជាច្រើន រួមទាំងក្នុងការពិចារណាលើសារៈប្រយោជន៍ ឬឱកាសក្នុងការអនុវត្តកិច្ចស៊ើបសួរដែលស្នើសុំនោះ[1372]។ ការបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដែលអនុញ្ញាតឱ្យធ្វើទៅបានអនុលោមតាមវិធានផ្ទៃក្នុង បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍តាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង[1373]។

សមត្ថភាពរបស់ភាគីក្នុងការអនុវត្តកិច្ចស៊ើបសួរដោយខ្លួនឯងរបស់ពួកគេ កម្រិតត្រឹមតែការស៊ើបអង្កេតបឋម ដែលចាំបាច់ខ្លាំងសម្រាប់ការអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ[1374]។ ដូច្នេះ ភាគីអាចពិនិត្យប្រភពសាធារណៈ អាចទាក់ទងរដ្ឋនានា ដើម្បីស្វែងរកអត្ថិភាពសម្ភារៈពាក់ព័ន្ធ និងស្នើសុំសំណៅចម្លងសម្ភារៈទាំងនោះ និងអាចទាក់ទងបុគ្គលនានា ដើម្បីស្វែងរកថាតើពួកគេមានឯកសារជាក់លាក់ដែរ ឬទេ[1375]។ យ៉ាងណាមិញ ការពិនិត្យប្រភពអសាធារណៈ អាចជាកិច្ចស៊ើបសួរដែលត្រូវហាមឃាត់[1376]។

---

[1367] សំណុំរឿង ០០២ សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង' ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៤៩-៥០។ សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ អោ អាន ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៧ ឯកសារ D320/1/1/4 កថាខណ្ឌ ១៣។

[1368] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D260/1/1/3 កថាខណ្ឌ ១៦។

[1369] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០៤ និងការទទួលខុសត្រូវរបស់ អោ អាន ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D41/2 កថាខណ្ឌ ១១។

[1370] វិធានផ្ទៃក្នុង វិធាន ៥៥(១០)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេតរបស់មេធាវីនួនជា: ចំពោះលិខិតចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០៩ ស្តីពីការ "ខ្វះទំនុកចិត្តចំពោះការស៊ើបសួរ" ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៩ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ឯកសារ D221/1 ទំព័រ ៣។

[1371] វិធានផ្ទៃក្នុង វិធាន ៥៥(១០)។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំង 'ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ' ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២២-២៨។

[1372] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។

[1373] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ខ)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ១៥។

[1374] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី បានដែរឬអត់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D173/2.3 កថាខណ្ឌ ១០។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E251 កថាខណ្ឌ ៣៧។

[1375] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលគាំទ្រការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ១២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើ សំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D273/3/5 កថាខណ្ឌ ២៩។

[1376] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី បានដែរឬអត់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D173/2.3 កថាខណ្ឌ ១១។

ភាគីក៏អាចជំទាស់ទៅនឹងសុពលភាពនៃការស៊ើបអង្កេតរបស់ភាគីណាមួយ ហើយស្នើសុំឱ្យមោឃភាព នៅពេលដែលវិការៈផ្នែកនីតិវិធី បានប៉ះពាល់ដល់សិទ្ធិរបស់ភាគីនោះ[1377]។ សហព្រះរាជអាជ្ញាក៏អាចស្នើសុំឱ្យបន្ថែមបទចោទ ក្នុងអំឡុងពេលស៊ើបអង្កេតផងដែរ[1378]។

នៅគ្រប់ពេលវេលាក្នុងអំឡុងពេលស៊ើបអង្កេត ជនត្រូវចោទអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត ជំនួសខ្លួន[1379]។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់សំអាងហេតុពិតប្រាកដ[1380]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅក្នុងករណីណាក៏ដោយ នៅមុនបញ្ចប់កិច្ចស៊ើបសួរ[1381]។ ដីកាបដិសេធត្រូវមានសំអាងហេតុគាំទ្រការបដិសេធនោះ[1382]។ ជនត្រូវចោទត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ ហើយអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ[1383]។

នៅគ្រប់ពេលវេលាក្នុងអំឡុងពេលស៊ើបអង្កេត ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត ជំនួសខ្លួន។ សំណើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់សំអាងហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត មិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅក្នុងករណីណាក៏ដោយ នៅមុនបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុគាំទ្រការបដិសេធនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ ហើយអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ[1384]។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរណា ដែលទាក់ទងទៅនឹងអង្គហេតុដែលមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះឡើយ[1385]។

### ៥.៤.៧. ការផ្សព្វផ្សាយព័ត៌មាន

1377 វិធានផ្ទៃក្នុង វិធាន ៤៨ និង ៧៦។ ពត៌មានបន្ថែមអំពីនីតិវិធីនៃមោឃភាពសូមមើលផ្នែក ៥.៥.២។

1378 សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៨។

1379 វិធានផ្ទៃក្នុង វិធាន ៥៨(៦)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ៣៣។ សូមមើល*ឧទាហរណ៍* សំណុំរឿង ០០៣ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៥ ឯកសារ D128.1 កថាខណ្ឌ ២០-២១។

1380 វិធានផ្ទៃក្នុង វិធាន ៥៨(៦)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ៤២។

1381 វិធានផ្ទៃក្នុង វិធាន ៥៨(៦)។

1382 វិធានផ្ទៃក្នុង វិធាន ៥៨(៦)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៣។

1383 វិធានផ្ទៃក្នុង វិធាន ៥៨(៦)។

1384 វិធានផ្ទៃក្នុង វិធាន ៥៩(៥)។

1385 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១១។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ១៦។

ជាទូទៅ កិច្ចស៊ើបសួរមិនត្រូវធ្វើជាសាធារណៈឡើយ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី[1386]។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបអង្កេតត្រូវរក្សាការសម្ងាត់[1387]។ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់ និងផ្តល់សិទ្ធិតិចតួចក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ[1388]។ ការណ៍នេះរួមបញ្ចូលទាំងការធ្វើចំណាត់ថ្នាក់ឯកសារ និងការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ[1389]។ ទោះជាយ៉ាងណា ការរក្សាការសម្ងាត់ត្រូវតែមានតុល្យភាពជាមួយនឹងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង[1390]។

តាមរយៈផ្នែកកិច្ចការសាធារណៈ សហចៅក្រមស៊ើបអង្កេតអាចផ្តល់ដោយរួមគ្នា នូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿង ដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា "ជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មានមិនពិត ឬព័ត៌មាននាំឱ្យមានការភាន់ច្រឡំ"[1391]។

សហចៅក្រមស៊ើបអង្កេតអាចផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់អ្នកសារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគី ឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ ក្នុងកាលៈទេសៈពិសេស ស្ថិតក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងរបស់ខ្លួន និងបន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី[1392]។ ប្រសិនបើបុគ្គលណាមួយមិនគោរពតាមលក្ខខណ្ឌណាមួយ ដែលសហចៅក្រមស៊ើបអង្កេតបានតម្រូវ សហចៅក្រមស៊ើបអង្កេតអាចដោះស្រាយបញ្ហានេះអនុលោមតាមវិធាន៣៥ ដល់ ៣៨ នៃវិធានផ្ទៃក្នុង[1393]។ ករណីខ្វែងយោបល់គ្នាណាមួយដែលកើតមានរវាងសហចៅក្រមស៊ើបអង្កេត ចំពោះភាពសាធារណៈនៃការស៊ើបអង្កេត មិនត្រូវដោះស្រាយតាមវិធាន ៧២ នៃវិធានផ្ទៃក្នុងនោះទេ ដែលជាវិធានដោះស្រាយករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត[1394]។

---

[1386] វិធានផ្ទៃក្នុង វិធាន ៥៦(១)។ សូមមើល សំណុំរឿង ០០៤/០១ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D309/2 កថាខណ្ឌ ១៣។ សំណុំរឿង ០០៤/០១ សេចក្តីសម្រេចលើសំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួន ដែលបានជ្រើសរើសចេញពីក្នុងសំនុំរឿង ០០៤/១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D313/2 កថាខណ្ឌ ៤។ សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើទីពីររបស់ មាស មុត សុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជា ឯកសារសាធារណៈដោយមានឧបសម្ព័ន្ធ ក ជាឯកសារសារធារណៈ និងឧបសម្ព័ន្ធ ខ ជាឯកសារសម្ងាត់ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D142/1 កថាខណ្ឌ ១៣។

[1387] វិធានផ្ទៃក្នុង វិធាន ៥៦(១)។ សូមមើល សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩ ឯកសារ D138 កថាខណ្ឌ ១២។

[1388] សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D309/6 កថាខណ្ឌ ២០។

[1389] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D309/2 កថាខណ្ឌ ១២។

[1390] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ មាស មុត សុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាឯកសារសាធារណៈដោយមានឧបសម្ព័ន្ធ ក និង ខជាឯកសារសាធារណៈ និងឧបសម្ព័ន្ធ គ ជាឯកសារសម្ងាត់ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D129/1 កថាខណ្ឌ ១១។

[1391] វិធានផ្ទៃក្នុង វិធាន ៥៦(២)(ក)។ សូមមើល សំណុំរឿង ០០៣ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្តីប្រកាសព័ត៌មានជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ឯកសារ D14/1/3 កថាខណ្ឌ ២៥ និង ៣១។

[1392] វិធានផ្ទៃក្នុង វិធាន ៥៦(២)(ខ)។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរួមរបស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ យឹម ទិត្យ សុំពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70 D193/72 D193/75) ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D193/91/7 កថាខណ្ឌ ២៩។

[1393] វិធានផ្ទៃក្នុង វិធាន ៥៦(២)(ខ)។

[1394] វិធានផ្ទៃក្នុង វិធាន ៥៦(៣)។

បន្ទាប់ពីការចេញដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះអាចធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដោយមានការកោសលុប ប្រសិនបើខ្លួនយល់ឃើញថាវាចាំបាច់តាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ត្រង់ចំណុចនេះ អង្គបុរេជំនុំជម្រះថ្លឹងថ្លែងភាពសម្ងាត់នៃកិច្ចស៊ើបសួរ និងភាពចាំបាច់ក្នុងការធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរដំណែល[1395]។

## ៥.៤.៨. ការឃុំខ្លួនបណ្តោះអាសន្ន និងការដោះលែងឱ្យនៅក្រៅឃុំ

សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ក្រោយពេលមានសវនាការតទល់គ្នា[1396]។ ប្រសិនបើជនត្រូវចោទមិនមានជំនួយពីមេធាវីណាមួយនៅឡើយទេ ជនត្រូវចោទត្រូវបានប្រាប់អំពីសិទ្ធិមានមេធាវីការពារ ដូចមានចែងក្នុងវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង[1397]។ ជនត្រូវចោទអាចលះបង់សិទ្ធិមានមេធាវីរបស់ខ្លួនបាន[1398]។ ជនត្រូវចោទក៏មានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួនផងដែរ[1399]។ ក្នុងអំឡុងពេលសវនាការតទល់ សហចៅក្រមស៊ើបអង្កេត ស្តាប់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទ ហើយនៅពេលបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវចេញសេចក្តីសម្រេចលើការឃុំខ្លួន។ ប្រសិនបើមិនសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នទេ ជនត្រូវចោទត្រូវដោះលែងឱ្យមានសេរីភាព[1400]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន[1401]។

ទោះជាយ៉ាងណា ក្នុងករណីដែលជនត្រូវចោទ ឬមេធាវីរបស់ពួកគេស្នើសុំពេលវេលារៀបចំការការពារខ្លួនរបស់ពួកគេនោះ សហចៅក្រមស៊ើបអង្កេតមិនបង្គាប់ឱ្យមានការឃុំខ្លួនបណ្តោះអាសន្នភ្លាមៗនោះទេ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេត តាមរយៈដីកាសម្រេចមានសំអាងហេតុ អាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទក្នុងរយៈពេលមានកំណត់ណាមួយ ដែលមិនអាចលើសរយៈពេលប្រាំពីរថ្ងៃឡើយ។ ក្នុងរយៈពេលនោះ ជនត្រូវចោទត្រូវនាំខ្លួនមកចំពោះមុខសហចៅក្រមស៊ើបអង្កេតម្តងទៀត ដែលបន្ទាប់មកត្រូវធ្វើនីតិវិធីឃុំខ្លួនបណ្តោះអាសន្ន ទោះជាជនត្រូវចោទមានជំនួយពីមេធាវី ឬមិនមានក៏ដោយ។ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នណាមួយ ត្រូវពិចារណាដោយគណនារយៈពេលឃុំខ្លួនបណ្តោះអាសន្នដែលអនុញ្ញាតដោយវិធាន ៦៣ នៃវិធានផ្ទៃក្នុង[1402]។

ក្នុងករណីដែលមេធាវីរបស់ជនត្រូវចោទមិនទំនេរ ឬប្រសិនបើពួកគេមិនមានវត្តមាននៅកាលបរិច្ឆេទ និងពេលវេលាដែលបានគ្រោងទុក និងក្នុងករណីដែលជនត្រូវចោទបានស្នើសុំជំនួយពីមេធាវីនោះ សហចៅក្រមស៊ើបអង្កេតត្រូវស្នើទៅផ្នែកគាំពារការពារក្តី ឱ្យចាត់តាំងមេធាវីបណ្តោះអាសន្ន ចេញពីបញ្ជីដែលមានចែងក្នុងវិធាន ១១ នៃវិធានផ្ទៃក្នុង[1403]។

---

[1395] សំណុំរឿង ០០៤/០១ សេចក្តីសម្រេចលើសំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួន ដែលបានជ្រើសរើសចេញពីក្នុងសំនុំរឿង ០០៤/១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D313/2 កថាខណ្ឌ ៥។

[1396] វិធានផ្ទៃក្នុង វិធាន ៦៣(១)(ក)។

[1397] វិធានផ្ទៃក្នុង វិធាន ៦៣(១)(ក)។

[1398] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/54 កថាខណ្ឌ ១៣ និង ១៨។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធបណ្តឹងសុំមោឃភាពចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ឯកសារ D55/I កថាខណ្ឌ ៧។

[1399] វិធានផ្ទៃក្នុង វិធាន ៦៣(១)(ក)។ សំណុំរឿង ០០២ សេចក្តីសម្រេចឃាត់ខ្លួន អៀង ធីរិទ្ធ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C15 ទំព័រ ២។ សំណុំរឿង ០០២ សេចក្តីសម្រេចឃាត់ខ្លួន អៀង សារី ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C14 ទំព័រ ២។

[1400] វិធានផ្ទៃក្នុង វិធាន ៦៣(១)(ក)។

[1401] វិធានផ្ទៃក្នុង វិធាន ៦៣(១)(ក)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន (អៀង ធីរិទ្ធ) ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C20។ សំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន (នួន ជា) (ដំណាភ្ជាប់ឯកសារ) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ C11/1។ សំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន (ខៀវ សំផន) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ C26។ សំណុំរឿង ០០១ ដីកាបង្គាប់ឲ្យឃុំខ្លួន កាំង ហ្កេកអ៊ាវ (ឌុច) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ C4។

[1402] វិធានផ្ទៃក្នុង វិធាន ៦៣(១) (ខ)។

[1403] វិធានផ្ទៃក្នុង វិធាន ៦៣(១) (គ)។

ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នត្រូវ៖ (១) បង្ហាញមូលដ្ឋានអង្គច្បាប់ និងអង្គហេតុសម្រាប់ការឃុំខ្លួន ផ្អែកតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង (២) បញ្ជាក់រយៈពេលអតិបរមាដំបូងនៃការឃុំខ្លួនបណ្ដោះអាសន្ន និង (៣) នៅពេលជូនដំណឹងដល់ជនត្រូវចោទត្រូវអមទៅជាមួយនូវឯកសារបញ្ជាក់ប្រាប់អំពីសិទ្ធិរបស់គាត់[1404]។

សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន តែក្នុងករណីដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖ (១) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និង (២) ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

i. រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។
ii. ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង។
iii. ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។
iv. ការពារសន្តិសុខឱ្យជនដែលត្រូវចោទ។ ឬ
v. រក្សាសណ្ដាប់ធ្នាប់សាធារណៈ[1405]។

មានតែលក្ខខណ្ឌទាំងអស់នេះតែប៉ុណ្ណោះ ដែលត្រូវបំពេញ ហើយសហចៅក្រមស៊ើបអង្កេតមិនតម្រូវឱ្យបញ្ជាក់ទស្សនៈលើគ្រប់លក្ខខណ្ឌទាំងអស់នេះទេ[1406]។ ឃ្លាថា "បានប្រព្រឹត្ត" មានន័យថា "ជាការបង្កឱ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល" ដែលរួមបញ្ចូលការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជំរុញ ឬការប្រព្រឹត្តិ និងការទទួលខុសត្រូវរបស់ថ្នាក់លើ[1407]។ នៅក្នុងការពិនិត្យថាតើមានមូលហេតុច្បាស់លាស់ឱ្យជឿជាក់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អង្គបុរេជំនុំជម្រះបានសម្រេចថាតើ អង្គហេតុ ឬព័ត៌មានដែលមានស្រាប់ អាចធ្វើឱ្យអ្នកសង្កេតការដោយមិនលម្អៀងជឿជាក់ថា បុគ្គលដែលពាក់ព័ន្ធ ធ្លាប់បានប្រព្រឹត្តបទល្មើសដែរ ឬទេ[1408]។ ក្នុងការពិនិត្យលើតម្រូវការក្នុងការធានានូវវត្តមានរបស់ជនត្រូវចោទ វាសមស្របក្នុងការពិចារណាថាតើ ភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានចោទប្រកាន់ និងភវនីយភាពដែលថាការដាក់ទោសធ្ងន់ធ្ងរ អាចលើកទឹកចិត្តឱ្យមានការរត់គេចខ្លួនដែរ ឬទេ។ ទោះជាយ៉ាងណា ការណ៍នេះមិនមែនជាកត្តាសម្រេចតែមួយមុខនោះឡើយ[1409]។

---

[1404] វិធានផ្ទៃក្នុង វិធាន ៦៣(២)។

[1405] វិធានផ្ទៃក្នុង វិធាន ៦៣(៣)។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ២៥-៤៥។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៣៨-៦៣។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C20/I/27 កថាខណ្ឌ ៤៣-៧២។

[1406] សំណុំរឿង ០០២ ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ខៀវ សំផន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C26/8 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្ដោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៦៦។

[1407] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្ដោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៧១។

[1408] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C20/I/27 កថាខណ្ឌ ២១។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/54 កថាខណ្ឌ ៤៦។

[1409] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៤០។

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវប្រគល់ជាបន្ទាន់នូវដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នថតចម្លងមួយច្បាប់ទៅឱ្យជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ និងទៅឱ្យសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល[1410]។

ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតអាចពន្យាររយៈពេលនេះមួយឆ្នាំបន្ថែមទៀត។ ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងសម្រាប់រាល់បទឧក្រិដ្ឋទាំងអស់ ក្រៅពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. សម្រាប់រយៈពេលមិនលើសពីប្រាំមួយខែ។ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតអាចពន្យាររយៈពេលឃុំខ្លួនបណ្ដោះអាសន្ននេះ ចំនួនប្រាំមួយខែបន្ថែមទៀត[1411]។

ក្នុងការពិចារណាថាតើ រយៈពេលនៃការឃុំខ្លួនមានភាពសមហេតុផលឬទេនោះ លក្ខណៈវិនិច្ឆ័យទាំងនោះគឺ៖

i. រយៈពេលដែលនៅជាធរមាននៃការឃុំខ្លួន។
ii. រយៈពេលនៃការឃុំខ្លួន ដោយប្រៀបធៀបទៅនឹងចរិតលក្ខណៈនៃបទឧក្រិដ្ឋ។
iii. ផលវិបាកលើរូបរាងកាយ និងផ្លូវចិត្តនៃការឃុំខ្លួនជនជាប់ចោទ។
iv. ភាពស្មុគស្មាញនៃរឿងក្ដី និងការស៊ើបអង្កេត។
v. ការអនុវត្តនីតិវិធីទាំងមូល[1412]។

នៅក្នុងការពិនិត្យថាតើ ការបន្តការឃុំខ្លួនមានភាពចាំបាច់ឬអត់នោះ អង្គបុរេជំនុំជម្រះបានពិចារណាលើភាពសមហេតុផលនៃរយៈពេលឃុំខ្លួន និងការរីកចម្រើន និងការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួន[1413]។ ជាពិសេស ភាពសមាមាត្រនៃរយៈពេលឃុំខ្លួនធៀបទៅនឹងកាលៈទេសៈនានានៃរឿងក្ដី ត្រូវបានពិចារណា ថាតើស្ថាប័នស៊ើបអង្កេតបានអនុវត្តការងារយ៉ាងឆាប់រហ័ស និង “មិនមានដំណើរការនីតិវិធីណាមួយត្រូវបានធ្វើឡើងដោយអសកម្មនោះទេ” និងថាតើការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋទាំងឡាយ “កំពុងត្រូវបានបន្ត និងអនុវត្តនៅក្នុងលក្ខណៈមួយសមហេតុផល” ឬទេ[1414]។

ការឃុំខ្លួនបណ្ដោះអាសន្នអាចពន្យារពេលបាន ប្រសិនបើលក្ខខណ្ឌសម្រាប់ការឃុំខ្លួននោះនៅតែត្រូវបានបំពេញ[1415]។ ទោះជាយ៉ាងណា នៅពេលដែលអត្ថិភាពនៃ “មូលហេតុត្រូវបានរកឃើញយ៉ាងច្បាស់លាស់” ត្រូវបានបង្ហាញ លើកលែងតែភស្តុតាងដោះបន្ទុកត្រូវបានរកឃើញផ្សេងពីនេះទៅវិញ វាមាន

---

[1410] វិធានផ្ទៃក្នុង វិធាន ៦៣(៥)។
[1411] វិធានផ្ទៃក្នុង វិធាន ៦៣(៦)។
[1412] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៦៩។
[1413] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ៤៨ និង ៦១។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៦៤ និង ៦៨។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C20/9/15 កថាខណ្ឌ ៤៩។
[1414] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៧០។
[1415] សូមមើលសំណុំរឿង ០០២ ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួន បណ្ដោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ C20/4 កថាខណ្ឌ ១២។

លក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញលក្ខខណ្ឌតម្រូវនោះ នៅក្នុងដំណាក់កាលមុនការជំនុំជម្រះទាំងមូល[1416]។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងការពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុសម្រាប់ការពន្យារពេលបែបនោះ[1417]។

ការពន្យារពេលអាចត្រូវបានធ្វើឡើងតែក្រោយពេលដែលសហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ពួកគេ និងផ្ដល់រយៈពេល ១៥ថ្ងៃ ឱ្យដាក់អញ្ញត្រកម្មប៉ុណ្ណោះ[1418]។ មិនអាចមានការពន្យារពេលបែបនោះចំនួនពីរដងឡើយ ហើយដីកាសម្រេចពន្យារពេលនេះបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍[1419]។ ចំរវេលាកំណត់សម្រាប់ការពន្យារការឃុំខ្លួន គឺថាតើ អ្នកសង្កេតអព្យាក្រឹត ផ្អែកលើអង្គហេតុ និងព័ត៌មានដែលមាន ពេញចិត្តថានៅតែមានហេតុផលមានសំអាងហេតុច្បាស់លាស់ ដែលនាំឱ្យជឿជាក់ថាជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរ ឬយ៉ាងណា[1420]។

នៅក្នុងរឿងក្ដីទាំងអស់ ជនត្រូវចោទដែលស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបាននាំមកបង្ហាញខ្លួនចំពោះមុខសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់ យ៉ាងហោចណាស់រៀងរាល់បួនខែម្ដង[1421]។ រយៈពេលទាំងអស់នេះបានបន្តបន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1422]។ សហចៅក្រមស៊ើបអង្កេតត្រូវផ្ដល់ឱកាសឱ្យជនសង្ស័យពិភាក្សាអំពីការប្រព្រឹត្ត និងលក្ខខណ្ឌនានាក្នុងអំឡុងពេលឃុំខ្លួនបណ្ដោះអាសន្ន។ ក្នុងករណីដែលត្រូវមានវិធានការណ៍ណាមួយនោះ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាបង្គាប់សមស្រប។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយសម្រាប់នីតិវិធីនេះ ត្រូវដាក់ទៅក្នុងសំណុំរឿង[1423]។

ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ទៅអង្គបុរេជំនុំជម្រះ[1424]។ អង្គបុរេជំនុំជម្រះអាចពិនិត្យដីកាឃុំខ្លួនបណ្ដោះអាសន្ន ដោយធ្វើការពិនិត្យលើ៖ (១) នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតមុនពេលចេញដីកា (២) ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការពិចារណាលើការអនុវត្តវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង (៣) លក្ខណៈគ្រប់គ្រាន់នៃអង្គហេតុសម្រាប់ឈានដល់ការធ្វើសេចក្ដីសន្និដ្ឋានតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង (៤) ថាតើកាលៈទេសៈនានាដែលដីកានោះផ្អែកលើនៅតែមានអត្ថិភាពឬទេ និង (៥) បញ្ហាណាមួយបន្ថែមទៀត ដែលមិនទាន់បានដោះស្រាយ ដែលជាកម្មវត្ថុនៃ

---

[1416] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត អំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ C22/5/39 កថាខណ្ឌ ២១។

[1417] វិធានផ្ទៃក្នុង វិធាន ៦៣(៧)។

[1418] វិធានផ្ទៃក្នុង វិធាន ៦៣(៧)។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C9/4/7 កថាខណ្ឌ ៥២។ សូមមើលឧទាហរណ៍ សំណុំរឿង ០០១ លិខិតរបស់សហចៅក្រមស៊ើបអង្កេតជូនដំណឹងទៅជនជាប់ចោទ (វិធាន ៦៣.៧) ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C3/I។

[1419] វិធានផ្ទៃក្នុង វិធាន ៦៣(៧)។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C20/5/18 កថាខណ្ឌ ៥៥។

[1420] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C9/4/7 កថាខណ្ឌ ២៤។

[1421] វិធានផ្ទៃក្នុង វិធាន ៦៣(៨)។

[1422] សំណុំរឿង ០០២ សាលដីកាលើសំណើបន្ទាន់សុំឱ្យចេញដីកាបង្គាប់បន្តការសាកសួរ ទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនឡើងវិញ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ ឯកសារ 2 កថាខណ្ឌ ៥-៦។

[1423] វិធានផ្ទៃក្នុង វិធាន ៦៣(៨)។

[1424] វិធានផ្ទៃក្នុង វិធាន ៦៣(៤)។ សូមមើល*ឧទាហរណ៍* សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៦។

មូលដ្ឋានបណ្ដឹងឧទ្ធរណ៍[1425]។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន[1426]។

ក្នុងករណីដែលលក្ខខណ្ឌតម្រូវនៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលចែងក្នុងវិធាន ៦៣ នៃវិធានផ្ទៃក្នុង លែងបំពេញបាននោះ ជនត្រូវចោទអាចត្រូវបានដោះលែង តាមញត្តិរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសំណើរបស់សហព្រះរាជអាជ្ញា[1427]។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ពិចារណាដោះលែងជនសង្ស័យតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់របស់សហព្រះរាជអាជ្ញាមុនពេលចេញដីកាបែបនោះ។ "ដីកាណាមួយបង្គាប់ឱ្យដោះលែងជនត្រូវចោទណាម្នាក់ពីការឃុំខ្លួនមុនការជំនុំជម្រះ បើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍[1428]។

ក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់ពួកគេ អាចដាក់ពាក្យស្នើសុំឱ្យដោះលែង ទៅកាន់សហចៅក្រមស៊ើបអង្កេត រួមបញ្ចូលទាំងនៅពេលដែលសុខភាពរបស់ជនត្រូវចោទ "មានវិសមិតភាពជាមួយនឹងការឃុំខ្លួន"[1429]។ អាយុច្រើនមិនមែនជាឧបសគ្គនៃការឃុំខ្លួនទេ ហើយវិសមិតភាពនៃការឃុំខ្លួនជាមួយនឹងស្ថានភាពសុខភាពរបស់ជនត្រូវចោទ ត្រូវកំណត់តាមករណីជាក់ស្ដែងនីមួយៗ ដោយផ្អែកលើកាលៈទេសៈទាំងមូលនៃសាច់រឿង[1430]។ ភ្លាមៗបន្ទាប់ពីទទួលបានសំណើសុំឱ្យដោះលែង សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនវាទៅសហព្រះរាជអាជ្ញា ដែលបន្ទាប់មកត្រូវផ្ដល់មតិយោបល់របស់ខ្លួនក្នុងរយៈពេលប្រាំថ្ងៃ[1431]។"

យោងទៅតាមបទប្បញ្ញត្តិនៃវិធាន ៧២(២) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងករណីខ្វែងយោបល់ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុក្នុងរយៈពេលប្រាំថ្ងៃ ក្រោយពេលទទួលបានយោបល់ពីសហព្រះរាជអាជ្ញា[1432]។ រាល់ដីកាទាំងអស់ទាក់ទងនឹងការដោះលែង បើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ ដែលនៅក្នុងនោះជនត្រូវចោទមានបន្ទុកបង្ហាញភស្ដុតាងបញ្ជាក់ថា ការឃុំខ្លួនបណ្ដោះអាសន្នលែងមានអង្គសេចក្ដីទៀតហើយ[1433]។ ប្រសិនបើកាលៈទេសៈរបស់ជនត្រូវចោទផ្លាស់ប្ដូរចាប់ពីពាក្យសុំចុងក្រោយរបស់ខ្លួន ជនត្រូវចោទអាចដាក់ពាក្យសុំជាថ្មីម្ដងទៀត ក្នុងរយៈពេលមិនលើសពីបីខែ បន្ទាប់ពីសេចក្ដីសម្រេចចុងក្រោយលើពាក្យសុំដោះលែងមុន[1434]។

[1425] សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៨។

[1426] សំណុំរឿង ០០២ សាលដីកាអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំង នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/53 កថាខណ្ឌ ៤១។

[1427] វិធានផ្ទៃក្នុង វិធាន ៦៤(១)។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ២១។

[1428] វិធានផ្ទៃក្នុង វិធាន ៦៤(១)។

[1429] វិធានផ្ទៃក្នុង វិធាន ៦៤(២)។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៨២។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធសំណើសុំឱ្យដោះលែង ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ C36/III កថាខណ្ឌ ២។ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធសំណើសុំឱ្យដោះលែង ខៀវ សំផន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ C40/4 កថាខណ្ឌ ៣៣។

[1430] សំណុំរឿង ០០២ ដីកាសម្រេចបដិសេធសំណើសុំឱ្យដោះលែង ខៀវ សំផន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ C40/4 កថាខណ្ឌ ៣៣។

[1431] វិធានផ្ទៃក្នុង វិធាន ៦៤(២)។

[1432] វិធានផ្ទៃក្នុង វិធាន ៦៤(២)។

[1433] វិធានផ្ទៃក្នុង វិធាន ៦៤(២)។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ២១។

[1434] វិធានផ្ទៃក្នុង វិធាន ៦៤(៣)។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាសម្រេចបដិសេធសំណើសុំឱ្យដោះលែង ខៀវ សំផន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ C40/4 កថាខណ្ឌ ២។

សហព្រះរាជអាជ្ញា និងជនត្រូវចោទត្រូវទទួលបានការជូនដំណឹងភ្លាមអំពីដីកាសម្រេចដោះលែងជនត្រូវចោទពីការឃុំខ្លួន។ សហព្រះរាជអាជ្ញា និងជនត្រូវចោទ ក៏ត្រូវទទួលបានការជូនដំណឹងភ្លាមៗអំពីដីកាសម្រេចបដិសេធដោះលែងជនត្រូវចោទផងដែរ។ ការិយាល័យរដ្ឋបាល និង ប្រធានមន្ទីរឃុំឃាំង ត្រូវទទួលបានការជូនដំណឹងភ្លាមៗ នៅពេលដែលដីកាសម្រេចដោះលែងពីការឃុំខ្លួននេះចាប់ផ្តើមមានអានុភាពអនុវត្ត[1435]។

តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមសំណើរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឱ្យ ជនត្រូវចោទមានសេរីភាពឡើងវិញ ឬត្រូវដោះលែងពីការឃុំខ្លួន រួមបញ្ចូលទាំងការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[1436]។ សេចក្តីសម្រេចនេះតម្រូវឱ្យមានការកំណត់ពីភាពសមាមាត្ររវាងផលប្រយោជន៍សាធារណៈ និងសិទ្ធិមានសេរីភាពរបស់ជនត្រូវចោទ[1437]។ ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនត្រូវបានអនុញ្ញាតទេ នៅពេលដែលលក្ខខណ្ឌនៃការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ មានអាទិភាពតិចជាងតម្រូវការចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន[1438]។ ដីការបស់សហចៅក្រមស៊ើបអង្កេត ត្រូវមានបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើប្រាក់ធានា និងលក្ខខណ្ឌមួយចំនួន ដើម្បីធានាវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និងដើម្បីការពារអ្នកដទៃទៀត។ ដីកាសម្រេចនេះបើកផ្លូវប្តឹងឧទ្ធរណ៍[1439]។ ជនត្រូវចោទទទួលបានបង្កាន់ដៃពីក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ចំពោះទ្រព្យសម្បត្តិ ឬថវិកាដែលបានប្រគល់មកឱ្យ ជាការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[1440]។ ជនត្រូវចោទ និង សហព្រះរាជអាជ្ញា ត្រូវទទួលបានការជូនដំណឹងភ្លាមៗអំពីដីកាសម្រេចដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[1441]។

តាមសំណើរបស់សហព្រះរាជអាជ្ញា ឬតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន សហចៅក្រមស៊ើបអង្កេតអាចផ្លាស់ប្តូរ ព្យួរ ឬបន្ថែមលក្ខខណ្ឌ ឬបញ្ចប់ដីកាសម្រេចដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការពេលណាក៏បាន។ ជនត្រូវចោទ និងសហព្រះរាជអាជ្ញាត្រូវជូនដំណឹងភ្លាមអំពីដីកាសម្រេច ដែលបើកផ្លូវប្តឹងឧទ្ធរណ៍នេះ[1442]។

នៅពេលណាក៏បាន ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យមានការផ្លាស់ប្តូរ ឬ ព្យួរ លក្ខខណ្ឌណាមួយនៃដីកាសម្រេចដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសុំឱ្យបញ្ចប់ដីកាសម្រេចនោះ។ សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណើនេះទៅសហព្រះរាជអាជ្ញាភ្លាម ដើម្បីសុំយោបល់ ដែលសហព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលប្រាំថ្ងៃ។ ដោយយោងទៅលើបទប្បញ្ញត្តិនៃវិធាន ៧២(២) ទាក់ទងនឹងករណីខ្វែងយោបល់ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានយោបល់ពីសហព្រះរាជអាជ្ញា។ ជនត្រូវចោទ និងសហព្រះរាជអាជ្ញា ត្រូវទទួលបានការជូនដំណឹងភ្លាមអំពីដីកាសម្រេចនេះ[1443]។

---

[1435] វិធានផ្ទៃក្នុង វិធាន ៦៤(៤)។
[1436] វិធានផ្ទៃក្នុង វិធាន ៦៥(១)។
[1437] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៩១។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ឯកសារ C26/9/12 កថាខណ្ឌ ៥៩។
[1438] សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C20/I/27 កថាខណ្ឌ ៧៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/54 កថាខណ្ឌ ៨៣។
[1439] វិធានផ្ទៃក្នុង វិធាន ៦៥(១)។
[1440] វិធានផ្ទៃក្នុង វិធាន ៦៥(២)។
[1441] វិធានផ្ទៃក្នុង វិធាន ៦៥(៣)។
[1442] វិធានផ្ទៃក្នុង វិធាន ៦៥(៤)។
[1443] វិធានផ្ទៃក្នុង វិធាន ៦៥(៥)។

ប្រសិនបើជនត្រូវចោទរំលោភលក្ខខណ្ឌដែលមានចែងក្នុងដីកានេះ សហចៅក្រមស៊ើបអង្កេតអាចចេញសេចក្តីព្រមាន ឬចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះបាន។ ដីកាសម្រេចនេះបើកផ្លូវប្តឹងឧទ្ធរណ៍[1444]។

ការដាក់កម្រិតទំនាក់ទំនងរវាងបុគ្គលដែលស្ថិតក្នុងការឃុំខ្លួនមុនការជំនុំជម្រះ អាចត្រូវបានធ្វើឡើងដើម្បីការពារការដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ នៅពេលមានភ័ស្តុតាងសមរម្យ ដែលអាចបង្ហាញថាពិតជាមានហានិភ័យដែលថា ជនត្រូវចោទអាចត្រូវរ៉ូវគ្នាជាមួយជនត្រូវចោទផ្សេងទៀត ដើម្បីដាក់សម្ពាធបែបនេះ ខណៈពេលកំពុងស្ថិតនៅក្រោមការឃុំខ្លួន[1445]។

ការចេញដីកាដំណោះស្រាយ បញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន និង ដីកាសម្រេចដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅពេលដែលពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានផុត[1446]។ ទោះជាយ៉ាងណា នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាលក្ខខណ្ឌសម្រាប់ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមវិធាន ៦៣ និង ៦៥ នៃវិធានផ្ទៃក្នុង នៅតែបំពេញបាន សហចៅក្រមស៊ើបអង្កេត នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់ក្នុងដីកាដំណោះស្រាយ អាចសម្រេចបន្តឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ឬបន្តការដាក់ជនជាប់ចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតទាល់តែពួកគេត្រូវបាននាំមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1447]។

ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍បានដាក់ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការឃុំខ្លួន ឬដីកាសម្រេចដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត បន្តមានអានុភាពរហូតទាល់តែមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ[1448]។ អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងរយៈពេលបួនខែ ហើយថិរវេលានេះចាប់ផ្តើមគិតចាប់ពីការដាក់សេចក្តីសន្និដ្ឋានបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ[1449]។

ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ក្នុងការបន្តដាក់ជនជាប់ចោទក្នុងការឃុំខ្លួនបណ្តោះអាសន្ន ឬបន្តការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវលែងមានអានុភាពក្រោយរយៈពេលបួនខែ លើកលែងតែជនជាប់ចោទត្រូវបាននាំមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរយៈពេលនោះ[1450]។

ប្រសិនបើជនជាប់ចោទមិនអាចបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងដោយសារកាលៈទេសៈពិសេស ដូចជាស្ថានភាពសុខភាព អង្គជំនុំជម្រះសាលាដំបូងសម្រេចអំពីការឃុំខ្លួន

---

[1444] វិធានផ្ទៃក្នុង វិធាន ៦៥(៦)។

[1445] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ C33/I/7 កថាខណ្ឌ ២១។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិចូលទស្សនា សូមមើលផ្នែក ៤.១៣។

[1446] វិធានផ្ទៃក្នុង វិធាន ៦៨(១)។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដីការដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/10 កថាខណ្ឌ ២៥។

[1447] វិធានផ្ទៃក្នុង វិធាន ៦៨(១)។ ចំពោះអ្វីទៅដែលជា “សេចក្តីសម្រេចមានសំអាងហេតុជាក់លាក់” សូមមើលសំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដីការដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/10 កថាខណ្ឌ ២៥-៣៣។

[1448] វិធានផ្ទៃក្នុង វិធាន ៦៨(២)។ សូមមើល*ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ D427/1/27 កថាខណ្ឌ ៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/2/13។

[1449] វិធានផ្ទៃក្នុង វិធាន ៦៨(២)។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ២៤។

[1450] វិធានផ្ទៃក្នុង វិធាន ៦៨(៣)។

បណ្ដោះអាសន្ន បន្ទាប់ពីស្ដាប់ចម្លើយរបស់ជនជាប់ចោទ ដោយប្រើប្រាស់មធ្យោបាយសោតទស្សន៍សម ស្រប ឬដោយចុះទៅជួបជនជាប់ចោទនៅកន្លែងឃុំខ្លួនពួកគេ[1451]។

### ៥.៤.៩. ការបិទបញ្ចប់ការស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេតបានបិទបញ្ចប់ការស៊ើបអង្កេត នៅពេលដែលពួកគេសម្រេចបានរាល់កិច្ចការទាំងអស់ដែលខ្លួនជឿជាក់ថាចាំបាច់ដល់ការបញ្ជាក់ការពិត ទាក់ទងនឹងអង្គហេតុដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[1452]។ ការណ៍នេះរួមបញ្ចូលការពិនិត្យមើលភស្តុតាងដោះបន្ទុកទាំងអស់[1453]។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបអង្កេតបានចប់សព្វគ្រប់ហើយ ពួកគេជូនដំណឹងទៅភាគី និងមេធាវីរបស់ពួកគេ[1454]។ សេចក្ដីសម្រេចនេះត្រូវធ្វើជាសាធារណៈ[1455]។

បន្ទាប់មក ភាគីមានរយៈពេល ១៥ ថ្ងៃ ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ដែលអាចត្រូវបានពន្យារពេលអនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង[1456]។ ភាគីអាចបោះបង់រយៈពេលនេះ[1457]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតបន្ថែមទៀត សហចៅក្រមស៊ើបអង្កេតត្រូវចេញសេចក្ដីជូនដំណឹងថ្មី និងអនុញ្ញាតឱ្យបន្ថែមរយៈពេល ១៥ ថ្ងៃ ហើយបន្ទាប់មកចេញសេចក្ដីជូនដំណឹងមួយផ្សេងទៀតអំពីការស៊ើបអង្កេត[1458]។

នៅពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ពួកគេត្រូវចេញដីកាសម្រេចមានសំអាងហេតុ។ ដីកានោះក៏បដិសេធសំណើសុំណាមួយផ្សេងទៀតផងដែរ ដែលបានដាក់ពីមុននៅក្នុងការស៊ើបអង្កេត ដែលសហចៅក្រមស៊ើបអង្កេតមិនទាន់បានចេញសេចក្ដីសម្រេចនៅឡើយ[1459]។

ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីការជូនដំណឹងអំពីដីកាបដិសេធកិច្ចស៊ើបសួរបន្ថែម ភាគីទាំងអស់អាចដាក់បណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ភាគីអាចបោះបង់សិទ្ធិចោលមិនប្ដឹងឧទ្ធរណ៍នេះបាន ទោះបីជាមានវត្តមានរបស់មេធាវី ឬក្នុងករណីដែលមេធាវីត្រូវបានកោះហៅដោយត្រឹមត្រូវ ប៉ុន្តែមិនបានចូលបង្ហាញខ្លួន[1460]។ នៅពេលដែលរយៈពេលនេះផុត ឬត្រូវបានបោះបង់ចោល ឬ បណ្ដឹងឧទ្ធរណ៍ដែលបាន

---

[1451] វិធានផ្ទៃក្នុង វិធាន ៦៨(៤)។
[1452] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៣៦។
[1453] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ៣៥។
[1454] វិធានផ្ទៃក្នុង វិធាន ៦៦(១)។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៣៦។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226 កថាខណ្ឌ ៨។
[1455] វិធានផ្ទៃក្នុង វិធាន ៦៦(១)។
[1456] វិធានផ្ទៃក្នុង វិធាន ៦៦(១)។ សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៦។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំពន្យាពេលរយៈពេលកំណត់ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្រោយពីមានការជូនដំណឹងអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D340/1 កថាខណ្ឌ ៦ និង ៨។
[1457] វិធានផ្ទៃក្នុង វិធាន ៦៦(១)។ សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៦។
[1458] សូមមើល សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៥។ សំណុំរឿង ០០៤/០២ សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១៧ ឯកសារ D334/2 កថាខណ្ឌ ១៣។
[1459] វិធានផ្ទៃក្នុង វិធាន ៦៦(២)។
[1460] វិធានផ្ទៃក្នុង វិធាន ៦៦(៣)។

លើកឡើងពីខាងលើត្រូវបានជម្រះ និងសម្រេចហើយ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា[1461]។

នៅពេលដែលសហព្រះរាជអាជ្ញា យល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា ការស៊ើបសួរត្រូវបានចប់សព្វគ្រប់ហើយ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរមួយជាលាយលក្ខណ៍អក្សរ នឹងមានសំអាងហេតុ ហើយត្រូវបញ្ជូនសំណុំរឿងនោះត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ក្នុងរយៈពេល ៤៥ ថ្ងៃ ប្រសិនបើជនជាប់ចោទជាប់ក្នុងឃុំ និងរយៈពេលបីខែក្នុងករណីផ្សេងទៀត គិតចាប់ពីថ្ងៃដែលសហព្រះរាជអាជ្ញាបានទទួលសំណុំរឿង[1462]។ សហព្រះរាជអាជ្ញាអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់[1463]។ ជនត្រូវចោទអាចឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា[1464]។

នៅពេលដែលមានភស្តុតាងថ្មី ក្រោយចេញដីកាសម្រេចលើកលែងចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរឡើងវិញ តាមគំនិតផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា[1465]។

### ៥.៤.១០. ការកាត់បន្ថយវិសាលភាពកិច្ចស៊ើបសួរ

ដើម្បីធានាបាននូវកិច្ចដំណើរការតុលាការប្រកបដោយ យុត្តិធម៌ អត្ថន័យ និងឆាប់រហ័ស ដោយពិចារណាលើលក្ខខណ្ឌតម្រូវជាក់លាក់នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. នៅពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ(ច្រើន)[1466]។ សហចៅក្រមស៊ើបអង្កេតត្រូវធានាថា អង្គហេតុដែលនៅសល់ អាចយកមកធ្វើជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ(ច្រើន)[1467]។

---

[1461] វិធានផ្ទៃក្នុង វិធាន ៦៦(៤)។ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣២។ សូមមើលឧទាហរណ៍ សំណុំរឿង ០០២ ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D385។ ចំពោះអ្វីទៅដែលថា "ភ្លាមៗ" សូមមើលសំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៧។

[1462] វិធានផ្ទៃក្នុង វិធាន ៦៦(៥) និង ទំព័រ ៨៣។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០១៨ ឯកសារ D378 កថាខណ្ឌ ២៩-៣០។

[1463] វិធានផ្ទៃក្នុង វិធាន ៦៦(៥)។

[1464] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស. បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៧។

[1465] វិធានផ្ទៃក្នុង វិធាន ៧០។

[1466] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (១)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D337 កថាខណ្ឌ ៧។

[1467] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (១)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន (២) ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D354 កថាខណ្ឌ ១០។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន(២) ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D307/4 កថាខណ្ឌ ៦។

មុនពេលកាត់បន្ថយវិសាលភាពកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត[1468]។ បន្ទាប់មកភាគីមានរយៈពេល ១៥ ថ្ងៃ ដើម្បីដាក់សារណា[1469]។

សហចៅក្រមស៊ើបអង្កេតក៏ត្រូវកំណត់អំពីអានុភាពនៃសេចក្តីសម្រេចដែលបានធ្វើឡើង អនុលោមវិធាន ៦៦*ស្ទួន*(១) ទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ[1470]។ សេចក្តីសម្រេចកាត់បន្ថយវិសាលភាពកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦*ស្ទួន* បើកផ្លូវប្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង[1471]។

សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងអង្គហេតុដែលបានដកចេញ[1472]។ នៅពេលដែលសេចក្តីសម្រេច កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរចូលជាស្ថាពរ អង្គហេតុដែលត្រូវបានដកចេញអនុលោមតាមវិធាន ៦៦*ស្ទួន*(១) មិនអាចប្រើជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ប្រឆាំងនឹងបុគ្គលណាម្នាក់(ច្រើន)ដែលស្ថិតក្រោមការស៊ើបអង្កេតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង/ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ(ច្រើន)នោះទេ[1473]។ ទោះជាយ៉ាងណា សហចៅក្រមស៊ើបអង្កេត និងភាគីអាចផ្អែកលើភស្តុតាងដែលពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវបានដកចេញពីវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងកម្រិតដែលភស្តុតាងទាំងនោះ មានការពាក់ព័ន្ធនឹងអង្គហេតុដែលនៅសល់ផ្សេងទៀត[1474]។

### ៥.៤.១១. ដីកាដំណោះស្រាយ

សហចៅក្រមស៊ើបអង្កេតបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ដោយការចេញដីកាដំណោះស្រាយដែលចោទប្រកាន់ជនត្រូវចោទ និងបញ្ជូនខ្លួនពួកគេទៅជំនុំជម្រះ ផ្អែកលើមូលដ្ឋាននៃអង្គហេតុក្រោមការស៊ើបអង្កេត ឬលើកលែងការចោទប្រកាន់[1475]។ ដីកាដំណោះស្រាយអាចបញ្ជូនរឿងក្តីទៅជំនុំជម្រះចំពោះអង្គហេតុជាក់លាក់ ឬប្រឆាំងនឹងបុគ្គលជាក់លាក់ និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត[1476]។ ដីកាដំណោះស្រាយត្រូវតែជាសេចក្តីសម្រេចមានសំអាងហេតុ[1477]។

---

[1468] វិធានផ្ទៃក្នុង វិធាន៦៦ *ស្ទួន* (២)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226 កថាខណ្ឌ ៥។ សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D359 កថាខណ្ឌ ២។

[1469] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (២)។ សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ D184/3 កថាខណ្ឌ ៧។

[1470] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (៣)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន (២) ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D354 កថាខណ្ឌ ១២។ សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D359 កថាខណ្ឌ ១៤។

[1471] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (៤) និងវិធាន ៧៤។

[1472] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (៥)។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D359 កថាខណ្ឌ ១១។

[1473] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (៥)។

[1474] វិធានផ្ទៃក្នុង វិធាន ៦៦ *ស្ទួន* (៥)។ សូមមើល*ឧទាហរណ៍* សំណុំរឿង ០០៤ សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន (២) ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D354 កថាខណ្ឌ ១១។ សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226 កថាខណ្ឌ ១១។

[1475] វិធានផ្ទៃក្នុង វិធាន៦៧(១) ទំព័រ ៨៣ និង ៨៤។ សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២។

[1476] វិធានផ្ទៃក្នុង វិធាន៦៧(៤)។ សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២។

[1477] វិធានផ្ទៃក្នុង វិធាន៦៧(៤)។ សំណុំរឿង ០០២ សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្ធតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក

សហចៅក្រមស៊ើបអង្កេតត្រូវពិចារណាទាំងភ័ស្តុតាងដាក់បន្ទុក និងភ័ស្តុតាងដោះបន្ទុក[1478]។ នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចលើអង្គហេតុទាំងអស់ ប៉ុន្តែអង្គហេតុទាំងអស់នោះគឺជាផ្នែកមួយនៃការស៊ើបអង្កេតរបស់ខ្លួន ហើយត្រូវបដិសេធអង្គហេតុទាំងនោះ ឬប្រើប្រាស់ពួកវាជាមូលដ្ឋានសម្រាប់ការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ការសម្រេចនេះមិនពាក់ព័ន្ធនឹងការអនុវត្តអំណាចតាមឆន្ទានុសិទ្ធិណាមួយឡើយ ហើយសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុងយ៉ាងតឹងរឹង[1479]។

សហចៅក្រមស៊ើបអង្កេតមិនត្រូវបានតម្រូវឱ្យកំណត់បទល្មើសណាមួយនៃអង្គហេតុនោះទេ រហូតដល់ពេលចេញដីកាដំណោះស្រាយ[1480]។ សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចជាមួយនឹងការកំណត់បទល្មើស ដែលបានធ្វើឡើងដោយដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះទេ។ អង្គហេតុនានាដែលបានរកឃើញក្នុងអំឡុងពេលស៊ើបអង្កេតគឺមានលក្ខណៈច្បាស់លាស់ សម្រាប់ការកំណត់បទចោទ ដោយមិនគិតថាតើពួកវាត្រូវបានសហព្រះរាជអាជ្ញាកំណត់ពីដំបូងយ៉ាងដូចម្តេចនោះឡើយ[1481]។

ដើម្បីចោទប្រកាន់លើបទចោទណាមួយ ចាំបាច់ត្រូវតែមាន “ភ័ស្តុតាងគ្រប់គ្រាន់” ដែលមានន័យថាជា “ភវនីយភាព” ឬ “ភាពអាចជឿជាក់បាន” នៃពិរុទ្ធភាព។ ការណ៍នេះតម្រូវឱ្យមានលក្ខណៈលើសពីសូចនាករបញ្ជាក់ ឬភាពមន្ទិលសង្ស័យ ប៉ុន្តែភ័ស្តុតាងនោះមិនចាំបាច់បញ្ជាក់ពីរុទ្ធភាពឱ្យបានជាក់លាក់ ឬឱ្យហួសពីវិមតិសង្ស័យនោះទេ[1482]។ ជនត្រូវចោទអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះតែលើអង្គហេតុនានា ដែលខ្លួនត្រូវបានចោទប្រកាន់ជាផ្លូវការ ពោលគឺដាច់ដោយឡែកពីកាលៈទេសៈនានាជុំវិញអង្គហេតុទាំងអស់នោះប៉ុណ្ណោះ[1483]។ ក្នុងការវាយតម្លៃលើភ័ស្តុតាង សហចៅក្រមស៊ើបអង្កេតដំបូងឡើយបានអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធនឹងតម្លៃភ័ស្តុតាងនៃប្រភេទភ័ស្តុតាងជាច្រើន ដូចជា ចម្លើយដែលប្រមូលដោយស្ថាប័នក្រៅ អ.វ.ត.ក. និងរបាយការណ៍នានាពីមជ្ឈមណ្ឌលឯកសារកម្ពុជា[1484]។ អង្គបុរេជំនុំជម្រះក្រោយមកបានពិចារណាថាវិធីសាស្ត្រនេះមានកំហុសឆ្គង ដោយផ្តល់សំអាងហេតុថា តម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងទាំងនោះត្រូវវាយតម្លៃផ្អែកទៅ

---

.ស.ច.ស. នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D130/7/3/5 កថាខណ្ឌ ៣២។

[1478] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ៣៥។

[1479] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧។

[1480] សំណុំរឿង ០០២ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនិងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D268/2 កថាខណ្ឌ ៩។ សំណុំរឿង ០០២ ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D180/6 កថាខណ្ឌ ៧។

[1481] វិធានផ្ទៃក្នុង វិធាន៦៧(១)។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២ និង ៣៩។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស. បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៨។

[1482] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៤-៨៥។

[1483] សូមមើល សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៥-៣៦។

[1484] សូមមើល សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១០៣-១៣៩។ សម្រាប់ព័ត៌មានបន្ថែមអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល លើប្រភេទភ័ស្តុតាងជាក់លាក់ សូមមើលផ្នែក ៥.៦.៣។ចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ លើតម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូមមើលផ្នែក ៧.២.៥។

លើតម្លៃខាងក្នុងរបស់ភ័ស្តុតាង ជាជាងការកំណត់ឋានានុក្រមរបស់វា ផ្អែកលើប្រភពផ្លូវការរបស់ភ័ស្តុតាង[1485]។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងទៅជាមោឃៈដោយសារវិការៈនីតិវិធី ប្រសិនបើដីកានេះមិនបានកំណត់អត្តសញ្ញាណជនជាប់ចោទ ដែលជាការរៀបរាប់អំពីអង្គហេតុសំខាន់ៗ និងការកំណត់បទល្មើសរបស់អង្គហេតុទាំងនោះ ដោយសហចៅក្រមស៊ើបអង្កេត ដែលរួមមានបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[1486]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវកំណត់អង្គហេតុសំខាន់ៗនៃរឿងក្តីដោយមានព័ត៌មានលម្អិតគ្រប់គ្រាន់ ដើម្បីជូនដំណឹងដល់ជនជាប់ចោទឱ្យបានច្បាស់លាស់អំពីបទចោទប្រកាន់ប្រឆាំងនឹងពួកគេ ដើម្បីឱ្យពួកគេអាចរៀបចំការការពារខ្លួន[1487]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវចែងបទចោទនីមួយៗឱ្យបានច្បាស់លាស់ និង ដាច់ដោយឡែកពីគ្នា ហើយកំណត់អត្តសញ្ញាណអំពើជាក់លាក់ទាំងឡាយ ក្នុងលក្ខខណ្ឌមួយអាចឱ្យជឿជាក់បាន[1488]។

ប្រសិនបើជនជាប់ចោទត្រូវបានចោទប្រកាន់ដោយទម្រង់ជម្រើសនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវចែងអំពីទម្រង់នីមួយៗ ដែលត្រូវបានចោទប្រកាន់[1489]។ វិសាលភាពនៃលក្ខណៈពិសេសអាស្រ័យលើទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ ដែលជាភាពពាក់ព័ន្ធនៃអង្គហេតុមួយចំនួន ដូចជា អត្តសញ្ញាណជនរងគ្រោះ ទីកន្លែង កាលបរិច្ឆេទ និងការរៀបរាប់អំពីព្រឹត្តិការណ៍នានាផ្អែកលើភាពនៅកៀកនឹងព្រឹត្តិការណ៍ ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ[1490]។ នៅពេលដែលមានការចោទប្រកាន់ថា ជនជាប់ចោទបានប្រព្រឹត្តដោយផ្ទាល់នូវអំពើ ដែលជាមូលដ្ឋាននៃបទឧក្រិដ្ឋដែលជាបញ្ហាចោទនេះ អត្តសញ្ញាណរបស់ជនរងគ្រោះ ទីកន្លែង និងកាលបរិច្ឆេទប្រហាក់ប្រហែល នៃអំពើឧក្រិដ្ឋដែលបានចោទប្រកាន់ និងមធ្យោបាយដែលប្រើដើម្បីប្រព្រឹត្តបទល្មើស ត្រូវតែចែង "បញ្ជាក់ឱ្យច្បាស់ជាទីបំផុត"។ ទោះជាយ៉ាងណា លក្ខណៈ ឬ ទំហំនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ មិនអាចធ្វើឱ្យមានការបញ្ជាក់ឱ្យបានច្បាស់លាស់ចំពោះអត្តសញ្ញាណរបស់គ្រប់ជនរងគ្រោះ ឬកាលបរិច្ឆេទនៃការប្រព្រឹត្តិបទល្មើសឡើយ[1491]។

ក្នុងករណីដែលចោទប្រកាន់ថាជនជាប់ចោទបានរៀបចំផែនការ បានញុះញង់ បានបញ្ជា ឬបានជួយ និងជំរុញ ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ "អំពើជាក់លាក់" ឬ "ការប្រព្រឹត្តិជាក់លាក់" របស់ជនជាប់ចោទ ដែលបង្កើតជាមូលដ្ឋានសម្រាប់បទចោទដែលជាបញ្ហាចោទនេះ ត្រូវតែកំណត់អត្តសញ្ញាណ។ ចំពោះការចោទប្រកាន់អំពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន មិនត្រឹមតែការប្រព្រឹត្តិផ្ទាល់របស់ថ្នាក់លើប៉ុណ្ណោះទេ ថែមទាំងការប្រព្រឹត្តិរបស់បុគ្គលទាំងឡាយដែលថ្នាក់លើមានការទទួលខុសត្រូវ។ សហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ទាមទារឱ្យមានការបញ្ជាក់ច្បាស់លាស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1492]។

---

[1485] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥១-៥៩។
[1486] វិធានផ្ទៃក្នុង វិធាន៦៧(២)។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៣៧។
[1487] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៧។ បទដ្ឋាននេះមិនតម្រូវឱ្យមានចំនួនជាក់លាក់នៃជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណនោះទេ។ សូមមើល សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៦។
[1488] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៧។
[1489] ដូចខាងលើ។
[1490] ដូចខាងលើ កថាខណ្ឌ ៤៨។
[1491] ដូចខាងលើ កថាខណ្ឌ ៤៩។
[1492] ដូចខាងលើ។

នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតក៏ត្រូវចេញសេចក្តីសម្រេចចាំបាច់ណាមួយទាក់ទងនឹងវត្ថុតាង ដែលបិទស្លាកបោះត្រា ហើយក្នុងគោលបំណងនេះ សហចៅក្រមស៊ើបអង្កេតអាចអញ្ជើញ ឬផ្តល់ឱកាសឱ្យមានការដាក់ជូនសារណាពីសំណាក់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី[1493]។

សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងកាលៈទេសៈដូចខាងក្រោម៖ (១) អំពើដែលចោទប្រកាន់មិនរាប់បញ្ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក. (២) ជនប្រព្រឹត្តបទល្មើសនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ និង (៣) ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ[1494]។

សហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវទទួលបានការជូនដំណឹងភ្លាមៗ នៅពេលដែលចេញដីកាដំណោះស្រាយ និងទទួលបានច្បាប់ចម្លងនៃដីកានៅពេលបន្ទាប់[1495]។ ដីកាដំណោះស្រាយបើកផ្លូវប្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង[1496]។ ក្នុងករណីនេះ វិសាលភាពនៃការពិនិត្យរបស់អង្គបុរេជំនុំជម្រះ នឹងកម្រិតត្រឹមបញ្ហានានា ដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍[1497]។ ដើមបណ្តឹងរដ្ឋប្បវេណីណា ដែលបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានជោគជ័យអនុលោមតាមវិធាន ២៣(៥) នៃវិធានផ្ទៃក្នុង បានចូលរួមជាមួយក្រុមនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នាតែមួយ ហើយដើមបណ្តឹងរដ្ឋប្បវេណីណាដែលប្តឹងឧទ្ធរណ៍លើដីកាសម្រេចលើកលែងចោទប្រកាន់ ដែលកំពុងរង់ចាំសេចក្តីសម្រេច ក៏ត្រូវចូលរួមជាមួយនឹងក្រុមនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នាតែមួយនោះផងដែរ[1498]។ ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងវិធាន ៧៧ នៃវិធានផ្ទៃក្នុង[1499]។

ក្នុងករណីដែលមិនមានការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទេនោះ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង៖ (១) ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់កាលបរិច្ឆេទសវនាការ។ (២) ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយពីផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍[1500]។ ការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនបានរារាំងការចូលពិនិត្យសំណុំរឿងដោយអង្គជំនុំជម្រះសាលាដំបូង និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះនោះទេ[1501]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នាផ្អែកលើករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត លើបញ្ហាថាតើជនត្រូវចោទស្ថិតក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ដែរ ឬយ៉ាងណានោះឡើយ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះពិចារណាថា សហចៅក្រម

---

[1493] វិធានផ្ទៃក្នុង វិធាន៦៧(៦)។

[1494] វិធានផ្ទៃក្នុង វិធាន៦៧(៣) ទំព័រ ៨៣។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២-៣៣។

[1495] វិធានផ្ទៃក្នុង វិធាន៦៧(៥)។

[1496] វិធានផ្ទៃក្នុង វិធាន៦៧(៥)។

[1497] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨-២៩។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី)។

[1498] វិធានផ្ទៃក្នុង វិធាន៦៧(៥)។

[1499] វិធានផ្ទៃក្នុង វិធាន ៦៩(១)។ សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E163/5/1/13 ជើងទំព័រ ១០៥។

[1500] វិធានផ្ទៃក្នុង វិធាន ៦៩(២)។

[1501] វិធានផ្ទៃក្នុង វិធាន ៦៩(៣)។

ស៊ើបអង្កេត គប្បីបញ្ជូនករណីខ្វែងយោបល់គ្នារបស់ពួកគេមកអង្គបុរេដោះស្រាយ ឬឈានដល់ការព្រមព្រៀងដោយតុល្យភាព ប៉ុន្តែក្នុងករណីណាក៏ដោយ មិនអាចបន្តធ្វើដោយផ្អែកលើមូលដ្ឋានដែលមិនជាប់ពាក់ព័ន្ធនឹងយន្តការ"ស្វ័យប្រវត្តិ"ក្នុងក្របខ័ណ្ឌ អ.វ.ត.ក. ដែលថា "ការស៊ើបអង្កេតបន្តទៅមុខ" ដូចជាការចេញដីកាដំណោះស្រាយដាច់ដោយឡែកនោះឡើយ[1502]។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការក៏ពួលបានប្រកាស់បញ្ចប់រឿងក្តីទាំងបីនេះ ដោយសារមិនមានដីកាដំណោះស្រាយមានសុពលភាព[1503]។

## ៥.៤.១២. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត

នៅពេលដែលសហចៅក្រមស៊ើបអង្កេតខ្វែងយោបល់គ្នា សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬពួកគាត់ទាំងពីរនាក់ អាចធ្វើកំណត់ហេតុជាក់ស្តែងនៃការខ្វែងយោបល់របស់ខ្លួន នៅក្នុងឯកសារដែលចុះហត្ថលេខា និងកាលបរិច្ឆេទដាក់ទៅក្នុងកំណត់ហេតុនៃការខ្វែងយោបល់ ដើម្បីត្រូវរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត[1504]។ ក្នុងរយៈពេល ៣០ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ អាចបញ្ជូនករណីខ្វែងយោបល់នេះ ទៅអង្គបុរេជំនុំជម្រះ ដោយបញ្ជូនសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងសំអាងហេតុនៃករណីខ្វែងយោបល់នេះ ទៅការិយាល័យរដ្ឋបាល ដែលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនេះទៅកាន់ចៅក្រមទាំងអស់នៃអង្គបុរេ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត[1505]។ ប្រសិនបើការខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន របស់ជនត្រូវចោទ រយៈពេលដែលសហចៅក្រមណាម្នាក់អាចបញ្ជូនករណីខ្វែងយោបល់ទៅអង្គបុរេជំនុំជម្រះ ត្រូវបន្ថយមកត្រឹម ៥ ថ្ងៃវិញ។ សហចៅក្រមស៊ើបអង្កេតម្ខាងទៀត អាចដាក់ចម្លើយតបក្នុងរយៈពេល ១០ ថ្ងៃ[1506]។

សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនៃអង្គហេតុ និងសំអាងហេតុសម្រាប់ករណីខ្វែងយោបល់ មិនត្រូវដាក់ក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណីដែលការខ្វែងយោបល់នោះ ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេច ដែលភាគីនៃសំណុំរឿងមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះតាមវិធានផ្ទៃក្នុង[1507]។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម[1508]។

ខណៈដែលដំណើរការដោះស្រាយការខ្វែងយោបល់គ្នានេះកំពុងដំណើរការ សហចៅក្រមស៊ើបអង្កេតត្រូវបន្តស្វែងរកការឯកភាពគ្នា[1509]។ សហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចដោយពុំមានការព្រមព្រៀងពីសហចៅក្រមស៊ើបអង្កេតម្នាក់ផ្សេងទៀតបាន ក្នុងករណីដែលពុំមាននរណាម្នាក់ក្នុងចំណោមអ្នកទាំងពីរបញ្ជូនករណីខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេលកំណត់[1510]។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេត "មិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលខ្លួនមិនព្រមព្រៀងគ្នាលើបញ្ហាណាមួយដែល

---

[1502] សូមមើល សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១០៦-១០៧។ សម្រាប់ព័ត៌មានបន្ថែមអំពីដីកាដំណោះស្រាយផ្សេងគ្នា និងផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ និង សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើលទ្ធភាពអាចអនុញ្ញាតបាននៃសកម្មភាពបែបនោះ សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.៣។

[1503] សម្រាប់ព័ត៌មានបន្ថែមអំពីការបញ្ចប់កិច្ចដំណើរការនីតិវិធី សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.៣.២.១២ (សំណុំរឿង ០០៣) ៥.៣.៣.៦.៦ (សំណុំរឿង ០០៤/០២) ៥.៣.៣.៧.៧ (សំណុំរឿង ០០៤)។

[1504] វិធានផ្ទៃក្នុង វិធាន ៧២(១)។

[1505] វិធានផ្ទៃក្នុង វិធាន ៧២(២)។ សូមមើល សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៧។

[1506] វិធានផ្ទៃក្នុង វិធាន ៧២(២)។

[1507] វិធានផ្ទៃក្នុង វិធាន ៧២(២) និង ៧២(៤)(ខ)។

[1508] វិធានផ្ទៃក្នុង វិធាន ៧២(២)។

[1509] វិធានផ្ទៃក្នុង វិធាន ៧២(៣)។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៤ និង ១១៨។

[1510] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៦។

នៅចំពោះមុខ”[1511]។ ទោះជាយ៉ាងណា ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ឆន្ទានុសិទ្ធិក្នុងការមិនជូនដំណឹងដល់អង្គបុរេជំនុំជម្រះនេះគឺតែក្នុងករណី “ប្រសិនបើចៅក្រមឯកភាពលើវិធីសាស្ត្រដែល “ស្រប” ទៅនឹង “គោលជំហរស្វ័យប្រវត្តិ” [...] គឺថា “ការស៊ើបអង្កេតត្រូវតែបន្ត””[1512]។ អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿងទាំងបីនេះ បានពិចារណាថា លក្ខណៈ និងភាពធ្ងន់ធ្ងរនៃករណីខ្វែងយោបល់គ្នានេះ គប្បីជូនដំណឹងទៅនីតិវិធីដែលសមស្របបំផុតដើម្បីអនុវត្តតាម ដែលអាចចាប់ផ្តើមពីការអត់ធ្មត់ដោយតុណ្ហីភាពអំពីកិច្ច ឬសេចក្តីសម្រេចនោះ រហូតដល់ការចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នា បញ្ជូនករណីខ្វែងយោបល់គ្នាដើម្បីស្នើសុំការធ្វើមោឃភាពកិច្ច ឬសេចក្តីសម្រេចនោះជាផ្លូវការ[1513]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា នៅពេលដែល “នីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា ដែលនៅមានស្រាប់ជាធរមាន គឺជាយន្តការតែមួយគត់ដែលនៅអាចអនុវត្តបានសម្រាប់សហចៅក្រមស៊ើបអង្កេតក្នុងការទប់ស្កាត់ការកើតមានភាពទាល់ច្រកផ្នែកនីតិវិធី និងធានាអំពីនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃការស៊ើបសួរតាមផ្លូវតុលាការនោះ” សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចចាប់ផ្តើមយន្តការដោះស្រាយវិវាទនេះ[1514]។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើករណីខ្វែងយោបល់គ្នា ត្រូវមានសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់បួនរូប[1515]។ ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវនេះមិនអាចរកបានទេ គោលជំហរស្វ័យប្រវត្តិនោះគឺថា ដីកា ឬការស៊ើបអង្កេតដែលបានធ្វើឡើងដោយសហចៅក្រមម្នាក់មានសុពលភាព ឬដីកា ឬកិច្ចដែលស្នើឡើងនោះ ត្រូវបន្តអនុវត្ត[1516]។

សកម្មភាព ឬសេចក្តីដែលជាកម្មវត្ថុនៃការខ្វែងយោបល់ណាមួយ ត្រូវបានអនុវត្ត លើកលែងតែវាពាក់ព័ន្ធទៅនឹងប្រភេទបីខាងក្រោម៖ (១) សេចក្តីសម្រេចណាមួយដែលបើកផ្លូវឱ្យជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ តាមវិធានផ្ទៃក្នុង (២) ការជូនដំណឹងអំពីបទចោទប្រកាន់ ឬ (៣) ដីកាបង្គាប់ឱ្យចាប់ខ្លួន[1517]។ ប្រសិនបើវាពាក់ព័ន្ធនឹងករណីណាមួយក្នុងចំណោមករណីទាំងនេះ គ្មានសកម្មភាពណាមួយត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានធ្វើឡើង ឬរយៈពេល ៣០ថ្ងៃ បានកន្លងផុត ឬអង្គបុរេជំនុំជម្រះបានទទួលយកករណីខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយនីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះបានបញ្ចប់ តាមដែលអាចធ្វើទៅបាន[1518]។

### ៥.៥. ដំណាក់កាលមុនការជំនុំជម្រះ

#### ៥.៥.១. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ និងវិធានស្តីពីសំឡេងភាគច្រើនលើសលប់

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ផ្តល់ឱ្យអង្គបុរេជំនុំជម្រះនូវយុត្តាធិការដោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត[1519]។ វិធានផ្ទៃក្នុងផ្តល់យុត្តាធិការឱ្យអង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅ

---

[1511] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ២៧៤។

[1512] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១០៦។ សូមមើល សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៩៤។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១០០។

[1513] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៣។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៩៩។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១០៥។

[1514] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៩-១២០។

[1515] វិធានផ្ទៃក្នុង វិធាន ៧២(៤)(ឃ)។

[1516] វិធានផ្ទៃក្នុង វិធាន ៧២(៤)(ឃ)។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥។ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D212/1/2/2 កថាខណ្ឌ ៧។

[1517] ច្បាប់ អ.វ.ត.ក. មាត្រា ២៣ (ថ្មី)(៣)។ វិធានផ្ទៃក្នុង វិធាន ៧២(៣)។

[1518] វិធានផ្ទៃក្នុង វិធាន ៧២(៣)។

[1519] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៧(២)។ វិធានផ្ទៃក្នុង វិធាន ៧១ និង ៧២។ សម្រាប់ព័ត៌មានបន្ថែមអំពី នីតិវិធីខ្វែងយោលប់ សូមមើល ផ្នែក ៥.៤.១២។

ក្រុមស៊ើបអង្កេត[1520] សំណើសុំមោឃភាពកិច្ចស៊ើបសួរ[1521] ក៏ដូចជាបណ្តឹងឧទ្ធរណ៍ផ្សេងទៀតដែលរៀបរាប់យ៉ាងជាក់លាក់ក្នុងវិធាន ៧៣(គ) នៃវិធានផ្ទៃក្នុង[1522]។ ក្នុងកាលៈទេសៈពិសេស អង្គបុរេជំនុំជម្រះបានពង្រីកវិសាលភាពយុត្តាធិការរបស់ខ្លួនដើម្បីធ្វើការជំនុំជម្រះបណ្តឹងឧទ្ធរណ៍នានា ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[1523]។ រាល់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាំងអស់តម្រូវឱ្យមានសំឡេងគាំទ្រវេជ្ជមានពីចៅក្រមបួនរូប ក្នុងចំណោមចៅក្រមប្រាំរូបនៃអង្គបុរេ[1524]។ នៅពេលដែលអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលប់ដែលតម្រូវបានទេ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា៖

> ក-ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ ។
>
> ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូងដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ។

ក្នុងសំណុំរឿង ០០៣ និង ០០៤ អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលប់ដែលតម្រូវបាន លើបញ្ហាជាច្រើននៅចំពោះមុខអង្គបុរេ។ ឧទាហរណ៍ ក្នុងសំណុំរឿង ០០៤/០១ អង្គបុរេជំនុំជម្រះមិនអាចសម្រេចលើអង្គសេចក្តីចំពោះពាក្យសុំមោឃភាពកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលជាលទ្ធផលនាំឱ្យកិច្ចស៊ើបសួរទាំងអស់នោះមានសុពលភាព[1525]។ នៅក្នុងរឿងក្តីដដែលនោះ អសមត្ថភាពរបស់អង្គបុរេជំនុំជម្រះក្នុងការរកបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរួមលើកលែងការចោទប្រកាន់ បាននាំឱ្យដីកានោះមានសុពលភាព ហើយរឿងក្តីត្រូវបានលើកលែងចោទប្រកាន់[1526]។ ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ អង្គបុរេជំនុំជម្រះបានខកខានក្នុងការរកសំឡេងភាគច្រើនលើសលប់ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា ដែលនាំឱ្យមានការបញ្ចប់រឿងក្តីទាំងអស់នេះ ដោយសារមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[1527]។

---

[1520] វិធានផ្ទៃក្នុង វិធាន ៧៣(ក) និង ៧៤។ សម្រាប់ព័ត៌មានបន្ថែមអំពីប្រវត្តិនៃការបង្កើតអង្គបុរេជំនុំជម្រះ សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៣.៧.៣។

[1521] វិធានផ្ទៃក្នុង វិធាន ៧៣(ខ) និង ៧៦។

[1522] វិធានផ្ទៃក្នុង វិធាន ៧៣(គ) រៀបរាប់អំពីបណ្តឹងឧទ្ធរណ៍ដែលមានចែងក្រោមវិធានផ្ទៃក្នុង ១១(៥) និង (៦) (សេចក្តីសម្រេចទាក់ទងនឹងបញ្ជីឈ្មោះមេធាវីការពារក្តីជនក្រីក្រ ការស្រេចអំពីជនណាមួយជាជនក្រីក្រ និងការចាត់តាំងមេធាវីការពារជនក្រីក្រ)) ៣៥(៦) (សេចក្តីសម្រេចទាក់ទងនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ) ៣៨(៣) (សេចក្តីសម្រេចពាក់ពន្ធ័នឹងកុំហួសវិជ្ជាជីវៈរបស់មេធាវី និង ៧៧ *ស្ទួន* (សេចក្តីសម្រេចពាក់ពន្ធ័នឹងពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)។

[1523] សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ខៀវ សំផន) កថាខណ្ឌ ១៨។

[1524] វិធានផ្ទៃក្នុង វិធាន៧៧(១៣)។

[1525] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យមោឃភាពលើប្រតិចារិក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D298/2/1/3 ផ្នែកសេចក្តីសម្រេច។

[1526] សំណុំរឿង ០០៤០១/ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ផ្នែកសេចក្តីសម្រេច។

[1527] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៧១។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1 កថាខណ្ឌ ៤4។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ឯកសារ 2/1/1/1 កថាខណ្ឌ ៣២។ សម្រាប់ព័ត៌មានបន្ថែមអំពីកិច្ចដំណើរការនីតិវិធីទាក់ទងនឹងសាលដីកាដំណោះស្រាយពីផ្ទុយគ្នា សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.៣.១។

### ៥.៥.២. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះលើពាក្យសុំមោឃភាពកិច្ចស៊ើបសួរ

អង្គបុរេជំនុំជម្រះមានយុត្តាធិការផ្តាច់មុខលើពាក្យសុំមោឃភាពកិច្ចស៊ើបសួរ[1528]។ ទោះជាយ៉ាងណា មានតែសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ អាចប្តឹងទៅអង្គបុរេជំនុំជម្រះ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមរយៈសំណើរបស់ភាគីណាមួយ ដោយមានពាក្យសុំមោឃភាព "ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី"[1529] ពោលគឺ "កិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបសួរ ឬបុគ្គលដែលបំពេញកិច្ចជាអ្នកតំណាងឱ្យតុលាការ និងសំដៅលើសម្ភារៈទាំងឡាយ ដែលកើតចេញពីកិច្ចទាំងនេះតែមួយប៉ុណ្ណោះ"[1530]។ យោងតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យសំណើផ្អែកលើមូលដ្ឋានចំនួនពីរគឺ ៖ (១) វត្តមាននៃវិការៈនីតិវិធី និង (២) ការរំលោភបំពានលើសិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំនោះ[1531]។ ជាពិសេស ពាក្យសុំមោឃភាពត្រូវដាក់បញ្ជូន និងសម្រេចមុនពេលចេញដីកាដំណោះស្រាយ ដែលបានកែតម្រូវវិការៈនីតិវិធី[1532]។

#### ៥.៥.២.១. តួនាទីរបស់សហចៅក្រមស៊ើបអង្កេតក្នុងនីតិវិធីមោឃភាព

នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ថា ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវបានចាត់ទុកជាមោឃៈ វិធាន ៧៦(១) នៃវិធានផ្ទៃក្នុងកំណត់ថា សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងឡាយ ហើយត្រូវដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅ អង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព *លើកលែងតែ* ភាគីណាមួយដែលផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់នោះ បានផ្តល់នីយតភាពដល់កិច្ចដំណើរការនីតិវិធីដោយបោះបង់សិទ្ធិរបស់ខ្លួនក្នុងការស្នើសុំមោឃភាព[1533]។ ផ្ទុយទៅវិញ ភាគីណាមួយដែលយល់ឃើញថា ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវបានចាត់ទុកជាមោឃៈ មិនប្តឹងដោយផ្ទាល់ទៅអង្គបុរេជំនុំជម្រះស្នើសុំមោឃភាពបានទេ[1534]។

វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យភាគីដាក់ពាក្យស្នើសុំមានសំអាងហេតុ ទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំពួកគេឱ្យប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព[1535]។ មានករណីមួយ អង្គបុរេជំនុំជម្រះសន្និដ្ឋានថាពាក្យស្នើសុំមោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អាច

---

[1528] វិធានផ្ទៃក្នុង វិធាន ៧៣(ខ)។

[1529] វិធានផ្ទៃក្នុង វិធាន ៧៦(១) ៧៦(២)។

[1530] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E43/4 កថាខណ្ឌ ១១។

[1531] វិធានផ្ទៃក្នុង វិធាន ៤៨។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៣៣-៣៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២១។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យមោឃភាពលើប្រតិចារិក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D298/2/1/3 យោបល់របស់ចៅក្រម Olivier Beauvallet និង ចៅក្រម Baik Kang Jin កថាខណ្ឌ ៤២។ អង្គបុរេជំនុំជម្រះបានបកស្រាយឃ្លា "ការរំលោភសិទ្ធិទាំងឡាយ" ថាជា "ផលប្រយោជន៍ដែលបានប៉ះពាល់" ។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៣៦។

[1532] វិធានផ្ទៃក្នុង វិធាន ៧៦(៧)។ សំណុំរឿង ០០៤/០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D350/1/1/4 កថាខណ្ឌ ២០។ វិសាលភាពនៃកំហុសនីតិវិធីដែលត្រូវបានជួសជុលដោយដីកាដំណោះស្រាយ ពុំគ្របដណ្តប់លើកំហុសទាំងឡាយដែលមាននៅក្នុងសម្ភារៈ និងឯកសារ ដែលបានលើកឡើងដោយភាគីនោះឡើយ។ សូមមើល សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E43/4 កថាខណ្ឌ ១១។

[1533] វិធានផ្ទៃក្នុង វិធាន ៧៦(១) ៧៦(៦)។

[1534] វិធានផ្ទៃក្នុង វិធាន ៧៦(២)។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៦។

[1535] វិធានផ្ទៃក្នុង វិធាន ៧៦(២)។

ទទួលយកបាន ប៉ុន្តែបដិសេធមិនដោះស្រាយភាពអាចទទួលយកបាននៃសំណើបន្ថែមទៅនឹងពាក្យស្នើសុំនោះ ដោយសារតែសំណើបន្ថែមនោះ មិនត្រូវបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតជាមុន[1536]។

នៅពេលពិចារណាលើសំណើសុំប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យមោឃភាព សហចៅក្រមស៊ើបអង្កេតត្រូវពិចារណាថាតើ ពាក្យស្នើសុំនោះបានកំណត់អត្តសញ្ញាណវិការៈនីតិវិធី និងញ្ញសនកម្មដែលបណ្តាលឡើងដោយវិការៈនោះមានទៅលើភាគីធ្វើសំណើសុំនេះដែរ ឬយ៉ាងណា[1537]។ម្យ៉ាងវិញទៀត វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង "ផ្តល់មុខងារជាអ្នកពិនិត្យមើលដល់សហចៅក្រមស៊ើបអង្កេត" តែមួយគត់[1538]។ ពួកគេចាំបាច់ត្រូវជឿជាក់ថា មាន "ករណីដែលអាចតវ៉ាបាន" ដែលសំណើនោះ៖ (១) *តាមការពិនិត្យបឋម* លើកឡើងអំពីវត្ថុករណ៍ដែលមានសំអាងហេតុ និង (២) ពុំមែនគ្មានមូលដ្ឋានជាក់លាក់ឡើយ[1539]។

ផ្ទុយទៅវិញ គឺអង្គបុរេជំនុំជម្រះដែលមានតួនាទីពិនិត្យអង្គសេចក្តីនៃពាក្យសុំឱ្យមោឃភាព[1540]។ តាមពិត "ភាពចាំបាច់ក្នុងការធានានូវភាពមិនលម្អៀងនៃការស៊ើបសួរបឋម ជាភ័ស្តុតាងបង្ហាញថាការពិចារណាលើពាក្យសុំមោឃភាពដែលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី ត្រូវបានប្រគល់ទៅឱ្យអង្គបុរេ តែមិនមែនឱ្យទៅសហចៅក្រមស៊ើបអង្កេត ដែលមានភារកិច្ចច្បាស់លាស់ គឺត្រូវដឹកនាំ និងបិទការស៊ើបសួរនោះទេ"[1541]។

### ៥.៥.២.២. តួនាទីរបស់អង្គបុរេជំនុំជម្រះក្នុងនីតិវិធីមោឃភាព

#### *៥.៥.២.២.១. ភាពអាចទទួលយកបាននៃពាក្យសុំមោឃភាព*

នៅពេលដែលសហចៅក្រមស៊ើបអង្កេត ទទួលយកសំណើសុំឱ្យប្តឹងទៅអង្គបុរេជំនុំជម្រះ ស្នើសុំឱ្យមោឃភាពកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងនោះទៅអង្គបុរេជំនុំជម្រះ ដើម្បីឱ្យអង្គបុរេជំនុំជម្រះពិចារណាលើអង្គសេចក្តី[1542]។ អនុលោមតាមវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ

---

[1536] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យមោឃភាពលើប្រតិចារិក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D298/2/1/3 កថាខណ្ឌ ២២។

[1537] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ១៨។

[1538] សំណុំរឿង ០០៣ សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D165/2/26 កថាខណ្ឌ ៣៣។

[1539] សំណុំរឿង ០០៤/០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D350/1/1/4 កថាខណ្ឌ ១៣។

[1540] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ១៨។ សំណុំរឿង ០០៣ សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D165/2/26 កថាខណ្ឌ ៣៧។

[1541] សំណុំរឿង ០០៣ សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D165/2/26 កថាខណ្ឌ ៣៧។

[1542] វិធានផ្ទៃក្នុង វិធាន ៧៦(៣)។

អាចប្រកាសថា ពាក្យសុំឱ្យមោឃភាពណាមួយមិនអាចទទួលយកបាន ប្រសិនបើពាក្យសុំនោះគ្មានមូលដ្ឋានជាក់លាក់ មិនបង្ហាញមូលហេតុគ្រប់គ្រាន់ ឬទាក់ទងទៅនឹងដីកាដែលបើកផ្លូវប្តឹងឧទ្ធរណ៍[1543]។

ពាក្យសុំទាំងឡាយណាដែលគ្មានមូលដ្ឋានជាក់លាក់ មិនអាចទទួលយកបានឡើយ។ សំណើណាមួយ ជាសំណើ "គ្មានមូលដ្ឋានជាក់លាក់" នៅពេលដែល "វាមានភាព*ជាក់ស្តែង ឬជាក់ច្បាស់*ថាវាគ្មានមូលដ្ឋានគតិយុត្តិ ឬមូលដ្ឋានអង្គហេតុ និងគ្មានលទ្ធភាពជោគជ័យ"[1544]។ ឧទាហរណ៍ អង្គបុរេជំនុំជម្រះយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា សំណើសុំឱ្យប្តឹងទៅអង្គបុរេជំនុំជម្រះដោយមានពាក្យសុំស្នើសុំឱ្យមោឃភាពការស៊ើបអង្កេតទាំងមូល ក្នុងសំណុំរឿង ០០៤/០២ "ខកខានពុំបានលើកឡើងអំពីទឡ្ហីករណ៍ដែលមានមូលដ្ឋានគតិយុត្តិ ឬមូលដ្ឋានអង្គហេតុសម្រាប់វិការៈនីតិវិធី" ហេតុដូច្នេះគ្មានមូលដ្ឋានជាក់លាក់[1545]។ ក្នុងសំណុំរឿង ០០៤/០១ បើទោះជាមិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ដែលតម្រូវ ដើម្បីធ្វើសេចក្តីសម្រេចលើអង្គសេចក្តីនៃពាក្យសុំឱ្យមោឃភាពកំណត់ហេតុស្តាប់ចម្លើយសាក្សីយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថាពាក្យសុំនោះអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋានដែលថា ពាក្យសុំនោះពុំមានលក្ខណៈ "ប្រចក្ស ឬច្បាស់ក្រឡែតបញ្ជាក់ថា សំណើសុំធ្វើមោឃភាពនេះ គ្មានមូលដ្ឋាន ទាំងផ្នែកអង្គច្បាប់ និងអង្គហេតុ រហូតធ្វើឱ្យវាមិនអាចត្រូវទទួលយកបាននោះឡើយ"[1546]។

ពាក្យសុំទាំងឡាយដែលមិនបង្ហាញមូលហេតុគ្រប់គ្រាន់ គឺមិនអាចទទួលយកបានទេ។ ភាគីដែលស្នើសុំមោឃភាពកិច្ចស៊ើបសួរ ត្រូវតែបានលើកឡើងថាតើថាតើផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវទៅជាមោឃៈ ហើយត្រូវផ្តល់មូលហេតុគាំទ្រអំណះអំណាងបែបនោះ[1547]។ ការបញ្ជាក់អំពីផ្នែកនៃដំណើការនីតិវិធីដែលត្រូវបានជំទាស់ តាមរយៈឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសំណើ គឺអាចទទួលយកបាន[1548]។ ជាទូទៅ អង្គបុរេជំនុំជម្រះពិចារណាថា ខ្លួនមិនអាច "ត្រូវបានរំពឹងថានឹងពិចារណាលើការលើកឡើងរបស់ភាគីនោះទេ ប្រសិនបើភាគីពុំបានចង្អុលយោងឱ្យបានច្បាស់លាស់នោះ"។ យ៉ាងណាមិញ នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌ និងភាពឆាប់រហ័សត្រូវឱ្យធ្វើដូច្នោះ អង្គបុរេជំនុំជម្រះសម្រេចថា ខ្លួននឹងពិចារណាលើការលើកឡើងទូទៅ និងតម្រូវឱ្យមានសេចក្តីសន្និដ្ឋានបន្ថែមទៀតក្នុងករណីសមស្រប[1549]។

ពាក្យសុំទាក់ទងនឹងដីកាដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ គឺមិនអាចទទួលយកបានទេ។ ក្នុងសំណុំរឿង ០០៤ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានសង្កេតឃើញថា របបសម្រាប់ការពិនិត្យលើបណ្តឹងឧទ្ធរណ៍ និងសម្រាប់មោឃភាព "មានលក្ខណៈដាច់ដោយឡែកពីគ្នា ហើយអនុវត្តចំពោះប្រភេទចំណាត់ការផ្លូវច្បាប់ខុសៗគ្នា ដែលបំពេញឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធនឹងស្តង់ដាផ្សេងៗនៃការពិនិត្យឡើងវិញដោយតុលាការតាមរយៈអង្គបុរេជំនុំជម្រះ"[1550]។ ឧទាហរណ៍ ក្នុងសំណុំរឿង ០០៣ អង្គបុរេជំនុំជម្រះបានសម្រេចថា វិធាន ៧៦(២) បានដកចេញពាក្យសុំមោឃភាពដីកាដំណោះស្រាយ ដោយសារ៖

---

[1543] វិធានផ្ទៃក្នុង វិធាន ៧៦(៤)។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យមោឃភាពលើប្រតិចារិក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D298/2/1/3 កថាខណ្ឌ ២០-២១។
[1544] សំណុំរឿង ០០៤/០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D350/1/1/4 កថាខណ្ឌ ១៣ (ទំរង់ដើមជាអក្សរទ្រេត)។
[1545] ដូចខាងលើ កថាខណ្ឌ ១៥-១៧។
[1546] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យមោឃភាពលើប្រតិចារិក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D298/2/1/3 កថាខណ្ឌ ២១។
[1547] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/1/15 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៣៥។
[1548] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត ក.ស.ច.ស. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៧។
[1549] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលមិនមានខ្សែអាត់សំឡេង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D296/1/1/4 កថាខណ្ឌ ១២។
[1550] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រម Olivier Beauvallet និង Baik Kang Jin កថាខណ្ឌ ១៦៥។

(១) ពាក្យសុំមោឃភាពត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ និង (២) ដីកាដំណោះស្រាយអាចត្រូវបានប្តឹងឧទ្ធរណ៍អនុលោមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង[1551]។

### ៥.៥.២.២.២. *ការវាយតម្លៃលើពាក្យសុំមោឃភាព*

អង្គបុរេជំនុំជម្រះមិនអាចប្រកាសថាកិច្ចស៊ើបសួរណាមួយត្រូវទៅជាមោឃៈ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនបានឡើយ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចតាមរយៈពាក្យសុំដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬភាគី[1552]។ ការធ្វើមោឃភាពត្រូវបានចែងយ៉ាងច្បាស់លាស់ដោយវិធានផ្ទៃក្នុងចំពោះវិការៈនីតិវិធីមួយចំនួន[1553]។ ចំពោះវិការៈនីតិវិធីដែលមិនត្រូវបានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងថាត្រូវទុកជាមោឃៈនោះ អង្គបុរេជំនុំជម្រះត្រូវបញ្ជាក់ថាតើ ពាក្យសុំ៖ (១) បញ្ជាក់អំពីផ្នែកទាំងឡាយណានៃនីតិវិធីដែលបង្កព្យសនកម្មដល់សិទ្ធិ ឬផលប្រយោជន៍របស់ភាគីម្ចាស់បណ្តឹងដែរឬទេ (២) បង្ហាញឱ្យឃើញច្បាស់ថាមានព្យសនកម្មដែរឬទេ ហើយប្រសិនបើមាន (៣) មានភ័ស្តុតាងគាំទ្រដល់ការចោទប្រកាន់ដែរឬទេ[1554]។

ឧទាហរណ៍ វិធាន ៦៧(២) នៃវិធានផ្ទៃក្នុងចែងថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី"[1555]។ វិធាន ៥៣(៣) តម្រូវឱ្យមានទម្រង់ការស្រដៀងគ្នានេះ សម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អវត្តមានផ្នែកណាមួយនៃទម្រង់ការបែបនេះ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ [...] ត្រូវទុកជាមោឃៈ"។

"ការរំលោភសិទ្ធិ" មានន័យថា "ជាការប៉ះពាល់ដល់ផលប្រយោជន៍"[1556]។ ឧទាហរណ៍ ភ័ស្តុតាងដែលទទួលបានមកពីការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដូចដែលទទួលស្គាល់នៅក្នុង ICCPR ត្រូវបានចាត់ទុកថាជាវិការៈនីតិវិធី ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ ដែលអាចនាំឱ្យមានការធ្វើមោឃភាពបាន[1557]។ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះបានសម្រេចថា ដើម្បីឱ្យមោឃភាពភ័ស្តុតាងបែបនោះបាន អង្គបុរេត្រូវពិចារណាលើកត្តានានា ដូចជា "វិធីសាស្ត្រ និងកាលៈទេសៈជុំវិញការប្រមូលភ័ស្តុតាង ភាពជឿជាក់របស់ភ័ស្តុតាងនោះ ព្រមទាំងផលប៉ះពាល់លើផលប្រយោជន៍នៃកិច្ចដំណើរការនីតិវិធី"[1558]។ ផ្សេងពីនេះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាថា វិការៈនីតិវិធីដែលមិនបង្កព្យសនកម្មដល់អ្នក

---

[1551] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១៨។

[1552] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៣៥។

[1553] ដូចខាងលើ កថាខណ្ឌ ៣៧។

[1554] សំណុំរឿង ០០៣ សាលដីការបស់អង្គជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 កថាខណ្ឌ ២២។

[1555] វិធានផ្ទៃក្នុង វិធាន៦៧(២)។

[1556] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៣៦។

[1557] សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត ក.ស.ច.ស. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ១៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៤០។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២១។

[1558] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ៤១។

ស្នើសុំ ដូចជា ឯកសារវិការៈនីតិវិធីដែលពុំមានតម្លៃជាភ័ស្តុតាង ពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងអ្នកស្នើសុំនោះ "មិនតម្រូវឱ្យមានការធ្វើមោឃភាពឡើយ"[1559]។

### ៥.៥.២.២.៣. អានុភាពនៃការមោឃភាពកិច្ចស៊ើបសួរ

នៅពេលដែលពាក្យសុំមោឃភាពត្រូវបានទទួលយក កិច្ចស៊ើបសួរ ឬកិច្ចតុលាការមួយ(ច្រើន) ត្រូវប្រកាសទុកជាមោឃៈ (ឬត្រូវ) ដកចេញពីសំណុំរឿង[1560]។ អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើមោឃភាពនោះបានប៉ះពាល់លើកិច្ច ឬដីកាដទៃទៀតឬទេ[1561]។ ទោះជាយ៉ាងណា ពុំមានអ្វីអាចរារាំងដល់ការស៊ើបអង្កេតថ្មីក្នុងការដាក់សម្ភារៈថ្មី ដែលមិនប៉ះពាល់ដោយវិការៈទាំងអស់នេះ ទៅក្នុងសំណុំរឿងបានឡើយ[1562]។ ទោះបីជានីតិវិធីធ្វើមោឃភាពត្រូវបានតាក់តែងឡើងដើម្បីធ្វើមោឃភាពផ្នែកនៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបានប៉ះពាល់ដោយវិការៈនីតិវិធី "មិនមែន [...] កិច្ចស៊ើបសួរទូទៅ"[1563] ក៏ដោយ ក៏អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការលើកឡើងពីផលវិបាក នៃការធ្វើមោឃភាពទៅលើរឿងក្ដីទាំងមូល[1564]។ ចៅក្រម សហព្រះរាជអាជ្ញា ឬសហមេធាវី ណាម្នាក់ ដែលត្រូវបានរកឃើញថាមានកំហុសពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ឬដីកា ដែលត្រូវបានធ្វើមោឃភាព ត្រូវប្រឈមនឹងទណ្ឌកម្មផ្នែកវិន័យ អនុលោមតាមវិធាន ៦ នៃវិធានផ្ទៃក្នុង ដែលចែងអំពីកំហុស ឬការធ្វេសប្រហែសរបស់បុគ្គលិក អ.វ.ត.ក. ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងវិធាន ៣៥ ដែលចែងអំពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[1565]។

### ៥.៥.៣. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និង សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត

វិធាន ៧៣(ក) នៃវិធានផ្ទៃក្នុង ផ្ដល់យុត្តាធិការដល់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ មានតែភាគីទៅនឹងរឿងក្ដីប៉ុណ្ណោះ ពោលគឺ សហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី[1566] អាចទាមទារសិទ្ធិជំនុំជម្រះចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយលើបណ្ដឹងឧទ្ធរណ៍[1567]។

---

[1559] សំណុំរឿង ០០៤/០១ សេចក្ដីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យមោឃភាពលើប្រតិចារិក និងកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D298/2/1/3 យោបល់របស់ចៅក្រម Olivier Beauvallet និង Baik Kang Jin កថាខណ្ឌ ៤២ និង ៥០-៥៣។

[1560] វិធានផ្ទៃក្នុង វិធាន ៧៦(៥)។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២៧។

[1561] វិធានផ្ទៃក្នុង វិធាន ៧៦(៥)។

[1562] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២៧។

[1563] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ឯកសារ D197/5/8 កថាខណ្ឌ ២៤។

[1564] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២៤-២៦។

[1565] វិធានផ្ទៃក្នុង វិធាន ៦ និង ៣៥(១) និង ៧៦(៥)។

[1566] សូមមើល វិធានផ្ទៃក្នុង សទ្ទានុក្រម ("ភាគី")។

[1567] សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្ដីពីការអនុវត្តន៍ទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ "ឌុច" ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ១០ (យោងតាម វិធានផ្ទៃក្នុង វិធាន ៧៧(៣) និង (១០))។ សូមមើលផងដែរ សំណុំរឿង ០០៤ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការផ្ដល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D309/6 កថាខណ្ឌ ១៧។ ជនដែលមិនមែនជាភាគីដែលរងផលប៉ះពាល់ មានសិទ្ធិប្ដឹងឧទ្ធរណ៍សេចក្ដីសម្រេច ដែលបដិសេធមិនប្រគល់វត្ថុទាំងឡាយដែលបានចាប់យក។ សូមមើល វិធានផ្ទៃក្នុង វិធាន ៧៤(៥)។ ចំពោះប្រភេទបណ្ដឹងឧទ្ធរណ៍ដែលមានសម្រាប់សហព្រះរាជអាជ្ញា ជន

ជនសង្ស័យដែលមិនមែនជាភាគី មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅនឹងដីកា និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះទេ[1568]។ ស្រដៀងគ្នានេះ ជនត្រូវចោទមិនមានសិទ្ធិធ្វើអន្តរាគមន៍ក្នុងបណ្តឹងឧទ្ធរណ៍ នៅក្នុងរឿងក្តីទាំងឡាយណាដែលពួកគេមិនមែនជាភាគីនោះឡើយ[1569]។ ផ្ទុយទៅវិញ នៅក្នុងរឿងក្តីដែលមានជនត្រូវចោទច្រើន ជនត្រូវចោទម្នាក់ៗដែលរងការប៉ះពាល់ មានសិទ្ធិប្តឹងឧទ្ធរណ៍ ដោយមិនគិតថាតើពួកគេបានចូលរួមក្នុងសំណើដើមដែរ ឬយ៉ាងណានោះឡើយ[1570] ឬ បានដាក់សំណើសុំពាក់ព័ន្ធណាមួយ ដែលមិនត្រូវបានយោងនៅក្នុងដីកា ឬសេចក្តីសម្រេច ដែលកំពុងត្រូវបានប្តឹងឧទ្ធរណ៍នោះ[1571]។

### ៥.៥.៣.១. នីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និង សេចក្តីសម្រេច

វិធាន ៧៥ និង ៧៧(៣) នៃវិធានផ្ទៃក្នុងគ្រប់គ្រងលើនីតិវិធីបណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកា និង សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើកលែងតែបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានគ្រប់គ្រងដោយវិធាន ៧៧*ស្ទួន*[1572]។

យោងតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ត្រូវដាក់នៅអង្គបុរេជំនុំជម្រះក្នុងរយៈពេលដប់ថ្ងៃ ហើយសារណាលើបណ្តឹងឧទ្ធរណ៍ ត្រូវដាក់នៅអង្គបុរេជំនុំជម្រះក្នុងរយៈសាបសិបថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីដីកា ឬ សេចក្តីសម្រេច ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬបារាំង[1573]។ ចម្លើយតបទៅនឹងសារណាលើបណ្តឹងឧទ្ធរណ៍ ត្រូវដាក់ក្នុងរយៈពេលដប់ថ្ងៃនៃប្រតិទិន ហើយ ការឆ្លើយតបទៅនឹងចម្លើយតបត្រូវដាក់ក្នុងរយៈពេលប្រាំថ្ងៃនៃប្រតិទិន គិតចាប់ពីការជូនដំណឹងអំពីឯកសារដែលភាគីដាក់ចម្លើយតប ឬដាក់ការឆ្លើយតបនោះ[1574]។ សារណាជាលាយលក្ខណ៍អក្សរទាំងអស់ត្រូវដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬបារាំង[1575] ហើយត្រូវគោរពតាមចំនួនទំព័រកំណត់ដែលមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក.[1576]។ ក្នុងកាលៈទេសៈពិសេស អង្គបុរេជំនុំជម្រះអាចផ្តល់ការអនុញ្ញាតទទួលយកសំណើរបស់ភាគី ស្នើសុំការបន្ថែមពេល

---

ត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី សូមមើល វិធានផ្ទៃក្នុង វិធាន ៧៤(២), ៧៤(៣) និង ៧៤(៤) តាមលំដាប់នីមួយៗ។

[1568] សូមមើល វិធានផ្ទៃក្នុង សទ្ទានុក្រម (“ភាគី”)។ សូមមើលផងដែរ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D190/1/2 កថាខណ្ឌ ១៨ (យោង សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ D121/4 កថាខណ្ឌ ៣៧)។ សូមមើលផងដែរ សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D309/6 កថាខណ្ឌ ១៧។

[1569] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ "ឌុច" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ១៤។ សំណុំរឿង ០០៤/០១ សេចក្តីសម្រេចទៅលើសំណើរបស់ អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់ អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសម្លេង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D296/4 កថាខណ្ឌ ៦។

[1570] សូមមើល សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយកបាននៃ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ សហចៅក្រមស៊ើបអង្កេតសម្រេចអំពី ការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ឯកសារ D130/10/12 កថាខណ្ឌ ១៤។

[1571] សំណុំរឿង ០០២ សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D130/7/3/5 កថាខណ្ឌ ១៨។

[1572] វិធានផ្ទៃក្នុង វិធាន ៧៥ និង ៧៧(៣) និង ៧៧ ស្ទួន។

[1573] វិធានផ្ទៃក្នុង វិធាន ៧៥(១) និង ៧៥(៣)។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.៥។

[1574] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.៣ និង ៨.៤។

[1575] ដូចខាងលើ មាត្រា ៧.១។

[1576] ដូចខាងលើ មាត្រា ៥.២។

វេលា[1577] និងទំព័រ[1578] ក៏ដូចជាអនុញ្ញាតឱ្យពួកគេដាក់សារណាជាលាយលក្ខណ៍អក្សរជាភាសាបារាំង ឬអង់គ្លេស ជាមុន ដោយដាក់អត្ថបទបកប្រែជាភាសាខ្មែរតាមក្រោយ[1579]។

អវត្តមានមូលហេតុត្រឹមត្រូវសម្រាប់ការដាក់ឯកសារយឺត និងអវត្តមានការអនុញ្ញាតជាមុនពីអង្គបុរេជំនុំជម្រះ នោះសារណាដែលដាក់យឺត ត្រូវសម្រេចថាមិនអាចទទួលយកបាន[1580]។ យោងតាមវិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង បន្ទាប់ពីទទួលបានការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ប្រធានអង្គបុរេជំនុំជម្រះត្រូវ "កំណត់កាលបរិច្ឆេទសវនាការ"[1581]។ យ៉ាងណាមិញ អង្គបុរេជំនុំជម្រះអាចសម្រេចកំណត់លើបណ្តឹងឧទ្ធរណ៍ផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែឯងប៉ុណ្ណោះ[1582]។ តាមការអនុវត្ត អង្គបុរេជំនុំជម្រះបើកសវនាការតែក្នុងករណីពិសេសប៉ុណ្ណោះ នៅពេលដែលអង្គបុរេពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[1583] និងដីកាឃុំខ្លួនបណ្តោះអាសន្ន[1584]។

អង្គបុរេជំនុំជម្រះបានពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង "ឱ្យបានឆាប់រហ័សដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ"[1585]។ "សារណាជាលាយលក្ខណ៍អក្សរត្រូវដាក់ក្នុងរយៈពេលដប់ថ្ងៃ គិតចាប់ពីការជូនដំណឹងអំពីដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ហើយចម្លើយតបវិញត្រូវដាក់ក្នុងរយៈពេលប្រាំថ្ងៃ គិតចាប់ពីការជូនដំណឹងនៃសារណាបណ្តឹងឧទ្ធរណ៍ ចំណែកការឆ្លើយតបវិញ មិនត្រូវបានអនុញ្ញាតឡើយ"[1586]។ ក្នុងករណីពិសេស អង្គបុរេជំនុំជម្រះអាចងាកចេញពីនីតិវិធីដែលមានចែងក្នុងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង ដោយអនុញ្ញាតផ្តល់ឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវពេលវេលា និងចំនួនទំព័របន្ថែម ក៏ដូចជា សិទ្ធិក្នុងការដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនតែមួយភាសា ដោយដាក់សំណៅបកប្រែតាមក្រោយ នៅពេលដែលប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់នៅក្នុងសំណុំរឿងភ្លាមៗ[1587]។

### ៥.៥.៣.២. ដីកា និង សេចក្តីសម្រេចដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍

វិធាន ៧៤ នៃវិធានផ្ទៃក្នុងផ្តល់នូវបញ្ជីពេញលេញអំពីដីកា និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍។ បើទោះជាសហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ "ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត"[1588] ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកំណត់ត្រឹមតែដីកា និងសេចក្តីសម្រេចមួយចំនួនដូចខាងក្រោម៖

i. *ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍*៖ ដីកា និងសេចក្តីសម្រេចដែលបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ[1589] ការបដិសេធពាក្យសុំឱ្យ

---

[1577] វិធានផ្ទៃក្នុង វិធាន ៣៩(៤)(ក)។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.១។
[1578] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៥.៤។
[1579] ដូចខាងលើ មាត្រា ៧.២។
[1580] សូមមើល សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D338/1/1/3 កថាខណ្ឌ ៦-៧។
[1581] វិធានផ្ទៃក្នុង វិធាន៧៧(៣)(ក)។
[1582] វិធានផ្ទៃក្នុង វិធាន៧៧(៣)(ខ)។
[1583] សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៣ ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D266/12។
[1584] សូមមើល *ឧទាហរណ៍* សំណុំរឿង ០០១ សេចក្តីសម្រេចអំពីការកំណត់ ថ្ងៃបើកសវនាការ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៧ C5/20។
[1585] វិធានផ្ទៃក្នុង វិធាន៧៧ ស្ទួន (១)។
[1586] វិធានផ្ទៃក្នុង វិធាន៧៧ ស្ទួន (២)។
[1587] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/4 កថាខណ្ឌ ៩-១២។
[1588] វិធានផ្ទៃក្នុង វិធាន ៧៤(២)។
[1589] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ខ) និង ៧៤(៤)(ក)។

ប្រគល់មកវិញនូវទ្រព្យសម្បត្តិដែលចាប់យក[1590] ការបដិសេធសំណើសុំរបាយការណ៍របស់អ្នកជំនាញ[1591] និង កិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញ[1592] ការបដិសេធពាក្យសុំប្ដឹងទៅអង្គបុរេជំនុំជម្រះ ដើម្បីមោឃភាពកិច្ចស៊ើបសួរណាមួយ[1593] ពាក់ព័ន្ធទៅនឹងវិធានការការពារ[1594] និងការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[1595]។

ii. *លើកលែងតែដើមបណ្ដឹងរដ្ឋប្បវេណីចេញ ជនត្រូវចោទ/ជនជាប់ចោទ អាចប្ដឹងឧទ្ធរណ៍៖* ដីកា និងសេចក្ដីសម្រេចដែលបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក.[1596] ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ[1597] និងការប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[1598]។

iii. *លើកលែងតែជនត្រូវចោទ/ជនជាប់ចោទចេញ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍៖* ដីកាប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[1599] និងដីកាសម្រេចលើកលែងចោទប្រកាន់ ប្រសិនបើសហព្រះរាជអាជ្ញាបានប្ដឹងឧទ្ធរណ៍ដែរ[1600]។

មូលដ្ឋានមួយចំនួនក្នុងចំណោមមូលដ្ឋាននានាដែលមានរៀបរាប់ខាងលើ មិនត្រូវបានតវ៉ានៅចំពោះមុខអង្គបុរេជំនុំជម្រះទេ ហេតុដូច្នេះនឹងមិនត្រូវបានពិនិត្យក្នុងផ្នែកខាងក្រោមឡើយ[1601]។

### ៥.៥.៣.២.១. *ការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក.*

មានតែការជំទាស់ទៅនឹងយុត្តាធិការប៉ុណ្ណោះ ដែលអាចត្រូវបានលើកឡើងនៅលើបណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[1602]។ ការជំទាស់ទៅនឹងយុត្តាធិការជាទូទៅត្រូវបានយល់ថាជា ការជំទាស់ទាំងឡាយ "ចំពោះសមត្ថកិច្ចរបស់តុលាការ *លើបុគ្គល លើរឿងក្ដី តាមពេលវេលា និងទីកន្លែង*"[1603]។ អង្គបុរេជំនុំជម្រះអនុម័តយុត្តិសាស្ត្ររបស់សាលាក្ដី *មិនអចិន្ត្រៃយ៍* ជាជាងយុត្តិសាស្ត្ររបស់ប្រព័ន្ធច្បាប់ស៊ីវិលជាតិ ក្នុងការសម្រេចថាអ្វីខ្លះដែលបង្កើតបានជាការជំទាស់យុត្តាធិការត្រឹមត្រូវមួយ[1604]។

---

[1590] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(គ) និង ៧៤(៤)(គ)។
[1591] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ឃ) និង ៧៤(៤)(ឃ)។
[1592] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ង) និង ៧៤(៤)(ង)។
[1593] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ឆ) និង ៧៤(៤)(ឆ)។
[1594] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ជ) និង ៧៤(៤)(ជ)។
[1595] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ញ) និង ៧៤(៤)(ញ)។
[1596] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ក)។
[1597] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ច)។
[1598] វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ឈ)។
[1599] វិធានផ្ទៃក្នុង វិធាន ៧៤(៤)(ខ)។
[1600] វិធានផ្ទៃក្នុង វិធាន ៧៤(៤)(ច)។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៣។
[1601] ទាំងនេះរួមមាន៖ បណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងដីកា និងសេចក្ដីសម្រេចបដិសេធសំណើសុំប្រគល់មកវិញនូវវត្ថុដែលចាប់យក (វិធានផ្ទៃក្នុង ៧៤(៣)(គ) និង ៧៤(៤)(គ) និង ៧៤(៥)) បណ្ដឹងឧទ្ធរណ៍ដោយដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ (វិធានផ្ទៃក្នុង ៧៤(៤)(ច)) បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទាក់ទងនឹងវិធានការការពារ (វិធានផ្ទៃក្នុង ៧៤(៣)(ជ) និង ៧៤(៤)(ជ)) និង បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និងសេចក្ដីសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ (វិធានផ្ទៃក្នុង ៧៤(៣)(ញ) និង ៧៤(៤)(ញ))។
[1602] សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ២១។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥។
[1603] សូមមើល សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១៦ ឯកសារ D128/1/9 កថាខណ្ឌ ២៧។ កថាខណ្ឌ ២៧។
[1604] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥។

វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង មិនបានរៀបរាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងចំណោមដីកាដែលបើកផ្លូវប្ដឹងឧទ្ធរណ៍ដោយជនត្រូវចោទនោះទេ។ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះសម្រេចថា "ដើម្បីឱ្យដីកាណាមួយបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក. ដីកានោះត្រូវតែអាចប្ដឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងបញ្ហាស្ដីពីយុត្តាធិការ ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត"។ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះបានផ្ដល់សំអាងហេតុថា វានឹងមិនស្របជាមួយនឹងវិធីសាស្ត្រ ដែលបានអនុម័តដោយវិធានផ្ទៃក្នុង ក្នុងការអនុញ្ញាតឱ្យជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "លើគ្រប់ផ្នែកទាំងអស់" ដើម្បីឱ្យមានការបញ្ជាក់ជាទូទៅលើយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការវិនិច្ឆ័យពួកគេនោះទេ[1605]។

ហេតុដូច្នេះ ការជំទាស់ទៅនឹងភាពមិនប្រក្រតីផ្នែកនីតិវិធីក្នុងការស៊ើបអង្កេត ដែលបានលើកឡើងនៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬការជំទាស់ដែលចោទប្រកាន់អំពីវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ មិនបង្កើតបានជាការជំទាស់ទៅនឹងយុត្តាធិការនៅក្នុងអត្ថន័យនៃវិធាន ៧៥(៣)(ក) នោះទេ[1606]។

ការជំទាស់ទាក់ទងនឹង "បញ្ហាជាក់លាក់មួយចំនួន" នៃឧក្រិដ្ឋកម្មសំខាន់ៗ ឬទម្រង់នៃការទទួលខុសត្រូវ គឺមិនអាចទទួលយកបាននៅដំណាក់កាលមុនការជំនុំជម្រះ ដោយសារតែការជំទាស់ទាំងនោះ "ទាក់ទិនទៅនឹងបញ្ហាពិតប្រាកដ ឬបញ្ហាចម្រុះរវាងការសម្រេចលើអង្គច្បាប់ និងអង្គហេតុដែលត្រូវធ្វើឡើង នៅពេលសវនាការ ផ្អែកតាមការសួរដេញដោល និងការវិនិច្ឆ័យលើភស្តុតាងដែលពាក់ព័ន្ធ"។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះចាត់ទុកបណ្ដឹងឧទ្ធរណ៍ណាមួយថាជាការជំទាស់ទៅនឹងយុត្តាធិការប្រកបដោយសុពលភាព ប្រសិនបើបណ្ដឹងឧទ្ធរណ៍នោះជំទាស់ទៅនឹង "អត្ថិភាព" ឬ "ការទទួលស្គាល់" ឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ នៅពេលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានបង្ហាញថា ការអនុវត្តបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវដែលបានលើកឡើងនោះ នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព[1607]។ អង្គបុរេជំនុំជម្រះបានផ្ដល់សំអាងហេតុថា "គោលការណ៍នីត្យានុកូលភាពត្រូវតែជាគោលការណ៍មួយដែលបានបង្កើតឡើងពីមុន និងមានភាពសមហេតុផលសមស្របអាចទទួលយកបានថាបទល្មើសជាក់ស្ដែងមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវ បានកើតឡើងនៅពេលដែលបទល្មើសត្រូវលើកឡើងថាបានប្រព្រឹត្ត"[1608]។

ការជំទាស់ទៅនឹងសេចក្ដីសម្រេច*បង្គប់ន័យ*របស់សហចៅក្រមស៊ើបអង្កេត ដែលថា សហឧក្រិដ្ឋកម្មរួមបានអនុវត្តនៅ អ.វ.ត.ក. ក៏ត្រូវបានចាត់ទុកថាជាការជំទាស់យុត្តាធិការប្រកបដោយសុពលភាពផងដែរ[1609]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់ច្បាស់លាស់អំពីយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ ក៏សេចក្ដីសម្រេចរបស់ពួកគេ "ផ្អែកយ៉ាងច្បាស់លើយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលចាត់ទុកថាជាបញ្ហាយុត្តាធិការ ចំពោះបញ្ហាថាតើទម្រង់នៃការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ឬយ៉ាងណា"[1610]។

ការជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការដាក់ជនសង្ស័យឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដោយមិនមានបទប្បញ្ញត្តិជាក់លាក់ គឺជា "សេចក្ដីសម្រេចមួយ

---

[1605] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ខៀវ សំផន) កថាខណ្ឌ ១៤។
[1606] ដូចខាងលើ។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៧។
[1607] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៥-៤៦។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងការជូនដំណឹងស្ដីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋមួយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D347.1/1/7 កថាខណ្ឌ ១១។
[1608] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៦៩។
[1609] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ២២-២៥។
[1610] ដូចខាងលើ កថាខណ្ឌ ២៤។

“ដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក.” នៅពេលបកស្រាយយ៉ាងទូលំទូលាយនោះ”[1611]។ អង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុថា ការបកស្រាយទូលំទូលាយនៃសញ្ញាណនៃយុត្តាធិការ មានលក្ខណៈសមស្របនៅក្នុងកាលៈទេសៈទាំងអស់នេះ ដោយហេតុថា៖ (១) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបាន “ព្យាយាមលើកឡើងនូវស្ថានភាពមួយដែលគាត់យល់ថា ពុំអាចប្រមើលដឹងមុនបាន” នៅក្នុងក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. និង (២) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺជា “ឱកាសដំបូងសម្រាប់ភាគីក្នុងការបង្ហាញនូវទស្សនៈរបស់ខ្លួន” និងត្រូវ “ដោះស្រាយឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ពីព្រោះវាអាចមានអានុភាពទៅលើការបន្តកិច្ចដំណើរការនីតិវិធីទៅទៀតប្រឆាំងនឹង [ពួកគេ]”[1612]។

### ៥.៥.៣.២.២. *ការបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ*

យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ខ) និង ៧៤(៤)(ក) នៃវិធានផ្ទៃក្នុង តម្រូវឱ្យ៖ (១) សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដែល “ត្រូវអនុញ្ញាតក្រោមវិធានផ្ទៃក្នុង” និង (២) ការបដិសេធសំណើនោះដោយសហចៅក្រមស៊ើបអង្កេត[1613]។

អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ គឺជាសំណើមួយ “សុំឱ្យសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេត ឬក៏មន្ត្រីនគរបាលយុត្តិធម៌ តាមរយៈដីកាចាត់ឱ្យសួរជំនួស បំពេញកិច្ចណាមួយ ក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត”[1614]។ សំណើដែលមានគោលបំណងទទួលបានព័ត៌មាន ដូចជាការបង្ហាញពី “អំពើពុករលួយ” របស់ស្ថាប័ន[1615] ការបញ្ជាក់ពីភាពអាចទទួលយកបាន ឬវិធីសាស្ត្រដែលប្រើដើម្បីសម្រាប់ការវាយតម្លៃភស្តុតាងជាក់លាក់មួយចំនួនដោយសហចៅក្រមស៊ើបអង្កេត[1616] ការទទួលបានការបកប្រែឯកសារជាភាសារបស់ជនត្រូវចោទ ឬសហមេធាវីរបស់ពួកគេ[1617] មិនបង្កើតបានជាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនោះទេ។

[1611] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១៦ ឯកសារ D128/1/9 កថាខណ្ឌ ២៩។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ២៤។

[1612] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១៦ ឯកសារ D128/1/9 កថាខណ្ឌ ២៨។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ២៣។

[1613] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/1/15 កថាខណ្ឌ ២១។

[1614] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ២៨។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ ក.ស.ច.ស. លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស. នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D130/7/3/5 កថាខណ្ឌ ២៣។

[1615] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/1/15 កថាខណ្ឌ ២៤-២៨។

[1616] សំណុំរឿង ០០២ សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ ក.ស.ច.ស. លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស. នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D130/7/3/5 កថាខណ្ឌ ២២-២៤។

[1617] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ២៨-៣០។

សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិ ក្នុងការសម្រេចលើភាពចាំបាច់ ឬឱកាសក្នុងការសម្រេចបានកិច្ចស៊ើបសួរណាមួយ[1618]។ នៅពេលដែលសហចៅក្រមស៊ើបអង្កេត មិនឯកភាពជាមួយនឹងសំណើរបស់ភាគី សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធ ឱ្យបានឆាប់ដូចដែលអាចធ្វើទៅបាន ហើយក្នុងករណីណាក៏ដោយ ត្រូវចេញមុនពេលបិទកិច្ចស៊ើបសួរ[1619]។

### ៥.៥.៣.២.៣. *ការបដិសេធពាក្យសុំរបាយការណ៍អ្នកជំនាញ ឬសុំការស៊ើបសួរបន្ថែមដោយអ្នកជំនាញ*

វិធាន ៧៤ នៃវិធានផ្ទៃក្នុង បែងចែកមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធ៖ (១) ពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធាន ៧៤(៣)(ឃ) និង ៧៤(៤)(ឃ) និង (២) ពាក្យសុំកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាន ៧៤(៣)(ង) និង ៧៤(៤)(ង)។ ទោះជាយ៉ាងណា មូលដ្ឋានទាំងពីរនេះមានសារៈសំខាន់ស្រដៀងគ្នា និងត្រូវបានអនុវត្តលើបណ្ដឹងឧទ្ធរណ៍ ទាក់ទងនឹងសំណើសុំអនុលោមតាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង[1620] ដែលអនុញ្ញាតឱ្យភាគីស្នើសុំឱ្យមានការតែងតាំងអ្នកជំនាញ ដើម្បីធ្វើការពិនិត្យណាមួយ ដែលមិនធ្លាប់បានធ្វើពីមុនមក និង/ឬ ដើម្បីធ្វើការពិនិត្យឡើងវិញលើបញ្ហាណាមួយ ដែលជាកម្មវត្ថុនៃរបាយការណ៍របស់អ្នកជំនាញណាម្នាក់រួចហើយនោះ[1621]។ ហេតុដូច្នេះ យុត្តាធិការរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមាន៖ (១) សំណើសុំរបាយការណ៍អ្នកជំនាញណាមួយ ឬពាក្យសុំកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង និង (២) ការបដិសេធពាក្យសុំដោយសហចៅក្រមស៊ើបអង្កេត[1622]។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាថា លក្ខខណ្ឌតម្រូវដែលថា សហចៅក្រមស៊ើបអង្កេត "បង្ហាញពីសំអាងហេតុក្នុងការបដិសេធ" ចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង អនុវត្តដូចគ្នាចំពោះសំណើសុំអ្នកជំនាញអនុលោមតាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង[1623]។ សហចៅក្រមស៊ើបអង្កេត ត្រូវសម្រេចលើសំណើសុំអ្នកជំនាញ "ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមុនពេលបញ្ចប់ការស៊ើបសួរ"[1624]។ លក្ខខណ្ឌទាំងពីរនេះគឺជាលក្ខខណ្ឌរួមគ្នា៖ សហចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឱ្យជ្រើសរើសយកការចេញសេចក្ដីសម្រេច "ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន" ឬក៏ចេញសេចក្ដីសម្រេច "មុនពេលបញ្ចប់ការស៊ើបអង្កេតឡើយ"[1625]។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចលើ សំណើសុំឱ្យតែងតាំងអ្នកជំនាញកោសល្យវិច័យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន

---

[1618] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២២។

[1619] *វិធានផ្ទៃក្នុង* វិធាន ៥៥(១០)។

[1620] *ធៀបទៅនឹង* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២៤ (យោង វិធានផ្ទៃក្នុង ៧៤(៣)(ឃ))។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីកា របស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D140/4/5 កថាខណ្ឌ ១៤ (យោង វិធានផ្ទៃក្នុង ៧៤(៣)(ង))។ សម្រាប់ព័ត៌មានបន្ថែមអំពីសំណើសុំអ្នកជំនាញ សូមមើល ផ្នែក ៤.១២។

[1621] *វិធានផ្ទៃក្នុង* វិធាន ៣១(១០)។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីកា របស់សហចៅក្រមស៊ើបអង្កេតសម្រេច លើសំណើសុំអ្នកជំនាញបន្ថែម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D140/4/5 កថាខណ្ឌ ១១។

[1622] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីកា របស់សហចៅក្រមស៊ើបអង្កេតសម្រេច លើសំណើសុំអ្នកជំនាញបន្ថែម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D140/4/5 កថាខណ្ឌ ១១-១៤។

[1623] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើលើកទីប្រាំរបស់ សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D260/1/1/3 យោបល់របស់ចៅក្រម Olivier Beauvallet និង Baik Kang Jin កថាខណ្ឌ ៦០។

[1624] *វិធានផ្ទៃក្នុង* វិធាន ៣១(១០)។

[1625] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២១។

ធ្វើឱ្យជនត្រូវចោទបាត់បង់លទ្ធភាពទទួលបានផលប្រយោជន៍ដែលខ្លួនចង់បាន ពោលគឺ ឱ្យអ្នកជំនាញធ្វើកោសល្យវិច័យលើសមត្ថភាពស្មារតីរបស់ខ្លួន ដើម្បីជួយគាត់ក្នុងការពារខ្លួន និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ដូច្នេះបង្កើតបានជាការបដិសេធតាមការសន្មតលើសំណើសុំ ដែលអាចប្ដឹងឧទ្ធរណ៍បាននៅចំពោះមុខអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ឃ) នៃវិធានផ្ទៃក្នុង[1626]។ យ៉ាងណាមិញនៅក្នុងរឿងក្ដីដដែលនេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍តាមវិធាន ៧៤(៣)(ង) មិនអាចទទួលយកបាន នៅពេលដែលអ្នកជំនាញណាម្នាក់ត្រូវបានតែងតាំងដោយសហចៅក្រមស៊ើបអង្កេត ប៉ុន្តែរបាយការណ៍របស់អ្នកជំនាញនោះ មិនទាន់ត្រូវបានបញ្ចប់នៅឡើយ[1627]។

### ៥.៥.៣.២.៤. *ការបដិសេធពាក្យសុំឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃភាពកិច្ចស៊ើបសួរណាមួយ*

យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ យោងតាមមាត្រា ៧៤(៣)(ឆ) និង ៧៤(៤)(ឆ) តម្រូវឱ្យមាន៖ (១) ពាក្យសុំមានសំអាងហេតុទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យមោឃភាពកិច្ចស៊ើបសួរណាមួយ និង (២) ការបដិសេធសំណើនោះដោយសហចៅក្រមស៊ើបអង្កេត[1628]។ សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឱ្យចេញដីកាសម្រេច លើសំណើសុំប្ដឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យមោឃភាពកិច្ចស៊ើបសួរ "ភ្លាមៗតាមដែលអាចធ្វើទៅបាន និងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ"[1629] ដោយលើកឡើងនូវសំអាងហេតុសម្រាប់ការប្ដឹងទៅអង្គបុរេជំនុំជម្រះ ឬសម្រាប់ការបដិសេធធ្វើដូច្នោះ[1630]។

### ៥.៥.៣.២.៥. *ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន និង ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ*

*ការឃុំខ្លួនបណ្ដោះអាសន្ន*៖ ជនត្រូវចោទ ឬជនជាប់ចោទអាចប្ដឹងឧទ្ធរណ៍ដីកា ឬ សេចក្ដីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន[1631]។ ការណ៍នេះរួមមាន

---

[1626] ដូចខាងលើ កថាខណ្ឌ ២២-២៤។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ ឯកសារ D54/V/6 កថាខណ្ឌ ១៦។

[1627] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីកា របស់សហចៅក្រមស៊ើបអង្កេតសម្រេច លើសំណើសុំអ្នកជំនាញបន្ថែម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D140/4/5 កថាខណ្ឌ ១២-១៤។

[1628] សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ១១។ សំណុំរឿង ០០៣ សាលដីការបស់អង្គបុរេជំនុំជម្រះ (១) លើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្ដឹងទៅអង្គបុរេជំនុំជម្រះឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង (២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D165/2/26 កថាខណ្ឌ ២០-២៧។ សូមមើល សំណុំរឿង ០០៣ សាលដីការបស់អង្គជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 កថាខណ្ឌ ១៣។ ចំពោះព័ត៌មានបន្ថែមអំពីនីតិវិធីមោឃភាព សូមមើល ផ្នែក ៥.៥.២។

[1629] វិធានផ្ទៃក្នុង វិធាន ៧៦(២)។

[1630] សំណុំរឿង ០០៣ សាលដីការបស់អង្គជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 កថាខណ្ឌ ១៨។

[1631] សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងដីការដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/5/10 កថាខណ្ឌ ១៦។

ឧទាហរណ៍ ការជំទាស់ទៅនឹងដីកាដំបូងស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន[1632] ការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្ន[1633] ក៏ដូចជា ទម្រង់ការនានា[1634] និងលក្ខខណ្ឌនៃការឃុំខ្លួន[1635]។

អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ទាំងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និង ច្បាប់ អ.វ.ត.ក. ពុំបានចែងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតទេ។ វិធាន ៧៤(៣)(ច) អនុញ្ញាតឱ្យមានលទ្ធភាពនេះ "ដោយដឹងថាក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មានចែងអំពីបទប្បញ្ញត្តិទាក់ទងនឹងសភាស៊ើបសួរ"[1636]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបានសម្រេចថា យុត្តាធិការរបស់ខ្លួនក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន បានមកពីយុត្តាធិការដែលផ្ដល់ឱ្យសភាស៊ើបសួរ ដែលធ្វើការពិនិត្យបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីបញ្ហាការឃុំខ្លួនបណ្ដោះអាសន្ន យោងតាមច្បាប់កម្ពុជា[1637]។

*ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការដោះលែង៖* សំណើសុំដោះលែងណាមួយ ដែលបានដាក់ទៅប្រធានអង្គបុរេជំនុំជម្រះ ជាជាងទៅសហចៅក្រមស៊ើបអង្កេត គឺមិនអាចទទួលយកបានទេ[1638]។ នៅពេលដែលដាក់ពាក្យស្នើសុំឱ្យដោះលែងពីការឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទមានបន្ទុក "បង្ហាញថា លក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង លែងត្រូវបំពេញទៀតហើយ"[1639]។ ទោះបីជាវិធានផ្ទៃក្នុងពុំមានចែងអំពីការដោះលែងជនត្រូវចោទ ផ្អែកលើមូលដ្ឋាននៃការពិចារណាលើសុខភាព ក៏វិធានស្ដីពីនីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ អនុញ្ញាតឱ្យមានការដោះលែងជនត្រូវចោទពីការឃុំខ្លួនបណ្ដោះអាសន្ន ផ្អែកលើមូលដ្ឋានមនុស្សធម៌ តែនៅពេលណាដែលលក្ខខណ្ឌរបស់ពួកគេមានវិសមិតភាពជាមួយនឹងការឃុំខ្លួន[1640]។

### ៥.៥.៣.២.៦. *ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី*

អង្គបុរេជំនុំជម្រះបានពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និង សេចក្ដីសម្រេច ទាក់ទងនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៧៧*ស្ទួន*នៃវិធានផ្ទៃក្នុង[1641]។ នៅពេលវាយតម្លៃសម្ភារៈគាំទ្រពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះ

---

[1632] សូមមើល *ឧទាហរណ៍* សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45។

[1633] សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C9/4/7។

[1634] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ១១។

[1635] សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិចូលជួប ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០០៨ ឯកសារ A104/II/4 កថាខណ្ឌ ១០។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ C33/I/7 កថាខណ្ឌ ១០។

[1636] សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៧។

[1637] ដូចខាងលើ កថាខណ្ឌ ៧។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងបណ្ដឹងឧទ្ធរណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/53 កថាខណ្ឌ ៣៨។

[1638] សូមមើល សំណុំរឿង ០០២ សេចក្ដីសម្រេចលើសំណើជាយថាហេតុរបស់លោក ខៀវ សំផន សុំដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ C26/5/5 កថាខណ្ឌ ១២-១៤។

[1639] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ២១។

[1640] ដូចខាងលើ កថាខណ្ឌ ៧៩-៨៣។

[1641] វិធានផ្ទៃក្នុង វិធាន៧៧ *ស្ទួន*។

ត្រូវតែ “ជឿជាក់ថា អង្គហេតុដែលបានអះអាងដើម្បីគាំទ្រដល់ពាក្យសុំនោះ មានភាពពិតប្រាកដ”[1642]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាថា អង្គហេតុដែលបានដកចេញពីកិច្ចស៊ើបសួរ ផ្អែកលើមូលដ្ឋានរបស់វិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង អាចនៅតែបង្កើតបានជាផ្នែកមួយនៃសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង[1643]។

## ៥.៥.៣.៣. បណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង

ក្នុងកាលៈទេសៈពិសេស អង្គបុរេជំនុំជម្រះពង្រីកវិសាលភាពបណ្តឹងឧទ្ធរណ៍ ដែលមានរៀបរាប់នៅក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង[1644] នៅពេលដែលអង្គហេតុ និងកាលៈទេសៈជាក់លាក់នៃរឿងក្តី លើកឡើងបញ្ហានានាអំពីសិទ្ធិជាមូលដ្ឋាន ឬបញ្ហាធ្ងន់ធ្ងរនៃភាពត្រឹមត្រូវយុត្តិធម៌[1645]។ ក្នុងការសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអនុវត្តតេស្តពីរប្រភេទ ដែលតាមរយៈតេស្តទាំងពីរនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតែបង្ហាញថា៖ (១) ស្ថានភាពដែលជាបញ្ហាចោទនេះ មិនស្ថិតក្នុងវិធានជាធរមាន និង(២) កាលៈទេសៈជាក់លាក់នៃរឿងក្តីតម្រូវឱ្យមានកិច្ចអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះ ដើម្បីជៀសវាងកុំឱ្យមាន “ព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះភាពយុត្តិធម៌នៃការស៊ើបអង្កេត ឬកិច្ចដំណើរការនីតិវិធី” ឬចំពោះ “សិទ្ធិជាមូលដ្ឋាន”[1646]។

ទោះជាយ៉ាងណា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានផ្តល់វិធីសាស្ត្រជាស្វ័យប្រវត្តិសម្រាប់បណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងអំពីការរំលោភលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌នោះទេ[1647]។ ឧទាហរណ៍ អង្គបុរេជំនុំជម្រះនឹងមិនអនុវត្តយុត្តាធិការរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍តាមវិធាន ២១ នៃវិធានផ្ទៃក្នុង ក្នុងការដោះស្រាយសំណើទូទៅស្នើសុំឱ្យមានការបំភ្លឺអំពីច្បាប់ សំណើដែលចោទប្រកាន់អំពីសេណា

---

[1642] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ ៣៩។ សម្រាប់ព័ត៌មានបន្ថែមអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សូមមើល ផ្នែក ៧.១។

[1643] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 យោបល់របស់ចៅក្រម Olivier Beauvallet និង Baik Kang Jin កថាខណ្ឌ ៨៧។

[1644] សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៨-៤៩។

[1645] សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៣។ *ធៀបទៅនឹង* សំណុំរឿង ០០២/០១ សាលដីការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើរស្តីពីការរក្សាការសម្ងាត់ សមភាព និង ភាពយុត្តិធម៌ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ ឯកសារ A410/2/6 កថាខណ្ឌ ១០។

[1646] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៧។

[1647] សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧។ សំណុំរឿង ០០២ សាលដីការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើរស្តីពីការរក្សាការសម្ងាត់ សមភាព និង ភាពយុត្តិធម៌ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ ឯកសារ A410/2/6 កថាខណ្ឌ ១០។

វីយ៉ូបែបសម្ងាត់កម្ម ឬសំណើដែលមិនលើកឡើងនូវព្យសនកម្មពិតប្រាកដដែលភាគីនឹងទទួលរង បើសិនជាសេណារីយ៉ូបែបសម្ងាត់កម្មនោះកើតឡើង[1648]។

អង្គបុរេជំនុំជម្រះបានពង្រីកវិសាលភាពមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ ដែលមានចែងក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានពិចារណាថា ទោះបីជាវិធានផ្ទៃក្នុងមិនបានអនុញ្ញាតដោយផ្ទាល់ សម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏បណ្ដឹងឧទ្ធរណ៍បែបនេះអាចត្រូវបានអនុញ្ញាតតាមករណីជាក់ស្ដែងនីមួយៗ ក្នុងករណីដែលបណ្ដឹងទាំងនោះ "លើកឡើងអំពីបញ្ហាដែលមិនអាចឱ្យអង្គជំនុំជម្រះសាលាដំបូងកែតម្រូវបាន" ដោយសារក្នុងកាលៈទេសៈបែបនោះ "មិនអនុញ្ញាតឱ្យមានលទ្ធភាពប្ដឹងឧទ្ធរណ៍ [...] និងបង្កការខូចខាតដែលមិនអាចជួសជុលបានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌"[1649]។ ក្នុងស្ថានភាពផ្សេងទៀត អង្គបុរេជំនុំជម្រះបានអនុវត្តយុត្តាធិការរបស់ខ្លួន វិនិច្ឆ័យបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង រួមមានលើបញ្ហាចោទដូចជា៖

i. ថាតើផលវិបាកត្រួតគ្នានៃភាពមិនប្រក្រតី និងការរំលោភបំពានក្នុងការស៊ើបអង្កេត អាចនាំឱ្យគេយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនយុត្តិធម៌ មិនអព្យាក្រឹត្យ និងលម្អៀងដែរ ឬយ៉ាងណា[1650]

ii. ថាតើការចោទប្រកាន់ពីអំពើពុករលួយស្ថាប័នដ៏រីករាលដាល និងភស្តុតាងដែលទទួលបានដោយមិនប្រក្រតី បានគំរាមកំហែងដល់សិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានតុលាការមួយដែលឯករាជ្យ និង អព្យាក្រឹត្យដែរ ឬយ៉ាងណា[1651]

iii. ថាតើការបោះពុម្ពផ្សាយអាសយដ្ឋានផ្ទះរបស់ជនត្រូវចោទនៅលើឯកសារ និង គេហទំព័ររបស់ អ.វ.ត.ក. ក្នុងអំឡុងពេលដំណាក់កាលកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះ បានប៉ះពាល់ដល់សិទ្ធិឯកជនភាពរបស់ពួកគេដែរ ឬយ៉ាងណា[1652]

iv. ថាតើកង្វះខាតភាពជាក់លាក់ និងវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាននាំឱ្យមានព្យសនកម្មមិនអាចជួសជុលបានទៅលើផលប្រយោជន៍របស់ជនត្រូវចោទដែរ ឬយ៉ាងណា[1653] និង

---

[1648] សូមមើល សំណុំរឿង ០០៣ សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១៤។ សំណុំរឿង ០០៤ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៨។

[1649] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) កថាខណ្ឌ ៤៨។

[1650] សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ២៩-៣៩។

[1651] សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/1/15 កថាខណ្ឌ ៣០-៥១។

[1652] សូមមើល សំណុំរឿង ០០៤ សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្ដោះអាសន្ន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 កថាខណ្ឌ ១០-១៣។

[1653] សូមមើល សំណុំរឿង ០០៣ សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១៥។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៤។

v. ថាតើការបដិសេធចោលបណ្ដឹងឧទ្ធរណ៍ ដើម្បីរក្សាធនធានតុលាការ និងដើម្បីពន្លឿនដំណើរការច្បាប់ និងនីតិវិធី សំខាន់ជាងផលប្រយោជន៍ត្រឹមត្រូវរបស់ជនត្រូវចោទដែរ ឬយ៉ាងណា[1654]។

### ៥.៥.៣.៤. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងឧទ្ធរណ៍

***បទដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់សេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ៖*** ក្នុងការពិនិត្យឡើងវិញលើសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត - ដូចជាសេចក្ដីសម្រេចទាក់ទងនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ តាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង[1655] សំណើសុំតែងតាំងអ្នកជំនាញ តាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង[1656] ឬការសម្រេចរបស់ខ្លួនថាតើបុគ្គលណាមួយ ស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដើម្បីគោលដំណងនៃយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក.[1657] - តួនាទីរបស់អង្គបុរេជំនុំជម្រះគឺ "កំហិតត្រឹមតែ ថាតើ សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវដែរ ឬយ៉ាងណា"[1658]។

អង្គបុរេជំនុំជម្រះអាចច្រានចោលសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ នៅពេលណាដែលសេចក្ដីសម្រេចទាំងនោះ៖ (១) ផ្អែកលើការបកស្រាយច្បាប់ជាធរមានមិនបានត្រឹមត្រូវ ដូច្នេះធ្វើឱ្យសេចក្ដីសម្រេចនោះទៅជាមោឃៈ (២) ផ្អែកលើសេចក្ដីសន្និដ្ឋានមិនត្រឹមត្រូវទៅលើអង្គហេតុ ដែលបណ្ដាលឱ្យមានភាពអយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដោយសារតែមានការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ហាញឱ្យមានការសន្និដ្ឋានថា ពួកគេខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយមានការពិចារណាល្អិតល្អន់[1659]។ កំហុស ឬការរំលោភបំពានត្រូវតែ "ជាកត្តាកំណត់សំខាន់ក្នុងការ

---

1654 សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៥។

1655 សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៤។ សំណុំរឿង ០០២ សាលដីកាស្ដីពីការពិចារណាឡើងវិញ ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៣៦។

1656 សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់ខ្លួនសុំការតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមដើម្បីពិនិត្យឡើងវិញ នូវខ្លឹមសារនៃរបាយការណ៍អ្នកជំនាញដាក់ជូនដោយលោកស្រី EWA TABEAU និងលោក ធី ឃាម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D140/9/5 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D356/2/9 កថាខណ្ឌ ១៧។

1657 សូមមើល *ឧទាហរណ៍* សំណុំរឿង ០០៤/០១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២០។ សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៨។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៤។ សំណុំរឿង ០០៤ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤។

1658 សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់ខ្លួនសុំការតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមដើម្បីពិនិត្យឡើងវិញ នូវខ្លឹមសារនៃរបាយការណ៍អ្នកជំនាញដាក់ជូនដោយលោកស្រី EWA TABEAU និងលោក ធី ឃាម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D140/9/5 កថាខណ្ឌ ១៦។

1659 សំណុំរឿង ០០២ សាលដីកាស្ដីពីការពិចារណាឡើងវិញ ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់ខ្លួនសុំការតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមដើម្បីពិនិត្យឡើងវិញ នូវខ្លឹមសារនៃរបាយការណ៍អ្នកជំនាញដាក់ជូនដោយលោកស្រី EWA TABEAU និងលោក ធី ឃាម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D140/9/5 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធលើសំណើសុំ

អនុវត្តឆន្ទានុសិទ្ធិ [របស់សហចៅក្រមស៊ើបអង្កេត] ដែលបណ្តាលឱ្យមានការសម្រេចដែលរងការជំទាស់”[1660]។

នៅពេលដែលអង្គបុរេជំនុំជម្រះបដិសេធសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ ជាធម្មតាអង្គបុរេបង្វែរសេចក្តីសម្រេចនោះត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការពិចារណាឡើងវិញ[1661] ដោយពិចារណាថាវាគឺជារឿង “មិនសមស្របសម្រាប់អង្គបុរេជំនុំជម្រះ ធ្វើការជំនួសសហចៅក្រមស៊ើបអង្កេត”ដែរ ឬទេ[1662]។ មានតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ ដែលអង្គបុរេជំនុំជម្រះជំនួសសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជា ឧទាហរណ៍ នៅពេលដែលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតខកខានមិនបានអនុវត្តតាមសេចក្តីណែនាំពីមុនរបស់អង្គបុរេជំនុំជម្រះ ស្តីពីបញ្ហាដែលកំពុងកើតមាន[1663] ឬស្ថិតក្រោមទ្រឹស្តីការបដិសេធតាមការសន្មត នៅពេលដែលភាពអសកម្ម ឬការពន្យារពេលរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញកិច្ច បានបណ្តាលឱ្យមានព្យសនកម្មទៅលើភាគីស្នើសុំ[1664]។

***បទដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់សេចក្តីសម្រេចមិនតាមឆន្ទានុសិទ្ធិ៖*** ចំពោះដីកា ឬសេចក្តីសម្រេចមិនតាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដូចជា ដីកា ឬសេចក្តីសម្រេចដែលដោះស្រាយបញ្ហាផ្នែកយុត្តាធិការ[1665] “អង្គបុរេជំនុំជម្រះមិន [បាន] អនុវត្តបទដ្ឋាននៃការពិនិត្យឡើងវិញផ្សេងពីគ្នា ដែលអាចអនុវត្តចំពោះសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ”[1666]នោះទេ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះវាយតម្លៃថាតើ សហចៅក្រមស៊ើបអង្កេត “បានប្រព្រឹត្តនូវការភាន់ច្រឡំអង្គច្បាប់ ឬអង្គហេតុជាក់លាក់ ដែលធ្វើមោឃភាពសេចក្តីសម្រេច ឬបានថ្លឹងថ្លែងការពិចារណានានាដែលពាក់ព័ន្ធ ឬការពិចារណានានាដែលមិនពាក់ព័ន្ធនៅក្នុងលក្ខណៈមិនសមស្រប” ដែរ ឬយ៉ាងណា[1667]។ ការភាន់ច្រឡំផ្នែកអង្គច្បាប់ដែលត្រូវបានលើកឡើង

---

យោបល់ពីអ្នកជំនាញជាលើកទីពីរ ចុះថ្ងៃទី១ ខែកក្កដា ២០១០ ឯកសារ D356/2/9 កថាខណ្ឌ ១៧។ សំណុំរឿង ០០៤/០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D350/1/1/4 កថាខណ្ឌ ១៤។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ២៩។ សំណុំរឿង ០០៤០១/ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២១។

[1660] សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។

[1661] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២២។

[1662] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៥។

[1663] សំណុំរឿង ០០២ សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៦-៦៧។

[1664] សូមមើលឧទាហរណ៍ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២២-២៤ និង កថាខណ្ឌ៤១-៤៦ (ទទួលស្គាល់ការបិដសេធតាមការសន្មតនៃសំណើសុំតែងតាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដើម្បីវាយតម្លៃសម្បទារបស់ អៀង សារី ក្នុងការចូលរួមក្នុងការការពារក្តីរបស់គាត់ និងក្នុងការវាយតម្លៃថាតើ អ្នកជំនាញគប្បីត្រូវបានតែងតែងឬ ទេ)។ ចំពោះការអនុវត្តការបដិសេធតាមការសន្មត សូមមើល សំណុំរឿង ០០៣ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ចំពោះញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D120/1/1/2 កថាខណ្ឌ ៨។

[1665] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៣៦។

[1666] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) កថាខណ្ឌ ៨៦។

[1667] ដូចខាងលើ។

ត្រូវបានពិនិត្យឡើងវិញ *ជាថ្មី* ដើម្បីសម្រេចថាតើការលើកឡើងតាមផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរ ឬទេ ចំណែកឯការភាន់ច្រឡំផ្នែកអង្គហេតុដែលបានលើកឡើង ត្រូវបានពិនិត្យមើលក្រោមបទដ្ឋាននៃភាពសមស្រប ដើម្បីសម្រេចថាតើពិតជាមាន ឬគ្មាន អ្នកកាត់សេចក្តីដែលសមហេតុផល បានឈានដល់ការយល់ឃើញលើអង្គហេតុដែលកំពុងមានបញ្ហានេះដែរ ឬយ៉ាងណា[1668]។

***បទដ្ឋាននៃការពិនិត្យឡើងវិញចំពោះដីកាសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ៖*** អង្គបុរេជំនុំជម្រះបានពិនិត្យឡើងវិញនូវដីកាសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន តាមរយៈការធ្វើការវិភាគរបស់ខ្លួនផ្ទាល់ ការអនុវត្តលក្ខណៈវិនិច្ឆ័យចែងក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង ការពិចារណាលើទាំងវិធានផ្ទៃក្នុង និងទាំងនីតិវិធីជាធរមាននៅក្រោមច្បាប់ជាតិកម្ពុជា[1669]។ ជាពិសេស អង្គបុរេជំនុំជម្រះបានពិនិត្យដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយវាយតម្លៃលើកត្តានានាដូចជា៖ (១) នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត មុនពេលចេញដីកាឃុំខ្លួន (២) ភាពគ្រប់គ្រាន់នៃអង្គហេតុសម្រាប់ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន (៣) ថាតើកាលៈទេសៈដែលដីកាឃុំខ្លួនបណ្តោះអាសន្នផ្អែកលើ នៅតែមានអត្ថិភាពនៅពេលពិនិត្យឡើងវិញនោះដែរ ឬយ៉ាងណា (៤) ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង និង(៥) ការឃុំខ្លួននៅក្នុងមន្ទីរពេទ្យ ដែលជាជម្រើសមួយបែបផ្សេងទៀតនៃការឃុំខ្លួន[1670]។ នៅពេលដែលទឡ្ហីករណ៍ដែលជាមូលដ្ឋាននៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន លែងត្រូវបានបំពេញទៀតហើយនោះ អង្គបុរេជំនុំជម្រះពិនិត្យឡើងវិញលើសំណើរបស់ជនត្រូវចោទ ស្នើសុំឱ្យដោះលែងក្រោមការពិនិត្យតាមផ្លូវតុលាការ *ជាថ្មី*[1671]។

### ៥.៥.៤. យុត្តាធិការឥស្សរចិត្តរបស់អង្គបុរេជំនុំជម្រះ

អង្គបុរេជំនុំជម្រះបានសម្រេចថា "ក្នុងករណីដែលបញ្ញត្តិលក្ខន្តិកៈពុំចែងអំពីសិទ្ធិអំណាចដើម្បីសម្រេចលើបញ្ហាណាមួយនោះ ខ្លួនមានយុត្តាធិការឥស្សរចិត្ត "ដើម្បីសម្រេចអំពីបញ្ហាបន្ទាប់បន្សំ ដែលកើតឡើងដោយសារតែផលវិបាកផ្ទាល់នៃនីតិវិធីដែលត្រូវបានប្តឹងមកខ្លួន""[1672]។ ដើម្បីឱ្យអង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការឥស្សរចិត្តរបស់ខ្លួន មុនយុត្តាធិការបណ្តឹងឧទ្ធរណ៍ចម្បងរបស់ខ្លួនបាន មានលក្ខខណ្ឌពីរត្រូវបំពេញ៖ (១) ត្រូវតែមានសិទ្ធិប្តឹងឧទ្ធរណ៍តាមលក្ខន្តិកៈ ហើយ (២) ប្រសិទ្ធភាពនៃសិទ្ធិនេះអាចគ្មានប្រសិទ្ធភាព ដោយសារការរំលោភសិទ្ធិជាសារវន្តជាក់លាក់[1673]។

---

[1668] ដូចខាងលើ កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៣៥។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ ២៩។

[1669] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៨។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C20/I/27 កថាខណ្ឌ ១៨។

[1670] សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C20/I/27 កថាខណ្ឌ ១៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៩។

[1671] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យាពេលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26 កថាខណ្ឌ ៨៩។

[1672] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១១។

[1673] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាព ដីកាដំណោះស្រាយ ឬផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១២។

អង្គបុរេជំនុំជម្រះបានអនុវត្តយុត្តាធិការឥស្សរចិត្តរបស់ខ្លួន តាមករណីជាក់ស្តែងនីមួយៗក្នុងឱកាសជាច្រើន។ ឧទាហរណ៍ ក្នុងសំណុំរឿង ០០៣ អង្គបុរេជំនុំជម្រះបានសម្រេចលុបចោលដីការបស់សហចៅក្រមស៊ើបអង្កេតដែលបានផ្អាកការប្រាស្រ័យទំនាក់ទំនងគ្នារវាងជនត្រូវចោទ និងសហមេធាវីរបស់ខ្លួន ដោយពិចារណាឃើញថា "វាមានសារៈសំខាន់ជាសារវន្តដើម្បីអាចឱ្យ ម៉ាស មុត មានលទ្ធភាពប្រាស្រ័យទំនាក់ទំនង [ជាមួយពួកគេ] ក្នុងការទទួលបានព័ត៌មាន និងការផ្តល់យោបល់ជាចាំបាច់ដើម្បីសម្រេចថាតើ [ត្រូវបន្តប្តឹងឧទ្ធរណ៍] ដែរ ឬយ៉ាងណា"[1674]។ ក្នុងសំណុំរឿង ០០៤/០១ អង្គបុរេជំនុំជម្រះបានអនុវត្តយុត្តាធិការឥស្សរចិត្តរបស់ខ្លួន ក្នុងការអញ្ជើញអ្នកដាក់ពាក្យសុំ ដែលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានបដិសេធ ដើម្បីបង្ហាញទស្សនៈរបស់ខ្លួន ក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់រួមគ្នា ក្នុងសំណុំរឿងនោះ[1675]។ អង្គបុរេជំនុំជម្រះបានពិចារណាថា ទោះបីជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លែងជាភាគីនៃកិច្ចដំណើរការនីតិវិធីដែលជាលទ្ធផលនៃដីកាសម្រេចលើកលែងចោទប្រកាន់រួមគ្នា ហើយដូច្នេះពុំមានសិទ្ធិចូលរួមការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍យ៉ាងណាក្តី ក៏សារៈសំខាន់នៃបញ្ហានេះបានលើកឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ និងនៅលើកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ ក៏ដូចជាដើម្បីផលប្រយោជន៍យុត្តិធម៌ វាចាំបាច់ក្នុងការផ្តល់ឱកាសឱ្យពួកគេចូលរួមការជំនុំជម្រះលើបញ្ហាមានកម្រិតមួយចំនួនអំពីគោលជំហររបស់ អ.វ.ត.ក. នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា[1676]។

### ៥.៥.៥. តួនាទីរបស់អង្គបុរេជំនុំជម្រះក្នុងនាមជាសភាស៊ើបសួរ

ទោះបីជាកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុង មិនបានចែងច្បាស់លាស់អំពីសភាស៊ើបសួរ ក៏អង្គបុរេជំនុំជម្រះបានសម្រេចថា ខ្លួនបានបំពេញតួនាទីជាសភាស៊ើបសួរកម្ពុជា[1677] ដែលមានអំណាចទូលំទូលាយនៅពេលបានទទួលបណ្តឹងឧទ្ធរណ៍[1678]។

ក្នុងសំណុំរឿង ០០១ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ សភាស៊ើបសួរអាច៖

> "(ក) ពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី ហើយធ្វើមោឃភាពផ្នែកណាមួយនៃនីតិវិធីទាំងមូល [...]
>
> (ខ) បង្គាប់ឱ្យធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម [...]
>
> (គ) [...] បង្គាប់ឱ្យពន្លាតការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ដល់បទល្មើសដែលទាក់ទងគ្នានឹងបទល្មើស ដែលចង្អុលដោយចៅក្រមស៊ើបសួរ [...]"[1679]។

ក្នុងសំណុំរឿង ០០៤/០២ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា តួនាទីនៃសភាស៊ើបសួរកម្ពុជារួមមាន "ទាំងយុត្តាធិការឧទ្ធរណ៍លើកិច្ចរបស់ចៅក្រមស៊ើបសួរ និងសេចក្តីសម្រេច ព្រមទាំងយុត្តាធិការស៊ើបសួរទី

[1674] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើសុំឲ្យមានវិធានការបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ D56/19/8 កថាខណ្ឌ ១៥។

[1675] សំណុំរឿង ០០៤/០១ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឲ្យដាក់សារណា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ ឯកសារ D308/3/1/8 កថាខណ្ឌ ១៣។

[1676] សំណុំរឿង ០០៤/០១ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឲ្យដាក់សារណា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ ឯកសារ២០១៧ ឯកសារ D308/3/1/8 កថាខណ្ឌ ១១-១៣។

[1677] សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះ អាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៧។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៤។

[1678] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥១។

[1679] ដូចខាងលើ។

ពីរផង”[1680] និងថាខ្លួនអនុវត្ត “អំណាចចុងក្រោយនៅដំណាក់កាលស៊ើបសួរ”[1681]។ អង្គបុរេជំនុំជម្រះបាន យល់ឃើញជាឯកច្ឆន្ទថា អំណាចក្នុងការពិនិត្យឡើងវិញរបស់ខ្លួនក្នុងនាមជាសភាស៊ើបសួរទីពីរ ផ្តល់លទ្ធភាពឱ្យខ្លួនក្នុងការ “ដោះស្រាយទាំងអស់ទៅលើកិច្ចទាំងឡាយទាក់ទិននឹងរឿងក្តីដែលអយ្យការ ឬចៅក្រមស៊ើបសួរមាន ឬគួរមាន ដើម្បីឱ្យការណែនាំនោះមានលក្ខណៈពេញលេញ និងស្របច្បាប់”[1682]។ ចំណុចនេះរួមមានអំណាចក្នុងការ៖

i. “បោសសម្អាតភាពមិនប្រក្រតីនៅក្នុងនីតិវិធីដែលខ្លួនបានទទួលវិនិច្ឆ័យ មុនពេលបញ្ជូនទៅជំនុំជម្រះ”។
ii. ពិនិត្យទាំងមូល និងកែសម្រួលរឿងក្តី រួមទាំងការកែតម្រូវកំហុស ក្នុងការកំណត់ប្រភេទនៃបទល្មើសរបស់ចៅក្រមស៊ើបអង្កេត និងកត់សម្គាល់គ្រប់កាលៈទេសៈច្បាប់ទាំងអស់ដែលពាក់ព័ន្ធនឹងអង្គហេតុ”។ និង
iii. ការពិនិត្យ និងកែតម្រូវការងាររបស់ចៅក្រមស៊ើបអង្កេតនៅក្នុងនីតិវិធីនៃប្រតិបត្តិការចាំបាច់ណាមួយសម្រាប់បម្រើផលប្រយោជន៍នៃការបញ្ជាក់ការពិត”[1683]។

អង្គបុរេជំនុំជម្រះក៏បានបញ្ជាក់ថា សភាស៊ើបសួរ “ត្រូវធ្វើការស៊ើបសួររឿងក្តីដោយខ្លួនឯង” នៅពេលបានទទួលដីកាសម្រេចលើកលែងចោទប្រកាន់ ដែលជាលទ្ធផលនៃបណ្តឹងឧទ្ធរណ៍[1684]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/០២ “ពុំបានជ្រើសរើសវិធីសាស្ត្របែបនោះទេ” បើទោះបីជាបាន “ដឹងអំពីអំណាចរបស់ខ្លួនក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់នៃស្ថានការណ៍ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងចេញដីកាដំណោះស្រាយមានសុពលភាពរបស់ខ្លួនថ្មីមួយបាន”[1685]។

## ៥.៦. ដំណាក់កាលជំនុំជម្រះ

វិធាន ៧៩-១០៣ នៃវិធានផ្ទៃក្នុងបានបញ្ញត្តិនីតិវិធីដែលអាចអនុវត្តបានក្នុងអំឡុងពេលដំណាក់កាលជំនុំជម្រះរបស់ អ.វ.ត.ក.។ វិធានជាច្រើនក្នុងចំណោមវិធានទាំងនេះ ត្រូវបានបកស្រាយនៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ហួសពីពាក្យពេចន៍ដែលកំហិតរបស់វិធានទាំងនោះផ្ទាល់ ខណៈដែលវិធានផ្សេងទៀតទាក់ទាញការធ្វើអធិប្បាយយ៉ាងទូលំទូលាយ។ ផ្នែកនេះលើកឡើងនូវទិដ្ឋភាពមួយចំនួនអំពីនីតិវិធីជំនុំជម្រះពោលគឺ (១) ការទទួលយកសំណុំរឿង (២) ការឃុំខ្លួនបណ្តោះអាសន្ន និង ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (៣) វិធានស្តីពីភស្តុតាង (៤) អញ្ញត្រកម្ម (៥) ការបំបែកកិច្ចដំណើរការនីតិវិធី (៦) កិច្ចស៊ើបសួរបន្ថែម (៧) ការកំណត់បទល្មើសឡើងវិញ និង (៨) បន្ទុក និងបទដ្ឋាននៃភស្តុតាង។

### ៥.៦.១. ការទទួលយកសំណុំរឿង

វិធាន ៧៩(១) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត *ឬ* តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ជាទូទៅ

[1680] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៤។
[1681] ដូចខាងលើ កថាខណ្ឌ ៤៩។
[1682] ដូចខាងលើ កថាខណ្ឌ ៤៧។
[1683] ដូចខាងលើ (គូសបញ្ជាក់បន្ថែម)។ កត់សម្គាល់ថា នៅលើបណ្តឹងឧទរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ លើកលែងសមភាគីជាតិរបស់ខ្លួនចេញ បានពិភាក្សាអំពីមុខងាររបស់អង្គបុរេជំនុំជម្រះក្នុងនាមសភាស៊ើបសួរកម្ពុជា។ សូមមើល សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រម Olivier Beauvallet និង Baik Kang Jin កថាខណ្ឌ ១២៩-៣០។ អង្គបុរេជំនុំជម្រះ មិនបានពិភាក្សាអំពីមុខងាររបស់ខ្លួន ដែលជាសភាស៊ើបសួរកម្ពុជានោះទេ នៅក្នុងសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុង សំណុំរឿង ០០៤។
[1684] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០។ សូមមើល សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២២។
[1685] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០៤/២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៦១។

ចំណុចនេះមានន័យថា ប្រសិនបើបណ្តឹងឧទ្ធរណ៍ណាមួយត្រូវបានដាក់ ប្រឆាំងនឹងដីកាដំណោះស្រាយ នោះអង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹង បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះពិចារណាថា វិធាន៧៩(១) នៃវិធានផ្ទៃក្នុង ណែនាំថា អង្គបុរេមានអំណាចចេញដីកាដំណោះស្រាយថ្មី ឬដីកាដំណោះស្រាយដែលកែតម្រូវ ដែលអាចប្រើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះ[1686]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា អង្គជំនុំជម្រះយល់ថា "ការចូលមើលសំណុំរឿងនេះ មិនមែនជាការទទួលសំណុំរឿងជាលក្ខណៈផ្លូវការនោះទេ រហូតដល់ពេលមានការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយនេះសិន"[1687]។ ដើម្បីចាប់ផ្តើមការងាររៀបចំ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំ និងបានទទួលការអនុញ្ញាតពីអង្គបុរេជំនុំជម្រះឱ្យចូលមើលសំណុំរឿង ពេលកំពុងរង់ចាំសេចក្តីសម្រេចណាមួយលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ ដោយពិចារណាលើលក្ខណៈនៃបញ្ហាស្ថិតក្រោមបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា ការអនុញ្ញាតឱ្យចូលមើលសំណុំរឿងតាមការស្នើសុំនោះ អាចឱ្យអង្គជំនុំជម្រះសាលាដំបូងចាប់ផ្តើមការងាររៀបចំរបស់ខ្លួន និង "ជួយក្នុងការធានាដល់ការជំនុំជម្រះឱ្យដំណើរការទៅប្រកបដោយយុត្តិធម៌ និង ឆាប់រហ័ស"[1688]។

ការអនុវត្តនេះបានបន្តធ្វើក្នុងសំណុំរឿង ០០២។ បន្ទាប់ពីកិច្ចស៊ើបសួររយៈពេលបីឆ្នាំ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះជនជាប់ចោទចំនួនបួនរូប ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះតម្កល់ដីកាដំណោះស្រាយ ដោយធ្វើការកែប្រែមួយចំនួន ហើយបានបញ្ជូនជនជាប់ចោទជាផ្លូវការទៅជំនុំជម្រះ[1689]។ ក្រោយពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងចាត់ទុកខ្លួនឯងថាបានទទួលសំណុំរឿង ០០២ ជាផ្លូវការ[1690]។

កាលៈទេសៈពិសេសនៃសំណុំរឿង ០០៣ និង ០០៤ ដែលកំណត់លក្ខណៈដោយការខ្វែងយោបល់គ្នារវាងភាគីជាតិ និងភាគីអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ តម្រូវឱ្យមានការអនុវត្តខុសៗគ្នា។ អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ មិនអាចធានាបាននូវសំឡេងភាគច្រើនលើសលប់ដែលតម្រូវ សម្រាប់ចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបាន បើទោះជាខ្លួនបានសម្រេចថាការចេញដីកាដំណោះស្រាយផ្ទុយគ្នាក្នុងពេលដំណាលគ្នារបស់សហចៅក្រមស៊ើបអង្កេតខុសច្បាប់យ៉ាងណាក៏ដោយ យោងតាមក្របខ័ណ្ឌរបស់ អ.វ.ត.ក.[1691]។ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង ០០៤/០២ ព្យាយាមឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយករឿងក្តីនេះ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា ខ្លួនមិនដែលទទួលបានការជូនដំណឹងជាផ្លូវការអំពីរឿងក្តីនេះទេ ហើយក៏មិនដែលបានទទួលសំណុំរឿងនេះដែរ[1692]។ អង្គជំនុំជម្រះតុលាការ

---

[1686] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤០។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២២។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦។

[1687] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំការអនុញ្ញាតពិនិត្យសំណុំរឿង ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨២០១៧ ឯកសារ D99/3/5 កថាខណ្ឌ ៧។

[1688] ដូចខាងលើ កថាខណ្ឌ ១ និង៨។

[1689] សូមមើល សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣។

[1690] សូមមើល សំណុំរឿង ០០២/០១ ដីកាកំណត់កាលបរិច្ឆេទសវនាការដែលត្រូវធ្វើឡើងអនុលោមតាមវិធាន ៦៨(៣) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ ឯកសារ E79។

[1691] សម្រាប់ព័ត៌មានបន្ថែមអំពីដីកាដំណោះស្រាយផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងការបញ្ចប់សំណុំរឿងទាំងនេះដោយអង្គជំនុំជម្រះតុលាការកំពូល សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.៣។

[1692] សូមមើល សំណុំរឿង ០០៤/០២ សេចក្តីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ឯកសារ E004/2/1.1.16។

កំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូង "ពុំមានតួនាទីក្នុងការអនុញ្ញាត និង/ឬ ជូនដំណឹងអំពីការដាក់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិក" ដោយសារតែសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះបានធ្វើឱ្យដីកាដំណោះស្រាយទៅជាមោឃៈ និងគ្មានសុពលភាព[1693]។ "ក្នុងករណីពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាន" អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា សំណុំរឿង០០៤/០២ ត្រូវបានបញ្ចប់[1694]។ ក្រោយមកទៀត អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចស្រដៀងគ្នាក្នុងសំណុំរឿង ០០៣ និង ០០៤[1695]។

### ៥.៦.២. ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

វិធាន ៨២(១) នៃវិធានផ្ទៃក្នុងចែងថា លើកលែងតែការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបង្គាប់រួចហើយយោងតាមវិធានផ្ទៃក្នុង ជនជាប់ចោទត្រូវបន្តមានសេរីភាពខណៈពេលកំពុងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលជនជាប់ចោទស្ថិតក្នុងការឃុំខ្លួន នៅពេលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពួកគេបន្តស្ថិតក្នុងការឃុំខ្លួនរហូតអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចថ្មីលើការឃុំខ្លួនបណ្តោះអាសន្ន ឬ សាលក្រមរបស់ខ្លួន[1696]។ ពាក្យ "ការបង្ហាញខ្លួនលើកដំបូង" ក្នុងវិធាន ៨២(១) នៃវិធានផ្ទៃក្នុងមានន័យខុសគ្នាពីការបង្ហាញខ្លួនលើកដំបូង ដែលកំណត់ការចាប់ផ្តើមការជំនុំជម្រះ អនុលោមតាមវិធាន ៨០*ស្ទួន*(១) នៃវិធានផ្ទៃក្នុង និងរួមបញ្ចូល "ការបង្ហាញខ្លួនណាមួយរបស់ជនជាប់ចោទ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទោះបីជាតាមសំណើសុំរបស់ខ្លួន ឬ តាមការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង និងពាក់ព័ន្ធទៅនឹងបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង ក៏ដោយ"[1697]។

ជនជាប់ចោទ ឬមេធាវីរបស់ខ្លួនអាចស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងពួកគេ ដោយផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការ ឬតាមរយៈពាក្យសុំជាលាយលក្ខណ៍អក្សរ ដាក់ទៅក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង។ បន្ទាប់ពីស្តាប់សហព្រះរាជអាជ្ញា ជនជាប់ចោទ និងសហមេធាវីការពារក្តីរបស់ពួកគេរួចហើយ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចលើសំណើនោះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយក្នុងករណីណាក៏ដោយ មិនត្រូវលើសពី ៣០ ថ្ងៃ ក្រោយពេលទទួលបានសំណើសុំផ្ទាល់មាត់ ឬ ពាក្យសុំជាលាយលក្ខណ៍អក្សរនោះ[1698]។ នៅពេលបានទទួលពាក្យសុំឱ្យដោះលែង អង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យមើលថាតើ លក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងផ្នែកអង្គហេតុទាំងអស់ត្រូវបានបំពេញដែរ ឬទេ នៅដំណាក់កាលបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធីនោះ[1699]។

ក្នុងពេលណាមួយក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទ ឬ នៅពេលចាំបាច់ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬឃុំខ្លួន

---

[1693] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៥៣-៥៤។

[1694] ដូចខាងលើ កថាខណ្ឌ ៧១។

[1695] សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1។

[1696] វិធានផ្ទៃក្នុង វិធាន ៨២(១)-(២)។ សូមមើលផងដែរ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E39/5 កថាខណ្ឌ ២៣។

[1697] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៤៤។

[1698] វិធានផ្ទៃក្នុង វិធាន ៨២(៣)។

[1699] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E39/5 កថាខណ្ឌ ២៤។

ជនជាប់ចោទ[1700]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា វិធាន ៨២(១) នៃវិធានផ្ទៃក្នុង បានបង្កើតសច្ចធារណ៍មិនអាចបដិសេធបាន "ដែលថា លក្ខខណ្ឌសម្រាប់ការឃុំខ្លួនដែលបង្គាប់ពីមុនមកដោយសហចៅក្រមស៊ើបអង្កេត [ឬអង្គបុរេជំនុំជម្រះ] ត្រូវបន្តអនុវត្តនៅពេលដែលសំណុំរឿងបញ្ជូនទៅជំនុំជម្រះ"។ ជនជាប់ចោទមានបន្ទុកក្នុងការតវ៉ាប្រឆាំងទៅនឹងមូលដ្ឋាននៃការឃុំខ្លួន តាមការស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូង[1701]។

ប្រសិនបើសំណើសុំដោះលែងណាមួយត្រូវបានបដិសេធ ជនជាប់ចោទអាចដាក់ពាក្យស្នើសុំបន្ថែមទៀត ក្នុងករណីដែលកាលៈទេសៈរបស់ខ្លួនមានការប្រែប្រួល ចាប់តាំងពីពាក្យស្នើសុំចុងក្រោយត្រូវបានបដិសេធ[1702]។ ទាំងជនជាប់ចោទ និងទាំងសហព្រះរាជអាជ្ញា អាចប្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចលើការឃុំខ្លួនបណ្តោះអាសន្នរបស់អង្គជំនុំជម្រះសាលាដំបូង[1703]។

ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ព្រមតាមសំណើសុំឱ្យដោះលែង ជនជាប់ចោទត្រូវទទួលបានការដោះលែង "លើកលែងតែប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្សេងពីនេះ តាមសំណើរបស់សហព្រះរាជអាជ្ញា"។ សហព្រះរាជអាជ្ញាត្រូវស្នើសុំឱ្យផ្អាកដីកាសម្រេចឱ្យដោះលែងបែបនេះ នៅក្នុងរយៈពេល ២៤ ម៉ោង គិតចាប់ពីពេលជូនដំណឹងដីកានោះ ដោយភ្ជាប់ជាមួយនូវឯកសារថតចម្លង នៃពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដោះលែង។ ប្រធានអង្គជំនុំជម្រះតុលាការកំពូល ត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ៤៨ ម៉ោង លើសំណើសុំផ្អាកដីកាដោះលែងនោះ ដែលក្នុងអំឡុងពេលនោះអានុភាពនៃដីកានេះត្រូវផ្អាកការអនុវត្តសិន។ ប្រសិនបើប្រធានអង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំផ្អាកការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឬខកខានក្នុងការសម្រេចលើសំណើសុំនេះក្នុងរយៈពេលដែលបានកំណត់ នោះជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពភ្លាម។ ប្រសិនបើប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចឱ្យផ្អាកការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនដដែល រហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលសម្រេចសេចក្តីលើពាក្យបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានេះ។ លើកលែងតែ នៅក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើពាក្យបណ្តឹងសាទុក្ខបែបនេះ ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណុំរឿង[1704]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ ឌុច សុំឱ្យដោះលែងដោយផ្អែកលើការឃុំខ្លួនបន្តរបស់គាត់ ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដោយអាជ្ញាធរកម្ពុជា។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការឃុំខ្លួនពីមុនរបស់ជនជាប់ចោទបង្កើតបានជាការរំលោភច្បាប់ជាតិជាធរមាននាពេលនោះ និងបានរំលោភលើសិទ្ធិដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប និងការឃុំខ្លួនស្របតាមច្បាប់យ៉ាងណាក្តី[1705] ក៏អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ភាពខុសច្បាប់នេះ ឌុច មានសិទ្ធិទទួលបានដំណោះស្រាយ *នៅដំណាក់កាលក្រោយ*[1706]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលបញ្ហាថាតើ ការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ស្ថិតក្រោមសិទ្ធិអំណាចរបស់ អ.វ.ត.ក. បានបន្តមានយុត្តិកម្មតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មូលហេតុចំនួនបី នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅបន្តមានសុពលភាព ពោលគឺ ទាក់ទងទៅនឹងការចៀសវាងកុំឱ្យមានការគេចវេះ ភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការការពារសុវត្ថិភាពដល់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញថា

---

[1700] វិធានផ្ទៃក្នុង វិធាន ៨២(២)។
[1701] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៤៧-៤៨។
[1702] វិធានផ្ទៃក្នុង វិធាន ៨២(៤)។
[1703] វិធានផ្ទៃក្នុង វិធាន ៨២(៥)។
[1704] វិធានផ្ទៃក្នុង វិធាន ៨២(៦)។
[1705] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទអោយនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E39/5 កថាខណ្ឌ ១៨-២១។
[1706] ដូចខាងលើ កថាខណ្ឌ ២៧-៣៧។

ការឃុំខ្លួនបណ្ដោះអាសន្នគឺត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ជាពិសេស តម្រូវការក្នុងការធានាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ[1707]។

ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថាតើ កង្វះសំអាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បានធ្វើឱ្យសេចក្ដីសម្រេចទាំងនោះអសុពលភាព និងតម្រូវឱ្យមានការដោះលែងជនជាប់ចោទបួនរូបភ្លាមៗដែរ ឬយ៉ាងណា[1708]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការយឺតយ៉ាវរបស់អង្គបុរេជំនុំជម្រះក្នុងការផ្ដល់សំអាងហេតុ គឺជាវិការៈផ្នែកនីតិវិធី ដែលប៉ះពាល់ដល់សិទ្ធិជំនុំជម្រះត្រឹមត្រូវជាសារវន្តរបស់ជនជាប់ចោទយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពិចារណាថា វិការៈនេះត្រូវបានដោះស្រាយដោយការចេញសំអាងហេតុពេញលេញពេលក្រោយមកទៀត។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា ការឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្នត្រូវបានពិនិត្យឡើងវិញជាប្រចាំ និងជាញឹកញាប់ ដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ដោយធានាបានថាពួកគេបានដឹងពីមូលដ្ឋានគាំទ្រការបន្តការឃុំខ្លួនជនជាប់ចោទទាំងនោះ[1709]។ អង្គជំនុំជម្រះសាលាដំបូងបានបន្តពិនិត្យមើលមូលដ្ឋានគតិយុត្តិ សម្រាប់ការឃុំខ្លួនជនជាប់ចោទតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការឃុំខ្លួនគឺជាមធ្យោបាយតែមួយគត់ដើម្បីការពារប្រឆាំងនឹងការគេចវេះ ហើយបានបង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទទាំងបួនរូប។ ដោយកត់សម្គាល់ថា ការមិនមានការជូនដំណឹងជាមុនដើម្បីត្រៀមរៀបចំឱ្យបានគ្រប់គ្រាន់នូវសេចក្ដីសន្និដ្ឋានរបស់ពួកគេ តាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មេធាវីការពារក្ដីមិនតម្រូវឱ្យបង្ហាញនូវការប្រែប្រួលស្ថានភាព ផ្អែកតាមវិធាន ៨២(៤) នៃវិធានផ្ទៃក្នុងនោះទេ ប្រសិនបើពួកគេមានសំណើសុំថ្មីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1710]។

នៅក្នុងការសម្រេចលើបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ជំទាស់នឹងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា បើទោះជាវិធាន ៨២(១) នៃវិធានផ្ទៃក្នុងបានបង្កើតសច្ចធារណ៍មិនអាចបដិសេធបាន ដែលថាលក្ខខណ្ឌសម្រាប់ការឃុំខ្លួនបន្តអនុវត្ត នៅពេលដែលរឿងក្ដីត្រូវបានបញ្ជូនទៅជំនុំជម្រះយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការពិនិត្យឡើងវិញ "ប្រកបដោយអត្ថន័យ"[1711]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់ការគាំទ្រគ្រប់គ្រាន់លើសេចក្ដីសម្រេចបន្តការឃុំខ្លួន ដែលផ្អែកទាំងស្រុងតែទៅលើវិធាន៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង ពោលគឺ ហានិភ័យនៃការគេចវេះ ដោយផ្អែកលើការដាក់ទោសធ្ងន់ជាសក្ដានុពល ដោយមិនបានថ្លឹងថ្លែងឱ្យបានត្រឹមត្រូវលើកត្តាផ្សេងទៀត[1712]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខ្លួនមិនស្ថិតក្នុងតួនាទីពិចារណាថាតើ លក្ខខណ្ឌណាផ្សេងទៀតក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា តួនាទីរបស់ខ្លួនក្នុងនាមជាតុលាការចុងក្រោយលើបណ្ដឹងសាទុក្ខ គឺត្រូវពិនិត្យឡើងវិញលើសេចក្ដីសម្រេចដែលរងការជំទាស់ ផ្អែកលើមូលដ្ឋាននៃបណ្ដឹងសាទុក្ខដែលបានបង្ហាញ។ អង្គជំនុំជម្រះយល់ឃើញថា តុលាការជាន់ខ្ពស់អាចដាក់សំអាងហេតុរបស់ខ្លួនជំនួសសំអាងហេតុដែលខុសឆ្គងនៃសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូងបាន លុះត្រាតែបញ្ហានោះត្រូវបានប្ដឹងសាទុក្ខ និងគាំទ្រដោយសំអាងហេតុដែលមាន។ ដោយសារតែសហព្រះរាជអាជ្ញា មិនបានប្ដឹងសាទុក្ខសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដូច្នេះការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលកំហិតត្រឹមតែមូលដ្ឋានជាក់លាក់នៃការឃុំខ្លួន ទាក់ទងនឹងការធានាវត្តមានរបស់ជនជាប់ចោទ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ។ ហេតុដូច្នេះ បន្ទាប់ពីបានរកឃើញកំហុសអង្គច្បាប់ អង្គជំនុំ

[1707] ដូចខាងលើ កថាខណ្ឌ ២២-២៦។

[1708] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E50 កថាខណ្ឌ ៩។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យមានការដោះលែង ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ ឯកសារ E79/2។

[1709] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E50 កថាខណ្ឌ ២៩-៣៤។

[1710] ដូចខាងលើ កថាខណ្ឌ ៣៨-៤២។

[1711] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៤៩។

[1712] ដូចខាងលើ កថាខណ្ឌ ៤០-៤១។

ជម្រះតុលាការកំពូលបញ្ជូនសេចក្តីសម្រេចនេះត្រឡប់ទៅអង្គជំនុំជម្រះសាលាដំបូងវិញ ដើម្បីធ្វើការកំណត់សាជាថ្មី[1713]។

### ៥.៦.៣. វិធាននៃភស្តុតាង

វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងចែងថា លើកលែងតែមានការចែងផ្សេងពីនេះ ភស្តុតាងទាំងអស់អាចទទួលយកបាននៅចំពោះមុខ អ.វ.ត.ក.។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាំងអស់ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាង ដែលបានដាក់នៅចំពោះមុខខ្លួន និងជាកម្មវត្ថុនៃការដេញដោល[1714]។ ដើម្បីត្រូវបានពិចារណាថា "ដាក់នៅចំពោះមុខ" អង្គជំនុំជម្រះ ខ្លឹមសារនៃភស្តុតាងទាំងអស់ត្រូវតែបានសង្ខេប ត្រូវតែបានអាន ឬ ត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្រប[1715]។ ប្រសិនបើមិនមានការជំទាស់ទៅនឹងឯកសារណាមួយ ឬ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធការជំទាស់ទៅនឹងឯកសារណាមួយនោះ អង្គជំនុំជម្រះទទួលយក និងពិចារណាឯកសារដែលត្រូវបានសង្ខេបខ្លឹមសារត្រឹមត្រូវ ឬបានកំណត់អត្តសញ្ញាណត្រឹមត្រូវ (រួមមាននៅក្នុងសំណើសុំឱ្យទទួលយក) និងម្យ៉ាងវិញទៀត ដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣)-(៤) នៃវិធានផ្ទៃក្នុង។ ឯកសារនីមួយៗដែលបានទទួលយក នៅចំពោះមុខអង្គជំនុំជម្រះត្រូវផ្តល់លេខសម្គាល់ "E3"[1716]។

អង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិបដិសេធសំណើសុំឱ្យពិនិត្យភស្តុតាងណា ដែល "ពុំជាប់ពាក់ព័ន្ធ ឬជាន់គ្នា ឬ ពុំអាចរកបានក្នុងរយៈពេលសមស្របណាមួយ ពុំសមស្របក្នុងការបញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ដែលច្បាប់មិនអនុញ្ញាត ឬដែលមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី"[1717]។ អង្គជំនុំជម្រះក៏មានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការសម្រេចថាតើសាក្សីរូបណាត្រូវស្តាប់សក្ខីកម្មផងដែរ[1718]។

ភាគីអាចស្នើសុំឱ្យទទួលយកភស្តុតាង នៅដំណាក់កាលណាមួយនៃការជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងក៏អាចកោះហៅ ឬស្តាប់សក្ខីកម្មបុគ្គលណាមួយក្នុងនាមជាសាក្សី ឬទទួលយកភស្តុតាងថ្មីណាមួយ ដែលខ្លួនយល់ឃើញថាជួយដល់ការបង្ហាញការពិត[1719]។ ដើម្បីអាចត្រូវបានទទួលយក ភស្តុតាងចាំបាច់ត្រូវពាក់ព័ន្ធ និងអាចជឿទុកចិត្ត*ជាបឋម*។ ភាគីត្រូវតែមានឱកាសក្នុងការជំទាស់ទៅលើភាពអាចទទួលយកបាននៃភស្តុតាងនៅក្នុងអំឡុងពេលនៃការពិភាក្សាដេញដោល ទោះបីជាភាគីមិនបានប្រើប្រាស់ឱកាសនេះក្តី[1720]។

ភស្តុតាងណាដែលមិនអាចរកបាន នៅពេលបើកការជំនុំជម្រះ ត្រូវចាត់ទុកថាជា "ភស្តុតាងថ្មី"។ យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ភាគីដាក់បណ្តឹងត្រូវបង្ហាញថា ភស្តុតាងថ្មីនោះមិនអាចរកបាននៅមុនពេលបើកការជំនុំជម្រះ និង/ឬ មិនអាចរកបានពីមុន ទោះបីជាបានខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្តី។ ប្រសិនបើសំណើសុំឱ្យទទួលយកភស្តុតាងពុំបានធ្វើទាន់ពេលវេលានោះទេ អង្គជំនុំជម្រះនៅតែអាចទទួលយកភស្តុតាងដែលបានស្នើសុំនោះ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌[1721]។

---

[1713] ដូចខាងលើ កថាខណ្ឌ ៤២-៥០,៥២ និង ៥៤។

[1714] វិធានផ្ទៃក្នុង វិធាន ៨៧(២)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៣៩។

[1715] វិធានផ្ទៃក្នុង វិធាន ៨៧(៣)។

[1716] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤ (យោង វិធានផ្ទៃក្នុង វិធាន ៨៧(៣)-(៤))។ សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤០។

[1717] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤២ សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤១។

[1718] សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៤។ សូមមើលជាទូទៅ សំណុំរឿង ០០២/០១ សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E312។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចស្តីពីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ E459។

[1719] វិធានផ្ទៃក្នុង វិធាន ៨៧(៤)។

[1720] សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៦។

[1721] សូមមើល សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៥។

អង្គជំនុំជម្រះសាលាដំបូងផ្អែកការសម្រេចរបស់ខ្លួនលើភ័ស្តុតាង ដែលបានដាក់នៅចំពោះមុខខ្លួន និងដែលស្ថិតក្រោមការពិភាក្សាដេញដោលតទល់។ អង្គជំនុំជម្រះបានពិចារណាលើការជំទាស់ទៅនឹងតម្លៃជាភ័ស្តុតាង ជាពិសេស ភ័ស្តុតាងទាំងឡាយដែលបានបំពេញនូវ*ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភ័ស្តុតាងដែលបានស្នើសុំ។ កត្តាទាំងឡាយដែលពាក់ព័ន្ធទៅនឹងតម្លៃជាភ័ស្តុតាងរួមមាន ៖ (១) លក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង (២) កាលៈទេសៈជុំវិញការបង្កើត ឬ ការកត់ត្រាភ័ស្តុតាង (៣) ថាតើឯកសារដែលត្រូវបានទទួលយកនោះជាឯកសារដើម ឬជាឯកសារថតចម្លង (៤) លទ្ធភាពនៃការអានបាន (៥) ភាពមិនស៊ីចង្វាក់ខ្លះៗទៅនឹងឯកសារដទៃទៀត (៦) កង្វះចន្លោះដែលអាចចោទប្រកាន់បាន (៧) ថាតើភាគីមានឱកាសសួរដេញដោលភ័ស្តុតាង និង (៨) សញ្ញាណផ្សេងៗទៀតនៃភាពគួរឱ្យទុកចិត្តបាន រួមទាំងដំណើរការនៃការរក្សាភ័ស្តុតាង និងប្រភពភ័ស្តុតាង[1722]។ កថាខណ្ឌខាងក្រោមរៀបរាប់អំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល និងការវាយតម្លៃពីប្រភេទផ្សេងៗនៃភ័ស្តុតាង។

***ភ័ស្តុតាងឯកសារ៖*** តាមវិធានទូទៅ ភ័ស្តុតាងឯកសារតម្រូវឱ្យមានជាបីភាសាផ្លូវការរបស់ អ.វ.ត.ក. (ភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស) ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ[1723]។ ករណីលើកលែងគឺអនុវត្តចំពោះតែភ័ស្តុតាងណា ដែលបានបង្ហាញជាក់ច្បាស់ថា ឯកសារទាំងនោះពុំតម្រូវឱ្យមានការបកប្រែ។ ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះនៅតែពិចារណាលើភ័ស្តុតាងដែលមិនមានការបកប្រែ នៅក្នុងសាលក្រមរបស់ខ្លួន ប៉ុន្តែតែក្នុងករណីដែលភ័ស្តុតាងទាំងនោះមានលក្ខណៈស៊ីចង្វាក់គ្នាជាមួយនឹងប្រភពផ្សេៗទៀតដែលអាចជឿទុកចិត្តបានតែប៉ុណ្ណោះ។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាថាតើ ជនជាប់ចោទបានបង្ហាញពីការយល់ដឹងលើភ័ស្តុតាងទាំងនេះដែរ ឬអត់ ឬមួយថា តើជនជាប់ចោទបានពឹងផ្អែកលើភ័ស្តុតាងបែបនោះនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែរ ឬទេ[1724]។ ភ័ស្តុតាងឯកសារក៏ចាំបាច់ត្រូវតែមានភាពត្រឹមត្រូវ មានន័យថា វាគឺជា “ឯកសារដើម ឬជាប្រភពដើម”[1725]។

***បញ្ជីឯកសារ៖*** ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យភាគីដាក់បញ្ជីឯកសារដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ[1726]។ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការអនុវត្តនេះ ដោយលើកឡើងថា វិធាន ៨០(៣) នៃវិធានផ្ទៃក្នុងគឺជា “ឧបករណ៍សម្រាប់គ្រប់គ្រង” ដែលដាក់វិន័យលើភាគីក្នុងកម្រិតណាមួយ ដែលមានភាពចាំបាច់ដោយសារតែទំហំសំណុំរឿងធំនៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក.[1727]។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង បានណែនាំភាគីឱ្យផ្តល់បញ្ជីបច្ចុប្បន្នភាពនៃបញ្ជីឯកសារដែលបានដាក់ពីមុន និងបញ្ជីវត្ថុតាងសម្រាប់សំណុំរឿង ០០២/០២ រួមទាំងការរៀបរាប់អំពីលក្ខណៈ និងខ្លឹមសាររបស់ឯកសារទាំងនោះ ព្រមទាំងចំណុចពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយផងដែរ។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យភាគីមានឱកាសដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរ ចំពោះឯកសារនៅក្នុងបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ភាគី និងជំទាស់ទៅនឹងការសន្មតពីភាពពាក់ព័ន្ធនិងភាពអាចជឿជាក់បាននៃឯកសារទាំងឡាយ ដែលបានលើកយោងនៅក្នុងដីកាដំណោះស្រាយ។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរទាំងអស់នេះ គឺជាមូលដ្ឋានសម្រាប់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភាពអាចទទួលយកបាននៃឯកសារភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ ជំនួសឱ្យការរៀបចំសវនាការស្តីពីការទទួលយកឯកសារ ដែលបានធ្វើក្នុងសំណុំរឿង ០០២/០១ កន្លងមក[1728]។

***សវនាការលើឯកសារគន្លឹះ៖*** អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ បានផ្តល់ឱកាសឱ្យភាគីបង្ហាញឯកសារគន្លឹះ ដែលពួកគេយល់ថាជាប់ពាក់ព័ន្ធជាពិសេសទៅនឹងប្រធានបទ

---

[1722] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦១។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣៤។ សូមមើលផងដែរ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២។
[1723] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៧។
[1724] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣៦។
[1725] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៤៣០។
[1726] សំណុំរឿង ០០២/០១ ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ឯកសារ E9។
[1727] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១៧៤-១៧៥។
[1728] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៥៥។ *ធៀបទៅនឹង* សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៦៦។

សវនាការនីមួយៗ។ សវនាការទាំងអស់នេះបានពិចារណាឃើញថា ភស្តុតាងឯកសារមិនចាំបាច់ត្រូវបង្ហាញក្នុងអំឡុងពេលសួរដេញដោលសាក្សីនោះទេ និងក្នុងគោលបំណងធ្វើឱ្យសាធារណៈជនអាចពិនិត្យមើលឯកសារភស្តុតាងនៃការជំនុំជម្រះកាន់តែទូលំទូលាយ[1729]។

***ភស្តុតាងរបស់ជនជាប់ចោទ***៖ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងជាច្រើនដងថា សេចក្តីថ្លែងរបស់ជនជាប់ចោទគឺជាភស្តុតាង[1730]។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសួរសំណួរជនជាប់ចោទ ទាក់ទងនឹងអង្គហេតុគោលចំនួនប្រាំពីរ ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី[1731]។ ក្នុងសំណុំរឿង០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា បន្ទាប់ពីសេចក្តីថ្លែងបើក សវនាការលើអង្គសេចក្តីបានចាប់ផ្តើមជាមួយនឹងសេចក្តីថ្លែងដោយជនជាប់ចោទ និងការសួរសំណួរជនជាប់ចោទ តាមលំដាប់ដែលបានកំណត់ឈ្មោះនៅក្នុងដីកាដំណោះស្រាយ។ អនុលោមតាមវិធាន ២១(១)(ឃ) និង ៩០(១) នៃវិធានផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះជូនដំណឹងជនជាប់ចោទម្នាក់ៗ មុនពេលសេចក្តីថ្លែងបើករបស់ពួកគេ អំពីសិទ្ធិជាសារវន្តរបស់ពួកគេក្នុងការនៅស្ងៀមមិនឆ្លើយតប។ ក្រៅពីចម្លើយដែលបានព្យាករនៅក្នុងវិធានផ្ទៃក្នុង នៅពេលដែលជនជាប់ចោទមានបំណងឆ្លើយតប អង្គជំនុំជម្រះសួរគ្រប់សំណួរទាំងអស់ដែលខ្លួនយល់ថាពាក់ព័ន្ធ ទោះបីជាសំណួរទាំងអស់នេះបង្ហាញភស្តុតាង ឬមិនបង្ហាញភស្តុតាងពាក់ព័ន្ធពិរុទ្ធភាពរបស់ជនជាប់ចោទក៏ដោយ។ ភាគីក៏ត្រូវបានផ្តល់ឱកាសឱ្យសួរសំណួរជនជាប់ចោទផងដែរ[1732]។

***ភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី***៖ សាក្សីត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង និង បន្ទាប់ពីសំណើ ត្រូវបានជួយដោយមេធាវី។ ដោយសារតែឋានៈពិសេសរបស់ពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីមិនតម្រូវឱ្យធ្វើសម្បថទេ។ អង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីតាមករណីជាក់ស្តែងនីមួយៗ ផ្អែកលើភាពអាចជឿជាក់បាននៃសក្ខីកម្ម និងស្របជាមួយនឹងកត្តានានា ដូចជា អត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីចង្វាក់គ្នា និងភាពពុំស៊ីចង្វាក់គ្នាទាក់ទងនឹងអង្គហេតុសំខាន់ៗ ការជំរុញពីខាងក្រៅដែលអាចមាន ការអះអាងបញ្ជាក់ និងកាលៈទេសៈទាំងអស់នៃរឿងក្តី[1733]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ភាពអាចជឿជាក់បាននៃភស្តុតាងរបស់សាក្សី អាស្រ័យលើ "សមត្ថភាពរបស់គាត់ក្នុងការយល់ការចងចាំ និងការបង្ហាញយ៉ាងត្រឹមត្រូវ" របស់គាត់ ដែលអាចត្រូវបានប៉ះពាល់ដោយកត្តាមួយចំនួន ដូចជា (១) សុខភាព អាយុ និងស្ថានភាពផ្លូវចិត្តរបស់សាក្សី នៅពេលហេតុការណ៍នោះបានកើតឡើង និងពេលវេលានៃការផ្តល់សក្ខីកម្ម និង (២) ភាពលម្អៀងដែលអាចកើតចេញពីបញ្ហានានា ដូចជា ចេតនាគេចចេញពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង ឬ ភាពអាម៉ាស់ជាសាធារណៈ និងគោលបំណងការពារបុគ្គលផ្សេងទៀត[1734]។

***ភស្តុតាងរបស់អ្នកជំនាញ***៖ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភស្តុតាងអ្នកជំនាញ ដែល "ផ្តោតលើចំណេះដឹងផ្នែកជំនាញ ដែលវាជាជំនាញ ឬចំណេះដឹងដែលទទួលបានតាមរយៈការបណ្តុះបណ្តាល ឬតាមរយៈការស្រាវជ្រាវ ដែលមតិយោបល់របស់អ្នកជំនាញនេះជួយដល់អង្គជំនុំជម្រះឱ្យបានយល់ដឹងអំពីភស្តុតាងនានាដែលបានបង្ហាញ"[1735]។ អង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យយ៉ាងប្រុងប្រយ័ត្ននូវធនធាននានាដែលត្រូវបានប្រើប្រាស់ដោយអ្នកជំនាញ ក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ពួកគេ។ នៅពេលដែលអង្គជំនុំជម្រះផ្អែកការសន្និដ្ឋានរបស់ខ្លួនលើការងាររបស់អ្នកជំនាញ អង្គជំនុំជម្រះត្រូវបញ្ជាក់ប្រភពពិតប្រាកដ និងដែលអាចផ្ទៀងផ្ទាត់បាន ដែលគាំទ្រមតិយោបល់របស់អ្នកជំនាញនោះ។ ប្រសិនបើប្រភពទាំងនោះមិនអាចពិនិត្យមើលបានពេញលេញ និងផ្ទៀងផ្ទាត់បានទេនោះ ភស្តុតាងរបស់អ្នកជំនាញត្រូវផ្តល់ទម្ងន់តិច[1736]។

---

[1729] សូមមើល សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៥៨។
[1730] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥០។
[1731] សូមមើល សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១។
[1732] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២៧។ សូមមើល សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥១។
[1733] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៩-៥០។
[1734] ដូចខាងលើ កថាខណ្ឌ ៦២។
[1735] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៥។ សូមមើល សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៥០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣០។
[1736] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៦។

***កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ៖*** អង្គជំនុំជម្រះសាលាដំបូងបានទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកមកពីកិច្ចដំណើរការនីតិវិធីមុនៗ រួមទាំង ឬជំនួសឱ្យភស្តុតាងផ្ទាល់មាត់[1737]។ ភស្តុតាងជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលមិនបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអ្នកដែលមិនត្រូវបានដេញដោល "ត្រូវតែផ្តល់តម្លៃជាភស្តុតាងទាបជាងភស្តុតាងនៃសក្ខីកម្មដែលសាក្សីបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ"[1738]។ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ដើម្បីជាប្រយោជន៍នៃភាពឆាប់រហ័ស ប្រធានអង្គជំនុំជម្រះបានបង្គាប់ឱ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញខ្លួននៅក្នុងតុលាការ ដើម្បីបញ្ជាក់អះអាងពីភាពត្រឹមត្រូវនៃចម្លើយពីមុនរបស់ពួកគេ ដែលបានផ្តល់ជូន ក.ស.ច.ស. និងដូចដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ។ បន្ទាប់ពីការបញ្ជាក់រួចខណៈដែលកត់សម្គាល់ថា ភាគីមានសិទ្ធិក្នុងការពិនិត្យទៅលើភាពអាចជឿជាក់បានរបស់សាក្សី លើផ្នែកនានានៅក្នុង ឬហួសពីចម្លើយមុនៗ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យភាគីសួរដេញដោលបន្ថែមទៀត ប៉ុន្តែកម្រិតត្រឹមតែចំណុចណាដែលចាំបាច់តម្រូវឱ្យមានការបំភ្លឺ ពាក់ព័ន្ធទៅនឹងបញ្ហាដែលមិនបានគ្របដណ្តប់ពេញលេញនៅក្នុងចម្លើយទាំងនោះ ឬមិនបានដោះស្រាយក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ[1739]។ ក្នុងសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចប្រើនីតិវិធីមួយដែលមានភាពស៊ីចង្វាក់ច្រើនជាមួយនឹងនីតិវិធីកម្ពុជាក៏ដោយ ក៏អង្គជំនុំជម្រះមិនបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដែរ[1740]។

***ចម្លើយជាលាយលក្ខណ៍អក្សរដែលមិនត្រូវបានប្រមូលដោយ អ.វ.ត.ក.៖*** ចម្លើយដែលធ្វើឡើងក្រៅក្របខ័ណ្ឌនៃដំណើរការតុលាការ ដូចជាចម្លើយដែលបានកត់ត្រាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍ ការរៀបរាប់របស់ជនភៀសខ្លួនដែលមិនស្ថិតក្រោមសម្បថ និងអត្ថបទកាសែតគឺ "ពុំសូវមានតម្លៃជាភស្តុតាង"ទេ[1741]។ ជាពិសេស ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ពុំទទួលបានសច្ចធារណ៍នៃភាពអាចជឿទុកចិត្តបាន និងក្នុងករណីដែលកាលៈទេសៈពុំមានភាពច្បាស់លាស់ក្នុងការបំពេញពាក្យសុំទាំងនេះ" ពួកវាទទួលបាន "តម្លៃជាភស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើមាន"[1742]។ នៅពេលដែលការសន្និដ្ឋានណាមួយផ្អែកដោយផ្អែកលើចម្លើយបែបនោះ សំអាងហេតុគាំទ្រការសន្និដ្ឋាននោះត្រូវតែពន្យល់យ៉ាងច្បាស់លាស់ ជាពិសេសប្រសិនបើការផ្តន្ទាទោសណាមួយពឹងផ្អែកលើភស្តុតាងបែបនោះទាំងស្រុង ឬជាសំខាន់។ អង្គជំនុំជម្រះក៏មានឆន្ទានុសិទ្ធិពិចារណា "ថាតើចម្លើយនោះស៊ីចង្វាក់គ្នាជាមួយនឹងភស្តុតាងផ្សេងដែរ ឬទេ និងពិចារណាទៅលើលក្ខណៈនៃភស្តុតាងនោះប្រសិនបើចម្លើយស៊ីចង្វាក់គ្នា" ព្រមទាំងភាពស៊ីចង្វាក់គ្នាផ្នែកខាងក្នុង និងខាងក្រៅជាមួយនឹងភស្តុតាងផ្សេងទៀត[1743]។

***ចម្លើយជាលាយលក្ខណ៍អក្សរទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ៖*** អវត្តមានឱកាសសួរដេញដោល អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចម្លើយទាំងឡាយណាដែលយកមកបញ្ជាក់អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ[1744]។ ទោះជាយ៉ាងណា យោងតាមអង្គជំនុំជម្រះតុលាការកំពូល ការដាក់ពិរុទ្ធភាពមិនអាចពឹងផ្អែកលើ "តែមួយមុខ ឬជាសំខាន់ទៅលើភស្តុតាងរបស់សាក្សីដែលមេធាវី

---

[1737] ដូចខាងលើ កថាខណ្ឌ ៥១។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣១។
[1738] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៤៣៩។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៩៦។
[1739] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៥២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣១។
[1740] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៦៩។
[1741] ដូចខាងលើ កថាខណ្ឌ ៩០។
[1742] ដូចខាងលើ កថាខណ្ឌ ២៩៦ត២៩៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៣។
[1743] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៩។ សហចៅក្រមស៊ើបអង្កេតអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលត្រង់ចំណុចនេះ ចំណែកអង្គបុរេជំនុំជម្រះយល់ឃើញថា មិនមានឋានានុក្រមនៃភស្តុតាងផ្អែកលើប្រភពផ្លូវការនោះទេ ប៉ុន្តែត្រូវផ្អែកលើខ្លឹមសារនៃភស្តុតាងនោះវិញ។ សូមមើលផ្នែក ៧.២.៥។
[1744] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១-៧២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣១។

ការពារក្តីពុំបានឱកាសសួរដេញដោលឡើយ ដរាបណាមានកត្តាថ្លឹងថ្លែងតុល្យភាពជាអត្ថិភាព ដើម្បីឱ្យជនជាប់ចោទមានឱកាសដោយប្រសិទ្ធភាព ក្នុងការជំទាស់ទៅនឹងភស្តុតាងដាក់បន្ទុកលើខ្លួន"[1745]។

***ភស្តុតាងរបស់សាក្សីដែលមិនអាចចូលខ្លួនមកធ្វើសក្ខីកម្ម៖*** អង្គជំនុំជម្រះសាលាដំបូងបានទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹករបស់សាក្សីដែលបានទទួលមរណភាព ឬមិនអាចចូលខ្លួនមកធ្វើសក្ខីកម្ម តែនៅពេលណាដែលខ្លួនជឿជាក់ថា សាក្សីនោះពិតជាមិនអាចរកបានមែន ភស្តុតាងនោះអាចជឿជាក់បាន ហើយភស្តុតាងនោះមានតម្លៃជាភស្តុតាងដែលមានសារៈសំខាន់ចំពោះភាពចាំបាច់ក្នុងការធានាឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌[1746]។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានរំលឹកថា វិធាន និងការអនុវត្តពាក់ព័ន្ធនៅកម្រិតអន្តរជាតិ បានអនុញ្ញាតឱ្យពឹងផ្អែកលើភស្តុតាងរបស់សាក្សីដែល (១) បានទទួលមរណភាពក្រោយពេលដែលពួកគេបានផ្តល់សក្ខីកម្មរួចមក (២) សាក្សីដែលមិនអាចទាក់ទងបាន "មិនអាចផ្តល់សក្ខីកម្មផ្ទាល់មាត់បាន ដោយសារតែសកម្មភាពផ្លូវកាយ ឬផ្លូវចិត្ត"[1747]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា អង្គហេតុដែលថាភស្តុតាងទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទមិនមែនជាឧបសគ្គនោះទេ ប៉ុន្តែវាប៉ះពាល់ដល់ទម្ងន់ដែលផ្តល់ចំពោះភស្តុតាងនោះ[1748]។

***ភស្តុតាងចចាមអារ៉ាម៖*** ភស្តុតាងចចាមអារ៉ាមត្រូវបានពិនិត្យដោយប្រុងប្រយ័ត្ន។ ក្នុងការវាយតម្លៃលើតម្លៃនៃភស្តុតាងចចាមអារ៉ាម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអង្គហេតុដែលថា ប្រភពនៃពាក្យចចាមអារ៉ាមនោះមិនត្រូវបានសួរដេញដោល រួមទាំង "កាលៈទេសៈផ្សេងៗដែលកើតជុំវិញភស្តុតាងចចាមអារ៉ាមនោះ"[1749]។

***ភស្តុតាងប្រយោល៖*** ដើម្បីផ្តន្ទាទោសផ្អែកលើភស្តុតាងប្រយោល ការសន្និដ្ឋានដ៏មានហេតុផលទាំងអស់ដែលទាញចេញពីភស្តុតាង ត្រូវតែស៊ីចង្វាក់គ្នាជាមួយនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។ សេចក្តីសន្និដ្ឋានទូទៅ អាចទាញចេញពីភស្តុតាងជាក់លាក់របស់សាក្សីដែលមានកម្រិត ប៉ុន្តែ "អាចធ្វើបែបនេះបានតែក្នុងករណីដែលការយល់ឃើញទូទៅនោះ ត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យប៉ុណ្ណោះ"។ មុននឹងទាញសេចក្តីសន្និដ្ឋានផ្ទុយណាមួយចេញពីភស្តុតាង អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាទៅលើភាពសមស្របនៃការពន្យល់ផ្សេងៗទៀត ដែលអាចជាប្រយោជន៍ដល់ជនជាប់ចោទ។ ឧទាហរណ៍ សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងក្នុងគោលបំណងឃោសនា អាចមិនសូវមានភាពអាចជឿជាក់បាន។ បន្ថែមលើនេះ អង្គជំនុំជម្រះចាំបាច់ត្រូវបង្ហាញអត្តសញ្ញាណ និងពិចារណាទៅលើភស្តុតាងដោះបន្ទុក រួមទាំងភស្តុតាងដាក់បន្ទុកលើបញ្ហាណាមួយផងដែរ[1750]។

***ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម៖*** ដោយមានការកំហិតមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតតាមសំណើសុំឱ្យទទួលយកឯកសារ ដែលអាចបានមកដោយការប្រើទារុណកម្ម ដូចជា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ និងសៀវភៅកំណត់ហេតុរបស់មន្ទីរឃុំឃាំង។ ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មអាចប្រើសម្រាប់តែជាភស្តុតាងបញ្ជាក់ថា ចម្លើយនោះត្រូវបានធ្វើឡើង តែមិនអាចជាភស្តុតាងបញ្ជាក់ពីការពិតនៃខ្លឹមសាររបស់វាបានឡើយ។ ក្នុងករណីដែលអង្គជំនុំជម្រះសម្រេចថា មានហានិភ័យពិតប្រាកដដែលថាភស្តុតាងនោះបានមកតាមរយៈការធ្វើទារុណកម្ម ភស្តុតាងនោះត្រូវបានដកចេញពីកិច្ចដំណើរការនីតិវិធី លើកលែងតែ (១) ភាគីណាមួយបានជំទាស់ទៅនឹងការសន្និដ្ឋាននេះដោយការសំអាងទៅលើភស្តុតាងផ្សេង ឬ (២) ការប្រើប្រាស់ភស្តុតាងនេះស្ថិតនៅក្នុងករណីលើកលែងដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួនឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ("អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម")។ ករណីលើកលែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម អនុញ្ញាតឱ្យប្រើភស្តុតាងដែល

---

[1745] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៤៣៩។ សូមមើល សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧១។
[1746] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២។ សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣១។
[1747] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២។
[1748] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៨៩ និង ២៩៦-២៩៩។ សូមមើល សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧២។
[1749] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៣។ សូមមើល សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣០២-៣០៤។
[1750] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៤-៦៥។ សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ៣៥។

បានមកដោយការធ្វើទារុណកម្ម តែដើម្បីប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ចំពោះការធ្វើទារុណកម្ម ដែលជាភ័ស្តុតាងបញ្ជាក់ថា ចម្លើយនោះពិតជាត្រូវបានធ្វើឡើងមែនតែប៉ុណ្ណោះ[1751]។

***ភ័ស្តុតាងចេញពីភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម៖*** ការពឹងផ្អែកលើភ័ស្តុតាងចេញពីភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មត្រូវបានអនុញ្ញាត ដរាបណាវាមិនបានបំពានលើការហាមឃាត់មិនឱ្យប្រើខ្លឹមសារនៃចម្លើយសារភាពបែបនោះ ដើម្បីបញ្ជាក់ការពិតរបស់ពួកវា។ ផ្ទុយទៅវិញ ភ័ស្តុតាងដែលបានមកដោយការធ្វើទុក្ខបុកម្នេញ ឬការបង្ខិតបង្ខំ បើទោះបីជាមិនត្រូវបានហាមឃាត់ដោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មក៏ដោយ មិនត្រូវបានពឹងផ្អែកលើនោះទេ អនុលោមតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា “ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបរាងកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភ័ស្តុតាងទេ”[1752]។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ បានលើកឡើង (ដោយមានចៅក្រម Fenz មានមតិជំទាស់) ថា ព័ត៌មានដែលមាននៅក្នុងភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីអង្គហេតុ ជាជាងការប្រើដើម្បីបញ្ជាក់ពីការពិតនៃចម្លើយនោះក្រោមករណីលើកលែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ប៉ុន្តែភ័ស្តុតាងនេះត្រូវបានប្រើតែក្នុងគោលបំណងដើម្បីកំណត់ថា តើមានអំពើអ្វីដែលបានកើតឡើង ដោយផ្អែកលើការពិតដែលចម្លើយនោះត្រូវបានធ្វើឡើង។ ការណ៍នេះអនុញ្ញាតឱ្យអង្គជំនុំជម្រះពិចារណាថា តើការចាប់ខ្លួនបុគ្គលជាក់លាក់មួយចំនួនដែលត្រូវបានធ្វើឡើងក្រោយពីមានចម្លើយសារភាពដែលមានឈ្មោះបុគ្គលទាំងនេះនៅក្នុងនោះ អាចជាការបញ្ជាក់ពីគោលនយោបាយរបស់រដ្ឋាភិបាលដែរឬទេ[1753]។ នៅក្នុងមតិជំទាស់របស់គាត់ ចៅក្រម Fenz ពិចារណាថា ការបកស្រាយទូលំទូលាយរបស់មតិភាគច្រើនអំពីករណីលើកលែងនេះ ប្រឈមនឹងការធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. និង គោលបំណងនៃការរារាំងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[1754]។

### ៥.៦.៤. អញ្ញត្រកម្ម

វិធាន ៨៩ នៃវិធានផ្ទៃក្នុងបានផ្តល់ឱកាសឱ្យភាគី យ៉ាងយូរ៣០ថ្ងៃ ក្រោយដីកាដំណោះស្រាយចូលជាស្ថាពរ ដើម្បីដាក់អញ្ញត្រកម្មណាមួយទាក់ទងនឹង៖ (១) យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង (២) ការរលត់បណ្តឹងអាជ្ញា និង (៣) មោឃភាពនីតិវិធីដែលត្រូវបានធ្វើឡើងបន្ទាប់ពីមានដីកាដំណោះស្រាយ។

អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃថាតើ ការជំទាស់ផ្អែកលើយុត្តាធិការលើរូបបុគ្គលអាចទទួលយកបានដែរ ឬទេ បើទោះជាវាមិនត្រូវបានលើកឡើងនៅដំណាក់កាលសមស្របនៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដូចដែលតម្រូវដោយវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង[1755]។ អង្គជំនុំជម្រះតុលាការកំពូលបានសង្កត់ធ្ងន់ថា គោលបំណងចម្បងរបស់វិធានគឺត្រូវដោះស្រាយបញ្ហាយុត្តាធិការមុនពេលជំនុំជម្រះ ដើម្បីចៀសវាងកិច្ចដំណើរការនីតិវិធីមិនចាំបាច់។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការជំទាស់មួយចំនួនទៅនឹងយុត្តាធិការ អាចអាស្រ័យលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងអាច “ប្រើដើម្បីដោះស្រាយបញ្ហាកង្វះយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ ប៉ុន្តែ មិនអាចប្រើវិធាននេះចំពោះកង្វះយុត្តាធិការដែលមិនស្តែងឱ្យឃើញច្បាស់នោះឡើយ”។ កង្វះយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ គឺសំដៅលើកង្វះយុត្តាធិការដែលបង្ហាញឱ្យឃើញនៅក្នុងកិច្ចដំណើរការនីតិវិធី នៅមុនកាលបរិច្ឆេទកំណត់ដែលមានចែងក្នុងវិធាន ៨៩(១)នៃវិធានផ្ទៃក្នុង។ កង្វះយុត្តាធិការដែលមិនស្តែងឱ្យឃើញច្បាស់ គឺសំដៅលើកង្វះយុត្តាធិការដែលមិនបង្ហាញឱ្យឃើញនៅក្នុងកិច្ចដំណើរការនីតិវិធី ហេតុដូច្នេះហើយបានជា

---

[1751] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៧៤។
[1752] ដូចខាងលើ កថាខណ្ឌ ៧៥។
[1753] ដូចខាងលើ កថាខណ្ឌ ៧៧។
[1754] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម សំអាងហេតុសម្រាប់មតិជំទាស់ដោយផ្នែករបស់ចៅក្រម Fenz ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០១៦ ឯកសារ E350/8.1។
[1755] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៨-៣៨។ ក្នុងអំឡុងពេលអំណះអំណាងបិទបញ្ចប់កិច្ចពិភាក្សាដេញដោល មេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់អំពីកង្វះយុត្តាធិការ ដោយផ្អែកលើមូលដ្ឋានថា ជនជាប់ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់ផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.១.៥.២.៣។

មិនត្រូវបានរកឃើញនៅមុនពេលកំណត់ ដែលមានចែងនៅក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង[1756]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ប្រសិនបើកង្វះយុត្តាធិការដែលបានលើកឡើងនោះ មានអនុភាពធ្វើឱ្យដំណើរការនីតិវិធីក្លាយជាមោឃៈបាន ភាគីអាចលើកវាឡើងនៅពេលណាមួយ រួមទាំងដំណាក់កាលដំបូងលើបណ្តឹងសាទុក្ខ[1757]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បន្ថែមទៀតថា អំណាចមុខងាររបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យមានការជឿជាក់ជានិច្ចកាលថា ខ្លួនពិតជាមានយុត្តាធិការក្នុងការជំនុំជម្រះជនជាប់ចោទ ហើយជនជាប់ចោទមានសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹង (ហើយអំណាចតាមច្បាប់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការកែប្រែ) កំហុសអង្គហេតុ ឬអង្គច្បាប់ដែលចោទប្រកាន់ណាមួយ ដែលអាចមោឃៈសាលក្រម ឬនាំឱ្យមានភាពអយុត្តិធម៌[1758]។

នៅដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានលើអញ្ញត្រកម្មមួយចំនួន ទាក់ទងនឹងយុត្តាធិការ។ អញ្ញត្រកម្មទាំងឡាយណាជាឧបសគ្គដល់ការចាប់ផ្តើមការជំនុំជម្រះ ត្រូវបានសម្រេចក្នុងរយៈពេលប៉ុន្មានខែក្រោយមក អញ្ញត្រកម្មទាំងនោះមានដូចជា ការជំទាស់ពាក់ព័ន្ធទៅនឹងលក្ខណៈនៃវិធានផ្ទៃក្នុង ភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (“JCE”) *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស[1759]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាអញ្ញត្រកម្មផ្សេងទៀតថាមានលក្ខណៈសមស្របជាងសម្រាប់ដំណោះស្រាយ នៅក្នុងសាលក្រម ឬទុកសម្រាប់ការជំនុំជម្រះនាពេលខាងមុខក្នុងសំណុំរឿង ០០២ ក្នុងកម្រិតដែលថាអញ្ញត្រកម្មទាំងនោះពាក់ព័ន្ធទៅនឹងបញ្ហាក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១[1760]។ ដើម្បីជាប្រយោជន៍នៃការរៀបចំការជំនុំជម្រះប្រកបដោយប្រសិទ្ធភាព និងដោយសារអញ្ញត្រកម្មមួយចំនួន ទាក់ទងនឹងកម្មវត្ថុដែលបានជំនុំជម្រះពីមុននៅ ចំពោះមុខអង្គបុរេជំនុំជម្រះរួចហើយនោះ អនុស្សរណៈមួយចំនួនទៅកាន់ភាគីបានផ្តល់នូវគោលការណ៍ណែនាំបន្ថែម ទាក់ទងនឹងការរៀបចំកាលវិភាគ ចំនួនទំព័រកំណត់ ការចៀសវាងភាពច្រំដែល ការបកប្រែភាសា និង បញ្ហាពាក់ព័ន្ធ[1761]។ សម្រាប់ព័ត៌មានបន្ថែមអំពីអញ្ញត្រកម្ម ដែលបានលើកឡើងក្នុងសំណុំរឿង ០០២/០១ សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.២.៥.១។

### ៥.៦.៥. ការបំបែកកិច្ចដំណើរការនីតិវិធី

វិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចែងថា នៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និង ផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំ

---

[1756] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២៨-៣០។

[1757] ដូចខាងលើ កថាខណ្ឌ ៣១។ ឧទាហរណ៍អំពីចំណុចនេះ រួមបញ្ចូលធាតុផ្សំយុត្តាធិការផ្ទាល់មុខ ដូចជា ថាតើជនជាប់ចោទស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. និងការជំទាស់ទៅនឹងយុត្តាធិការលើរឿងក្តី និងយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. ដែរ ឬយ៉ាងណា។

[1758] ដូចខាងលើ កថាខណ្ឌ ៣៥ និង ៣៧។

[1759] សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E116។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E100/6។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និង ការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15។

[1760] សំណុំរឿង ០០២/០១ ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E141។

[1761] សូមមើលឧទាហរណ៍ សំណុំរឿង ០០២/០១ សេចក្តីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ឯកសារ E51/7។ សំណុំរឿង ០០២/០១ ការជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹង នីតិវិធីដែលត្រូវបានធ្វើការកែប្រែសម្រាប់ដាក់អញ្ញត្រកម្ម និង ការបញ្ជាក់អំពីកាលបរិច្ឆេទសម្រាប់ការឆ្លើយតប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ E51។

ជម្រះតុលាការកំពូល បានផ្តល់គោលការណ៍ណែនាំលើការពិចារណាផ្នែកច្បាប់ និងផ្នែកនីតិវិធីមួយចំនួន ដែលចែងថាតើការបំបែកកិច្ចដំណើរការនីតិវិធីត្រឹមត្រូវតាមវិធាន ៨៩*ស្ទួនពីរ*ដែរ ឬយ៉ាងណា។

ទោះបីជាការបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងជនជាប់ចោទ ឬក៏បទចោទក៏ដោយ ក៏លទ្ធផលផ្នែកដំណើរការនីតិវិធីនៅដដែល។ ពាក្យពេចន៍នៃវិធាន ៨៩*ស្ទួនពីរ* ប្រកាសថា "ការបំបែកកិច្ចដំណើរការនីតិវិធី បង្ហាញពីការបំបែក (ឬញែក) កិច្ចដំណើរការនីតិវិធី ដែលជាផលវិបាកនាំឱ្យមានសំណុំរឿងព្រហ្មទណ្ឌពីរ ឬច្រើន ជំនួសឱ្យរឿងក្តីព្រហ្មទណ្ឌតែមួយ"។ ការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀងធីរិទ្ធ ពីសំណុំរឿង ០០២ បណ្តាលឱ្យមានការបំបែកសំណុំរឿងរបស់គាត់ចេញពីសំណុំរឿងប្រឆាំងនឹងសហជនជាប់ចោទដទៃទៀត ដូច្នេះសំណុំរឿងរបស់គាត់ដំណើរការដោយឡែកតែឯង[1762]។

បើទោះបីជាការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានអនុវត្តមុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី ឬក្រោយពេលសវនាការលើអង្គសេចក្តីក៏ដោយ "ជាការសំខាន់ដែលសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅពេលដែលមានអានុភាព ហើយត្រូវកំណត់វិសាលភាពនៃរឿងក្តីដែលត្រូវបានបំបែកនោះ។ បញ្ហាទាំងឡាយទាក់ទងនឹងរយៈពេលនៃកិច្ចដំណើរការនីតិវិធី និងការឃុំខ្លួនមុនការជំនុំជម្រះ ចាំបាច់ត្រូវវាយតម្លៃដាច់ដោយឡែកពីគ្នាសម្រាប់រឿងក្តីថ្មី ដែលបានបង្កើតដោយដីកាបំបែកកិច្ចដំណើរការនីតិវិធី" គ្មានផ្នែកណាមួយនៃបទចោទអាចត្រូវបានទុកចោលដោយមិនមានជំនុំជម្រះនោះទេ[1763]។

សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី រួមមានការថ្លឹងថ្លែងពីផលប្រយោជន៍ស្របច្បាប់ផ្សេងៗ ដោយធ្វើការប្រៀបធៀបគុណសម្បត្តិ និងគុណវិបត្តិនៃការរៀបចំការជំនុំជម្រះរួមតែមួយទៅលើបទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាមួយនឹងគុណសម្បត្តិ និងគុណវិបត្តិនៃការរៀបចំការជំនុំជម្រះជាច្រើនទៅលើបទចោទទាំងអស់ដូចគ្នានោះ[1764]។ មុនពេលបង្គាប់ឱ្យមានការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះជាដំបូងត្រូវអញ្ជើញភាគីឱ្យដាក់សារណាលើលក្ខខណ្ឌនៃដីកានេះ ហើយអាចធ្វើទៅបានតែក្រោយពេលដែលធ្វើការថ្លឹងថ្លែងលើអត្ថប្រយោជន៍របស់ភាគី ជាមួយនឹងកត្តាពាក់ព័ន្ធទាំងអស់[1765]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា យុត្តិសាស្ត្រអន្តរជាតិសម្រាប់ការវិភាគបែបនេះ ពិចារណាលើកត្តានានា ដែលរួមមានការប៉ះពាល់ជាសក្តានុពលដល់សិទ្ធិរបស់ជនជាប់ចោទ ប្រសិទ្ធភាព និងភាពអាចចាត់ចែងបាននៃកិច្ចដំណើរការនីតិវិធី គោលបំណងជៀសវាងភាពពុំស៊ីចង្វាក់គ្នារវាងការជំនុំជម្រះដាច់ដោយឡែកពីគ្នា និងបន្ទុកជាសក្តានុពលទៅលើសាក្សី។ កត្តាដែលពាក់ព័ន្ធផងដែរនោះ គឺផលប៉ះពាល់នៃការបំបែកបទចោទលើលទ្ធភាពរបស់ជនជាប់ចោទ ក្នុងការចូលរួមនៅក្នុងការត្រៀមខ្លួនសម្រាប់ការជំនុំជម្រះទីពីរ ដោយសារវាតម្រូវឱ្យមានការចូលរួមរបស់ជនជាប់ចោទក្នុងពេលដំណាលគ្នានៅក្នុងរឿងក្តីចំនួនពីរ[1766]។

អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា មានការសន្មតលើអង្គហេតុថា ការជំនុំជម្រះដែលត្រូវបានបំបែក ចំណាយពេលយូរក្នុងការវិនិច្ឆ័យ ជាងការជំនុំជម្រះរួមតែមួយ ដែលការណ៍នេះមិនត្រឹមតែកើតចេញពីយុត្តិសាស្ត្រអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងជាបញ្ហាទាក់ទងនឹងសុភនិច្ឆ័យផងដែរ[1767]។ យ៉ាងណាមិញ អង្គជំនុំជម្រះតុលាការកំពូលបានសង្កត់ធ្ងន់ថា ក្តីកង្វល់សំខាន់មិនមែនអំពីថាតើអាចមានការពន្យារ

---

[1762] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3 កថាខណ្ឌ ៤២។

[1763] ដូចខាងលើ កថាខណ្ឌ ៤៤។

[1764] ដូចខាងលើ កថាខណ្ឌ ៤៩។

[1765] ដូចខាងលើ កថាខណ្ឌ ៥០។

[1766] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E284/4/8 កថាខណ្ឌ ៣៨។

[1767] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3 កថាខណ្ឌ ៥១។

ពេល ឬយ៉ាងណានោះទេ ប៉ុន្តែថាតើ ការពន្យារពេលអាចជា *ការមិនត្រឹមត្រូវ* ឬយ៉ាងណា និងថាតើ មានកត្តាផ្សេងទៀតដែលសំខាន់ដូចគ្នាដែរ ឬទេ ប្រសិនបើមិនសំខាន់ជាងកត្តាទាំងនេះនោះ ក្នុងការយកមកថ្លឹងថ្លែង ដែលគាំទ្រដល់ការបំបែកកិច្ចដំណើរការនីតិវិធី[1768]។

ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាថា ការបំបែកកិច្ចដំណើរការនីតិវិធីគឺជា "អត្ថប្រយោជន៍យុត្តិធម៌" អង្គជំនុំជម្រះត្រូវ "ផ្តល់ការពិចារណាសមស្របទៅលើការតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅជាការជំនុំជម្រះតូចជាងនេះ"[1769]។ វិធាន ៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីត្រូវតែផ្តល់យុត្តិកម្មដោយផ្អែកលើ "ផលប្រយោជន៍យុត្តិធម៌" ដូច្នេះមិនមែនជាឆន្ទានុសិទ្ធិសុទ្ធសាធទេ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា វិធានផ្ទៃក្នុងមិនបានផ្តល់ការណែនាំណាមួយ ចំពោះអ្វីទៅជាកាលៈទេសៈដែលបំពេញលក្ខខណ្ឌតម្រូវនោះបាន។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយឃ្លា "ផលប្រយោជន៍យុត្តិធម៌" ត្រូវតែបង្ហាញលក្ខខណ្ឌដែលជនជាប់ចោទ និង/ឬ បទចោទដែលបានជំនុំជម្រះដាច់ដោយឡែកនោះ "បម្រើឱ្យគោលដៅនៃកិច្ចដំណើរការនីតិវិធី និងគោលការណ៍ ដែលជាមូលដ្ឋានសំអាង"។ ដូច្នេះ "ផលប្រយោជន៍យុត្តិធម៌" ក្នុងការបំបែក នឹងបង្កើតឱ្យមានកត្តាផ្សេងៗជាច្រើន ក្នុងការសម្រេចទៅតាមករណីជាក់ស្តែង ក្រោយពីបានធ្វើការពិចារណាថាតើអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេច ក្នុងការបំបែកសំណុំរឿងមួយ។ ទោះជាយ៉ាងណា "ផលប្រយោជន៍យុត្តិធម៌" ចាំបាច់ត្រូវតែបង្ហាញជាមួយសំអាងហេតុគ្រប់គ្រាន់ ដែលលើកឡើងពីកាលៈទេសៈជាប់ពាក់ព័ន្ធ និងច្បាស់លាស់ និងការពន្យល់អំពីអានុភាពរួមរបស់ពួកវាទៅលើសំណុំរឿងដែលបានបំបែកទាំងមូល[1770]។

ការអនុវត្តលក្ខណៈវិនិច្ឆ័យនេះក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងកត្តាមួយចំនួន "ត្រឹមវិសាលភាពមួយមានកំណត់ប៉ុណ្ណោះ" ពោលគឺ៖ (១) អាយុ និងភាពទ្រុឌទ្រោមផ្នែកផ្លូវកាយរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២ ដែលនៅសេសសល់ (២) ផលប្រយោជន៍សាធារណៈ នៅក្នុងការសម្រេចបានសាលក្រមមួយទាក់ទងយ៉ាងហោចណាស់ទៅនឹងផ្នែកនៃដីកាដំណោះស្រាយនៃសំណុំរឿង ០០២ (៣) លទ្ធភាពចាត់ចែង និងគ្រប់គ្រងបាននៃសំណុំរឿង ០០២/០១ នៅដំណាក់កាលចុងក្រោយនេះ រួមទាំងការដែលអាចមានផលប៉ះពាល់ចំពោះជនជាប់ចោទ ប្រសិនបើមានការពង្រីកវិសាលភាពនៃការជំនុំជម្រះបន្ថែមទៀត (៤) ភាពមិនច្បាស់លាស់មួយទៅលើថិរវេលានៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១ ប្រសិនបើមានការដាក់បញ្ចូលមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះ និង (៥) ភាពមិនច្បាស់លាស់ទាក់ទងនឹងថិរវេលានៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ អ.វ.ត.ក.[1771]។ កត្តាដែលមិនត្រូវបានពិភាក្សាទាល់តែសោះនោះគឺ បន្ទុកដែលអាចមានចំពោះសាក្សី និងការចង់បានដើម្បីចៀសវាងភាពមិនស៊ីចង្វាក់គ្នានៃការជំនុំជម្រះដាច់ដោយឡែកពីគ្នា[1772]។ អង្គជំនុំជម្រះតុលាការកំពូលក៏សន្និដ្ឋានផងដែរថា ការពិចារណាលើកត្តា (៥) ខាងលើ ដែលជាភាពមិនច្បាស់លាស់ទាក់ទងនឹងថិរវេលានៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ អ.វ.ត.ក. នោះ ជាកត្តាមិនពាក់ព័ន្ធ និងមិនសមហេតុសមផល ក្នុងការពិចារណានៅក្នុងដំណើរការធ្វើការសម្រេចចិត្តរបស់តុលាការ[1773]។

អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធី បានលើកឡើងជាដដែលៗថា គោលបំណងរបស់ខ្លួនគឺដើម្បីរក្សាលទ្ធភាពរបស់ខ្លួនក្នុងសម្រេចបាននូវ "សាលក្រមឱ្យទាន់ពេលវេលា" ដោយពិចារណាលើវ័យចាស់ជរា និងភាពទ្រុឌទ្រោមផ្នែករូបរាងកាយកាន់តែខ្លាំងរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូលបាន

---

[1768] ដូចខាងលើ កថាខណ្ឌ ៥៣។

[1769] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E163/5/1/13 កថាខណ្ឌ ៥០។

[1770] ដូចខាងលើ កថាខណ្ឌ ៣៥។

[1771] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E284/4/8 កថាខណ្ឌ ៤៥-៦៧។

[1772] ដូចខាងលើ កថាខណ្ឌ ៤៨។

[1773] ដូចខាងលើ កថាខណ្ឌ ៤៩។

ទទួលស្គាល់ថា គោលបំណងនេះត្រូវបានរួមបញ្ចូលតាមរយៈសញ្ញាណនៃ "ផលប្រយោជនយុត្តិធម៌"។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ដោយសារតែបាត់បង់ អៀង ធីរិទ្ធិ ដោយសារបញ្ហាវង្វេងស្មារតី និង អៀង សារី ដោយសារមរណភាព និងដំណាក់កាលដែលអង្គជំនុំជម្រះសាលាដំបូងអាចដំណើរការកិច្ចនីតិវិធី បានជួបប្រទះនឹងការបង្អាក់ការជំនុំជម្រះជាច្រើនលើកច្រើនសា ដោយសារតែបញ្ហាសុខភាព និងភាពចាស់ជរានៃសហជនជាប់ចោទដែលមានជីវិត ដែលការណ៍នេះបានបង្កើតឱ្យមានស្ថានភាពមួយដែល "ពិតជាត្រូវការនូវឆន្ទានុសិទ្ធិយ៉ាងច្រើនណាស់"។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ការបំបែកដីកាចោទប្រកាន់ ដើម្បីធានាថា យ៉ាងហោចណាស់ផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានជំនុំជម្រះនៅក្នុងពេលរស់រានមានជីវិតរបស់សហជនជាប់ចោទនោះ គឺ "មានលក្ខណៈសមហេតុផល"។ សំអាងលើមូលហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសបដិសេធ សំណើរបស់ នួន ជា ដែលថា សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ លើកទីពីរ គប្បីត្រូវបានបដិសេធចោល[1774]។

ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន តាមរយៈការបដិសេធចោលលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះថាមិនអាចយកមកអនុវត្តបាន[1775]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា គោលបំណងនៃការសម្រេចបាននូវ "សាលក្រមឱ្យទាន់ពេលវេលា" ក្នុងពេលរស់រានមានជីវិតរបស់សហជនជាប់ចោទនោះ ពុំធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងរួចផុតពីកាតព្វកិច្ចរបស់ខ្លួនក្នុងការថ្លឹងថ្លែងផលប្រយោជន៍នៃការជំនុំជម្រះត្រឹមត្រូវ និងឆាប់រហ័ស និងតម្រូវការឱ្យមានការជំនុំជម្រះមួយដែលជាតំណាងសមហេតុផលនៃដីកាដំណោះស្រាយទាំងមូល ក្នុងសំណុំរឿង ០០២ នោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល អនុវត្តយុត្តាធិការរបស់ខ្លួនក្នុងការកែតម្រូវ ដើម្បីធានាថា យ៉ាងហោចណាស់បទចោទដែលនៅសេសសល់ក្នុងដីកាដំណោះស្រាយអប្បបរមាដែលមិនអាចកាត់បន្ថយតទៅទៀតបាននោះ ទទួលបានការជំនុំជម្រះ ដោយបានបង្គាប់ឱ្យសវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ ចាប់ផ្តើមឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងសម្រេចថា សំណុំរឿង ០០២/០២ មានបទចោទជាអប្បបរមាទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ការដ្ឋាន សហករណ៍ និងអំពើប្រល័យពូជសាសន៍[1776]
។

ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា តាមរយៈការនៅស្ងៀមស្ងាត់លើជោគវាសនានៃបទចោទដែលនៅសេសសល់ អង្គជំនុំជម្រះសាលាដំបូងមានកំហុសចំពោះការខកខានក្នុងការផ្តល់ជូនផែនការច្បាស់លាស់សម្រាប់រឿងក្តីត្រូវជំនុំជម្រះ ក្រោយសំណុំរឿង ០០២/០២ ដោយរំលឹកអំពីតម្រូវការចាំបាច់ឱ្យមានផែនការច្បាស់លាស់ សម្រាប់ការវិនិច្ឆ័យបទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1777]។ បញ្ហាទាំងអស់នេះទទួលបានការពិចារណាកាន់តែពេញលេញ នៅក្នុងសេចក្តីសម្រេចស្តាពរលើបណ្តឹងសាទុក្ខលើការបំបែកកិច្ចដំណើរការនីតិវិធី ដែលអង្គជំនុំជម្រះតុលាការកំពូលជាចុងក្រោយបានពិចារណាថា ការពន្យារពេលសេចក្តីសម្រេចលើបទចោទដែលនៅសល់ នៅក្រៅសំណុំរឿង ០០២/០២ បានបង្កើតស្ថានភាពមួយដែលផ្នែកនៅសល់នៃដីកាដំណោះស្រាយត្រូវបានផ្អាកដោយប្រសិទ្ធភាព[1778]។ ដោយយល់ឃើញថាមិនមានភាពប្រាកដប្រជាផ្នែកច្បាប់នោះ អង្គជំនុំជម្រះតុលាការកំពូល "ទទូចឱ្យអង្គជំនុំជម្រះសាលាដំបូង បំពេញនូវកាតព្វកិច្ចរបស់ខ្លួន ក្នុងការបញ្ចប់បទចោទទាំងអស់នៅចំពោះមុខ" និងបានប្រកាសព្យួរកិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទចោទដែលនៅសេសសល់ក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ "រង់ចាំការសម្រេចសេចក្តីសមស្របរបស់អង្គជំនុំជម្រះសាលាដំបូង"[1779]។

---

[1774] ដូចខាងលើ កថាខណ្ឌ ៥០-៥៣។
[1775] ដូចខាងលើ កថាខណ្ឌ ៥៤ និង៦៥។
[1776] ដូចខាងលើ កថាខណ្ឌ ៦៩-៧១។
[1777] ដូចខាងលើ កថាខណ្ឌ ៦៩។
[1778] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3 កថាខណ្ឌ ១៩ និង៣០-៣៦។
[1779] ដូចខាងលើ កថាខណ្ឌ ៩០-៩១។

សម្រាប់ព័ត៌មានបន្ថែមទៀតលើសេចក្ដីសម្រេចនីមួយៗរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.២.៥.២។

## ៥.៦.៦. ការស៊ើបអង្កេតបន្ថែមក្នុងអំឡុងពេលជំនុំជម្រះ

វិធាន៩៣ នៃវិធានផ្ទៃក្នុង ផ្ដល់អំណាចឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែម ដែលខ្លួនចាត់ទុកថាចាំបាច់ក្នុងអំឡុងពេលដំណាក់កាលជំនុំជម្រះ។ យោងតាមវិធាន ៩៣(២) នៃវិធានផ្ទៃក្នុង "ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ក៏ស្ថិតនៅក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតដែរ គឺអាចស្ដាប់ចម្លើយសាក្សី ដឹកនាំការឆែកឆេរ ចាប់យកវត្ថុតាង ឬបង្គាប់ឱ្យធ្វើកោសល្យវិច័យ។

ភាគីដែលស្នើសុំការស៊ើបអង្កេតបន្ថែមតាមវិធាន ៩៣ ត្រូវបង្ហាញនូវតម្រូវការចាំបាច់នៃការស៊ើបអង្កេតបន្ថែមទាំងនោះ[1780]។ គ្រាន់តែបង្ហាញពីវិការៈនីតិវិធីតែមួយមុខនៅក្នុងការស៊ើបអង្កេត ពុំគ្រប់គ្រាន់ដើម្បីបង្ហាញពីតម្រូវការចាំបាច់នោះទេ ហើយមិនអាចយកមកសំអាង "ឱ្យរួចផុតពីការសម្រេចចុងក្រោយរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះឡើយ"[1781]។ នោះមានន័យថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចដាច់ដោយឡែក ដែលឯករាជ្យពីសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ក្នុងការសម្រេចលើវាលកាលៈទេសៈដែលពាក់ព័ន្ធសម្រាប់ការជំនុំជម្រះរឿងក្ដី។ ហេតុដូច្នេះ ភាគីត្រូវបានអនុញ្ញាតឱ្យស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ដើម្បីកាត់បន្ថយអានុភាពនៃការយល់ឃើញដែលបានធ្វើឡើងនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ។ ទោះជាយ៉ាងណា នៅក្នុងស្ថានភាពបែបនេះ ការស៊ើបអង្កេតមិនអាចត្រូវបានធ្វើឡើងដើម្បីជំទាស់ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនោះទេ ប៉ុន្តែត្រូវបង្ហាញអង្គហេតុដែលខុសប្លែកពីការយល់ឃើញផ្នែកអង្គហេតុដែលបានធ្វើឡើងនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ[1782]។

អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការទទួលយកភស្តុតាងថ្មី ដែលខ្លួនជឿជាក់ថាមានប្រយោជន៍ក្នុងការបញ្ជាក់ការពិត នៅពេលដែលភស្តុតាងនោះបំពេញផងដែរនូវបទដ្ឋាន*បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[1783]។ ជាធម្មតា ភាគីស្នើសុំក៏ត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលបានស្នើឡើងនោះមិនអាចរកបាននៅមុនបើកការជំនុំជម្រះ ឬមិនអាចរកបានពីមុន ទោះបីជាបានខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្ដី។ ទោះជាយ៉ាងណា អង្គជំនុំជម្រះម្ដងម្កាលបានទទួលយកឯកសារ ដែលមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យនេះ រួមមានក្នុងករណីនានាដែលឯកសារណាមួយ ពាក់ព័ន្ធខ្លាំងទៅនឹងសម្ភារៈដែលមានរួចហើយនៅក្នុងសំណុំរឿង និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើការវាយតម្លៃប្រភពទាំងនោះរួមគ្នា នៅពេលដែលឯកសារដែលស្នើឡើងនោះមានលក្ខណៈដោះបន្ទុក ហើយតម្រូវឱ្យមានការវាយតម្លៃ ដើម្បីចៀសវាងភាពអយុត្តិធម៌ ឬនៅពេលដែលភាគីផ្សេងទៀតមិនជំទាស់ទៅនឹងឯកសារនោះ។

សំណើត្រូវបានសម្រេចតាមអង្គសេចក្ដីដាច់ដោយឡែក និងអង្គហេតុនៃករណីនីមួយៗ។ សំណើទាំងនោះត្រូវបានបដិសេធក្នុងកាលៈទេសៈនានា នៅពេលដែលសំណើនោះត្រូវបានទុកជាមោឃៈ នៅពេលដែលសម្ភារៈដែលត្រូវបានស្នើសុំនោះមានរួចហើយនៅក្នុងសំណុំរឿង ឬនៅពេលដែលសាក្សីដែលស្នើឡើង ឬឯកសារដែលជាបញ្ហាចោទនោះពុំមានតម្លៃជាភស្តុតាង។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូង នៅដំណាក់កាលចុងក្រោយនៃការជំនុំជម្រះ មិនជឿជាក់លើតម្លៃនៃការកោះហៅសាក្សីណាម្នាក់ដែលនិយាយ

---

[1780] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៥១។

[1781] ដូចខាងលើ កថាខណ្ឌ ២៥២។

[1782] ដូចខាងលើ កថាខណ្ឌ ២៥៣។

[1783] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E294/1 កថាខណ្ឌ ១០។ សំណុំរឿង ០០២/០២ សេចក្ដីសម្រេចអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង លើសំណើរបស់នួន ជា សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងលោក Robert Lemkin (2-TCW-877) និងសំណើពាក់ព័ន្ធចំនួនពីរអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ E416/4 កថាខណ្ឌ ១៣។

ភាសាខ្មែរបានតិចតួច ដែលមិនមានវត្តមានក្នុងអំឡុងពេលភាគច្រើននៃបទសម្ភាសន៍ពាក់ព័ន្ធរបស់ជនជាប់ចោទ ហើយដែលពីមុនបានបង្ហាញភាពស្ទាក់ស្ទើរក្នុងការជួយដល់តុលាការនោះទេ[1784]។ យោងតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងត្រូវប្រុងប្រយ័ត្នអំពីភារកិច្ចរបស់ខ្លួន ក្នុងការថ្លឹងថ្លែងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីជាមួយនឹងការជំនុំជម្រះឆាប់រហ័ស ហើយតម្លៃជាសក្ខីកម្មនៃការទទួលយកភស្តុតាងត្រូវតែថ្លឹងថ្លែងជាមួយនឹងកង្វល់អំពីការពន្យារពេលហួសហេតុ[1785]។

នៅពេលសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាផងដែរពីភាពផ្សេងគ្នារវាងកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងដំណាក់កាលជំនុំជម្រះ។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះពិចារណាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរចំនួនមួយ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជនជាប់ចោទមានឱកាសជាច្រើនក្នុងអំឡុងពេលកិច្ចស៊ើបសួរ ដែលមានរយៈពេលស្ទើរតែពីរឆ្នាំកន្លះ ដើម្បីស្នើសុំថាកិច្ចស៊ើបសួរទាំងអស់នេះពាក់ព័ន្ធ និងដើម្បីជំទាស់ទៅនឹងការបដិសេធណាមួយនៃសំណើទាំងអស់នេះ ទៅកាន់អង្គបុរេជំនុំជម្រះ[1786]។

ភាគីត្រូវបានអនុញ្ញាតឱ្យចាត់វិធានការ "ស្វែងរកភស្តុតាងពាក់ព័ន្ធ ដរាបណាការស៊ើបសួរនោះមិននាំឱ្យមានការប៉ះពាល់ដល់សាក្សី ឬការបំភ្លៃភស្តុតាង"។ ទោះជាយ៉ាងណា ពួកគេមិនត្រូវបានអនុញ្ញាតឱ្យទទួលបានសិទ្ធិអំណាចស៊ើបអង្កេតរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា មេធាវីការពារក្តីគួរត្រូវបានអនុញ្ញាតឱ្យបើកកិច្ចស៊ើបសួរក្នុងកម្រិតមួយ ដែលតម្រូវសម្រាប់បំពេញចំណុចទីមួយនៃបទដ្ឋានស្តីពីភាពអាចទទួលយកបានចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ពោលគឺ កិច្ចស៊ើបសួរដែលស្នើសុំ "ត្រូវតែបង្ហាញអំពីភាពជាក់លាក់គ្រប់គ្រាន់" ដូចជាការកំណត់អត្តសញ្ញាណសាក្សី[1787]។

### ៥.៦.៧. ការកំណត់បទចោទឡើងវិញ

វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងចែងថា "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ"។ ទោះជាយ៉ាងណា វិធាននេះអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង "ផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"។

អង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចដោយការកំណត់បទចោទ ដែលបានអនុម័តដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ នៅក្នុងដីកាដំណោះស្រាយនោះទេ។ អង្គជំនុំជម្រះសាលាដំបូងអាចផ្លាស់ប្តូរបទចោទចំពោះអង្គហេតុ ដែលមាននៅក្នុងដីកាដំណោះស្រាយ ឬដីកាដំណោះស្រាយដែលត្រូវបានកែប្រែ នៅពេលណាក៏បាន ដើម្បីឱ្យស្របជាមួយនឹងបទល្មើស ឬ ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលអាចអនុវត្តបានរហូតដល់មានសាលក្រម និងរួមទាំងនៅក្នុងសាលក្រមផងដែរ។ ប្រការនេះ គឺអាស្រ័យទៅលើលក្ខខណ្ឌតម្រូវលើសលប់នៃការជំនុំជម្រះក្តីដោយយុត្តិធម៌៖ (១) អង្គជំនុំជម្រះត្រូវ "ស្ថិតក្នុងព្រំដែនកំណត់នៃអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយ" និង (២) ជនជាប់ចោទត្រូវបាន "ជូនដំណឹងអំពីលទ្ធភាពនៃការកំណត់បទចោទឡើងវិញនោះ"[1788]។

អំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់បទចោទឡើងវិញអនុលោមតាមវិធាន ៩៨ (២) នៃវិធានផ្ទៃក្នុង មិនត្រូវបានកម្រិតដោយធាតុផ្សំគតិយុត្តិនៃបទល្មើស ដែលមានរៀបរាប់នៅក្នុងដីកា

---

[1784] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E294/1 កថាខណ្ឌ ១៥-១៦។

[1785] ដូចខាងលើ កថាខណ្ឌ ១៩។

[1786] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E116 កថាខណ្ឌ ១៣-១៤ និង ១៩-២០។

[1787] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៤៩។

[1788] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ១៥3។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៩០។ សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៩៥-១០៩។

ដំណោះស្រាយនោះទេ។ ដូច្នេះ បើទោះបីជាដីកាដំណោះស្រាយអាចត្រូវបានបកស្រាយថា អនុញ្ញាតសម្រាប់តែការសម្លាប់រង្គាល *ដោយចេតនាផ្ទាល់* (*dolus directus*) ប៉ុណ្ណោះក៏ដោយ ក៏អង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ នៅតែអាចគាំទ្រការកំណត់បទល្មើសនៃ*ចេតនាប្រយោល* (*dolus eventualis*) បានដែរ[1789]។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានជំទាស់ទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានណែនាំធាតុផ្សំថ្មី នៅពេលខ្លួនកំណត់បទល្មើសឡើងវិញចំពោះអង្គហេតុ ពីបទល្មើសសម្លាប់រង្គាលទៅជាបទការធ្វើមនុស្សឃាត ដោយសារតែការធ្វើមនុស្សឃាតនិងការសម្លាប់រង្គាលមានធាតុផ្សំបទល្មើសផ្សេងគ្នា[1790]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហានៅចំពោះមុខខ្លួននោះគឺថាតើ អង្គហេតុនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គាំទ្របទចោទដែលអាចមាននៃការធ្វើមនុស្សឃាតដោយចេតនាប្រយោល (*dolus eventualis*) ជាជាងបទសម្លាប់រង្គាលដោយចេតនាផ្ទាល់ដែរ ឬទេ។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា អង្គហេតុដែលដាក់បញ្ចូលក្នុងដីកាដំណោះស្រាយ គាំទ្រសំអាងហេតុនៃការធ្វើមនុស្សឃាតដោយចេតនាប្រយោល (*dolus eventualis*) ក៏ដូចជា បទសម្លាប់រង្គាល ការកំណត់បទចោទឡើងវិញគឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ទោះជាយ៉ាងណា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងរួមបញ្ចូលអង្គហេតុដែលមិនមាននៅក្នុងដីកាដំណោះស្រាយទេនោះ ការកំណត់បទចោទឡើងវិញនឹងមិនត្រឹមត្រូវតាមច្បាប់ទេ[1791]។

នៅពេលដែលការផ្លាស់ប្តូរត្រូវបានធ្វើឡើង រួមបញ្ចូលទាំងតាមរយៈការកំណត់បទចោទឡើងវិញ ភាគីត្រូវទទួលបានការជូនដំណឹងអំពីបំរែបំរួលនោះ ដើម្បីឱ្យពួកគេអាចលើកសារណាបានទាន់ពេលវេលា និងដោយប្រសិទ្ធភាព។ ព័ត៌មានដែលបានផ្តល់នោះត្រូវតែ “ពេញលេញ” និង “លម្អិត” បើទោះបីជាស្ថានភាពនៃអង្គហេតុនីមួយៗចាំបាច់ត្រូវធ្វើការវាយតម្លៃផ្អែកតាមលក្ខណៈជាក់ស្តែងក្តី។ សិទ្ធិទទួលបានការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ គឺជាទិដ្ឋភាពនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការត្រៀមលក្ខណៈរៀបចំការការពារខ្លួន[1792]។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង “ជារួម” និងបានសន្និដ្ឋានថា សេចក្តីសន្និដ្ឋានដូចគ្នាភាគច្រើនក្នុងសំណុំរឿង ០០២/០១ បានជូនដំណឹងយ៉ាងមានប្រសិទ្ធភាពដល់ភាគីថា ការកំណត់បទចោទឡើងវិញបែបនោះអាចធ្វើទៅបានក្នុងសំណុំរឿង ០០២/០២។ កិច្ចប្រជុំរៀបចំសវនាការពិសេសក៏ត្រូវបានធ្វើឡើងដើម្បីពិភាក្សាការកំណត់បទចោទឡើងវិញ និងបញ្ហាផ្សេងទៀត[1793]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានគាំទ្រការកំណត់បទចោទឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះអង្គហេតុជាក់លាក់នៅក្នុងដីកាដំណោះស្រាយ (ពីបទសម្លាប់រង្គាលទៅជាបទល្មើសនៃការធ្វើមនុស្សឃាតវិញ) ប៉ុន្តែមិនបានពិចារណាច្បាស់លាស់អំពីលក្ខខណ្ឌតម្រូវនៃការជូនដំណឹងឡើយ[1794]។

នៅពេលធ្វើការកំណត់បទចោទឡើងវិញ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា (១) សិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានរំលោភ និង (២) ទម្រង់នៃការទទួលខុសត្រូវដែលជាបញ្ហាចោទអាចអនុវត្តបាននៅ អ.វ.ត.ក.[1795]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះជាប់កាតព្វកិច្ចត្រូវសម្រេចលើភាពអាចអនុវត្តបាននៃទម្រង់ JCE មុនពេលការប្រជុំពិភាក្សាសម្ងាត់របស់ខ្លួន ហើយត្រូវផ្តល់ឱ្យជនជាប់ចោទនូវឱកាសបន្ថែមទៀតដើម្បីឆ្លើយតប មុនពេលធ្វើការកំណត់បទចោទឡើងវិញចំពោះទម្រង់ជាបុគ្គលនៃការទទួលខុសត្រូវតាម JCE។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ជនជាប់ចោទត្រូវបានជូនដំណឹងជាច្រើនដង និងមានពេលវេលាគ្រប់គ្រាន់ក្នុងការដោះស្រាយអំពីលទ្ធភាពជាក់លាក់ដែលថា JCE អាចនឹងត្រូវបានអនុវត្តចំពោះបទចោទប្រឆាំងនឹងគាត់[1796]។ បន្ទាប់មកអង្គជំនុំជម្រះ

[1789] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១០១។
[1790] ដូចខាងលើ កថាខណ្ឌ ៩៥-១០៩។
[1791] ដូចខាងលើ កថាខណ្ឌ ១០១។
[1792] ដូចខាងលើ កថាខណ្ឌ ១០៧។ សម្រាប់ព័ត៌មានបន្ថែមស្តីពីសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ និងជាពិសេស សិទ្ធិទទួលបានការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ សូមមើល ផ្នែក ៤.៦។
[1793] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១០៨។
[1794] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៥៦២។
[1795] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៩៦។
[1796] ដូចខាងលើ កថាខណ្ឌ ៥០២។

សាលាដំបូងបានវិភាគលើលទ្ធភាពអនុវត្ត JCE នៅ អ.វ.ត.ក. ដោយសន្និដ្ឋានថា វាបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩[1797]។

### ៥.៦.៨.បន្ទុកនៃភ័ស្តុតាង និងបទដ្ឋាននៃភ័ស្តុតាង

វិធាន៨៧(១) នៃវិធានផ្ទៃក្នុងចែងអំពីបន្ទុកនៃភ័ស្តុតាង និងបទដ្ឋាននៃភ័ស្តុតាង។ ជនជាប់ចោទគ្រប់រូបត្រូវសន្មតថាគ្មានទោសរហូតទាល់តែពិរុទ្ធភាពត្រូវបានបញ្ជាក់។ សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង។ សំណៅជាភាសាខ្មែរ និងភាសាអង់គ្លេសនៃវិធាន ៨៧(១) ចែងថា ដើម្បីផ្តន្ទាទោសបាន អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ "ដោយគ្មានវិមតិសង្ស័យ" អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ចំណែកសំណៅជាភាសាបារាំងចែងពីសញ្ញាណនៃ "ជំនឿស្មោះត្រង់ពិតប្រាកដ ឬ ជំនឿដោយឥស្សរចិត្ត (*intime conviction*)" របស់ចៅក្រម។ ទោះបីជាភាពផ្សេងគ្នាទាំងអស់នេះ ក៏អង្គជំនុំជម្រះសាលាដំបូងបានអនុម័តយកវិធីសាស្ត្រមួយដែល "វាយតម្លៃភាពគ្រប់គ្រាន់នៃភស្តុតាងនៅក្នុងគ្រប់កាលៈទេសៈទាំងអស់"[1798] នៅពេលណា (១) "ការបង្ហាញភ័ស្តុតាងអំពីធាតុផ្សំបទឧក្រិដ្ឋនីមួយៗ ទម្រង់នៃការទទួលខុសត្រូវ និងអង្គហេតុដែលជាកត្តាកំណត់ពិរុទ្ធភាព ត្រូវមានការវាយតម្លៃទៅលើភ័ស្តុតាងដោយមានសំអាងហេតុ"[1799] និង (២) "ភាពសង្ស័យអំពីពិរុទ្ធភាព ត្រូវបានបកស្រាយនៅក្នុងន័យដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ"[1800]។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយបទដ្ឋាននេះថា តម្រូវឱ្យមានការបញ្ជាក់ភ័ស្តុតាងហួសពីវិមតិសង្ស័យ[1801]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា "ពិរុទ្ធភាពរបស់ជនជាប់ចោទត្រូវតែបង្ហាញថា គ្មានវិមតិសង្ស័យនៅក្នុងដំណាក់កាលជំនុំជម្រះ" នៅពេលពន្យល់ពីបទដ្ឋាននៃការពិនិត្យឡើងវិញរបស់ខ្លួនចំពោះកំហុសអង្គហេតុ និងបកស្រាយសាលក្រមក្នុងសំណុំរឿង ០០១ ថាតម្រូវឱ្យមានការបញ្ជាក់ភ័ស្តុតាងហួសពីវិមតិសង្ស័យ[1802]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានសង្កេតឃើញថាខ្លួន "បានសម្រេចយកវិធីសាស្ត្រមួយទៅវាយតម្លៃភាពគ្រប់គ្រាន់នៃភស្តុតាងនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ នៅពេលមានការវាយតម្លៃភស្តុតាងដែលមានសំអាងហេតុ ភាពសង្ស័យអំពីពិរុទ្ធភាព ត្រូវបានបកស្រាយនៅក្នុងន័យដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ"[1803]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តគោលគំនិតនៃប្រព័ន្ធច្បាប់ស៊ីវិលអំពីបទដ្ឋាននៃ "ជំនឿដោយឥស្សរចិត្ត" ជាជាងបទដ្ឋានប្រព័ន្ធច្បាប់អង់គ្លូសាក់សុងក្នុងការបង្ហាញភ័ស្តុតាង "ឱ្យហួសពីវិមតិសង្ស័យ"។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង "បានសម្រេចយកបទដ្ឋានបង្ហាញភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យ" ដោយកត់សម្គាល់ថា សាលក្រមសំណៅជាភាសាបារាំងបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំដែលប្រើពាក្យ "ជំនឿដោយឥស្សរចិត្ត (*intime conviction*)" នៅពេលធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ប៉ុន្តែប្រើពាក្យថា "ហួសពីវិមតិសង្ស័យ (*il ne fait aucun doute*)"[1804]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាអង្គជំនុំជម្រះសាលាដំបូង "បានបង្ហាញត្រឹមត្រូវនូវបន្ទុក និងបទដ្ឋានជាធរមាននៃភស្តុតាង" ដែលតម្រូវឱ្យមានការបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានការយល់ឃើញបែបណាក៏ដោយចំពោះគោលគំនិតនៃប្រព័ន្ធច្បាប់ស៊ីវិលនៃពាក្យ "ជំនឿដោយឥស្សរចិត្ត" ក៏អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងត្រឹមត្រូវថា "អង្គហេតុ

[1797] ដូចខាងលើ កថាខណ្ឌ ៥០៤-៥១២។
[1798] ដូចខាងលើ កថាខណ្ឌ ៤៥។
[1799] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ៣៩។
[1800] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣៧៩។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ២២។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៨ និង៣៦។
[1801] សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៣០២-៣០៤។
[1802] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៨ និង៣៦។
[1803] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤៥។
[1804] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣៧៧ និង ៣៧៩-៣៨០។

ទាំងអស់ដែលជាមូលដ្ឋាននៃធាតុផ្សំឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នោះ ព្រមទាំងអង្គហេតុដែលចាំបាច់ខានពុំបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពនោះ [...] ត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ"។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានយល់យ៉ាងត្រឹមត្រូវថា "នេះត្រូវតែបានគាំទ្រដោយការផ្តល់សំអាងហេតុសមស្របដែលផ្អែកលើភស្តុតាងទាំងមូល ដោយពុំចាំបាច់អនុវត្តនូវបទដ្ឋាននៃការបង្ហាញភស្តុតាង "ឱ្យហួសពីវិមតិសង្ស័យ" តាមលក្ខណៈជាផ្នែកៗឡើយ"[1805]។

## ៥.៧. ដំណាក់កាលបណ្តឹងសាទុក្ខ

វិធាន ១០៤-១១២ នៃវិធានផ្ទៃក្នុង បញ្ញត្តិនីតិវិធីជាធរមានសម្រាប់បណ្តឹងសាទុក្ខលើសាលក្រម និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ផ្នែកនេះលើកឡើងអំពីទិដ្ឋភាពជាក់លាក់មួយចំនួនអំពីនីតិវិធីបណ្តឹងសាទុក្ខនៅ អ.វ.ត.ក. ពោលគឺ៖ (១) យុត្តាធិការ និងភាពអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល (២) បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ (៣) នីតិវិធីលើបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល និង (៤) ការស៊ើបអង្កេតបន្ថែមនៅដំណាក់កាលបណ្តឹងសាទុក្ខ។

### ៥.៧.១. យុត្តាធិការ និង ភាពអាចទទួលយកបាន

វិធាន ១០៤(១) និង ១០៥(២) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ប្រឆាំងនឹងសាលក្រម ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ផ្អែកលើ (១) កំហុសលើអង្គច្បាប់ "ដែលនាំឱ្យមោឃៈសាលក្រម" (២) កំហុសនៃអង្គហេតុដែល "នាំឱ្យមានភាពអយុត្តិធម៌" និង/ឬ (៣) មូលដ្ឋាននៃការភាន់ច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង "ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ"។ វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងបានបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងខាងក្រោមនេះ ចំណែកឯសេចក្តីសម្រេចផ្សេងទៀត អាចត្រូវបានប្តឹងសាទុក្ខតែនៅពេលប្តឹងសាទុក្ខសាលក្រមអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ៖

i. សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។
ii. សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន ៨២។
iii. សេចក្តីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) និង
iv. សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង។

វិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុងតម្រូវថាដើម្បីឱ្យបណ្តឹងសាទុក្ខអាចទទួលយកបាន ត្រូវមាន "សាលក្រម" ឬ "សេចក្តីសម្រេច" ពីអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/០២ បានសន្និដ្ឋានថា សេចក្តីថ្លែងការណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដែលលើកឡើងថា អង្គជំនុំជម្រះមិនអាចចូលពិនិត្យមើលសំណុំរឿងបាន បន្ទាប់ពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនបង្កើតបានជា "សេចក្តីសម្រេច" សម្រាប់គោលបំណងនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងទេ។ ក្នុងការសម្រេចថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់សំណុំរឿង ០០៤/០២ ជាធរមានដោយអង្គជំនុំជម្រះសាលាដំបូងមិនអាចទទួលយកបាន អង្គជំនុំជម្រះតុលាការកំពូល "បានបញ្ជាក់សាជាថ្មីថា អង្គជំនុំជម្រះសាលាដំបូងពុំអាចបញ្ចប់អានុភាពកិច្ចដំណើរការនីតិវិធីបាន ដោយសារអង្គជំនុំជម្រះពុំបានទទួលសំណុំរឿងជាផ្លូវការ" អាស្រ័យហេតុនេះ មិនអាច "ចេញដីកាត្រឹមត្រូវតាមច្បាប់ណាមួយបាន"[1806]។

---

[1805] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៣០២-៣០៤។

[1806] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថា

អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ថាអនុញ្ញាតបើកផ្លូវឱ្យធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹង "សេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី ដែលពុំមានសក្តានុពលជាក់ស្តែងក្នុងការបន្ត ដោយរារាំងការឈានទៅដល់ការចេញសាលក្រមលើអង្គសេចក្តីបាន"[1807]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា "ផលវិបាកនៃការអាក់ខាន ដែលបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធីនេះ មានកម្រិតធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា សេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីនេះ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ"។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបកស្រាយនេះត្រូវបានគាំទ្រដោយជម្រើសជាក់លាក់នៃពាក្យពេចន៍នៅក្នុងវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង ពោលគឺ "*អានុភាព*បញ្ចប់កិច្ចដំណើរការនីតិវិធី" ដែលផ្ទុយទៅនឹងសេចក្តីសម្រេចដែលគ្រាន់តែ "បញ្ចប់កិច្ចដំណើរការនីតិវិធី" ក៏ដូចជាយុត្តិសាស្ត្រពីតុលាការព្រហ្មទណ្ឌអន្តរជាតិ(ជាតួបនីយកម្ម)ផ្សេងទៀត ដែលអនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខបន្ទាន់បង្កប្រឆាំងនឹងការផ្អាកកិច្ចដំណើរការនីតិវិធី[1808]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ការជំទាស់ទៅនឹងលក្ខណៈនៃឧក្រិដ្ឋកម្មដែលអាចអនុវត្តបាន ឧទាហរណ៍ ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធដែរ ឬយ៉ាងណា ពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ[1809]។

ជនជាប់ចោទអាចប្តឹងសាទុក្ខ ចំពោះសេចក្តីសម្រេចទាំងអស់ របស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន។ ដូច្នេះ ប្រសិនបើសេចក្តីសម្រេចដែលរងការជំទាស់ ត្រូវបានធ្វើឡើងតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបើកផ្លូវឱ្យប្តឹងសាទុក្ខតាមវិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង[1810]។ ពុំមានសេចក្តីសម្រេចណាត្រូវបានចេញអនុលោមតាមវិធាន ១០៤(៤)(គ) នៃវិធានផ្ទៃក្នុងទេ។

វិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង បានប្រមើលទុកអំពី "សេចក្តីសម្រេច*ស្តីពី*" វិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល បានលើកឡើងថា ទោះបីជាវិធានពុំតម្រូវថា សេចក្តីសម្រេចដែលរងការជំទាស់ត្រូវ "យោងខ្លួនឯង" ថាជា "សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ"ក៏ដោយ ក៏សំណើណាមួយមិនអាច "បង្ហាញពីការលើកឡើងនានា ដែលជាក់ស្តែងមិនអាចទទួលយកបានតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះទេ"។ ជាងនេះទៀត "ការសម្រេចរបស់តុលាការដែលមានកំហុស គឺមិនគ្រប់គ្រាន់តាមផ្លូវច្បាប់ដើម្បីបំពេញនូវបទដ្ឋានស្របតាមវិធាន ៣៥ ឡើយ"[1811]។

---

ខណ្ឌ ៥៧។ សម្រាប់ព័ត៌មានបន្ថែមអំពីដីកាដំណោះស្រាយផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងការបញ្ចប់សំណុំរឿងទាំងនេះដោយអង្គជំនុំជម្រះតុលាការកំពូល សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.៣។

[1807] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៤៧។ សូមមើល សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E138/1/7 កថាខណ្ឌ ១៥។

[1808] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E138/1/7 កថាខណ្ឌ ១៥។

[1809] សូមមើលសំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១២ ឯកសារ E95/8/1/4 កថាខណ្ឌ ៨-១០។

[1810] សូមមើលឧទាហរណ៍ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំដោះលែង ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ឯកសារ E275/2/3 កថាខណ្ឌ ១៨-២០។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ២១។

[1811] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ E154/1/1/4 កថាខណ្ឌ ១៣។

វិធាន ១០៥(២) និង ១០៥(៣) នៃវិធានផ្ទៃក្នុង តម្រូវឱ្យម្ចាស់បណ្តឹងសាទុក្ខកំណត់អត្តសញ្ញាណកំហុសដែលបានចោទប្រកាន់ គាំទ្រមូលដ្ឋាននីមួយៗដោយអំណះអំណាង និងប្រភពនានា និងបង្ហាញថាហេតុដូចម្តេចបានជាកំហុសនោះបានធ្វើឱ្យសាលក្រមទៅជាមោឃៈ ឬបាននាំឱ្យមានភាពអយុត្តិធម៌។ បណ្តឹងសាទុក្ខត្រូវតែកំណត់អត្តសញ្ញាណការយល់ឃើញ ឬ ការសម្រេចដែលរងការចោទប្រកាន់ ដោយមានការយោងជាក់លាក់ទៅលើលេខទំព័រ និងកថាខណ្ឌ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[1812]។ អង្គជំនុំជម្រះតុលាការកំពូលតម្រូវឱ្យ "ម្ចាស់បណ្តឹងសាទុក្ខបង្ហាញនូវទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងសមស្រប"។ សារណាបណ្តឹងសាទុក្ខដែលមានលក្ខណៈមិនច្បាស់លាស់ ផ្ទុយគ្នា ស្រពេចស្រពិល ឬមិនពេញលេញ ពុំត្រូវបានពិចារណាទេ[1813]។

ម្ចាស់បណ្តឹងសាទុក្ខមិនអាចលើកអំណះអំណាងនៅពេលជំនុំជម្រះមកតវ៉ា*សាជាថ្មី* ឬតវ៉ាថា សេចក្តីសម្រេច ឬការយល់ឃើញណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងថាមានកំហុសឡើយ លើកលែងតែម្ចាស់បណ្តឹងសាទុក្ខអាចបង្ហាញថា ការបដិសេធអំណះអំណាងណាមួយគឺជាកំហុសអង្គច្បាប់ ដែលចាំបាច់ត្រូវមានអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល។ ដោយពុំចាំបាច់ពិចារណាលើអង្គសេចក្តី អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាង ដែលពុំអាចធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់នោះត្រូវបានបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលក៏មានឆន្ទានុសិទ្ធិ ក្នុងការជ្រើសរើសសារណាណាមួយដែលស័ក្តិសម ក្នុងការទទួលបានការពិនិត្យពិចារណាដោយល្អិតល្អន់ជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះតុលាការកំពូលអាចបដិសេធទឡ្ហីករណ៍ណាដែលមិនមានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដោយមិនចាំបាច់ផ្តល់សំអាងហេតុលម្អិតឡើយ[1814]។

អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចតម្កល់ ទុកជាមោឃៈ ឬកែប្រែសេចក្តីសម្រេចទាំងស្រុង ឬដោយផ្នែក។ រាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទាំងអស់គឺជាសេចក្តីសម្រេចស្ថាពរ[1815]។

### ៥.៧.២. បទដ្ឋាននៃការពិនិត្យឡើងវិញ

អនុលោមតាមវិធាន ១០៤(១) និងវិធាន ១០៥(២) នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខអាចផ្អែកលើមូលដ្ឋានមួយ ឬច្រើនក្នុងចំណោមមូលដ្ឋានទាំងបីនេះ៖ (១) កំហុសលើអង្គច្បាប់ ដែលនាំឱ្យ "មោឃៈសាលក្រមលើអង្គសេចក្តី" (២) កំហុសនៃអង្គហេតុ ដែលនាំឱ្យ "មានភាពមិនយុត្តិធម៌" និង (៣) ការភាន់ច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែល "នាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ"។ អង្គជំនុំជម្រះតុលាការកំពូលបានបង្កើតបទដ្ឋាននៃការពិនិត្យឡើងវិញ អនុលោមតាមមូលដ្ឋាននីមួយៗនេះ។

***កំហុសលើអង្គច្បាប់៖*** នៅពេលដែលម្ចាស់បណ្តឹងសាទុក្ខចោទអំពីកំហុសលើអង្គច្បាប់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងនាមជា "តុលាការចុងក្រោយនៃអង្គច្បាប់ដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក." ត្រូវបានចងកាតព្វកិច្ចក្នុងការកំណត់លើបញ្ហាថាតើ កំហុសលើអង្គច្បាប់ជាក់ស្តែងត្រូវបានប្រព្រឹត្តឡើងលើផ្នែកអង្គសេចក្តី ឬផ្នែកនីតិវិធីដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល បានពិនិត្យការយល់ឃើញផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់មិនត្រឹមតែ "ថាតើការយល់ឃើញផ្នែកអង្គច្បាប់សមហេតុផលប៉ុណ្ណោះទេ ថែមទាំងថាតើត្រឹមត្រូវដែរ ឬយ៉ាងណា"[1816]។ បើទោះបីជាអំណះអំណាងរបស់ភាគីពុំបានលើកគ្រប់ជ្រុងជ្រោយក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាលើហេតុផលដទៃ

---

[1812] វិធានផ្ទៃក្នុង វិធាន ១០៥(៤)។
[1813] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩។ សូមមើល សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១០១។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២០។
[1814] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ២០។ សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១០១។
[1815] វិធានផ្ទៃក្នុង វិធាន ១០៤(២) និង ១០៤(៣)។ សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២១។
[1816] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២៣។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨៥។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៤។

ទៀត ដើម្បីសន្និដ្ឋានថា កំហុសអង្គច្បាប់បានកើតមានឬទេ[1817]។ នៅពេលដែលសាលក្រមអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយសារការអនុវត្តបទដ្ឋានគតិយុត្តិមិនត្រឹមត្រូវ អង្គជំនុំជម្រះតុលាការកំពូលកំណត់អត្តសញ្ញាណបទដ្ឋានគតិយុត្តិត្រឹមត្រូវ និង ពិនិត្យឡើងវិញលើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូល កែតម្រូវកំហុសអង្គច្បាប់នោះដោយអនុវត្តបទដ្ឋានគតិយុត្តិត្រឹមត្រូវទៅលើភស្តុតាង និងកំណត់ថាតើសំអាងហេតុបានបំពេញបទដ្ឋាននៃភស្តុតាងឬ ទេ មុនពេលបញ្ជាក់លើសាលក្រមលើបណ្តឹងសាទុក្ខ[1818]។ បទដ្ឋាននៃការពិនិត្យឡើងវិញនេះមានកម្រិតខ្ពស់៖ កំហុសអង្គច្បាប់ត្រូវតែធ្វើឱ្យសាលក្រម ឬសេចក្តីសម្រេចទៅជាមោឃៈ។ សាលក្រម ឬសេចក្តីសម្រេចត្រូវបាន "ទៅជាមោឃៈ" ដោយកំហុសអង្គច្បាប់ នៅពេលណា "បង្ហាញថា ក្នុងករណីគ្មានកំហុស សាលក្រមមួយផ្សេងទាំងស្រុង ឬផ្នែកខ្លះ អាចត្រូវបានធ្វើឡើង"[1819]។

***កំហុសអង្គហេតុ***៖ អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តបទដ្ឋាននៃភាពសមហេតុផល ក្នុងការពិនិត្យឡើងវិញលើសំអាងហេតុដែលរងការជំទាស់ ជាជាងធ្វើការវាយតម្លៃថាតើ ការយល់ឃើញនោះត្រឹមត្រូវដែរ ឬយ៉ាងណា។ តាមបទដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែល "ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយ" អាចឈានដល់ការយល់ឃើញដែលជាបញ្ហាចោទនោះ។ ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹងវិធីសាស្ត្រទូទៅដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតាមវិធីសាស្ត្រនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (១) អនុវត្តក្នុងកម្រិតមួយចំពោះការយល់ឃើញផ្នែកអង្គហេតុដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង និង (២) ដាក់ការយល់ឃើញរបស់ខ្លួនជំនួសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបាន តែក្នុងករណីដែលមិនមានតុលាការអង្គហេតុសមហេតុផលណាមួយ អាចទទួលយកភស្តុតាងដែលបានផ្អែកលើ ឬក្នុងករណីដែលការវាយតម្លៃនៃភស្តុតាងនោះ "មានកំហុសទាំងស្រុង" ប៉ុណ្ណោះ។ មូលហេតុនៃបទដ្ឋានផ្តល់អាទិភាពពុំពិនិត្យឡើងវិញនេះគឺថា អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈអំណោយផលក្នុងការសង្កេតសាក្សីផ្ទាល់ និងស្ថិតក្នុងតួនាទីប្រសើរជាងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក្នុងការវាយតម្លៃភាពអាចទទួលយកបាន និងភាពអាចជឿជាក់បាននៃភស្តុតាង[1820]។ ហេតុដូច្នេះ ចំណុចចាប់ផ្តើមសម្រាប់ការវាយតម្លៃរបស់អង្គជំនុំជម្រះតុលាការកំពូលលើភាពសមហេតុផលនៃការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង គឺសំអាងហេតុដែលបានផ្តល់សម្រាប់ការវិភាគអង្គហេតុ។ ស្របតាមវិធានទូទៅ ក្នុងករណីដែលភស្តុតាងជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានផ្នែកអង្គហេតុ មើលទៅទំនងជាមានកម្រិតទាបនោះ តម្រូវឱ្យផ្តល់សំអាងហេតុឱ្យបានច្រើនជាង។ ទោះជាយ៉ាងណា អំណះអំណាងដែលមានកម្រិតត្រឹមតែជំទាស់ទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណាដែលបានផ្អែកទៅលើការបកស្រាយភស្តុតាងដដែល ពុំគ្រប់គ្រាន់សម្រាប់បដិសេធការយល់ឃើញផ្នែកអង្គហេតុបានឡើយ[1821]។ មានតែអង្គហេតុទាំងឡាយណា ដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ប៉ុណ្ណោះ អាចជាលទ្ធផលនាំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធសាលក្រម ឬ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមួយផ្នែក ឬទាំងស្រុងបាន។ ភាពអយុត្តិធម៌ត្រូវបានកំណត់និយមន័យថាជា "លទ្ធផលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការមានភាពមិនយុត្តិធម៌ទាំងស្រុង"។ ចំពោះកំហុសអង្គហេតុ ដែលនាំឱ្យសាលក្រមមានភាពអយុត្តិធម៌នោះ កំហុសនោះត្រូវតែ "កំហុសធ្ងន់ធ្ងរដល់ការប្រកាសអំពីពិរុទ្ធភាព"។ ភាគីត្រូវមានកាតព្វកិច្ចបង្ហាញឱ្យឃើញថា តើកំហុសអង្គហេតុនោះពិតជាស្តែងឱ្យឃើញភាពមិនយុត្តិធម៌ដោយរបៀបណា[1822]។

---

[1817] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២៣។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៥។
[1818] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២៤។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨៦។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៦។
[1819] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២៥។ សូមមើល សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៩៩។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៥។
[1820] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២៧។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៨៩។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៧។
[1821] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៩០។ សូមមើល សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២៧-២៨។
[1822] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៩៩។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៩។

បណ្ដឹងសាទុក្ខប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាព ត្រូវតែបង្ហាញថា កំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្កើតវិមតិសង្ស័យចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទ។ បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចឱ្យរួចខ្លួន ត្រូវបង្ហាញថា នៅពេលពិចារណាលើកំហុសអង្គហេតុដែលប្រព្រឹត្តដោយអង្គជំនុំជម្រះសាលាដំបូង គ្មានវិមតិសង្ស័យចំពោះការសម្រេចដាក់ពិរុទ្ធភាពទៅលើជនជាប់ចោទ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ឬដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្ដីសម្រេចឱ្យរួចខ្លួន អង្គជំនុំជម្រះតុលាការកំពូលអាចត្រឹមតែកែប្រែសំអាងហេតុផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ប្រសិនបើខ្លួនយល់ឃើញថាសាលក្រមមានកំហុស ប៉ុន្តែមិនអាចកែប្រែផ្នែកសម្រេចសេចក្ដីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ[1823]។

***កំហុសផ្នែកនីតិវិធី៖*** អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយទាក់ទងនឹងបញ្ហានីតិវិធី។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានអនុម័តវិធីសាស្ត្រក្នុងការពិនិត្យឡើងវិញដែលទទួលយកជាបានការនូវសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ និងធ្វើអន្តរាគមន៍ទៅលើការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែល "កំហុសស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិ [...] ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ"។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ICTR និង ICC បានអនុវត្តបទដ្ឋានក្នុងការពិនិត្យឡើងវិញដែលទទួលយកជាបានការសម្រាប់សេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ ហើយបានចាត់ទុកបទដ្ឋាននេះថា "មានលក្ខណៈសមស្របជាមួយនឹងបរិបទនៃ អ.វ.ត.ក."។ យោងតាមបទដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលនឹងជ្រៀតជ្រែកការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែល៖ (១) វា "ផ្អែកលើកំហុសក្នុងការបកស្រាយច្បាប់" (២) វាត្រូវបានអនុវត្តដោយ "មានកំហុសយ៉ាងច្បាស់ក្នុងការកំណត់អង្គហេតុ" ឬ (៣) សេចក្ដីសម្រេច "មានភាពមិនយុត្តិធម៌ និងពុំសមហេតុផល នាំឱ្យមានការរំលោភលើឆន្ទានុសិទ្ធិ"[1824]។ ប្រសិនបើសេចក្ដីសម្រេចបន្ទាន់បង្ខំពីអង្គជំនុំជម្រះសាលាដំបូងត្រូវបានតវ៉ានៅដំណាក់កាលបណ្ដឹងសាទុក្ខនោះ ម្ចាស់បណ្ដឹងសាទុក្ខក៏ត្រូវបង្ហាញឱ្យឃើញផងដែរនូវ "ការប៉ះពាល់យូរអង្វែង" ដើម្បីបង្ហាញចំណងទាក់ទងច្បាស់លាស់រវាងសេចក្ដីសម្រេចបន្ទាន់បង្ខំ ដែលកំពុងរងការជំទាស់ ជាមួយនឹងសាលក្រមរបស់អង្គជំនុំជម្រះផ្ទាល់[1825]។

***បញ្ហាសំខាន់ៗជាទូទៅ៖*** ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចលើកបញ្ហានានា*តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន* ឬ ស្ដាប់បណ្ដឹងសាទុក្ខក្នុងករណីដែលភាគីបានលើកនូវបញ្ហាច្បាប់ណាមួយ ដែលពុំនាំឱ្យសាលក្រមទៅជាមោឃៈ ប៉ុន្តែទោះជាយ៉ាងណាវាមានសារៈសំខាន់ជាទូទៅចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក.[1826]។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដំណោះស្រាយជាសេចក្ដីប្រកាស ថាតើ JCE III អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. ដែរ ឬយ៉ាងណា ដោយសារកំហុសនីតិវិធី។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាសំណើនោះ "ពិតជាមានការពាក់ព័ន្ធមួយចំនួនផងដែរទៅនឹងកិច្ចដំណើរការនីតិវិធីនាពេលអនាគតនិងនៅចំពោះមុខតុលាការនេះ" ដោយសារ JCE III ត្រូវបានប្រើប្រាស់ជាញឹកញាប់នៅក្នុងរឿងក្ដីនានានៅចំពោះមុខសាលាក្ដី*មិនអចិន្ត្រៃយ៍* និងអាចពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. ក៏អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថាមានហេតុផលត្រូវពិចារណាលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយឈរលើមូលដ្ឋានពិសេសនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ បានផ្ដល់ឱកាសឱ្យខ្លួនធ្វើការវិភាគលើ JCE ដែលរួមបញ្ចូលទិដ្ឋភាពពាក់ព័ន្ធទៅនឹងបញ្ហានានាដែលបានលើកដោយសហព្រះរាជអាជ្ញា ដែលខ្លួនយល់ឃើញថាមានលក្ខណៈគ្រប់គ្រាន់ក្នុងការផ្ដល់ជាគោលការណ៍ណែនាំសម្រាប់កិច្ចដំណើរការនីតិវិធីនាពេលអនាគត[1827]។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល*តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន*បានលើកយកបញ្ហាថាតើ ការទទួលខុសត្រូវ

[1823] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៨។
[1824] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៩៧-៩៨។
[1825] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៣១។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១០០ និង ១១៣៤។ សូមមើល*ឧទាហរណ៍* សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ F9 កថាខណ្ឌ ១៦។
[1826] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៣២។ សូមមើល សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៥។
[1827] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៣២។ សូមមើល សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១៥។

ព្រហ្មទណ្ឌតាមទម្រង់ JCE អនុវត្តចំពោះ *បទឧក្រិដ្ឋដោយចេតនាមានប្រយោល* (*dolus eventualis*)ដែរ ឬយ៉ាងណា នៅពេលដែលចារីបានដឹងអំពីហានិភ័យដែលធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋ អាចកើតចេញពីអំពើសកម្ម ឬអកម្មរបស់ពួកគេ ហើយនៅតែទទួលយកលទ្ធផលបែបនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាវាចាំបាច់ក្នុងការដោះស្រាយ "បញ្ហាដែលជាសារៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក." ដែលកើតចេញពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[1828]។

## ៥.៧.៣. នីតិវិធីលើបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល

វិធាន ១០៦ និង ១០៧ នៃវិធានផ្ទៃក្នុងចែងអំពីនីតិវិធីលើបណ្តឹងសាទុក្ខ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ការជូនដំណឹងនានាអំពីបណ្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខភ្លាមៗត្រូវតែដាក់ទៅកាន់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង និងចុះក្នុងបញ្ជីបណ្តឹងសាទុក្ខនៃអង្គជំនុំជម្រះសាលាដំបូង[1829]។ សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម រួមទាំងការដាក់ឯកសារផ្សេងៗបន្ទាប់ទៀត ត្រូវប្រគល់ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល[1830]។ វិធាន ១០៧ នៃវិធានផ្ទៃក្នុង ចែងអំពីគោលការណ៍ណែនាំសម្រាប់ប្រភេទជាក់លាក់នៃបណ្តឹងសាទុក្ខ៖

i. បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេច ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ឬ សេចក្តីសម្រេចលើការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ត្រូវដាក់ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ[1831]។

ii. បណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងការឃុំខ្លួន ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬវិធានការការពារ ត្រូវដាក់ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬការជូនដំណឹងពីសេចក្តីសម្រេចនោះ[1832]។

iii. បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ត្រូវដាក់ក្នុងរយៈពេល ២៤ ម៉ោង គិតចាប់ពីពេលជូនដំណឹងអំពីដីកាសម្រេចឱ្យដោះលែងនោះ[1833]។

iv. ការជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងអំពីសាលក្រមនោះ។ សារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីបណ្តឹងសាទុក្ខ[1834]។

v. នៅពេលភាគីប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ភាគីផ្សេងទៀតមានរយៈពេល ១៥ថ្ងៃ ក្នុងការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន ពេលវេលាបន្ថែមនេះត្រូវគិតចាប់ពីថ្ងៃផុតរលត់រយៈពេលកំណត់សម្រាប់ការដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខលើកដំបូង[1835]។

សារណាជាលាយលក្ខណ៍អក្សរទាំងអស់ តម្រូវឱ្យដាក់ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬបារាំង[1836] និងត្រូវគោរពចំនួនទំព័រកំណត់ដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក.[1837]។ ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចទទួលយកសំណើ

---

[1828] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៤៦-១៩៤៧។
[1829] វិធានផ្ទៃក្នុង វិធាន ១០៦(២)។
[1830] វិធានផ្ទៃក្នុង វិធាន ១០៦(៥)។
[1831] វិធានផ្ទៃក្នុង វិធាន ១០៧(១)។
[1832] វិធានផ្ទៃក្នុង វិធាន ១០៧(២)។
[1833] វិធានផ្ទៃក្នុង វិធាន ១០៧(៣)។
[1834] វិធានផ្ទៃក្នុង វិធាន ១៩៧(៤)។
[1835] វិធានផ្ទៃក្នុង វិធាន ១០៧(៤)។
[1836] សេចក្តីណែនាំអនុវត្តស្តីការដាក់ឯកសារ មាត្រា ៧.១។
[1837] ដូចខាងលើ មាត្រា ៥.២។

របស់ភាគីស្នើសុំពេលវេលា[1838] និងចំនួនទំព័របន្ថែម[1839] ក៏ដូចជាអនុញ្ញាតឱ្យពួកគេដាក់សារណាជាលាយលក្ខណ៍អក្សរតែមួយភាសាជាមុនសិន ដោយដាក់សំណៅបកប្រែតាមក្រោយ[1840]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងជាច្រើនដងថា ខ្លួនបានដឹងថាការពន្យារពេលមានភាពចាំបាច់ ដោយផ្អែកលើទំហំ និងភាពស្មុគស្មាញនៃរឿងក្តី នឹងសាលក្រម ហើយបានអនុញ្ញាតឱ្យមានការពន្យារពេលសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម[1841]។ អង្គជំនុំជម្រះតុលាការកំពូលមិនអនុញ្ញាតឱ្យមានការឆ្លើយតបទៅនឹងចម្លើយតបណាមួយសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមឡើយ ដោយហេតុថា ខ្លួនបានបើកសវនាការសាធារណៈស្តាប់អំណះអំណាងផ្ទាល់មាត់[1842]។

### ៥.៧.៤. ការស៊ើបអង្កេតបន្ថែមលើបណ្តឹងសាទុក្ខ

យោងតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ភាគីអាចស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យទទួលយកភស្តុតាងបន្ថែម ប្រសិនបើវាមិនអាចរកបានក្នុងអំឡុងពេលជំនុំជម្រះ និងអាចជាកត្តាកំណត់ក្នុងការឈានដល់ការធ្វើសេចក្តីសម្រេច។ សំណើបែបនេះត្រូវ "បញ្ជាក់ឱ្យបានច្បាស់លាស់ អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសំអាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក"។ ភាគីផ្សេងទៀតដែលរងការប៉ះពាល់ដោយសំណើសុំនេះ ត្រូវធ្វើការឆ្លើយតបក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីការជូនដំណឹងអំពីសំណើសុំនេះ[1843]។ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ក៏អនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូល "ខ្លួនឯងអាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ"។

ដើម្បីបង្ហាញថា ភស្តុតាងបន្ថែមដែលបានស្នើឡើងនោះ អាចជាកត្តាកំណត់បាន ភាគីដែលស្នើសុំភស្តុតាងត្រូវតែបង្ហាញថា "ភស្តុតាងនេះ ប្រសិនបើបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អាចនាំឱ្យអង្គជំនុំជម្រះនេះធ្វើការសម្រេចពីពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ"។ ភាគីដែលស្នើសុំដាក់ភស្តុតាងថ្មីត្រូវតែបង្ហាញពីឥទ្ធិពលរបស់ភស្តុតាងដែលបានស្នើសុំដាក់បន្ថែមនោះ ទៅលើការយល់ឃើញផ្នែកអង្គហេតុសំខាន់មួយ(ច្រើន) ដែលចាំបាច់សម្រាប់ការសម្រេចដាក់ពិរុទ្ធភាព ឬការប្រកាសទោស ដោយពិចារណាលើភស្តុតាងដែលបានបង្ហាញរួចហើយទៅកាន់អង្គជំនុំជម្រះសាលាដំបូង[1844]។

លក្ខខណ្ឌតម្រូវ "កត្តាកំណត់"ពុំអនុវត្តចំពោះការកោះហៅសាក្សីដែលជាភស្តុតាងថ្មី របស់អង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងទេ។ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចំពោះការកោះហៅសាក្សីដែលជាភស្តុតាងថ្មី អង្គជំនុំជម្រះតុលាការកំពូលពិចារណាថាតើ ការកោះហៅសាក្សីដែលជាភស្តុតាងថ្មីនេះ "មានផលប្រយោជន៍យុត្តិធម៌" ក្នុងន័យថា "អាចជួយស្វែងរកការពិតបាន" ដែរ ឬយ៉ាងណា[1845]។ ការណ៍នេះរួមបញ្ចូល ករណីដែលអង្គជំនុំជម្រះត្រូវប្រឈមជាមួយនឹងភស្តុតាងដោះបន្ទុកមានសក្តានុពល ដែលភស្តុតាងនេះចាំបាច់ត្រូវទទួលយកដើម្បីជៀសវាងភាពមិនយុត្តិធម៌ ឬក្នុងករណីដែលមេធាវីការពារក្តីបានលើកពីមន្ទិលសង្ស័យ ដែលមានលក្ខណៈធ្ងន់ធ្ងរ

---

[1838] ដូចខាងលើ មាត្រា ៨.១។ វិធានផ្ទៃក្នុង វិធាន ៣៩(៤)(ក)។
[1839] សេចក្តីណែនាំអនុវត្តស្តីការដាក់ឯកសារ មាត្រា ៥.៤។
[1840] ដូចខាងលើ មាត្រា ៧.២។
[1841] សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ F9 កថាខណ្ឌ ១៣។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ឯកសារ F3/3។
[1842] សូមមើល សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ F9 កថាខណ្ឌ ២២។
[1843] វិធានផ្ទៃក្នុង វិធាន ១០៨(៧)។
[1844] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣០។
[1845] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១។

ទាក់ទងទៅនឹងភាពសមស្របនៃការធ្វើកំណត់ហេតុភ័ស្តុតាងគន្លឹះ[1846]។ ទោះជាយ៉ាងណា នៅពេលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលត្រូវប្រកាន់ខ្ជាប់តួនាទីរបស់ខ្លួន ដែលជាចម្បង "ត្រូវកំណត់ថាតើសាលក្រមមានកំហុសដោយមូលហេតុកំហុសអង្គច្បាប់នាំឱ្យមោឃៈសាលក្រម ឬកំហុសអង្គហេតុនាំឱ្យមានភាពមិនយុត្តិធម៌ ដែរ ឬយ៉ាងណា ដោយមិនចាំបាច់បើកការជំនុំជម្រះលើអង្គសេចក្តីជាលើកទីពីរឡើយ"។ ហេតុដូច្នេះ លើកលែងតែមានកាលៈទេសៈជាក់លាក់ផ្តល់យុត្តិកម្មផ្សេងពីនេះ ទើបអង្គជំនុំជម្រះតុលាការកំពូលកោះហៅសាក្សីដែលជាភ័ស្តុតាងថ្មីនៅលើបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ជាពិសេសក្នុងករណីដែល "ភ័ស្តុតាងនេះ ប្រសិនបើបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ អាចនាំឱ្យអង្គជំនុំជម្រះនេះធ្វើការសម្រេចពីពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ"។ ដូច្នេះ ភ័ស្តុតាងដែលបានស្នើឡើងនោះត្រូវតែ "បានវាយតម្លៃទៅតាមបរិបទនៃភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការយល់ឃើញផ្នែកអង្គហេតុដែលមានសារៈសំខាន់ ឬចាំបាច់បំផុតដល់ការសម្រេចដាក់ពិរុទ្ធភាពនោះ[1847]។

អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ការបកស្រាយរបស់ខ្លួនចំពោះវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អាចត្រូវបានបកស្រាយថាត្រូតគ្នាជាមួយនឹងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ប៉ុន្តែយល់ឃើញថា វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងពុំមែនមិនសំខាន់នោះទេ។ ជាពិសេស វិធាន ១០៨(៧) អាចត្រូវបានផ្អែកលើក្នុងការទទួលយកភ័ស្តុតាងនៅក្នុងកិច្ចនីតិវិធីបណ្តឹងសាទុក្ខ ដែលអាចរកបាននៅពេលជំនុំជម្រះ ប៉ុន្តែមិនត្រូវបានកោះហៅ ចំណែកឯអង្គជំនុំជម្រះតុលាការកំពូលអាចប្រើវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងធ្វើជាមូលដ្ឋានក្នុងការកោះហៅសាក្សីដែលជាភ័ស្តុតាងថ្មីតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ដោយពុំចាំបាច់មានសំណើពីភាគីឡើយ[1848]។

[1846] ដូចខាងលើ កថាខណ្ឌ ៣១។ សូមមើល *ឧទាហរណ៍* សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ F2/5 កថាខណ្ឌ ១៧ កថាខណ្ឌ ២៣ និងកថាខណ្ឌ ២៥។
[1847] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣២។
[1848] ដូចខាងលើ កថាខណ្ឌ ៣៣។

# ៦. ការប្រកាសទោស

## ៦.១. ប្រភពនៃច្បាប់ស្ដីពីការប្រកាសទោស

វិធាន ៩៨(៥) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព អង្គជំនុំជម្រះសាលាដំបូងត្រូវ "ផ្ដន្ទាទោសជនជាប់ចោទនោះ ឱ្យស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង វិធានផ្ទៃក្នុង[ទាំងនេះ]"។ ឯកសារមូលដ្ឋានគោលទាំងអស់នេះមិនបែងចែករវាងឧក្រិដ្ឋកម្មជាតិ និងឧក្រិដ្ឋកម្មអន្តរជាតិទេ ទាក់ទងនឹងការប្រកាសទោស។ មាត្រា ១០ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ចែងថា ទណ្ឌកម្មជាអតិបរមាសម្រាប់ផ្ដន្ទាទោសឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. គឺកំណត់ត្រឹមដាក់ពន្ធនាគារអស់មួយជីវិត។ មាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. បំពេញបន្ថែមបទប្បញ្ញត្តិនេះដូចខាងក្រោម៖

> ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ដូចមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារពី ៥ ឆ្នាំ រហូតដល់មួយជីវិត។
>
> ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម។
>
> ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ[1849]។

ច្បាប់ អ.វ.ត.ក. និងកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ក៏បានចែងផងដែរថា អង្គជំនុំជម្រះសាលាដំបូងត្រូវអនុវត្តយុត្តិសាស្ត្ររបស់ខ្លួន ស្របតាមមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[1850]។ យោងតាមមាត្រា ១៥(១) នៃ ICCPR៖ (១) មិនត្រូវដាក់ទោស ឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ និង (២) ប្រសិនបើក្រោយពីការប្រព្រឹត្តិបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យឡើងវិញលើគោលការណ៍ណែនាំអន្តរជាតិស្ដីពីការប្រកាសទោសដែលពាក់ព័ន្ធ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយយល់ឃើញថាគោលការណ៍ណែនាំទាំងអស់នេះ "បង្ហាញថា ការផ្ដន្ទាទោស ដែលយកមកអនុវត្តនៅ អ.វ.ត.ក. ចំពោះបទឧក្រិដ្ឋទាំងនេះ មិនផ្ទុយនឹងមាត្រា ១៥(១) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ"[1851]។

ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. គឺជា*ច្បាប់ពិសេស* (*lex specialis*) ដែលចែងអំពីការដាក់ទោសមួយចំនួននៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក.។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលត្រូវប្រឈមមុខនឹងបញ្ហាថាតើ មាត្រា ១០ និង ៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាអាចអនុវត្តបាននៅក្នុងការកំណត់អំពីទោស និងចែងអំពីការកម្រិតទោសស្រាលជាងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. ដែរ ឬយ៉ាងណា[1852]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ទំនាក់ទំនងរវាងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក. និង ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ត្រូវពិចារណា "ផ្អែកតាមគោលការណ៍*ច្បាប់ពិសេស*"។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សំអាងហេតុថា ទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ គឺជាច្បាប់ទូទៅដែលដាក់ឱ្យអនុវត្តសម្រាប់តុលាការជាតិកម្ពុជាក៏ដោយ ក៏ច្បាប់ អ.វ.ត.ក. "ត្រូវបានតាក់តែងឡើងជាពិសេស សម្រាប់គោលបំណងពិសេសរបស់ អ.វ.ត.ក. តាមអាណត្តិ យុត្តាធិការ ចរិត និងរចនាសម្ព័ន្ធរបស់ខ្លួន"[1853]។

---

1849 សូមមើលផងដែរ ច្បាប់ អ.វ.ត.ក. មាត្រា ៣៨ ("ទណ្ឌកម្មទាំងអស់ដែលត្រូវយកមកដាក់ត្រូវកំណត់ត្រឹមទោសដាក់ពន្ធនាគារ")។

1850 សូមមើល ច្បាប់ អ.វ.ត.ក. មាត្រា ៣៣ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១២(២)។

1851 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៧៣។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល។

1852 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៤៥-៣៤៨។

1853 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៤៨។

អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុបន្ថែមទៀតថា ការបកស្រាយនេះត្រូវបានគាំទ្រដោយមាត្រា ៨ និង ៦៦៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ យោងតាមមាត្រា ៦៦៨ បទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្ត ក្នុងករណីដែលមានទំនាស់រវាងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត លើកលែងតែ "ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស"[1854]។ មាត្រា ៨ បញ្ជាក់ថា "ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា" គឺជា "បទល្មើសធ្ងន់ធ្ងរ" ដែលកំណត់ដោយ "ច្បាប់ដោយឡែក"[1855]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ច្បាប់ អ.វ.ត.ក. គឺជា "ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស" យោងតាមអត្ថន័យនៃមាត្រា ៦៦៨(៣) នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់លើ ទំនាស់រវាងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក. ដែលមិនកំហិត អ.វ.ត.ក. ក្នុងការប្រកាសទោសដាក់ពន្ធនាគារមានរយៈពេលកំណត់លើសពី ៣០ ឆ្នាំ ហើយមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលដកចេញនូវការប្រកាសទោសបែបនោះ។ ទោះជាយ៉ាងណា ដោយពិចារណាថា មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនអាចអនុវត្តបាននៅ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហា*ច្បាប់ដែលកំណត់ទោសស្រាលជាង* មិនអាចយកមកអនុវត្តបានឡើយ[1856]។

អង្គជំនុំជម្រះសាលាដំបូងបានបំភ្លឺថា ក្នុងករណីដែលពុំមានទ្រព្យសម្បត្តិពិតប្រាកដ ឬផ្ទាល់ខ្លួន ឬអចលនទ្រព្យនោះត្រូវបានកំណត់អត្តសញ្ញាណថា ទទួលបានដោយខុសច្បាប់ ឬដោយការប្រព្រឹត្តិអំពើឧក្រិដ្ឋនោះ មិនអាចជាកម្មវត្ថុនៃការរឹបអូសស្របតាមបទប្បញ្ញត្តិមាត្រា ៣៩ ថ្មី នៃច្បាប់ អ.វ.ត.ក. ឡើយ[1857]។

## ៦.២. គោលបំណងនៃការផ្តន្ទាទោស

ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. និងច្បាប់កម្ពុជា មិនចែងអំពីគោលដៅ ឬគោលបំណងនៃការផ្តន្ទាទោសទេ[1858]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការផ្តន្ទាទោសនៅ អ.វ.ត.ក. "ធ្វើឡើងក្នុងគោលបំណងឱ្យមានការញញើតទាំងជនជាប់ចោទ និងបុគ្គលទូទៅ និងការផ្តន្ទាទោសស្របតាមអំពើបានប្រព្រឹត្ត ដែលមិនមែនជាការសងសឹកនោះទេ"[1859]។ ក្រៅពីគោលបំណងនេះ អង្គជំនុំជម្រះសាលាដំបូងសំដៅលើ "ការរារាំងវិជ្ជមានជាទូទៅ និងជាលក្ខណៈបុគ្គល" ពោលគឺសារៈសំខាន់នៃការធានាដល់ជនរងគ្រោះដែលនៅរស់រានមានជីវិត ក្រុមគ្រួសាររបស់ពួកគេ សាក្សី និងសាធារណជន ថាច្បាប់ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងអនុវត្តចំពោះមនុស្សគ្រប់រូបដោយពុំគិតពីឋានៈ ឬតួនាទីឡើយ[1860]។ ការស្តារនីតិសម្បទាឡើងវិញមិនត្រូវបានចាត់ទុកថាជាគោលបំណងចម្បងនៃការផ្តន្ទាទោសទេ ប៉ុន្តែវាត្រូវបានទទួលស្គាល់ថាជាស្ថានសម្រាលទោស[1861]។

អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថាសាលាក្តី*មិនអចិន្ត្រៃយ៍* បានពិចារណាលើគោលបំណងនៃការផ្តន្ទាទោសខាងក្រោម៖ ការដាក់ទណ្ឌកម្ម ការទប់ស្កាត់ ការរារាំងជាវិជ្ជមាន ការថ្កោលទោសជាសាធារណៈ ការមាក់ងាយដោយសហគមន៍អន្តរជាតិ និងការស្តារនីតិសម្បទា[1862]។ អ.ជ.ត.ក. បានលើកឡើងពីការពន្យល់របស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") អំពីឃ្លា "ការរារាំងជាវិជ្ជមាន" ដូចខាងក្រោម៖

---

[1854] ដូចខាងលើ កថាខណ្ឌ ៣៤៩។ សូមមើលផងដែរ ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ៦៦៨។

[1855] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៥០។ សូមមើលផងដែរ ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ៨។

[1856] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៥១។

[1857] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១០៨។

[1858] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៨៣។

[1859] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៤៨។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៧។ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៨៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៧៩។

[1860] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៤៨។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៧៩។

[1861] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦១១។

[1862] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៨៥។

គោលបំណងសំខាន់បំផុតនៃការដាក់ទោស ដែលបានប្រកាសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថា ប្រព័ន្ធយុត្តិធម៌អន្តរជាតិត្រូវបានអនុវត្ត និងពង្រឹង។ គោលបំណងនៃការដាក់ទោសនេះគឺសំដៅទៅលើការអប់រំអំពីទោស និងធ្វើសារមួយថា គោលការណ៍ច្បាប់អន្តរជាតិស្តីពីមនុស្សធម៌ ត្រូវតែគោរពនៅគ្រប់កាលៈទេសៈ។ ក្នុងការធ្វើដូច្នេះ គោលការណ៍នៃការដាក់ទោសបានព្យាយាមដាក់បញ្ចូលគោលការណ៍ទាំងនេះ និងការទាមទារផ្នែកសីលធម៌តាមការចង់បានរបស់សាធារណជន[1863]។

ទាំងក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធ អំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការមើលស្រាលសារៈសំខាន់នៃការដាក់ទណ្ឌកម្ម និងការទប់ស្កាត់ជាលក្ខណៈបុគ្គល ក្នុងការកំណត់គោលការណ៍ស្តីពីការរារាំងជាវិជ្ជមាន រួមជាមួយនឹងគោលបំណងនៃដាក់ទណ្ឌកម្ម និងការទប់ស្កាត់។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា មិនមានសញ្ញាណបញ្ជាក់ថា ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលបំណងទាំងនេះ បង្កើតបានជាការបង្ហាញពីភាពលម្អៀង ប្រឆាំងនឹងជនជាប់ចោទនោះទេ[1864]។

អង្គជំនុំជម្រះសាលាដំបូងពិចារណាថា ទោះបីជាមុខងារជាក់ស្តែងនៃការផ្តន្ទាទោសគឺត្រូវដាក់ទណ្ឌកម្មយ៉ាងណាក្តី ក៏គោលដៅរបស់វា គឺពុំមែនជាការសងសឹកនោះទេ[1865]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា "ការដាក់ទោសដែលសមនឹងទទួល និងការធ្វើឱ្យរាងចាល" ពាក់ព័ន្ធជាពិសេសទៅនឹងសំណុំរឿង ០០១ ដោយសារស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ ឌុច ដោយបានសម្រេចថាទណ្ឌកម្ម "ត្រូវតែធ្ងន់គ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងដើម្បីទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មបែបនេះកើតឡើងជាថ្មីទៀត"[1866]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាពចាំបាច់នៃការធ្វើឱ្យរាងចាល ក្នុងការដាក់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ទាមទារឱ្យមានសេចក្តីថ្លែងការណ៍មួយដែលថា ទោះបីជាពេលវេលាកន្លងទៅ ក៏មិនអាចនាំឱ្យមាននិទណ្ឌភាព និងការដាក់ទោសស្រាលដែលមិនត្រឹមត្រូវនោះដែរ"[1867]។

## ៦.៣. គោលការណ៍ និង កត្តានានានៃការផ្តន្ទាទោស

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុង "មិនមានចែងអំពីគោលការណ៍ និងកត្តានានាដែលត្រូវយកមកពិចារណានៅពេលធ្វើការផ្តន្ទាទោសឡើយ"។ ពួកវាក៏មិនបានបញ្ជាក់ថាតើ ការផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក. ត្រូវ "អនុវត្តតាមបទដ្ឋានគតិយុត្តិជាតិ ឬអន្តរជាតិ ឬក៏ត្រូវរួមបញ្ចូលគ្នានៃបទដ្ឋានគតិយុត្តិទាំងពីរនេះ" ឬយ៉ាងណា។ ជាងនេះទៀត មិនមាន "របបនៃការផ្តន្ទាទោសអន្តរជាតិតែមួយដែលអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក." បានទេ ដោយសារមិនមានការឯកភាពគ្នាលើវិធីសាស្ត្រផ្តន្ទាទោសនៅចំពោះមុខសាលាក្តីផ្សេងៗទៀត[1868]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកំណត់ទោសសមស្របមួយ ដោយស្វែងរកការណែនាំពីគោលការណ៍ និងកត្តានានាដែលពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលរួមមាន៖ (១) គោលការណ៍នីត្យានុកូលភាព (២) គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ គោលការណ៍សមាមាត្រ និងគោលការណ៍ឯកត្តកម្មទោស (៣) ស្ថានទម្ងន់នៃបទឧក្រិដ្ឋ និងការចូលរួមរបស់ជនជាប់ចោទ (៤) ស្ថានសម្រាលទោស និង (៥) ស្ថានទម្ងន់ទោស[1869]។

### ៦.៣.១. គោលការណ៍នីត្យានុកូលភាព

គោលការណ៍នីត្យានុកូលភាពតម្រូវថា បទឧក្រិដ្ឋដែលមានអត្ថិភាពចំពោះមុខច្បាប់ជាធរមាន នៅមុនពេលអំពើដែលរងការចោទប្រកាន់នោះត្រូវបានធ្វើឡើង (*គ្មានបទល្មើសបើគ្មានច្បាប់ចែង*) និងថាទោស

---

[1863] ដូចខាងលើ កថាខណ្ឌ ១៩៨៤ (យោងខាងក្នុងត្រូវបានលុបចេញ)។
[1864] ដូចខាងលើ កថាខណ្ឌ ២០៤៦។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១០។
[1865] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨០។
[1866] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៨០។
[1867] ដូចខាងលើ កថាខណ្ឌ ៣៨០។
[1868] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៧៥-៥៧៦។
[1869] ដូចខាងលើ កថាខណ្ឌ ៥៧៨-៥៨៥។

សម្រាប់បទឧក្រិដ្ឋទាំងនោះត្រូវបានធ្វើឡើងមុនពេលការប្រព្រឹត្តបទឧក្រិដ្ឋរបស់ពួកវា (*គ្មានទោសបើគ្មានច្បាប់ចែង*)[1870]។ គោលបំណងនៃលក្ខខណ្ឌតម្រូវនេះ គឺដើម្បីធានានូវភាពជាក់លាក់ក្នុងកម្រិតអប្បបរមាទាក់ទងទៅនឹងការដាក់ទោស និងការយល់ដឹងអំពីទោស ប្រសិនបើត្រូវបានដាក់ពិរុទ្ធភាព។ នីត្យានុកូលភាពក៏តម្រូវដែរថា ប្រសិនបើច្បាប់បច្ចុប្បន្នដាក់ទោសស្រាលជាងច្បាប់ដែលមានអត្ថិភាពនៅខណៈពេលប្រព្រឹត្តបទល្មើសនោះ ត្រូវអនុវត្តទោសស្រាលជាង (*គោលការណ៍អនុវត្តទោសស្រាលជាង*)[1871]។ គោលការណ៍នីត្យានុកូលភាពនេះ គឺជាផ្នែកមួយនៃច្បាប់ជាតិកម្ពុជា និងច្បាប់អន្តរជាតិ មុនឆ្នាំ១៩៧៥ ដល់១៩៧៩[1872]។

អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ទោះបីជាទោសម្រាប់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវបានចែងច្បាស់នៅក្នុងច្បាប់ជាតិកម្ពុជាក៏ដោយ ក៏គោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* មិនត្រូវបានរំលោភឡើយ[1873]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម មិនមែនជាផ្នែកមួយនៃច្បាប់កម្ពុជានៅមុនឆ្នាំ១៩៧៥ ក៏ដោយ ក៏បទឧក្រិដ្ឋទាំងអស់នេះមានអត្ថិភាពក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយមាត្រា ២១ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងអំពីការដាក់ទោសព្រហ្មទណ្ឌចំពោះការធ្វើឱ្យស្លាប់ ឬការបង្ខំឱ្យធ្វើការ "ពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត"[1874]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានពិចារណាលើគោលការណ៍ II នៃគោលការណ៍ Nuremberg ដែលចែងថា "ការណ៍ដែលច្បាប់ក្នុងស្រុកពុំបានដាក់ទោសលើអំពើដែលជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ពុំអាចឱ្យបុគ្គលដែលបានប្រព្រឹត្តអំពើនោះរួចផុតពីការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិឡើយ" និងយុត្តិសាស្ត្រនៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECtHR") ដែលសម្រេចថា "ច្បាប់" សម្រាប់គោលបំណងនៃនីត្យានុកូលភាព បានរួមបញ្ចូលទាំង "ច្បាប់ដែលពុំត្រូវបានចែងជាលាយលក្ខណ៍អក្សរ"[1875]។

### ៦.៣.២. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ គោលការណ៍សមាមាត្រ និងគោលការណ៍ឯកត្តកម្មទោស

គោលការណ៍សមភាពតម្រូវថា ការដាក់ទោសគប្បីត្រូវដាក់ឱ្យទទួលខុសត្រូវស្មើភាពគ្នា[1876]។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"[1877]។ ស្រដៀងគ្នានេះដែរ វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង តម្រូវថា "បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត"។

គោលការណ៍សមាមាត្រក្នុងការដាក់ទោស ដែលជាគោលការណ៍មូលដ្ឋានក្នុងច្បាប់ស្តីពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ តម្រូវឱ្យការដាក់ទោសត្រូវមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងស្ថានភាពរបស់ជនជាប់ចោទ[1878]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា បើទោះបីជាទោសណាមួយអាចមិនច្បាស់លាស់ ឬធ្ងន់ធ្ងរហួសហេតុ ប្រសិនបើពុំមានសមាមាត្រនៃទោសដែលត្រូវបានដាក់នៅក្នុងកាលៈទេសៈស្រដៀងគ្នាសម្រាប់បទល្មើសតែមួយដូចគ្នាក៏ដោយ ក៏គោលការណ៍ណែនាំដែលបានផ្តល់តាមរយៈការដាក់ទោស ដែលបានធ្វើឡើងដោយតុលាការផ្សេងទៀតនោះ មានកម្រិតតិចតួច។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា ការប្រៀបធៀបបែបនេះតម្រូវថា បទល្មើសមានលក្ខណៈដូចគ្នា និងត្រូវបានប្រព្រឹត្តឡើងក្នុងកាលៈទេសៈស្រដៀងគ្នា នៅក្នុងសាលា

1870 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៨៧។
1871 ដូចខាងលើ កថាខណ្ឌ ១៩៨៧ និង ១៩៩៣។
1872 ដូចខាងលើ កថាខណ្ឌ ១៩៨៧។
1873 ដូចខាងលើ កថាខណ្ឌ ១៩៩២។
1874 ដូចខាងលើ កថាខណ្ឌ ១៩៨៨។
1875 ដូចខាងលើ កថាខណ្ឌ ១៩៨៨ និង ១៩៩០។
1876 ដូចខាងលើ កថាខណ្ឌ ១៩៩៤។
1877 ដូចខាងលើ។
1878 ដូចខាងលើ កថាខណ្ឌ ១៩៩៥។

ក្តីផ្សេងទៀត។ ជាលទ្ធផល ការដាក់ទោសផ្សេងគ្នាអាចត្រូវបានផ្តល់យុត្តិកម្ម នៅពេលដែលមានលក្ខណៈខុសប្លែកគ្នាខ្លាំងជាងលក្ខណៈស្រដៀងគ្នា ឬនៅពេលដែលស្ថានសម្រាលទោស និងស្ថានទម្ងន់ទោសខុសប្លែកគ្នា[1879]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ការអនុវត្តការផ្តន្ទាទោសរបស់សាលាក្តីផ្សេងទៀត ក្នុងរឿងក្តីដែលពាក់ព័ន្ធនឹងកាលៈទេសៈស្រដៀងគ្នាគឺគ្រាន់តែជា "កត្តាមួយដែលអង្គជំនុំជម្រះត្រូវតែពិចារណានៅពេលប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការដាក់ទោស"[1880]។

គោលការណ៍ឯកត្តកម្មនៃទោសនៅ អ.វ.ត.ក. តម្រូវថា កាលៈទេសៈជាបុគ្គលរបស់អ្នកដែលត្រូវដាក់ពិរុទ្ធ ត្រូវតែបានពិចារណានៅក្នុងអំឡុងពេលដាក់ទោស[1881]។ មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌចែងថា "តុលាការប្រកាសទោសដោយផ្អែកលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ"[1882]។

អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា គោលការណ៍ទាំងនេះ បង្ហាញអំពីយុត្តិសាស្ត្រនៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍*។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតមើលរបៀបដែលអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី *មិនអចិន្ត្រៃយ៍* ដែលបានកំណត់ទោស ដោយពិចារណាលើកាលៈទេសៈទាំងមូល "រួមទាំងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងស្ថានភាពជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ ប៉ុន្តែពុំបានសំដៅទៅលើកម្រិតនៃទោសដែលត្រូវបានកំណត់ជាមុនដោយកត្តាខាងក្រៅ ឬស្ថានទម្ងន់ទោស និងសម្រាលទោសដែលត្រូវបានកំណត់ជាមុននោះឡើយ"[1883]។ ចំណុចនេះខុសពីចក្រភពអង់គ្លេស ដែលគោលការណ៍ណែនាំបញ្ជាក់អំពីទោសសមស្របសម្រាប់បទល្មើសនីមួយៗ តែចំណុចនេះមានលក្ខណៈស្រដៀងគ្នាជាងទៅនឹងការអនុវត្តក្នុងប្រទេសបារាំង ដែលចៅក្រមពុំប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការដាក់ទោសឡើយ[1884]។

### ៦.៣.៣. ស្ថានទម្ងន់នៃបទឧក្រិដ្ឋ និងការចូលរួមរបស់ជនជាប់ចោទ

អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងយ៉ាងស៊ីចង្វាក់គ្នាថា កត្តាចម្បងដែលត្រូវថ្លឹងថ្លែងក្នុងការដាក់ទោសគឺ "ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ កាលៈទេសៈពិសេសនៃរឿងក្តី បូករួមជាមួយនឹងទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទ"[1885]។ កត្តាដែលត្រូវពិចារណាពាក់ព័ន្ធបញ្ហានេះរួមបញ្ចូល៖

i. ចំនួន និងភាពងាយរងគ្រោះរបស់ជនរងគ្រោះ
ii. ផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើជនរងគ្រោះ និងសាច់ញាត្តិរបស់ពួកគេ
iii. ចេតនារើសអើងរបស់ជនជាប់ចោទនៅពេលពុំទាន់ក្លាយជាធាតុផ្សំនៃបទឧក្រិដ្ឋ
iv. ទំហំ និងភាពសាហាវឃោរឃៅនៃបទល្មើស និង
v. តួនាទីរបស់ជនជាប់ចោទ[1886]។

សាលាក្តីអន្តរជាតិសម្រេចផ្តន្ទាទោសកម្រិតខ្ពស់បំផុត ចំពោះរឿងក្តីដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរពិសេស និងបានប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងរឿងក្តីដែលពិរុទ្ធ

---

[1879] ដូចខាងលើ កថាខណ្ឌ ១៩៩៦។
[1880] ដូចខាងលើ។
[1881] ដូចខាងលើ កថាខណ្ឌ ១៩៩៧ និង ២០០៣។
[1882] ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ៩៦។
[1883] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៩៩៩។
[1884] ដូចខាងលើ កថាខណ្ឌ ២០០០។
[1885] ដូចខាងលើ កថាខណ្ឌ ២០០៤។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១៨។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៥។
[1886] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០០៤។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១៨។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៥។

ជនបានរំលោភលើមុខតំណែងដឹកនាំតាមរយៈការរៀបចំផែនការ ឬបញ្ជាឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬតាមរយៈការបង្ហាញអំពីភាពឃោរឃៅ ឬការបំពេញភារកិច្ចរបស់ខ្លួនដោយពេញចិត្ត[1887]។

អង្គជំនុំជម្រះសាលាដំបូងបានពន្យល់យ៉ាងស៊ីចង្វាក់គ្នាពីរបៀបដែល ស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង គឺជា "លក្ខណៈវិនិច្ឆ័យសំខាន់សម្រាប់សម្រេចអំពីទោសឱ្យបានសមស្រប" ដែលតម្រូវឱ្យ "ពិចារណាអំពីកាលៈទេសៈពិសេសនៃរឿងក្ដី" ព្រមទាំងទម្រង់ និងកម្រិតនៃការចូលរួម" របស់ពិរុទ្ធជននៅក្នុងបទឧក្រិដ្ឋនោះ[1888]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា វិធាន ១៤៥(១)(គ) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC ចែងស្រដៀងគ្នាថា៖

> ត្រូវពិចារណាអំពីទំហំនៃព្យសនកម្មដែលបង្កឡើង ជាពិសេសព្យសនកម្មដែលបង្កឡើងចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគេ លក្ខខណ្ឌនៃអាកប្បកិរិយាខុសច្បាប់ និងវិធីដែលត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ។ ត្រូវពិចារណាអំពីកម្រិតនៃការចូលរួមរបស់ពិរុទ្ធជន កម្រិតនៃចេតនា សភាពលក្ខណៈផ្លូវចិត្ត ពេលវេលានិងទីកន្លែង និងអាយុ ចំណេះដឹង ស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ពិរុទ្ធជន[1889]។

### ៦.៣.៤. ស្ថានសម្រាលទោស

ក្នុងការកំណត់និយមន័យស្ថានសម្រាលទោសសម្រាប់គោលបំណងនៃការប្រកាសទោស អ.វ.ត.ក. បានអនុម័តកត្តានានា ដែលមានចែងក្នុងវិធាន ១៤៥(២)(ក) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC៖ (១) "កាលៈទេសៈដែលពុំគ្រប់គ្រាន់ធ្វើជាមូលដ្ឋានសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដូចជាសមត្ថភាពផ្នែកស្មារតីចុះខ្សោយខ្លាំង ឬស្ថិតក្រោមការគំរាមកំហែង" និង (២) "ឥរិយាបថរបស់ជនជាប់ចោទក្រោយពីការប្រព្រឹត្តិនោះ រួមទាំងការខិតខំប្រឹងប្រែងរបស់ខ្លួនសងសំណងជនរងគ្រោះ និងកិច្ចសហការណាមួយជាមួយតុលាការ"[1890]។ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា ស្ថានសម្រាលទោសក៏អាចរួមបញ្ចូល៖

i. ទង្វើល្អក្នុងអំឡុងពេលនៃការប្រព្រឹត្តិបទឧក្រិដ្ឋ (ឧទាហរណ៍ ថាតើ ទណ្ឌិតព្យាយាមរារាំងបទល្មើស ប៉ុន្តែត្រូវបានបង្ខំឱ្យចូលរួម ឬថាតើ គាត់បានជួយដល់ជនរងគ្រោះ)
ii. ទង្វើល្អនៅក្នុងមន្ទីរឃុំឃាំងនៃអង្គការសហប្រជាជាតិ
iii. ការប្រគល់ខ្លួនដោយស្ម័គ្រចិត្ត (ខុសពីការលាក់ខ្លួន ឬគេចវេះពីយុត្តិធម៌)
iv. របាយការណ៍ជាប់ទោសពីមុនពាក់ព័ន្ធទៅនឹងការចោទប្រកាន់បទឧក្រិដ្ឋសង្គ្រាមអន្តរជាតិ
v. កិច្ចសហការសំខាន់ជាមួយអយ្យការ
vi. អាយុ និងលក្ខខណ្ឌសុខភាព
vii. ការសម្ដែងវិប្បដិសារី
viii. ការទទួលកំហុស និងឆន្ទៈរបស់គាត់ក្នុងការប្រាប់ការពិត (ប្រសិនបើគាត់ពិតជាទទួលកំហុស)
ix. រយៈពេលដែលស្ថិតក្នុងការឃុំឃាំងមុនការជំនុំជម្រះ (លើកលែងតែគាត់បានអូសបន្លាយដោយចេតនា) និង
x. ស្ថានភាពគ្រួសាររបស់គាត់[1891]។

---

[1887] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៥។
[1888] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨២។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៤៩។
[1889] សូមមើល សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨២។
[1890] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០០៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៩-១០៧០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៤។
[1891] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០០៧។

ទណ្ឌិតមានបន្ទុកក្នុងការបង្ហាញពីស្ថានសម្រាលទោស[1892]។ បន្ទុកនេះមានកម្រិតទាបជាងបន្ទុករបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញពីស្ថានទម្ងន់ទោស។ ខុសពីស្ថានទម្ងន់ទោស ស្ថានសម្រាលទោសអាចត្រូវបានពិចារណា ដោយមិនគិតថាតើស្ថានសម្រាលទោសទាំងនោះពាក់ព័ន្ធផ្ទាល់ទៅនឹងបទល្មើសដែលត្រូវបានចោទប្រកាន់ដែរ ឬយ៉ាងណានោះទេ[1893]។

បរិយាកាសគាបសង្កត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានពិចារណាថាជាស្ថានសម្រាលទោសមួយក្នុងការសម្រេចអំពីទោស ប៉ុន្តែ "ក្នុងកម្រិតតិចតួច" ប៉ុណ្ណោះ[1894]។ សនិទានភាពស្នូលនៃ "បរិយាកាសគាបសង្កត់" ដែលជាស្ថានសម្រាល ត្រូវបានរួមចំណែកដោយកត្តាបង្ខិតបង្ខំ ទោះក្នុងកម្រិតតិចតួចក៏ដោយ "ក៏ការផ្តន្ទាទោសគប្បីធ្វើឡើងឱ្យសមស្របទៅនឹងលទ្ធភាពដែលមានតិចតួចរបស់ [ទណ្ឌិត] ក្នុងការជ្រើសរើសយកជម្រើសផ្សេង ដែលមានលក្ខណៈសីលធម៌ ដោយហេតុថាការបដិសេធក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ នឹងនាំទៅដល់ការគំរាមកំហែងដល់អាយុជីវិតរបស់[ទណ្ឌិត]"[1895]។ ការខកខានរបស់ទណ្ឌិតក្នុងការបង្ហាញថា ខ្លួនមិនមានជម្រើសអ្វីក្រៅពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬថាខ្លួនបានទទួលការគំរាមកំហែងផ្ទាល់ខ្លួន ឬថាខ្លួនបានព្យាយាមក្នុងការផ្តាច់ខ្លួនចេញពីអំពើឧក្រិដ្ឋ នាំឱ្យស្ថានសម្រាលទោសផ្អែកលើមូលដ្ឋាននេះមានកម្រិតអប្បបរមា[1896]។

អ្នកក្រោមបង្គាប់ដែលបានបង្ហាញពីអត្ថិភាពនៃបញ្ជារបស់ថ្នាក់លើអាច "នឹងទទួលការផ្តន្ទាទោសក្នុងកម្រិតស្រាលបានតែនៅក្នុងករណីដែលបង្ហាញច្បាស់ថា បញ្ជារបស់ថ្នាក់លើពិតជាអាចកាត់បន្ថយកម្រិតនៃពិរុទ្ធភាព"[1897]។ ទោះជាយ៉ាងណា ប្រសិនបើទណ្ឌិតបានដឹងថាបញ្ជានោះខុសច្បាប់ និងមិនមានការគំរាមកំហែងដែលនាំទៅដល់ការបង្ខិតបង្ខំទេនោះ នឹងពុំមានអានុភាពនៃស្ថានសម្រាលទោសឡើយ[1898]។ អានុភាពសម្រាលទោសនៃឋានៈរបស់ថ្នាក់ក្រោម ត្រូវតែវាយតម្លៃផ្អែកលើបញ្ជាដែលបានទទួលពីថ្នាក់លើ[1899]។ មិនមានវិធានណានៅ អ.វ.ត.ក. ដែលថាទោសខ្ពស់បំផុតត្រូវបានត្រៀមសម្រាប់បុគ្គលនៅថ្នាក់កំពូលនៃខ្សែចង្វាក់នៃការបញ្ជានោះទេ ហើយអង្គហេតុដែលថាទណ្ឌិតមិនស្ថិតនៅថ្នាក់កំពូលនៃខ្សែចង្វាក់នៃការបញ្ជានេះ មិនផ្តល់យុត្តិកម្មដល់ការដាក់ទោសមានលក្ខណៈស្រាលជាងនោះទេ[1900]។

ការសម្តែងពីវិប្បដិសារីអាចជាស្ថានសម្រាលទោស ដរាបណាការសម្តែងពីវិប្បដិសារីទាំងនោះមានលក្ខណៈ "ស្មោះត្រង់ និងពិតប្រាកដ"[1901]។ ការសម្តែងនូវវិប្បដិសារីនេះតម្រូវឱ្យមានការទទួលខុសត្រូវខាងផ្នែកសីលធម៌ចំពោះកំហុសរបស់ខ្លួន មិនមែនគ្រាន់តែសោកស្តាយអំពីការចូលរួមក្នុងបទឧក្រិដ្ឋនោះប៉ុណ្ណោះទេ។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា "ទម្ងន់" ដែលគប្បីផ្តល់ឱ្យចំពោះការសម្តែងវិប្បដិសារីដែលជាស្ថានសម្រាលទោសនោះ "មានកម្រិតតិចតួចប៉ុណ្ណោះ" ដោយសង្កេតឃើញថា ឌុច បានចំណាយពេលស្ទើរតែទាំងស្រុងដែលបានផ្តល់ឱ្យគាត់ សម្រាប់ធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយ ក្នុងការស្វែងរកឱ្យមានការបន្ថយការទទួលខុសត្រូវរបស់ខ្លួន តាមរយៈការទម្លាក់ការទទួលខុសត្រូវទៅ "មេដឹកនាំជាន់ខ្ពស់"[1902]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានសន្និដ្ឋានស្រដៀងគ្នាថា អានុភាពស្ថានសម្រាលទោសនៃវិប្បដិសារីរបស់ ឌុច ត្រូវបានប៉ះពាល់ដោយការខកខានរបស់គាត់ ក្នុងការផ្តល់នូវការទទួលស្គាល់ការទទួលខុសរបស់គាត់ឱ្យបានពេញលេញ និងគ្មានលក្ខខណ្ឌ[1903]។ ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការសុំទោសរបស់ នួន ជា ត្រូវបានប៉ះ

---

[1892] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៤។
[1893] ដូចខាងលើ កថាខណ្ឌ ៥៨៤។
[1894] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៦៤។
[1895] ដូចខាងលើ។
[1896] ដូចខាងលើ។
[1897] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦០៧។
[1898] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៦៥។
[1899] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៦៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦០៧។
[1900] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៧។
[1901] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៩៣។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦១០។
[1902] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៦៩។
[1903] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦១០។

ពាល់ដោយការខកខានរបស់គាត់ ក្នុងការទទួលស្គាល់ការទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន[1904]។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្ដីទាំងពីរ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខៀវ សំផន មិនបានបង្ហាញការសោកស្ដាយណាមួយ ឬ សេចក្ដីអាណិតអាសូរចំពោះជនរងគ្រោះ ឬទទួលស្គាល់ការទទួលខុសត្រូវចំពោះហេតុការណ៍ណាមួយ ដែលអាចជាយុត្តិកម្មសម្រាប់សម្រាលដល់ការផ្ដន្ទាទោសរបស់គាត់នោះទេ[1905]។ ទង្វើដែលចាត់ទុកថាជាកិច្ចសហការ រួមមាន ការបំភ្លឺអំពីភាពមន្ទិលសង្ស័យនៃការស៊ើបអង្កេត ការផ្ដល់ព័ត៌មានអំពីបទឧក្រិដ្ឋដែលពុំបានដឹងពីមុនដល់ព្រះរាជអាជ្ញា ការទទួលស្គាល់អង្គហេតុ ការជួយសម្រួលដល់កិច្ចប្រតិបត្តិការដែលនាំទៅដល់ការចាប់ខ្លួនជនសង្ស័យដទៃទៀត និងការយល់ព្រមផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត[1906]។ កត្តានានាទាក់ទងទៅនឹងភាពគ្រប់គ្រាន់នៃកិច្ចសហការរួមមាន ការបង្ហាញពីទិដ្ឋភាពពេញលេញនៃការយល់ដឹងអំពីអង្គហេតុ កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយជាអតិបរមានូវតួនាទីរបស់ខ្លួន ការគេចវេះក្នុងការឆ្លើយតបដោយពេញលេញនៅពេលប្រឈមនឹងការចោទប្រកាន់អំពីការចូលរួមដោយផ្ទាល់របស់ខ្លួន ការព្យាយាមទម្លាក់ការទទួលខុសត្រូវទៅលើអ្នកដទៃ និងការធ្វើសេចក្ដីថ្លែងការណ៍ដែលមិនស៊ីចង្វាក់ជាមួយនឹងភ័ស្តុតាងដែលមាន[1907]។ ក្នុងករណីដែលកិច្ចសហការខកខានមិនបានផ្ដល់ព័ត៌មានសំខាន់ៗ ទោះក្នុងបរិមាណ ឬគុណភាព កិច្ចសហការនោះទទួលបានទម្ងន់តិចតួចបំផុត[1908]។ ស្រដៀងគ្នានេះដែរ កិច្ចសហការដែលមានរយៈពេលខ្លី ផ្ដល់តម្លៃជាស្ថានសម្រាលទោសតិចតួចបំផុត[1909]។ ការដែលគ្រាន់តែចូលរួមក្នុងគ្រប់សវនាការទាំងអស់ ដែលមិនលើសពីលក្ខខណ្ឌតម្រូវអប្បបរមាតាមផ្លូវច្បាប់នោះ មិនអាចចាត់ទុកថាជាកិច្ចសហការដែលជាស្ថានសម្រាលទោសឡើយ[1910]។ អង្គហេតុដែលថា ទណ្ឌិតបានផ្ដល់សក្ខីកម្មអំពីសាវតារផ្ទាល់របស់ខ្លួន និងបានឆ្លើយសំណួរនានាដែលចោទសួរដោយដើមបណ្ដឹងរដ្ឋប្បវេណី ទោះជាមាន "ឥទ្ធិពលខ្លះនៅក្នុងការជួយសម្រួលដល់ការផ្សះផ្សា" ត្រូវបានផ្ដល់ "តម្លៃតិចតួចបំផុត [...] ជាស្ថានសម្រាលទោស"[1911]។

លទ្ធភាពនៃការស្ដារនីតិសម្បទារបស់ទណ្ឌិត ក៏ត្រូវបានពិចារណានៅ អ.វ.ត.ក. ផងដែរ ទោះបីជាត្រូវបានផ្ដល់តម្លៃតិចតួចក៏ដោយ។ ទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល បានផ្អែកលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ដែលសម្រេចថា ការស្ដារនីតិសម្បទាពុំគួរផ្ដល់តម្លៃច្រើនហួសហេតុនោះទេ[1912]។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធ ក្នុងការពិចារណាលើបញ្ហាសុខភាពថាជាស្ថានសម្រាលទោស ដោយយល់ឃើញថាបញ្ហានេះ "អាចត្រូវបានពិចារណាថាជាស្ថានសម្រាល តែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ"។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថាវ័យចាស់ គឺជាស្ថានសម្រាលទោសដែលពាក់ព័ន្ធក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់តម្លៃតិចតួចបំផុតចំពោះស្ថានសម្រាលនេះ ក្នុងសំណុំរឿង ០០២/០១[1913]។

សក្ខីកម្មទាក់ទងនឹងអត្តចរិតល្អរបស់ទណ្ឌិត និងសកម្មភាពនៅមុនពេល និងក្រោយពេលបទឧក្រិដ្ឋដែលបានចោទប្រកាន់ អាចទទួលយកបាននៅ អ.វ.ត.ក. និងត្រូវបានពិចារណាសម្រាប់គោលបំណងនៃការផ្ដន្ទាទោស[1914]។ សក្ខីកម្មដែលថាទណ្ឌិតប្រព្រឹត្តល្អមកលើភរិយារបស់ខ្លួន ឬមានសណ្ដានចិត្តល្អចំពោះប្រជាជនក្នុងករណីមួយចំនួន មិនបានដើរតួនាទីសំខាន់នៅក្នុងការសម្រាលទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះទេ

---

[1904] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៩៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៩៣។

[1905] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៩៦។

[1906] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៦៦។

[1907] ដូចខាងលើ កថាខណ្ឌ ៣៦៨។

[1908] ដូចខាងលើ។

[1909] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៩៤។

[1910] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៩៧។

[1911] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៩៧។

[1912] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧០។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦១១។

[1913] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៩៥។

[1914] សូមមើល សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៩៩-១១០៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦១៧-៦២២។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៩៩។

ហើយត្រូវបានផ្តល់តម្លៃតិចតួចជាស្ថានសម្រាលនៅក្នុងការសម្រេចអំពីទោស[1915]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ យល់ថាពុំមានកំហុសណាមួយនៅក្នុងសេចក្តីពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងស្តីពីអត្តចរិតរបស់ ខៀវ សំផន នោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផ្ទុយគ្នា ដោយសារអង្គជំនុំជម្រះសាលាដំបូងបាននិយាយអំពី "អត្តចរិតល្អ" របស់ ខៀវ សំផន ខណៈដែលនៅកន្លែងផ្សេងទៀតនៅក្នុងសាលក្រមយល់ឃើញថាអត្តចរិតរបស់គាត់ "គួរឱ្យទុកចិត្ត និងគួរឱ្យគោរព"។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាពុំមានភាពផ្ទុយគ្នានោះឡើយ ដោយពិចារណាថា "បុគ្គលម្នាក់គួរឱ្យទុកចិត្ត និងគួរឱ្យគោរព ប៉ុន្តែមិនធានាថា មានអត្តចរិតល្អនោះទេ"[1916]។

### ៦.៣.៥. ស្ថានទម្ងន់ទោស

ក្នុងការកំណត់និយមន័យស្ថានទម្ងន់ទោស អ.វ.ត.ក. បានអនុម័តកត្តានានាដែលមានចែងក្នុងវិធាន ១៤៥(២)(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC៖

i. ការផ្តន្ទាទោសលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តពីពេលមុន ដែលឧក្រិដ្ឋកម្មទាំងនោះស្ថិតក្រោមយុត្តាធិការរបស់តុលាការ ឬមានលក្ខណៈស្រដៀងគ្នា
ii. ការរំលោភអំណាច ឬសមត្ថកិច្ចផ្លូវការ
iii. ការប្រព្រឹត្តបទល្មើសដែលជនរងគ្រោះមិនអាចការពារខ្លួនបាន
iv. ការប្រព្រឹត្តបទល្មើសយ៉ាងសាហាវឃោរឃៅ ឬមានជនរងគ្រោះច្រើន
v. ការប្រព្រឹត្តបទល្មើសដោយសារមានការជំរុញចិត្ត ដែលពាក់ព័ន្ធការរើសអើង ដោយសារមូលហេតុខាងក្រោម៖ ភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗ ជាតិសាសន៍ដើម ជាតិពន្ធុដើម ឬសង្គមដើម ទ្រព្យសម្បត្តិ កំណើត ឬវណ្ណៈផ្សេងៗទៀត
vi. ស្ថានភាពផ្សេងៗទៀត បើទោះបីជាមិនមានចែងខាងលើ ប៉ុន្តែអាស្រ័យតាមលក្ខណៈរបស់វា គឺស្រដៀងគ្នានឹងអ្វីដែលមានចែងដែរ[1917]។

ក្រៅពីនេះ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ទោះបីជាវិធាននីតិវិធី និងភស្តុតាងរបស់សាលាក្តី *មិនអចិន្ត្រៃយ៍* មិនបានបញ្ជាក់ពីស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស ក៏យុត្តិសាស្ត្រស្តីពីស្ថានទម្ងន់ទោសរួមមាន៖

i. កម្រិតនៃការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទ ជាចារីផ្ទាល់ ឬជាអ្នកសហការ ឬអ្នកជួយទំនុកបម្រុង
ii. តួនាទីដោយស្ម័គ្រចិត្ត ដោយឆន្ទៈ ឬគាំទ្រការប្រព្រឹត្តិឧក្រិដ្ឋកម្ម
iii. ឋានៈ ឬមុខនាទីរបស់ទណ្ឌិត
iv. ចំនួន និងភាពងាយទទួលរងគ្រោះរបស់ជនរងគ្រោះ និងផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើពួកគេ
v. ទំហំ និងរយៈពេលនៃអំពើល្មើស
vi. ការមិនអើពើលើផលវិបាក អំពើឃោរឃៅ ឬអំពើសាហាវយង់ឃ្នងនៃបទឧក្រិដ្ឋ
vii. កម្រិតនៃការគិតទុកជាមុននៃបទល្មើស និង
viii. ចេតនានៃការរើសអើងដែលចារីបានប្រព្រឹត្តឡើង[1918]។

---

[1915] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១០៣។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥៤។
[1916] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១០៣។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១៥។
[1917] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៣។
[1918] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០០៦។

សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញពីស្ថានទម្ងន់ទោស ក្រោមបទដ្ឋានដូចគ្នាដែលត្រូវការសម្រាប់ការដាក់ពិរុទ្ធភាពណាមួយ៖ ពោលគឺ ហួសពីវិមតិសង្ស័យ[1919]។ មានតែកត្តាទាំងឡាយណាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការប្រព្រឹត្តបទល្មើស ដែលមានការដាក់ពិរុទ្ធភាពតែប៉ុណ្ណោះ ដែលអាចត្រូវបានពិចារណាជាស្ថានទម្ងន់។ អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិដែលបានបង្កើត ការសម្រេចចិត្តរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតប ក្នុងអំឡុងពេលសវនាការ មិនត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ទោសនោះទេ[1920]។

នៅពេលដែលកត្តាជាក់លាក់ណាមួយគឺជាធាតុផ្សំនៃបទល្មើសជាមូលដ្ឋាន វាមិនអាចត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ទោសនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា "ការគិតបញ្ចូលពីរដង" បែបនេះ ស្មើនឹងកំហុសអង្គច្បាប់[1921]។ ជាងនេះទៀត អង្គហេតុដដែលមិនអាចត្រូវបានប្រើដើម្បីបង្ហាញពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋផង និងជាស្ថានទម្ងន់ទោសផងនោះបានទេ[1922]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើ វាមានលក្ខណៈសមស្របជាង ក្នុងការពិចារណាលើកត្តាមួយចំនួនថាបានចូលរួមចំណែកដល់ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ឬជាស្ថានទម្ងន់ទោសដែរ ឬយ៉ាងណា[1923]។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ភាពងាយរងគ្រោះនៃជនរងគ្រោះមានភាពសមស្របជាងសម្រាប់ការពិចារណាលើស្ថានទម្ងន់ទោស ជាជាងជាការចូលរួមចំណែកដល់ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ[1924]។

តួនាទី ឬឋានៈខ្ពស់នៅក្នុងថ្នាក់ដឹកនាំ *ជាធម្មតា* ពុំអាចជាស្ថានទម្ងន់ទោសបានឡើយ[1925]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការពិចារណា៖ "ឋានៈខ្ពស់ តួនាទីក្នុងរដ្ឋអំណាច ឬតួនាទីជាថ្នាក់ដឹកនាំ" ជាស្ថានទម្ងន់ទោសបាន[1926]។ អ្វីដែលសំខាន់គឺ ថាតើសិទ្ធិអំណាចនេះត្រូវបានប្រើប្រាស់ក្នុងលក្ខណៈបែបណាខ្លះ។ ដូច្នេះ បើទោះជាតួនាទីផ្លូវការនេះជាទូទៅមិនមែនជាស្ថានទម្ងន់ទោសក៏ដោយ ក៏ការរំលោភលើតួនាទីអាចត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ទោស[1927]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាការរំលោភអំណាច ឬសមត្ថកិច្ចផ្លូវការរបស់ ឌុច ថាជាស្ថានទម្ងន់ទោស ដោយសារគាត់មានតួនាទីដឹកនាំសំខាន់នៅមន្ទីរ ស-២១ ដែលបាន "បំពានតួនាទីរបស់ខ្លួនដោយបានបង្ហាត់បង្រៀន បញ្ជា និងគ្រប់គ្រងទៅលើបុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកទោសដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ ដោយបង្ហាញពី "ការខិតខំប្រឹងប្រែងបំពេញភារកិច្ច"" នៃមន្ទីរឃុំឃាំងនោះ[1928]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ បានលើកឡើងអំពីស្ថានទម្ងន់ទោសនេះ ប៉ុន្តែមិនបានវិភាគថាតើ វាអាចត្រូវបានអនុវត្តចំពោះ នួន ជា និង ខៀវ សំផន ដែរ ឬយ៉ាងណានោះទេ។

តួនាទីដឹកនាំ និងការពេញចិត្តយ៉ាងខ្លាំងក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ត្រូវបានពិចារណាថាជាស្ថានទម្ងន់ទោស ដែលគប្បីត្រូវបានផ្តល់ទម្ងន់ធ្ងន់ នៅក្នុងការកំណត់ទោស[1929]។ ទោះជាយ៉ាងណា ការស្ម័គ្រចិត្តដោយមានសម្បជញ្ញៈ និងការខិតខំប្រឹងប្រែងរបស់ទណ្ឌិតក្នុងការបំពេញតួនាទីរបស់ខ្លួន នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលបានចោទប្រកាន់ មិនជាចាំបាច់មានន័យថាជាការពេញចិត្ត ដែលជាស្ថានទម្ងន់ទោសនោះទេ[1930]

---

[1919] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៣។
[1920] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៧១។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥៥។
[1921] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០៥៩-២០៦៤។
[1922] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៩ និង ១០៧៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៣។
[1923] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៧៨។
[1924] ដូចខាងលើ។
[1925] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១៣។
[1926] ដូចខាងលើ (ការដកស្រង់ខាងក្នុងត្រូវបានលុបចេញ)។
[1927] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០៥៧។
[1928] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៧។
[1929] ដូចខាងលើ កថាខណ្ឌ ៣៧៨។
[1930] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៨៥ និង១០៨៨។

។ ការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងតួនាទីជាន់ខ្ពស់ គឺជាការរំលោភបំពានលើតួនាទីដែលមានអំណាច និងមានឥទ្ធិពល ដែលការណ៍នេះបង្កើតបានជាស្ថានទម្ងន់ទោសរបស់ទណ្ឌិត[1931]។

ភាពឃោរឃៅដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ក៏ត្រូវបានពិចារណាជាស្ថានទម្ងន់ទោសដែរ។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា វិធីសាស្ត្រធ្វើទារុណកម្មដ៏សាហាវឃោរឃៅ ដែលប្រើទៅលើអ្នកទោស និងថាមានអ្នកស្លាប់មិនតិចជាង ១២.២៧៣ នាក់នោះ ជាស្ថានទម្ងន់ទោស[1932]។

ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ភាពងាយរងគ្រោះ និងគ្មានមធ្យោបាយការពារខ្លួន គឺជាស្ថានទម្ងន់ទោស។ អង្គជំនុំជម្រះបានពិចារណាថា៖ (១) ជនរងគ្រោះជាច្រើនដូចជាកុមារ ជនចាស់ជរា អ្នកជំងឺ និងអ្នករបួស ស្ត្រីមានផ្ទៃពោះ និងស្ត្រីទើបឆ្លងទន្លេ គឺជាកម្មវត្ថុនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និង (២) អ្នកដែលត្រូវទទួលរងការជម្លៀសដោយបង្ខំ មិនអាចជួយខ្លួនឯងបាន ទន់ខ្សោយ អស់កម្លាំង មានរបួស និងមានជំងឺ ដោយសារតែខ្វះចំណីអាហារ ទឹកស្អាត ជំនួយ ឬបង្គន់អនាម័យ[1933]។ ទោះជាយ៉ាងណា ដោយសារតែចំនួនជនរងគ្រោះត្រូវបានពិចារណានៅក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម បញ្ហានេះមិនត្រូវបានចាត់ទុកថាជាស្ថានទម្ងន់ទោសនោះទេ[1934]។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើចំនួន និងភាពងាយរងគ្រោះរបស់ជនរងគ្រោះរួមជាមួយនឹងទំហំ និងភាពសាហាវឃោរឃៅនៃឧក្រិដ្ឋកម្ម ក្នុងការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម[1935]។ ហេតុដូច្នេះ កត្តាទាំងនេះមិនត្រូវបានពិចារណាថាជាស្ថានទម្ងន់ទោសទេ[1936] ដោយសារការធ្វើបែបនេះនឹងរំលោភលើគោលការណ៍ដែលថា "អង្គហេតុដូចគ្នាមិនអាចយកមកប្រើប្រាស់សម្រាប់ការបង្ហាញពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋផង និងស្ថានទម្ងន់ទោសផងបាននោះទេ"[1937]។

ប្រសិនបើចេតនារើសអើងត្រូវបានពិចារណា ក្នុងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម វាក៏មិនអាចជាស្ថានទម្ងន់ទោសបានដែរ[1938]។ ស្រដៀងគ្នានេះដែរ ក្នុងករណីដែលចេតនារើសអើងគឺជាធាតុផ្សំនៃឧក្រិដ្ឋកម្ម ដូចជាចេតនាក្នុងបទឧក្រិដ្ឋធ្វើទុក្ខបុកម្នេញ វាមិនអាចត្រូវបានពិចារណាថាជាស្ថានទម្ងន់ទោសចំពោះបទឧក្រិដ្ឋនោះទេ។ ទោះជាយ៉ាងណា ចេតនារើសអើង អាចត្រូវបានចាត់ទុកជាស្ថានទម្ងន់ទោសទាក់ទងនឹងបទឧក្រិដ្ឋផ្សេងទៀត ក្នុងករណីដែលវាមិនមែនជាធាតុផ្សំគតិយុត្តិនៃបទល្មើសទាំងនោះ[1939]។

អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល បានពិចារណាថា នៅពេលដែលទណ្ឌិតគឺជា "បុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ ដែលធ្វើឱ្យគាត់យល់ដឹងច្បាស់លាស់អំពីបច្ច័យទាំងឡាយដែលកើតចេញពីសកម្មភាពរបស់គាត់" អង្គហេតុទាំងអស់នោះអាចបង្កើតបានជាស្ថានទម្ងន់ទោស[1940]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ បានបញ្ជាក់ថា អង្គជំនុំជម្រះដែលកំណត់អំពីទោស មានសិទ្ធិពិនិត្យមើលចំណេះដឹង សាវតារ បុព្វសិទ្ធិ និងគុណវិបត្តិរបស់បុគ្គលណាមួយ ជាកត្តាពាក់ព័ន្ធ[1941]។

### ៦.៤. អានុភាពនៃការផ្តន្ទាទោសច្រើនដងនៅក្នុងកិច្ចដំណើរការនីតិវិធីដូចគ្នា

---

[1931] ដូចខាងលើ កថាខណ្ឌ ១០៨៤ និង ១០៨៧។
[1932] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦០៣។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៦០ និង៣៧៥។
[1933] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៨២។
[1934] ដូចខាងលើ កថាខណ្ឌ ១០៨៣។
[1935] ដូចខាងលើ កថាខណ្ឌ ៤៣៨៦។
[1936] ដូចខាងលើ ផ្នែកសម្រេចសេចក្តី។
[1937] ដូចខាងលើ កថាខណ្ឌ ១០៦៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៣។
[1938] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៩ និង១០៧៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៣។
[1939] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦០៥។
[1940] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៨៦ និង១០៨៩។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥២។
[1941] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០៤៨។

ពុំមានបទប្បញ្ញត្តិណាក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. ឬវិធានផ្ទៃក្នុង ដែលបង្ហាញថាតើ អង្គជំនុំជម្រះសាលាដំបូងអាចដាក់ទោសរួមតែមួយ ក្រោយពីបានរកឃើញពិរុទ្ធភាពចំពោះបទល្មើសច្រើនដែរ ឬយ៉ាងណា នៅពេលដែលពិរុទ្ធភាពនីមួយៗផ្អែកលើអំពើឧក្រិដ្ឋដាច់ដោយឡែកពីគ្នា។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការដាក់ទោសអាចប្រកាសសរុបរួមតែមួយ ដែល "ឆ្លុះបញ្ចាំងអំពីអំពើឧក្រិដ្ឋរួមរបស់ជនជាប់ចោទ ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន"[1942]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានវិភាគថាតើ ក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក. អនុញ្ញាតឱ្យអង្គជំនុំជម្រះដាក់ទោសរួមតែមួយ ក្រោយពីបានរកឃើញពិរុទ្ធភាពចំពោះបទល្មើសច្រើនដែរ ឬយ៉ាងណា នៅពេលដែលពិរុទ្ធភាពនីមួយៗផ្អែកលើអំពើឧក្រិដ្ឋដាច់ដោយឡែកពីគ្នា[1943]។ អង្គជំនុំជម្រះសង្កេតឃើញថា ការអនុវត្តនៅតុលាការ Nuremberg និងតុលាការ Tokyo គឺអាចផ្តន្ទាទោសសរុបរួមតែមួយ ទោះបីជាបទល្មើសច្រើន និងថាសាលាក្តីមិនអចិន្ត្រៃយ៍ ទុកបញ្ហានេះឱ្យអង្គជំនុំជម្រះសាលាដំបូងនីមួយៗធ្វើការសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ផ្ទុយមកវិញអង្គជំនុំជម្រះកត់សម្គាល់ថា មាត្រា ៧៨(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC ប្រកាសទោសសម្រាប់បទល្មើសព្រហ្មទណ្ឌមួយម្តងៗ *និង*ទោសរួម ដែលបញ្ជាក់នូវរយៈពេលសរុបនៃទោសដាក់ពន្ធនាគារ។ ជាចុងក្រោយអង្គជំនុំជម្រះសាលាដំបូងពិចារណាលើមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលចែងថា ការដាក់ទោសរួមអាចធ្វើទៅបាន "កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា"[1944]។ អង្គជំនុំជម្រះតុលាការកំពូលមិនបានពិនិត្យបញ្ហាជាក់លាក់នេះទេ ប៉ុន្តែបានកត់សម្គាល់ថា តាមនីតិវិធីច្បាប់កម្ពុជា សិទ្ធិទទួលបានការដោះលែងមុនពេលកំណត់ត្រូវបានសម្រេចតាមរយៈ "ការពិនិត្យមើលរយៈពេលនៃទោសរួមដែលត្រូវបានប្រកាស មិនមែនតាមរយៈបទល្មើសច្រើនដែលត្រូវបានចោទប្រកាន់ត្រួតគ្នានោះទេ"[1945]។

អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ បានអនុវត្តវិធិសាស្ត្រពីមុនរបស់ខ្លួន ក្នុងសំណុំរឿង ០០១ ដែលថាខ្លួនអាចដាក់ទោសសរុបរួមតែមួយ ដែលឆ្លុះបញ្ចាំងអំពីអំពើឧក្រិដ្ឋរួម[1946]។

### ៦.៥. អានុភាពនៃការផ្តន្ទាទោសច្រើននៅក្នុងកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់

ពុំមានបទប្បញ្ញត្តិណានៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង អាចអនុវត្តបានចំពោះស្ថានភាពដែលជនជាប់ចោទ ត្រូវបានផ្តន្ទាទោសក្នុងការជំនុំជម្រះចំនួនពីរ ដែលបណ្តាលមកពីការបំបែកកិច្ចដំណើរការនីតិវិធី ហើយជនជាប់ចោទនោះកំពុងតែអនុវត្តទោសដែលអនុញ្ញាតជាអតិបរមាហើយនោះទេ ពោលគឺទោសជាប់ពន្ធនាគារអស់មួយជីវិត[1947]។

ក្នុងសំណុំរឿង ០០២/០២ ដោយកត់សម្គាល់ថាទណ្ឌិតបានកំពុងអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតពីសំណុំរឿង ០០២/០១ ហើយនោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា "ថាតើអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីទោសដាច់ដោយឡែកពីគ្នាដែរ ឬយ៉ាងណា ចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២"[1948]។ អង្គជំនុំជម្រះបានពិនិត្យមើលមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែលក្នុងនោះការកំណត់ទោសដែលបានដាក់ចំពោះបទល្មើសច្រើន នៅក្នុងការជំនុំជម្រះដាច់ដោយឡែកពីគ្នា "ទោសដែលនឹងត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ" ហើយ "តុលាការចុងក្រោយដែលត្រូវសម្រេចអាចប្រកាសឱ្យអនុវត្តទោសស្របបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា"[1949]។ អង្គជំនុំជម្រះក៏បានពិចារណាទស្សនៈច្បាប់

---

[1942] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៧២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៩០។
[1943] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥៨៦។
[1944] ដូចខាងលើ កថាខណ្ឌ ៥៨៦-៥៨៩។
[1945] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣២៨។
[1946] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៧២។
[1947] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥៧-៤៣៥៨។
[1948] ដូចខាងលើ កថាខណ្ឌ ៤៣៥៧។
[1949] ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ១៣៨។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៥៩។

របស់បារាំងអំពី *"confusion des peines"* ដោយបានសន្និដ្ឋានថា នៅពេលដែលទោសជាប់ពន្ធនាគារត្រូវបានប្រកាស និងជាស្ថាពរហើយនោះ ទោសបន្ថែមណាផ្សេងទៀតសម្រាប់បទល្មើសត្រួតគ្នា នៅក្នុងកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ គប្បីត្រូវរួមបញ្ចូលគ្នាជាមួយការប្រកាសទោសដំបូងនោះ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា បទឧក្រិដ្ឋនៅក្នុងសំណុំរឿងទាំងពីរគឺ សំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ គឺជាបទល្មើសត្រួតគ្នា យោងតាមច្បាប់កម្ពុជា។ ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម រួមជាមួយស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស អង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតមួយទៀតសម្រាប់បទឧក្រិដ្ឋបន្ថែម នៅក្នុងសំណុំរឿង ០០២/០២ ប៉ុន្តែរួមបញ្ចូលទោសនេះជាមួយនឹងទោសជាប់ពន្ធនាគារអស់មួយជីវិតពីសំណុំរឿង ០០២/០១ សរុបជាទោសជាប់ពន្ធនាគារអស់មួយជីវិតតែមួយ។ ការសម្រេចនេះមានគោលបំណងធានាថា ការប្រកាសទោសនេះឆ្លុះបញ្ចាំងពីអំពើឧក្រិដ្ឋរួមរបស់ទណ្ឌិត នៅក្នុងសំណុំរឿងទាំងពីរ ដោយចៀសវាងការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតច្រើនដងត្រួតគ្នា[1950]។

អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាថា កាផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត និងការរួមបញ្ចូលវាជាមួយនឹងទោសជាប់ពន្ធនាគារអស់មួយជីវិតដែលបានដាក់ក្នុងសំណុំរឿង ០០២/០១ ដែលបង្កើតបានជាការផ្តន្ទាទោស*រួមតែមួយ* ដែលគ្របដណ្តប់លើអំពើរបស់ទណ្ឌិតនៅក្នុងសំណុំរឿងទាំងពីរ គឺមានលក្ខណៈត្រឹមត្រូវ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង "មានការភាន់ច្រឡំតាមរយៈសំដៅទៅលើទោសត្រួតគ្នា ឬទោសពីរដែលត្រូវអនុវត្តក្នុងពេលតែមួយដូចគ្នា និងតាមរយៈការប្រៀបធៀបស្ថានការណ៍នៅចំពោះមុខខ្លួនជាមួយនឹងស្ថានការណ៍ដែលដោះស្រាយក្នុងច្បាប់ក្នុងស្រុករបស់កម្ពុជា នៃមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា"[1951]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ស្ថានការណ៍នេះមានលក្ខណៈដូចគ្នាជាងទៅនឹង "ការចោទប្រកាន់តែមួយ" នៅក្នុងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការរួមបញ្ចូលនូវទោសពីរទៅជាទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិត បានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងចៀសផុតពីភាពមិនត្រឹមត្រូវ ដែលបណ្តាលមកពីការត្រួតទោសដាច់ដោយឡែកពីគ្នា ខណៈពេលដែលធានាបានផងដែរថា ទោសតែមួយបានឆ្លុះបញ្ចាំងអំពើល្មើសជារួមរបស់ទណ្ឌិត[1952]។

### ៦.៦. ផលប៉ះពាល់នៃការរំលោភបំពានលើសិទ្ធិពីមុន ទៅលើការផ្តន្ទាទោស

ពុំមានបទប្បញ្ញត្តិណានៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង ចែងអំពីដំណោះស្រាយសម្រាប់ការរំលោភបំពានលើសិទ្ធិមនុស្សរបស់ទណ្ឌិតទេ[1953]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា អ.វ.ត.ក. មិនអាចទទួលខុសត្រូវលើការរំលោភបំពានលើសិទ្ធិរបស់ទណ្ឌិតបានឡើយ ក្នុងករណីដែលការរំលោភបំពាននោះមិនបានបង្កឡើងដោយ អ.វ.ត.ក. និងក្នុងករណីដែល អ.វ.ត.ក. មិនមែនជាអ្នករំលោភកិច្ចនីតិវិធី[1954]។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានកាត់បន្ថយការផ្តន្ទាទោសរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច រយៈពេលប្រាំឆ្នាំ និងទូទាត់ឱ្យគាត់សម្រាប់រយៈពេលអនុវត្តនៅតុលាការយោធាកម្ពុជា ជាសំណងសម្រាប់ការឃុំខ្លួនគាត់ខុសច្បាប់ដោយតុលាការយោធា[1955]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ពុំមានរូបមន្តណាជាធរមានសម្រាប់គណនាការកាត់បន្ថយទោសរបស់ជនជាប់ចោទនៅ អ.វ.ត.ក. ផ្អែកលើការរំលោភលើសិទ្ធិរបស់ពួកគេពីមុនយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា យុត្តិសាស្ត្រនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR") ផ្តល់ការណែនាំខ្លះៗចំពោះបញ្ហានេះ[1956]។ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុទៀតថា ទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលគាត់ជាប់សង្ស័យ ទាំង

---

[1950] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៣៦០ និង៤៤០២។
[1951] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០២៩។
[1952] ដូចខាងលើ កថាខណ្ឌ ២០៣១-២០៣២។
[1953] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៩១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦២៥។
[1954] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៩០។
[1955] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦២៣-៦២៧។
[1956] ដូចខាងលើ កថាខណ្ឌ ៦២៥។

ឧបសគ្គនៃប្រព័ន្ធច្បាប់កម្ពុជា ដែលដំណើរការនៅពេលនោះ គឺមិនអាចធ្វើជាយុត្តិកម្មចំពោះការរំលោភលើសិទ្ធិរបស់ ឌុច បាននោះទេ[1957]។

ទោះបីជាសហព្រះរាជអាជ្ញាមិនបានជំទាស់ និងមិនបានប្តឹងសាទុក្ខសេចក្តីសម្រេចនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ថាតើដំណោះស្រាយនេះអាចត្រូវបានរក្សាទុកជាបញ្ហាច្បាប់ដែរ ឬទេ[1958]។ ដោយយល់ឃើញថាមិនមានសំណងចំពោះការរំលោភសិទ្ធិមនុស្សរបស់ទណ្ឌិតនៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. ច្បាប់ អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង និងថាសំណងបែបនេះមិនមានចែងនៅក្នុងច្បាប់ និងការអនុវត្តនៃប្រព័ន្ធតុលាការកម្ពុជានោះ អង្គជំនុំជម្រះតុលាការកំពូលស្វែងរកគោលការណ៍ណែនាំពីយុត្តិសាស្ត្រអន្តរជាតិ[1959]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធ ត្រង់ចំណុចដែលមានខ្លឹមសារថា ការបំពារបំពានទៅលើសិទ្ធិរបស់ ឌុច ដោយស្ថាប័នមួយផ្សេងទៀត គប្បីត្រូវទទួលបានសំណងពី អ.វ.ត.ក.[1960]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់លាស់ថា មុនពេលអាចទទួលបានសំណង ទណ្ឌិតត្រូវតែបង្ហាញថា ការរំលោភលើសិទ្ធិរបស់ខ្លួនមានជាប់ពាក់ព័ន្ធនឹងស្ថាប័នតុលាការណាមួយ ឬបង្ហាញថា ៉យ៉ាងហោចណាស់តុលាការមានការទទួលខុសត្រូវមួយចំនួនចំពោះការរំលោភសិទ្ធិនោះ[1961]។ ដោយសារតែការឃុំខ្លួនរបស់ ឌុច ដោយតុលាការយោធា មិនជាប់ពាក់ព័ន្ធនឹង អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានបដិសេធសំណើសុំសំណងរបស់ ឌុច នេះ[1962]។

ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe បានជំទាស់ដោយផ្នែកទៅនឹងមតិភាគច្រើននៃអង្គជំនុំជម្រះតុលាការកំពូលលើបញ្ហានេះ។ ទោះបីជាពួកគាត់ឯកភាពថា ចាំបាច់ត្រូវដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតក៏ដោយ ក៏ពួកគាត់ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់សំឡេងភាគច្រើនក្នុងការបដិសេធសំណងចំពោះ “ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ” លើសិទ្ធិជាសារវន្តរបស់ ឌុច ក្នុងអំឡុងពេលការឃុំខ្លួនគាត់មុនពេលជំនុំជម្រះរយៈពេលយ៉ាងយូរ[1963]។ ជាពិសេស ពួកគាត់មិនឯកភាពទៅនឹងសំឡេងភាគច្រើនដែល “អនុវត្តជាស្វ័យប្រវត្តិនូវវិធីសាស្ត្ររបស់តុលាការ ICTY និងតុលាការ ICTR ទៅលើអង្គហេតុនៃរឿងក្តីនេះ” ដោយយល់ឃើញថាវិធីសាស្ត្រនេះមិនសមស្រប ដោយផ្អែកលើ “ភាពខុសគ្នាយ៉ាងច្បាស់ ពាក់ព័ន្ធទៅនឹងគោលជំហររបស់ អ.វ.ត.ក. ធៀបជាមួយនឹងគោលជំហររបស់តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ និងប្រព័ន្ធតុលាការជាតិដែលបង្កឱ្យមានការរំលោភបំពានទាំងនេះ”។ ខុសពី អ.វ.ត.ក. ដែលត្រូវបាន “បង្កើតឡើងដោយប្រព័ន្ធច្បាប់ជាតិ ហើយស្ថិតក្រោមប្រព័ន្ធច្បាប់ជាតិ” តុលាការ ICTY និងតុលាការ ICTR មិនត្រូវបានបង្កើតឡើងផ្អែកលើកិច្ចព្រមព្រៀងណាមួយជាមួយនឹងរដ្ឋាភិបាលរ៉ាន់ដា ឬអតីតយូហ្គោស្លាវី ឬច្បាប់របស់ពួកគេទេ[1964]។ នៅក្នុង “ភាពខុសគ្នាយ៉ាងច្បាស់” ធៀបជាមួយនឹងយុត្តាធិការតុលាការមិនអចិន្ត្រៃយ៍ រដ្ឋកម្ពុជាបានឃុំខ្លួន ឌុច “អស់រយៈពេល ៨ (ប្រាំបី) ឆ្នាំ ដោយមិនមានកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីណាមួយ ហើយក្នុងពេលជាមួយគ្នានោះ ខ្លួនបានធ្វើការចរចាដើម្បីបង្កើត អ.វ.ត.ក. ហើយបន្ទាប់មកបានបញ្ជូន កាំង ហ្គេកអ៊ាវ ទៅតុលាការមួយដែលបានបង្កើតដោយខ្លួនឯង ដើម្បីធ្វើការស៊ើបអង្កេតទៅលើបទចោទដែល “ប្រហាក់ប្រហែលគ្នាយ៉ាងខ្លាំង”” ដូច្នេះ “ពិតជាមានទំនាក់ទំនង” រវាងការឃុំខ្លួនពីមុន និងករណី អ.វ.ត.ក.[1965]។

---

[1957] ដូចខាងលើ កថាខណ្ឌ ៦២៧។
[1958] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៨៩។
[1959] ដូចខាងលើ កថាខណ្ឌ ៣៩១។
[1960] ដូចខាងលើ កថាខណ្ឌ ៣៩០។
[1961] ដូចខាងលើ កថាខណ្ឌ ៣៩២។
[1962] ដូចខាងលើ កថាខណ្ឌ ៣៩៦។
[1963] សំណុំរឿង ០០១ សាលដីកា យោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម Agnieszka Klonowiecka-Milart និងចៅក្រម Chandra Nihal Jayasinghe កថាខណ្ឌ ១។
[1964] ដូចខាងលើ កថាខណ្ឌ ៤-៦ និង ៩។
[1965] ដូចខាងលើ កថាខណ្ឌ ១៣។

## ៦.៧. ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

កិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា និងវិធានផ្ទៃក្នុង ពុំមានបទប្បញ្ញត្តិស្តីពីការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះទេ[1966]។ ទោះជាយ៉ាងណា មាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ចែងអំពីការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬថិរវេលាសរុបនៃការស្រូបទោសបញ្ចូលគ្នា ហើយមាត្រា ៥១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចែងស្រដៀងគ្នាថា ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល[1967]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា ការអនុវត្តការគិតបញ្ចូលថិរវេលាទៅលើការប្រកាសទោសដែលមានរយៈពេលកំណត់ និងការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត គឺជាការអនុវត្តជាក់ស្តែងរបស់កម្ពុជា និងអន្តរជាតិ[1968]។

ដោយសារតែសំណងសម្រាប់ការរំលោភបំពានសិទ្ធិ គឺជាបញ្ហាដាច់ដោយឡែកពីការគិតបញ្ចូលថិរវេលាសម្រាប់រយៈពេលនៃការអនុវត្តទោស អង្គជំនុំជម្រះតុលាការកំពូលបានវិភាគថាតើ ខ្លួនអាចគិតបញ្ចូលថិរវេលានៃការឃុំខ្លួនរបស់ ឌុច ដោយតុលាការយោធាដែរ ឬទេ បើទោះបីជាខ្លួនបានបដិសេធសំណើរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ[1969]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ក្នុងការសន្និដ្ឋានថា ការចោទប្រកាន់ "មានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំង" ទៅនឹងការចោទប្រកាន់ទាំងឡាយនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក.។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ *មិនអចិន្ត្រៃយ៍* បញ្ជាក់ថា ក្នុងកាលៈទេសៈបែបនេះ រយៈពេលដែលជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនជាបណ្តោះអាសន្ននៅក្រោមអំណាចតុលាការជាតិតែម្នាក់ឯង គឺត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោស។ ដោយពិចារណាលើការអនុវត្តច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាឯកច្ឆន្ទថា ឌុច មានសិទ្ធិទទួលបាននូវការគិតបញ្ចូលនូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ មក ដោយមិនរាប់បញ្ចូលថ្ងៃចេញសាលដីកាសំណុំរឿង ០០១[1970]។

## ៦.៨. ការដោះលែងដោយមានលក្ខខណ្ឌ

មាត្រា ៥១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ចែងថា គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នត្ថិភាពនៃបទប្បញ្ញត្តិពិសេសស្តីពីការដោះលែងដោយមានលក្ខខណ្ឌ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. បានបញ្ជាក់ថា បញ្ហានេះគប្បីត្រូវបានសម្រេចស្របតាមនីតិវិធីជាធរមាន "នាពេលដែលការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវបានលើកមកពិចារណាសម្រាប់ទណ្ឌិតជាក់លាក់ណាម្នាក់ ហើយអាចជាពេលវេលាដែល អ.វ.ត.ក. បានបញ្ចប់អាណត្តិការងាររបស់ខ្លួន" បន្ទាប់ពីការបញ្ចប់ដំណើរការនីតិវិធីរួចហើយ[1971]។

## ៦.៩. បទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខចំពោះការផ្តន្ទាទោស

វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះតុលាការកំពូលសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ផ្អែកលើមូលដ្ឋាន៖ (១) "កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ" ឬ (២) "កំហុសនៃអង្គហេតុ ដែលនាំឱ្យសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌"។ ទោះជាយ៉ាងណា

---

[1966] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤០១។

[1967] ដូចខាងលើ។

[1968] ដូចខាងលើ កថាខណ្ឌ ៤០១ និង ៤០៣។

[1969] ដូចខាងលើ កថាខណ្ឌ ៤០៣។

[1970] ដូចខាងលើ កថាខណ្ឌ ៤០៣-៤០៤។

[1971] ដូចខាងលើ កថាខណ្ឌ ៣៨៧។

ពុំមានគោលការណ៍ណែនាំនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. វិធានផ្ទៃក្នុង ឬច្បាប់និងយុត្តិសាស្ត្ររបស់តុលាការកម្ពុជា ស្តីពីការអនុវត្តវិធាននេះចំពោះការផ្តន្ទាទោសក្នុងបណ្តឹងសាទុក្ខឡើយ[1972]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បានស្វែងរកគោលការណ៍ណែនាំនៅកម្រិតអន្តរជាតិ ដោយបានទទួលយក "បទដ្ឋានដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ថាជាការបកស្រាយអំពីការអនុវត្តដ៏ត្រឹមត្រូវនៃវិធាន ១០៤(១)(ក)-(ខ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ទាក់ទងទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោស"។ យោងតាមបទដ្ឋាននេះ៖

i. អង្គជំនុំជម្រះសាលាដំបូងត្រូវបានផ្តល់នូវឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ក្នុងការសម្រេចប្រកាសទោសសមស្រប ដូចជាការសម្រេចអំពីទម្ងន់ ទៅលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស។

ii. តាមវិធានទូទៅ អង្គជំនុំជម្រះតុលាការកំពូលនេះ ពុំត្រូវកែប្រែការប្រកាសទោសណាមួយឡើយ លើកលែងតែអង្គជំនុំជម្រះសាលាដំបូង "បានប្រព្រឹត្តកំហុសដែលស្តែងចេញឱ្យឃើញពីការប្រើប្រាស់ឆន្ទានុសិទ្ធិ ឬពុំបានគោរពតាមច្បាប់ជាធរមាន" និង

iii. ម្ចាស់បណ្តឹងសាទុក្ខមានកាតព្វកិច្ចក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់ទៅលើការពិចារណានានាដែលពុំជាប់ពាក់ព័ន្ធ ឬពុំចាំបាច់ ពុំបានផ្តល់ទម្ងន់ណាមួយ ឬគ្រប់គ្រាន់ទៅលើការពិចារណាដែលជាប់ពាក់ព័ន្ធ បានប្រព្រឹត្តកំហុសច្បាស់លាស់នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងអង្គហេតុ ឬថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល ឬមិនយុត្តិធម៌យ៉ាងច្បាស់ដែលធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងពិតជាពុំបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនបានសមស្របឡើយ[1973]។

ការប្រៀបធៀបទោសដែលបានសម្រេចដោយតុលាការផ្សេងនៅក្នុងរឿងក្តីផ្សេងគ្នានោះ ត្រូវបានពិចារណាថា "ពុំសមស្របក្នុងការបង្ហាញថា ជាកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីដាក់ទោសសមស្របណាមួយឡើយ"។ ផ្ទុយទៅវិញ ការផ្តន្ទាទោសសមស្រប "ជានិច្ចកាលនឹងត្រូវកំណត់ផ្អែកលើអង្គហេតុនៃរឿងក្តីជាក់លាក់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនីមួយៗ"[1974]។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ប្រសិនបើការប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង "មិនស្របទៅនឹងរបបនៃការប្រកាសទោស"នោះ អង្គជំនុំជម្រះតុលាការកំពូលមានអំណាចផ្លាស់ប្តូរទម្ងន់ទោសជាថ្មី[1975]។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញកំហុសអង្គច្បាប់ និងការរំលោភឆន្ទានុសិទ្ធិ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង "បានផ្តល់ទម្ងន់មិនសមហេតុផលចំពោះស្ថានសម្រាលទោស និងមិនបានផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់ចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ទោស" និងហេតុដូច្នេះ "មានកំហុសក្នុងការប្រកាសទោសដែលមានលក្ខណៈមិនគ្រប់គ្រាន់យ៉ាងច្បាស់ក្រឡែត និងមានកំហុសក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន" ដែលមិនឆ្លុះបញ្ចាំងបានសមរម្យទៅនឹងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានភាពបុគ្គលរបស់ ឌុច[1976]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានកែប្រែការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត[1977]។

នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបដិសេធការដាក់ពិរុទ្ធភាពមួយ ឬច្រើន ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើសម្រាប់ការធ្វើការប្រកាសទោសណាមួយនោះ អង្គជំនុំជម្រះតុលាការកំពូលមានសមត្ថកិច្ចក្នុងការសម្រេចប្រកាសទោសមួយផ្សេង ឬប្រកាសទោសដដែលសម្រាប់ការដាក់ពិរុទ្ធ

---

[1972] ដូចខាងលើ កថាខណ្ឌ ៣៥៤។
[1973] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១០៧។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៥៤។
[1974] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១១២។
[1975] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៩ (ការដកស្រង់ខាងក្នុងត្រូវបានលុបចេញ)
[1976] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៣៧៣ និង៣៨៣។
[1977] ដូចខាងលើ ផ្នែកសម្រេចសេចក្តី។ សម្រាប់ព័ត៌មានបន្ថែមស្តីពីកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុង សំណុំរឿង ០០១ សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៥.១.៦.២។

ភាពដែលនៅសេសសល់ផ្សេងទៀត។ ការធ្វើដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលអាចកែប្រែការប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង[1978]។

ក្នុងករណីដែលកំហុសណាមួយត្រូវបានរកឃើញនៅក្នុងបណ្តឹងសាទុក្ខ ដែលរួមទាំងទាក់ទងទៅនឹងការរក្សាបទឧក្រិដ្ឋជាក់លាក់ ពុំប៉ះពាល់ដល់ការយល់ឃើញដែលការប្រកាសទោសបានផ្អែកលើនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការប្រកាសទោសដែលបានកំណត់នោះពុំគួរផ្លាស់ប្តូរទេ[1979]។ ទោះបីជាក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូល រកឃើញកំហុសណាមួយនៅដំណាក់កាលបណ្តឹងសាទុក្ខ ដែលប៉ះពាល់ដល់ការយល់ឃើញដែលការប្រកាសទោសនោះបានផ្អែកលើ នោះអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ក្នុងកាលៈទេសៈនៃរឿងក្តីនេះ ការពិចារណាលើកំហុសនេះមិនបានធ្វើឱ្យការប្រកាសទោសចុងក្រោយទៅជាពុំសមស្រប ឬមិនយុត្តិធម៌នោះឡើយ[1980]។

---

1978 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១១០៩។
1979 ដូចខាងលើ កថាខណ្ឌ ១១១៩-១១២១។
1980 សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ២០៦៩។

## ៧. សកម្មភាពដើមបណ្តឹងរដ្ឋប្បវេណី

អ.វ.ត.ក. ត្រូវបានបង្កើតឡើងដោយមានគោលការណ៍ណែនាំអំពី "ការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និង សន្តិសុខ"[1981]។ ការដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី ត្រូវបានពិចារណាថាជាមធ្យោបាយមួយនៃការបង្រួបបង្រួមជាតិ[1982]។

ការអនុម័តវិធានផ្ទៃក្នុងឆ្នាំ២០០៧ ជាផ្លូវការ បានដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងកិច្ចដំណើរការនីតិវិធី ដែលផ្តល់ឱ្យពួកគេនូវសិទ្ធិក្នុងការចូលរួមមួយចំនួន[1983]។ ដោយសារតែការផ្តោតរបស់ អ.វ.ត.ក. មានលក្ខណៈខុសគ្នាខ្លាំងពីតុលាការជម្រះរបស់កម្ពុជា ដើម្បីធានាបាននូវប្រព័ន្ធមួយដែលមានលក្ខណៈពិសេស នោះក្របខ័ណ្ឌដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ.វ.ត.ក. មិនដូចគ្នាទៅនឹងក្របខ័ណ្ឌដែលមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ[1984]។

វិធាន ២១(១) នៃវិធានផ្ទៃក្នុង តម្រូវថា ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ"។ ហេតុដូច្នេះ អ.វ.ត.ក. ត្រូវគោរពសិទ្ធិរបស់ជនរងគ្រោះ នៅទូទាំងកិច្ចដំណើរការនីតិវិធី និងត្រូវធានាថាកិច្ចដំណើរការនីតិវិធីទាំងនោះត្រូវបានធ្វើឡើងដោយមានលក្ខណៈយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ និងរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងអស់[1985]។ លើសនេះទៀត វិធាន ២៣(១) នៃវិធានផ្ទៃក្នុង បានកំណត់និយមន័យគោលបំណងនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពោលគឺ ដើម្បី៖ (១) "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រការចោទប្រកាន់" និង(២) "ទាមទារសំណងផ្លូវចិត្ត និងសមូហភាព"។

តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការគាំទ្រដល់ការចោទប្រកាន់ ត្រូវបានបំភ្លឺជាបន្តបន្ទាប់[1986]។ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញា មានផលប្រយោជន៍រួមក្នុងការទទួលបានសេចក្តីសម្រេចមួយស្តីពីអំពើឧក្រិដ្ឋរបស់ជនជាប់ចោទក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបំពេញកិច្ចបន្ថែមលើសសហព្រះរាជអាជ្ញាទេ និងមិនមានសិទ្ធិចូលរួមស្មើជាមួយនឹងសហព្រះរាជអាជ្ញាឡើយ[1987]។ ជាងនេះទៀត សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខុសពីសិទ្ធិរបស់ភាគីការពារក្តី និងសហព្រះរាជអាជ្ញា[1988]។

---

[1981] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល បុព្វកថា។ វិធានផ្ទៃក្នុង បុព្វកថា។

[1982] សំណុំរឿង ០០២ សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំង នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/53 កថាខណ្ឌ ៣៧។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៦៤-៦៥។

[1983] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី០) វិធាន ២៣។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៨៨។ សូមមើលផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២ មាត្រា ១៣ និងមាត្រា ២២។

[1984] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤។ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ១២។

[1985] វិធានផ្ទៃក្នុង វិធាន ២១(១)។

[1986] សម្រាប់ព័ត៌មានបន្ថែមស្តីពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូមមើលផ្នែក ៧.២។

[1987] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ២៥-២៦។

[1988] សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩ ឯកសារ E23/4 កថាខណ្ឌ ៥។ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ២៥។

ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីទទួលខុសត្រូវចំពោះការទាមទារសំណង ចំណែកឯសហព្រះរាជអាជ្ញាវិញមានការទទួលខុសត្រូវផ្តាច់មុខចំពោះបណ្តឹងអាជ្ញា ការធ្វើការស៊ើបអង្កេតបឋម និងការបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ[1989]។

ចាប់តាំងពីឆ្នាំ២០០៧ កិច្ចប្រជុំពេញអង្គ អ.វ.ត.ក. បានធ្វើវិសោធនកម្មវិធានផ្ទៃក្នុងចំនួនដប់លើក ដែលជាលទ្ធផលមានវិធានជាច្រើនថែងអំពី ទិដ្ឋភាពមួយចំនួននៃសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី[1990]។

## ៧.១. ភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី

វិធានផ្ទៃក្នុងកំណត់និយមន័យ "ជនរងគ្រោះ" ថាសំដៅលើ "រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ"[1991]។ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ត្រូវបានទទួលស្គាល់ថាជា ដើមបណ្តឹងរដ្ឋប្បវេណីយោងតាមវិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុង ត្រូវបំពេញលក្ខខណ្ឌតម្រូវរួមចំនួនបួនគឺៈ (១) ការខូចខាត (២) អត្ថិភាពនៃទំនាក់ទំនងហេតុនិងបច្ច័យរវាងឧក្រិដ្ឋកម្ម និងព្យសនកម្ម (៣) ភស្តុតាងបំពេញតាមបទដ្ឋាននៃការបញ្ជាក់ភស្តុតាង និង (៤) ភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណ[1992]។

### ៧.១.១. ព្យសនកម្ម

ដើម្បីត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យសុំត្រូវបង្ហាញពីព្យសនកម្មដែលអាចជាខាងរូបរាងកាយ ខាងសម្ភារៈ និងផ្លូវចិត្ត[1993]។ ពាក្យ "ព្យសនកម្ម" សំដៅលើការឈឺចាប់ ការខូចខាត ឬការអន្តរាយ[1994]។ ទោះបីជាការរំលោភបំពានលើសិទ្ធិមិនតែងតែត្រូវបានសន្មតជាមុនថានាំឱ្យមានព្យសនកម្មក៏ដោយ ក៏ព្យសនកម្មត្រូវបានពិចារណាថាអាចកើតឡើងជាយថាហេតុ ឬអាចកើតមានឡើងពិតប្រាកដ នៅពេលដែលមានការរំលោភសិទ្ធិកើតឡើង[1995]។

---

[1989] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ៣០ និង ៥១។

[1990] វិធានផ្ទៃក្នុង វិធាន ២៣ (គោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី) ២៣ ស្ទួន (បណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ២៣*ស្ទួនពី* និង ២៣ *ស្ទួនបី* (ការតំណាងផ្នែកច្បាប់) ២៣*ស្ទួនបួន* (សំណង) ១២ និង ១២ *ស្ទួន* និង១២*ស្ទួនពី* (រចនាសម្ព័ន្ធគាំទ្រ)។ សម្រាប់ព័ត៌មានបន្ថែមស្តីពីវិសោធនកម្មទៅលើវិធានផ្ទៃក្នុង សូមមើល *សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១)* ផ្នែក ៣.២.៣. (ជាទូទៅ) ៤.៤.៣ (ទាក់ទងនឹងការដំណាងដើមបណ្តឹរដ្ឋប្បវេណី)។

[1991] វិធានផ្ទៃក្នុង សន្ទានុក្រម។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២(ក)។

[1992] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៥៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 កថាខណ្ឌ ៣៣។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 កថាខណ្ឌ ៣៦។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ ៣៤។

[1993] វិធានផ្ទៃក្នុង វិធាន ២៣ ស្ទួន (១)(ខ)។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៦។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ២២។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ២១។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ២២។

[1994] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៥។

[1995] ដូចខាងលើ កថាខណ្ឌ ៤១៥-៤១៦។

### ៧.១.១.១. លក្ខណៈបុគ្គលនៃព្យសនកម្ម

ព្យសនសកម្មត្រូវតែជាលក្ខណៈបុគ្គលចំពោះអ្នកដាក់ពាក្យស្នើសុំ[1996]។ ក្នុងបរិបទនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំ ដែលមានលក្ខណៈជាប្រព័ន្ធ និងរីករាលដាល ដែលបានប្រព្រឹត្តឡើងនៅទូទាំងប្រទេស "បុគ្គលទាំងនោះប្រហែលជាទទួលរង *ផងដែរ* នូវព្យសនកម្មជាសមូហភាព"។ ក្នុងករណីបែបទាំងនេះ ព្យសនកម្មអាចត្រូវបានវាស់វែងក្នុងបរិបទនៃការខូចខាតជាសមូហភាព ចំពោះសង្គមទាំងមូល ឬក៏ផ្នែកមួយនៃសង្គមនោះ"ជាជាងសម្រាប់បុគ្គលម្នាក់ៗ[1997]។

បើទោះបីជាព្យសនកម្មត្រូវតែជាលក្ខណៈបុគ្គល វាមិនចាំបាច់ជាព្យសនកម្មផ្ទាល់នោះទេ[1998]។ ទំនាក់ទំនងពាក់ព័ន្ធត្រូវតែមានអត្ថិភាពរវាងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងព្យសនកម្មដែលទទួលរងជាជាងគោលដៅដែលជាចេតនានៃអំពើឧក្រិដ្ឋ[1999]។ ចំណុចនេះមានន័យថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះព្យសនកម្ម ដែលបណ្តាលឡើងដោយផ្ទាល់ពីអំពើឧក្រិដ្ឋរបស់ពួកគេ ទោះបីជាអ្នកដែលទទួលរងព្យសនកម្មទាំងនោះ មិនមែនជាគោលដៅជាក់លាក់នៃអំពើឧក្រិដ្ឋក៏ដោយ[2000]។

យុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានបែងចែករវាងជនរងគ្រោះពីរប្រភេទគឺ៖ ជនរងគ្រោះផ្ទាល់ និងជនរងគ្រោះមិនផ្ទាល់។ ជនរងគ្រោះផ្ទាល់សំដៅលើ "ក្រុមបុគ្គលណាដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬទទួលរងការប៉ះពាល់ដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់"។ ជនរងគ្រោះមិនផ្ទាល់រួមមានបុគ្គលដែល "ទទួលរងព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់"។ ឧទាហរណ៍ ជនរងគ្រោះមិនផ្ទាល់ រួមបញ្ចូលជនទាំងឡាយណាដែលពិតជាបានទទួលរងព្យសនកម្មខាងផ្លូវចិត្ត ដោយសារលទ្ធផលនៃព្យសនកម្មដែលកើតមានចំពោះអ្នកជាទីស្រឡាញ់របស់ខ្លួន[2001]។

---

[1996] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២(ខ)(ii)។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៣៩-៦៤១។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៤៧ និង ៨៣។ សំណុំរឿង ០០៥/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ១៣ និង២០។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ១២ និង១៩។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ១៣ និង២០។

[1997] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៤៩ និង៦៨ (គូសបញ្ជាក់បន្ថែម)។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ៣២។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ៣១។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ៣២។

[1998] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៧-៤១៨ និង ៤២២។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤២-៦៤៣។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 កថាខណ្ឌ ៣៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 កថាខណ្ឌ ៣៨។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ ៣៦។

[1999] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤២។ សម្រាប់ព័ត៌មានបន្ថែមអំពីទំនាក់ទំនងហេតុនិងបច្ច័យរវាងព្យសនកម្ម និងឧក្រិដ្ឋកម្ម សូមមើលផ្នែក ៧.១.២។

[2000] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤២។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៨ និង៤៤២។

[2001] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៦-៤១៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤៣។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមប

ច្បាប់ជាធរមានមិនបានដាក់កំហិតប្រភេទនៃជនរងគ្រោះមិនផ្ទាល់ ត្រឹមតែប្រភេទបុគ្គលជាក់លាក់នោះទេ ប៉ុន្តែអាចរួមបញ្ចូលសមាជិកគ្រួសារសាច់ជិត ញាតិសាច់ឆ្ងាយ ប្តីប្រពន្ធ មិត្តភក្តិ និងឪពុកម្តាយធម៌ និងកូនធម៌*តាមព្រឹត្តិន័យ* នៅពេលដែលពួកគេអាចបង្ហាញថា ព្យសនកម្មបានកើតឡើងចំពោះខ្លួន។ សិទ្ធិរបស់ជនរងគ្រោះមិនផ្ទាល់ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី អាចអនុវត្តយ៉ាងឯករាជ្យពីសិទ្ធិរបស់ជនរងគ្រោះផ្ទាល់ ដែលអនុញ្ញាតឱ្យជនរងគ្រោះមិនផ្ទាល់អាចទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាក្នុងករណីដែលជនរងគ្រោះផ្ទាល់នៅរស់រានមានជីវិត ហើយមិនបានប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយខ្លួនឯងក៏ដោយ[2002]។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គល ដែលបានចូលរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើសដែលខ្លួនអះអាងថាជាជនរងគ្រោះនោះ ត្រូវបានប្រកាសថាមិនអាចទទួលយកបាន។ ទោះបីជាទទួលស្គាល់ថា ចៅរីអាចទទួលរងការប៉ះទង្គិចផ្លូវចិត្ត ដែលជាលទ្ធផលមកពីការចូលរួមដោយផ្ទាល់របស់ខ្លួនក្នុងឧក្រិដ្ឋកម្មអន្តរជាតិយ៉ាងណាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាថា ជនរងគ្រោះដែលជាចៅរីបែបនេះ “មិនអាចត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងអ្នកប្រព្រឹត្តផ្សេងទៀត ដែលត្រូវបានចោទអំពីបទល្មើសដូចគ្នានេះឡើយ” ជាពិសេស នៅពេលដែលកាលៈទេសៈមិនហួសពីការគ្រប់គ្រងរបស់ខ្លួន[2003]។

ករណីលើកលែងតែមួយគត់ចំពោះលក្ខខណ្ឌតម្រូវព្យសនកម្មនោះ គឺអនុញ្ញាតឱ្យសិទ្ធិវន្តផ្តួចផ្តើម ឬបន្តបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក. *ក្នុងនាមជា*ជនរងគ្រោះដែលបានទទួលមរណភាព។ សិទ្ធិរបស់សិទ្ធិវន្តមិនអាស្រ័យលើថាតើជនរងគ្រោះផ្ទាល់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមុនពេលមរណភាពរបស់ខ្លួននោះទេ[2004]។

### ៧.១.១.២. ព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ និងផ្លូវចិត្ត

ព្យសនកម្មខាងរូបរាងកាយសំដៅដល់ការខូចខាតខាងជីវសាស្ត្រ ខាងសរីរាង្គ ឬខាងប្រព័ន្ធដំណើរការនៃសរីរាង្គ ដែលអាចជារបួសស្នាម កាយវិកលកម្ម ការខូចទ្រង់ទ្រាយ មានជំងឺ ការបាត់បង់ ឬ ការមិនដំណើរការនៃសរីរាង្គណាមួយ ឬ មរណភាព។ ព្យសនកម្មខាងរូបរាងកាយ “ពាក់ព័ន្ធនឹងរូបរាងកាយ” និង

---

ណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 កថាខណ្ឌ ៣៥។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 កថាខណ្ឌ ៣៨។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ ៣៦។

[2002] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៨។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ២០។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ១៩។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ២០។

[2003] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ២១។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ២០។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ២១។

[2004] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៩-៤២១។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ១៨-១៩។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ១៧-១៨។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ១៨-១៩។

“តាមធម្មតាតម្រូវឱ្យមានការព្យាបាលកម្រិតណាមួយសម្រាប់ជនរងគ្រោះ”។ វាក៏អាចបណ្តាលមកពីរបួសផ្លូវចិត្តរយៈពេលយូរ ដែលបណ្តាលឱ្យមានជំងឺនានា[2005]។

ព្យសនកម្មខាងសម្ភារៈសំដៅដល់ការបាត់បង់តម្លៃជាវត្ថុរូបិយ ដែលរួមបញ្ចូលការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងស្រុង ឬមួយផ្នែក ឬការបាត់បង់ប្រាក់ចំណូលជាដើម។ ទម្រង់នៃព្យសនកម្មនេះលាតសន្ធឹងដល់បរិបទគ្រួសារ។ ព្យសនកម្មខាងសម្ភារៈអាចបណ្តាលមកពី ឬជាផលវិបាកផ្នែកសម្ភារៈ ដែលធ្វើឱ្យខូចខាតដល់បេតិកភណ្ឌរបស់គ្រួសារ។ ចំពោះជនរងគ្រោះផ្ទាល់វិញ ព្យសនកម្មខាងសម្ភារៈក៏អាចធ្លាក់ទៅលើជនទាំងឡាយដែលជនរងគ្រោះដោយផ្ទាល់ បានផ្ទេរទៅឱ្យនៅពេលទទួលរងគ្រោះ ឬនឹងអាចផ្ទេរទៅឱ្យនាពេលអនាគត ដូចជានៅក្នុងទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ ព្យសនកម្មខាងសម្ភារៈក្នុងបរិបទនេះអាច “មានប្រភពនៅក្នុងបណ្តឹងទាមទាររបស់ជនរងគ្រោះផ្ទាល់ ដោយផ្អែកលើច្បាប់ ឬដោយផ្អែកលើកិច្ចសន្យា ដែលឧក្រិដ្ឋកម្មនេះបានរារាំងដល់ការអនុវត្ត”[2006]។

សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះបានពិចារណាថា ព្យសនកម្មផ្លូវចិត្តរួមបញ្ចូល ជំងឺធ្លាក់ទឹកចិត្ត វិបល្លាសផ្លូវចិត្ត ឬជំងឺផ្លូវចិត្ត ឬវិកលចរិត ដែលរួមបញ្ចូល តែមិនកម្រិតត្រឹមតែ ជំងឺបាក់ស្បាតនោះទេ[2007]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាថា ព្យសនកម្មផ្លូវចិត្តនៃជនរងគ្រោះមិនផ្ទាល់ក៏អាច “បណ្តាលមកពីការគ្រាន់តែបានមើលឃើញហេតុការណ៍រន្ធត់ ឬព្រឹត្តិការណ៍ហិង្សាដោយផ្ទាល់ភ្នែក ឬមានអារម្មណ៍ពិបាកក្នុងចិត្តពេលរម្លឹកហេតុការណ៍នោះឡើងវិញ មិនថារឿងនោះកើតឡើង ៣០ ឆ្នាំ កន្លងទៅហើយក៏ដោយ”[2008]។ ចៅក្រម Marchi-Uhel បានពិចារណាថា សាក្សីនៃព្រឹត្តិការណ៍ដែលជាមូលដ្ឋាននៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនោះ គប្បីមានគុណវុឌ្ឍិជាដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាព្រឹត្តិការណ៍ទាំងនោះមិនមានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់ក៏ដោយ ប្រសិនបើពួកគេបង្ហាញភស្តុតាងថា ខ្លួនបានទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង[2009]។

---

[2005] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៥ និង៤១៧។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ២៤-២៥។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ២៣-២៤។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ២៤-២៥ (យោងខាងក្នុងត្រូវបានលុបចេញ)។

[2006] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៥ និង៤១៧។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ២៦-២៧។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ២៥-២៦។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ២៦ និង២៧។

[2007] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤១។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៨៣។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 កថាខណ្ឌ ៣៩។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ ៣៧។

[2008] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ២៩។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ២៨។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ២៩។

[2009] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4

ព្យសនកម្មផ្លូវចិត្តនៃជនរងគ្រោះមិនផ្ទាល់ អាចកើតចេញពីការស្លាប់ញាតិសន្តាន ភាពមិនច្បាស់លាស់ និងការភ័យខ្លាចអំពីជោគវាសនារបស់ជនរងគ្រោះផ្ទាល់ ការដឹងអំពីការឈឺចាប់របស់ជនរងគ្រោះទាំងនោះ ឬការមានអារម្មណ៍ភ័យខ្លាចអំពីសុវត្ថិភាព និងបូរណភាពខាងផ្លូវចិត្ត។ ព្យសនកម្មផ្លូវចិត្តក៏អាចត្រូវបានបង្ហាញក្នុងស្ថានការណ៍ដែលបុគ្គលងាយរងគ្រោះ ត្រូវបានបំបែកចេញពីអ្នកថែរក្សារបស់ខ្លួន[2010]។

ដើម្បីបង្ហាញពីព្យសនកម្មផ្លូវចិត្តសម្រាប់ជនរងគ្រោះផ្ទាល់ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះតម្រូវឱ្យមានភស្តុតាងអំពីញាតិសន្តាន ឬ “ចំណងពិសេសនៃក្តីស្រឡាញ់ ឬអ្នករស់នៅក្នុងបន្ទុក” ដែលភ្ជាប់អ្នកដាក់ពាក្យស្នើសុំទៅនឹងជនរងគ្រោះផ្ទាល់[2011]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា ប្រសិនបើពុំមាន “ចំណងទាក់ទងពីមុនដែលចងភ្ជាប់ម្ចាស់បណ្តឹងទាមទារសំណង តាមផ្លូវមនោសញ្ចេតនា ញាតិលោហិត ឬសេដ្ឋកិច្ច ជាមួយនឹងជនរងគ្រោះផ្ទាល់ទេនោះ ព្យសនកម្មដែលបណ្តាលមកពីការប្រព្រឹត្តិបទល្មើសនេះ មិនអាចកើតមានចំពោះម្ចាស់បណ្តឹងទាំងនេះបានទេ”[2012]។ ចំណងពិសេសនៃសេចក្តីស្រឡាញ់មិនមានអត្ថិភាពទេ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបានកើតក្រោយការស្លាប់របស់ជនរងគ្រោះផ្ទាល់[2013]។ ទោះជាយ៉ាងណា ភាពក្មេងវ័យមិនជាចាំបាច់រារាំងជនរងគ្រោះមិនផ្ទាល់ក្នុងការមានចំណងពិសេសនៃក្តីស្រឡាញ់ជាមួយនឹងជនរងគ្រោះផ្ទាល់នោះឡើយ[2014]។

អង្គបុរេជំនុំជម្រះបានទទួលស្គាល់លទ្ធភាពនៃការបង្កើតចំណងនៃអ្នកនៅក្នុងបន្ទុក ក្នុងអំឡុងពេលអនុវត្តគោលនយោបាយរបស់ខ្មែរក្រហម សូម្បីតែក្នុងចំណោមបុគ្គលដែលមិនធ្លាប់ជួបគ្នាពីមុន ដោយសារពួកគេមានជោគវាសនា និងការភ័យខ្លាចរួម។ ឧទាហរណ៍ អង្គជំនុំជម្រះបានយោងទៅចំណងទាក់ទងរវាងអ្នកទោស ដែលឃុំក្នុងបន្ទប់ឃុំឃាំងជាមួយគ្នា។ ព្យសនកម្មផ្លូវចិត្តក៏អាចបណ្តាលមកពីព្យសនកម្មដែលទទួលរងដោយបុគ្គលដែលស្ថិតក្នុងក្រុមគោលដៅដូចគ្នាឬសហគមន៍គោលដៅដូចគ្នាផងដែរ[2015]។

### ៧.១.២. ចំណងទាក់ទងហេតុនិងបច្ច័យរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មស្ថិតក្រោមការស៊ើបអង្កេត

ម្ចាស់បណ្តឹងត្រូវបង្ហាញថាព្យសនកម្មរបស់ខ្លួន គឺជាផលវិបាកផ្ទាល់ពី “យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ”[2016]។ ផ្ទុយទៅវិញ ការពង្រីកបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទ ហួសពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដែលជាមូលដ្ឋាននៃរឿងក្តី ត្រូវចាត់ទុកថា “ជារឿងមិនត្រឹមត្រូវ និងមិនយុត្តិធម៌”[2017]។ លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង

និង ឯកសារ D411/3/6 យោបល់ជំទាស់ដោយឡែក និង ដោយផ្នែករបស់ចៅក្រម Catherine Marchi-Uhel កថាខណ្ឌ ៣៨-៣៩។

[2010] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២(គ)។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤១៧ ជើងទំព័រ ៨៧៩។ សំណុំរឿង ០០២ ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងពាក្យសុំ D250/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារ D250/3/2 កថាខណ្ឌ ១២។

[2011] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៤៦-៤៤៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤៣។

[2012] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៤៧។

[2013] ដូចខាងលើ កថាខណ្ឌ ៥៨៤។

[2014] ដូចខាងលើ កថាខណ្ឌ ៥៦៣ និង៥៩០។

[2015] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៨៦-៨៩។

[2016] វិធានផ្ទៃក្នុង វិធាន ២៣ ស្ទួន ស្ទួន (១)(ខ)។ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២(ក) និង (ខ)(ii)។

[2017] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 យោបល់ចៅក្រម Olivier Beauvallet និង Kang Jin Baik កថាខណ្ឌ៥៥។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 យោបល់ចៅក្រម Olivier Beauvallet និង Kang Jin Baik កថាខណ្ឌ ៦៤។

ហេតុនិងបច្ច័យនេះគឺបន្ថែមទៅលើវិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង ដែលដាក់កំហិតការចូលរួមចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក.[2018]។

ដោយឡែក និងខុសពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជនរងគ្រោះដែលស្វែងរកឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក. អាច “ធ្វើទៅបានតែតាមផ្លូវអន្តរាគមន៍ប៉ុណ្ណោះ”។ និយាយម្យ៉ាងទៀត អ្នកដាក់ពាក្យស្នើសុំមិនអាចធ្វើការស៊ើបអង្កេតតាមផ្លូវតុលាការ ដោយគ្រាន់តែបានចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើយ។ ប៉ុន្តែពួកគេអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តតាមរយៈពាក្យស្នើសុំដែលស្ថិតក្នុងវិសាលភាពនៃឧក្រិដ្ឋកម្មដែលសហព្រះរាជអាជ្ញាបានជ្រើសរើសចោទប្រកាន់[2019]។

វិធាន២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ពុំតម្រូវឱ្យមានទំនាក់ទំនងហេតុនិងបច្ច័យ រវាងព្យសនកម្ម និង អង្គហេតុសំខាន់ៗស្ថិតក្រោមការស៊ើបអង្កេតឡើយ។ ប៉ុន្តែ ទំនាក់ទំនហេតុនិងបច្ច័យ ត្រូវតែស្ថិតនៅចន្លោះព្យសនកម្ម និងឧក្រិដ្ឋកម្មណាមួយដែលបានចោទប្រកាន់ ដោយសារតែឧក្រិដ្ឋកម្មគឺជាការកំណត់ប្រភេទបទល្មើសនៃអង្គហេតុដែលត្រូវបានស៊ើបអង្កេត[2020]។

ទោះបីជាអង្គហេតុដែលត្រូវបានស៊ើបអង្កេតត្រូវបានកំណត់ត្រឹមតែតំបន់ ឬទីតាំងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុ រួមបញ្ចូលនូវ “ឧក្រិដ្ឋកម្មដែលតំណាងឱ្យអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់ថា ជនត្រូវចោទបានធ្វើឡើងរួមគ្នាក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម [...] ប្រឆាំងប្រជាជន និង “*នៅទូទាំង*ប្រទេស”។ ក្នុងបរិបទបែបនេះ អង្គបុរេជំនុំជម្រះបានសម្រេចថា ទីតាំងឧក្រិដ្ឋកម្មដែលបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយ “គ្រាន់តែជាឧទាហរណ៍ ដើម្បីបង្ហាញពីរបៀបដំណើរការ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស*នៅទូទាំង*ប្រទេសកម្ពុជាតែប៉ុណ្ណោះ”។ ដោយសារតែឧក្រិដ្ឋកម្ម និងគោលនយោបាយជាមូលដ្ឋានរបស់ ប.ក.ក. ដែលបង្កើតបានជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ “ត្រូវបានគេយកទៅអនុវត្តនៅទូទាំងប្រទេសកម្ពុជា” អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនចាំបាច់ត្រូវបង្ហាញពីទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ ដែលបានកំណត់អត្តសញ្ញាណនៅក្នុងផ្នែកសន្និដ្ឋានទៅលើអង្គហេតុ នៃដីកាដំណោះស្រាយនោះទេ[2021]។

នៅក្នុងមតិជំទាស់ដោយផ្នែករបស់គាត់ ចៅក្រម Marchi-Uhel យល់ឃើញថា ការបកស្រាយរបស់អង្គបុរេជំនុំជម្រះផ្ទុយទៅនឹងស្មារតី និងពាក្យពេចន៍របស់វិធានផ្ទៃក្នុង តាមរយៈការទទួលស្គាល់ជនរងគ្រោះ ដែលមិនបានចោទប្រកាន់អំពីព្យសនកម្មទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ ដែលបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ចៅក្រម Marchi-Uhel យល់ឃើញថា ជនជាប់ចោទមិនត្រូវបានចោទប្រកាន់ “ពីបទឧក្រិដ្ឋនីមួយៗ ឬបទឧក្រិដ្ឋទាំងអស់ដែលត្រូវបានលើកឡើងថា បានប្រព្រឹត្តដោយខ្មែរក្រហម

---

[2018] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ២៨ និង៥១។

[2019] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ៣០ និង៥២។ សំណុំរឿង ០០២ ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានអាស័យដ្ឋាននៅក្នុងខេត្តស្វាយរៀង ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D409 កថាខណ្ឌ ១៧។

[2020] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៤២។

[2021] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៤២ កថាខណ្ឌ ៧២ និង ៧៥។

នៅក្នុងរបបបក្សកុម្មុយនីស្តកម្ពុជានោះទេ ទោះបីជាផ្នែកមួយនៃគោលនយោបាយ [...] និង/ឬ ប្រឆាំងនឹងសមាជិកក្រុមនានាដែលត្រូវបានកំណត់ក៏ដោយ"[2022]។

ក្នុងសំណុំរឿង ០០១ ជនរងគ្រោះត្រូវបានតម្រូវឱ្យភ្ជាប់ទំនាក់ទំនងការទាមទាររបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ជាក់លាក់ ពីព្រោះជនជាប់ចោទមិនត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទូទាំងប្រទេសនោះទេ។ ហេតុដូច្នេះ ជនរងគ្រោះចាំបាច់ត្រូវភ្ជាប់ទំនាក់ទំនងការទាមទាររបស់ខ្លួន ទៅមន្ទីរសន្តិសុខ ស-២១ ឬ កន្លែងណាមួយក្រោមការគ្រប់គ្រងរបស់ ស-២១[2023]។

ក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៤ អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនដែលតម្រូវ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងសំណុំរឿង ០០៤/០២ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានលើកឡើងថា ដីកានេះបានកម្រិតវិសាលភាពយ៉ាងត្រឹមត្រូវចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចទទួលយកបានជាសក្តានុពល ត្រឹមតែតំបន់ និង ព្រឹត្តិការណ៍ជាក់លាក់មួយចំនួនប៉ុណ្ណោះ។ ចៅក្រមបានផ្តល់សំអាងហេតុថា កាលៈទេសៈក្នុងសំណុំរឿង ០០២ មិនអាចអនុវត្តបានក្នុងសំណុំរឿងនេះទេ ដោយសារតែឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ កម្រិតត្រឹមតែទីតាំងឧក្រិដ្ឋកម្ម និងបរិបទជាក់លាក់មួយចំនួន ឬ កម្រិតតាមតំបន់ភូមិសាស្ត្រ[2024]។ ក្នុងសំណុំរឿង ០០៣ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានពិចារណាថា អ្នកដាក់ពាក្យស្នើសុំគប្បីត្រូវបានទទួលយក ប្រសិនបើពួកគេបានចោទប្រកាន់ពីព្យសនកម្មដែលកើតចេញពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ណាមួយ ដែលមានទំនាក់ទំនងទៅនឹងការអនុវត្តគោលនយោបាយរបស់ ប.ក.ក. នៅក្នុងតំបន់ស្ថិតក្រោមសិទ្ធិអំណាចរបស់ជនត្រូវចោទ បើទោះបីជាឧក្រិដ្ឋកម្មនោះមិនបានកើតឡើងនៅទីតាំងជាក់លាក់ ដែលបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ។ ចៅក្រមពិចារណាថា ទោះបីជាព្យសនកម្មដែលទទួលរងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គប្បីត្រូវមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មណាមួយ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏វាមិនចាំបាច់ត្រូវភ្ជាប់ទំនាក់ទំនងទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ[2025]។

### ៧.១.៣. បន្ទុកនៃការបង្ហាញភស្តុតាង

ដើម្បីអាចទទួលយកបាន ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានព័ត៌មានគ្រប់គ្រាន់ដើម្បីអាចធ្វើការផ្ទៀងផ្ទាត់បានថាពាក្យសុំទាំងនោះគោរពតាមវិធានផ្ទៃក្នុង[2026]។ វិធាន ២៣*ស្ទួន*(៤) តម្រូវជាពិសេសឱ្យពាក្យសុំ "ផ្តល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬ ការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវបានចោទប្រកាន់"។ នៅពេលពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ ត្រូវតែមានជំនឿថា "អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ"[2027]។

---

2022 ដូចខាងលើ យោបល់ជំទាស់ដាច់ដោយឡែក និង ដោយផ្នែករបស់ចៅក្រម Catherine Marchi-Uhel កថាខណ្ឌ ៣។

2023 សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤៥។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៦៩ និង៧២។

2024 សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៥៥-៥៨។

2025 សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ៧៣-៧៤ និង៧៧។

2026 វិធានផ្ទៃក្នុង វិធាន ២៣ ស្ទួន (៤)។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.៥។

2027 វិធានផ្ទៃក្នុង វិធាន ២៣ ស្ទួន (១)។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៣១។

បទដ្ឋាននៃការបង្ហាញភ័ស្តុតាងស្តីពីភាព “បានកើតឡើងពិតប្រាកដ” មានលក្ខណៈជាក់លាក់ចំពោះភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដែលខុសប្លែកពីតេស្តស្តីពីភាពគ្រប់គ្រាន់នៃភ័ស្តុតាងដែលជាលក្ខខណ្ឌតម្រូវសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[2028]។ បទដ្ឋាននេះសន្មតជាមុនថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រពាក្យសុំរបស់ខ្លួន ប៉ុន្តែក៏តម្រូវឱ្យមានភាពពេញលេញ ភាពពិតប្រាកដ និងភាពអាចជឿជាក់បានក្នុងកម្រិតណាមួយផងដែរ។ ដូច្នេះ អ្នកដាក់ពាក្យប្តឹងត្រូវផ្តល់ភ័ស្តុតាងគាំទ្រ ឬជ្រោមជ្រែងទម្រង់បែបបទព័ត៌មានជនរងគ្រោះ និងសេចក្តីថ្លែងការណ៍របស់ខ្លួន[2029]។

ពាក្យសុំត្រូវបានបដិសេធក្នុងករណីដែលមិនមានភ័ស្តុតាងសត្យានុម័ត ឯកសារ ការបញ្ជាក់អះអាង ឬ ការពន្យល់ ដែលបង្ហាញពីឋានៈជនរងគ្រោះ អត្ថិភាពនៃជនរងគ្រោះផ្ទាល់ ចំណងនៃក្តីស្រឡាញ់ ឬភាពក្នុងបន្ទុក ភាពជាញាតិសន្តាន ឬព្យសនកម្ម[2030]។ ក្នុងន័យនេះដែរ សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្អែកលើពាក្យចចាមអារ៉ាម ពីប្រភពដែលមិនបានកំណត់អត្តសញ្ញាណច្បាស់លាស់ ឬប្រភពដែលភាពអាចជឿជាក់បានមានភាពមន្ទិលសង្ស័យយ៉ាងខ្លាំង ខកខានក្នុងការបំពេញបទដ្ឋានតម្រូវនៃការបង្ហាញភ័ស្តុតាង[2031]។ យ៉ាងណាក៏ដោយ សេចក្តីបន្ថែមនៃចម្លើយពីតតិយជនដែលមានអត្តសញ្ញាណ ដែលបញ្ជាក់អះអាងពីអត្ថិភាពនៃជនរងគ្រោះផ្ទាល់ ញាតិសន្តាន ឬ ចំណងពិសេស អាចបំពេញបទដ្ឋានតម្រូវនៃការបង្ហាញភ័ស្តុតាងបាន[2032]។ សច្ចភាពនៃឯកសារ និងសេចក្តីថ្លែងរបស់អ្នកដាក់ពាក្យសុំ ក៏ត្រូវបានទទួលយកផងដែរ នៅពេលដែលជនជាប់ចោទបានដឹងអំពីភាពពិតប្រាកដរបស់ពួកវា[2033]។

សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះបានអនុម័តវិធីសាស្ត្រដែលមានភាពបត់បែនចំពោះភ័ស្តុតាង ដោយទទួលស្គាល់មធ្យោបាយនៃការបង្ហាញភ័ស្តុតាងយ៉ាងទូលំទូលាយ ដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបានផ្សេងៗ[2034]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ទោះបីជាមានភាពមិនស៊ីចង្វាក់គ្នា ឬភាពផ្ទុយគ្នាតិចតួច អាចត្រូវបានពន្យល់ដោយផ្អែកលើកំហុសឆ្គងនៃការយល់ដឹង ឬមកពីការចងចាំមិនគ្រប់ជ្រុងជ្រោយរបស់មនុស្ស ” ជាពិសេសនៅពេលដែលពេលវេលាកន្លងផុតទៅយ៉ាងណាក៏ដោយ ក៏អ្នកដាក់ពាក្យសុំនៅតែចាំបាច់ត្រូវរៀបរាប់ព្រឹត្តិការណ៍ “ឱ្យបានលម្អិតក្នុងកម្រិតដែលអាចទទួលយកបាន”[2035]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាថា កត្តាជាក់លាក់មួយចំនួនអាច “កាត់បន្ថយកម្រិតនៃលក្ខខណ្ឌតម្រូវសម្រាប់ភ័ស្តុតាងបញ្ជាក់អំពីព្យសនកម្ម” មានដូចជា៖

i. ពេលវេលាកន្លងផុតទៅយូរ និងផលប៉ះពាល់ដែលបញ្ហានេះអាចមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំ ក្នុងការផ្តល់ឯកសារភ័ស្តុតាង ដូចជា ឯកសារពេទ្យ។

---

[2028] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាស័យដ្ឋាននៅក្នុងខេត្តស្វាយរៀង ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D409 កថាខណ្ឌ ៩។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាស័យដ្ឋាននៅក្នុងខេត្តរតនគីរី ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០ ឯកសារ D394 កថាខណ្ឌ ៨។

[2029] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥០៨ កថាខណ្ឌ ៥២៦ កថាខណ្ឌ៥៣៦ និង ៥៩៧។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ៤០។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ៤០។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ៤០។

[2030] សូមមើល ឧទាហរណ៍ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤៧-៦៤៩ សម្គាល់ជើងទំព័រ ១០៧៩។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥០៨ និង ៥៤៦-៥៤៧។ ៥៦៤-៥៦៦ កថាខណ្ឌ ៦០០-៦០៣ កថាខណ្ឌ ៦០៨-៦១២ និង ៦១៣-៦១៥។

[2031] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៤៧ និង៥៥៧។

[2032] សូមមើល ឧទាហរណ៍ ដូចខាងលើ កថាខណ្ឌ ៥៤៤ កថាខណ្ឌ ៥៦៩-៥៧០ កថាខណ្ឌ ៥៧៤-៥៧៥ កថាខណ្ឌ ៥៧៩-៥៨០ កថាខណ្ឌ ៥៨៨ និង ៦១៨-៦១៩។

[2033] សំណុំរឿង ០០១ សាលក្រម ជើងទំព័រ ១០៧៩។

[2034] សូមមើល *ឧទាហរណ៍*សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥២៦-៥២៧ (យោងទៅ សំណុំរឿង ០០១ សាលក្រម សម្គាល់ជើងទំព័រ ១០៧៩ ជើងទំព័រ ១១២២ ជើងទំព័រ ១១២៥-១១២៧ និង ១១២៩-១១៣២។

[2035] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៥៩៧។

ii. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានបញ្ហាសមត្ថភាពក្នុងការបង្ហាញ ក្នុងការឆ្លើយតប ឬធ្វើកំណត់ហេតុឱ្យបានស៊ីជម្រៅ និងត្រឹមត្រូវអំពីផលប៉ះពាល់ដែលស្ថានភាពនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានមកលើសុខភាពផ្លូវចិត្តរបស់ប្រជាជន និង
iii. ការជម្លៀស ការប្តូរទីកន្លែង និង ការផ្លាស់ទីលំនៅរបស់ប្រជាជនទៅតាមតំបន់ផ្សេងៗ និងផលប៉ះពាល់ដែលបញ្ហានេះមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការផ្តល់ភ័ស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិ ក្នុងករណីមានការចោទប្រកាន់អំពីការបាត់បង់ទ្រព្យសម្បត្តិ និងលទ្ធភាពក្នុងការផ្តល់ភ័ស្តុតាងបញ្ជាក់អំពីប្រាក់ចំណូលក្នុងករណីមានការចោទប្រកាន់អំពីការបាត់បង់ប្រាក់ចំណូល[2036]។

### ៧.១.៤. ការសន្មតទុកជាមុនតាមឆន្ទានុសិទ្ធិសម្រាប់ជនរងគ្រោះមិនផ្ទាល់

ប្រភេទជាក់លាក់នៃជនរងគ្រោះមិនផ្ទាល់មួយចំនួន អាចទទួលអត្ថប្រយោជន៍ពីការសន្មតជាមុនពីព្យសនកម្មផ្លូវចិត្ត។ ការសន្មតទុកជាមុននេះមិនលុបបំបាត់ធាតុផ្សំដែលចាំបាច់នៃការកំណត់និយមន័យ (អត្ថិភាពនៃព្យសនកម្មដោយផ្ទាល់ និងផ្ទាល់ខ្លួន) នោះទេ ប៉ុន្តែយោងតាមលក្ខខណ្ឌមួយចំនួន ការសន្មតទុកជាមុននេះអាច "បន្ថយបន្ទុកនៃការបង្ហាញភ័ស្តុតាងអំពីធាតុផ្សំនោះ"[2037]។ បុគ្គលដែលរួចផុតពីបន្ទុកនៃការបង្ហាញភ័ស្តុតាងនៃពន្យសនកម្មផ្លូវចិត្តនេះ រួមមាន៖

i. សមាជិកគ្រួសារជិតស្និទ្ធបំផុតរបស់ជនរងគ្រោះផ្ទាល់ ដោយរួមបញ្ចូលឪពុកម្តាយ កូន ប្តីប្រពន្ធ និង បងប្អូនបង្កើត។
ii. សមាជិកគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះផ្ទាល់ ដោយរួមបញ្ចូលជីដូនជីតា ម្តាយមីង និងឪពុកមា ក្មួយប្រុស និងក្មួយស្រី បងប្អូនជីដូនមួយ សាច់ថ្លៃ និងញាតិសន្តានសាច់ឆ្ងាយផ្សេងទៀត។
iii. សមាជិកនៃក្រុមគោលដៅ ឬ សហគមន៍ដូចគ្នានឹងជនរងគ្រោះផ្ទាល់។ "ការសន្មតទុកជាមុនអំពីការខូចខាតជាសមូហភាព" នេះ កើតចេញពីបរិបទសង្គម និងវប្បធម៌ ការរៀបចំរចនាសម្ព័ន្ធសង្គមឡើងវិញដែលជាលទ្ធផលនៃគោលនយោបាយខ្មែរក្រហម និង លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដូចជា អំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យ គឺក្រុមគោលដៅ ឬប្រជាជន[2038]។

### ៧.១.៥. ការបង្ហាញភ័ស្តុតាងអំពីអត្តសញ្ញាណ

វិធាន ២៣*ស្ទួន*(១)(ក) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអ្នកដាក់ពាក្យសុំបញ្ជាក់អត្តសញ្ញាណឱ្យបានច្បាស់លាស់ នៅពេលដាក់ពាក្យសុំរបស់ខ្លួន[2039]។ ដោយពិចារណាលើសិទ្ធិក្នុងការចូលរួម ដែលបានផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងផលប៉ះពាល់ជាសក្តានុពលនៃការទទួលយកផ្អែកលើភាពឆាប់រហ័សនៃកិច្ច

---

[2036] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ៤១-៤២។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ៤១-៤២។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ៤១-៤២។
[2037] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤២៥។
[2038] ដូចខាងលើ កថាខណ្ឌ ៤៤៨-៤៤៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៤៣។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៤៩ កថាខណ្ឌ ៨៦-៨៧ និង ៩៣។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ៤៥។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ៤៥។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ៤៥។
[2039] សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.៥(ក)។

ដំណើរការនីតិវិធី វាចាំបាច់ដែលថា អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំត្រូវតែ "មានភាពច្បាស់លាស់"[2040] ។ ការបញ្ជាក់ណាមួយដែលមិនបានចេញដោយអាជ្ញាធរមានសមត្ថកិច្ច ឬលេខប័ណ្ណបោះឆ្នោតដែលគ្មានសេចក្តីចម្លងរបស់ប័ណ្ណនោះ ពុំគ្រប់គ្រាន់ក្នុងការបញ្ជាក់អត្តសញ្ញាណនោះទេ[2041]។

សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះមិនអាចធ្វើអ្វីដែលផ្ទុយពីលក្ខខណ្ឌតម្រូវក្នុងការបញ្ជាក់អត្តសញ្ញាណបានទេ[2042]។ ទោះជាយ៉ាងណា ដោយទទួលស្គាល់ពីបរិបទជាក់លាក់របស់កម្ពុជា និងបញ្ហាប្រឈមជាក់ស្តែងជាសក្តានុពល ក្នុងការផ្តល់ភស្តុតាងបញ្ជាក់អត្តសញ្ញាណ អ.វ.ត.ក. បានអនុម័តវិធីសាស្រ្តដែលមានភាពបត់បែន និង ផ្អែកតាមករណីជាក់ស្តែងនីមួយៗ ដែលតាមរយៈវិធីសាស្រ្តនេះ ប្រភេទឯកសារមួយចំនួន ដែលចេញដោយអាជ្ញាធរផ្សេងៗគ្នា អាចប្រើប្រាស់ជាភស្តុតាងបញ្ជាក់អត្តសញ្ញាណបាន។ ស្របជាមួយនឹងការអនុវត្តជាទូទៅរបស់តុលាការជាតិកម្ពុជា អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយកសេចក្តីថ្លែងពីអ្នកភូមិចាស់ទុំ ឬមេភូមិ ធ្វើជាភស្តុតាងបញ្ជាក់អត្តសញ្ញាណ[2043]។

## ៧.២. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី

យោងតាមវិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីអនុញ្ញាតឱ្យជនរងគ្រោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម នៅចំពោះមុខយុត្តាធិការរបស់ អ.វ.ត.ក. តាមរយៈការគាំទ្រដល់ការចោទប្រកាន់។ តួនាទីគាំទ្រនេះបានឆ្លុះបញ្ចាំងពីផលប្រយោជន៍រួម "ទាំងសហគមន៍កម្ពុជា ដែលតំណាងដោយសហព្រះរាជអាជ្ញា និង [...] ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការសម្រេចលើការផ្តន្ទាទោសចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ"[2044]។ ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយស្ម័យប្រវត្តិ តម្រូវឱ្យមាននីតិវិធីមួយចំនួន និងសិទ្ធិចូលរួម ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ដែលលាតសន្ធឹងដល់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី[2045]។

---

[2040] សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាង លើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E2/94 កថាខណ្ឌ ៦។ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើសុំអោយពិចារណាឡើងវិញ ពាក់ព័ន្ធនឹងភស្តុតាងនៃអត្តសញ្ញាណចាំបាច់ ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (E2/36) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ឯកសារ E2/94/4 កថាខណ្ឌ ៤។

[2041] សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាង លើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E2/94 កថាខណ្ឌ ៧។ សំណុំរឿង ០០១ សេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះអ្នកដាក់ពាក្យសុំ E2/36 E2/51 និង E2/69 ចុះថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៩ ឯកសារ E2/94/2 ទំព័រ ២។

[2042] សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់ភស្តុតាង លើអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E2/94 កថាខណ្ឌ ៨។

[2043] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៩៥។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 កថាខណ្ឌ ៤៧-៤៨។ សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269 កថាខណ្ឌ ៤៧-៤៨។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ ៤៧-៤៨។

[2044] សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្ម ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ២៥។

[2045] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៣៨ និង៤៤៨។

ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ[2046] ដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាជាក់លាក់មួយចំនួន ដែលចេញដោយសហចៅក្រមស៊ើបអង្កេត[2047] និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ[2048]។ ពួកគេក៏មានសិទ្ធិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ប្រមូលយកវត្ថុតាងដទៃទៀតតំណាងឱ្យខ្លួន[2049] ឬចាត់តាំងអ្នកជំនាញថ្មីបន្ថែមដើម្បីធ្វើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលធ្វើរួចហើយ និងមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន[2050] ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការតទល់រវាំងជនត្រូវចោទជាមួយនឹងភាគីណាមួយផ្សេងទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចសួរសំណួរបាន ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត[2051]។

ក្នុងអំឡុងពេលដំណាក់កាលជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បញ្ជីឈ្មោះសាក្សី មុនពេលសវនាការបឋម[2052] ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីណា ឬទទួលយកភស្តុតាងថ្មីណាមួយក្នុងអំឡុងពេលជំនុំជម្រះ[2053] ពិនិត្យ និងទទួលយកសំណៅចម្លងនៃសំណុំរឿង តាមរយៈមេធាវីរបស់ពួកគេ[2054] ឆ្លើយតបទៅនឹងអញ្ញត្រកម្ម[2055] ឬ សួរសំណួរទៅកាន់ជនជាប់ចោទ សាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត និង អ្នកជំនាញ[2056]។ ពួកគេក៏មានសិទ្ធិត្រូវបានស្តាប់ចម្លើយ[2057] ធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[2058] ធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល និង សេចក្តីសន្និដ្ឋានឆ្លើយតប[2059]។

ទាក់ទងទៅនឹងសាលក្រម ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខសេចក្តីសម្រេចស្តីពីសំណង។ នៅពេលដែលសហព្រះរាជអាជ្ញាប្តឹងសាទុក្ខ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខសាលក្រមបាន។ ទោះជាយ៉ាងណា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងសាទុក្ខលើសេចក្តីសម្រេចផ្តន្ទាទោសបានឡើយ[2060]។ នៅក្នុងរយៈពេលនៃនីតិវិធីបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សំណើសុំភស្តុតាងបន្ថែម ប្រសិនបើភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ នឹងអាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ[2061]។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ[2062]។

ក្នុងរយៈពេលនៃកិច្ចដំណើរការនីតិវិធី វិសាលភាពនៃតួនាទី និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ជាក់បំភ្លឺ ផ្អែកតាមវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។ យុត្តិសាស្ត្រនេះមានរៀបរាប់នៅក្នុងផ្នែកខាងក្រោម។

---

2046 វិធានផ្ទៃក្នុង វិធាន ៥៥(១០)។
2047 វិធានផ្ទៃក្នុង វិធាន ៧៤(៤)។
2048 វិធានផ្ទៃក្នុង វិធាន ៧៤(៤) និង ៧៧(៣)(ខ)។
2049 វិធានផ្ទៃក្នុង វិធាន ៥៩(៥)។
2050 វិធានផ្ទៃក្នុង វិធាន ៣១(១០)។
2051 វិធានផ្ទៃក្នុង វិធាន ៥៨(៤)-(៥)។
2052 វិធានផ្ទៃក្នុង វិធាន ៨០(២)។
2053 វិធានផ្ទៃក្នុង វិធាន ៨៧(៤)។
2054 វិធានផ្ទៃក្នុង វិធាន ៨៦។ ក្នុងដំណាក់កាលបណ្តឹងសាទុក្ខ មេធាវីតំណាងភាគីក៏អាចពិនិត្យសំណុំរឿង នៅពេលណាមួយ មុនពេលវនាការ។ សូមមើល វិធានផ្ទៃក្នុង វិធាន ១០៨(៦)។
2055 វិធានផ្ទៃក្នុង វិធាន ៨៩(២)។
2056 វិធានផ្ទៃក្នុង វិធាន ៩០(២) និង ៩១(២)។
2057 វិធានផ្ទៃក្នុង វិធាន ៩១(១)។
2058 វិធានផ្ទៃក្នុង វិធាន ៩២។
2059 វិធានផ្ទៃក្នុង វិធាន ៩៤(១)(ក) និង ៩៤(២)។
2060 វិធានផ្ទៃក្នុង វិធាន ១០៥(១)(គ)។
2061 វិធានផ្ទៃក្នុង វិធាន ១០៨(៧)។
2062 វិធានផ្ទៃក្នុង វិធាន ១០៥(២)។

### ៧.២.១. សិទ្ធិក្នុងការធ្វើសេចក្ដីសន្និដ្ឋាន

ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុង "ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី"។ ផ្ទុយទៅនឹងក្របខ័ណ្ឌតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក. មិនចាំបាច់ "បង្ហាញអំពីផលប្រយោជន៍ពិសេសណាមួយនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធី"ទេ។ ហេតុដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ រួមបញ្ចូលទាំងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សមត្ថភាពរបស់ជនត្រូវចោទក្នុងការឆ្លើយតបទៅនឹងសារណានានា ដែលបានធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីណាមួយនោះ បានការពារសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងធានាបាននូវតុល្យភាពជាមួយនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការចូលរួមជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់[2063]។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចបង្ហាញការពិត ទាក់ទងនឹង "អង្គហេតុ ឬកត្តានានាដែលទាក់ទងទៅនឹងការកំណត់ពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធនៃជនជាប់ចោទ"[2064]។ ទោះជាយ៉ាងណា ដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានលើបញ្ហាទាក់ទងនឹងការផ្ដន្ទាទោសនោះទេ[2065]។ ការណ៍នេះរួមបញ្ចូលសារណាលើ ឬការវាយតម្លៃពីអង្គហេតុដែលជាមូលដ្ឋាននៃសេចក្ដីសម្រេចលើការផ្ដន្ទាទោស លើកលែងតែអង្គហេតុបែបនោះយោងសំដៅលើពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬការទាមទារសំណងណាមួយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[2066]។

ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចសួរសំណួរជនជាប់ចោទ សាក្សី ឬអ្នកជំនាញ ទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទបានទេ។ ភស្តុតាងបែបនេះទាក់ទងទៅនឹងការផ្ដន្ទាទោស (និងមិនមែនពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធ) លើកលែងតែមានភស្តុតាងច្បាស់លាស់អំពីអសមត្ថភាពផ្នែកសតិបញ្ញា ដែលអាចមានឥទ្ធិពលទៅលើអំពើរបស់ជនជាប់ចោទ ឬសមត្ថភាពរបស់ខ្លួនដើម្បីបង្កើតបានជាចេតនា ដែលចាំបាច់ត្រូវទទួលការផ្ដន្ទាទោស[2067]។ ដោយជំទាស់ទៅនឹងមតិភាគច្រើនក្នុងសំណុំរឿង ០០១ ចៅក្រម Lavergne យល់ឃើញថា ការវិភាគបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ និងលក្ខណៈជាក់លាក់នៃសាវតាររបស់ពួកគេ អាចមានភាពពាក់ព័ន្ធទៅនឹងបញ្ហាចោទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ចៅក្រម Lavergne យល់ឃើញថា ការបដិសេធសិទ្ធិក្នុងការសួរសំណួរសាក្សី ឬអ្នកជំនាញ អំពីអត្តចរិតរបស់ជនជាប់ចោទមិនស្របគ្នាទៅនឹងគោលការណ៍ចំពោះមុខ ដោយបន្ថែមថា ក្នុងករណីមួយចំនួន ដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់ព័ត៌មានសំខាន់ ដោយសារតែចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេអំពីជនជាប់ចោទ[2068]។

ពេលវេលាដែលបានផ្ដល់សម្រាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ ផ្អែកលើតម្រូវការឱ្យមានតុល្យភាពនៃសិទ្ធិរបស់ភាគី។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិទទួលបានពេលវេលាស្មើគ្នា សម្រាប់ធ្វើសេចក្ដី

---

[2063] សំណុំរឿង ០០២ សាលដីកាអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំង នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ឯកសារ C11/53 កថាខណ្ឌ ៣៦ កថាខណ្ឌ ៤៣-៤៤ កថាខណ្ឌ ៤៦ និង ៤៩ ផ្នែកសម្រេចសេចក្ដី។

[2064] សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្ដល់សក្ខីក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ៣២-៣៤។

[2065] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១០៦៤។

[2066] សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្ដល់សក្ខីក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ១, ៣៦ និង ៤០។

[2067] ដូចខាងលើ កថាខណ្ឌ ៤៥-៤៧។

[2068] ដូចខាងលើ យោបល់ជំទាស់របស់ចៅក្រម Jean-Marc Lavergne កថាខណ្ឌ ១៧, ២៧ និង ៣៥-៣៦។

សន្និដ្ឋានផ្ទាល់មាត់ ដោយមានតួនាទី "គាំទ្រ" ការចោទប្រកាន់។ ពេលវេលាបន្ថែម អាចត្រូវបានផ្តល់ឱ្យប្រសិនបើយល់ឃើញថាចាំបាច់ ឬ កាត់បន្ថយនៅពេលណាដែលសេចក្តីសន្និដ្ឋានមិនពាក់ព័ន្ធ ឬជាន់គ្នា[2069]។

### ៧.២.២. សិទ្ធិក្នុងការចូលរួមដោយផ្ទាល់

ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចលើកអំណះអំណាងដោយផ្ទាល់ទៅកាន់អង្គជំនុំជម្រះបានទេ ក្រៅពីតាមរយៈតំណាងរបស់ពួកគេ លើកលែងតែក្នុងកាលៈទេសៈពិសេស។ ដូចដែលបានថែងពីដើមដំបូង វិធាន ២៣ នៃវិធានផ្ទៃក្នុង មិនមានការដាក់កំហិតលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងការនិយាយតំណាងឱ្យខ្លួនឯងទេ ហើយក៏មិនតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវតំណាងដោយមេធាវីណាម្នាក់ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនោះដែរ[2070]។ អង្គបុរេជំនុំជម្រះបានពិចារណាថា ដើម្បីធានាបាននូវ "កិច្ចដំណើរការនីតិវិធីឆាប់រហ័ស" "សេចក្តីសន្និដ្ឋានពាក់ព័ន្ធ" និង ដើម្បី "ជៀសវាងការរាំងស្ទះ" វិធានផ្ទៃក្នុងគប្បីបកស្រាយថា តម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែលបានជ្រើសរើស ត្រូវបានតំណាងដោយមេធាវីណាម្នាក់ ដើម្បី "ធ្វើការកត់សម្គាល់ដោយសង្ខេបរបស់ខ្លួន អំពីពាក្យសុំ ឬ បណ្តឹងឧទ្ធរណ៍ តាមរយៈមេធាវីរបស់ខ្លួន"[2071]។ អង្គបុរេជំនុំជម្រះបានបកស្រាយវិធានផ្ទៃក្នុង ៧៧(១០) ដែលចែងថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាំងអស់តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី "ត្រូវធ្វើឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី"[2072]។

នៅក្នុងការសម្រេចលើសំណើសុំជាបន្ទុបន្ទាប់ ដែលបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំថ្លែងទៅកាន់អង្គជំនុំជម្រះដោយផ្ទាល់ ចៅក្រមភាគច្រើនលើសលប់នៃអង្គបុរេជំនុំជម្រះបានសម្រេចថា មានតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើសេចក្តីសង្កេតផ្ទាល់មាត់ដោយសង្ខេប និងថា ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ "មិនអាចអនុញ្ញាតឱ្យ [...] លើកអំណះអំណាងដោយផ្ទាល់នៅចំពោះមុខតុលាការបានទេ"[2073]។ នៅក្នុងមតិជំទាស់របស់ខ្លួន ចៅក្រម Downing យល់ឃើញថា មានភាពផ្ទុយគ្នារវាងវិធាន ២៣ នៃវិធានផ្ទៃក្នុង ដែលបានផ្តល់ "សិទ្ធិចូលរួមជាទូទៅ" ហើយវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង ដែលដាក់កម្រិតលើការសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គបុរេជំនុំជម្រះទៅឱ្យមេធាវីរបស់ខ្លួនទៅវិញ។ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់មេធាវីរបស់ខ្លួន និងលែងមានអ្នកតំណាងហើយនោះ ចៅក្រម Downing នឹងអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនោះចូលរួមដោយខ្លួនឯង និងលើកអំណះអំណាងអំពីបញ្ហាយុត្តាធិការនៅចំពោះមុខអង្គបុរេជំនុំជម្រះបាន[2074]។

ការបកស្រាយដោយសំឡេងភាគច្រើននៃអង្គបុរេជំនុំជម្រះ ត្រូវបានចងក្រងនៅក្នុងវិសោធនកម្ម (លើកទី ៣) នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩ ដោយវិធាន ២៣*ស្ទួនពីរ* ដែលចែងថា "នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយមេធាវី សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានអនុវត្តតាមរយៈមេធាវីនោះ"[2075]។ ទោះជាយ៉ាងណា វិធាននេះមិនបានអនុវត្តក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណី ត្រូវ

---

[2069] សំណុំរឿង ០០២ សេចក្តីសម្រេចទទួលយកសេចក្តីសង្កេតជាទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ មិថុនា ឆ្នាំ ២០០៨ ឯកសារ C22/I/41 កថាខណ្ឌ ៦។

[2070] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី០) វិធាន ២៣(៧)។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីណែនាំអំពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍ចំពោះដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ឧសភា ឆ្នាំ២០០៨ ឯកសារ C20/I/21 កថាខណ្ឌ ៣។

[2071] សំណុំរឿង ០០២ សេចក្តីណែនាំអំពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍ចំពោះដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ឧសភា ឆ្នាំ២០០៨ ឯកសារ C20/I/21 កថាខណ្ឌ ១ និង ៥។

[2072] ដូចខាងលើ ផ្នែកសម្រេចសេចក្តី។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ អំពីសំណើសុំលើកអំណះអំណាងនៅចំពោះមុខតុលាការដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C22/I/54 កថាខណ្ឌ ៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ខំ ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C22/I/46 កថាខណ្ឌ ៨។

[2073] សំណុំរឿង ០០២ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ អំពីសំណើសុំលើកអំណះអំណាងនៅចំពោះមុខតុលាការដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C22/I/54 កថាខណ្ឌ ២-៣។

[2074] ដូចខាងលើ យោបល់ជំទាស់របស់ចៅក្រម Rowan Downing កថាខណ្ឌ ១-៤។

[2075] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី៣) វិធាន ២៣(៧)(i) (បច្ចុប្បន្នមាននៅក្នុង វិធានផ្ទៃក្នុង (វិសោធនកម្មលើទី១០) វិធាន ២៣ ស្ទួនពី ស្ទួន (២)។

បានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលស៊ើបអង្កេត ឬត្រូវបានសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលសវនាការនោះទេ[2076]។

យ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងស្របច្បាប់អាចលើកអំណះអំណាងទៅកាន់អង្គជំនុំជម្រះដោយផ្ទាល់ នៅពេលដែលផលប្រយោជន៍របស់ខ្លួនខុសពីផលប្រយោជន៍របស់សហព្រះរាជអាជ្ញា ពោលគឺ ក្នុងករណីដែលផលប៉ះពាល់ដែលអាចកើតចេញពីសេចក្តីសម្រេចណាមួយនោះ អាចនឹងធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីនោះមិនមានលទ្ធភាពទាមទារសំណង[2077]។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងដែលទាមទារសិទ្ធិលើកអំណះអំណាងនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងសវនាការដែលបានគ្រោងទុក ត្រូវបានតម្រូវឱ្យផ្តល់ការជូនដំណឹងជាមុន តាមរយៈការធ្វើសំណើជាលាយលក្ខណ៍អក្សរពន្យល់អំពីខ្លឹមសារ និងភាពជាក់ព័ន្ធនៃសេចក្តីសន្និដ្ឋានរបស់ខ្លួន យ៉ាងហោចណាស់រយៈពេល ១០ ថ្ងៃ មុនថ្ងៃសវនាការ[2078]។

តាំងពីវិសោធនកម្មក្នុងខែកុម្ភៈ ឆ្នាំ២០១០ (វិសោធនកម្មលើកទី៥) ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតម្រូវឱ្យ៖ (១) ត្រូវបានតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[2079] និង (២) ត្រូវបង្កើតជាក្រុមរួមបញ្ចូលគ្នាតែមួយ ដែលផលប្រយោជន៍របស់ពួកគេត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[2080]។ ជាលទ្ធផល ចាប់ពីដំណាក់កាលជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមាន "ការទទួលខុសត្រូវជាចុងក្រោយទៅកាន់តុលាការ សម្រាប់ការផ្តល់ការអះអាង និង យុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការអំពីផលប្រយោជន៍ របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយនោះ"[2081]។ ដើម្បីធានាបាននូវប្រសិទ្ធភាពនីតិវិធី អង្គជំនុំជម្រះក៏អាចកម្រិតចំនួនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលអាចថ្លែងការណ៍ផងដែរ[2082]។

ទោះបីជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តម្រូវឱ្យស្វែងរកទស្សនៈផ្សេងៗពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនឹងព្យាយាមឱ្យអស់ពីលទ្ធភាពដើម្បីឈានដល់ការឯកភាពគ្នាជាឯកច្ឆន្ទ ក្នុងការសម្របសម្រួលការតំណាងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ពួកគេមិនតម្រូវឱ្យ "មានការឯកភាពពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី *នៅគ្រប់ដំណាក់កាល*" នោះទេ។ ជាពិសេស ពួកគេមិនតម្រូវឱ្យធ្វើដូច្នោះឡើយ ក្នុងស្ថានភាពមួយដែលការណ៍នេះមិនស្របជាមួយកាតព្វកិច្ចចម្បងរបស់សហមេធាវីនាំមុខ អនុលោមតាមវិធាន១២*ស្ទួនពីរ*(១) នៃវិធានផ្ទៃក្នុង ដើម្បី "ធានាឱ្យមានប្រសិទ្ធភាពនូវការរៀបចំការតំណាងដើមបណ្តឹងរដ្ឋប្បវេណីចាប់ពីដំណាក់កាលជំនុំជម្រះតទៅ [...] ដែលធ្វើឱ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឱ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័សក្នុងបរិបទពិសេសរបស់ អ.វ.ត.ក."[2083]។ នៅក្នុងមតិជំទាស់របស់គាត់ ចៅក្រម Lavergne ពិចារណាថាដំណាក់កាលបឋមនៃការពិគ្រោះយោបល់នេះ ពុំមែនធ្វើឡើងតាមការជ្រើសរើសឡើយ ដែលក្នុងដំណាក់កាលនេះ សហមេធាវីនាំមុខអាច "ស្វែងរកទស្សនៈផ្សេងៗពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី"។

---

[2076] វិធានផ្ទៃក្នុង វិធាន ២៣*ស្ទួនពីរ*(២) ត្រូវបកស្រាយរួមគ្នាជាមួយវិធាន ៥៩ និង ៩១(១)។
[2077] សំណុំរឿង ០០២ សេចក្តីបង្គាប់ស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ C22/I/69 កថាខណ្ឌ ៩-១០ ផ្នែកសម្រេចសេចក្តី។
[2078] ដូចខាងលើ កថាខណ្ឌ ១១ ផ្នែកសម្រេចសេចក្តី។
[2079] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី៥) វិធាន ២៣ *ស្ទួនពីរ*(១) បច្ចុប្បន្ននេះមាននៅក្នុងវិធានដដែលនៃ វិធានផ្ទៃក្នុង (វិសោធនកម្មលើទី១០)។
[2080] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី៥) វិធាន ២៣(៥) បច្ចុប្បន្ននេះមាននៅក្នុងវិធានផ្ទៃក្នុង (វិសោធនកម្មលើទី១០) វិធាន ២៣(៣)។
[2081] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ*(៥)(ខ)។
[2082] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ ប្រតិចារឹកសវនាការបឋម ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E1/6.1 ទំព័រ ៦៩-៧០។
[2083] សំណុំរឿង ០០២ សេចក្តីសម្រេចលើ "សារណាបន្ទាន់ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យកែតម្រូវអនុស្សរណៈ E62/3/10" (លេខឯកសារ E62/3/10/1) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ឯកសារ E62/3/10/4 ទំព័រ ២ (ដកស្រង់ វិធានផ្ទៃក្នុង (វិសោធនកម្មលើទី៧) វិធាន ១២*ស្ទួនពីរ*(១))។

យោងតាមចៅក្រម Lavergne "ការទទួលខុសត្រូវចុងក្រោយ" កើតឡើងនៅពេលដែលសហមេធាវីនាំមុខមិនអាចឈានទៅដល់ការឯកភាពគ្នា[2084]។

### ៧.២.៣. សិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានបើក និងបិទកិច្ចពិភាក្សាដេញដោល

ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានបើកការពិភាក្សាដេញដោលទេ។ ទោះជាយ៉ាងណា ពួកគេមានឱកាសធ្វើសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានឆ្លើយតប[2085]។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ ឬ ចំណាប់អារម្មណ៍បឋមក្នុងសំណុំរឿង ០០១ និង ០០២ ដោយលើកឡើងថា ទាំងវិធាន ៨៩*ស្ទួន* នៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនផ្តល់សិទ្ធិបែបនេះដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ[2086]។ អង្គជំនុំជម្រះបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណី "ពុំមានសិទ្ធិដូច ឬស្មើគ្នាទាំងស្រុងទៅនឹងចុងចោទ និងសហព្រះរាជអាជ្ញា"នោះទេ។ ដោយពិចារណាថា សេចក្តីសន្និដ្ឋានចោទប្រកាន់គឺជាការពន្យល់សង្ខេបអំពីការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី "ពុំមានតួនាទីជាស្វ័យប្រវត្តិដើម្បីអនុវត្តនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ"។ ហេតុដូច្នេះ ការបដិសេធនេះមិនរំលោភបំពានលើកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ និងការធានាឱ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយនោះទេ អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង[2087]។

### ៧.២.៤. វិសាលភាពនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានស្តាប់ចម្លើយ ដូចសាក្សីធម្មតានៅក្នុងរឿងក្តីដូចគ្នានោះទេ។ ពួកគេអាចត្រូវបានស្តាប់ចម្លើយក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬជនជាប់ចោទដែរ[2088]។

ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានរៀបចំកាលវិភាគ "សវនាការស្តីពីផលប៉ះពាល់លើជនរងគ្រោះ"[2089] ដើម្បីផ្តល់លទ្ធភាពឱ្យមានការបង្ហាញ "ភ័ស្តុតាងស្តីពីការទទួល

[2084] សំណុំរឿង ០០២ មតិជំទាស់របស់ចៅក្រម Jean-Marc Lavergne ពាក់ព័ន្ធនិងសេចក្តីសម្រេចដែល ចេញដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអនុស្សរណៈ E62/3/10/4 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ឯកសារ E62/3/10/4.1 កថាខណ្ឌ ១៤ (ដកស្រង់ វិធានផ្ទៃក្នុង (វិសោធនកម្មលើទី៨) វិធាន ១២ *ស្ទួនពីរ* (៣))។

[2085] វិធានផ្ទៃក្នុង វិធាន ៩៤(១)(ក) និង ៩៤(២)។ សូមមើលផងដែរ សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩ ឯកសារ E23/4 កថាខណ្ឌ ៥, ៧ និង ៩។ សូមមើល សំណុំរឿង ០០២ ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារ E131 ទំព័រ ៣។ សំណុំរឿង ០០២ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំធ្វើការកត់សម្គាល់បឋមត្រួសៗជំនួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណី (E131/4) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E131/4/1 ទំព័រ ១។

[2086] សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩ ឯកសារ E23/4 កថាខណ្ឌ ៤, ៧ និង ៩។ សំណុំរឿង ០០២ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំធ្វើការកត់សម្គាល់បឋមត្រួសៗជំនួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណី (E131/4) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E131/4/1 ទំព័រ ១។

[2087] សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩ ឯកសារ E23/4 កថាខណ្ឌ ៥-៧ និង ៩។

[2088] វិធានផ្ទៃក្នុង វិធាន ២៣(៤)។

[2089] សំណុំរឿង ០០២/០១ ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ឯកសារ E218 កថាខណ្ឌ ១៦ និង ១៨។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សេចក្តីជូនដំណឹងបន្ថែមពាក់ព័ន្ធការកំណត់កាលបរិច្ឆេទនៃសវនាការ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E236/5 កថាខណ្ឌ ២ និង ៤។ សំណុំរឿង ០០២/០២ ព័ត៌មានអំពី (១) សវនាការ

រងនូវការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងផលប៉ះពាល់លើជនរងគ្រោះដោយសារតែឧក្រិដ្ឋកម្ម"[2090]។

ដើមបណ្ដឹងរដ្ឋប្បវេណីក៏ទទួលបានឱកាសធ្វើ "សេចក្ដីថ្លែងអំពីទុក្ខសោក" នៅពេលបញ្ចប់សក្ខីកម្មរបស់ខ្លួន ក្នុងអំឡុងពេលសវនាការលើអង្គសេចក្ដីផងដែរ ដើម្បីបង្ហាញពីវិសាលភាពពេញលេញនៃព្យសនកម្មជាទូទៅ ដែលពួកគេបានទទួលរងគ្រោះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[2091]។ អង្គជំនុំជម្រះសាលាដំបូងបានបែងចែករវាងសក្ខីកម្មលើបញ្ហាអង្គហេតុ ដែលកំណត់ត្រឹមវិសាលភាពនៃការជំនុំជម្រះ និងជាកម្មវត្ថុនៃអំណះអំណាងតទល់គ្នា និងសេចក្ដីថ្លែងអំពីទុក្ខសោកជាទូទៅ[2092]។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានទាមទារឱ្យបែងចែកនៅក្នុងសេចក្ដីថ្លែងរបស់ខ្លួនរវាង ព្យសនកម្មដែលទទួលរងការឈឺចាប់ដែលជាលទ្ធផលនៃអង្គហេតុស្ថិតក្នុងវិសាលភាពនៃរឿងក្ដី នឹងព្យសនកម្មជារួម ដែលទទួលរងការឈឺចាប់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ[2093]។ ទោះជាយ៉ាងណា ភាគីត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីអធិប្បាយ និងលើកឡើងពីធាតុផ្សំនានានៃសេចក្ដីថ្លែងអំពីទុក្ខដែលទំនងជាមិនពាក់ព័ន្ធ បន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ[2094]។ ភាគីការពារក្ដីមានឱកាសជំទាស់ ក្នុងករណីដែលសិទ្ធិរបស់ជនជាប់ចោទត្រូវបានជឿជាក់ថាទទួលរងការរំលោភបំពាន[2095]។ ជាងនេះទៀត ប្រសិនបើសេចក្ដីថ្លែងអំពីទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី លើកឡើងពីអង្គហេតុ ឬការចោទប្រកាន់ថ្មីប្រឆាំងនឹងជនជាប់ចោទនោះភាគីការពារក្ដីអាចស្នើសុំឱ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើងវិញ ដើម្បីធ្វើការស្ដាប់ចម្លើយបន្ថែមទៀត។ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកសំណើបែបនេះ ដើម្បីធានាថាព័ត៌មានថ្មីណាមួយដែលអាចប៉ះពាល់ដល់ពិរុទ្ធភាពរបស់ជនជាប់ចោទ អាចត្រូវបានពិនិត្យយ៉ាងហ្មត់ចត់[2096]។

ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានរារាំងមិនឱ្យផ្ដល់សក្ខីកម្មលើបញ្ហានានា ទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ[2097]។ ផ្ទុយទៅវិញ វិធានផ្ទៃក្នុងបានផ្អែកលើការសន្មតទុកជាមុនថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់ព័ត៌មានទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ[2098]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអាចបង្កើតបានជាផ្នែកមួយនៃភស្តុតាង ដែលត្រូវបានផ្អែកលើដើម្បីកំណត់ពិរុទ្ធភាព[2099]។ អង្គជំនុំជម្រះបានផ្ដល់សំអាងហេតុថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានលើកឡើងរួម

លើកាបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E315/1 កថាខណ្ឌ ៧ និង ៩។

[2090] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៧ និង ៣២១។

[2091] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្ដឹងរដ្ឋប្បវេណី TCCP-187 ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ឯកសា E267/3 កថាខណ្ឌ ១៤។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៧ និង ៣២០។

[2092] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្ដឹងរដ្ឋប្បវេណី TCCP-187 ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ឯកសា E267/3 កថាខណ្ឌ ១៤។ សំណុំរឿង ០០២/០២ ព័ត៌មានអំពី (១) សវនាការលើកាបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ឯកសា E315/1 កថាខណ្ឌ ៨។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣២០។

[2093] សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្ដឹងរដ្ឋប្បវេណី TCCP-187 ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ឯកសា E267/3 កថាខណ្ឌ ១៥ និង ១៧ និង ផ្នែកសម្រេចសេចក្ដី។ សំណុំរឿង ០០២/០២ ព័ត៌មានអំពី (១) សវនាការលើកាបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ឯកសា E315/1 កថាខណ្ឌ ៨។

[2094] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៧។

[2095] ដូចខាងលើ កថាខណ្ឌ ៣២០។

[2096] ដូចខាងលើ។ សូមមើលផងដែរ សំណុំរឿង ០០២/០២ ព័ត៌មានអំពី (១) សវនាការលើកាបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១២ ឯកសា E315/1 កថាខណ្ឌ ៨។

[2097] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១២-៣១៣។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៥។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។

[2098] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៣។

[2099] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៥ និង១៤១៨។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៣។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។

គ្នាជាមួយនឹងសាក្សី និងអ្នកជំនាញ នៅក្នុងវិធាន ៩១(១) នៃវិធានផ្ទៃក្នុង ថាជាប្រភពបង្ហាញការពិត។ ស្រដៀងគ្នានេះដែរ ការស្តាប់ចម្លើយធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៩ នៃវិធានផ្ទៃក្នុង អាចលើកឡើងបញ្ហាពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនសង្ស័យ[2100]។

### ៧.២.៥. តម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានលើកលែងចេញពីការផ្តល់សក្ខីកម្មក្រោមសម្បថយ៉ាងណាក៏ដោយ ក៏ភស្តុតាងរបស់ពួកគេមិនត្រូវបានបដិសេធនោះឡើយ[2101]។ ផ្ទុយទៅវិញ សេចក្តីថ្លែងការណ៍របស់ពួកគេត្រូវបានវាយតម្លៃជាភស្តុតាងនៅពេលដែលមានភាពពាក់ព័ន្ធ និងមានតម្រូយ[2102]។ ទោះជាយ៉ាងណា ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ អាចជាប់ពាក់ព័ន្ធទៅនឹងតម្លៃជាភស្តុតាង និង/ឬភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់ខ្លួន[2103]។

នៅពេលធ្វើការយល់ឃើញអំពីអង្គហេតុទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងអាចផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីថ្លែងអំពីទុក្ខសោកដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ក្រោយការផ្តល់សក្ខីកម្មក្នុងសវនាការរបស់ខ្លួន និងសក្ខីកម្មស្តីពីផលប៉ះពាល់លើជនរងគ្រោះ[2104]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ទោះបីជា “នេះអាចជាការខុសប្រក្រតីសម្រាប់ការយល់ឃើញដែលជាស្នូលនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ផ្អែកតែទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ [...] អង្គជំនុំជម្រះតុលាការកំពូលពុំដកចេញនូវលទ្ធភាពដែលថាការយល់ឃើញនៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលផ្នែកព្រហ្មទណ្ឌអាចសំអាងជាបឋមទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីឡើយ”[2105]។

អង្គជំនុំជម្រះបានវាយតម្លៃលើទម្ងន់ដែលបានផ្តល់ឱ្យសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី “តាមករណីជាក់ស្តែងនីមួយៗ” ដោយផ្អែកលើកត្តានានាដូចជា “អត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីចង្វាក់គ្នា ឬមិនស៊ីចង្វាក់គ្នាទាក់ទងទៅនឹងអង្គហេតុសត្យានុម័ត ការជំរុញទឹកចិត្តដោយខ្លួនឯង ការអះអាងបំភ្លឺបន្ថែម និងកាលៈទេសៈនានានៃរឿងក្តី”[2106]។ អង្គជំនុំជម្រះក៏ពិចារណាផងដែរលើកត្តានានាដែលពាក់ព័ន្ធទៅនឹងឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចជា នត្ថិភាពនៃសម្បថ ផលប្រយោជន៍របស់ពួកគេក្នុងការទាមទារសំណង កង្វះការដាក់ទណ្ឌកម្មចំពោះសក្ខីកម្មក្លែងក្លាយ និងលទ្ធភាពរបស់ពួកគេក្នុងការពិគ្រោះយោបល់ជាមួយមេធាវីក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី[2107]។

ទោះជាយ៉ាងណា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានជឿជាក់ថាមានតម្លៃជាភស្តុតាងទាបដោយខ្លួនឯងជាងភស្តុតាងក្នុងទម្រង់ផ្សេងទៀតនោះឡើយ[2108]។

---

[2100] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៣។
[2101] ដូចខាងលើ។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។
[2102] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៥ និង ១៤១៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៥២។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ឯកសា E267/3 កថាខណ្ឌ ២១។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។
[2103] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៣។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។
[2104] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣០៥ កថាខណ្ឌ ៣១៨ កថាខណ្ឌ ៣២០-៣២២ និង ៣២៤។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។
[2105] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៨ (គូសបញ្ជាក់បន្ថែម)។
[2106] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៤។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៩ និង ៣៥២៨។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៤២ និង ៥៣។
[2107] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៥។ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៧។
[2108] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ១៤១៥ (យោង សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៣១៣)។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៧។

ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ ត្រូវបានផ្តល់ទម្ងន់ធ្ងន់ច្រើនជាងការរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[2109]។ អង្គជំនុំជម្រះបានកត់សម្គាល់ជាច្រើនលើកថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានប្រមូលដោយមិនមានការត្រួតពិនិត្យដោយតុលាការ ពុំត្រូវបានសន្មតថា មានភាពអាចជឿជាក់បាននោះទេ និងទទួលបានទម្ងន់ជាភ័ស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមាន នៅពេលដែលគ្មានព័ត៌មានអំពីកាលៈទេសៈនានាដែលពួកវាត្រូវបានធ្វើកំណត់ហេតុ[2110]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ភាគច្រើននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ "ត្រឹមតែផ្តល់សេចក្តីសន្និដ្ឋានទូទៅដោយពុំមានពន្យល់នូវប្រភពអំពីការដឹងរបស់សាមីបុគ្គល ដូច្នេះអាចជា "ការចងចាំរួម" ឬ "ការពិពណ៌នាធម្មតា" ប៉ុន្តែពុំមែនបទពិសោធន៍ផ្ទាល់ខ្លួនដែលនេះពុំសមស្របក្នុងការបង្ហាញអង្គហេតុពាក់ព័ន្ធឡើយ"[2111]។ កាន់តែទូទៅជាងនេះ កំណត់ហេតុក្រៅតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភ័ស្តុតាងដែលមិនត្រូវបានប្រមូលសម្រាប់គោលបំណងការជំនុំជម្រះក្តីព្រហ្មទណ្ឌ ត្រូវបានពិចារណាថាមានតម្លៃជាភ័ស្តុតាងទាប[2112]។

សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/០១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤/០២, ០០៣ និង ០០៥ បានអនុម័ត និងតម្កល់វិធីសាស្ត្រនេះ ដោយបានរំលឹកថាសេចក្តីថ្លែងការណ៍ ឬភ័ស្តុតាងដែលបានប្រមូលដោយពុំមានការត្រួតពិនិត្យដោយតុលាការ ធ្វើឡើងដោយស្ថាប័នខាងក្រៅ អ.វ.ត.ក. មិនត្រូវបានបង្កើតឡើងដោយមានការធានាដោយតុលាការ និងទម្រង់ការដែលកំណត់ប្រភេទភ័ស្តុតាងដែលបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេតនោះទេ[2113]។

ទោះបីជាមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាន ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/០១ បានសម្រេចជាឯកច្ឆន្ទថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុង "ការបង្កើតឋានានុក្រមនៃភ័ស្តុតាងផ្អែកលើប្រភពផ្លូវការ ដោយមិនផ្អែកលើខ្លឹមសារនៃភ័ស្តុតាង"។ ចៅក្រមបានផ្តល់សំអាងហេតុថា ការប្រមូលភ័ស្តុតាងនៅអ.វ.ត.ក. ត្រូវបានកំណត់ដោយគោលការណ៍សេរីភាពនៃភ័ស្តុតាង ដែលក្រោមគោលការណ៍នេះ ភ័ស្តុតាងទាំងអស់អាចទទួលយកបាន ហើយជាទូទៅគប្បីមានសច្ចាធារណ៍ផ្លូវច្បាប់នៃតម្លៃជាភ័ស្តុតាងស្មើគ្នា។ ចៅក្រមបានលើកឡើងថា "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់" គួរតែជា "ឥទ្ធិពលដែលខ្លឹមសារនៃភ័ស្តុតាងនោះអាចមានទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហាថាតើមានភ័ស្តុតាងគ្រប់គ្រាន់ឬអត់ សម្រាប់ការចោទប្រកាន់នោះ"។ ជាវិបាក អង្គបុរេជំនុំជម្រះបានសម្រេចថា ភាពអាចជឿទុកចិត្តបាននៃភ័ស្តុតាងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គប្បីត្រូវបានវាយតម្លៃតាមករណីជាក់ស្តែងនីមួយៗ ហើយមិនត្រូវបានចាត់ទុកជាស្វ័យប្រវត្តិថាមិនអាចជឿជាក់បានដោយខ្លួនឯងនោះទេ[2114]។ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ដូចគ្នាក្នុងសំណុំរឿង ០០៤/០២[2115]។ ទោះបីជាអង្គបុរេជំនុំជម្រះមិនបានធ្វើការសម្រេចទាំងអស់

[2109] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៩ និង ៣៥២៨។
[2110] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ E96/7 កថាខណ្ឌ ២៩។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៤៥៥, ៤៦២ និង ៤៧៥។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៩៦។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៩ កថាខណ្ឌ ៧៣ និង ៣៥២៨។
[2111] សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ៤៥៧។
[2112] សំណុំរឿង ០០២/០២ សាលដីកា កថាខណ្ឌ ៤៦២។ សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ២៩៦ និង ៥៥០។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៦៩។
[2113] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១០៣-១០៤ និង ១០៧។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៧-១២០។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៩១-៥៩២ និង ៥៩៤។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១១៨-១១៩ និង ១២១។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៥៤-៣៥៥។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១២៣-១២៤ និង ១២៦។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៨៥-៤៨៦ និង ៤៨៨។
[2114] សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤១-៥៩។
[2115] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៧៣-៨៣។

នេះជាឯកច្ឆន្ទក្នុងសំណុំរឿង ០០៣ និង ០០៤ យ៉ាងណាក៏ដោយ ក៏ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់បញ្ហាទាំងនេះឡើងវិញ នៅក្នុងយោបល់ដាច់ដោយឡែករបស់ខ្លួន[2116]។

### ៧.៣. សំណង

គោលបំណងនៃសកម្មភាពដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូល "សំណងផ្លូវចិត្ត និងសមូហភាព"[2117]។ ផ្ទុយទៅនឹងក្របខ័ណ្ឌរបស់តុលាការ ICC ដែលឋានៈជនរងគ្រោះសម្រាប់ការចូលរួមការជំនុំជម្រះ មិនធានាសិទ្ធិក្នុងការចូលរួម និងអាចត្រូវបានវាយតម្លៃឡើងវិញនៅពេលផ្តន្ទាទោស ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក. អាចទាមទារសំណងដោយពុំមានការវាយតម្លៃឡើងវិញបែបនោះឡើយ[2118]។ ហេតុដូច្នេះ នៅពេលដែលជនរងគ្រោះបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ការចូលរួមរបស់ខ្លួនរួមបញ្ចូលសិទ្ធិជាភាគីមួយក្នុងការជំនុំជម្រះព្រហ្មទណ្ឌរបស់ជនជាប់ចោទ និងសិទ្ធិក្នុងការទាមទារសំណងផ្លូវចិត្ត និងសមូហភាព[2119]។

#### ៧.៣.១. សិទ្ធិទទួលបានសំណង

យន្តការសំណងរបស់ អ.វ.ត.ក. ទាញចេញពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ[2120]។ ទោះជាយ៉ាងណា ភាពពាក់ព័ន្ធនៃប្រភពទាំងអស់នេះមានកម្រិត ដោយសារតែគម្រោងសំណងដែលមានចែងដោយវិធាន ២៣*ស្ទួនបួន* "ដែលសមស្របទៅតាមអាណត្តិ និងយន្តការ*ពិសេសខុសប្លែកពីគេ*របស់ អ.វ.ត.ក."[2121]។ ការដកចេញពីច្បាប់ក្នុងស្រុកត្រូវបានពិចារណាថា "ចាំបាច់ដោយគិតអំពីចំនួនដ៏ច្រើននៃដើមបណ្តឹងរដ្ឋប្បវេណី ដែលរំពឹងថាមាននៅចំពោះមុខ អ.វ.ត.ក. និងផលវិបាកដែលមិនអាចចៀសផុត នៃការកំណត់បរិមាណក្នុងវិសាលភាពពេញលេញនៃការបាត់បង់ ដែលក្រុមជនរងគ្រោះដែលមានលក្ខណៈមិនច្បាស់លាស់បានទទួលរង"[2122]។

##### ៧.៣.១.១. គម្រោងសំណងផ្លូវចិត្ត និងសមូហភាព

ខុសពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. មិនបានផ្តល់អំណាចឱ្យអង្គជំនុំជម្រះផ្តល់សំណងជាលក្ខណៈបុគ្គល និងជាហិរញ្ញវត្ថុឡើយ ប៉ុន្តែអាចផ្តល់បានតែសំណងផ្លូវចិត្ត និងសមូហភាពប៉ុណ្ណោះ[2123]។

---

[2116] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់ចៅក្រម Olivier Beauvallet និង Kaing Jin Baik កថាខណ្ឌ ១៥៤-១៥៥។ សូមមើលផងដែរ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់ចៅក្រម Kaing Jin Baik និង Olivier Beauvallet កថាខណ្ឌ ២៣៥។
[2117] វិធានផ្ទៃក្នុង វិធាន ២៣(១)(ខ)។
[2118] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៤៨៣-៤៨៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦០។
[2119] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៣៩។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦០។
[2120] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៤១ និង ៦៤៥-៦៥២។
[2121] ដូចខាងលើ កថាខណ្ឌ ៦៣៩, ៦៤១, ៦៤៤ និង ៦៦៧។
[2122] សំណុំរឿង ០០១ សាលក្រម សម្គាល់ជើងទំព័រ ១១៤៤។
[2123] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤។ វិធានផ្ទៃក្នុង វិធាន ២៣*ស្ទួនបួន*(១)។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤០៧ និង ៤៤៦៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៧០ និង សម្គាល់ជើងទំព័រ ១១៤៤។

“សំណងផ្លូវចិត្ត” គឺជាការជួលជុលព្យសនកម្មផ្លូវចិត្ត មិនមែនជួសជុលព្យសនកម្មខាងសម្ភារៈនោះទេ[2124]។ វិធានការនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជានិមិត្តរូប ដែលផ្តល់ការទទួលស្គាល់ជាផ្លូវការដល់ជនរងគ្រោះ ជួយស្តារសេចក្តីថ្លៃថ្នូររបស់ពួកគេ និងថែរក្សាការចងចាំជាសមូហភាព[2125]។

លក្ខណៈ “សមូហភាព” នៃវិធានការនានាមានន័យថា ពុំមានការផ្តល់សំណងជាលក្ខណៈបុគ្គលនោះទេ[2126]។ ដរាបណាដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសំណងជាសមូហភាព សំណងផ្លូវចិត្តក៏អាច “ផ្តល់នូវផលប្រយោជន៍សម្រាប់សមាជិកនៃក្រុមសមូហភាពផងដែរ”[2127]។ បើទោះបីជាសំណងផ្លូវចិត្ត និងសមូហភាពមិនអាច “ផ្តល់សំណងពេញលេញដល់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សខាងរូបកាយ ឬខាងសេដ្ឋកិច្ចក្តី” ក៏គោលបំណងនៃសំណងផ្សេងទៀតត្រូវបានបំពេញ ក្នុងកម្រិតដែលវិធានការទាំងនោះឆ្លើយតបទៅនឹង “ការរំលោភបំពានខាងចិត្តសាស្ត្រ ផ្លូវចិត្ត និងនិមិត្តរូប”[2128]។

វិធានការការពារដែលទាមទារ តម្រូវឱ្យមានការទទួលស្គាល់ពីព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងគ្រោះ ដែលជាលទ្ធផលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស។ម្យ៉ាងវិញទៀត ការទាមទារសំណងត្រូវមានទំនាក់ទំនងទៅនឹងព្យសនកម្មដែលទទួលរងគ្រោះ និងត្រូវកម្រិតត្រឹមឧក្រិដ្ឋកម្មដែលបង្កើតបានជាមូលដ្ឋាននៃរឿងក្តី[2129]។

សំណងត្រូវផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលលើកឡើងពីព្យសនកម្ម[2130]។ ដោយមិនគិតពីលក្ខខណ្ឌតម្រូវផ្សេងទៀត ប្រភេទសំណងខាងក្រោមនេះត្រូវបានទទួលស្គាល់ថាបំពេញតាមលក្ខខណ្ឌជាក់លាក់នេះ៖

i. គម្រោងទាក់ទងនឹងការចងក្រងឯកសារ ការអប់រំជាសាធារណៈ ឬដែលផ្តោតលើការធានាមិនឱ្យមានការកើតឡើងសាជាថ្មី[2131]។
ii. គម្រោងទាក់ទងនឹងការរម្លឹក ការចងចាំ និងការរម្លឹកការចងចាំ[2132]។

---

[2124] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤០៩ និង ៤៤៦៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៥។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៨។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ៧០។

[2125] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៤៤។ សំណុំរឿង ០០១ សាលក្រម សម្គាល់ជើងទំព័រ ១១៤៤។

[2126] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ៦៥៨-៦៥៩។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤០៩។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៥។

[2127] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៨។

[2128] ដូចខាងលើ កថាខណ្ឌ ៦៦១។

[2129] វិធានផ្ទៃក្នុង វិធាន ២៣ *ស្ទួនបួន*(១)(ក)។

[2130] វិធានផ្ទៃក្នុង វិធាន ២៣ *ស្ទួនបួន*(១)(ខ)។

[2131] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៧០៨-៧០៩ (ការបង្កើត និងការចែកចាយសម្ភារៈសោតទស្សន៍ពីសំណុំរឿង ០០១)។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៥៤-៤៤៦០ (ការសិក្សាតាមកម្មវិធីទូរសព្ទ(App) អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាលគ្រូ និងគ្រូសាកលវិទ្យាល័យ និងសិក្ខាសាលា។ គម្រោងប្រព័ន្ធផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋក្នុងប្រទេសកម្ពុជា។ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍ ស្តីពីបទពិសោធន៍របស់ជនជាតិចាមក្នុងសម័យខ្មែរក្រហម។ ការសម្តែងរបាំ និងការតាំងពិព័រណ៍ បង្ហាញពីបទបញ្ហាស្តីពីការរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ការចងក្រងឯកសារ និងកិច្ចសន្ទនាអន្តរជំនាន់អំពីការប្រព្រឹត្តិលើជនជាតិចាម និងវៀតណាម ក្នុងពេលរបបខ្មែរក្រហម)។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៥៦-១១៦០ (ការតាំងពិព័រណ៍អចិន្ត្រៃយ៍ និងចលត និងគម្រោងអប់រំ។ ការដាក់បញ្ចូលជំពូកមួយស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់នៅទួលពោធិ៍ជ្រៃនៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនកម្ពុជា។ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព។ កូនសៀវភៅអំពីអង្គហេតុ ដែលត្រូវបានសម្រេចសេចក្តីក្នុង សំណុំរឿង ០០២/០១ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមសំណុំរឿង ០០២/០១ ជាពីរប្រភេទ។ ការដាក់បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីលើគេហទំព័រ អ.វ.ត.ក.)។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៧ និង ៦៦៩ (ការដាក់បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ពួកគេនៅក្នុងសាលក្រមស្ថាពរ។ ការបោះពុម្ពសាលក្រម និង ការផ្សព្វផ្សាយ)។

[2132] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៣ និង ៧១៣ (ការសាងសង់បូជនីយដ្ឋាន)។ ការប្រកាសថ្ងៃចងចាំថ្នាក់ជាតិ។ ការប្រារព្ធពិធីជាផ្លូវការនានា។ ការសាងសង់នូវផ្ទាំងសិលាជាព័ត៌មាន និងជាការរំលឹក)។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ

iii. គម្រោងដែលបម្រើជាការស្តារនីតិសម្បទា ការជួយតាមវិធីព្យាបាលតាមរយៈការចងក្រងនូវសក្ខីកម្ម និងការព្យាបាលជំងឺផ្លូវចិត្ត[2133]។
iv. គម្រោងដែលផ្តោតលើវិធានការបំពេញចិត្ត[2134]។

### ៧.៣.១.២. មធ្យោបាយសំណងតាមផ្លូវតុលាការ និងក្រៅប្រព័ន្ធតុលាការ

នៅក្នុងអត្ថបទដំបូងនៃវិធានផ្ទៃក្នុង ការផ្តល់សំណងត្រូវធ្វើឡើងប្រឆាំងទៅនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត[2135]។ ទោះជាយ៉ាងណា សំណុំរឿង ០០១ បានរៀបរាប់ថា នៅពេលដែលទំហំនៃការបាត់បង់ដែលរងគ្រោះនោះមានចំនួនច្រើន ហើយនៅពេលដែលទណ្ឌិតជាជនទីទ័លក្រគ្មានលទ្ធភាព ការផ្តល់សំណងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្រោមទម្រង់ចាស់កន្លងមក "មិនអាចផ្តល់សំណងជាក់ស្តែងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីបាននោះទេ"[2136]។ វិសោធកម្មឆ្នាំ២០១០ ទៅលើវិធានផ្ទៃក្នុង ដោះស្រាយការដាក់កម្រិតទាំងនេះដោយពង្រីកទំហំនៃសំណងនៅចំពោះមុខ អ.វ.ត.ក.[2137]។

ទីមួយ មធ្យោបាយសំណងបំពេញបន្ថែមតាមផ្លូវតុលាការត្រូវបានណែនាំ ដែលអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះឱ្យទទួលស្គាល់ថា វិធានការសំណងជាក់លាក់ណាមួយផ្អែកលើធនធានខាងក្រៅ ដែលត្រូវបានរៀបចំឡើង ឬក៏ណាត់អត្តសញ្ញាណក្នុងកិច្ចសហការជាមួយនឹងផ្នែកគាំពារជនរងគ្រោះនោះ មានលក្ខណៈសមស្រប និងអាចអនុវត្តបាន[2138]។ នៅពេលដាក់ការទាមទាររបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបញ្ជាក់ទម្រង់មួយក្នុងចំណោមទម្រង់ទាមទារអនុវត្តចំនួនពីរ[2139]។ មធ្យោបាយតាមផ្លូវតុលាការចំនួនពីរនៃសំណងមិនត្រឹមតែមានភាពដាច់ដោយឡែកពីគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានលក្ខណៈមិនអាស្រ័យគ្នាទៅវិញទៅមកទៀតផង[2140]។ ជាលទ្ធផល វា "មិនត្រូវបាន

---

១១៥២-១១៥៣ និង ១១៦១-១១៦៣ (ការបង្កើតថ្ងៃចងចាំថ្នាក់ជាតិ និងការសាងសង់បូជនីយដ្ឋានសាធារណៈស្ថិតក្នុងប្រភេទនេះ)។

[2133] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៧០១ និង ៧០៤ (ការផ្តល់នូវការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រដល់ដើមបណ្តឹងរដ្ឋប្បវេណី)។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦៣-៤៤៦៥ (កម្មវិធីព្យាបាលនិងផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមមានកិច្ចសន្ទនាសហគមន៍ដែលប្រាប់អំពីការពិត គំនិតផ្តួចផ្តើមការចងចាំ/វេទិកាមហោស្រព និងសកម្មភាពផ្សព្វផ្សាយដល់យុវជន។ ការផ្តល់ការថែទាំផ្លូវចិត្ត និង ផ្លូវកាយ)។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៥៤-១១៥៥ (កម្មវិធីសុខភាពផ្លូវចិត្ត ដូចជា ការបង្កើតក្រុមជួយខ្លួនឯង និងការរៀបចំការព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម)។

[2134] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៧៥។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៨ សម្គាល់ជើងទំព័រ ១១៥៣ (ការចងក្រង និងផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោសរបស់ ឌុច)។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦១-៤៤៦២ (ការផលិតសៀវភៅរៀបរាប់ដែលមានរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសរឿងរ៉ាវរបស់អ្នកដែលមានឱកាសផ្តល់សក្ខីកម្ម។ ការប្រកួតប្រជែងតាក់តែងបទចម្រៀង។ ការតាំងបង្ហាញផ្ទាំងគំនូរដើម្បីការចងចាំអំពីមន្ទីរសន្តិសុខ។ ការចូលរមើលកំណត់ត្រារបស់តុលាការស្តីពីការជំនុំជម្រះមេដឹកនាំខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី)។

[2135] វិធានផ្ទៃក្នុង (វិសោធនកម្មលើទី០) វិធាន ២៣(១១)។ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦១។

[2136] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤០៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១២។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារ E284 ជើងទំព័រ ២៦៤។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៦៨ កថាខណ្ឌ ៦៨៤ កថាខណ្ឌ ៦៩២ កថាខណ្ឌ ៧០៣ កថាខណ្ឌ ៧០៩ និង ៧១៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦២ កថាខណ្ឌ ៦៦៤ និង ៦៦៦។

[2137] វិធានផ្ទៃក្នុង វិធាន ១២ ស្ទួន (៣)-(៤) និង ២៣*ស្ទួនបួន*(៣)។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១០៩ និង ១១១២-១១១៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤០៥។

[2138] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួន* (៣), ២៣*ស្ទួនបួន* (៣)(ខ)។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៣។ សំណុំរឿង ០០២/០១ ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E125 ទំព័រ ២។

[2139] សូមមើល វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៦) វិធាន ១២ *ស្ទួន*(២), ២៣(៣) និង ២៣*ស្ទួនបួន*(១)-(៣)។

[2140] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៨ និង ១១២៣-១១២៤។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១៣។

អនុញ្ញាតតាមផ្លូវច្បាប់” សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីផ្អែកតាមការទាមទាររបស់ខ្លួនក្នុងពេលដំណាលគ្នាលើទម្រង់នៃការអនុវត្តទាំងពីរនោះទេ[2141]។

ទីពីរ វិសោធនកម្មបានពង្រីកអាណត្តិរបស់ផ្នែកគាំពារជនរងគ្រោះ។ វិធាន ១២*ស្ទួន*(៤) ផ្ដល់សិទ្ធិឱ្យផ្នែកគាំពារជនរងគ្រោះបង្កើត និងអនុវត្ត “កម្មវិធីនិងវិធានការនានាក្រៅកម្មវិធីនិងវិធានការដែលមានលក្ខណៈគតិយុត្តិ ដែលបង្ហាញពីផលប្រយោជន៍របស់ជនរងគ្រោះទូលំទូលាយជាង” រួមបញ្ចូលទាំង ក្នុងករណីសមស្រប នៅក្នុងកិច្ចសហការជាមួយអង្គភាពរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដែលនៅក្រៅ អ.វ.ត.ក.។ ចៅក្រម Catherine Marchi-Uhel បានផ្ដល់សំអាងហេតុថា ការណែនាំនេះផ្ដល់លទ្ធភាពឱ្យផលប្រយោជន៍របស់ជនរងគ្រោះត្រូវបានដោះស្រាយក្នុងពេលជាមួយគ្នានឹងដំណើរការតុលាការ រួមបញ្ចូលទាំងផលប្រយោជន៍របស់អ្នកដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបាន ដើម្បីមានគុណវុឌ្ឍិក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី[2142]។

អង្គជំនុំជម្រះមិនមានសិទ្ធិអំណាចបង្គាប់ឱ្យមានការបង្កកទ្រព្យសម្បត្តិមុនពេលជំនុំជម្រះ ដើម្បីគោលបំណងធានាការអនុវត្តការផ្ដល់សំណងនាពេលអនាគតនោះទេ[2143]។

## ៧.៣.១.៣. ការបង្កើត និងខ្លឹមសារនៃការទាមទារសំណង

យន្តការសំណងរបស់ អ.វ.ត.ក. គឺជា “យន្តការដែលចង់ឱ្យសំណងផុសចេញពីអ្នកទាមទារ” ដែលតម្រូវឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដាក់ការទាមទារសំណងដែលមានការរៀបចំ និងបញ្ជាក់គ្រប់គ្រាន់ ដើម្បីទទួលបានការអនុម័ត[2144]។ វិធានផ្ទៃក្នុងតម្រូវថា ដើមបណ្ដឹងរដ្ឋប្បវេណីដាក់ការទាមទារតែមួយ ដែលផ្ដល់ការរៀបរាប់អំពីសំណងដែលទាមទារ ”អំណះអំណាងមានសំអាងហេតុអំពីថាតើសំណងទាំងនេះដោះស្រាយព្យសនកម្មដែលទទួលរងគ្រោះដោយរបៀបណា បញ្ជាក់ពីក្រុមដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធក្នុងករណីសមស្រប និងទម្រង់ជាក់លាក់នៃការអនុវត្តសម្រាប់វិធានការនីមួយៗ[2145]។

ចាប់តាំងពីការណែនាំវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង ការទាមទារសំណងដែលផ្អែកលើថវិកា ឬវិភាគទានពីខាងក្រៅ អាចត្រូវបានអនុញ្ញាត ក្នុងករណីដែលមានការបញ្ជាក់ពីការព្រមព្រៀង និងកិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធ (ឬតតិយជនណាមួយ ដូចជា ម្ចាស់ជំនួយ ឬម្ចាស់ដឹងកជន) ត្រូវបានបង្ហាញ។ ម្យ៉ាងវិញទៀត គម្រោងសំណងផ្អែកតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង - ដែលការចំណាយមិនមែនជាបន្ទុករបស់ទណ្ឌិត - តម្រូវឱ្យមានការធានាការផ្គត់ផ្គង់ថវិកាគ្រប់គ្រាន់[2146]។

---

[2141] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១២៤។
[2142] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 យោបល់ដាច់ដោយឡែក និង ជំទាស់ដោយផ្នែករបស់ចៅក្រម Catherine Marchi-Uhel កថាខណ្ឌ៥។
[2143] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី៤ សីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ២៤-២៥។
[2144] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៥ និង ៦៨៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥។
[2145] វិធានផ្ទៃក្នុង វិធាន ២៣(៣) និង ២៣*ស្ទួនបួន*(២)។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១១។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៧។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥។
[2146] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦៣ និង ៤៤៦៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១២២, ១១២៦, ១១៥៣, ១១៥៥, ១១៦២ និង ១១៦៣។ សំណុំរឿង ០០២/០១ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីគម្រោង អាទិភាពសម្រាប់ការអនុវត្តសំណង អនុលោមតាមវិធាន៨០ ស្ទួន (៤) (E218/7/1) ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៣ ឯកសារ E218/7/2 កថាខណ្ឌ ៤។ សំណុំរឿង ០០២/០១ សេចក្ដីសម្រេចជាបន្តបន្ទាប់និងចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពជាក់លាក់ដែលបានធ្វើបច្ចុប្បន្នភាពនៃគម្រោងសំណងជាអាទិភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨១*ស្ទួន* (៤) (E218/7/3) ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ E218/7/4 កថាខណ្ឌ ៣។

ដើម្បណ្ដឹងរដ្ឋប្បវេណីមានបន្ទុកបង្ហាញភ័ស្ដុតាង ទាក់ទងនឹងភាពអាចទទួលយកបាននៃពាក្យសុំ និងខ្លឹមសារនៃការទាមទារសំណង[2147]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា តម្រូវការវិនិច្ឆ័យរឿងក្ដីព្រហ្មទណ្ឌក្នុងរយៈពេលមួយសមស្រប មិនបានផ្ដល់លទ្ធភាពឱ្យ អ.វ.ត.ក. អនុម័តវិធីសាស្ដ្ររបស់តុលាការអន្ដរអាមេរិកកាំងស្ដីពីសិទ្ធិមនុស្សទេ ដែលយោងតាមវិធីសាស្ដ្រនេះអង្គជំនុំជម្រះនឹងទទួលបន្ទុក "ភារកិច្ចចុងក្រោយក្នុងការកំណត់សំណងប្រកបដោយសមធម៌ និងត្រឹមត្រូវសម្រាប់ភាគីដែលទទួលរងព្យសនកម្ម" និងកំណត់ "សំណងដែលសមស្រប ហើយមិនចងកាតព្វកិច្ចខ្លួនឯង ទៅតាមសំណើសុំរបស់ជនរងគ្រោះឡើយ"[2148]។

ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងអនុវត្តអំណាចរបស់ខ្លួនអនុលោមតាមវិធាន ៨០*ស្ទួន*(៤) នៃវិធានផ្ទៃក្នុង ក្នុងការបង្គាប់ឱ្យសហមេធាវីនាំមុខផ្ដល់ការចង្អុលបង្ហាញអំពីការទាមទារដំបូង ផ្ដល់ព័ត៌មានអំពីបច្ចុប្បន្នភាពទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុសម្រាប់គម្រោងទាំងនេះក្នុងអំឡុងរយៈពេលនៃការជំនុំជម្រះ បញ្ជីគម្រោងអាទិភាព និងការទាមទារចុងក្រោយ[2149]។ វិធីសាស្ដ្រដ៏សកម្មនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ពិនិត្យមើលការគោរពតាមក្របខ័ណ្ឌច្បាប់នៅដំណាក់កាលដំបូង ហើយដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់ការចង្អុលបង្ហាញឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ខណៈដែលការផ្លាស់ប្ដូរនានាទៅលើការអភិវឌ្ឍគម្រោងនៅតែអាចធ្វើទៅបាន[2150]។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យក្រុមដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗដាក់សារណាជាលាយលក្ខណ៍អក្សរ ដែលគួសបញ្ជាក់ទម្រង់នៃសំណងផ្លូវចិត្ត និងសមូហភាពដែលទាមទារប្រឆាំងនឹងទណ្ឌិត[2151]។

ការទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាពអាចទាញចេញពីការចង្អុលបង្ហាញពីដំបូង[2152]។ តាមរយៈការទាមទារចុងក្រោយ "គម្រោងណាមួយអាចស្ថិតក្រោមការអភិវឌ្ឍ" ប្រសិនបើគម្រោងនោះរក្សានូវខ្លឹមសារសំខាន់ៗដដែលដូចបានរៀបរាប់នៅក្នុងបណ្ដឹងទាមទារ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការពង្រីកគម្រោង ឬការដាក់បញ្ចូលខ្លឹមសារថ្មីដែលមិនបានគ្រោងទុកជាមុនទៅក្នុងគម្រោងណាមួយគឺមានលក្ខណៈ "ហួសពីក្របខ័ណ្ឌដែលបានទទួលស្គាល់ដោយអង្គជំនុំជម្រះ"[2153]។

នៅដំណាក់កាលបណ្ដឹងសាទុក្ខ ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចលើកឡើងការទាមទារសំណងថ្មីដែលមិនបានដាក់ទៅកាន់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ[2154]។

### ៧.៣.១.៤. ការអនុវត្តគម្រោងសំណង

[2147] សំណុំរឿង ០០១ សេចក្ដីណែនាំស្ដីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E159 ទំព័រ ២។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥។

[2148] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៥។

[2149] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១៤-៤៤១៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១២០-១១២២។

[2150] សំណុំរឿង ០០២/០១ ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងទាមទារដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E125 ទំព័រ ២-៣។

[2151] សូមមើល សំណុំរឿង ០០១ សេចក្ដីណែនាំស្ដីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E159 កថាខណ្ឌ ១-២ និង ៥។

[2152] វិធានផ្ទៃក្នុង វិធាន ៨០ *ស្ទួន* (៥)។ សូមមើលផងដែរ សំណុំរឿង ០០២/០១ ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងទាមទារដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E125 ទំព័រ ២-៣។

[2153] សំណុំរឿង ០០២/០២ អនុស្សរណៈឆ្លើយតបទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំគោលការណ៍ណែនាំពាក់ព័ន្ធនឹងការផ្ដល់ហិរញ្ញប្បទានបន្ថែម និងសកម្មភាពសម្រាប់គម្រោងសំណងមួយចំនួន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ឯកសារ E457/6/2/5 កថាខណ្ឌ ៥។

[2154] វិធានផ្ទៃក្នុង វិធាន ១១០(៥)។

ក្របខ័ណ្ឌច្បាប់មិនផ្តល់យុត្តាធិការឱ្យស្ថាប័នណាមួយរបស់ អ.វ.ត.ក. អនុវត្តការផ្តល់សំណងនោះឡើយ[2155]។ វិធាន ១១៣(១) នៃវិធានផ្ទៃក្នុងចែងថា ការអនុវត្តសំណងប្រឆាំងនឹងទណ្ឌិត "ត្រូវធ្វើឡើងដោយអាជ្ញាធរជាតិដែលមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់កម្ពុជា តាមការផ្តួចផ្តើមគំនិតរបស់សមាជិកណាម្នាក់នៃក្រុមសមូហភាព លើកលែងតែសាលក្រមបញ្ជាក់ច្បាស់លាស់ថា សំណងនេះត្រូវផ្តល់ទៅឱ្យក្រុមមួយជាក់លាក់"។ សំណងផ្អែកតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) មិនទាំឱ្យមានការទាមទារដែលអាចអនុវត្តបាន ប្រឆាំងនឹងទណ្ឌិតនោះទេ ហើយការអនុវត្តសំណងទាំងនោះមិនស្ថិតក្នុងវិសាលភាពនៃវិធាន ១១៣(១) នៃវិធានផ្ទៃក្នុងនោះទេ[2156]។

### ៧.៣.២. គោលការណ៍

#### ៧.៣.២.១. វិសាលភាពនៃក្របខ័ណ្ឌសំណង

ដើមបណ្តឹងរដ្ឋប្បវេណីអាចទាមទារសំណង ប៉ុន្តែមិនមែនជាការធានាថាសំណងទាំងនោះនឹងត្រូវអនុវត្តនោះទេ[2157]។ ទោះបីជាសំណើជាច្រើនបង្កើតបានជាទម្រង់សំណងសមស្រប និង/ឬ ត្រូវបានបញ្ជាក់យ៉ាងគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏ឧបសគ្គដែលកើតចេញពីក្របខ័ណ្ឌសំណងរបស់ អ.វ.ត.ក. បានរារាំងការអនុម័តការផ្តល់សំណងមួយចំនួន[2158]។ ក្នុងករណីបែបទាំងនោះ អង្គជំនុំជម្រះបានលើកទឹកចិត្តឱ្យអាជ្ញាធរជាតិ សហគមន៍អន្តរជាតិ និងម្ចាស់ជំនួយសក្តានុពលផ្សេងទៀត បង្ហាញសាមគ្គីភាពជាមួយជនរងគ្រោះតាមរយៈការផ្តល់ហិរញ្ញវត្ថុ និងទម្រង់នៃការគាំទ្រផ្សេងទៀត ដើម្បីបង្កើត និងអនុវត្តទម្រង់នៃសំណងដែលសមស្រប ដែលមិនត្រូវបានអនុម័តយ៉ាងជាក់លាក់នៅក្នុងសាលក្រម ដែលអាចរួមចំណែកដល់ការស្តារនីតិសម្បទា ការបញ្ចូលក្នុងសង្គមឡើងវិញ និងការស្តារកិត្តិយសរបស់ពួកគេ[2159]។ វិសាលភាពដ៏មានកម្រិតនៃសំណងដែលអាចរកបាននៅ អ.វ.ត.ក. នេះ "មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ ដើម្បីស្វែងរក និងទទួលសំណងដែលអាចដោះស្រាយទាំងស្រុងនូវការខូចខាតរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី ដែលអាចមាន សម្រាប់គោលបំណងនេះនាពេលអនាគត"នោះទេ[2160]។

#### ៧.៣.២.២. សមត្ថភាពក្នុងការចងកាតព្វកិច្ច ឬបង្គាប់រដ្ឋ និងតតិយជនផ្សេងទៀត

អ.វ.ត.ក. ពុំមានយុត្តាធិការក្នុងការបង្គាប់ឱ្យមានការអនុវត្ត ឬការផ្តល់ថវិកាចំពោះវិធានការសំណងប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា ឬ បុគ្គល ឬស្ថាប័នណាផ្សេងទៀត ដែលមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីនោះទេ[2161]។ បន្ថែមលើនេះ អ.វ.ត.ក. មិនមានសិទ្ធិអំណាចក្នុងការវាយតម្លៃអំពីការ

---

2155 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី៤ សីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ២៥។ *សូមមើលផងដែរ* សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦១។

2156 សំណុំរឿង ០០២/០១ ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E125 ទំព័រ ២។ វិធានផ្ទៃក្នុង វិធាន ១១៣(១)។

2157 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី៤ សីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ២១។

2158 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៧១៧។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរសម្រេចរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ២៥។

2159 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៩២ និង ៧១៧។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៦៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៣។

2160 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៦៨។

2161 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៦ និង ៦៦៣។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១០។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១១៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៣។

គោរពពីសំណាក់រដ្ឋចំពោះកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនលើវិធានការសំណងនោះទេ ដោយបែងចែកវាដាច់ដោយឡែកពីតុលាការសិទ្ធិមនុស្សក្នុងតំបន់ជាក់លាក់មួយចំនួន[2162]។

បើគ្មានការប្ដេជ្ញាចិត្តផ្ដល់ថវិកាគាំទ្រគម្រោងណាមួយយោងតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុងទេនោះ ការទាមទារសំណងណាមួយដែលតម្រូវឱ្យមានការចូលរួមដ៏សកម្មពីសំណាក់អាជ្ញាធរកម្ពុជា ឬតតិយជននោះ គឺត្រូវបានបដិសេធចោល[2163]។ ជាពិសេស នេះគឺជាករណីសម្រាប់សំណើទាមទារវិធានការដែលស្ថិតក្នុងបុព្វសិទ្ធិរដ្ឋាភិបាល ដូចជា ការបង្កើតថ្ងៃរំឭកបុណ្យជាតិ ការយកឈ្មោះជនរងគ្រោះដាក់ជាឈ្មោះអគារសាធារណៈ ការផ្ដល់សញ្ជាតិដល់ជនរងគ្រោះ ការចេញការសុំទោសជាផ្លូវការ ឬការរៀបចំសេវាថែរក្សាសុខភាព[2164]។

## ៧.៣.២.៣. ការទាមទារសំណង

### ៧.៣.២.៣.១. *លទ្ធភាពនៃវិធានការសំណង*

អង្គជំនុំជម្រះបានអនុម័តទស្សនៈដែលថា សំណងគប្បីត្រូវកំណត់ត្រឹមសកម្មភាពនានា ដែលជាក់ស្ដែងអាចអនុវត្តបាន[2165]។ ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "តាមគ្រប់លទ្ធភាពសំណងដែលមិនអាចអនុវត្តបាន ពោលគឺ សំណងដែលមានលក្ខណៈ*ប្រឌិតតាមព្រឹត្តិន័យ* មិនបានបង្ហាញពីគោលបំណងនៃសំណងប្រកបដោយ*ប្រសិទ្ធភាព* និងធ្វើឱ្យភ័ន្តច្រឡំ និងធ្វើឱ្យសោកស្ដាយចំពោះជនរងគ្រោះ"[2166]។ ហេតុដូច្នេះ វិធានការសំណងសមស្របគឺជាវិធានការមួយដែល "មានលក្ខណៈសាមញ្ញ តែអាចអនុវត្តបាន"[2167]។

វិធានការសំណងដែលបានទាមទារ តម្រូវឱ្យមានការពិចារណាពីលទ្ធភាពអាចរកថវិកាបាន[2168]។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធការអនុម័តយល់ព្រមលើគម្រោងសំណងនានា ដែលការផ្ដល់ថវិកាត្រូវបានផ្អែកលើលទ្ធភាពទណ្ឌិតក្រីក្រ អាចទទួលបានចំណូលនាពេលអនាគត ឬថាតតិយជននឹងផ្ដល់សំណងជំនួស ដោយជ្រើសរើសធ្វើដូច្នោះតំណាងឱ្យទណ្ឌិត ជាជាងក្នុងនាមខ្លួនឯងផ្ទាល់[2169]។ គម្រោងដែលទទួលការគាំទ្រថវិកាដោយផ្អែក មិនត្រូវបានអនុម័តយល់ព្រមទេ[2170]។ ស្រដៀងគ្នានេះដែរ ការប្ដេជ្ញាចិត្តបន្តកៀងគរថវិកាមិនមែនជាការធានាមួយ ដែលថានឹងទទួលបានការផ្ដល់ថវិកានោះទេ[2171]។ ដោយពិចារណាអំពី "មូលនិធិរបស់ម្ចាស់ជំនួយនិងធនធានមនុស្សមានកំណត់ ទាំងនៅផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងនៅអង្គភាពគាំពារជនរងគ្រោះ" អង្គជំនុំជម្រះសាលាដំបូងជំរុញឱ្យសហមេធាវីនាំមុខ "កំណត់អាទិភាពគម្រោងសំណងដែលទំនងជាអាចសម្រេចបាន"[2172]។

---

2162 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៣។

2163 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៦២-៦៦៤។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៧១ និង ៦៧៤។

2164 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៦៤។ សំណុំរឿង ០០២/០១ ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងទាមទារដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E125 ទំព័រ ៣។

2165 សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៦៨។

2166 ដូចខាងលើ កថាខណ្ឌ ៦៦៧ (គូសបញ្ជាក់ក្នុងច្បាប់ដើម)។

2167 ដូចខាងលើ កថាខណ្ឌ ៦៦៨។

2168 ដូចខាងលើ កថាខណ្ឌ ៦៦៨ ជើងទំព័រ ១៣៤៣។

2169 ដូចខាងលើ កថាខណ្ឌ ៦៤៣ កថាខណ្ឌ ៦៦៦ និង ៦៦៨។

2170 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១២២ និង ១១៦២-១១៦៣។ សំណុំរឿង ០០២/០១ សេចក្ដីសម្រេចជាបន្តបន្ទាប់និងចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពជាក់លាក់ដែលបានធ្វើបច្ចុប្បន្នភាពនៃគម្រោងសំណងជាអាទិភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨១*ស្ទួន*(៤) (E218/7/3) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ E218/7/4 កថាខណ្ឌ ៣។

2171 សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៦៣។

2172 សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១៥។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១២១។ សូមមើលផងដែរ សំណុំរឿង ០០២/០១ ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ឯកសារ E218 កថាខណ្ឌ ១៩។

### ៧.៣.២.៣.២. *កម្រិតនៃភាពលម្អិត និងភាពជាក់លាក់*

ការទាមទារសំណងតម្រូវឱ្យមានភាពជាក់លាក់ និងលម្អិតគ្រប់គ្រាន់ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងអាចផ្តល់ការអនុញ្ញាតលើសំណើនោះ តាមរយៈសេចក្តីសម្រេចមួយដែលអាចអនុវត្តបាន[2173]។ ដីកាមិនអាចចេញបានឡើយ នៅពេលដែលកម្មវត្ថុនៃការផ្តល់សំណង និងថ្លៃចំណាយរបស់វាមិនមានភាពច្បាស់លាស់ ឬមិនអាចកំណត់បាន[2174]។ ចាំបាច់ត្រូវសង្កត់ធ្ងន់លើលទ្ធភាពនៃការផ្តល់សំណងដែលមានអានុភាពអនុវត្តដោយខ្លួនឯង[2175]។

កង្វះភាពជាក់លាក់មិនមែនជាវិការៈធ្ងន់ធ្ងរនោះទេ "ប្រសិនបើ សំណើបង្ហាញថា ការផ្តល់សំណងដែលបានទាមទារនោះមានលក្ខណៈសមស្រប និងអាចអនុវត្តបាន"[2176]។ លក្ខខណ្ឌតម្រូវឱ្យមានកម្រិតនៃភាពលម្អិតអាស្រ័យលើលក្ខណៈនៃការទាមទារសំណង។ ប៉ុន្តែលក្ខខណ្ឌទៅនឹងការផ្តល់សំណង គឺការចង្អុលបង្ហាញច្បាស់លាស់អំពីលក្ខណៈនៃដំណោះស្រាយដែលស្នើសុំ ទំនាក់ទំនងរបស់វាទៅនឹងព្យសនកម្មដែលបង្កឡើងដោយជនជាប់ចោទ និងចំនួននៃសំណងដែលជនជាប់ចោទត្រូវសង ដើម្បីធ្វើឱ្យការទាមទារសំណងនោះមានប្រសិទ្ធភាព[2177]។

### ៧.៣.២.៣.៣. *ទំនាក់ទំនងរវាងព្យសនកម្មដែលបណ្តាលមកពីឧក្រិដ្ឋកម្ម និងសំណងដែលស្នើសុំ*

វិធាន ២៣*ស្ទួនបួន*(១)(ក) នៃវិធានផ្ទៃក្នុងតម្រូវថា វិធានការសំណងត្រូវបញ្ជាក់អំពីព្យសនកម្មដែលទទួលរងគ្រោះដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលជាលទ្ធផលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស[2178]។

ការណ៍នេះបង្កប់ន័យទំនាក់ទំនងរវាងទម្រង់នៃសំណងដែលទាមទារ និងព្យសនកម្មដែលបណ្តាលមកពីឧក្រិដ្ឋកម្ម[2179]។ "ពាក់ព័ន្ធនឹងព្យសនកម្មដែលមាននៅក្នុងទម្រង់នៃសំណងដែលចង់បាន និងសមស្របបានលុបបំបាត់ចោលនូវផលវិបាកនៃអំពើល្មើស ព្រមទាំងស្តារឡើងវិញតាមដែលអាចធ្វើបាននូវឋានៈស្របច្បាប់ពីមុន"។ ឧទាហរណ៍ ក្នុងករណីដែលព្យសនកម្មបង្ហាញឡើងដោយជនរងគ្រោះបណ្តាលមកពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនោះ គឺជាព្យសនកម្មចំពោះសុខភាពរូបរាងកាយ និងចិត្តសាស្ត្រ ដូច្នេះការផ្តល់នូវការព្យាបាលលើរូបរាងកាយ និងចិត្តសាស្ត្រនៃព្យសនកម្មនេះ គឺជាទម្រង់សមស្របនៃសំណង[2180]។

ជាងនេះទៀត វិធានការសំណងដែលបានស្នើឡើងត្រូវបានកម្រិតត្រឹមតែឧក្រិដ្ឋកម្មដែលបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់ក្នុងរឿងក្តីនេះ[2181]។ ឧទាហរណ៍ ការទាមទារណាមួយដែលស្វែងរកឱ្យមានការទទួលស្គាល់ការឈឺចាប់ដែលបានជួបប្រទះដោយជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងមណ្ឌលគិរីដោយសារសេចក្តីទុក្ខសោក ការរើសអើង និងការធ្វើទុក្ខបុកម្នេញ មិនអាចត្រូវបានអនុញ្ញាតទេ ប្រសិនបើរឿងក្តីនេះមិនបានបញ្ចូលការចោទប្រកាន់ទាំងនេះក្នុងតំបន់ទាំងអស់នេះ[2182]។

---

[2173] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៧-៦៨៨។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៥១ និង ៦៦៥។
[2174] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥ កថាខណ្ឌ ៦៦៩ និង ៦៧២-៦៧៤។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៩៤ និង ៧០៤។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៦២។
[2175] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៨។
[2176] ដូចខាងលើ កថាខណ្ឌ ៦៨៥។
[2177] សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៩៤។
[2178] សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៩៩។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៣៦។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៤១។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥។
[2179] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ 699។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៦៥ និង ៦៧៤។
[2180] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៩៩។
[2181] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១៤ និង ៤៤៦៦។ សំណុំរឿង ០០១ សាលក្រម កថាខណ្ឌ ៦៧៤។
[2182] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦៦។

ផលវិបាកមួយនៃការបំបែកសំណុំរឿង ០០២ គឺថា ជនរងគ្រោះជាច្រើនត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើមូលដ្ឋាននៃព្យសនកម្មបណ្តាលមកពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែមិនស្ថិតក្នុងសំណុំរឿង ០០២/០២ ឬផ្ទុយមកវិញ។ នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា "ការកម្រិតវិសាលភាពនៃអង្គហេតុដែលគ្រោងនឹងយកមកជំនុំជម្រះ" ពុំមានផលប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលជំនុំជម្រះនោះឡើយ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីលែងចូលរួមការជំនុំជម្រះជាលក្ខណៈបុគ្គលទៀតហើយ ផ្អែកលើមូលដ្ឋាននៃព្យសនកម្មជាក់លាក់របស់ពួកគេដែលទទួលរង ប៉ុន្តែផ្ទុយទៅវិញដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះរួមបញ្ចូលជាបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមបញ្ចូលជាក្រុមតែមួយដែលផលប្រយោជន៍សមូហភាពរបស់ពួកគេ នឹងត្រូវតំណាងជាសមូហភាព។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ការទាមទារសំណងដែលធ្វើឡើងតំណាងឱ្យបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ ត្រូវតែគិតពិចារណាលើវិធាន ២៣*ស្ទួនបួន*(១)(ក) នៃវិធានផ្ទៃក្នុង[2183]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា អង្គជំនុំជម្រះគប្បីពិចារណាតែព្យសនកម្មដែលទទួលរង ដែលបណ្តាលមកពីការចោទប្រកាន់ដែលបង្កើតបានជាមូលដ្ឋាននៃសំណុំរឿង ០០២/០១ ទាក់ទងទៅនឹងសំណងដែលទាមទារអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ក) នៃវិធានផ្ទៃក្នុង ដែលការចំណាយមិនជាបន្ទុករបស់ទណ្ឌិត។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចផ្តល់សក្ខីកម្មអំពីអង្គហេតុដែលជាបញ្ហាចោទក្នុងសំណុំរឿង ០០២/០១ បាន ប៉ុន្តែមានបទពិសោធន៍របស់ខ្លួនពាក់ព័ន្ធនឹងកម្មវត្ថុនៃការជំនុំជម្រះនាពេលខាងមុខ អាច "នឹងត្រូវ [...] ស្តាប់សក្ខីកម្មអំឡុងសវនាការទាំងនេះ"[2184]។

### ៧.៣.២.៣.៤. *វិសាលភាពនៃអត្ថប្រយោជន៍*

លក្ខខណ្ឌតម្រូវក្នុងវិធាន ២៣*ស្ទួនបួន*(១)(ខ) នៃវិធានផ្ទៃក្នុងដែលថា ការផ្តល់សំណងត្រូវតែផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវលើកឡើងអំពីព្យសនកម្មនោះ តំណាងបទដ្ឋានជាអប្បបរមា។ ដោយសារតែពួកគេបង្កើតជាក្រុមរួមបញ្ចូលគ្នានៅដំណាក់កាលជំនុំជម្រះ សំណងផ្លូវចិត្ត និងសមូហភាពដែលទាមទារតំណាងឱ្យពួកគេនោះ អាចលើកឡើងពីព្យសនកម្មដែលបានទទួលរងគ្រោះដោយក្រុមដ៏មានកម្រិតនេះ *ហើយ*ក៏អាចផ្តល់អត្ថប្រយោជន៍ពាក់ព័ន្ធដល់ក្រុមជនរងគ្រោះមួយចំនួនធំដែលមិនមានតំណាង ដែលបានទទួលរងព្យសនកម្មដែលបណ្តាលមកពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសផងដែរ[2185]។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា លក្ខណៈសមូហភាពនៃគម្រោងសំណងគាំទ្រ "វិធានការទាំងឡាយដែលផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះជាច្រើនតាមតែអាចធ្វើបាន"។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា "គួរផ្តល់អាទិភាពដល់វិធានការនៃសំណងទាំងឡាយដែលមានលក្ខណៈពេញលេញ" ដោយពិចារណាថាជនរងគ្រោះមួយចំនួន (១) មិនបានដឹងពីកិច្ចដំណើរការនីតិវិធី ឬឱកាសក្នុងការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី(២) មិនស្ថិតក្នុងស្ថានភាពជាបុគ្គលដែលមានលទ្ធភាពខាងហិរញ្ញវត្ថុ មិនមានកាយសម្បទារឹងមាំ មិនមានសម្បទាផ្លូវចិត្ត ឬមិនមានលទ្ធភាពខាងភ័ស្តុភារដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី (៣) មិនមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបំពេញបាននូវលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបានសម្រាប់ពាក្យសុំរបស់ពួកគេ ឬ (៤) មិនចង់ចូលរួមដោយមូលហេតុផ្សេងៗទៀត[2186]។

---

[2183] សំណុំរឿង ០០២ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E124 កថាខណ្ឌ ៨។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារ E284 កថាខណ្ឌ ១០ និង ១៥៧-១៥៨។

[2184] សំណុំរឿង ០០២/០១ សេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើដែលនៅសេសសល់មុនសវនាការ និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E145 ទំព័រ ២។

[2185] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ជើងទំព័រ ៣២១០។

[2186] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៥៩។

ការបកស្រាយបែបបរិយាបន្ននៃវិធាន ២៣*ស្ទួនបួន*(១)(ខ) នៃវិធានផ្ទៃក្នុងនេះ ជាឧទាហរណ៍ ត្រូវបានឆ្លុះបញ្ចាំង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុម័តគម្រោងនានា ដែលផ្ដោតគោលបំណងលើការបង្កើតទិវាជាតិនៃការចងចាំ និងការសាងសង់បូជនីយស្ថានដើម្បីផ្ដល់ "ការទទួលស្គាល់ជាសាធារណៈចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងព្យសនកម្មដែលបានទទួលរង" និង "ជួយដល់ការព្យាបាលរបួសស្នាមរបស់ជនរងគ្រោះទាំងអស់ ដោយវាបានពង្រីកឥទ្ធិពលនៃសំណង មិនត្រឹមតែចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថាជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ"[2187]។ ការសង្កត់ធ្ងន់ជាពិសេសត្រូវបានធ្វើឡើងទៅលើលទ្ធភាពនៃវិធានការសំណងមួយចំនួន ក្នុងការចូលរួមចំណែកដល់គោលបំណងនៃ "ការយល់ដឹងរបស់សាធារណជន" "ការផ្សះផ្សាជាតិ" និងការលើកកម្ពស់ "វប្បធម៌សន្តិភាព"[2188]។

### ៧.៣.២.៤. ការអនុវត្តវិធានការសំណង

ដោយពិចារណាលើបញ្ហាលំបាកជាក់ស្ដែង ក្នុងការធានាបាននូវការគាំទ្រផ្នែកថវិកាពីខាងក្រៅសម្រាប់ការសម្រេចបាននូវវិធានការសំណង ផ្អែកលើវិធាន ២៣*ស្ទួនបួន*(៣)(ខ) ការអនុវត្តគម្រោងសំណងអាចចាប់ផ្ដើមមុនពេលចេញសាលក្រម[2189]។ ការទទួលស្គាល់ជាបន្តបន្ទាប់នៃគម្រោងដែលបានចាប់ផ្ដើមអនុវត្តរួចហើយនោះ ឬថែមទាំងបានបញ្ចប់មុនពេលសាលក្រមនោះ គឺស្របគ្នា "ទៅនឹងការអនុម័តវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលនឹងជម្រុញដល់ការអនុវត្តសំណងប្រកបដោយអត្ថន័យក្នុងពេលវេលាដ៏សមស្របដោយមានជំនួយពីម្ចាស់ជំនួយ និងកិច្ចសហការពីខាងក្រៅ"[2190]។

---

[2187] សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៥២។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៦៨៣។

[2188] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ៦៨៣ និង ៧០៨។ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤៦៧។ សំណុំរឿង ០០២/០១ សាលក្រម កថាខណ្ឌ ១១៥២, ១១៥៤, ១១៥៦ និង ១១៥៨។

[2189] សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១៨ និង ៤៤២០-៤៤៣៣។ សំណុំរឿង ០០២/០១ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី៖ ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន៨០ *ស្ទួន*(៤)) ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E218/7 ទំព័រ ១។

[2190] សំណុំរឿង ០០២/០១ ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន៨០*ស្ទួន*(៤)) ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E218/7 ទំព័រ ១។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៤៤១៨។

## ៨. កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់ អ.វ.ត.ក. ត្រូវបានចែងនៅក្នុងឯកសារបង្កើតរបស់ខ្លួន ដូចដែលត្រូវបានបំពេញបន្ថែមតាមរយៈក្រមសីលធម៌ និងត្រូវបានបង្កើតឡើងតាមរយៈករណីយុត្តិសាស្ត្រ។ បទដ្ឋានជាក់លាក់គ្របដណ្ដប់លើគោលការណ៍ស្ដីពីក្រមសីលធម៌ និងវិជ្ជាជីវៈចៅក្រម ការដកខ្លួន និងបណ្ដឹងជំទាស់ចំពោះចៅក្រម ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និងកំហុសវិជ្ជាជីវៈរបស់មេធាវី។ គោលការណ៍នីមួយៗត្រូវបានពិភាក្សាដាច់ដោយឡែកពីគ្នាខាងក្រោម។

### ៨.១. គោលការណ៍ស្ដីពីក្រមសីលធម៌ និងការទទួលខុសត្រូវផ្នែកតុលាការ

ក្របខ័ណ្ឌច្បាប់ និងគោលការណ៍ស្ដីពីក្រមសីលធម៌ និងការទទួលខុសត្រូវសម្រាប់ចៅក្រម ត្រូវបានចែងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ អ.វ.ត.ក. ហើយត្រូវបានបង្កើតឡើងបន្ថែមទៀតនៅក្នុងក្រមសីលធម៌ចៅក្រមនៃ អ.វ.ត.ក.[2191]។ ចៅក្រមមានកាតព្វកិច្ចស្ម័គ្រប្រកបដោយឯករាជ្យភាព[2192] អព្យាក្រឹតភាព[2193] សេចក្ដីសង្វាតព្យាយាម[2194] សុចរិតភាព[2195] និងការរក្សាភាពសម្ងាត់[2196] ដែលឆ្លុះបញ្ចាំងពីនិយាមជាតិ និងអន្តរជាតិ[2197]។ សហព្រះរាជអាជ្ញាមានកាតព្វកិច្ចស្រដៀងគ្នានេះដែរអំពីសុចរិតភាព សមត្ថភាព និងសេចក្ដីសង្វាតព្យាយាម[2198]។

ឯករាជ្យភាពតុលាការគឺ "ពិតជាមានសារៈសំខាន់ខ្លាំង និងជាមូលដ្ឋានស្នូលដើម្បីលើកកម្ពស់ និងរក្សាបាននូវជំនឿទុកចិត្តពីសាធារណៈជនលើប្រព័ន្ធតុលាការ"[2199]។ សិទ្ធិទទួលបាននូវតុលាការមួយឯករាជ្យ និងឥតលម្អៀង "[ក៏ជា]ធាតុសំខាន់នៃសិទ្ធិជាសារវន្ត ដើម្បីទទួលការជំនុំជម្រះក្ដីដោយយុត្តិធម៌"[2200]។ ចៅក្រមមិនត្រូវទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ[2201] ឬកាន់តួនាទីនយោបាយណាមួយឡើយ[2202]។ ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និងចៀសវាងការបង្ហាញពីភាព

[2191] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. ដែលបានអនុម័តនៅកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានវិសោធនកម្មនៅកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០០៨ ("ក្រមសីលធម៌ចៅក្រម អ.វ.ត.ក.")។
[2192] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(៣) និង ៥(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី) និង ២៥។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ១។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១៤(១) និង ១៧(១)។
[2193] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(៣) និង ៥(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី) និង ២៥។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ២។
[2194] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៥។
[2195] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(៣) និង ៥(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី)។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៣។
[2196] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៤។
[2197] ដូចខាងលើ បុព្វកថា។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៣០។
[2198] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៦(២)។ ច្បាប់ អ.វ.ត.ក. មាត្រា ១៩។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១៣(១)។
[2199] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងរបស់លោក អៀង សារី ដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឯកសារ E5/3 កថាខណ្ឌ ១១។
[2200] ដូចខាងលើ កថាខណ្ឌ ៥។
[2201] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(៣) និង ៥(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី)។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ២។ សូមមើលផងដែរ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៨។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. ក៏បញ្ជាក់ផងដែរថា ក្រមនេះផ្ដាល់មិន "សំដៅកំណត់ ឬដាក់កំហិតតាមមធ្យោបាយណាមួយទៅលើឯករាជ្យភាពរបស់ចៅក្រមឡើយ"។ សូមមើល ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៩(២)។
[2202] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៨(២)។

លម្អៀង[2203] និងត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសេចក្តីសុចរិតទៀងត្រង់ និងដោយសីលធម៌ ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ[2204]។

ចៅក្រមដែលត្រូវជ្រើសតាំងត្រូវមានបទពិសោធន៍ច្បាប់ពាក់ព័ន្ធ[2205]។ ពួកគេត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម ក្នុងការបំពេញភារកិច្ចរបស់ខ្លួន[2206] ត្រូវចាត់វិធានការសមស្របដើម្បីរក្សាចំណេះដឹង និងជំនាញរបស់ខ្លួន ហើយត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យបានឆាប់រហ័ស[2207]។ ចៅក្រមក៏ត្រូវគោរពនូវសារៈសំខាន់នៃការរក្សាការសម្ងាត់ ចំពោះព័ត៌មានដែលទទួលបានក្នុងការបំពេញមុខនាទីរបស់ខ្លួន និងរក្សាភាពសម្ងាត់នៃការពិភាក្សាសម្រេច[2208] ហើយត្រូវមានសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈដែលសមស្របជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពលលើ ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ[2209]។

ដូចគ្នានឹងចៅក្រមដែរ សហព្រះរាជអាជ្ញាត្រូវមានចរិតលក្ខណៈស្មារតីខ្ពស់ និងសុចរិត[2210] និងមានសមត្ថភាពវិជ្ជាជីវៈកម្រិតខ្ពស់ រួមមានបទពិសោធន៍ទូលំទូលាយនៅក្នុងការធ្វើការស៊ើបអង្កេត និងការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌ[2211]។ សហព្រះរាជអាជ្ញាក៏ត្រូវតែឯករាជ្យផងដែរ ក្នុងការបំពេញមុខនាទីរបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតនោះឡើយ[2212]។

### ៨.២. ការដកខ្លួន និង បណ្តឹងជំទាស់

ក្នុងការឆ្លើយតបទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង[2213] ចៅក្រមអាចត្រូវបានដកខ្លួន ឬប្តឹងជំទាស់ ដោយសារភាពលម្អៀងជាក់ស្តែង ឬ ភាពលម្អៀងដែលស្តែងឱ្យឃើញ[2214]។ យន្តការសម្រាប់ការដកខ្លួន និងការប្តឹងជំទាស់ចៅក្រម ត្រូវបានចែងនៅក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង និងត្រូវបានបង្កើតឡើងតាមរយៈករណីយុត្តិសាស្ត្រ ដែលបានផ្អែកយ៉ាងខ្លាំងលើយុត្តិសាស្ត្រមកពីតុលាការមិនអចិន្ត្រៃយ៍ ហើយក្នុងករណីខ្លះតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (“ECtHR”)[2215]។

#### ៨.២.១. នីតិវិធីសម្រាប់ការដកខ្លួន ឬការប្តឹងជំទាស់ចៅក្រម

---

2203 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី)។ ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា២។

2204 ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា៣។

2205 ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី)។

2206 ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មាត្រា ៥។

2207 ដូចខាងលើ។

2208 ដូចខាងលើ មាត្រា ៤។

2209 ដូចខាងលើ មាត្រា ៧.១។

2210 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៦(២)។ ច្បាប់ អ.វ.ត.ក. មាត្រា ១៩។

2211 ដូចខាងលើ។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១៣(១)។

2212 ច្បាប់ អ.វ.ត.ក. មាត្រា១៩។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១៣(១)។

2213 សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 កថាខណ្ឌ ៣៣។

2214 វិធានផ្ទៃក្នុង វិធាន 34. សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ១១។ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ អៀង ធិរិទ្ធ សុំជំទាស់ចៅក្រម សោម សិរីវឌ្ឍ ដោយសារកង្វះឯករាជ្យភាព ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារ 1/4 កថាខណ្ឌ ១០។

2215 វិធានផ្ទៃក្នុង វិធាន ៣៤។ ចំពោះបញ្ជីសេចក្តីសម្រេចលើពាក្យប្តឹងជំទាស់នៅ អ.វ.ត.ក. សៀវភៅណែនាំអំពី អ.វ.ត.ក. (ភាគ ១) ឧបសម្ព័ន្ធ ៥(ក)។

ចៅក្រមអាចដកខ្លួនដោយខ្លួនឯង ឬភាគីណាមួយអាចដាក់បណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រម[2216]។ បណ្តឹងជំទាស់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុដែលបានចោទប្រកាន់ ដោយផ្តល់ភស្តុតាងគាំទ្រ និងត្រូវដាក់ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលដែលភាគីបានដឹងអំពីមូលហេតុនោះ[2217]។

ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពច្បាស់លាស់ សម្រាប់គោលបំណងនៃការទទួលយកពាក្យបណ្តឹង "ម្ចាស់បណ្តឹងត្រូវតែបង្ហាញមូលហេតុនៃបណ្តឹងជំទាស់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឱ្យអង្គបុរេជំនុំជម្រះ អាចធ្វើការត្រួតពិនិត្យលើអង្គសេចក្តីបានត្រឹមត្រូវ"[2218]។ រាល់ភស្តុតាងគាំទ្រទាំងអស់ដែលម្ចាស់បណ្តឹងផ្អែកលើ ត្រូវដាក់ជាមួយនឹងពាក្យបណ្តឹងជំទាស់[2219]។ វិធាន ៣៥ នៃវិធានផ្ទៃក្នុង "មិនមែនជាយន្តការសុក្រិត្យដើម្បីបង្ហាញនូវភស្តុតាងក្នុងការគាំទ្រលើបណ្តឹងជំទាស់នេះឡើយ"[2220]។ ចៅក្រមដែលត្រូវបានគេប្តឹងជំទាស់ប្រឆាំងនឹងខ្លួន មានសិទ្ធិដាក់សារណាទៅអង្គជំនុំជម្រះ ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃដែលគាត់បានទទួលពាក្យបណ្តឹង[2221]។

ពាក្យបណ្តឹងត្រូវដាក់ក្នុងក្របខ័ណ្ឌពេលវេលាដែលបានចែងក្នុងវិធាន ៣៤(៤) នៃវិធានផ្ទៃក្នុង៖

- ប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេត មុនពេលមានដីកាដំណោះស្រាយ
- ប្រឆាំងនឹងចៅក្រមនៃអង្គបុរេជំនុំជម្រះ មុនពេលធ្វើសេចក្តីសម្រេចទៅលើរឿងក្តីណាមួយ
- ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ យ៉ាងយូរបំផុតត្រឹមពេលសវនាការបឋម ឬ ពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលជំនុំជម្រះ ឬកាលណាភាគីមិនបានដឹង នៅមុនពេលជំនុំជម្រះ នៅមុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើសំណុំរឿងនោះ ឬ
- ប្រឆាំងនឹងចៅក្រមរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងមុនពេលធ្វើបណ្តឹងសាទុក្ខ នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ ឬ ពាក់ព័ន្ធទៅនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលនីតិវិធីបណ្តឹងសាទុក្ខ ឬ បញ្ហាដែលភាគីមិនបានដឹងនៅមុនពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ មុនពេលធ្វើសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខនោះ។

ពាក្យបណ្តឹងក៏ត្រូវដាក់ទៅកាន់អង្គជំនុំជម្រះពាក់ព័ន្ធ ដែលចៅក្រមរូបនោះស្ថិតនៅ ឬទៅកាន់អង្គបុរេជំនុំជម្រះ ប្រសិនធ្វើឡើងប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេត[2222]។ ចៅក្រមពេញសិទ្ធិអាចត្រូវជំនួសដោយចៅក្រមបម្រុង ដើម្បីបើកសវនាការជំនុំជម្រះពាក្យបណ្តឹងនោះ[2223]។ ចៅក្រមត្រូវបានអនុញ្ញាតបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដោយរង់ចាំសេចក្តីសម្រេចពីបណ្តឹងជំទាស់ ប៉ុន្តែចៅក្រមនោះអាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន[2224]។

---

[2216] វិធានផ្ទៃក្នុង វិធាន ៣៤(១)-(២)។
[2217] វិធានផ្ទៃក្នុង វិធាន ៣៤(៣)។
[2218] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ 8 កថាខណ្ឌ ២៦។
[2219] វិធានផ្ទៃក្នុង វិធាន ៣៤(៣)។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ១៤។ ភាគីអាចដឹងពី (អ្វីដែលអាចជា) "ភស្តុតាងដែលគាំទ្រ" មុនពេលពួកគេដឹងពីមូលដ្ឋានសម្រាប់ការប្តឹងជំទាស់៖ ក្នុងកាលៈទេសៈបែបនេះ ភាគីត្រូវបង្ហាញភស្តុតាងថ្មីៗនៅពេលដែលដឹងអំពីភាពពាក់ព័ន្ធនោះ។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងរបស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១០ ឯកសារលេខ 4 កថាខណ្ឌ ១៣។
[2220] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១១ ឯកសារ E137/5 កថាខណ្ឌ ១៤។
[2221] វិធានផ្ទៃក្នុង វិធាន ៣៤(៧)។
[2222] វិធានផ្ទៃក្នុង វិធាន ៣៤(៥)។
[2223] វិធានផ្ទៃក្នុង វិធាន ៣៤(៦)។
[2224] វិធានផ្ទៃក្នុង វិធាន ៣៤(៥)។

ទម្រង់ការនៃការសម្រេចលើពាក្យបណ្តឹងមិនត្រូវបានដោះស្រាយផ្សេងពីនេះនៅក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុងទេ។ យោងតាមអង្គបុរេជំនុំជម្រះ វិធាន ៣៤ នៃវិធានផ្ទៃក្នុងបានចែងអំពី "នីតិវិធីមួយចំនួនដែលផ្តល់លទ្ធភាព ក្នុងការធ្វើការសម្រេចចិត្តលើបណ្តឹងជំទាស់"[2225]។ នីតិវិធីទាំងនេះរួមមាន ការសម្រេចលើបញ្ហាផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ ការបើកសវនាការជាសាធារណៈ ឬការស្វែងរកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី[2226]។ អង្គបុរេជំនុំជម្រះបានពិចារណាដាច់ដោយឡែកពីគ្នាថា វិធាន ៣៤ នៃវិធានផ្ទៃក្នុង ពុំមានចែងពីសវនាការផ្ទាល់មាត់ ឬការឆ្លើយតបជាលាយលក្ខណ៍អក្សរទេ[2227]។ បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើបណ្តឹងជំទាស់មិនត្រូវបានអនុញ្ញាតនោះឡើយ[2228]។

### ៨.២.២. បទដ្ឋានសម្រាប់ការដកខ្លួន ឬ បណ្តឹងជំទាស់

បទដ្ឋានសម្រាប់ការដកខ្លួន ឬការប្តឹងជំទាស់ គឺផ្អែកលើភាពលម្អៀងជាក់ស្តែង ឬភាពលម្អៀងដែលត្រូវបានគេយល់ឃើញ[2229]។ ការផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") ក្នុងរឿងក្តី *Furundžija* អ.វ.ត.ក. បានសម្រេចថា ភាពអាចកើតមាននៃភាពលម្អៀង[2230] អាចត្រូវបានបង្ហាញប្រសិនបើ៖ (ក) ចៅក្រមរូបនោះគឺជាភាគីណាមួយក្នុងរឿងក្តី ឬមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ចំពោះលទ្ធផលនៃរឿងក្តី ឬប្រសិនបើការសម្រេចរបស់ចៅក្រមរូបនោះ នឹងនាំឱ្យកើតចេញនូវបុព្វហេតុអ្វីមួយផ្សេងទៀតដែលចៅក្រមរូបនោះមានការពាក់ព័ន្ធ ឬ (ខ) កាលៈទេសៈនោះ ដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង[2231]។ "អ្នកសង្កេតការណ៍មិនលម្អៀង" ក្នុងគោលបំណងទាំងនេះ គឺជាបុគ្គលដែលបានទទួលព័ត៌មានគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងប្រពៃណី និងភារកិច្ចនៃសុចរិតភាព និងអនាគតិភាព[2232]។

---

[2225] សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៨។

[2226] ដូចខាងលើ។ វិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនបានយោងច្បាស់លាស់ទៅវិធីសាស្ត្រនីតិវិធីទាំងអស់នេះទេ។

[2227] សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ១៤។

[2228] វិធានផ្ទៃក្នុង វិធាន ៣៤(៨)។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ លោកស្រីចៅក្រម SILVIA Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ១១។

[2229] វិធានផ្ទៃក្នុង វិធាន ៣៤(២)។ សូមមើលផងដែរ សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 កថាខណ្ឌ ៣៣។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១១ ឯកសារ E137/5 កថាខណ្ឌ ១៣។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ១០-១១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ 8 កថាខណ្ឌ ៣៤។

[2230] វិធាន ៣៤ នៃវិធានផ្ទៃក្នុងមានពាក្យពេចន៍ដែលបង្ហាញផ្លូវទៅកាន់ករណីយុត្តិសាស្ត្រ ស្តីពីការស្វែងឱ្យឃើញនូវភាពលម្អៀង និងមិនគ្របដណ្តប់ផ្ទាល់លើភាពលម្អៀងពិតប្រាកដឡើយ ដែលស្រដៀងគ្នាទៅនឹងសាហៅក្តី *មិនអចិន្ត្រៃយ៍*។ *ធៀងទៅនឹង* សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ១៦។

[2231] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ១១-១២។ ការបញ្ជាក់នៃការធ្វើតេស្តនេះទាញចេញពីករណីយុត្តិសាស្ត្រនៃតុលាការ ICTY និងមិនអនុវត្តតាមវិធាន ៣៤ (២) នៃវិធានផ្ទៃក្នុងឡើយ។

[2232] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ សុំជំទាស់ចៅក្រម សោម សិរិវឌ្ឍ ដោយសារកង្វះឯករាជភាព ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខ 1/4 កថាខណ្ឌ ១០ និងដែលបានតម្កល់សេចសម្រេចក្នុង សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ១១-១២។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជា

នៅក្នុងបណ្តឹងឧបត្ថម្ភ “ការស្វែងរកភស្តុតាងគឺជាបន្ទុករបស់អ្នកដាក់បណ្តឹងទាំងស្រុង”[2233]។ ចំណុចចាប់ផ្តើមសម្រាប់ការកំណត់លើការចោទប្រកាន់អំពីភាពលម្អៀងរបស់ចៅក្រម គឺការសន្និដ្ឋានជាមុនសិនអំពីភាពមិនលម្អៀង ដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែង និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់ជាចៅក្រម[2234]។ លក្ខខណ្ឌខ្ពស់នេះតម្រូវឱ្យមាន “ពីព្រោះថា វាជាការគំរាមខ្លាំងមកលើផលប្រយោជន៍នៃការស្វែងរកយុត្តិធម៌ ដោយមិនលម្អៀង និងយុត្តិធម៌ចំពោះចៅក្រមដែលត្រូវបានប្តឹងជំទាស់ ដោយផ្អែកលើការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងគ្មានភស្តុតាងគាំទ្រអំពីភាពលម្អៀងនោះ”[2235]។

ពាក្យបណ្តឹងដែលមានលក្ខណៈទាយស្មាន ឬផ្អែកតែទៅលើការសង្ស័យ គឺមិនគ្រប់គ្រាន់នោះទេ។ ទោះបីជាភាពលម្អៀងពិតប្រាកដ ឬភាពលម្អៀងដែលចៅក្រមបង្ហាញឱ្យឃើញច្បាស់ ប៉ះពាល់ដល់ភាពជឿទុកចិត្តក្នុងកិច្ចការរដ្ឋបាលតុលាការ ការប្តឹងជំទាស់ចៅក្រមទាំងនោះដោយផ្អែកលើការចោទប្រកាន់អំពីភាពលម្អៀងដែលគ្មានមូលដ្ឋាន ក៏អាចធ្វើឱ្យប៉ះពាល់ដល់ភាពជឿទុកចិត្តក្នុងរដ្ឋបាលតុលាការផងដែរ។ ក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើអង្គហេតុដែល “បណ្តឹងជំទាស់ដដែលៗ ឬឥតបានការ” នៅចំពោះមុខសាលាក្តីអន្តរជាតិផ្សេងទៀត ដែលជាលទ្ធផលនាំឱ្យមានការដាក់ទណ្ឌកម្ម ឬការព្រមានដាក់ទណ្ឌកម្មចំពោះអ្នកប្តឹង[2236]។

## ៨.២.៣. សេចក្តីថ្លែងការណ៍ធ្វើឡើងដោយចៅក្រម

ក្នុងការឆ្លើយតបទៅនឹងគោលការណ៍ដែលថា ចៅក្រមត្រូវតែអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមរបស់ខ្លួន តាមវិធីណាមួយដែលមិនប៉ះពាល់ (ឬបង្ហាញឱ្យឃើញថាប៉ះពាល់) ឯករាជ្យភាព ឬអនាគតិភាពតុលាការនោះ[2237] មានបណ្តឹងជាច្រើនត្រូវបានធ្វើឡើងទាមទារឱ្យមានការដកខ្លួន ឬការប្តឹងជំទាស់ចៅក្រម ផ្អែកលើមូលដ្ឋាននៃសេចក្តីថ្លែងការណ៍ធ្វើឡើងដោយចៅក្រម[2238]។ ពុំមានបណ្តឹងណាមួយទទួលបានជោគជ័យនោះទេ។

---

បន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ២១។

[2233] សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ១៥។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ 8 កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ១៩។

[2234] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ១២ និងដែលបានតម្កល់សេចក្តីសម្រេចក្នុង សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ១៥-១៧។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ១៥។

[2235] សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 កថាខណ្ឌ ៣៥។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១១ ឯកសារ E137/5 កថាខណ្ឌ ១៥។ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យ ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម KATINKA Lahuis និងចៅក្រម ROWAN Downing ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ 5 កថាខណ្ឌ ៧។

[2236] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១១ ឯកសារ E137/5 កថាខណ្ឌ ១៤-១៥។

[2237] សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ១៨-១៩។

[2238] សូមមើល ឧទាហរណ៍ ដូចខាងលើ។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម Silvia CARTWRIGHT ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E171/2។

អង្គបុរេជំនុំជម្រះបានច្រានចោលបណ្ដឹងជំទាស់ចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយផ្អែកលើពាក្យសម្ដីដែលគេចោទថាគាត់បានលើកឡើងនៅក្នុងការប្រជុំបុគ្គលិក។ អង្គបុរេជំនុំជម្រះបានពិចារណាថា ភ័ស្តុតាងអំពីហេតុការណ៍ដែលបានចោទប្រកាន់នោះមិនគ្រប់គ្រាន់ ដោយពិចារណាលើវេទិកានៃការប្រជុំ (ពោលគឺ ជាលក្ខណៈឯកជន មិនមែនសាធារណៈ) ដែលសហចៅក្រមស៊ើបអង្កេតបាននិយាយជាភាសាអង់គ្លេស មិនមែនជាភាសាបារាំងទេ (ពោលគឺ មិនមែនជាភាសាការងាររបស់គាត់) និងថា វាអាចទៅរួចដែលថាពាក្យសម្ដីនោះត្រូវបាននិយាយជាការលេងសើច ឬជា "ទំនោរ" ជាជាងការណែនាំផ្ទាល់[2239]។

អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលបណ្ដឹងជំទាស់ចៅក្រម ចំពោះពាក្យសម្ដីដែលគាត់បញ្ចេញក្នុងសារព័ត៌មាន ក៏ដូចជាសេចក្ដីថ្លែងការណ៍ជាក់លាក់ដែលបានធ្វើឡើងក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើករណីយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ដែលបានសម្រេចថា ការបញ្ចេញយោបល់របស់ចៅក្រមនៅក្នុងប្រព័ន្ធសារព័ត៌មាន មិនបង្ហាញពីភាពខ្វះអនាគតិនោះទេ លើកលែងតែបានបង្ហាញពីទស្សនៈមិនពេញចិត្តចំពោះរឿងក្ដីរបស់អ្នកដាក់ពាក្យសុំនោះ។ ក្នុងករណីនេះ អង្គជំនុំជម្រះយល់ឃើញថា សេចក្ដីថ្លែងការណ៍ព័ត៌មានមិនបង្ហាញពីទស្សនៈមិនពេញចិត្តចំពោះជនជាប់ចោទនោះទេ។ ទាក់ទងទៅនឹងសេចក្ដីថ្លែងនៅក្នុងតុលាការវិញ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាសេចក្ដីថ្លែងទាំងនេះគឺ "ជាការអនុវត្តសមស្របនូវឆន្ទានុសិទ្ធិរបស់ចៅក្រម [...] ដើម្បីធានាឱ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ"។ ហេតុដូច្នេះភ័ស្តុតាងទាំងមូលដែលបានផ្ដល់ឱ្យ "ពុំមានភាពគ្រប់គ្រាន់ក្នុងការដកចេញនូវការសន្មតអំពីភាពអនាគតិរបស់ចៅក្រម" នោះទេ អាស្រ័យហេតុនេះបណ្ដឹងនេះត្រូវបានបដិសេធចោល[2240]។

## ៨.២.៤. ការចោទប្រកាន់ពីអំពើពុករលួយ និងសម្បទាក្នុងការបំពេញមុខងារ

សំណើសុំប្ដឹងជំទាស់ចៅក្រមដែលផ្អែកលើការចោទប្រកាន់ពីអំពើពុករលួយ ការពុំមានសម្បទាក្នុងការបំពេញមុខងារ និងកង្វះភាពអនាគតិ ពុំទទួលបានជោគជ័យទេ ដោយសារតែពុំបានបង្ហាញពីផលប៉ះពាល់ដែលអាចស្ដែងឱ្យឃើញ។ នៅពេលដែលកើតមានការព្រួយបារម្ភអំពីសម្បទារបស់ចៅក្រមក្នុងការបំពេញមុខងារនោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា បញ្ហានេះគប្បីដោះស្រាយតាមរយៈយន្តការជាតិ ដើម្បីធានាបាននូវសុចរិតភាពតុលាការនៅក្នុងតុលាការកម្ពុជា[2241]។

## ៨.២.៥. ការចោទប្រកាន់ពីកង្វះឯករាជ្យភាព និងអនាគតិភាព

ពាក្យសុំជាច្រើនដែលប្ដឹងជំទាស់ បានផ្អែកលើការជាប់ពាក់ព័ន្ធផ្នែកតុលាការក្នុងបញ្ហានយោបាយកម្ពុជា និងការចោទប្រកាន់ពីការធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាព និងអនាគតិភាព[2242]។ បណ្ដឹងទាំងអស់នេះមិនបានបំពេញលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់បណ្ដឹងជំទាស់ទេ ដោយ អ.វ.ត.ក. បានបញ្ជាក់សច្ចាធារណ៍ ថា "នៅពេលដែលចៅក្រមម្នាក់បានស្បថចូលកាន់តំណែង គឺមានការសន្មតថា[ពួកគេ]អាច ហើយនឹង

---

[2239] សំណុំរឿង ០០២ សាលដីកាលើពាក្យបណ្ដឹងជំទាស់របស់ជនត្រូវចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ 7 កថាខណ្ឌ ៥ និង ២០-២៦។

[2240] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចំពោះចៅក្រម Silvia CARTWRIGHT ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E171/2 កថាខណ្ឌ ១៤ កថាខណ្ឌ ១៧-១៨ និង ២០។

[2241] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងរបស់លោក អៀង សារី ដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ឯកសារ E5/3 កថាខណ្ឌ ១៦។

[2242] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ 8។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើសំណើរបស់ អៀង ធិរិទ្ធ សុំជំទាស់ចៅក្រម សោម សិរីវឌ្ឍ ដោយសារកង្វះឯករាជភាព ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខ 1/4។

ធ្វើការកែតម្រូវចិត្តរបស់គាត់ មិនឱ្យមានជាប់ពាក់ព័ន្ធទៅនឹងជំនឿផ្ទាល់ខ្លួន ឬភាពលម្អៀងណាមួយឡើយ"[2243]។

## ៨.២.៦. ការប្រាស្រ័យទំនាក់ទំនង *ជាមួយភាគីតែម្ខាង*

ទោះបីជាសង្កត់ធ្ងន់លើសារៈសំខាន់នៃឯករាជ្យភាព និងអនាគតិភាពតុលាការក៏ដោយ ក៏ក្រមសីលធម៌ចៅក្រម អ.វ.ត.ក. មិនមានបទប្បញ្ញត្តិណាចែងអំពីការប្រាស្រ័យទំនាក់ទំនង *ជាមួយភាគីតែម្ខាង*នោះឡើយ។ ប្រសិនបើការប្រាស្រ័យទំនាក់ទំនងរវាងសហព្រះរាជអាជ្ញា និង ចៅក្រមមិនទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីដែលកំពុងធ្វើទេនោះ ការប្រាស្រ័យទំនាក់ទំនង *ជាមួយភាគីតែម្ខាង*នេះមិនបង្ហាញពីភាពលម្អៀង ឬការលេចឡើងពីភាពលម្អៀងនោះទេ[2244]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការជួបគ្នាបែបនោះអាចបង្កើតជាអាការៈបង្ហាញសិទ្ធិចូលរួមប្រជុំជាលក្ខណៈប្រព័ន្ធ និងបានណែនាំឱ្យរួមបញ្ចូលផ្នែកគាំពារការការពារក្តី ឬសមាជិកក្រុមមេធាវីការពារក្តីផង[2245]។

ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលការចោទប្រកាន់អំពីភាពលម្អៀងរបស់ចៅក្រមម្នាក់ បន្ទាប់ពីការចូលរួមរបស់គាត់ក្នុងការសន្ទនាជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានរដ្ឋបាលនៃ អ.វ.ត.ក.។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា នៅក្នុងតុលាការអន្តរជាតួបនីយកម្មផ្សេងទៀត ការជួបប្រជុំជាប្រចាំរវាងប្រធាន អយ្យការ និងក្រឡាបញ្ជី គឺជារឿងធម្មតា។ ជារួម អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការចូលរួមរបស់ចៅក្រមក្នុងការប្រជុំទាំងនេះ មិនបង្កើតបានជាការព្រួយបារម្ភសមហេតុផលអំពីភាពលម្អៀងនោះទេ ហើយបានបដិសេធបណ្តឹងជំទាស់ចៅក្រមនោះ[2246]។

អង្គជំនុំជម្រះតុលាការកំពូល ដោយបានពិចារណាអង្គហេតុលើបណ្តឹងសាទុក្ខដូចគ្នានេះ បានសន្និដ្ឋានថា ការជួបប្រជុំជាមួយ*ភាគីតែម្ខាង* ដែលក្នុងពេលនោះពុំមានបញ្ហាណាមួយមិនសមរម្យត្រូវបានចោទប្រកាន់ថាបានពិភាក្សានោះ មិនបង្កើតបានជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនោះទេ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ការប្រជុំបែបនោះអាច "បង្កើតអាការបង្ហាញថា សហព្រះរាជអាជ្ញាមានសិទ្ធិចូលរួមប្រជុំ ដូចចៅក្រមជំនុំជម្រះ" ហើយដូច្នេះបានណែនាំថា ការប្រជុំបែបនោះគប្បីចូលរួមដោយផ្នែកគាំពារការការពារក្តី ឬសមាជិកក្រុមមេធាវីការពារក្តីផងដែរ[2247]។

## ៨.២.៧. ការរកឃើញនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការពីមុន

មេធាវីការពារក្តីបានដាក់បណ្តឹងជំទាស់ចៅក្រមក្នុងសំណុំរឿង ០០២ ដោយបានអះអាងថា ការចូលរួមរបស់ចៅក្រមដដែលក្នុងរឿងក្តីមុន បានបង្ហាញពីភាពលម្អៀងពិតប្រាកដ ឬដែលបង្ហាញឱ្យឃើញ

---

[2243] សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ចៅក្រមជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ២៨។

[2244] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១១ ឯកសារ E137/5 កថាខណ្ឌ ១៨ និង ២២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ លោកស្រីចៅក្រម SILVIA Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ២៣។

[2245] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ លោកស្រីចៅក្រម SILVIA Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ២៤។

[2246] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ចុះថ្ងៃទី២ ធ្នូ ឆ្នាំ២០១១ ឯកសារ E137/5 កថាខណ្ឌ ១៥ និង ២២។

[2247] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ លោកស្រីចៅក្រម SILVIA Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ២៣-២៤។

[2248]។ ការសម្រេចផ្នែកតុលាការបានបង្កើតបទដ្ឋានរឹងមាំសម្រាប់ការបង្ហាញពីភាពលម្អៀង ដោយផ្អែកលើករណីយុត្តិសាស្ត្ររបស់តុលាការ ECtHR។

ចំពោះការចោទប្រកាន់ពីភាពលម្អៀងផ្អែកលើការសម្រេចរបស់តុលាការពីមុន វាមិនគ្រប់គ្រាន់ឡើយក្នុងការចោទប្រកាន់ពីកំហុសអង្គច្បាប់ ដែលអាចមានការបកស្រាយលើសពីមួយនោះ។ អ្នកដាក់ពាក្យប្តឹងក៏ពុំត្រូវបានអនុញ្ញាតឱ្យ "គ្រាន់តែលើកឡើងថាសេចក្តីសម្រេចមានកំហុស" ឬជំទាស់ទៅនឹងការវាយតម្លៃអង្គហេតុពាក់ព័ន្ធនោះទេ។ ការមិនឯកភាពទៅនឹងខ្លឹមសារនៃសេចក្តីសម្រេចគឺជាបញ្ហាសម្រាប់បណ្តឹងសាទុក្ខ ពុំមែនពាក្យសុំប្តឹងជំទាស់ចៅក្រមនោះទេ[2249]។ ពាក្យបណ្តឹងដែលផ្អែកលើការចោទប្រកាន់ពីការប្រព្រឹត្តិខុសឆ្គងក្នុងរឿងក្តីផ្សេង និងមិនទទួលបានជោគជ័យទេ លើកលែងតែមានភស្តុតាងបង្ហាញថាកំហុសនោះនឹងរារាំងមិនឱ្យចៅក្រមរូបនោះអនុវត្តបាននូវគំនិតអនាគតិក្នុងរឿងក្តីបច្ចុប្បន្ន[2250]។ ការរកឃើញភាពលម្អៀងនៅក្នុងរឿងក្តីពីមុន មិនតម្រូវឱ្យចៅក្រមរូបនោះដកខ្លួនចេញពីរឿងក្តីដទៃទៀតដែលមិនពាក់ព័ន្ធនោះទេ[2251]។

អត្ថិភាពនៃសមាសភាពចៅក្រមដដែល ដែលបើកសវនាការជំនុំជម្រះរឿងក្តីជាបន្តបន្ទាប់ មិនបង្កើតបានជាមូលដ្ឋានសម្រាប់បណ្តឹងជំទាស់ចៅក្រមនៅ អ.វ.ត.ក. នោះទេ[2252]។ លក្ខណៈយុត្តាធិការដែលបានអនុវត្តដោយសាលាក្តីព្រហ្មទណ្ឌអន្តរជាតិពិសេសនោះគឺថា ជាញឹកញាប់វានាំឱ្យមានការជំនុំជម្រះច្រើនកើតចេញពីអង្គហេតុតែមួយ[2253]។

ទោះជាយ៉ាងណា ការសម្រេចពីមុនលើពិរុទ្ធភាពរបស់បុគ្គលដែល "ពិតជាបានធ្វើបុរេវិនិច្ឆ័យ" លើពិរុទ្ធភាពរបស់ជនជាប់ចោទ អាចបង្ហាញពីការយល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង។ ដោយពិចារណាលើករណីយុត្តិសាស្ត្ររបស់តុលាការ ICTR និង ECtHR អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ពិតជាបានធ្វើបុរេវិនិច្ឆ័យ" មានន័យថា បានពិចារណាលើ "លក្ខណៈវិនិច្ឆ័យចាំបាច់ពាក់ព័ន្ធទាំងអស់ក្នុងការបង្កើតជាបទល្មើសព្រហ្មទណ្ឌ និង ... ថាតើអ្នកដាក់ពាក្យសុំមានពិរុទ្ធភាពលើសពីវិមតិសង្ស័យចំពោះការប្រព្រឹត្តិបទល្មើសបែបនេះ" ដែរ ឬយ៉ាងណា[2254]។ អង្គជំនុំជម្រះសាលាដំបូងបាន

---

[2248] សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 ។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4។

[2249] សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 កថាខណ្ឌ ៣៦។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ១៣។

[2250] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ឯកសារ E5/3 កថាខណ្ឌ ៧។ សំណុំរឿង ០០២ សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ចៅក្រមជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29 កថាខណ្ឌ ៣១។

[2251] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ឯកសារ E5/3 កថាខណ្ឌ ៧។

[2252] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ២០។

[2253] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ២០។ *ធៀបទៅនឹង* សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 និង យោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម Rowan Downing កថាខណ្ឌ ១៧។

[2254] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ២១។

ពិចារណាលើអំណះអំណាងរបស់មេធាវីការពារក្តី ដែលថាការយល់ឃើញដែលបានធ្វើឡើងដោយអង្គជំនុំជម្រះដែលក្នុងសំណុំរឿង ០០១ និង ០០២/០១ អាចបណ្តាលឱ្យអ្នកសង្កេតការណ៍ដ៏សមហេតុផល មានមន្ទិលលើសមត្ថភាពរបស់ក្រុមប្រឹក្សាចៅក្រមដដែល ក្នុងការវាយតម្លៃឡើងវិញឱ្យបានត្រឹមត្រូវលើបញ្ហាទាំងអស់នោះនៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២។ បទដ្ឋាននេះមិនត្រូវបានបំពេញនៅក្នុងរឿងក្តីណាមួយនោះឡើយ[2255]។

### ៨.២.៨. ការចោទប្រកាន់ពីភាពលម្អៀងរបស់បុគ្គលិក

យន្តការបណ្តឹងជំទាស់មិនអនុវត្តចំពោះបុគ្គលិកទេ។ ក្នុងសំណុំរឿង ០០២ អៀង សារី បានប្តឹងជំទាស់ចិត្តបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត "ពីព្រោះថា កាតព្វកិច្ចនៃភាពអនាគតិរបស់តុលាការត្រូវតែអនុវត្តស្មើគ្នាចំពោះអ្នកទាំងឡាយណា ដែលបម្រើការងារយ៉ាងជិតស្និទ្ធជាមួយសហចៅក្រមស៊ើបអង្កេត និងអនុវត្តមុខងារតុលាការក្នុងនាមសហចៅក្រមស៊ើបអង្កេត"។ អង្គបុរេជំនុំជម្រះបានសម្រេចថា មូលដ្ឋាននៃភាពអាចទទួលយកបាននៃពាក្យសុំតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងសំដៅយ៉ាងច្បាស់តែទៅលើចៅក្រមប៉ុណ្ណោះ។ បុគ្គលិកមិនត្រូវបានរួមបញ្ចូលទេ ហើយតួនាទី និងមុខងាររបស់អ្នកស៊ើបអង្កេត ឬមន្ត្រីច្បាប់គឺខុសគ្នាពីតួនាទី និងមុខងាររបស់សហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះសម្រេចថា ពាក្យបណ្តឹងនោះមិនអាចទទួលយកបាន[2256]។

### ៨.៣. ការចោទប្រកាន់ពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

វិធាន ៣៥ នៃវិធានផ្ទៃក្នុងចែងពីយន្តការគ្រប់គ្រងលើការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ នៅ អ.វ.ត.ក.[2257]។ អនុវត្តតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY អ.វ.ត.ក. បានបង្ហាញថា គោលបំណងនៃការហាមឃាត់ទង្វើបែបនេះគឺ "ដើម្បីធានាថា ការអនុវត្តនូវយុត្តាធិការរបស់តុលាការពុំត្រូវបានរារាំង ហើយភារកិច្ចជាមូលដ្ឋានរបស់តុលាការត្រូវបានការពារ"[2258]។ អ.វ.ត.ក. បានពិចារណាយុត្តិសាស្ត្ររបស់តុលាការ ICTY នៅក្នុងការបកស្រាយបទប្បញ្ញត្តិនានាទាក់ទងនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយយោងទៅលើភាពស្រដៀងគ្នាដែលអាចបង្ហាញបានរវាងយន្តការទាំងពីរ[2259]។

អង្គជំនុំជម្រះតុលាការកំពូលបានញែករវាងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពោលគឺ បទប្បញ្ញត្តិទូទៅដែលបង្ហាញពីប្រភេទនៃទង្វើដែលហាមឃាត់ ជាមួយនឹងវិធាន ៣៤ នៃវិធានផ្ទៃក្នុងដែលជា "នីតិវិធីពិសេសមួយដែលមានគោលបំណងធានានូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសុចរិតភាពនៃតួនាទីតុលាការ"។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បញ្ហាចោទពាក់ព័ន្ធស្ថិតក្រោមវិធាន ៣៥ គឺ "ថាតើបទល្មើសប្រឆាំងនឹងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ត្រូវបានប្រព្រឹត្តឡើងដែរ ឬយ៉ាងណា"[2260]។

---

[2255] សំណុំរឿង ០០២ សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1 កថាខណ្ឌ៩២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ ឯកសារ E55/4 កថាខណ្ឌ ២២-២៥។

[2256] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងជំទាស់ចិត្តរបស់ជនត្រូវចោទ ទៅលើលោកបណ្ឌិត Stephen Heder និងលោកបណ្ឌិត David Boyle ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារលេខ 3 កថាខណ្ឌ ៧ កថាខណ្ឌ ១៤ កថាខណ្ឌ ១៩-២០ និង ២២។

[2257] វិធានផ្ទៃក្នុង វិធាន ៣៥។

[2258] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឯកសារ E176/2 កថាខណ្ឌ ២១។

[2259] សំណុំរឿង ០០២ សាលដីកាលើកទីពីរ លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ D314/1/12 កថាខណ្ឌ ៣២។

[2260] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជំទាស់ចិត្ត លោកស្រីចៅក្រម SILVIA Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ១៥។

ភាពអាចអនុវត្តបាននៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចំពោះចៅក្រម គឺមានកម្រិតខ្លាំងណាស់។ អង្គបុរេជំនុំជម្រះបដិសេធមិនផ្តួចផ្តើមការស៊ើបអង្កេតតាមវិធាន ៣៥ លើការចោទប្រកាន់ថា សេចក្តីសម្រេចរបស់តុលាការត្រូវបានទទួលរងឥទ្ធិពលមិនត្រឹមត្រូវ ដោយសម្រេចថា អង្គជំនុំជម្រះនៃ អ.វ.ត.ក. ពុំមានយុត្តាធិការកំណត់ថាតើ "កិច្ចតាមផ្លូវតុលាការ" គឺជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងដែរ ឬយ៉ាងណានោះឡើយ។ អង្គបុរេក៏បានសន្និដ្ឋានផងដែរថា ពុំមានយុត្តាធិការណាចែងសម្រាប់ឱ្យអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក. ដោះស្រាយបញ្ហាវិន័យចំពោះចៅក្រមណាម្នាក់នៃ អ.វ.ត.ក. ហួសពីការកម្រិតរបស់វិធាន ៣៤ នៃវិធានផ្ទៃក្នុងឡើយ។ ទោះជាយ៉ាងណាអង្គជំនុំជម្រះតុលាការកំពូលពិចារណាថា "ជាគោលការណ៍ ចៅក្រម យ៉ាងហោចណាស់ស្ថិតនៅក្នុងយុត្តាធិការនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលបានចែងថា ការប្រព្រឹត្តិរបស់ចៅក្រមឈានទៅដល់កម្រិតនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ យោងតាមខ្លឹមសារនៃវិធាននេះ"[2261]។

### ៨.៣.១. លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៃការអនុវត្តតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង

បុគ្គលណាម្នាក់ដែលស្ថិតក្រោមកិច្ចដំណើរការនីតិវិធីតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង មានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ហើយសេចក្តីសម្រេចតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍/ប្តឹងសាទុក្ខ (ផ្ទុយនឹងបទប្បញ្ញត្តិទាំងឡាយក្រោមវិធាន ៣៤ នៃវិធានផ្ទៃក្នុង)[2262]។

វិធាន ៣៥ នៃវិធានផ្ទៃក្នុងពុំបានបញ្ជាក់ក្របខ័ណ្ឌពេលវេលាសម្រាប់ពាក្យបណ្តឹងឡើយ ប៉ុន្តែក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់មួយអំពីការជ្រៀតជ្រែក ឬកំហុសវិជ្ជាជីវៈ ទាក់ទងនឹងសាក្សីសក្តានុពលម្នាក់ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា មេធាវីការពារក្តីបាន "ខកខានមិនបានលើកឡើងអំពីការចោទប្រកាន់ពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការដែលបង្ហាញពីការខ្វះការយកចិត្តទុកដាក់ និងមិនបានបង្ហាញពីភាពបន្ទាន់នៃសំណើនេះទេ រហូតដល់រយៈពេលជាងពីរឆ្នាំក្រោយមកទើបលើកពីបញ្ហានេះ"។ ជាទូទៅ ការស៊ើបអង្កេតអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អាចត្រូវបាន "អនុវត្តដោយប្រសិទ្ធភាព ដោយស្ថាប័នតុលាការដែលទទួលសំណុំរឿងនេះ"[2263]។ អង្គជំនុំជម្រះតុលាការកំពូល បានឯកភាពជាទូទៅជាមួយនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែបានបញ្ជាក់ថា ក្នុងកាលៈទេសៈជាក់លាក់ ស្ថាប័នតុលាការដែលទទួលរឿងក្តីអាចមានអំណាច ទាក់ទងនឹងការចោទប្រកាន់អំពីការជ្រៀតជ្រែកពីមុន ដោយសារ "ស្ថាប័នណាមួយនៃអង្គជំនុំជម្រះដែលទទួលសំណុំរឿង [...] គ្មានជម្រើសអ្វីក្រៅពីអនុវត្តអំណាចដែលមាន ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ដោយមិនគិតថា រឿងរ៉ាវដែលបានចោទប្រកាន់អំពីការជ្រៀតជ្រែកបានកើតឡើងនៅពេលណានោះទេ"[2264]។

### ៨.៣.២. អំពើដែលអាចរងទណ្ឌកម្មវិន័យ

---

[2261] ដូចខាងលើ កថាខណ្ឌ ១១-១៧ (យោង សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ ឯកសារ E130/4/3)។

[2262] វិធានផ្ទៃក្នុង វិធាន ៣៥(៣) និង ៣៥(៦)។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៣៤(៨)។

[2263] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E116 កថាខណ្ឌ ២១ និង ២៣។

[2264] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E116/1/7 កថាខណ្ឌ ៣១។

អំពើដែលអាចរងទណ្ឌកម្មវិន័យគឺជាការប្រព្រឹត្តិទាំងឡាយណាដែលព្យាយាម "បង្អាក់សិទ្ធិអំណាច ឬដំណើរការរបស់តុលាការ"។ អំពើនោះមិនចាំបាច់ជ្រៀតជ្រែកជាក់ស្តែងចូលទៅក្នុងកិច្ចដំណើរការនីតិវិធីទេ ប្រសិនបើវា "ប៉ះពាល់ដល់ធម្មានុរូបរបស់តុលាការជាមួយនឹងភាគីនានា និងសាធារណជនទូទៅ"[2265]។

វិធាន ៣៥ នៃវិធានផ្ទៃក្នុងចែងអំពី "ទម្រង់មួយចំនួននៃអំពើដែលអាចចាត់ជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ" ឬ "កិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីបង្អាក់សិទ្ធិអំណាច ឬដំណើរការរបស់តុលាការ"[2266]។ អនុកថាខណ្ឌ (ក), (ខ) និង (ង) ចែងពាក់ព័ន្ធនឹងការមិនគោរពតាមដីការបស់ អ.វ.ត.ក.។ អនុកថាខណ្ឌ (គ) និង (ឃ) ដោះស្រាយការជ្រៀតជ្រែកទៅលើការផ្តល់ភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក.។ អនុកថាខណ្ឌ (ច) ចែងអំពីការជួយជនជាប់ចោទឱ្យរួចផុតពីយុត្តាធិការរបស់ អ.វ.ត.ក.[2267]។ ទោះជាយ៉ាងណា វិធាន ៣៥(១) នៃវិធានផ្ទៃក្នុងមិនបាន "កំណត់អំពើដែលច្បាប់បានហាមឃាត់ឱ្យបានលម្អិតឡើយ" ដែលមានន័យថា អំពើផ្សេងទៀតដែលស្រដៀងទៅនឹងអំពើនានាដែលត្រូវបានរៀបរាប់ក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក៏ត្រូវចាត់ទុកថាស្ថិតនៅក្នុងវិសាលភាពនៃវិធាននេះដែរ[2268]។

អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា អំពើដែលអាចរងទណ្ឌកម្មវិន័យអាច តែមិនចាំបាច់ ជាអំពើព្រហ្មទណ្ឌឡើយ ហើយផ្ទុយទៅនឹងសាលាក្តីអន្តរជាតិ វិធាន ៣៥ នៃវិធានផ្ទៃក្នុងពុំមែនជាប្រភពស្វ័យប្រវត្តិនៃការកំណត់បទល្មើសព្រហ្មទណ្ឌទេ[2269]។ ទាក់ទងនឹងអំពើព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌកម្ពុជាអនុវត្ត ចំណែកឯទាក់ទងនឹងបទល្មើសដែលមិនមែនជាបទព្រហ្មទណ្ឌវិញ ចៅក្រម អ.វ.ត.ក. មានការទទួលខុសត្រូវក្នុងការសម្រេចថាតើបទល្មើសដែលមិនមែនជាបទព្រហ្មទណ្ឌណាមួយ ត្រូវបានរួមបញ្ចូល[2270]។

ការសម្រេចរបស់តុលាការបានគ្របដណ្តប់លើអំពើទាំងឡាយស្ថិតក្នុងវិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានផ្អែកលើករណីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ទាក់ទងនឹងការជ្រៀតជ្រែកសាក្សី ដែលបង្ហាញថា ការគំរាមកំហែងត្រូវបានកំណត់និយមន័យថាជា "ចេតនាបង្កឱ្យមានរបួស ឬការខូចខាតនានាទៅលើសាក្សីណាមួយ និង/ឬទ្រព្យសម្បត្តិរបស់សាក្សី ឬទៅលើបុគ្គលទីបីណាមួយ និង/ឬទ្រព្យសម្បត្តិរបស់គាត់ ដើម្បីជះឥទ្ធិពលទៅលើឆន្ទៈរបស់សាក្សីដែលទទួលរងនូវការគំរាមកំហែងនោះ"។ ក្នុងគោលបំណងនេះ ការបំភិតបំភ័យមានន័យថាជា "អំពើ ឬការធ្វេសប្រហែសទាំងឡាយណា ដែលអាចបង្កឱ្យមានការគំរាមកំហែងដោយផ្ទាល់ ដោយប្រយោល ឬដោយមានសក្តានុពល ទៅលើសាក្សីណាមួយ ដែលអំពើនេះ អាចរំខានដល់ ឬជ្រៀតជ្រែកទៅលើសក្ខីកម្មរបស់សាក្សី"។ ម្យ៉ាងវិញទៀតការជ្រៀតជ្រែកទៅលើសាក្សីគឺជា "បទប្បញ្ញត្តិដែលមានន័យទូលំទូលាយមួយដែលគ្របដណ្តប់ទៅលើរាល់អំពើ ឬការធ្វេសប្រហែសទាំងឡាយណា ក្រៅពីការគំរាម ការបំភិតបំភ័យ ការបង្ករបួសស្នាម ឬការផ្តល់សំណូក ដែលអាច និងទំនងជាអាចធ្វើឱ្យសាក្សីផ្តល់សក្ខីកម្មមិនពេញលេញ និងមិនពិតប្រាកដ ឬដោយមធ្យោបាយផ្សេងទៀត អាចជ្រៀតជ្រែកទៅលើលក្ខណៈនៃភ័ស្តុតាងរបស់សាក្សី

---

2265 សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៤-៣៥។

2266 ដូចខាងលើ។

2267 វិធានផ្ទៃក្នុង វិធាន ៣៥(១)។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៤។

2268 សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៣-៣៤។

2269 ដូចខាងលើ កថាខណ្ឌ ៣២។

2270 ដូចខាងលើ កថាខណ្ឌ ៣២-៣៣។

នោះ”[2271]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ការបញ្ចេញឯកសារសម្ងាត់គឺជាបទល្មើសមួយដែលអាចនាំឱ្យមានការដាក់ទណ្ឌកម្មវិន័យ ស្របតាមច្បាប់កម្ពុជា និង/ឬ ការសន្និដ្ឋានអំពីកំហុសវិជ្ជាជីវៈរបស់មេធាវី[2272]។

វិធាន ៣៥ នៃវិធានផ្ទៃក្នុងក៏ “ទាមទារឱ្យមជ្ឈដ្ឋានខាងក្រៅបញ្ឈប់ការព្យាយាមដាក់ឥទ្ធិពលមកលើចៅក្រម ឬបញ្ឈប់ទង្វើដែលគេអាចចាត់ទុកជាការព្យាយាមដាក់ឥទ្ធិពលមកលើចៅក្រម”។ អង្គជំនុំជម្រះសាលាដំបូងចាត់ទុកការអត្ថាធិប្បាយទៅកាន់សារព័ត៌មានធ្វើឡើងដោយនាយករដ្ឋមន្ត្រី អំពី នួន ជា គឺមិនស្របគ្នាទៅនឹងគោលការណ៍នៃការសន្និតថាគ្មានទោសទេ និង “មានហានិភ័យដែលអាចត្រូវបានគេយកទៅបកស្រាយថា មានការប៉ុនប៉ងដាក់សម្ពាធដោយមិនសមរម្យមកលើចៅក្រមដែលកំពុងទទួលបន្ទុកចាត់ការរឿងក្តីនេះ”[2273]។ អង្គជំនុំជម្រះតុលាការកំពូលឯកភាពថា សកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាព និងអនាគតិភាពរបស់ចៅក្រម គឺជាការជ្រៀតជ្រែកដែលត្រូវបានហាមឃាត់ក្រោមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង។ ដូច្នេះ ការធ្វើឱ្យប៉ះពាល់ដល់ការបង្ហាញឱ្យឃើញនូវឯករាជ្យភាព និងភាពអនាគតិរបស់ អ.វ.ត.ក . គឺជាការជ្រៀតជ្រែក ដែលមិនគ្រាន់តែជាការបង្ហាញឱ្យឃើញនូវការជ្រៀតជ្រែកនោះឡើយ[2274]។ បន្ទាប់ពីបានសន្និដ្ឋានថា សេចក្តីថ្លែងការណ៍នោះគឺជាហានិភ័យមួយចំពោះការសន្និតថាគ្មានទោសរបស់ នួន ជា អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសចេញសេចក្តីប្រកាស “យ៉ាងច្បាស់លាស់ជាសាធារណៈអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការសន្និតថាគ្មានទោស និងភាពចាំបាច់ដែលមន្ត្រីនានាគប្បីចៀសវាងការធ្វើសេចក្តីអធិប្បាយណាមួយដែលមិនស្របទៅនឹងគោលការណ៍នេះ”។[2275]

មេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចប្រព្រឹត្តអំពើដែលអាចរងទណ្ឌកម្មវិន័យបាន (ហើយប្រសិនបើដូច្នោះ អាចទទួលខុសត្រូវចំពោះកំហុសវិជ្ជាជីវៈអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង)[2276]។ ទង្វើដែលអាចរងទណ្ឌកម្មវិន័យដែលបានប្រព្រឹត្តដោយមេធាវីណាម្នាក់រួមបញ្ចូលទាំង “ការធ្វើឱ្យមានការរំខាននៅក្នុងបន្ទប់សវនាការ” និង “ការធ្វើឱ្យប៉ះពាល់ដល់ដំណើរការផ្នែកភ័ស្តុភាររបស់តុលាការ”[2277]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចផងដែរថា ការប្រព្រឹត្តិខុសរបស់ចៅក្រម យ៉ាងហោចណាស់ជាគោលការណ៍ ស្ថិតក្នុងយុត្តាធិការនៃវិធាន ៣៥ ផងដែរ[2278]។

---

[2271] សំណុំរឿង ០០២ ការជូនដំណឹងរបស់មេធាវីការពារក្តី ពីភាសាសម្រាប់ដាក់ និងទទួលឯកសារ និង ការស្នើសុំពន្យាពេលដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះហៅសាក្សី ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ D314/1/12 កថាខណ្ឌ ៣៣។

[2272] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E116/1/7 កថាខណ្ឌ ៣៦។

[2273] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឯកសារ E176/2 កថាខណ្ឌ ២១ និង ២៩។

[2274] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៦។

[2275] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឯកសារ E176/2 កថាខណ្ឌ ៣១។

[2276] វិធានផ្ទៃក្នុង វិធាន ៣៥(៥)។

[2277] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៥។

[2278] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងជិតចិត្ត លោកស្រីចៅក្រម SILVIA Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ១៤។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៦។ អង្គបុរេជំនុំជម្រះពីមុនធ្លាប់បដិសេធធ្វើការស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ទៅលើការចោទប្រកាន់នានាថា សេចក្តីសម្រេចរបស់តុលាការទទួលរងឥទ្ធិពលមិនត្រឹមត្រូវ ដោយសម្រេចថា អង្គជំនុំជម្រះ អ.វ.ត.ក. មិនមានយុត្តាធិការក្នុងការពិចារណាថាតើ កិច្ចតុលាការមានតម្លៃស្មើទៅនឹងការជ្រៀតជ្រែកកិច្ចការយុត្តិធម៌ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះទេ។

### ៨.៣.៣. លក្ខខណ្ឌតម្រូវ *ធាតុផ្សំអត្តនោម័ត*

យោងតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ទង្វើដែលអាចរងទណ្ឌកម្មវិន័យត្រូវតែមាន "ចេតនាពិតប្រាកដ"[2279] ជាបទដ្ឋានមួយដែលត្រូវបានបង្កើតឡើងតាមរយៈករណីយុត្តិសាស្ត្រ។

យោងតាមអង្គបុរេជំនុំជម្រះ បទដ្ឋាន*ធាតុផ្សំអត្តនោម័ត* តម្រូវថា "ជនជាប់ចោទបានប្រព្រឹត្តអំពើដោយចេតនាពិតប្រាកដ ហើយដឹងថា អំពើរបស់ខ្លួនទំនងនឹងរារាំង ឬជ្រៀតជ្រែកដល់សាក្សី ឬអ្នកដែលអាចក្លាយទៅជាសាក្សី"[2280]។ អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយយោងទៅលើយន្តការនៃការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការនៃតុលាការ ICTY ដែលតម្រូវឱ្យមាន "ចេតនាជាក់លាក់" ក្នុងការជ្រៀតជ្រែក[2281]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បំភ្លឺថា បទដ្ឋានត្រូវបានអនុវត្តខុសៗគ្នាអាស្រ័យលើប្រភេទនៃបទល្មើសដែលជាបញ្ហាចោទ។ បទល្មើសព្រហ្មទណ្ឌ និងធាតុផ្សំអត្តនោម័តរបស់ពួកវា ត្រូវបានកំណត់និយមន័យតាមច្បាប់ជាតិកម្ពុជា។ ចំពោះបទល្មើសមិនមានលក្ខណៈព្រហ្មទណ្ឌវិញ ធាតុផ្សំចេតនាគឺត្រូវកំណត់និយមន័យ "ដើម្បីរួមបញ្ចូលពិរុទ្ធភាពដូចដែលសមស្រប ក្នុងការធានាបាននូវការការពារដែលការចែងហាមឃាត់កំណត់ឡើង"។ ចេតនាជាក់លាក់ ពោលគឺដូចដែលបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY សម្រាប់បទល្មើសព្រហ្មទណ្ឌនៃបទប្រមាថតុលាការ ត្រូវបានចាត់ទុកថាមានលក្ខណៈតឹងរ៉ឹងពេកសម្រាប់បទល្មើសផ្នែករដ្ឋបាល[2282]។

### ៨.៣.៤. វិធីសាស្ត្រសម្រាប់ដោះស្រាយអំពើដែលអាចរងទណ្ឌកម្មវិន័យជាសក្តានុពល

ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមានមូលហេតុជឿថា បុគ្គលណាម្នាក់អាចបានប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើទាំងឡាយ ដែលមានចែងក្នុងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ពួកគេអាច៖ (១) ដោះស្រាយបញ្ហានោះជាបន្ទាន់ (២) ធ្វើការស៊ើបអង្កេតបន្ថែមដើម្បីបញ្ជាក់ថាតើមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីចាត់ការតាមនីតិវិធី ឬ (៣) បញ្ជូនបញ្ហានោះទៅឱ្យអាជ្ញាធរកម្ពុជា ឬអង្គការសហប្រជាជាតិ[2283]។ វិធានការផ្អែកតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺជាអំណាចតាមឆន្ទានុសិទ្ធិ[2284]។

នីតិវិធីសង្ខេបផ្អែកតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង សមស្របជាពិសេសចំពោះអំពើទាំងឡាយដែល "ដឹងជាសាធារណៈ ដោយសារតែចរិតលក្ខណៈនៃអំពើទាំងនោះ អំពើដែលត្រូវបានថតនៅក្នុងវីដេអូរបស់តុលាការ"។ នៅពេលដែលវាជាបញ្ហាទាក់ទងនឹងការជ្រៀតជ្រែកលក្ខណៈព្រហ្មទណ្ឌ វិធានការដែលសមស្របបំផុតនោះគឺការបញ្ជូនទៅឱ្យអាជ្ញាធរកម្ពុជា។ ដោយយោងទៅលើពេលវេលា និងធនធានមានកម្រិត អ.វ.ត.ក. "មិនទំនងជាធ្វើការកំណត់ការទទួលខុសត្រូវ និងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌនោះទេ"[2285]
។

### ៨.៣.៥. បទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់ការស៊ើបអង្កេត និងការដាក់ទណ្ឌកម្ម

---

[2279] វិធានផ្ទៃក្នុង វិធាន ៣៥(១)។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៧។

[2280] សំណុំរឿង ០០២ សាលដីកាលើកទីពីរ លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ D314/1/12 កថាខណ្ឌ ៣៥។

[2281] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឯកសារ E176/2 កថាខណ្ឌ ២២។

[2282] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៨។

[2283] វិធានផ្ទៃក្នុង វិធាន ៣៥(២)។

[2284] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៩។

[2285] ដូចខាងលើ កថាខណ្ឌ ៣៩ និង ៤១។

យោងតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ចៅក្រមត្រូវមាន "ហេតុផលជឿ" ថាអំពើដែលអាចដាក់ទណ្ឌកម្មបាននោះបានកើតឡើង មុនពេលបន្តចាត់ការតាមនីតិវិធីទៅរកវិធានការណាមួយក្នុងចំណោមវិធានការនានាដែលរៀបរាប់ក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង (ការសម្រេចជាបន្ទាន់ ការបញ្ជូន ឬការស៊ើបសួរបន្ថែម)។ មធ្យោបាយ "ស៊ើបសួរបន្ថែម" តម្រូវឱ្យមាន "មូលដ្ឋានគ្រប់គ្រាន់" សម្រាប់ចាត់ការតាមនីតិវិធី[2286]។ បទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់ការស៊ើបសួរ និងការដាក់ទណ្ឌកម្ម មិនត្រូវបានកំណត់ផ្សេងពីនេះនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុងទេ ហើយត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[2287]។

វិធាន ៣៥(២) នៃវិធានផ្ទៃក្នុងផ្តល់នូវវិធានការបីយ៉ាង នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមាន*ហេតុផលជឿ* ថា បុគ្គលណាម្នាក់អាចបានប្រព្រឹត្តអំពើណាមួយ ដូចបានរៀបរាប់ក្នុងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះចាត់ទុកថា នេះគឺជា "បទដ្ឋានដែលមានលក្ខណៈស្រាលបំផុត ហើយនឹងអាចនាំឱ្យមានការស៊ើបសួរពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ"។ ពុំមានលក្ខខណ្ឌតម្រូវឱ្យមានសេចក្តីសម្រេចណាមួយទៅលើអង្គសេចក្តីនៃការចោទប្រកាន់ ឬភាពសង្ស័យនៃការជ្រៀតជ្រែកនោះទេ ប៉ុន្តែសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវតែមានមូលដ្ឋានជាក់លាក់ ឬមូលហេតុដែលជាមូលដ្ឋាននៃជំនឿរបស់ខ្លួន (ដែលការណ៍នេះអាចមានលក្ខណៈជាអត្តនោម័ត)[2288]។

ទាក់ទងនឹងមធ្យោបាយផ្នែកនីតិវិធីដែលអាចរកបាន បន្ទាប់ពីការសង្ស័យត្រូវបានបង្ហាញ មានតែមធ្យោបាយមួយប៉ុណ្ណោះក្នុងចំណោមមធ្យោបាយនានា បានលើកឡើងអំពីបទដ្ឋាននៃភស្តុតាង ពោលគឺការធ្វើការស៊ើបសួរបន្ថែមដើម្បីបញ្ជាក់ថាតើមាន*មូលដ្ឋានគ្រប់គ្រាន់*សម្រាប់ចាត់ការតាមនីតិវិធីឬយ៉ាងណា[2289]។ ស្របគ្នាទៅនឹងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY អង្គបុរេជំនុំជម្រះបានពិចារណាថាការណ៍នេះតម្រូវឱ្យមានការពិចារណាថាតើ ភស្តុតាងបង្ហាញជា *បឋម* ថាមានករណីជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការដែរឬទេ ហើយមិនមែនជាការសម្រេចចុងក្រោយលើបញ្ហាថាតើ អំពើដែលរងការចោទប្រកាន់នោះពិតជាបានកើតឡើងឬយ៉ាងណានោះទេ[2290]។

បញ្ហាដែលកាន់តែចម្រូងចម្រាសទៀតនោះ គឺបទដ្ឋានដែលត្រូវអនុវត្តនៅពេលដែលដោះស្រាយជាមួយនឹងបញ្ហាណាមួយជាបន្ទាន់ ពោលគឺ នៅពេលដែល អ.វ.ត.ក. ជ្រើសរើសដាក់ទណ្ឌកម្មដោយខ្លួនឯង។ អង្គបុរេជំនុំជម្រះបានពិចារណាថា បទដ្ឋាននៃភស្តុតាង*ឱ្យហួសពីវិមតិសង្ស័យ* ត្រូវតែបំពេញ មុនពេលទណ្ឌកម្មអាចត្រូវបានដាក់ទៅលើបុគ្គលណាម្នាក់ចំពោះការរំលោភបំពានលើវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ដោយសារតែនេះគឺជា "បទដ្ឋានដែលត្រូវបានទទួលយកជាសកល ជាបទដ្ឋាននៃការបង្ហាញភស្តុតាងនៅក្នុងរឿងព្រហ្មទណ្ឌ"[2291]។

---

2286 វិធានផ្ទៃក្នុង វិធាន ៣៥(២)(ខ)។

2287 សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4។ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឯកសារ E176/2។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E116/1/7។ សំណុំរឿង ០០២ ការជូនដំណឹងរបស់មេធាវីការពារក្តី ពីភាសាសម្រាប់ដាក់ និងទទួលឯកសារ និង ការស្នើសុំពន្យាពេលដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះហៅសាក្សី ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ D314/1/12។

2288 សំណុំរឿង ០០២ ការជូនដំណឹងរបស់មេធាវីការពារក្តី ពីភាសាសម្រាប់ដាក់ និងទទួលឯកសារ និង ការស្នើសុំពន្យាពេលដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់ នួន ជា និង អៀង សារី ស្នើសុំកោះហៅសាក្សី ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ D314/1/12 កថាខណ្ឌ ៣៦-៣៧។

2289 ដូចខាងលើ កថាខណ្ឌ ៣៦ និង ៣៨។

2290 ដូចខាងលើ កថាខណ្ឌ ៣៨។ អង្គបុរេជំនុំជម្រះបកស្រាយបទដ្ឋាននេះថាអាចអនុវត្តបានចំពោះវិធីសាស្ត្រទាំងបី ក្រោមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។

2291 ដូចខាងលើ កថាខណ្ឌ ៣៦ និង ៣៩។

ដូចដែលបានគូសបញ្ជាក់ពីមុនដែល អង្គជំនុំជម្រះតុលាការកំពូលបានបំភ្លឺថា អំពើរួមបញ្ចូលទាំងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសរដ្ឋបាល អង្គជំនុំជម្រះបានបង្ហាញថា ការសម្រេចលើការទទួលខុសត្រូវត្រូវតែ "អនុវត្តតាមលក្ខខណ្ឌមូលដ្ឋាននៃភាពយុត្តិធម៌"[2292]។ ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌវិញ ការណ៍នេះតម្រូវឱ្យមានបទដ្ឋាននៃភស្តុតាងខ្ពស់ជាង "ហេតុផលជឿ"[2293]។ បន្ទុកនៃភស្តុតាងសម្រាប់បទល្មើសដែលមិនមែនជាបទព្រហ្មទណ្ឌប្រែប្រួលពី "តុល្យភាពនៃភវនីយភាព" ទៅ "ហួសពីវិមតិសង្ស័យ" ផ្អែកតាមវិធានការ ឬទណ្ឌកម្មដែលមាន[2294]។

ក្នុងការឈានដល់សេចក្តីសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូលបានងាកចេញពីអង្គជំនុំជម្រះសាលាដំបូង។ ក្នុងការពិចារណាលើការចោទប្រកាន់អំពីសេចក្តីថ្លែងការណ៍ជាសាធារណៈលើពិរុទ្ធភាពរបស់ នួន ជា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ទោះបីជាភស្តុតាង "ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យមានកិច្ចស៊ើបសួរផ្នែកព្រហ្មទណ្ឌ ហើយវាគ្រាន់តែជាសំណើមួយដែលផ្អែកលើការស្មានៗប៉ុណ្ណោះ" ក៏សេចក្តីថ្លែងការណ៍នោះ "បំពេញបទដ្ឋានអប្បបរមាសម្រាប់ការអន្តរាគមន៍" ទាក់ទងនឹងរឿងក្តីដែលមិនមែនជាបទព្រហ្មទណ្ឌ ហើយបានបន្តកំណត់អត្តសញ្ញាណអំពើដែលអាចដាក់ទណ្ឌកម្មបាន[2295]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាឃើញថា ទម្ងន់នៃភស្តុតាងពុំគួរត្រូវបានពិចារណាថាជាផ្នែកមួយនៃការវាយតម្លៃថាតើ បទល្មើសគប្បីត្រូវបញ្ជូនឬយ៉ាងណានោះទេ៖ ការដោះស្រាយជាមួយបញ្ហាណាមួយដោយប្រើនីតិវិធីសង្ខេប គឺជាវិធីសាមញ្ញសម្រាប់ធ្វើការសម្រេច និង "មិនអនុញ្ញាតឱ្យសម្រេចដោយសេរី ដោយផ្អែកតាមភស្តុតាងកម្រិតទាបនោះទេ"[2296]។

### ៨.៣.៦. ទណ្ឌកម្មដែលអាចអនុវត្តបាន

វិធាន ៣៥(៤) នៃវិធានផ្ទៃក្នុងចែងថា ច្បាប់កម្ពុជាអនុវត្តចំពោះ "ការដាក់ទណ្ឌកម្ម" ទាក់ទងនឹងអំពើណាមួយដែលមានចែងក្នុងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ប៉ុន្តែក្រៅពីនេះមិនបានកំណត់និយមន័យទណ្ឌកម្មដែលមាននោះទេ។

អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ខ្លួនត្រូវបានអនុញ្ញាតឱ្យដាក់ការឆ្លើយតបណាមួយចាំបាច់ដើម្បីធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ថាតើមានឬមិនមានលក្ខណៈជាទណ្ឌកម្មបន្ថែម ឬយ៉ាងណា បន្ថែមលើទណ្ឌកម្មព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់កម្ពុជា នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង[2297]។ ទណ្ឌកម្មដែលអាចអនុវត្តបានរួមបញ្ចូល "ការព្រមាន" "ការជូនដំណឹងដល់អង្គភាពដាក់

---

[2292] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៤២។

[2293] ដូចខាងលើ កថាខណ្ឌ ៣៩។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើកទីពីរ លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី D314/1/12 កថាខណ្ឌ ៣៦។

[2294] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣៩។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E116/1/7 កថាខណ្ឌ ៣៦ (ដែលអង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការដាក់បង្ហាញឯកសារដែលបានធ្វើចំណាត់ថ្នាក់រួចហើយ "ប្រសិនបើត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ" គឺជាបទល្មើសមួយប្រភេទ ដែលអាចបណ្តាលឱ្យមានការដាក់ទណ្ឌកម្មស្របតាមច្បាប់កម្ពុជា និង/ឬ ក៏ជាកំហុសវិជ្ជាជីវៈរបស់មេធាវី)។

[2295] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ឯកសារ E176/2 កថាខណ្ឌ ៣០។

[2296] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៤១។

[2297] ដូចខាងលើ កថាខណ្ឌ ៤៤-៤៥។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៣។

វិន័យ” “ការបោះពុម្ពផ្សាយលទ្ធផលនៃដំណើរការនីតិវិធីនៅក្នុងសារព័ត៌មាន” និង “ការផាកពិន័យរដ្ឋបាលដោយមានកម្រិត”[2298]។ រាល់ទណ្ឌកម្មទាំងអស់ត្រូវអនុវត្តស្របតាមគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ[2299]។

## ៨.៤. ភារកិច្ចផ្នែកសីលធម៌ និង ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈរបស់មេធាវី

មេធាវីការពារក្ដី និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានកាតព្វកិច្ចផ្នែកសីលធម៌ និងការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ ដែលមានចែងក្នុងវិធានផ្ទៃក្នុង[2300] និងនៅក្នុងក្រមសីលធម៌របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[2301]។

មេធាវីការពារក្ដី និង សហមេធាវីតំណាងជនរងគ្រោះត្រូវចុះបញ្ជីជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[2302]។ ពួកគេមានកាតព្វកិច្ចគោរពតាមយន្តការរបស់ អ.វ.ត.ក. ច្បាប់ស្ដីពីលក្ខន្តិកៈរបស់គណៈមេធាវី និង “បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈដែលបានទទួលស្គាល់”[2303]។ មេធាវីត្រូវមានសមត្ថភាពខាងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីនៅកម្រិតជាតិ និងអន្តរជាតិ ហើយក្រៅពីនេះតម្រូវឱ្យមានបទពិសោធន៍ច្រើនឆ្នាំសម្រាប់មេធាវីអន្តរជាតិ[2304] និងមានកាតព្វកិច្ចលើកកម្ពស់យុត្តិធម៌ ៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធភាព[2305]។

មេធាវីត្រូវគោរព “គោលការណ៍សុចរិតភាព និងភាពស្មោះត្រង់”[2306] និងត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យអស់ពីសមត្ថភាពដើម្បីការពារផលប្រយោជន៍របស់កូនក្ដីខ្លួន[2307]។ កាតព្វកិច្ចផ្សេងទៀតរួមបញ្ចូលការរក្សាការសម្ងាត់[2308] និង “ការប្រុងប្រយ័ត្ន” ក្នុងសកម្មភាពសាធារណៈ ឬសារព័ត៌មាន[2309]។ មេធាវី

---

[2298] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៤៤។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៣។ ខុសពីទណ្ឌកម្មដែលបានចេញតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ទណ្ឌកម្មដែលដាក់តាមវិធាន៣៥ នៃវិធានផ្ទៃក្នុង មិនតម្រូវឱ្យមានការព្រមានជាមុននោះទេ។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការព្រមាន ដោយអនុលោមតាមវិធាន ៣៨ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D367/1/5 កថាខណ្ឌ ១១។

[2299] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៤៤។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៣។

[2300] វិធានផ្ទៃក្នុង វិធាន ១១(២) វិធាន១១(៤) វិធាន ១២ ស្ទួន (១) វិធាន ១២ ស្ទួន (២) វិធាន ២២(១) និង ២២(៤)។

[2301] ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (“ក្រមសីលធម៌មេធាវី”)។

[2302] វិធានផ្ទៃក្នុង វិធាន ១១(២)(ខ)-(គ) វិធាន ១២ ស្ទួន (១)(គ) និង ២២(១)។ សូមមើលផងដែរ ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីគណៈមេធាវី អនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ (“ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី”) មាត្រា ៦, ៨។ BAKC ក៏បានអនុម័តគោលការណ៍នានាស្ដីពីឯករាជ្យភាពផងដែរ សូមមើល ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី មាត្រា ១៣ (“គណៈមេធាវីមិនស្ថិតនៅក្រោមគណៈបក្សនយោបាយណាមួយ ឬអង្គការសាសនាណាមួយ ឬអង្គការនានាផ្សេងទៀតឡើយ។ ការសម្ដែងមនោគមវិជ្ជា សាសនា ឬនយោបាយ ត្រូវហាមឃាត់”)។

[2303] វិធានផ្ទៃក្នុង វិធាន ២២(៤)។ សូមមើលផងដែរ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី មាត្រា ១។

[2304] វិធានផ្ទៃក្នុង វិធាន ១១(៤)(គ)-(ឃ)។ មេធាវីការពារក្ដីអន្តរជាតិ ត្រូវមានបទពិសោធន៍ការងារពាក់ព័ន្ធ ១០ ឆ្នាំ ចំណែកសហមេធាវីអន្តរជាតិមិនពេលវេលាកំណត់ជាក់លាក់នោះទេ។

[2305] វិធានផ្ទៃក្នុង វិធាន ១២ ស្ទួន(២) និង ២២(៤)។

[2306] ក្រមសីលធម៌មេធាវី មាត្រា ៦ (សូមមើលផងដែរ មាត្រា ១៦)។ មាត្រា ៣៤ នៃ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ចែងអំពីសម្បថដែលមេធាវីត្រូវតែធ្វើនៅចំពោះមុខ “សាលាឧទ្ធរណ៍” ដែលមានសេចក្ដីថា៖ “ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំដោយសេចក្ដីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្ដីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា”។ មាត្រា ៥៨ នៃ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ចែងថា “មេធាវីកំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួនត្រូវលើកឡើងដើម្បីការពារ ផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក”។

[2307] សូមមើល សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E320/2 កថាខណ្ឌ ១៨ (យោង វិធានផ្ទៃក្នុង វិធានផ្ទៃក្នុង ២២)។

[2308] ក្រមសីលធម៌មេធាវី មាត្រា ៧។

[2309] ក្រមសីលធម៌មេធាវី មាត្រា ១៥។ សូមមើលផងដែរ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី មាត្រា ៧។

ការពារក្តីមានភារកិច្ចចំពោះតុលាការ ក៏ដូចជាចំពោះកូនក្តីរបស់ខ្លួនផងដែរ[2310] ដោយមាន "កាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវ"[2311]។ មេធាវីការពារក្តីមិនជាប់កាតព្វកិច្ចអនុវត្តតាមការណែនាំរបស់កូនក្តីខ្លួនទេ នៅពេលដែលការណែនាំទាំងនេះនាំឱ្យមានការបំផ្លាញកិច្ចដំណើរការនីតិវិធី ឬផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌[2312]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ក្របខ័ណ្ឌច្បាប់ជាធរមានបានបញ្ជាក់ "ច្បាស់លាស់ថា មេធាវី បើទោះបីជាធ្វើតាមសម្បជញ្ញៈ និងការណែនាំរបស់កូនក្តីក៏ដោយ ក៏ត្រូវតែគោរពច្បាប់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត រួមទាំងការបង្គាប់របស់តុលាការផងដែរ"[2313]។ មេធាវីការពារក្តីដែលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក. ក៏ត្រូវបានតម្រូវដោយច្បាប់កម្ពុជាឱ្យ "សំដែងជូនចៅក្រមក្នុងភាពឯករាជ្យ និងភាពថ្លៃថ្នូរ នូវការគោរពទៅតាមមុខងារ"ផងដែរ[2314]។

### ៨.៤.១. កំហុសវិជ្ជាជីវៈរបស់មេធាវី

វិធាន ៣៨ នៃវិធានផ្ទៃក្នុងចែងអំពីកំហុសវិជ្ជាជីវៈរបស់មេធាវី[2315]។ វិធាននេះចែងអំពីអំពើដែល "ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬ ផ្ទុយទៅនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង"[2316]។ អំពើនេះមិនត្រូវបានកំណត់និយមន័យផ្សេងពីនេះ និងត្រូវបានបញ្ជាក់តាមរយៈករណីយុត្តិសាស្ត្រ។ រាល់ទណ្ឌកម្មទាំងអស់ត្រូវបានដាក់ទៅលើមេធាវីការពារក្តី[2317]។ ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវីដែលត្រូវបានអនុម័តឱ្យការពារក្តីនៅចំពោះមុខ អ.វ.ត.ក. ដោយសារតែវិធានការវិន័យនោះ មេធាវីរូបនោះត្រូវប្រគល់រាល់សម្ភារៈទាំងអស់ទៅកាន់អង្គភាពពាក់ព័ន្ធនៃការិយាល័យរដ្ឋបាល ដើម្បីធានានិរន្តរភាពក្នុងការការពារក្តី[2318]។

វិធាន ៣៨ នៃវិធានផ្ទៃក្នុងផ្តល់ជា "ដំណោះស្រាយងាយស្រួលជាង និងមានទម្រង់បែបបទនៃនីតិវិធីខ្លីជាងវិធាន ៣៥ នៃវិធានផ្ទៃក្នុង"[2319]។ វិធាន ៣៨ នៃវិធានផ្ទៃក្នុង ដែលមានគោលបំណង "ធានាបានថាដំណើរការនីតិវិធីមិនត្រូវបានរាំងស្ទះដោយ [...] ការប្រព្រឹត្តណាមួយដែល [...] នាំឱ្យមានគ្រោះថ្នាក់ដល់

---

[2310] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៦។

[2311] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E320/2 កថាខណ្ឌ ១៨ (ដកស្រង់ វិធានផ្ទៃក្នុង វិធាន ២២(៤))។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E330 កថាខណ្ឌ ២៨។

[2312] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E320/2 កថាខណ្ឌ ១៨។

[2313] ក្នុងសំណុំរឿង ០០២ មេធាវីការពារក្តីជាតិរបស់ នួន ជា បានតវ៉ាថា ក្នុងការពន្យល់អំពីការចាកចេញពីបន្ទប់សវនាការរបស់ខ្លួននៅថ្ងៃដំបូងនៃសវនាការលើបណ្តឹងសាទុក្ខ ថាមាត្រា ៥៨ នៃច្បាប់ស្តីពីគណៈមេធាវីកម្ពុជា ចែងថា មេធាវីត្រូវជាប់កាតព្វកិច្ចតាមសម្បជញ្ញៈ និងការណែនាំរបស់កូនក្តី ក្នុងសម្រេចចិត្តលើយុទ្ធសាស្ត្រការពារក្តី។ សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៥។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ៨។

[2314] សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ៨។ សូមមើលផងដែរ ក្រមសីលធម៌មេធាវី មាត្រា ២៤។

[2315] វិធានផ្ទៃក្នុង វិធាន ៣៨។

[2316] វិធានផ្ទៃក្នុង វិធាន ៣៨។

[2317] ក្នុងសំណុំរឿងមួយ មេធាវីការពារក្តីតវ៉ាថា តំណាងអយ្យការគប្បីត្រូវរងទណ្ឌកម្មចំពោះការខកខានក្នុងការបង្ហាញសម្ភារៈដោះបន្ទុក។ ការលើកឡើងនេះត្រូវបានបដិសេធផ្អែកលើមូលដ្ឋានថា មិនមានផលប៉ះពាល់ដល់ភាគីការពារក្តី។ សូមមើល សំណុំរឿង ០០២ ដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តី អៀង សារី ស្តីពីការដាក់ទណ្ឌកម្មចំពោះសហព្រះរាជអាជ្ញា ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D97/9/7 កថាខណ្ឌ ៩ និង ១៣។

[2318] វិធានផ្ទៃក្នុង វិធាន ៣៨(៤)។

[2319] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។

កិច្ចការរដ្ឋបាលរបស់តុលាការ”[2320] ត្រូវគ្នាមួយចំនួនជាមួយនឹងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ហើយយន្តការនៃកំហុសវិជ្ជាជីវៈអាចអនុវត្តស្របគ្នាជាមួយនឹង ឬដាច់ដោយឡែកពី វិធាន ៣៥ នៃវិធានផ្ទៃក្នុង[2321]។ ទោះជាយ៉ាងណា វិធាន ៣៨ នៃវិធានផ្ទៃក្នុងត្រូវបាន "តាក់តែងឡើងដើម្បីដោះស្រាយកំហុសវិជ្ជាជីវៈរបស់មេធាវីដោយពុំគិតថាតើ កំហុសនេះមានគុណវុឌ្ឍិជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ដែរ ឬយ៉ាងណានោះឡើយ [យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង]"[2322]។ ក្នុងករណីមួយ អង្គជំនុំជម្រះតុលាការកំពូលទោះបីជាយល់ឃើញថា មានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចប្រើទណ្ឌកម្មចែងក្នុងវិធាន ៣៨ នៃវិធានផ្ទៃក្នុងវិញ ដោយសារវិធាន ៣៥ នៃវិធានផ្ទៃក្នុង "នឹងធ្វើឱ្យចំណាយពេលវេលា និងធនធានបន្ថែមទៀត"[2323]។

អាកប្បកិរិយាវាយប្រហារ មិនមានការគោរព ឬអាកប្បកិរិយាដទៃទៀតក្នុងតុលាការដែលប្រាសចាកពីក្រមសីលធម៌ គឺជាការរំលោភលើវិជ្ជាជីវៈដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវ[2324]។ ឧទាហរណ៍នានារួមបញ្ចូលទាំងការបន្តសួរសំណួរដែលមិនពាក់ព័ន្ធ និងមិនសមរម្យចំពោះសាក្សី ដោយមិនអើពើទៅនឹងការបង្គាប់ និងការព្រមានជាច្រើនដង[2325] ខកខានមិនបានបង្ហាញខ្លួនពេលសវនាការ បណ្តាលឱ្យមានការពន្យារពេលកិច្ចដំណើរការនីតិវិធី និងខ្ជះខ្ជាយធនធាន[2326] ការបដិសេធមិនបន្តចូលរួមក្នុងសវនាការ[2327] ការខក

[2320] សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22 កថាខណ្ឌ ២៥។ អង្គបុរេជំនុំជម្រះបានពិចារណាលើការបកស្រាយរបស់តុលាការ ICTY លើវិធានស្រដៀងគ្នាទៅនឹងវិធាន ៣៨ នៃវិធានផ្ទៃក្នុង ដោយឯកភាពថា វិធាននេះ "មានន័យទាក់ទងទៅនឹងបញ្ហាចរិយាមាយាទនៅក្នុងសាលសវនាការ ឬក៏ឥរិយាបថផ្សេងទៀតនៅក្នុងការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធី ដែលធ្វើឱ្យវិធាននេះមានលក្ខណៈចាំបាច់ក្នុងការធានាថា មេធាវីមិនមានវេទិកានៅក្នុងសវនាការ ដើម្បីបន្តនូវការប្រព្រឹត្តិដែលមានលក្ខណៈរាំងស្ទះរបស់គាត់នោះឡើយ"។ អង្គបុរេជំនុំជម្រះក៏បានពិចារណាផងដែរលើករណីយុត្តិសាស្ត្ររបស់តុលាការ ICTY និង SCSL រួមបញ្ចូលទាំងករណីយុត្តិសាស្ត្រដែលលើកឡើងថា ការរំខានដល់ការជំនុំជម្រះអាចនាំឱ្យមានហានិភ័យដល់ភាពអយុត្តិធម៌ និងថា វាគឺជាភារកិច្ចរបស់អង្គជំនុំជម្រះក្នុងការធានាថា កិច្ចដំណើរការនិតិវិធីត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ ស្របតាមនីយាមនៃដំណើរការតុលាការ។ សូមមើល សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22 កថាខណ្ឌ ២០-២៤។

[2321] សំណុំរឿង ០០២ ដិកាសម្រេចស្តីពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩ ឯកសារ D138 កថាខណ្ឌ ២០។

[2322] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។ សូមមើលផងដែរ សំណុំរឿង ០០១ ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E330 កថាខណ្ឌ ១៤។

[2323] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៩-៣៣។

[2324] សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ៦។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២០។

[2325] សំណុំរឿង ០០២ ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E1/153.1 ទំព័រ ៤៩ ទំព័រ ៥៦ និង ៦០-៦៥។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២០។

[2326] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២០។ សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22 កថាខណ្ឌ ៣១។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E321/2 កថាខណ្ឌ ១២ (ទាក់ទងនឹងមេធាវីដែលត្រូវបានតែងតាំងដោយតុលាការ)។

[2327] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២០។

ខានមិនបានចូលរួមប្រកបដោយអត្ថន័យក្នុងសវនាការ[2328] និង "ការជម្រុញយ៉ាងសកម្មដល់ជនជាប់ចោទដែលខ្លួនតំណាងឱ្យ បង្កឱ្យអង្គជំនុំជម្រះមានការភ័ន្តច្រឡំ"[2329]។

ឥរិយាបថមិនគោរពចំពោះចៅក្រម ទោះជានៅក្នុងបន្ទប់សវនាការ ឬខាងក្រៅ គឺជាអំពើដែលអាចរងទណ្ឌកម្ម។ អង្គបុរេជំនុំជម្រះបានពិចារណាថា "នៅពេលដែលសមាសភាព និងមុខងាររបស់តុលាការអាចរងនូវការរិះគន់នោះ [...] អំពើវាយប្រហារដោយសារតែបញ្ហាផ្ទាល់ខ្លួន ដែលធ្វើឡើងប្រឆាំងនឹងចៅក្រម ដែលបានបង្កើតនូវបរិយាកាសដែលខូចប្រយោជន៍ដល់កិច្ចការរដ្ឋបាលរបស់តុលាការដ៏មានសណ្តាប់ធ្នាប់នោះ អាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្ម"[2330]។ នៅក្នុងករណីនោះ ការចោទប្រកាន់ដែលមិនមានការគាំទ្រ និងពាក្យពេចន៍ដែលសហមេធាវីបានប្រើ ត្រូវបានរកឃើញថា "ជាការប្រមាថមើលងាយចំពោះចៅក្រមនៃអង្គបុរេជំនុំជម្រះ"[2331] ការប្រើពាក្យពេចន៍វាយប្រហារ ឬមិនមានការគោរព នៅក្នុងសំណើនានាជាលាយលក្ខណ៍អក្សរ ក៏ត្រូវបានសន្និដ្ឋានថាជាកំហុសវិជ្ជាជីវៈផងដែរ[2332]។

នៅក្នុងការពិចារណាលើការខកខានរបស់សហមេធាវីក្នុងការចូលរួមវគ្គសវនាការបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា គាត់បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[2333]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ខ្លួនមិនប្រើវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ "គោលបំណងដើម្បីទទួលបាននូវប្រសិទ្ធភាព"[2334]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្របក្នុងការយោងទៅលើទណ្ឌកម្មតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង គឺការស្តីបន្ទោសផ្លូវការជាសាធារណៈ[2335]។

---

[2328] សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22 កថាខណ្ឌ ៣១។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២០។

[2329] សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ១៣។

[2330] សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22 កថាខណ្ឌ ២១និង ២៥។

[2331] ដូចខាងលើ កថាខណ្ឌ៣០។

[2332] សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ១២។ ឧទាហរណ៍ដែលបានយោង សំដៅលើការណែនាំថា អង្គជំនុំជម្រះ "ពុំមានសំអាងហេតុ" "ពុំមានហេតុផលត្រឹមត្រូវ" និង "មានកំហុស"។

[2333] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ៣១។

[2334] ដូចខាងលើ កថាខណ្ឌ ៣២។

[2335] ដូចខាងលើ កថាខណ្ឌ ៣៣។

ការបង្ហាញអំពីកំហុសវិជ្ជាជីវៈផ្សេងទៀតរួមមាន ការផ្សព្វផ្សាយឯកសារសម្ងាត់ដោយមេធាវី[2336] និងការខកខានក្នុងការអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះ ក្នុងការដាក់ឯកសារក្នុងពេលវេលាដែលបានកំណត់[2337]។

### ៨.៤.២. ការព្រមាន ទណ្ឌកម្ម និង ការបញ្ជូន

យោងតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ បន្ទាប់ពីការព្រមាន អាចដាក់ទណ្ឌកម្មប្រឆាំងនឹង ឬបដិសេធមិនឱ្យមេធាវីចូលរួមសវនាការ ប្រសិនបើខ្លួនយល់ឃើញថា ទង្វើរបស់មេធាវីរូបនោះត្រូវបានចាត់ទុកថាជាការប្រមាថមើលងាយ[2338]។ ចំនួនពិតប្រាកដនៃទណ្ឌកម្មមិនត្រូវបានកំណត់និយមន័យ នៅក្នុងវិធាន ៣៨(១) នៃវិធានផ្ទៃក្នុងទេ[2339] ហើយត្រូវបានបង្កើតតាមរយៈករណីយុត្តិសាស្ត្រ។

ទោះបីជាការព្រមាន ឬទណ្ឌកម្មជាវិបាក គឺជាអំណាចតាមឆន្ទានុសិទ្ធិយោងតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុងយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ខ្លួនមាន "ភារកិច្ចការពារភាពថ្លៃថ្នូរដំណើរការនីតិវិធី" ក្នុងការឈានមកដល់ដំណាក់កាលនេះ[2340]។

ការព្រមាន "ជាញឹកញាប់ ដែលជាវិធានការទប់ស្កាត់ផង និងដាក់ទោសផងសម្រាប់កំហុសវិជ្ជាជីវៈ" មានដូចជាការបញ្ចេញព័ត៌មានសម្ងាត់ ការបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ការខកខានក្នុងការបង្ហាញខ្លួន និងការប្រើប្រាស់អាកប្បកិរិយាប្រមាថមើលងាយនៅក្នុងបន្ទប់សវនាការ[2341]។ ទណ្ឌកម្មទូទៅគឺជាការស្តីបន្ទោសជាលក្ខណៈឯកជន ឬជាសាធារណៈ ដែលត្រូវបានអង្គជំនុំជម្រះតុលាការកំពូល

---

[2336] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ៣១។ សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយលបាននៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D138/1/8។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២០។ សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ៧។ សំណុំរឿង ០០២ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E115/3 កថាខណ្ឌ ៣៩ ជើងទំព័រ ៩៣។ អង្គជំនុំជម្រះកត់សម្គាល់ថា អ្នកពិគ្រោះយោបល់វេជ្ជសាស្ត្រពីខាងក្រៅ ត្រូវបានផ្តល់ឱ្យនូវឯកសារសម្ងាត់ និងសម្ងាត់បំផុតមួយចំនួន ដោយរំលោភលើមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការធ្វើចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង។

[2337] សំណុំរឿង ០០២ សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 កថាខណ្ឌ ១៥។

[2338] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។

[2339] ដូចខាងលើ។

[2340] សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22 កថាខណ្ឌ ២៥។

[2341] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E116/1/7 កថាខណ្ឌ ៣៧។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E115/3 កថាខណ្ឌ ៣៩ ជើងទំព័រ ៩៣។ សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩ ឯកសារ D138។ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំពន្យាពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ឯកសារ C26/I/25។ សំណុំរឿង ០០២ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ឯកសារ E320 កថាខណ្ឌ ៦ និង ៨។ សំណុំរឿង ០០២ ការព្រមានចំពោះសហមេធាវីអន្តរជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C26/5/22។

ពិចារណាថាជា "ទម្រង់សមគួរមួយស្ដីពីវិន័យមេធាវី" ដែល "ប្រកាសអំពីការប្រព្រឹត្តិរបស់មេធាវីថាពុំត្រឹមត្រូវ ប៉ុន្តែពុំបានកម្រិតលើសិទ្ធិរបស់មេធាវីក្នុងការអនុវត្តច្បាប់ឡើយ"[2342]។ ទណ្ឌកម្មផ្សេងទៀតរួមបញ្ចូលការបញ្ជូនការប្រព្រឹត្តិរបស់មេធាវីទៅគណៈមេធាវីថ្នាក់ជាតិ[2343] ការណែនាំឱ្យបដិសេធការផ្ដល់ប្រាក់កម្រៃ[2344] ការបណ្ដេញចេញពីបន្ទប់សវនាការ[2345] ឬត្រូវបានបង្គាប់ឱ្យបញ្ឈប់អាកប្បកិរិយាពាក់ព័ន្ធនោះ[2346]។ ទណ្ឌកម្មជាសក្តានុពលផ្សេងទៀតរួមមាន "ការបដិសេធយូរអង្វែង ឬជាអចិន្ត្រៃយ៍នូវសិទ្ធិរបស់មេធាវីក្នុងការចូលរួមសវនាការ ឬទណ្ឌកម្មជាប្រាក់កាស"[2347]។

យោងតាមវិធាន ៣៨(៣) នៃវិធានផ្ទៃក្នុង មេធាវីបរទេសដែលបំពេញវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក. ដែលស្ថិតក្រោមវិធានការវិន័យដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចប្ដឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ ក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីពេលទទួលបានការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[2348]។ បណ្ដឹងឧទ្ធរណ៍នេះព្យួរការអនុវត្តសេចក្ដីសម្រេច លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចផ្សេង។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្ដឹងតវ៉ា[2349]។ វិធាន ៣៨ នៃវិធានផ្ទៃក្នុងមិនមានចែងអំពីសិទ្ធិណាផ្សេងទៀតដើម្បីប្ដឹងឧទ្ធរណ៍ឡើយ។ នៅក្នុងការសម្រេចរបស់ខ្លួនថា ការព្រមានអាចត្រូវបានជំទាស់តវ៉ា តែក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការដាក់ទណ្ឌកម្មនៅពេលបន្ទាប់មកទៀតអនុលោមតាមវិធាន ៣៨ ប៉ុណ្ណោះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា សិទ្ធិប្ដឹងឧទ្ធរណ៍ជាសារវន្តពិតជាមានអត្ថិភាព[2350]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញថា ផ្ទុយទៅនឹងវិធាន ៣៨ នៃវិធានផ្ទៃក្នុង វិធាន ៣៥ ពុំផ្ដល់ "សិទ្ធិប្ដឹងឧទ្ធរណ៍" ឡើយ[2351]។

### ៨.៤.៣. ការតែងតាំងមេធាវីជំនួស

ផ្អែកលើការអនុវត្តរបស់សាលាក្ដីព្រហ្មទណ្ឌអន្តរជាតិ អ.វ.ត.ក. បានបង្ហាញថា នៅពេលដែលជម្រើសរបស់ជនជាប់ចោទស្ដីពីការទទួលបានមេធាវីការពារក្ដី បានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីនោះ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការតែងតាំងមេធាវីដើម្បីជួយជ្រោមជ្រែងជនជាប់ចោទ[2352]។ ការណ៍នេះចាំបាច់ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីអាចដំណើរការទៅមុខ "ប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស"[2353]។

[2342] សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។

[2343] សំណុំរឿង ០០២ សេចក្ដីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្ដី នួន ជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E214 ទំព័រ ៨។ សូមមើលផងដែរ សំណុំរឿង ០០១ ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្ដី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E330 កថាខណ្ឌ ៣១។

[2344] សំណុំរឿង ០០១ ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្ដី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E330 កថាខណ្ឌ ៣០។

[2345] សូមមើល សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។

[2346] សំណុំរឿង ០០២ ដីកាសម្រេចស្ដីពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩ ឯកសារ D138 ទំព័រ ១០។

[2347] សូមមើល សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៦ F30/18 កថាខណ្ឌ ២៤។

[2348] វិធានផ្ទៃក្នុង វិធាន ៣៨(៣)។

[2349] វិធានផ្ទៃក្នុង វិធាន ៣៨(៣)។

[2350] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការព្រមាន ដោយអនុលោមតាមវិធាន ៣៨ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D367/1/5 កថាខណ្ឌ ១១។

[2351] សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ F30/18 កថាខណ្ឌ ២៤។

[2352] សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E321/2 កថាខណ្ឌ ១៥។

[2353] ដូចខាងលើ កថាខណ្ឌ ១៨។